# ព្រះ
# ត្រៃបិដកបាលី
# នឹង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក

ទីឃនិកាយ ចតុត្ថភាគ

មហាវគ្គ

១៧

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស. ២៥១៦

សុត្តន្តបិដក

ទីឃនិកាយ ចតុត្ថភាគ

មហាវគ្គ

១៧

មហាសុទស្សនសូត្រ ជនវសភសូត្រ

មហាគោវិន្ទសូត្រ មហាសមយសូត្រ

សក្កបញ្ហសូត្រ មហាសតិប្បដ្ឋានសូត្រ

និង

បាយាសិរាជញ្ញសូត្រ

ព.ស. ២៥១៦

# សុត្តន្តបិដកេ ទីឃនិកាយស្ស

## ចតុត្ថោ ភាគោ

---

## មហាវគ្គោ

### មហាសុទស្សនសុត្តំ ចតុត្ថំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ឧបវត្តនេ មល្លានំ សាលវនេ អន្តរេ(១) យមកសាលានំ បរិនិព្វានសមយេ ។ អថ ខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច មា ភន្តេ ភគវា ឥមស្មឹ ខុទ្ទកនគរកេ(២) ឧជ្ជង្គលនគរកេ សាខានគរកេ បរិនិព្វាយិ សន្តិ ភន្តេ អញ្ញានិ មហានគរានិ សេយ្យថីទំ ចម្បា រាជគហំ សាវត្ថី សាកេតំ កោសម្ពី ពារាណសី ឯត្ថ ភគវា បរិនិព្វាយតុ ។ ឯត្ថ ពហូ ខត្តិយមហាសាលា

---

១ ម. អន្តរេន ។ ២ ម. កុឌ្ឌនគរកេ ។

# សុត្តន្តបិដក ទីឃនិកាយ

## ចតុត្ថភាគ

---

## មហាវគ្គ

### មហាសុទស្សនសូត្រ ទី ៤

(១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសាលវ័ន ដែលជាផ្លូវបត់ចូល (ទៅកាន់ក្រុង) របស់ពួកមល្លក្សត្រ នាចន្លោះ នៃដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងកាលទៀបបរិនិព្វាន ។ គ្រានោះឯង ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ស៊ប់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូល ចំពោះព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ កុំបរិនិព្វាន ក្នុងនគរកុសិនារានេះ ដែលជានគរតូច នគរទួល ជាសាខានគរឡើយ បពិត្រព្រះអង្គដ៏ចម្រើន នគរធំ ៗ ឯទៀតក៏មាន ដូចយ៉ាងនគរចម្បា រាជគ្រឹះ សាវត្ថី សាកេត កោសម្ពី និងពារាណសី សូមព្រះមានព្រះភាគ ទ្រង់បរិនិព្វាន ក្នុងនគរទាំងនុ៎ះវិញ (ព្រោះ) ក្នុងនគរទាំងនុ៎ះ មានខត្តិយមហាសាល

ព្រាហ្មណមហាសាលា គហបតិមហាសាលា តថា-
គតេ អភិប្បសន្នា តេ តថាគតស្ស សរីរបូជំ
ករិស្សន្តីតិ ។ មា ហេវំ អានន្ទ អវច ខុទ្ទកនគរកំ
ឧជ្ជង្គលនគរកំ សាខានគរកន្តិ ។ ភូតបុព្វំ អានន្ទ
រាជា មហាសុទស្សនោ នាម អហោសិ ខត្តិយោ
មុទ្ធាវសិត្តោ(១) ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្ប-
ត្តោ ។ រញ្ញោ អានន្ទ មហាសុទស្សនស្ស អយំ
កុសិនារា កុសាវតី នាម រាជធានី អហោសិ ។
បុរត្ថិមេន ច បច្ឆិមេន ច ទ្វាទសយោជនានិ(២) អាយា-
មេន ឧត្តរេន ច ទក្ខិណេន ច សត្តយោជនានិ
វិត្ថារេន កុសាវតី អានន្ទ រាជធានី ឥទ្ធា ចេវ អហោ-
សិ ផីតា ច ពហុជនា ច អាកិណ្ណមនុស្សា ច
សុភិក្ខា ច ។ សេយ្យថាបិ អានន្ទ ទេវានំ អា-
ឡកមន្ទា នាម រាជធានី ឥទ្ធា ចេវ អហោ-
សិ ផីតា ច(៣) ពហុជនា ច អាកិណ្ណយក្ខា ច
សុភិក្ខា ច ឯវមេវ ខោ អានន្ទ កុសាវតី រាជធានី

១ ឱ. មុទ្ធាភិសិត្តោ ។ ២ ឱ. សា ខោ អានន្ទ កុសាវតី បច្ឆិមេន ច បុរត្ថិមេន ច ទ្វាទសយោជនានិ អហោសិ ។ ៣ ឱ. ឥទ្ធា ចេវ ផីតា ច ។



ព្រាហ្មណមហាសាល និងគហបតិមហាសាល ជាច្រើននាក់ ដែលជ្រះថ្លាស៊ប់ ក្នុងព្រះតថាគត ពួកជនទាំងនោះ នឹងធ្វើការបូជាព្រះសរីរៈរបស់ព្រះតថាគត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលថា នគរនេះ ជានគរតូច នគរព្រៃ ជាសាខានគរយ៉ាងនេះឡើយ ។ ម្នាលអានន្ទ កាលពីព្រេងនាយមក មានព្រះរាជាទ្រង់ព្រះនាម មហាសុទស្សនៈ ជាក្សត្របានមុទ្ធាភិសេក (ផ្សាយរះលើផែនដី) មានមហាសមុទ្រទាំង ៤ ជាទីបំផុត ព្រះអង្គជាស្ដេចឈ្នះសង្គ្រាម ទ្រង់មានជនបទ ដល់នូវសេចក្ដីមាំមួន ។ ម្នាលអានន្ទ នគរកុសិនារានេះ ជារាជធានីឈ្មោះកុសាវតី របស់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ កុសាវតីរាជធានី បណ្ដោយពីបូព៌ទិស ទៅបច្ចិមទិស ១២ យោជន៍ ទទឹងពីឧត្តរទិស ទៅទក្ខិណទិស ៧ យោជន៍ ជានគរស្ដុកស្ដម្ភ ធំទូលាយ មានជនច្រើន មានមនុស្សកុះករ ជាស្រុកមានភិក្ខាហារបរិបូណ៌ ។ ម្នាលអានន្ទ រាជធានីឈ្មោះអាឡកមន្ទា របស់ពួកទេវតា ជារាជធានីដ៏ស្ដុកស្ដម្ភ ធំទូលាយ មានជនច្រើន មានទេវតាកុះករ ជាស្រុកមានភិក្ខាហារបរិបូណ៌ យ៉ាងណាមិញ ម្នាលអានន្ទ កុសាវតីរាជធានី

ឥទ្ធា ចេវ អហោសិ ផីតា ច ពហុជនា ច អាកិណ្ណ-មនុស្សា ច សុភិក្ខា ច ។ កុសាវតី អានន្ទ រាជធានី ទសហិ សទ្ទេហិ អវិវិត្តា អហោសិ ទិវា ចេវ រត្តិំ ច[១] សេយ្យថីទំ ហត្ថិសទ្ទេន អស្សសទ្ទេន រថសទ្ទេន ភេរិ-សទ្ទេន មុទិង្គសទ្ទេន វីណាសទ្ទេន គីតសទ្ទេន សម្ម-សទ្ទេន តាលសទ្ទេន អស្នថ បិវថ ខាទថាតិ ទសមេន សទ្ទេន ។ កុសាវតី អានន្ទ រាជធានី សត្តហិ បាការេហិ បរិក្ខិត្តា អហោសិ ឯកោ[២] បាការោ សោវណ្ណមយោ ឯកោ រូបិយមយោ ឯកោ វេឡុរិយ-មយោ ឯកោ ផលិកមយោ ឯកោ លោហិតង្គមយោ ឯកោ មសារគល្លមយោ ឯកោ សព្វរតនមយោ ។ កុសាវតិយា អានន្ទ រាជធានិយា ចតុន្នំ វណ្ណានំ ទ្វារានិ អហេសុំ ឯកំ ទ្វារំ សោវណ្ណមយំ ឯកំ រូបិយមយំ ឯកំ វេឡុរិយមយំ ឯកំ ផលិកមយំ ។

១ ម. រត្តឹ ច ។ ២ ម. តត្ថ ឯកោ ។



ជារាជធានីដ៏ស្តុកស្តម្ភ ធំទូលាយ មានជនច្រើន មានមនុស្សកុះករ ជាស្រុកមានភិក្ខាហារបរិបូណ៌ យ៉ាងនេះដែរ ។ ម្នាលអានន្ទ កុសាវតីរាជធានី ជាក្រុងគឹកកងរំពងដោយសូរសព្ទ ១០ យ៉ាង ទាំងថ្ងៃ ទាំងយប់ គឺសូរសព្ទដំរី សូរសព្ទសេះ សូរសព្ទរថ សូរសព្ទស្គរ សូរសព្ទសម្ភោរ សូរសព្ទពិណ សូរសព្ទចម្រៀង សូរសព្ទមហោស្រព សូរសព្ទប្រគំ សូរសព្ទមនុស្សនិយាយគ្នាថា អ្នកទាំងឡាយ ចូរបរិភោគទៅ ចូរផឹកទៅ ចូរស៊ីទៅ រួមជាគម្រប់ ១០ យ៉ាង ។ ម្នាលអានន្ទ កុសាវតីរាជធានី មានកំពែងព័ទ្ធជុំវិញ ៧ ជាន់ គឺកំពែងមាស ១ ជាន់ កំពែងប្រាក់ ១ ជាន់ កំពែងកែវពៃទូរ្យ ១ ជាន់ កំពែងកែវផលិក ១ ជាន់ កំពែងកែវទទឹម ១ ជាន់ កំពែងកែវមរកត ១ ជាន់ កំពែងកែវគ្រប់យ៉ាង ១ ជាន់ ។ ម្នាលអានន្ទ កុសាវតីរាជធានី មានទ្វារ ៤ ពណ៌ គឺទ្វារមាស ១ ទ្វារប្រាក់ ១ ទ្វារកែវពៃទូរ្យ ១ ទ្វារកែវផលិក ១ ។

ឯកមេកស្មឹ(១) ទ្វារេ សត្ត សត្ត ឯសិកា(២) និខាតា អហេសុំ តិបោរិសង្គា តិបោរិសំ និខាតា ទ្វាទសបោរិសា ឧព្វេធេន(៣) ។ ឯកា ឯសិកា សោវណ្ណមយា ឯកា រូបិយមយា ឯកា វេឡុរិយមយា ឯកា ផលិកមយា ឯកា លោហិតង្គមយា ឯកា មសារគល្លមយា ឯកា សព្វរតនមយា ។ កុសាវតី អានន្ទ រាជធានី សត្តហិ តាលបន្តីហិ បរិក្ខិត្តា អហោសិ ឯកា តាលបន្តិ សោវណ្ណមយា ឯកា រូបិយមយា ឯកា វេឡុរិយមយា ឯកា ផលិកមយា ឯកា លោហិតង្គមយា ឯកា មសារគល្លមយា ឯកា សព្វរតនមយា ។ សោវណ្ណមយស្ស តាលស្ស សោវណ្ណមយោ ខន្ធោ អហោសិ រូបិយមយានិ បត្តានិ ច ផលានិ ច ។ រូបិយមយស្ស តាលស្ស រូបិយមយោ ខន្ធោ អហោសិ សោវណ្ណមយានិ បត្តានិ ច ផលានិ ច ។ វេឡុរិយមយស្ស តាលស្ស វេឡុរិយមយោ ខន្ធោ អហោសិ ផលិកមយានិ បត្តានិ ច ផលានិ ច ។

១ ម. ឯកេកស្មឹ ។ ២ ឱ. សត្ត ឯសិកា ។ ៣ ឱ. តិបោរិសង្គា ចតុប្បោរិសា ឧព្វេធេន ។



ក្នុងទ្វារមួយ ៗ គេដាំសសរគោលប្រាំពីរ ៗ ដើម ជាសសរមានទំហំ ៣ ជួរបុរស(១) គេដាំចុះទៅក្នុងដីជម្រៅ ៣ ជួរបុរស កម្ពស់ពីដីឡើង ១៦ ជួរបុរស ៗ គឺសសរមាស ១ ដើម សសរប្រាក់ ១ ដើម សសរកែវពិទូរ្យ ១ ដើម សសរកែវផលិក ១ ដើម សសរកែវទទឹម ១ ដើម សសរកែវមរកត ១ ដើម សសរកែវគ្រប់យ៉ាង ១ ដើម ៗ ម្នាលអានន្ទ កុសាវតីរាជធានី មានជួរដើមត្នោតព័ទ្ធជុំវិញ ៧ ជាន់ គឺជួរដើមត្នោតមាស ១ ជាន់ ដើមត្នោតប្រាក់ ១ ជាន់ ដើមត្នោតកែវពិទូរ្យ ១ ជាន់ ដើមត្នោតកែវផលិក ១ ជាន់ ដើមត្នោតកែវទទឹម ១ ជាន់ ដើមត្នោតកែវមរកត ១ ជាន់ ដើមត្នោតកែវគ្រប់យ៉ាង ១ ជាន់ ៗ ត្នោតមាស ដើមជាមាស ឯស្លឹកនិងផ្លែជាប្រាក់ ៗ ត្នោតប្រាក់ ដើមជាប្រាក់ ឯស្លឹកនិងផ្លែជាមាស ៗ ត្នោតកែវពិទូរ្យ ដើមជាកែវពិទូរ្យ ឯស្លឹកនិងផ្លែជាកែវផលិក ៗ

១ អដ្ឋកថា ថា ក្នុងមួយជួរបុរស គឺមួយទទឹងមនុស្សប្រុស ជា ៥ ហត្ថបុរស ។

ផលិកមយស្ស តាលស្ស ផលិកមយោ ខន្ធោ អហោសិ វេឡុរិយមយានិ បត្តានិ ច ផលានិ ច ។ លោហិតង្គមយស្ស តាលស្ស លោហិតង្គមយោ ខន្ធោ អហោសិ មសារគល្លមយានិ បត្តានិ ច ផលានិ ច ។ មសារគល្លមយស្ស តាលស្ស មសារគល្លមយោ ខន្ធោ អហោសិ លោហិតង្គមយានិ បត្តានិ ច ផលានិ ច ។ សព្វរតនមយស្ស តាលស្ស សព្វរតនមយោ ខន្ធោ អហោសិ សព្វរតនមយានិ បត្តានិ ច ផលានិ ច ។ តាសំ ខោ បនានន្ទ តាលបន្តីនំ វាតេរិតានំ សទ្ទោ អហោសិ វគ្គុ(១) ច រជនីយោ ច ខមនីយោ ច មទនីយោ ច ។ សេយ្យថាបិ អានន្ទ បញ្ចង្គិកស្ស តុរិយស្ស សុវិនីតស្ស សុប្បដិតាឡិតស្ស(២) កុសលេហិ សុសមន្នាហតស្ស(៣) សទ្ទោ ហោតិ វគ្គុ ច រជនីយោ ច ខមនីយោ ច មទនីយោ ច ។ ឯវមេវ ខោ អានន្ទ តាសំ តាលបន្តីនំ វាតេរិតានំ សទ្ទោ អហោសិ វគ្គុ ច រជនីយោ ច ខមនីយោ ច មទនីយោ ច ។

១ ឱ. ម. វគ្គុ ច ។ ២ ឱ. សុប្បដិតាឡិតស្ស ។ ៣ ឱ. ម. សមន្នាហតស្ស ។



ត្នោតកែវផលិក ដើមជាកែវផលិក ឯស្លឹកនិងផ្លែជាកែវពិទូរ្យ ។ ត្នោតកែវទទឹម ដើមជាកែវទទឹម ឯស្លឹកនិងផ្លែជាកែវមរកត ។ ត្នោតកែវមរកត ដើមជាកែវមរកត ឯស្លឹកនិងផ្លែជាកែវទទឹម ។ ត្នោតកែវគ្រប់យ៉ាង ដើមជាកែវគ្រប់យ៉ាង ឯស្លឹកនិងផ្លែជាកែវគ្រប់យ៉ាង ។ ម្នាលអានន្ទ ជួរដើមត្នោតទាំងនោះ ត្រូវខ្យល់បក់មក ក៏មានសូរសព្ទពីរោះ គួរត្រេកអរ គួរស្រឡាញ់ គួរជក់ចិត្ត ។ ម្នាលអានន្ទ តូរ្យតន្ត្រីប្រកបដោយអង្គប្រាំ(១) ដែលពួកអ្នកឈ្លាសវៃវាយ ហើយវាយឲ្យល្មមពីរោះល្អ ទើបចេញដំប្រគំ ក៏មានសូរសព្ទពីរោះ គួរត្រេកអរ គួរស្រឡាញ់ គួរជក់ចិត្ត មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ ឯជួរដើមត្នោតទាំងនោះ កាលត្រូវខ្យល់បក់មក ក៏មានសូរសព្ទពីរោះ គួរត្រេកអរ គួរស្រឡាញ់ គួរជក់ចិត្ត ក៏មានឧបមេយ្យ ដូច្នោះឯង ។

១ អង្គិកហំ គឺ តូរ្យតន្ត្រីប្រកបដោយអង្គ ៥ នោះគឺ អាតតំ ស្គរគួបឬស្គរធំដែលគេពាសស្បែកតែម្ខាង ១ វិតតំ ស្គរដែលគេពាសស្បែកទាំងពីរខាង ១ អាតតវិតតំ គ្រឿងតន្ត្រីដែលរឹតដោយខ្សែ មានរនាតជាដើម ១ សុសិរំ គ្រឿងផ្លុំមានខ្លុយនិងស្រឡៃជាដើម ១ ឃនំ កណ្ដឹង ឬឈឹង ឬក្រាប់ ១ ។

យេ ខោ បនានន្ទ តេន សមយេន កុសាវតិយា រាជធានិយា ធុត្តា អហេសុំ សោណ្ឌា បិបាសា តេ តាសំ តាលបន្តីនំ វាតេរិតានំ សទ្ទេន បរិចារេសុំ ។

(២) រាជា អានន្ទ មហាសុទស្សនោ សត្តហិ រតនេហិ សមន្នាគតោ អហោសិ ចតូហិ ច ឥទ្ធីហិ ។ កតមេហិ សត្តហិ ។ ឥធានន្ទ រញ្ញោ មហាសុទស្ស-នស្ស តទហុបោសថេ បណ្ណរសេ សីសន្ហាតស្ស ឧបោសថិកស្ស ឧបរិបាសាទវរគតស្ស ទិព្វំ ចក្ករតនំ បាតុរហោសិ សហស្សារំ សនេមិកំ សនាភិកំ សព្វា-ការបរិបូរំ ទិស្វា រញ្ញោ មហាសុទស្សនស្ស ឯតទ-ហោសិ សុតំ ខោ បនេតំ យស្ស រញ្ញោ ខត្តិយស្ស មុទ្ធាវសិត្តស្ស តទហុបោសថេ បណ្ណរសេ សីសន្-ហាតស្ស ឧបោសថិកស្ស ឧបរិបាសាទវរគតស្ស ទិព្វំ ចក្ករតនំ បាតុភវតិ សហស្សារំ សនេមិកំ សនាភិកំ សព្វាការបរិបូរំ សោ ហោតិ រាជា ចក្កវត្តីតិ អស្សំ នុ ខោ អហំ រាជា ចក្កវត្តីតិ ។ អថខោ អានន្ទ រាជា មហាសុទស្សនោ ឧដ្ឋាយាសនា ឯកំសំ ឧត្ត-



ម្នាលអានន្ទ សម័យនោះ ក្នុងកុសាវតីរាជធានី មានអ្នកលេងបាសក្ក អ្នកលេងស៊ីផឹក ពួកអ្នកលេងទាំងនោះ ក៏នាំគ្នាកំរែកលេង តាមសូរសព្ទនៃជួរដើមត្នោត ដែលខ្យល់បក់មកត្រូវនោះ ។

(២) ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បរិបូណ៌ដោយរតន៍ ៧ ប្រការ និងដោយឫទ្ធិ ៤ យ៉ាង ។ រតន៍ ៧ ប្រការ តើដូចម្ដេច ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់កក់ព្រះសិរ្ស ក្នុងថ្ងៃ១៥ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករតន៍ជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់និងផ្ចិត បរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដឡើង លុះព្រះបាទមហាសុទស្សនៈ ទ្រង់ទតឃើញហើយ ទើបត្រិះរិះដូច្នេះថា អាត្មាអញ ក៏បានឮរឿងនេះ មកហើយថា ស្ដេចអង្គណា ជាក្សត្របានមុទ្ធាភិសេកហើយ ទ្រង់កក់ព្រះសិរ្ស ក្នុងថ្ងៃ១៥ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទ ដ៏ប្រ-សើរ ចក្ករតន៍ជាទិព្វ មានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ទាំងផ្ចិត បរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដឡើង ព្រះរាជាអង្គនោះ ជាស្ដេចចក្រពត្តិ ខ្ញុំ អាត្មាអញ បានជាស្ដេចចក្រពត្តិហើយតើ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់ក្រោកអំពីអាសនៈ

រាសង្គំ ករិត្វា វាមេន ហត្ថេន សុវណ្ណភិង្ការំ(១) គហេត្វា ទក្ខិណេន ហត្ថេន ចក្ករតនំ អព្ភុក្កិរិ បវត្តតុ ភវំ ចក្ករតនំ អភិវិជិនាតុ ភវំ ចក្ករតនន្តិ ។ អថខោ តំ អានន្ទ ចក្ករតនំ បុរត្ថិមទិសំ បវត្តិ ។ អន្វទេវ រាជា មហាសុទស្សនោ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បនានន្ទ បទេសេ ចក្ករតនំ បតិដ្ឋាសិ តត្ថ រាជា មហាសុទស្សនោ វាសំ ឧបគច្ឆិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យេ ខោ បនានន្ទ បុរត្ថិមាយ ទិសាយ បដិរាជានោ តេ រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ ស្វាគតំ(២) មហារាជ សកំ តេ មហារាជ អនុសាស មហារាជាតិ ។ រាជា មហាសុទស្សនោ ឯវមាហ ៖ បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ

១ ម. ម. ភិង្ការំ ។ ២ ម. ស្វាគតន្តេ ។



ហើយ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ទើបយកព្រះហស្តខាងឆ្វេង កាន់ព្រះសុវណ្ណភិង្ការ (ក្អមមាស) យកព្រះហស្តខាងស្តាំប្រោះព្រំចក្ករ័ត្ន ហើយត្រាស់ថា ចក្ករ័ត្នដ៏ចម្រើន ចូរអណ្តែតទៅ ចក្ករ័ត្នដ៏ចម្រើន ចូរមានជ័យជម្នះ ។ ម្នាលអានន្ទ លំដាប់នោះ ចក្ករ័ត្ននោះឯង ក៏អណ្តែតទៅខាងបូព៌ទិស ។ ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចទៅតាមក្រោយ ជាមួយនឹងសេនាប្រកបដោយអង្គ ៤ ។ ម្នាលអានន្ទ ចក្ករ័ត្នទៅប្រតិស្ឋាន ក្នុងប្រទេសណា ព្រះបាទមហាសុទស្សនៈព្រមទាំងចតុរង្គសេនា ក៏ទ្រង់ប្រថាប់ក្នុងប្រទេសនោះ ។ ម្នាលអានន្ទ ពួកស្តេចណា ដែលជាសត្រូវ គង់នៅក្នុងបូព៌ទិស ពួកស្តេចនោះ ក៏ស្តេចចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះមហារាជ សូមព្រះអង្គទ្រង់ស្តេចមកចុះ បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ខ្ញុំព្រះអង្គ ជារបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការយ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវលួចរបស់ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវនិយាយពាក្យកុហក មិនត្រូវផឹកទឹកស្រវឹង

យថាភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បនានន្ទ បុរត្ថិមាយ ទិសាយ បដិរាជានោ តេ រញ្ញោ មហាសុទស្សនស្ស អនុយន្តា(១) អហេសុំ ។ អថខោ តំ អានន្ទ ចក្ករតនំ បុរត្ថិមំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា ទក្ខិណំ ទិសំ បវត្តតិ ទក្ខិណំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា បច្ឆិមំ ទិសំ បវត្តតិ បច្ឆិមំ សមុទ្ទំ អជ្ឈោគាហេត្វា បច្ចុត្តរិត្វា ឧត្តរំ ទិសំ បវត្តតិ ។ អន្វទេវ រាជា មហាសុទស្សនោ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យស្មឹ ខោ បនានន្ទ បទេសេ ចក្ករតនំ បតិដ្ឋាសិ តត្ថ រាជា មហាសុទស្សនោ វាសំ ឧបគច្ឆិ សទ្ធឹ ចតុរង្គិនិយា សេនាយ ។ យេ ខោ បនានន្ទ ឧត្តរាយ ទិសាយ បដិរាជានោ តេ រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯវមាហំសុ ឯហិ ខោ មហារាជ ស្វាគតំ មហារាជ សកំ តេ មហារាជ អនុសាស មហារាជាតិ ។ រាជា មហាសុទស្សនោ ឯវមាហ

១ ឱ. អនុយុត្តា ។



ឡើយ អ្នកទាំងឡាយ ចូរបរិភោគតាមសមគួរចុះ ។ ម្នាលអានន្ទ មួយទៀត ពួកស្តេចណា ដែលជាសត្រូវ នៅក្នុងបុរត្ថិមទិស ពួកស្តេចនោះ ក៏ទៅជាចុះចូលព្រះបាទមហាសុទស្សនៈវិញ ។ ម្នាលអានន្ទ វេលានោះ ចក្រកែវនោះ ក៏ចុះទៅកាន់សមុទ្រខាងបុរត្ថិមទិស ហើយផុតឡើង ត្រឡប់វិលទៅខាងទក្ខិណទិស ចុះកាន់សមុទ្រ ខាងទក្ខិណទិស ហើយផុតឡើង វិលទៅខាងបច្ឆិមទិស ចុះកាន់សមុទ្រខាងបច្ឆិមទិស ហើយផុតឡើង វិលទៅខាងឧត្តរទិសវិញ ។ ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់ស្តេចទៅតាមក្រោយ ជាមួយនឹងចតុរង្គសេនា ។ ម្នាលអានន្ទ ចក្រកែវ ប្រតិស្ឋានទៅ ក្នុងប្រទេសណា ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់ប្រថាប់នៅ ក្នុងប្រទេសនោះ ព្រមទាំងចតុរង្គសេនា ។ ម្នាលអានន្ទ មួយទៀត ពួកស្តេចណា ជាសឹកសត្រូវ នៅក្នុងឧត្តរទិស ពួកស្តេចនោះ ក៏ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចមក បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ទ្រ ព្រះអង្គ ជាព្រះរាជទ្រព្យរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការ

បាណោ ន ហន្តព្វោ អទិន្នំ នាទាតព្វំ កាមេសុ មិច្ឆា ន ចរិតព្វា មុសា ន ភាសិតព្វា មជ្ជំ ន បាតព្វំ យថាភុត្តញ្ច ភុញ្ជថាតិ ។ យេ ខោ បនានន្ទ ឧត្តរាយ ទិសាយ បដិរាជានោ តេ រញ្ញោ មហាសុទស្សនស្ស អនុយន្តា អហេសុំ ។ អថ ខោ តំ អានន្ទ ចក្ករតនំ សមុទ្ទបរិយន្តំ បឋវឹ អភិវិជិត្វា(១) កុសាវតឹ រាជធានឹ បច្ចាគន្ត្វា រញ្ញោ មហាសុទស្សនស្ស អន្តេបុរទ្វារេ អត្ថករណបមុខេ អក្ខាហតំ មញ្ញេ អដ្ឋាសិ រញ្ញោ មហាសុទស្សនស្ស អន្តេបុរំ ឧបសោភយមានំ ។ រញ្ញោ អានន្ទ មហាសុទស្សនស្ស ឯវរូបំ ចក្ករតនំ បាតុរហោសិ ។

(៣) បុន ចបរំ អានន្ទ រញ្ញោ មហាសុទស្សនស្ស ហត្ថិរតនំ បាតុរហោសិ សព្វសេតោ សត្តប្បតិដ្ឋោ ឥទ្ធិមា វេហាសង្គមោ ឧបោសថោ នាម នាគរាជា ។ តំ ទិស្វា(២) រញ្ញោ មហាសុទស្សនស្ស

១ ឱ. ម. អភិវិជិនិត្វា ។ ២ ម. តំ ទិស្វា ។



យ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវលួចរបស់ដែលគេមិនបានឱ្យ មិនត្រូវប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ មិនត្រូវនិយាយពាក្យកុហក មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយ ចូរបរិភោគតាមសមគួរចុះ ។ ម្នាលអានន្ទ មួយវិញទៀត ពួកស្តេចណាដែលជាសឹកសត្រូវក្នុងឧត្តរទិស ពួកស្តេចនោះ ក៏ត្រឡប់ជាចុះចូលព្រះបាទមហាសុទស្សនៈវិញ ។ ម្នាលអានន្ទ តពីនោះមក ចក្ករ័តន៍នោះបានបង្ក្រាបផែនដី ដែលមានសមុទ្រជាទីបំផុត រួចហើយត្រឡប់មកកាន់កុសាវតីរាជធានីវិញ ហើយឋិតនៅក្នុងរបៀងសាលាសម្រាប់វិនិច្ឆ័យ ទៀបទ្វារព្រះបរមរាជវាំង របស់ព្រះបាទមហាសុទស្សនៈ នៅនឹងថ្កល់ហាក់ដូចជាបាក់ក្តៅ ហើយបំភ្លឺក្នុងព្រះរាជវាំង របស់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ចក្ករ័តន៍ មានសភាពយ៉ាងនេះ កើតប្រាកដឡើង ដល់ព្រះបាទមហាសុទស្សនៈ ។

(៣) ម្នាលអានន្ទ តទៅទៀត ហត្ថិរ័តន៍ (ដំរីកែវ) ជាស្តេចដំរីឈ្មោះឧបោសថ មានសម្បុរសសុទ្ធ មានអវយវៈ គួរធំសមរម្យទាំងអស់ ជាដំរីមានឫទ្ធិ អាចហោះទៅលើអាកាសបាន កើតប្រាកដឡើងដល់ព្រះបាទមហាសុទស្សនៈ ។ លុះព្រះបាទមហាសុទស្សនៈទ្រង់ទតឃើញហើយ

ចិត្តំ បសីទិ ភទ្ទកំ វត ភោ ហត្ថិយានំ សចេ ទមថំ ឧបេយ្យាតិ ។ អថខោ តំ អានន្ទ ហត្ថិរតនំ សេយ្យថាបិ នាម ភទ្ទោ ហត្ថាជានីយោ ទីឃរត្តំ សុបរិទន្តោ ឯវមេវ ទមថំ ឧបគច្ឆិ ។ ភូតបុព្វំ អានន្ទ រាជា មហាសុទស្សនោ តមេវ ហត្ថិរតនំ វីមំសមានោ បុព្វណ្ហសមយំ អភិរុហិត្វា សមុទ្ទបរិយន្តំ បឋវឹ អនុយាយិត្វា[១] កុសាវតឹ រាជធានឹ បច្ចាគន្ត្វា បាតរាសមកាសិ ។ រញ្ញោ អានន្ទ មហាសុទស្សនស្ស ឯវរូបំ ហត្ថិរតនំ បាតុរហោសិ ។

(៤) បុន ចបរំ អានន្ទ រញ្ញោ មហាសុទស្សនស្ស អស្សរតនំ បាតុរហោសិ សព្វសេតោ កាឡសីសោ មុញ្ជកេសោ ឥទ្ធិមា វេហាសង្គមោ វលាហកោ នាម អស្សរាជា ។ ទិស្វា រញ្ញោ មហាសុទស្សនស្ស ចិត្តំ បសីទិ ភទ្ទកំ វត ភោ អស្សយានំ សចេ ទមថំ ឧបេយ្យាតិ ។ អថខោ តំ អានន្ទ អស្សរតនំ សេយ្យថាបិ នាម ភទ្ទោ អស្សាជានីយោ

១ ម. អនុសំយាយិត្វា ។



ក៏មានព្រះហឫទ័យជ្រះថ្លាថា អើយានដំរីល្អណាស់តើហ្ន៎ ប្រសិនបើចូលទៅបង្ហាត់បាន (ជាការប្រពៃ) ។ ម្នាលអានន្ទ ឯហត្ថិរ័តន៍នោះ ក៏ដល់នូវការបង្ហាត់បាន ដូចជាដំរីអាជានេយ្យដ៏ល្អ ដែលគេបង្ហាត់បានចេះល្អយូរអង្វែងហើយ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់ពិនិត្យមើល ហត្ថិរ័តន៍នោះឯង មុនដំបូងទ្រង់ឡើងជិះ (លើហត្ថិរ័តន៍) ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រានូវផែនដី មានសមុទ្រជាទីបំផុត រួចហើយ ស្តេចត្រឡប់មកសោយព្រះក្រយាហារ ក្នុងវេលាព្រឹក ឯកុសាវតីរាជធានីវិញបាន ។ ម្នាលអានន្ទ ហត្ថិរ័តន៍ មានសភាពយ៉ាងនេះបានកើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។

(៤) ម្នាលអានន្ទ តទៅទៀត អស្សរ័តន៍ (សេះកែវ) ជាស្តេចសេះឈ្មោះវលាហកៈ មានសម្បុរសសុទ្ធ មានសម្បុរត្រង់ក្បាលខ្មៅ (របើម) ដូចជាសម្បុរនៃក្អែក មានសក់ (សក្បុស) ដូចបណ្តូលស្មៅយាប្លង់ ជាសេះមានឫទ្ធិអាចហោះទៅលើអាកាសបាន កើតប្រាកដដល់ព្រះបាទមហាសុទស្សនៈ ។ លុះព្រះបាទមហាសុទស្សនៈ ទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើយានសេះល្អណាស់តើហ្ន៎ ប្រសិនបើចូលទៅបង្ហាត់បាន (ជាការប្រពៃ) ។ ម្នាលអានន្ទ លំដាប់នោះ អស្សរ័តន៍ ក៏ដល់នូវការបង្ហាត់បាន ដូចជាសេះអាជានេយ្យ

ធីឃរត្តំ សុបរិទន្តោ ឯវមេវ ទមថំ ឧបគច្ឆិ ។ ភូតបុព្វំ អានន្ទ រាជា មហាសុទស្សនោ តមេវ អស្សរតនំ វីមំសមានោ បុព្វណ្ហសមយំ អភិរុហិត្វា សមុទ្ទបរិយន្តំ បថវឹ អនុយាយិត្វា(១) កុសាវតឹ រាជធានឹ បច្ចាគន្ត្វា បាតរាសមកាសិ ។ រញ្ញោ អានន្ទ មហាសុទស្ស-នស្ស ឯវរូបំ អស្សរតនំ បាតុរហោសិ ។

(៥) បុន ចបរំ អានន្ទ រញ្ញោ មហាសុទស្សនស្ស មណិរតនំ បាតុរហោសិ មណិវេឡុរិយោ(២) សុភោ ជា-តិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ ។ តស្ស ខោ បនានន្ទ មណិរត-នស្ស អាភា សមន្តា យោជនំ ផុដា អហោសិ ។ ភូតបុព្វំ អានន្ទ រាជា មហាសុទស្សនោ តមេវ មណិ-រតនំ វីមំសមានោ ចតុរង្គិនឹ សេនំ សន្នយ្ហិត្វា មណឹ ធជគ្គំ អារោបេត្វា រត្តន្ធការតិមិសាយំ បាយាសិ(៣) ។ យេ ខោ បនានន្ទ សមន្តា គាមា អហេសុំ តេ

១ ម. អនុសាយិត្វា ។ ២ ឱ. ម. បាតុរហោសិ សោ អហោសិ មណិវេឡុរិយោ ។ ៣ ម. បាយាតិ ។



ដ៏ល្អ ដែលគេបង្ហាត់បានរៀបល្អ យូរអង្វែងហើយ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់ពិនិត្យមើល អស្សរ័តន៍នោះឯង មុនអំបូចទ្រង់ឡើងគង់លើអស្សរ័តន៍ ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រាផែនដី ដែលមានសមុទ្រជាទីបំផុត រួចហើយស្តេចត្រឡប់មកសោយ ព្រះស្ងោយ ក្នុងវេលាព្រឹក ឯកុសាវតីរាជធានីវិញទាន់ ។ ម្នាលអានន្ទ អស្សរ័តន៍ មានសភាពយ៉ាងនេះ កើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។

(៥) ម្នាលអានន្ទ តទៅទៀត មណិរ័តន៍ ជាកែវពិទូរ្យមានជាតិដ៏ល្អ មានជ្រុង ៨ ដែលជាងនៃឆ្នៃល្អហើយ មានពណ៌ថ្លាស្អាត បរិបូណ៌ ដោយអាការគ្រប់យ៉ាង បានកើតប្រាកដ ដល់ព្រះបាទមហា-សុទស្សនៈ ។ ម្នាលអានន្ទ មណិរ័តន៍នោះឯង មានពន្លឺផ្សាយទៅបានមួយយោជន៍ជុំវិញ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់ពិនិត្យមើល នូវមណិរ័តន៍នោះឯង មុនអំបូចទ្រង់ប្រជុំសេ ពួកចតុរង្គសេនាមក ហើយទ្រង់ស្ទួយកែវមណី ឡើងទៅកាន់ចុងទង់ ហើយទ្រង់ស្តេចទៅ ក្នុងទីងងឹតអន្ធកាលរាត្រី ។ ម្នាលអានន្ទ ចំណែកអ្នកស្រុកទាំងឡាយណា ដែលនៅជិតខាង អ្នកស្រុកទាំងនោះ

ឱភាសេន(១) កម្មន្តេ បយោជេសុំ ទិវាតិ មញ្ញមានា ។ រញ្ញោ អានន្ទ មហាសុទស្សនស្ស ឯវរូបំ មណិរតនំ បាតុរហោសិ ។

(៦) បុន ចបរំ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឥត្ថីរតនំ បាតុរហោសិ អភិរូបា ទស្សនីយា បាសាទិកា បរមាយ វណ្ណបោក្ខរតាយ សមន្នាគតា នាតិទីឃា នាតិរស្សា នាតិកិសា នាតិថូលា នាតិកាឡិកា(២) នាច្ចោទាតា អតិក្កន្តា មនុស្សវណ្ណំ(៣) អប្បត្តា ទិព្វវណ្ណំ ។ តស្ស ខោ បនានន្ទ ឥត្ថីរតនស្ស ឯវរូបោ កាយសម្ផស្សោ ហោតិ សេយ្យថាបិ នាម តូលបិចុនោ វា កប្បាសបិចុនោ វា ។ តស្ស ខោ បនានន្ទ ឥត្ថីរតនស្ស សីតេ ឧណ្ហានិ គត្តានិ ហោន្តិ ឧណ្ហេ សីតានិ ។ តស្ស ខោ បនានន្ទ ឥត្ថីរតនស្ស កាយតោ ចន្ទនគន្ធោ វាយតិ មុខតោ ឧប្បលគន្ធោ ។ តំ ខោ បនានន្ទ ឥត្ថីរតនំ រញ្ញោ មហាសុទស្សនស្ស បុព្វុដ្ឋាយិនី អហោសិ បច្ឆានិបាតិនី កិង្ការប្បដិស្សាវិនី

១ ម. ឱ ភេ ឱភាសេន ។ ២ ម. នាតិកាឡី ។ ៣ ម. មានុស្សំ វណ្ណំ ។



សម្គាល់ថាជាវេលាថ្ងៃ ក៏នាំគ្នាប្រកបការងារដោយសារពន្លឺ (នៃកែវនោះឯង) ។ ម្នាលអានន្ទ កែវមណីមានសភាពយ៉ាងនេះ បានកើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។

(៦) ម្នាលអានន្ទ គឺនៅទៀត ឥត្ថីរតន៍(១) (ស្ត្រីកែវ) មានរូបឆោមល្អ គួរឲ្យអ្នកផងពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក លើសលែងកន្លងហួសសម្បុរស្ត្រីមនុស្ស តែមិនដល់សម្បុរទេវតាទេ បានកើតប្រាកដ ដល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ឥត្ថីរតន៍នោះឯង មានកាយសម្ផស្ស (ទន់ល្មើយ) ដូចជាសំឡីគរ ឬសំឡីកប្បាស ។ ម្នាលអានន្ទ មួយទៀត ឥត្ថីរតន៍នោះឯង កាលរដូវត្រជាក់មានខ្លួនក្តៅ កាលរដូវក្តៅមានខ្លួនត្រជាក់ ។ ម្នាលអានន្ទ មិនតែប៉ុណ្ណោះ ឥត្ថីរតន៍នោះឯង មានក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយ មានក្លិនផ្កាឧប្បលផ្សាយចេញអំពីមាត់ ។ ម្នាលអានន្ទ ឥត្ថីរតន៍នោះឯង ជាស្ត្រីតែងក្រោកឡើងមុន តែងអង្គុយក្រោយ(២) យកចិត្តទុកដាក់ធ្វើអ្វី ។

១ អដ្ឋកថា ថា ស្ត្រីដែលគេនាំមកអំពីរាជត្រកូលក្នុងដែនមទ្ទរដ្ឋ មកថ្វាយជាព្រះអគ្គមហេសី ។ ន័យមួយទៀតថា ស្ត្រីដែលមកអំពីឧត្តរកុរុទ្វីបដោយអានុភាពរបស់ព្រះអង្គ ។ ២ ស្ត្រីនោះ បើឃើញព្រះរាជាស្តេចមក តែងក្រោកអំពីអាសនៈដែលខ្លួនអង្គុយជាមុន លុះតែព្រះរាជាគង់ ទើបនាងអង្គុយទៅវិញ កាន់ព្រះវីជនីបក់ថ្វាយព្រះរាជាខាងក្រោយ ។

មនាបចារិនី បិយវាទិនី ។ តំ ខោ អានន្ទ ឥត្ថីរតនំ រាជានំ មហាសុទស្សនំ មនសាបិ នោ អតិចារី កុតោ បន កាយេន ។ រញ្ញោ អានន្ទ មហាសុទស្សនស្ស ឯវរូបំ ឥត្ថីរតនំ បាតុរហោសិ ។

(៧) បុន ចបរំ អានន្ទ រញ្ញោ មហាសុទស្សនស្ស គហបតិរតនំ បាតុរហោសិ ។ តស្ស កម្មវិបាកជំ ទិព្វចក្ខុំ បាតុរហោសិ យេន និធី បស្សតិ សស្សាមិ-កានិ អស្សាមិកានិ ។ សោ រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯវមាហ អប្បោស្សុក្កោ ត្វំ ទេវ ហោហិ អហំ តេ ធនេន ធនករណីយំ ករិស្សាមីតិ ។ ភូត-បុព្វំ អានន្ទ រាជា មហាសុទស្សនោ តមេវ គហបតិ-រតនំ វីមំសមានោ នាវំ អភិរុហិត្វា មជ្ឈេ គង្គាយ នទិយា សោតំ ឱគាហិត្វា គហបតិរតនំ ឯតទវោច



ប្រព្រឹត្តត្រូវព្រះហឫទ័យ ពោលតែពាក្យជាទីពេញព្រះហឫទ័យ របស់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ឥត្ថីរ័តន៍នោះឯង សូម្បីតែចិត្ត ក៏មិនប្រព្រឹត្តកន្លងព្រះបាទមហាសុទស្សនៈទៅហើយ ម្ដេចឡើយនឹងប្រព្រឹត្តកន្លងដោយកាយបាន ។ ម្នាលអានន្ទ ឥត្ថីរ័តន៍ មានសភាពយ៉ាងនេះ បានកើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។

(៧) ម្នាលអានន្ទ តទៅទៀត គហបតិរ័តន៍[១] (គហបតីកែវ) បានកើតប្រាកដ ដល់ព្រះបាទមហាសុទស្សនៈ ។ ឯគហបតិរ័តន៍នោះ មានទិព្វចក្ខុ កើតអំពីផលនៃកុសលកម្ម អាចមើលឃើញកំណប់ទ្រព្យ ដែលមានម្ចាស់នឹងមិនមានម្ចាស់បាន ។ គហបតីនោះ ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក៏ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គ កុំមានសេចក្ដីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងចាត់ចែងការ ដែលគួរធ្វើដោយទ្រព្យថ្វាយ ដោយព្រះរាជទ្រព្យព្រះអង្គ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលទ្រង់នឹងល្បងមើល គហបតិរ័តន៍នោះឯង មុនដំបូងទ្រង់ប្រថាប់លើព្រះទីនាំងនាវា សំដៅទៅកាន់ខ្សែទឹកក្នុងកណ្ដាលនៃស្ទឹងគង្គា ទើបទ្រង់ត្រាស់នឹងគហបតិរ័តន៍យ៉ាងនេះថា ម្នាល

---

១ អដ្ឋកថា ថា គហបតីដែលកើតក្នុងត្រកូលមានភោគសម្បត្តិច្រើន ។

អត្ថោ មេ គហបតិ ហិរញ្ញសុវណ្ណេនាតិ ។ តេនហិ មហារាជ ឯកតីរំ នាវំ(១) ឧបេតូតិ ។ ឥធេវ មេ គហបតិ អត្ថោ ហិរញ្ញសុវណ្ណេនាតិ ។ អថខោ តំ អានន្ទ គហបតិរតនំ ឧភោហិ ហត្ថេហិ ឧទកំ ឱមសិត្វា បូរំ ហិរញ្ញសុវណ្ណស្ស កុម្ភឹ ឧទ្ធរិត្វា រាជានំ មហាសុទស្សនំ ឯតទវោច អលមេត្តាវតា មហារាជ កតមេត្តាវតា មហារាជាតិ ។ រាជា មហាសុទស្សនោ ឯវមាហ អលមេត្តាវតា គហបតិ កតមេត្តាវតា គហបតិ បូជិតមេត្តាវតា គហបតីតិ ។ រញ្ញោ អានន្ទ មហាសុទស្សនស្ស ឯវរូបំ គហបតិរតនំ បាតុរហោសិ ។

(៨) បុន ចបរំ អានន្ទ រញ្ញោ មហាសុទស្សនស្ស បរិណាយករតនំ បាតុរហោសិ បណ្ឌិតោ វិយត្តោ មេធាវី បដិពលោ រាជានំ មហាសុទស្សនំ ឧបេយ្យាបេតព្វំ ឧបេយ្យាបេតុំ អបេយ្យាបេតព្វំ អបេយ្យាបេតុំ(២)

១ ម. ឯកំ តីរំ នាវា ។ ឧ. ឯកំ តីរំ ។ ២ ឧ. ម. ឧបយាបេតព្វំ ឧបយាបេតុំ អបយាបេតព្វំ អបយាបេតុំ ។



គហបតី យើងមានសេចក្តីត្រូវការ ដោយប្រាក់និងមាស ។ គហបតី នោះ ក្រាបបង្គំទូលតបថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់បែរ នាវាទៅកាន់ត្រើយម្ខាងសិន ។ ទ្រង់មានព្រះរាជឱង្ការថា ៖ គហបតី យើងមានសេចក្តីត្រូវការតែប្រាក់ និងមាសត្រង់ទីនេះឯង ។ ម្នាលអានន្ទ លំដាប់នោះ គហបតីរតនៈនោះឯង យកដៃទាំងពីរ លូកចុះទៅក្នុងទឹក លើកយកឆ្នាំង ដែលពេញដោយប្រាក់និងមាស ហើយក្រាបទូលព្រះបាទមហាសុទស្សនៈថា បពិត្រមហារាជ ល្មមហើយ ដោយប្រាក់និងមាសប៉ុណ្ណេះ បពិត្រមហារាជ ប្រាក់និងមាសប៉ុណ្ណេះ ល្មមធ្វើព្រះរាជកិច្ចបានហើយ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ប្រាក់និងមាសប៉ុណ្ណេះល្មមហើយ ម្នាលគហបតី ប្រាក់និងមាសប៉ុណ្ណេះ ល្មមធ្វើកិច្ចបានហើយ ម្នាលគហបតី ប្រាក់និងមាសទាំងប៉ុណ្ណេះ យើងបូជាអ្នកឯង ។ ម្នាលអានន្ទ គហបតិរតនៈ មានសភាពយ៉ាងនេះ កើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។

(៨) ម្នាលអានន្ទ តទៅទៀត បរិណាយករតនៈ(១) ( បរិណាយក តែង ) ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា អង់អាច ដើម្បីញ៉ាំងព្រះបាទមហាសុទស្សនៈ ដែលខ្លួនឲ្យស្តេចចូលទៅ ឲ្យចូលទៅបាន ដើម្បីញ៉ាំងព្រះបាទមហាសុទស្សនៈ ដែលខ្លួនគួរឲ្យស្តេចចេញ ឲ្យចេញទៅបាន

១ អដ្ឋកថា ថា ជាព្រះរាជបុត្រច្បងរបស់ព្រះបាទមហាសុទស្សនៈ ។

ឋបេតព្វំ ឋបេតុំ ។ សោ រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯវមាហ អប្បោស្សុក្កោ ត្វំ ទេវ ហោ-ហិ អហមនុសាសិស្សាមីតិ ។ រញ្ញោ អានន្ទ មហា-សុទស្សនស្ស ឯវរូបំ បរិណាយករតនំ បាតុរហោសិ ។ រាជា អានន្ទ មហាសុទស្សនោ ឥមេហិ សត្តហិ រតនេហិ សមន្នាគតោ អហោសិ ។

(៨) រាជា អានន្ទ មហាសុទស្សនោ ចតូហិ ឥទ្ធីហិ សមន្នាគតោ ហោតិ(១) ។ កតមាហិ ចតូហិ ឥទ្ធីហិ ។ ឥធានន្ទ រាជា មហាសុទស្សនោ អភិរូបោ អហោសិ ទស្សនីយោ បាសាទិកោ បរ-មាយ វណ្ណបោក្ខរតាយ សមន្នាគតោ អតិវិយ អញ្ញេហិ មនុស្សេហិ ។ រាជា អានន្ទ មហាសុ-ទស្សនោ ឥមាយ បឋមាយ ឥទ្ធិយា សមន្នាគតោ អហោសិ ។

១ ម. អហោសិ ។



ដើម្បីញុំាងព្រះបាទមហាសុទស្សនៈ ឲ្យតាំងនូវបុគ្គល ដែលគួរតាំងទុក កើតប្រាកដ ដល់ព្រះបាទមហាសុទស្សនៈ ។ បរិនាយករតនៈនោះ ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ហើយក្រាបបង្គំទូល យ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គ កុំមានសេចក្ដីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងប្រៀនប្រដៅថ្វាយ ។ ម្នាលអានន្ទ បរិនាយករតនៈ មានសភាពយ៉ាងនេះ កើតប្រាកដហើយ ដល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយរតនៈ ៧ ប្រការនេះឯង ។

[៨] ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាង ។ ឫទ្ធិ ៤ យ៉ាងដូចម្ដេចខ្លះ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្ស-នៈ ទ្រង់មានព្រះរូបល្អ គួរឲ្យរកមើលពិតពិលរមិលមើល គួរឲ្យជ្រះថ្លា ទ្រង់ប្រកបដោយព្រះឆវិវណ្ណ ដ៏ល្អក្រៃពេក លើសមនុស្សទាំងឡាយដទៃទៀតក្នុងលោកនេះ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិនេះ ជាឫទ្ធិទី ១ ។

(១០) បុន ចបរំ អានន្ទ រាជា មហាសុទស្សនោ ទីឃាយុកោ អហោសិ ចិរដ្ឋិតិកោ អតិវិយ អញ្ញេហិ មនុស្សេហិ ។ រាជា អានន្ទ មហាសុទស្សនោ ឥមាយ ទុតិយាយ ឥទ្ធិយា សមន្នាគតោ អហោសិ ។

(១១) បុន ចបរំ អានន្ទ រាជា មហាសុទស្សនោ អប្បាពាធោ អហោសិ អប្បាតង្កោ សមវេបាកិនិយា គហណិយា សមន្នាគតោ នាតិសីតាយ នាច្ចុណ្ហាយ អតិវិយ អញ្ញេហិ មនុស្សេហិ ។ រាជា អានន្ទ មហាសុទស្សនោ ឥមាយ តតិយាយ ឥទ្ធិយា សមន្នាគតោ អហោសិ ។

(១២) បុន ចបរំ អានន្ទ រាជា មហាសុទស្សនោ ព្រាហ្មណគហបតិកានំ បិយោ អហោសិ មនាបោ ។ សេយ្យថាបិ អានន្ទ បិតា បុត្តានំ បិយោ ហោតិ មនាបោ ឯវមេវ ខោ អានន្ទ រាជា មហាសុទស្សនោ ព្រាហ្មណគហបតិកានំ បិយោ អហោសិ មនាបោ ។ រញ្ញោ បន អានន្ទ មហាសុទស្សនស្ស ព្រាហ្មណគហបតិកា បិយា អហេសុំ មនាបា ។ សេយ្យ-



(១០) ម្នាលអានន្ទ តទៅទៀត ព្រះបាទមហាសុទស្សនៈ មានព្រះជន្មាយុវែង ទ្រង់ឋិតនៅអស់កាលជាយូរអង្វែងក្រៃលែង ជាងមនុស្សទាំងឡាយដទៃទៀត ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិនេះ ជាឫទ្ធិទី ២ ។

(១១) ម្នាលអានន្ទ តទៅទៀត ព្រះបាទមហាសុទស្សនៈ ទ្រង់មិនមានអាពាធ មិនមានទុក្ខ ប្រកបដោយភ្លើងធាតុ ដែលកើតអំពីកម្មជាទីរំលាយស្មើ មិនត្រជាក់ពេក មិនក្តៅពេក លើសជាងមនុស្សដទៃ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិនេះ ជាឫទ្ធិទី ៣ ។

(១២) ម្នាលអានន្ទ តទៅទៀត ព្រះបាទមហាសុទស្សនៈ ទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្តនៃព្រាហ្មណ៍ និងគហបតីទាំងឡាយ ។ ម្នាលអានន្ទ បិតាជាទីស្រឡាញ់ ពេញចិត្តនៃបុត្រទាំងឡាយ យ៉ាងណាមិញ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ជាទីស្រឡាញ់ពេញចិត្តនៃព្រាហ្មណ៍ និងគហបតីទាំងឡាយ យ៉ាងនោះដែរ ។ ម្នាលអានន្ទ ចំណែកខាងព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ ពេញព្រះហឫទ័យ នៃព្រះបាទមហាសុទស្សនៈដែរ ។ ម្នាលអានន្ទ កូនទាំងឡាយ ជាទីស្រឡាញ់ ពេញចិត្តនៃបិតា យ៉ាងណាមិញ ម្នាលអានន្ទ

ថាបិ អានន្ទ បិតុ បុត្តា បិយា ហោន្តិ មនាបា ឯវមេវ ខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ព្រាហ្មណ-គហបតិកា បិយា អហេសុំ មនាបា ។ ភូតបុព្វំ អានន្ទ រាជា មហាសុទស្សនោ ចតុរង្គិនិយា សេនាយ ឧយ្យានភូមឹ និយ្យាសិ ។ អថខោ អានន្ទ ព្រាហ្មណ-គហបតិកា រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯតទវោចុំ អតរមានោ ទេវ យាហិ យថា តំ មយំ ចិរំ បស្សេយ្យាមាតិ ។ រាជាបិ អានន្ទ មហាសុ-ទស្សនោ សារថឹ អាមន្តេសិ អតរមានោ សារថិ រថំ បេសេហិ យថា អហំ ព្រាហ្មណគហបតិកេ ចិរំ បស្សេយ្យន្តិ ។ រាជា អានន្ទ មហាសុទស្សនោ ឥមាយ ចតុត្ថាយ ឥទ្ធិយា សមន្នាគតោ អហោសិ ។ រាជា អានន្ទ មហាសុទស្សនោ ឥមាហិ ចតូហិ ឥទ្ធីហិ សមន្នាគតោ អហោសិ ។

[១៣] អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ យំនូនាហំ ឥមេសុ តាលន្តរេសុ ធនុសតេ ធនុសតេ បោក្ខរណិយោ មាបេយ្យន្តិ ។



ចំណែកខាងព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យនៃព្រះបាទមហាសុទស្សនៈ យ៉ាងនោះដែរ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ កាលមុនដំបូង ទ្រង់ស្តេចទៅកាន់ឧទ្យាន ដោយចតុរង្គសេនា ។ ម្នាលអានន្ទ លំដាប់នោះ ព្រាហ្មណ៍និងគហបតីទាំងឡាយ ចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំស្តេចទៅ ដោយរហ័សរួសរាន់ ដូចខ្ញុំព្រះអង្គទាំងឡាយ ធ្លាប់ឃើញព្រះអង្គមកអស់កាលយូរនោះឡើយ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់នឹងសារថីថា ម្នាលសារថី អ្នកកុំបររថទៅ ដោយរហ័សរួសរាន់ ដូចយើងធ្លាប់ឃើញព្រាហ្មណ៍ និងគហបតីទាំងឡាយ មកអស់កាលយូរយារនោះឡើយ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិនេះ ជាឫទ្ធិទី ៤ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ប្រកបដោយឫទ្ធិទាំង ៤ នេះឯង ។

(១៣) ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញសាងស្រះបោក្ខរណីទាំងឡាយ ស្ទើរតែ ១ រយធ្នូ ៗ ក្បែរចន្លោះដើមត្នោតទាំងឡាយនេះ ។

មាបេសិ ខោ អានន្ទ រាជា មហាសុទស្សនោ ឥមេសុ តាលន្តរេសុ ធនុសតេ ធនុសតេ បោក្ខរណិយោ ។ តា ខោ បនានន្ទ បោក្ខរណិយោ ចតុន្នំ វណ្ណានំ ឥដ្ឋកាហិ ចិតា អហេសុំ ឯកា ឥដ្ឋកា សោវណ្ណមយា ឯកា រូបិយមយា ឯកា វេឡុរិយមយា ឯកា ផលិកមយា ។ តាសុ ខោ បនានន្ទ បោក្ខរណីសុ ចត្តារិ(១) សោបានានិ អហេសុំ ចតុន្នំ វណ្ណានំ សោបានំ សោវណ្ណមយំ ឯកំ រូបិយមយំ ឯកំ វេឡុរិយមយំ ឯកំ ផលិកមយំ ។ សោវណ្ណមយស្ស សោបានស្ស សោវណ្ណមយា ថម្ភា អហេសុំ រូបិយមយា សូចិយោ ច ឧណ្ហីសញ្ច ។ រូបិយមយស្ស សោបានស្ស រូបិយមយា ថម្ភា អហេសុំ សោវណ្ណមយា សូចិយោ ច ឧណ្ហីសញ្ច ។ វេឡុរិយមយស្ស សោបានស្ស វេឡុរិយមយា ថម្ភា អហេសុំ ផលិកមយា សូចិយោ ច ឧណ្ហីសញ្ច ។ ផលិកមយស្ស សោបានស្ស ផលិកមយា

១ ម. ឆ. ចត្តារិ ចត្តារីតិ អាមេណ្ឌិតំ ទិស្សតិ ។



ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់កសាងស្រះបោក្ខរណីទាំងឡាយ(១) ស្មើតែ ១ រយធ្នូ ៗ ក្នុងចន្លោះដើមត្នោតទាំងនោះ ។ ម្នាលអានន្ទ ឯស្រះបោក្ខរណីទាំងនោះឯង វិចិត្រដោយឥដ្ឋ ៤ យ៉ាង គឺឥដ្ឋមាសមួយយ៉ាង ឥដ្ឋប្រាក់មួយយ៉ាង ឥដ្ឋកែវពិទូរ្យមួយយ៉ាង ឥដ្ឋកែវផលិកមួយយ៉ាង ។ ម្នាលអានន្ទ ក្នុងស្រះបោក្ខរណីទាំងនោះ មានជណ្ដើរ ៤ បែប គឺជណ្ដើរមាសមួយបែប ជណ្ដើរប្រាក់មួយបែប ជណ្ដើរកែវពិទូរ្យមួយបែប ជណ្ដើរកែវផលិកមួយបែប ។ ជណ្ដើរមាស មានសសរជាមាស តែកាំនិងក្បាលជណ្ដើរជាប្រាក់ ។ ជណ្ដើរប្រាក់ មានសសរជាប្រាក់ តែកាំនិងក្បាលជណ្ដើរជាមាស ។ ជណ្ដើរកែវពិទូរ្យ មានសសរជាកែវពិទូរ្យ តែកាំនិងក្បាលជណ្ដើរជាកែវផលិក ។ ជណ្ដើរកែវផលិក

១ អដ្ឋកថា ថា ស្រះបោក្ខរណី ៨៤.០០០ ទម្លាយផែនដីកើតឡើង ដោយព្រោះតែព្រះបាទមហាសុទស្សនៈនឹកក្នុងព្រះហឫទ័យ ។

ថម្ភា អហេសុំ វេឡុរិយមយា សុចិយោ ច ឧណ្ហីសញ្ច ។ តា ខោ បនានន្ទ បោក្ខរណិយោ ទ្វីហិ វេទិកាហិ បរិក្ខិត្តា អហេសុំ ឯកា វេទិកា សោវណ្ណមយា ឯកា រូបិយមយា ។ សោវណ្ណមយាយ វេទិកាយ សោវណ្ណមយា ថម្ភា អហេសុំ រូបិយមយា សុចិយោ ច ឧណ្ហីសញ្ច ។ រូបិយមយាយ វេទិកាយ រូបិយមយា ថម្ភា អហេសុំ សោវណ្ណមយា សុចិយោ ច ឧណ្ហីសញ្ច ។ អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ យន្នូនាហំ ឥមាសុ បោក្ខរណីសុ ឯវរូបំ មាលំ រោបាបេយ្យំ ឧប្បលំ បទុមំ កុមុទំ បុណ្ឌរីកំ សព្វោតុកំ សព្វជនស្ស អនាវដ្ដំ(១) ។ រោបាបេសិ ខោ អានន្ទ រាជា មហាសុទស្សនោ តាសុ បោក្ខរណីសុ ឯវរូបំ មាលំ ឧប្បលំ បទុមំ កុមុទំ បុណ្ឌរីកំ សព្វោតុកំ សព្វជនស្ស អនាវដ្ដំ ។ អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ យន្នូនាហំ ឥមាសំ បោក្ខរណីនំ តីរេ ន្ហាបកេ បុរិសេ ឋបេយ្យំ

១ ម. អនាវដ្ដំ ។



មានជើងជាកែវផលិក តែកាំនិងកំពូលដងជណ្ដើរជាកែវពេទូរ្យ ។ ម្នាលអានន្ទ មួយទៀត ស្រះបោក្ខរណីទាំងនោះឯង ព័ទ្ធជុំវិញដោយរបងពីរជាន់ គឺរបងមាស ១ របងប្រាក់ ១ ។ របងមាស មានសសរបង្គោលជាមាស តែបារបងនិងកំពូលបង្គោលរបងជាប្រាក់ ។ របងប្រាក់ មានសសរបង្គោលជាប្រាក់ តែបារបងនិងកំពូលបង្គោលរបងជាមាស ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា ក្នុងស្រះបោក្ខរណីទាំងនេះ គួរតែអាត្មាអញនឹងដាំដើមផ្កាទាំងនេះ គឺឧប្បល ឈូកក្រហម កុមុទ ឈូកស ដែលមានផ្កាកើតគ្រប់រដូវ មិនបានឃាត់ឃាំងដល់ជនទាំងពួង ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ដាំដើមផ្កាទាំងនេះ ក្នុងស្រះបោក្ខរណីទាំងនោះ គឺឧប្បល ឈូកក្រហម កុមុទ ឈូកស ដែលមានផ្កាកើតគ្រប់រដូវ មិនបានឃាត់ឃាំងដល់ជនទាំងពួង ។ ម្នាលអានន្ទ គ្រានោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញតាំងន្ហាបកបុរស (អ្នកផ្ងូតទឹក) ទុកទៀបឆ្នេរស្រះបោក្ខរណីទាំងនេះ សម្រាប់

យេ អាគតាគតំ ជនំ បានេន បរិចារេស្សន្តីតិ ។ ឋបេសិ(១) ខោ អានន្ទ រាជា មហាសុទស្សនោ តាសំ បោក្ខរណីនំ តីរេ បរិចារកេ បុរិសេ យេ អាគតាគតំ ជនំ បានេន បរិចារេន្តិ ។ អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ យន្នូនាហំ ឥមាសំ បោក្ខរណីនំ តីរេ ឯវរូបំ ទានំ បដ្ឋបេយ្យំ អន្នំ អន្នត្ថិកស្ស បានំ បានត្ថិកស្ស វត្ថំ វត្ថត្ថិកស្ស យានំ យានត្ថិកស្ស សយនំ សយនត្ថិកស្ស ឥត្ថឹ ឥត្ថត្ថិកស្ស(២) ហិរញ្ញំ ហិរញ្ញត្ថិកស្ស សុវណ្ណំ សុវណ្ណត្ថិកស្សាតិ ។ បដ្ឋបេសិ ខោ អានន្ទ រាជា មហាសុទស្សនោ តាសំ បោក្ខរណីនំ តីរេ ឯវរូបំ ទានំ អន្នំ អន្នត្ថិកស្ស បានំ បានត្ថិកស្ស វត្ថំ វត្ថត្ថិកស្ស យានំ យានត្ថិកស្ស សយនំ សយនត្ថិកស្ស ឥត្ថឹ ឥត្ថត្ថិកស្ស ហិរញ្ញំ ហិរញ្ញត្ថិកស្ស សុវណ្ណំ សុវណ្ណត្ថិកស្សាតិ ។

១ ម. បដ្ឋបេសិ ។ ២ ម. ឥត្ថិកស្ស ។



*ផឹកទឹកដល់ជនដែលមកហើយ ៗ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់តាំងនូវបរិចារកបុរស ទុកទៀបឆ្នេរស្រះបោក្ខរណីទាំងនោះ សម្រាប់ផ្តុកទឹកដល់ជនដែលមកហើយ ៗ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កៈយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញតាំងនូវទាន (រោងទាន) មានសភាពយ៉ាងនេះ ក្បែរឆ្នេរស្រះបោក្ខរណីទាំងនេះ គឺ បាយសម្រាប់អ្នកត្រូវការបាយ ទឹកសម្រាប់អ្នកត្រូវការទឹក សំពត់សម្រាប់អ្នកត្រូវការសំពត់ យានសម្រាប់អ្នកត្រូវការយាន ទីដេកសម្រាប់អ្នកត្រូវការទីដេក ស្រីសម្រាប់អ្នកត្រូវការស្រី ប្រាក់សម្រាប់អ្នកត្រូវការប្រាក់ មាសសម្រាប់អ្នកត្រូវការមាស ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បានតាំងទានទុកនេះ ក្បែរឆ្នេរស្រះបោក្ខរណីទាំងនោះ គឺ បាយសម្រាប់អ្នកត្រូវការបាយ ទឹកសម្រាប់អ្នកត្រូវការទឹក សំពត់សម្រាប់អ្នកត្រូវការសំពត់ យានសម្រាប់អ្នកត្រូវការយាន ទីដេកសម្រាប់អ្នកត្រូវការទីដេក ស្រីសម្រាប់អ្នកត្រូវការស្រី ប្រាក់សម្រាប់អ្នកត្រូវការប្រាក់ មាសសម្រាប់អ្នកត្រូវការមាស ។*

[១៦] អថខោ អានន្ទ ព្រាហ្មណគហបតិកា បហូតំ សាបតេយ្យំ អាទាយ រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯវមាហំសុ ឥទំ ទេវ បហូតំ សាបតេយ្យំ ទេវស្សេវ(១) ឧទ្ទិស្ស អាភតំ តំ ទេវោ បដិគ្គណ្ហាតូតិ ។ អលំ ភោ មមមិទំ(២) បហូតំ សាបតេយ្យំ ធម្មិកេន ពលិនា អភិសង្ខតំ តំ វោ ហោតុ ឥតោ ច ភិយ្យោ ហរថាតិ ។ តេ រញ្ញា បដិក្ខិត្តា ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ ន ខោ ឯវំ(៣) អម្ហាកំ បដិរូបំ យំ ឥមានិ(៤) សាបតេយ្យានិ បុនទេវ សកានិ ឃរានិ បដិហរេយ្យាម(៥) យន្នូន មយំ រញ្ញោ មហាសុទស្សនស្ស និវេសនំ មាបេយ្យាមាតិ ។ តេ រាជានំ មហាសុទស្សនំ ឧបសង្កមិត្វា ឯវមាហំសុ និវេសនំ តេ ទេវ មាបេយ្យាមាតិ(៦) ។ អធិវាសេសិ ខោ អានន្ទ រាជា មហាសុទស្សនោ តុណ្ហីភាវេន ។

---

១ ម. ទេវញ្ញេវ ។ ២ ម. មមបិទំ ។ ៣ ម. ឯតំ ។ ៤ ម. យំ មយំ ឥមានិ ។ ៥ ម. បដិហរាម ។ ៦ ម. មាបេស្សាមាតិ ។



[១៦] ម្នាលអានន្ទ លំដាប់នោះ ព្រាហ្មណ៍និងគហបតីទាំងឡាយ នាំយកសម្បត្តិដ៏ច្រើន ចូលទៅគាល់ព្រះបាទមហាសុទស្សនៈក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សម្បត្តិដ៏ច្រើននេះ យើងខ្ញុំព្រះករុណានាំមកថ្វាយចំពោះព្រះអង្គ សូមព្រះអង្គ ទ្រង់ទទួលសម្បត្តិទាំងនោះ ។ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន កុំឡើយ សម្បត្តិដ៏ច្រើននេះ ដែលអ្នកនាំមកដើម្បីយើង ដោយពលិកម្មប្រកបដោយធម៌ហើយ តែទ្រព្យសម្បត្តិទាំងនោះ ចូរនៅជារបស់អ្នកទាំងឡាយវិញចុះ ចូរអ្នកទាំងឡាយ នាំយកពីនេះថែមទៅទៀតចុះ ។ ពួកព្រាហ្មណ៍និងគហបតីទាំងនោះ លុះស្ដេចឃាត់យ៉ាងនេះហើយ ក៏ថយចេញទៅនៅក្នុងទីដ៏សមគួរ ហើយគិតព្រមគ្នាយ៉ាងនេះថា ការដែលពួកយើង នាំយកសម្បត្តិទាំងនេះ ត្រឡប់ទៅទុកផ្ទះរបស់យើងវិញយ៉ាងនេះ មិនសមគួរ ដល់ពួកយើងឡើយ បើដូច្នេះ ពួកយើងនាំគ្នាសាងនិវេសនដ្ឋាន ថ្វាយព្រះបាទមហាសុទស្សនៈវិញ ។ ពួកព្រាហ្មណ៍និងគហបតីទាំងនោះ ក៏នាំគ្នាចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គនឹងនាំគ្នាសាងនិវេសន៍ ថ្វាយព្រះអង្គ ។ ម្នាលអានន្ទ ឯព្រះបាទមហាសុទស្សនៈ ទ្រង់ព្រមទទួលដោយតុណ្ហីភាព ។

(១៨) អថ ខោ អានន្ទ សក្កោ ទេវានមិន្ទោ រញ្ញោ មហាសុទស្សនស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ វិស្សកម្មំ(១) ទេវបុត្តំ អាមន្តេសិ ឯហិ ត្វំ សម្ម វិស្សកម្ម រញ្ញោ មហាសុទស្សនស្ស និវេសនំ មាបេហិ ធម្មំ នាម បាសាទន្តិ ។ ឯវំ ភទ្ទន្តវាតិ ខោ អានន្ទ វិស្សកម្មោ ទេវបុត្តោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុណិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ទេវេសុ តាវតិំសេសុ អន្តរហិតោ រញ្ញោ មហាសុទស្សនស្ស បុរតោ បាតុរហោសិ ។ អថ ខោ អានន្ទ វិស្សកម្មោ ទេវបុត្តោ រាជានំ មហាសុទស្សនំ ឯតទវោច និវេសនំ តេ ទេវ មាបេស្សាមិ ធម្មំ នាម បាសាទន្តិ ។ អធិវាសេសិ ខោ អានន្ទ រាជា មហាសុទស្សនោ តុណ្ហីភាវេន ។ មាបេសិ ខោ អានន្ទ

១ ម. វិស្សុកម្មំ ។





[១៨] ម្នាលអានន្ទ លំដាប់នោះឯង សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ បានជ្រាបបរិវិតក្កនៃព្រះហឫទ័យនៃព្រះបាទមហាសុទស្សនៈ ដោយព្រះហឫទ័យនៃព្រះអង្គ ក៏ត្រាស់ហៅវិស្សកម្មទេវបុត្តមកថា នែវិស្សកម្មទេវបុត្តជាសំឡាញ់ អ្នកចូរមកនេះ អ្នកចូរទៅនិម្មិតព្រះរាជនិវេសន៍ឈ្មោះធម្មប្រាសាទ ថ្វាយព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ វិស្សកម្មទេវបុត្ត បានទទួលបន្ទូលរបស់សក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ ដោយពាក្យថា អាកំពើយ៉ាងនេះ ជាការប្រពៃ ដល់ព្រះអង្គហើយ ដូច្នេះហើយក៏បាត់អំពីឋានទេវតាឈ្មោះតាវត្តិង្ស មកប្រាកដក្នុងទីចំពោះព្រះភក្ត្រ នៃព្រះបាទមហាសុទស្សនៈ ដូចបុរសដែលមានកម្លាំង លាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញ ដូច្នោះឯង ។ ម្នាលអានន្ទ គ្រានោះឯង វិស្សកម្មទេវបុត្ត បានក្រាបបង្គំទូលព្រះបាទមហាសុទស្សនៈយ៉ាងនេះថា បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំនឹងនិម្មិតព្រះរាជនិវេសន៍ឈ្មោះធម្មប្រាសាទ ថ្វាយព្រះអង្គ ។ ម្នាលអានន្ទ ឯព្រះបាទមហាសុទស្សនៈ ទ្រង់ទទួលដោយតុណ្ហីភាព ។ ម្នាលអានន្ទ វិស្សកម្ម-

វិស្សកម្មោ ទេវបុត្តោ រញ្ញោ មហាសុទស្សនស្ស និវេសនំ ធម្មំ នាម បាសាទំ ។ ធម្មោ អានន្ទ បាសាទោ បុរត្ថិមេន ច បច្ឆិមេន ច យោជនំ អាយាមេន អហោសិ ឧត្តរេន ច ទក្ខិណេន ច អឌ្ឍយោជនំ វិត្ថារេន ។ ធម្មស្ស អានន្ទ បាសាទស្ស តិគាវុតំ ឧព្វេធេន វត្ថុ ចិតំ អហោសិ ចតូហិ វណ្ណេហិ ឥដ្ឋកាហិ ឯកា ឥដ្ឋកា សោវណ្ណមយា ឯកា រូបិយមយា ឯកា វេឡុរិយមយា ឯកា ផលិកមយា ។ ធម្មស្ស អានន្ទ បាសាទស្ស ចតុរាសីតិថម្ភសហស្សានិ អហេសុំ ចតុន្នំ វណ្ណានំ ឯកោ ថម្ភោ សោវណ្ណមយោ ឯកោ រូបិយមយោ ឯកោ វេឡុរិយមយោ ឯកោ ផលិកមយោ ។ ធម្មោ អានន្ទ បាសាទោ ចតូហិ វណ្ណេហិ ផលកេហិ សន្ថតោ អហោសិ ឯកំ ផលកំ សោវណ្ណមយំ ឯកំ រូបិយមយំ ឯកំ វេឡុរិយមយំ ឯកំ ផលិកមយំ ។ ធម្មស្ស អានន្ទ បាសាទស្ស ចតុវីសតិសោបានានិ អហេសុំ ចតុន្នំ វណ្ណានំ ឯកំ





ទេវបុត្ត ក៏បាននិម្មិតប្រាសាទដ៏ប្រសើរ ឈ្មោះធម្មប្រាសាទ ថ្វាយព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ធម្មប្រាសាទ បណ្ដោយពីទិសខាងកើតទៅទិសខាងលិច ១ យោជន៍ ទទឹងពីទិសខាងជើង ទៅទិសខាងត្បូងកន្លះយោជន៍ ។ ម្នាលអានន្ទ ធម្មប្រាសាទ មានវត្ថុដែលវិចិត្រដោយឥដ្ឋមានពណ៌ ៤ យ៉ាង ដោយកម្ពស់ ៣ គាវុត គឺឥដ្ឋមាស ១ យ៉ាង ឥដ្ឋប្រាក់ ១ យ៉ាង ឥដ្ឋកែវពិទូរ្យ ១ យ៉ាង ឥដ្ឋកែវផលិក ១ យ៉ាង ។ ម្នាលអានន្ទ ធម្មប្រាសាទ មានសសរ ៨៤ ០០០ មានពណ៌ ៤ យ៉ាង គឺ សសរមាស ១ យ៉ាង សសរប្រាក់ ១ យ៉ាង សសរកែវពិទូរ្យ ១ យ៉ាង សសរកែវផលិក ១ យ៉ាង ។ ម្នាលអានន្ទ ធម្មប្រាសាទ ក្រាលដោយផែនក្ដារមានពណ៌ ៤ យ៉ាង គឺ ផែនក្ដារមាស ១ យ៉ាង ផែនក្ដារប្រាក់ ១ យ៉ាង ផែនក្ដារកែវពិទូរ្យ ១ យ៉ាង ផែនក្ដារកែវផលិក ១ យ៉ាង ។ ម្នាលអានន្ទ ធម្មប្រាសាទ មានជណ្ដើរ ២៤ មានពណ៌ ៤ យ៉ាង គឺ

តោរណានំ សោវណ្ណមយំ ឯកំ រូបិយមយំ ឯកំ វេឡុរិយមយំ ឯកំ ផលិកមយំ ។ សោវណ្ណមយស្ស តោរណស្ស សោវណ្ណមយា ថម្ភា អហេសុំ រូបិយមយា សូចិយោ ច ឧណ្ហីសញ្ច ។ រូបិយមយស្ស តោរណស្ស រូបិយមយា ថម្ភា អហេសុំ សោវណ្ណមយា សូចិយោ ច ឧណ្ហីសញ្ច ។ វេឡុរិយមយស្ស តោរណស្ស វេឡុរិយមយា ថម្ភា អហេសុំ ផលិកមយា សូចិយោ ច ឧណ្ហីសញ្ច ។ ផលិកមយស្ស តោរណស្ស ផលិកមយា ថម្ភា អហេសុំ វេឡុរិយមយា សូចិយោ ច ឧណ្ហីសញ្ច ។ ធម្មេ អានន្ទ បាសាទេ ចតុរាសីតិកូដាគារសហស្សានិ អហេសុំ ចតុន្នំ វណ្ណានំ ឯកំ កូដាគារំ សោវណ្ណមយំ ឯកំ រូបិយមយំ ឯកំ វេឡុរិយមយំ ឯកំ ផលិកមយំ ។ សោវណ្ណមយេ កូដាគារេ រូបិយមយោ បល្លង្កោ បញ្ញត្តោ អហោសិ ។ រូបិយមយេ កូដាគារេ



ជណ្ដើរមាស ១ យ៉ាង ជណ្ដើរប្រាក់ ១ យ៉ាង ជណ្ដើរកែវពិទូរ្យ ១ យ៉ាង ជណ្ដើរកែវផលិក ១ យ៉ាង ។ ជណ្ដើរមាស មេជាមាស តែកាំនិងក្បាលជណ្ដើរ ជាប្រាក់ ។ ជណ្ដើរប្រាក់ មេជាប្រាក់ តែកាំនិងក្បាលជណ្ដើរ ជាមាស ។ ជណ្ដើរកែវពិទូរ្យ មេជាកែវពិទូរ្យ តែកាំនិងក្បាលជណ្ដើរ ជាកែវផលិក ។ ជណ្ដើរកែវផលិក មេជាកែវផលិក តែកាំនិងក្បាលជណ្ដើរ ជាកែវពិទូរ្យ ។ ម្នាលអានន្ទ ធម្មប្រាសាទ មានផ្ទះកំពូល ៨៤ ០០០ មានបែប ៤ យ៉ាងគឺ ផ្ទះកំពូលដែលធ្វើដោយមាស ១ យ៉ាង ធ្វើដោយប្រាក់ ១ យ៉ាង ធ្វើដោយកែវពិទូរ្យ ១ យ៉ាង ធ្វើដោយកែវផលិក ១ យ៉ាង ។ ក្នុងផ្ទះកំពូល ដែលធ្វើដោយមាស មានតែងតាំងបល្ល័ង្កប្រាក់ ។ ក្នុងផ្ទះកំពូល ដែលធ្វើដោយប្រាក់ មាន

សោវណ្ណមយោ បល្លង្កោ បញ្ញត្តោ អហោសិ ។ វេឡុរិយមយេ កូដាគារេ ទន្តមយោ បល្លង្កោ បញ្ញត្តោ អហោសិ ។ ផលិកមយេ កូដាគារេ មសារគល្លមយោ បល្លង្កោ បញ្ញត្តោ អហោសិ ។ សោវណ្ណមយស្ស កូដាគារស្ស ទ្វារេ រូបិយមយោ តាលោ ឋិតោ អហោសិ តស្ស រូបិយមយោ ខន្ធោ សោវណ្ណមយានិ បត្តានិ ច ផលានិ ច ។ រូបិយមយស្ស កូដាគារស្ស ទ្វារេ សោវណ្ណមយោ តាលោ ឋិតោ អហោសិ តស្ស សោវណ្ណមយោ ខន្ធោ រូបិយមយានិ បត្តានិ ច ផលានិ ច ។ វេឡុរិយមយស្ស កូដាគារស្ស ទ្វារេ ផលិកមយោ តាលោ ឋិតោ អហោសិ តស្ស ផលិកមយោ ខន្ធោ វេឡុរិយមយានិ បត្តានិ ច ផលានិ ច ។ ផលិកមយស្ស កូដាគារស្ស ទ្វារេ វេឡុរិយមយោ តាលោ ឋិតោ អហោសិ តស្ស វេឡុរិយមយោ ខន្ធោ ផលិកមយានិ បត្តានិ ច ផលានិ ច ។



តែងតាំងបល្ល័ង្កមាស ។ ក្នុងផ្ទះកំពូលដែលធ្វើដោយកែវពិទូរ្យ មានតែងតាំងបល្ល័ង្កភ្លុក ។ ក្នុងផ្ទះកំពូលដែលធ្វើដោយកែវផលិក មានតែងតាំងបល្ល័ង្កកែវមរកត ។ មានដើមត្នោតប្រាក់ ឋិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយមាស ឯត្នោតនោះមានដើមជាប្រាក់ តែស្លឹកនិងផ្លែជាមាស ។ មានដើមត្នោតមាស ឋិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយប្រាក់ ឯត្នោតនោះ មានដើមជាមាស តែស្លឹកនិងផ្លែជាប្រាក់ ។ មានដើមត្នោតកែវផលិក ឋិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយកែវពិទូរ្យ ឯត្នោតនោះមានដើមជាកែវផលិក តែស្លឹកនិងផ្លែជាកែវពិទូរ្យ ។ មានដើមត្នោតកែវពិទូរ្យ ឋិតនៅជិតទ្វារផ្ទះកំពូលដែលធ្វើដោយកែវផលិក ឯត្នោតនោះមានដើមជាកែវពិទូរ្យ តែស្លឹកនិងផ្លែជាកែវផលិក ។

[១៦] អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ យន្នូនាហំ មហាវិយូហស្ស កូដាគារស្ស ទ្វារេ សព្វសោវណ្ណមយំ តាលវនំ មាបេយ្យំ យត្ថ ទិវាវិហារំ និសីទិស្សាមីតិ ។ មាបេសិ ខោ អានន្ទ រាជា មហាសុទស្សនោ មហាវិយូហស្ស កូដាគារស្ស ទ្វារេ សព្វសោវណ្ណមយំ តាលវនំ យត្ថ ទិវាវិហារំ និសីទិ ។ ធម្មោ អានន្ទ បាសាទោ ទ្វីហិ វេទិកាហិ បរិក្ខិត្តោ អហោសិ ឯកា វេទិកា សោវណ្ណមយា ឯកា រូបិយមយា ។ សោវណ្ណមយាយ វេទិកាយ សោវណ្ណមយា ថម្ភា អហេសុំ រូបិយមយា សូចិយោ ច ឧណ្ហីសញ្ច ។ រូបិយមយាយ វេទិកាយ រូបិយមយា ថម្ភា អហេសុំ សោវណ្ណមយា សូចិយោ ច ឧណ្ហីសញ្ច ។ ធម្មោ អានន្ទ បាសាទោ ទ្វីហិ កិង្កណិកជាលេហិ(១) បរិក្ខិត្តោ អហោសិ ឯកំ ជាលំ សោវណ្ណមយំ ឯកំ

១ ម. កិង្កណិកផលេហិ ។



[១៦] ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កៈយ៉ាងនេះថា បើដូច្នោះ មានតែអាត្មាអញ សាងព្រៃត្នោតមាសសុទ្ធ ជិតទ្វារនៃផ្ទះកំពូលដែលរុងរឿងដោយប្រាក់ ត្រង់កន្លែងដែលអាត្មាអញនឹងអង្គុយគង់វេលាថ្ងៃ ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់បានសាងព្រៃត្នោតមាសសុទ្ធ ជិតទ្វារនៃផ្ទះកំពូលដែលរុងរឿងដោយប្រាក់ ត្រង់កន្លែងដែលស្តេចគង់ក្នុងវេលាថ្ងៃ ។ ម្នាលអានន្ទ ធម្មប្រាសាទ ព័ទ្ធជុំវិញដោយរបង ២ ជាន់ គឺរបងមាស ១ ជាន់ របងប្រាក់ ១ ជាន់ ។ របងមាស មានសសរបង្គោល ជាមាស តែបង្អែកនិងក្បាលបង្គោលរបង ជាប្រាក់ ។ របងប្រាក់ មានសសរបង្គោលជាប្រាក់ តែបង្អែករបង និងក្បាលបង្គោលរបង ជាមាស ។ ម្នាលអានន្ទ ធម្មប្រាសាទព័ទ្ធជុំវិញ ដោយបណ្តាញនៃកណ្តឹង ២ យ៉ាង គឺបណ្តាញមាស ១ យ៉ាង បណ្តាញ

រូបិយមយំ ។ សោវណ្ណមយស្ស ជាលស្ស រូបិយម-
យា កិង្កណិកា(១) អហោសិ ។ រូបិយមយស្ស ជា-
លស្ស សោវណ្ណមយា កិង្កណិកា(២) អហោសិ ។
តេសំ ខោ អានន្ទ កិង្កណិកជាលានំ វាតេរិតានំ
សទ្ទោ អហោសិ វគ្គុ ច រជនីយោ ច ខមនីយោ ច
មទនីយោ ច ។ សេយ្យថាបិ អានន្ទ បញ្ចង្គិកស្ស
តុរិយស្ស សុវិនីតស្ស សុប្បដិតាឡិតស្ស កុសលេហិ
សុសមន្នាហតស្ស សទ្ទោ ហោតិ វគ្គុ ច រជនីយោ ច
ខមនីយោ ច មទនីយោ ច ឯវមេវ ខោ អានន្ទ តេសំ
កិង្កណិកជាលានំ វាតេរិតានំ សទ្ទោ អហោសិ វគ្គុ
ច រជនីយោ ច ខមនីយោ ច មទនីយោ ច ។ យេ
ខោ បនានន្ទ តេន សមយេន កុសាវតិយា រាជធានិ-
យា ធុត្តា អហេសុំ សោណ្ឌា បិបាសា តេ តេសំ
កិង្កណិកជាលានំ វាតេរិតានំ សទ្ទេន បរិចារេសុំ ។
និដ្ឋិតោ ខោ អានន្ទ(៣) ធម្មោ បាសាទោ ទុទ្ទិក្ខោ
អហោសិ មុសតិ ចក្ខូនិ ។ សេយ្យថាបិ អានន្ទ

១-២ ម. កិង្កណិកាយោ ។ ៣ ម. បនានន្ទ ។



ប្រាក់ ១ យ៉ាង ។ បណ្តាញមាស កណ្តឹងជាប្រាក់ ។ បណ្តាញ
ប្រាក់ កណ្តឹងជាមាស ។ ម្នាលអានន្ទ បណ្តាញកណ្តឹងទាំងនោះ
កាលបើត្រូវខ្យល់បក់មក ក៏មានសំឡេងពីរោះ គួរត្រេកអរ គួរឲ្យរីកត្រ-
ចៀកស្តាប់ គួរជក់ចិត្ត ។ ម្នាលអានន្ទ តន្ត្រីប្រកបដោយអង្គ ៥ ដែល
មនុស្សអ្នកឈ្លាសវៃផ្សំ ហើយវាយទំនួញពីរោះល្អ ទើបដេញប្រគំដី
មានសំឡេងពីរោះ គួរត្រេកអរ គួរឲ្យរីកត្រចៀកស្តាប់ គួរជក់ចិត្ត
មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ បណ្តាញកណ្តឹងទាំងនោះ ដែល
ខ្យល់បក់មកត្រូវ ក៏មានសំឡេងពីរោះពីរោះ គួរត្រេកអរ គួរឲ្យរីកត្រចៀក
ស្តាប់ គួរជក់ចិត្ត ដូច្នោះឯង ។ ម្នាលអានន្ទ ក្នុងសម័យនោះឯង
កុសាវតីរាជធានី មានអ្នកលេងល្បែងភ្នាល់ និងអ្នកលេងស៊ីផឹក ពួកអ្នក
លេងទាំងនោះ ក៏នាំគ្នាលេងរាំរែក តាមសំឡេងបណ្តាញកណ្តឹង ដែល
ខ្យល់បក់មកត្រូវទាំងនោះ ។ ម្នាលអានន្ទ លុះធម្មប្រាសាទ សម្រេច
ហើយ លំបាកនឹងមើលបាន អ្នកមើល ព្រិលភ្នែក ។ ម្នាលអានន្ទ

វស្សានំ បច្ឆិមេ មាសេ សារទសមយេ វិសុទ្ធេ ឧ-
ព្វិទ្ធេ វិគតវលាហកេ(1) ទេវេ អាទិច្ចោ នភំ អព្ភុ-
ស្សក្កមានោ(2) ទុទ្ទិក្ខោ អហោសិ មុសតិ ចក្ខូនិ
ឯវមេវ ខោ អានន្ទ ធម្មោ បាសាទោ ទុទ្ទិក្ខោ
អហោសិ មុសតិ ចក្ខូនិ ។ អថខោ អានន្ទ
រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ យន្នូនាហំ
ធម្មស្ស បាសាទស្ស បុរតោ ធម្មំ នាម បោក្ខរ-
ណឹ មាបេយ្យន្តិ ។ មាបេសិ ខោ អានន្ទ រាជា
មហាសុទស្សនោ ធម្មស្ស បាសាទស្ស បុរតោ ធម្មំ
នាម បោក្ខរណឹ ។ ធម្មា អានន្ទ បោក្ខរណី បុរត្ថិមេន
ច បច្ឆិមេន ច យោជនំ អាយាមេន អហោសិ(3)
ឧត្តរេន ច ទក្ខិណេន ច អឌ្ឍយោជនំ វិត្ថារេ-
ន ។ ធម្មា អានន្ទ បោក្ខរណី ចតូហិ វណ្ណេហិ
ឥដ្ឋកាហិ ចិតា អហោសិ ឯកា ឥដ្ឋកា សោ-
វណ្ណមយា ឯកា រូបិយមយា ឯកា វេឡុរិយមយា

១ ម. ឱ. វិទ្ធេ វិគតវលាហកេ ។ ២ ម. អព្ភុស្សុក្កមានោ ។ ឱ. អព្ភុគ្គមមានោ ។
៣ ម. អាយាមេន ។ អហោសិ ។



កាលដល់សារទសម័យ(1) ខែខាងចុងនៃវស្សានរដូវ មេឃក៏ស្រឡាស់
ចូលមកស៊ប់ពេញទី អាកាសជាត់ឆ្ងាយស្រឡះហើយ ព្រះអាទិត្យក៏
ក្តៅចាំងឡើងក្នុងអាកាស លំបាកនឹងមើលបាន អ្នកមើលរមែងពិលភ្នែក
យ៉ាងណាមិញ ម្នាលអានន្ទ ធម្មប្រាសាទ ដែលលំបាកនឹងមើលបាន
អ្នកមើលតែងពិលភ្នែក ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ លំដាប់នោះ
ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្កៈយ៉ាងនេះថា បើដូច្នោះ គួរតែ
អាត្មាអញសាងស្រះឈ្មោះធម្មបោក្ខរណី ខាងមុខធម្មប្រាសាទ ។ ម្នាល
អានន្ទ ព្រះបាទមហាសុទស្សនៈ ក៏ទ្រង់សាងស្រះឈ្មោះធម្មបោក្ខរណី
ខាងមុខធម្មប្រាសាទ ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី បណ្ដោយ
ពីខាងកើតទៅខាងលិច ១ យោជន៍ ទទឹងពីខាងជើង ទៅខាងត្បូង
កន្លះយោជន៍ ។ ម្នាលអានន្ទ ស្រះធម្មបោក្ខរណី វិចិត្រដោយឥដ្ឋមាន
ពណ៌ ៤ យ៉ាង គឺ ឥដ្ឋមាស ១ យ៉ាង ប្រាក់១យ៉ាង កែវពិទូរ្យ១ យ៉ាង

១ រាប់ពី ១ រោចខែអស្សុជ ដល់ ១៥ កើតខែកត្តិក ហៅថា សារទសម័យ ។

ឯកា ផលិកាមយា ។ ចន្នាយ អានន្ទ(១) បោក្ខរណិ-
យា ចតុវីសតិសោបានានិ អហេសុំ ចតុន្នំ វណ្ណានំ
ឯកំ សោបានំ សោវណ្ណមយំ ឯកំ រូបិយមយំ
ឯកំ វេឡុរិយមយំ ឯកំ ផលិកមយំ ។ សោវណ្ណ-
មយស្ស សោបានស្ស សោវណ្ណមយា ថម្ភា អហេសុំ
រូបិយមយា សូចិយោ ច ឧណ្ហីសញ្ច ។ រូបិយមយស្ស
សោបានស្ស រូបិយមយា ថម្ភា អហេសុំ សោវណ្ណ-
មយា សូចិយោ ច ឧណ្ហីសញ្ច ។ វេឡុរិយមយស្ស
សោបានស្ស វេឡុរិយមយា ថម្ភា អហេសុំ ផលិ-
កមយា សូចិយោ ច ឧណ្ហីសញ្ច ។ ផលិកមយស្ស
សោបានស្ស ផលិកមយា ថម្ភា អហេសុំ វេឡុ-
រិយមយា សូចិយោ ច ឧណ្ហីសញ្ច ។ ចន្នា អានន្ទ
បោក្ខរណី ទ្វីហិ វេទិកាហិ បរិក្ខិត្តា អហោសិ
ឯកា វេទិកា សោវណ្ណមយា ឯកា រូបិយមយា ។
សោវណ្ណមយា វេទិកា សោវណ្ណមយា ថម្ភា
អហេសុំ រូបិយមយា សូចិយោ ច ឧណ្ហីសញ្ច ។

១ ឱ. ចន្នាយ ខ អានន្ទ ។



កែវផលិក ១ យ៉ាង ។ ម្នាលអានន្ទ ស្រះបោក្ខរណី មាន
ជណ្តើរ ២៤ មានពណ៌ ៤ យ៉ាង គឺ ជណ្តើរមាស ១ យ៉ាង ប្រាក់
១ យ៉ាង កែវពិទូរ្យ ១ យ៉ាង ផលិក ១ យ៉ាង ។ ជណ្តើរមាស មេ
ជាមាស តែកាំនិងក្បាលជណ្តើរ ជាប្រាក់ ។ ជណ្តើរប្រាក់ មេ
ជាប្រាក់ តែកាំនិងក្បាលជណ្តើរ ជាមាស ។ ជណ្តើរកែវពិទូរ្យ
មេជាកែវពិទូរ្យ តែកាំនិងក្បាលជណ្តើរ ជាកែវផលិក ។ ជណ្តើរ
កែវផលិក មេជាកែវផលិក តែកាំនិងក្បាលជណ្តើរ ជាកែវពិទូរ្យ ។
ម្នាលអានន្ទ ស្រះបោក្ខរណី ព័ទ្ធជុំវិញ ដោយរបងពីរជាន់
គឺរបងមាស ១ ជាន់ របងប្រាក់ ១ ជាន់ ។ របងមាស មានសសរ
បង្គោលជាមាស តែរនាបនិងក្បាលបង្គោលនៃរបង ជាប្រាក់ ។

រូបិយមយាយ វេទិកាយ រូបិយមយា ថម្ភា អហេសុំ សោវណ្ណមយា សូចិយោ ច ឧណ្ហីសញ្ច ។ ធម្មា អានន្ទ បោក្ខរណី សត្តហិ តាលបន្តីហិ បរិក្ខិត្តា អហោសិ ឯកា តាលបន្តិ សោវណ្ណមយា ឯកា រូបិយមយា ឯកា វេឡុរិយមយា ឯកា ផលិកមយា ឯកា លោហិតង្គមយា ឯកា មសារគល្លមយា ឯកា សព្វរតនមយា ។ សោវណ្ណមយស្ស តាលស្ស សោវណ្ណមយោ ខន្ធោ អហោសិ រូបិយមយានិ បត្តានិ ច ផលានិ ច ។ រូបិយមយស្ស តាលស្ស រូបិយមយោ ខន្ធោ អហោសិ សោវណ្ណមយានិ បត្តានិ ច ផលានិ ច ។ វេឡុរិយមយស្ស តាលស្ស វេឡុរិយមយោ ខន្ធោ អហោសិ ផលិកមយានិ បត្តានិ ច ផលានិ ច ។ ផលិកមយស្ស តាលស្ស ផលិកមយោ ខន្ធោ អហោសិ វេឡុរិយមយានិ បត្តានិ ច ផលានិ ច ។ លោហិតង្គមយស្ស តាលស្ស លោហិតង្គមយោ ខន្ធោ អហោសិ មសារគល្លមយានិ បត្តានិ



របស់ប្រាក់ មានសសរទាំងឡាយរបស់ជាប្រាក់ តែក្ដារបង់និងក្បាល របស់ជាមាស ។ ម្នាលអានន្ទ ស្រះបោក្ខរណី ព័ទ្ធជុំវិញដោយ ជួរដើមត្នោត ៧ ជាន់ ជួរដើមត្នោតមាស ១ ជាន់ ជួរដើមត្នោតប្រាក់ ១ ជាន់ ជួរដើមត្នោត កែវពិទូរ្យ ១ ជាន់ ជួរដើមត្នោតកែវផលិក ១ ជាន់ ជួរដើមត្នោតកែវទទឹម ១ ជាន់ ជួរដើមត្នោតកែវមរកត ១ ជាន់ ជួរដើមត្នោតកែវគ្រប់យ៉ាង ១ ជាន់ ។ ត្នោតមាស ដើមជាមាស តែស្លឹកនិងផ្លែជាប្រាក់ ។ ត្នោតប្រាក់ ដើមជាប្រាក់ តែស្លឹកនិងផ្លែជាមាស ។ ត្នោតកែវពិទូរ្យ ដើមជាកែវពិទូរ្យ តែស្លឹកនិងផ្លែជាកែវផលិក ។ ត្នោតកែវផលិក ដើមជាកែវផលិក តែស្លឹកនិងផ្លែជាកែវពិទូរ្យ ។ ត្នោតកែវទទឹម ដើមជាកែវទទឹម តែស្លឹកនិងផ្លែ

ច ផលានិ ច ។ មសារគល្លមយស្ស តាលស្ស មសារគល្លមយោ ខន្ធោ អហោសិ លោហិតង្គមយានិ បត្តានិ ច ផលានិ ច ។ សព្វរតនមយស្ស តាលស្ស សព្វរតនមយោ ខន្ធោ អហោសិ សព្វរតនមយានិ បត្តានិ ច ផលានិ ច ។ តាសំ ខោ បនានន្ទ តាលបន្តីនំ វាតេរិតានំ សទ្ទោ អហោសិ វគ្គុ ច រជនីយោ ច ខមនីយោ(១) ច មទនីយោ ច ។ សេយ្យថាបិ អានន្ទ បញ្ចង្គិកស្ស តុរិយស្ស សុវិនីតស្ស សុប្បដិតាឡិតស្ស កុសលេហិ សុសមន្នាហតស្ស សទ្ទោ អហោសិ វគ្គុ ច រជនីយោ ច ខមនីយោ ច មទនីយោ ច ឯវមេវ ខោ អានន្ទ តាសំ តាលបន្តីនំ វាតេរិតានំ សទ្ទោ អហោសិ វគ្គុ ច រជនីយោ ច ខមនីយោ ច មទនីយោ ច ។ យេ ខោ បនានន្ទ តេន សមយេន កុសាវតិយា រាជធានិយា ធុត្តា អហេសុំ សោណ្ឌា បិបាសា តេ តាសំ តាលបន្តីនំ វាតេរិតានំ សទ្ទេន បរិចារេសុំ ។

១ ម. ខមនីយោ ។



ជាកែវមរកត ។ ត្នោតកែវមរកត ដើមជាកែវមរកត តែស្លឹកនិងផ្លែជាកែវទទឹម ។ ត្នោតកែវគ្រប់យ៉ាង ដើមជាកែវគ្រប់យ៉ាង ឯស្លឹកនិងផ្លែជាកែវគ្រប់យ៉ាង ។ ម្នាលអានន្ទ ជួរត្នោតទាំងនោះឯង កាលបើមានខ្យល់បក់មកត្រូវ មានសំឡេងពីរោះ គួរត្រេកអរ គួរផ្ទៀងក្រចៀកស្តាប់ គួរជក់ចិត្ត ។ ម្នាលអានន្ទ តូរ្យប្រកបដោយអង្គ ៥ ដែលមនុស្សឈ្លាសវៃបានផ្សំ ហើយគេវាយឲ្យល្មមពីរោះល្អ ទើបដេញប្រគំ មានសំឡេងពីរោះ គួរត្រេកអរ គួរផ្ទៀងក្រចៀកស្តាប់ គួរជក់ចិត្ត មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ ជួរត្នោតទាំងនោះឯង កាលបើមានខ្យល់បក់មកត្រូវ ក៏មានសំឡេងពីរោះ គួរត្រេកអរ គួរផ្ទៀងក្រចៀកស្តាប់ គួរជក់ចិត្តយ៉ាងនោះដែរ ។ ម្នាលអានន្ទ ក្នុងសម័យនោះឯង ក្រុងកុសាវតីរាជធានី មានអ្នកលេងល្បែងភ្នាល់ និងអ្នកលេងស៊ីផឹក ឯពួកអ្នកលេងទាំងនោះ នាំគ្នារាំរែកតាមសំឡេងនៃជួរដើមត្នោតដែលមានខ្យល់បក់មកត្រូវទាំងនោះ ។

និដ្ឋិតេ ខោ បនានន្ទ ធម្មេ បាសាទេ និដ្ឋិតាយ ច ធម្មាយ បោក្ខរណិយា(១) រាជា មហាសុទស្សនោ យេ ខោ បនានន្ទ តេន(២) សមយេន សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា តេ សព្វកាមេហិ សន្តប្បេត្វា ធម្មំ បាសាទំ អភិរុហីតិ(៣) ។

បឋមភាណវារោ ។

[១៧] អថ ខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ កិស្ស នុ ខោ មេ ឥទំ កម្មស្ស ផលំ កិស្ស កម្មស្ស វិបាកោ យេនាហំ ឯតរហិ ឯវំមហិទ្ធិកោ ឯវំមហានុភាវោតិ ។ អថ ខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ តិណ្ណំ ខោ មេ ឥទំ កម្មានំ ផលំ តិណ្ណំ កម្មានំ វិបាកោ យេនាហំ ឯតរហិ ឯវំមហិទ្ធិកោ ឯវំមហានុភាវោ សេយ្យថីទំ ទានស្ស

១ ម. ធម្មេ ច បាសាទេ ធម្មាយ ច បោក្ខរណិយា ។ ២ ម. យេ តេន ។ ៣ ម. អភិរូហិ ។



ម្នាលអានន្ទ លុះផលធម្មប្រាសាទ និងស្រះធម្មបោក្ខរណី សម្រេចហើយ ព្រះបាទមហាសុទស្សនៈ ទ្រង់និមន្តពួកសមណព្រាហ្មណ៍ ដែលសន្មតថាជាសមណៈ ជាព្រាហ្មណ៍ ក្នុងសម័យនោះឯង ឲ្យឆ្អែតស្កប់ស្កល់ដោយពេញចំណង់ ហើយស្ដេចឡើងកាន់ធម្មប្រាសាទ ។

ចប់បឋមភាណវារៈ ។

[១៧] ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានសេចក្ដីត្រិះរិះយ៉ាងនេះថា នេះជាផលនៃកម្មរបស់អាត្មាអញ ដូចម្ដេចហ្ន៎ ជាវិបាកនៃកម្មរបស់អាត្មាអញ ដូចម្ដេចហ្ន៎ បានជាឥឡូវនេះ អាត្មាអញ មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានបរិវិតក្ក យ៉ាងនេះថា នេះ ជាផលនៃកម្ម ៣ យ៉ាង ជាវិបាកនៃកម្ម ៣ យ៉ាង របស់អាត្មាអញ បានជាឥឡូវនេះ អាត្មាអញមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ កម្ម ៣ យ៉ាងនោះ គឺ ទានៈ (ការឲ្យ)១

ទមស្ស សញ្ញមស្សាតិ[១] ។ អថខោ អានន្ទ រាជា មហាសុទស្សនោ យេន មហាវិយូហំ កូដាគារំ តេនុបសង្កមិ ឧបសង្កមិត្វា មហាវិយូហស្ស កូដាគារស្ស ទ្វារេ ឋិតោ ឧទានំ ឧទានេសិ តិដ្ឋ កាមវិតក្ក តិដ្ឋ ព្យាបាទវិតក្ក តិដ្ឋ វិហឹសាវិតក្ក ឯត្តាវតា កាមវិតក្ក ឯត្តាវតា ព្យាបាទវិតក្ក ឯត្តាវតា វិហឹសាវិតក្កាតិ ។ អថខោ អានន្ទ រាជា មហាសុទស្សនោ មហាវិយូហំ កូដាគារំ បវិសិត្វា សោវណ្ណមយេ បល្លង្កេ និសិន្នោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហាសិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហាសិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហាសិ សតោ ច សម្បជានោ

១ ឱ. ម. សំយមស្សាតិ ។





ទមៈ (ការទូន្មានខ្លួន) ១ សញ្ញមៈ (ការសង្រួមក្នុងសីល) ១ ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចចូលទៅកាន់កូដាគារហ្លួង (ផ្ទះមានកំពូល) ប្រាក់ លុះស្តេចទៅដល់ហើយ ទ្រង់ប្រថាប់ទៀបទ្វារ នៃកូដាគារហ្លួងប្រាក់ ទ្រង់បន្លឺឧទានថា នែកាមវិតក្កៈ ព្យាបាទវិតក្កៈ និងវិហឹសាវិតក្កៈ អ្នកចូរឈប់ចុះ នែកាមវិតក្កៈ ព្យាបាទវិតក្កៈ និងវិហឹសាវិតក្កៈ ប៉ុណ្ណឹងហើយ ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចចូលទៅកាន់កូដាគារហ្លួងប្រាក់ ទ្រង់គង់លើបល្ល័ង្កមាស លុះស្ងប់ស្ងាត់ ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ ចាកអកុសលធម៌ទាំងឡាយហើយ ទ្រង់ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីវិវេក លុះទ្រង់រម្ងាប់វិតក្កវិចារៈហើយ ទ្រង់ចូលកាន់ ទុតិយជ្ឈាន ជាធម្មជាតជាគ្រឿងផូរផង់ក្នុងខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈឡើយ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ព្រោះប្រាសចាកបីតិផង មានឧបេក្ខា មានស្មារតីសម្បជញ្ញៈផង

សុខញ្ច កាយេន បដិសំវេទេសិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហាសិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហាសិ ។

(១៨) អថខោ អានន្ទ រាជា មហាសុទស្សនោ មហាវិយូហា កូដាគារា និក្ខមិត្វា សោវណ្ណមយំ កូដាគារំ បវិសិត្វា រូបិយមយេ បល្លង្កេ និសិន្នោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហាសិ ។ ករុណាសហគតេន ចេតសា ។ មុទិតាសហគតេន ចេតសា ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហាសិ



ទទួលសេចក្តីសុខ ដោយនាមកាយផង ទើបទ្រង់ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ ពោលទុកថា បុគ្គលអ្នកមានឧបេក្ខា មានសតិ មានប្រក្រតីនៅជាសុខ ទ្រង់ចូលកាន់ចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានតែឧបេក្ខា និងសតិដ៏បរិសុទ្ធ ព្រោះកិរិយាលះបង់ នូវទុក្ខ និងសុខ ព្រោះកិរិយាវិនាសទៅ នៃសោមនស្ស និងទោមនស្ស ក្នុងកាលមុន ។

(១៨) ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ស្តេចចេញពីកូដាគារដ្ឋានប្រាក់ ហើយស្តេចចូលទៅ កាន់កូដាគារដ្ឋានមាស ទ្រង់គង់លើបល្ល័ង្កប្រាក់ មានព្រះហឫទ័យ ប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ។ ទ្រង់មានព្រះហឫទ័យ ប្រកបដោយមេត្តាដ៏ទូលាយ ជាមហគ្គតៈ គឺរូបាវចរៈ និងអរូបាវចរៈ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វទាំងអស់ ដោយយកខ្លួនឯង ប្រៀបនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង គឺ ទិសខាងលើ ទិសខាងក្រោម ទទឹងទិសធំ គឺទិសតូច ៗ ដោយប្រការដូច្នេះ ។ ទ្រង់មានព្រះហឫទ័យ ប្រកបដោយករុណា ។ ទ្រង់មានព្រះហឫទ័យ ប្រកបដោយមុទិតា ។ ទ្រង់មានព្រះហឫទ័យ ប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ទី ១

តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ។ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហាសិ ។

(១៨) រញ្ញោ អានន្ទ មហាសុទស្សនស្ស ចតុរាសីតិនគរសហស្សានិ អហេសុំ កុសាវតីរាជធានីបមុខានិ ចតុរាសីតិបាសាទសហស្សានិ អហេសុំ ធម្មបាសាទប្បមុខានិ ចតុរាសីតិកូដាគារសហស្សានិ អហេសុំ មហាព្យូហកូដាគារប្បមុខានិ ចតុរាសីតិបល្លង្កសហស្សានិ អហេសុំ សោវណ្ណមយានិ រូបិយមយានិ ទន្តមយានិ មសារគល្លមយានិ គោណកត្ថតានិ បដិកត្ថតានិ បដលិកត្ថតានិ កទលិមិគបវរប្បច្ចត្ថរណានិ សឧត្តរច្ឆទានិ(១) ឧភតោលោហិតកូបធានានិ ចតុរាសីតិនាគសហស្សានិ អហេសុំ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ ឧបោសថនាគរាជប្បមុខានិ

១ ម. កទលិមិគបច្ចត្ថរណានិ សឧត្តរច្ឆទានិ ។





ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូច ១ គ្នា ។ ព្រះអង្គមានព្រះហឫទ័យ ប្រកបដោយឧបេក្ខា ជាធម្មជាតិដ៏ទូលាយ ដល់មហគ្គតៈ មានប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វទាំងអស់ ដោយយកខ្លួនឯង ប្រៀបនឹងសត្វទាំងអស់ ក្នុងទិសទាំងពួង គឺ ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺ ទិសតូច ១ ដោយប្រការដូច្នេះ ។

(១៨) ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់មាននគរ ៨៤.០០០ មានកុសាវតីរាជធានីជាប្រធាន ទ្រង់មានប្រាសាទ ៨៤.០០០ មានធម្មប្រាសាទជាប្រធាន ទ្រង់មានប្រាសាទកំពូល ៨៤.០០០ មានកូដាគារព្យូហប្រាសាទជាប្រធាន ទ្រង់មានបល្ល័ង្ក ៨៤.០០០ សុទ្ធសឹងជាមាសប្រាក់ ភ្លុក ខ្លឹមខ្លឹម ដែលក្រាលដោយសំពត់ធ្វើពីរោមសត្វ មានរូបសត្វសាហាវ ក្រាលដោយសំពត់ធ្វើពីរោមសត្វមានពណ៌ស ក្រាលដោយសំពត់ ធ្វើពីរោមសត្វមានផ្កាចង្ក្រាម ក្រាលដោយកម្រាលស្បែកម្រឹគយ៉ាងល្អ មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងមានពិតានក៏ពណ៌ក្រហមទាំងសងខាង ទ្រង់មានដំរី ៨៤.០០០ មានដំរីឈ្មោះឧបោសថនាគរាជជាប្រធាន សុទ្ធតែគ្រឿងអលង្ការមាស មានទង់មាស

ចតុរាសីតិអស្សសហស្សានិ អហេសុំ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វលាហកអស្សរាជប្បមុខានិ ចតុរាសីតិរថសហស្សានិ អហេសុំ សីហចម្មបរិវារានិ ព្យគ្ឃចម្មបរិវារានិ ទីបិចម្មបរិវារានិ បណ្ឌុកម្ពលបរិវារានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វេជយន្តរថប្បមុខានិ ចតុរាសីតិមណិសហស្សានិ អហេសុំ មណិរតនប្បមុខានិ ចតុរាសីតិឥត្ថីសហស្សានិ អហេសុំ សុភទ្ទាទេវីប្បមុខានិ ចតុរាសីតិគហបតិសហស្សានិ អហេសុំ គហបតិរតនប្បមុខានិ ចតុរាសីតិខត្តិយសហស្សានិ អហេសុំ អនុយន្តានិ(១) បរិណាយករតនប្បមុខានិ ចតុរាសីតិធេនុសហស្សានិ អហេសុំ ទុហសន្ទនានិ កំសុបធារណានិ(២) ចតុរាសីតិវត្ថកោដិសហស្សានិ អហេសុំ ខោមសុខុមានំ កប្បាសិកសុខុមានំ កោសេយ្យសុខុមានំ កម្ពលសុខុមានំ ។

១ ម. អនុយុត្តានិ ។ ២ ម. ទុកូលសន្ទនានិ កំសុបធារណានិ ។



បិទបាំងដោយបណ្តាញមាស ទ្រង់មានសេះ ៨៤.០០០ មានសេះឈ្មោះវលាហកអស្សរាជជាប្រធាន សឹងមានគ្រឿងអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស ទ្រង់មានរថ ៨៤.០០០ មានវេជយន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស ទ្រង់មានកែវមណី ៨៤.០០០ មានមណីរតនៈជាប្រធាន ទ្រង់មានស្ត្រី ៨៤.០០០ មាននាងសុភទ្ទាទេវីជាប្រធាន ទ្រង់មានគហបតី ៨៤.០០០ មានគហបតិរតនៈជាប្រធាន ទ្រង់មានក្សត្រិយ៍ ៨៤.០០០ ជាអ្នកចុះចូល មានបរិណាយករតនៈជាប្រធាន ទ្រង់មានមេគោ ៨៤.០០០ សម្រាប់រឹតបន្ទឹ (យកទឹកដោះ) មានភាជន៍សំរិទ្ធិសម្រាប់ត្រង ទ្រង់មានសំពត់ ៨៤.០០០ កោដិ ស្លូតៗជាសំពត់ ដែលត្បាញដោយសម្បកឈើ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាសមានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រមានសាច់ដ៏ល្អិត សំពត់កម្ពលគឺសំពត់ត្បាញដោយរោមសត្វមានសាច់ដ៏ល្អិត ។

រញ្ញោ អានន្ទ មហាសុទស្សនស្ស ចតុរាសីតិថាលិ-បាកសហស្សានិ(១) អហេសុំ សាយំ បាតំ ភត្តាភិ-ហារោ អភិហរិយិត្ថ ។

(២០) តេន ខោ បនានន្ទ សមយេន រញ្ញោ ម-ហាសុទស្សនស្ស ចតុរាសីតិនាគសហស្សានិ សាយំ បាតំ ឧបដ្ឋានំ អាគច្ឆន្តិ ។ អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស ឯតទហោសិ ឥមានិ ខោ មេ ចតុរាសីតិនាគសហស្សានិ សាយំ បាតំ ឧបដ្ឋានំ អាគច្ឆន្តិ យន្នូន វស្សសតស្ស វស្សសតស្ស អច្ចយេន ទ្វេចត្តាឡីសំ ទ្វេចត្តាឡីសំ នាគសហស្សានិ សកឹ សកឹ ឧបដ្ឋានំ អាគច្ឆេយ្យុន្តិ ។ អថខោ អានន្ទ រាជា មហាសុទស្សនោ បរិណាយករតនំ អាមន្តេសិ ឥមានិ ខោ មេ សម្ម បរិណាយករតន ចតុរាសីតិនា-គសហស្សានិ សាយំ បាតំ ឧបដ្ឋានំ អាគច្ឆន្តិ តេនហិ សម្ម បរិណាយករតន វស្សសតស្ស វស្សសតស្ស អច្ច-យេន ទ្វេចត្តាឡីសំ ទ្វេចត្តាឡីសំ នាគសហស្សានិ

១ ឱ. រញ្ញោ អានន្ទ មហាសុទស្សនស្ស ចតុរាសីតិ ថាលិ ន ទិស្សន្តិ ។





ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់មានភាជន៍ ក្រយាស្ងោយ ៨៤.០០០ ដែលគួរពិសេស នាំយកមកថ្វាយ ទាំងល្ងាចទាំងព្រឹក ។

(២០) ម្នាលអានន្ទ សម័យនោះឯង ដំរី ៨៤.០០០ តែងនាំគ្នាទៅគាល់បម្រើព្រះបាទមហាសុទស្សនៈ ទាំងល្ងាចទាំងព្រឹក ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា ដំរីទាំង ៨៤.០០០ នេះឯង តែងនាំគ្នាមកគាល់បម្រើអញ ទាំងល្ងាចទាំងព្រឹក បើដូច្នោះ លុះកាលកន្លងទៅបាន ១០០ ឆ្នាំ ៗ សឹមឲ្យដំរី ៤២.០០០ ៗ មកគាល់បម្រើ (សព្វគ្នា) ម្តង ៗ ។ ម្នាលអានន្ទ លំដាប់នោះឯង ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់ហៅបរិណាយករត្នមកថា ម្នាលបរិណាយក-រត្ន សំឡាញ់ ដំរី ៨៤.០០០ នេះឯង តែងនាំគ្នាមកគាល់បម្រើយើង ទាំងល្ងាចទាំងព្រឹក ម្នាលបរិណាយករត្ន សំឡាញ់ បើដូច្នោះ លុះកាលកន្លងទៅបាន ១០០ ឆ្នាំ ៗ សឹមឲ្យដំរី ៤២.០០០ ៗ មកគាល់បម្រើ

សកឹំ សកឹំ ឧបដ្ឋានំ អាគច្ឆន្តូតិ ។ ឯវំ ទេវាតិ អានន្ទ(១) បរិណាយករតនំ រញ្ញោ មហាសុទស្សនស្ស បច្ចស្សោសិ ។ អថខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស អបរេន សមយេន វស្សសតស្ស វស្សសតស្ស អច្ចយេន ទ្វេចត្តាឡីសំ ទ្វេចត្តាឡីសំ នាគសហស្សានិ សកឹំ សកឹំ ឧបដ្ឋានំ អាគមិំសុ ។ អថខោ អានន្ទ សុភទ្ទាយ ទេវិយា ពហុន្នំ វស្សានំ ពហុន្នំ វស្សសតានំ ពហុន្នំ វស្សសហស្សានំ(២) អច្ចយេន ឯតទហោសិ ចិរំ ទិដ្ឋោ ខោ មេ រាជា មហាសុទស្សនោ យន្នូនាហំ រាជានំ មហាសុទស្សនំ ទស្សនាយ ឧបសង្កមេយ្យន្តិ ។ អថខោ អានន្ទ សុភទ្ទា ទេវី ឥត្ថាគារំ អាមន្តេសិ ឯថ តុម្ហេ សីសន្ហាយថ បីតានិ វត្ថានិ បារុបថ ចិរំ ទិដ្ឋោ នោ រាជា មហាសុទស្សនោ រាជានំ មហាសុទស្សនំ ទស្សនាយ ឧបសង្កមេយ្យាមាតិ(៣) ។ ឯវំ អយ្យេតិ ខោ អានន្ទ ឥត្ថាគារំ សុភទ្ទាយ ទេវិយា បដិស្សុណិត្វា សីសន្ហាយិត្វា បីតានិ វត្ថានិ បារុបិត្វា

១ ឱ. ម. ឯវំ ទេវាតិ ខោ អានន្ទ ។ ២ ឱ. វស្សសតសហស្សានំ ។ ៣ ឱ. ម. ឧបសង្កមិស្សាមាតិ ។



បម្រើយើងម្ដង ៗ ចុះ ។ ម្នាលអានន្ទ បរិណាយករត្ន ក៏ទទួលព្រះរាជឱង្ការ នៃព្រះបាទមហាសុទស្សនៈថា ព្រះករុណាថ្លៃវិសេស ។ ម្នាលអានន្ទ សម័យខាងក្រោយមក លុះកាលកន្លងទៅ ១០០ ឆ្នាំ ៗ ដំរី ៤២.០០០ ក៏នាំគ្នាមកគាល់បម្រើ ព្រះបាទមហាសុទស្សនៈម្ដង ៗ ។ ម្នាលអានន្ទ លុះកាលកន្លងទៅច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ព្រះនាងសុភទ្ទាទេវី ទ្រង់មានសេចក្ដីត្រិះរិះដូច្នេះថា អាត្មាអញបានឃើញព្រះបាទមហាសុទស្សនៈ អស់កាលយូរមកហើយ បើដូច្នោះ គួរតែអាត្មាអញចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ទ្រង់ត្រាស់ហៅ (ពួក) ស្រីស្នំថា នាងទាំងឡាយ ចូរមក ចូរកក់ក្បាល ចូរស្លៀកសំពត់ពណ៌លឿង យើងមិនបានឃើញព្រះបាទមហាសុទស្សនៈ អស់កាលយូរមកហើយ យើងគួរនឹងចូលទៅគាល់ព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ ពួកស្រីស្នំក៏បានទទួលព្រះរាជសាវនីយ៍នៃព្រះនាងសុភទ្ទាទេវីថា ព្រះនាងម្ចាស់ យ៉ាងនេះមែនហើយ ដូច្នេះហើយក៏កក់ក្បាល ស្លៀកសំពត់ពណ៌លឿង ហើយចូលទៅត្រង់ទី

យេន សុភទ្ទា ទេវី តេនុបសង្កមិ ។ អថខោ អានន្ទ សុភទ្ទា ទេវី បរិណាយករតនំ អាមន្តេសិ តេនហិ សម្ម បរិណាយករតន ចតុរង្គិនឹ សេនំ ចិរំ ទិដ្ឋោ នោ រាជា មហាសុទស្សនោ រាជានំ មហាសុទស្សនំ ទស្ស-នាយ ឧបសង្កមេយ្យាមាតិ ។ ឯវំ ទេវីតិ ខោ អានន្ទ បរិណាយករតនំ សុភទ្ទាយ ទេវិយា បដិស្សុណិត្វា ចតុរង្គិនឹ សេនំ កប្បាបេត្វា សុភទ្ទាយ ទេវិយា បដិ-វេទេសិ កប្បិតា ខោ តេ ទេវិ ចតុរង្គិនី សេនា យស្ស-ទានិ កាលំ មញ្ញសីតិ ។ អថខោ អានន្ទ សុភទ្ទា ទេវី ចតុរង្គិនិយា សេនាយ សទ្ធឹ ឥត្ថាគារេន យេន ធម្មោ បាសាទោ តេនុបសង្កមិ ឧបសង្កមិត្វា ធម្មំ បាសាទំ អភិរុហិត្វា យេន មហាវិយូហំ កូដាគារំ តេនុបសង្កមិ ឧបសង្កមិត្វា មហាវិយូហស្ស កូដាគា-រស្ស ទ្វារពាហំ អាលម្ពិត្វា អដ្ឋាសិ ។ អថខោ អានន្ទ





ដែលព្រះនាងសុភទ្ទាទេវីគង់នៅ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ទ្រង់ត្រាស់ហៅបរិណាយករតនមកថា ម្នាលបរិណាយករតនសំឡាញ់ អ្នកចូរទៅរៀបចំចតុរង្គិនីសេនា (ទ័ពយើង) ព្រោះយើងខានជួបព្រះបាទមហាសុទស្សនៈ អស់កាលយូរហើយ យើងនឹងចូលទៅគាល់ដើម្បីនឹងឲ្យបានជួបព្រះបាទមហាសុទស្សនៈ ។ ម្នាលអានន្ទ បរិណា-យករតន ទទួលព្រះរាជសវនីយ៍របស់ព្រះនាងសុភទ្ទាទេវីថា បពិត្រព្រះរាជទេវី យ៉ាងនេះហើយ ក៏រៀបចំចតុរង្គិនីសេនា ហើយក្រាបទូលព្រះនាងសុភទ្ទាទេវីថា បពិត្រព្រះទេវី ចតុរង្គិនីសេនា របស់ព្រះនាង ខ្ញុំព្រះអង្គរៀបចំស្រេចហើយ ឥឡូវនេះ សូមព្រះនាងសម្គាល់នូវកាលដែលគួរនឹងស្ដេចចុះ ។ ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី មួយអន្លើដោយចតុរង្គិនីសេនានិង (ពួក) ស្រីស្នំ ស្ដេចសំដៅទៅរកធម្មប្រាសាទ លុះស្ដេចចូលទៅដល់ហើយ ក៏ឡើងទៅកាន់ធម្មប្រាសាទ ហើយស្ដេចចូលសំដៅទៅរកកូដាគារស្លុនប្រាក់ លុះចូលទៅដល់ហើយ ក៏ទ្រង់ព្រះសណ្ឋិតកៀនទ្វារ នៃកូដាគារស្លុនប្រាក់ ។ ម្នាលអានន្ទ លំដាប់នោះ

រាជា មហាសុទស្សនោ សទ្ទំ សុត្វា(១) កិំ នុ ខោ សោ(២) មហតោ វិយ ជនកាយស្ស សទ្ទោតិ មហា-វិយូហា កូដាគារា និក្ខមន្តោ អទ្ទស សុភទ្ទំ ទេវិំ ទ្វារពាហំ អាលម្ពិត្វា ឋិតំ ទិស្វា សុភទ្ទំ ទេវិំ ឯតទវោច ឯត្ថេវ ទេវិ តិដ្ឋ មា បាវិសីតិ ។ អថខោ អានន្ទ រាជា មហាសុទស្សនោ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស មហាវិយូហា កូដាគារា សោ-វណ្ណមយំ បល្លង្កំ នីហរិត្វា សព្វសោវណ្ណមយេ តាល-វនេ បញ្ញាបេហីតិ ។ ឯវំ ទេវាតិ ខោ អានន្ទ សោ បុរិសោ រញ្ញោ មហាសុទស្សនស្ស បដិស្សុត្វា មហា-វិយូហា កូដាគារា សោវណ្ណមយំ បល្លង្កំ នីហរិត្វា សព្វសោវណ្ណមយេ តាលវនេ បញ្ញាបេសិ ។ អថខោ អានន្ទ រាជា មហាសុទស្សនោ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេសិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ។

១ ម. សទ្ទំ សុត្វាតិ ន ទិស្សតិ ។ ២ ម. សោតិ នត្ថិ ។



ព្រះបាទមហាសុទស្សនៈ ទ្រង់ឮសូរស័ព្ទនោះហើយ ទើបទ្រង់ត្រាស់ថា សំឡេងនោះ ដូចជាសំឡេងពួកជនច្រើននាក់អ្វីហ្ន៎ ហើយទ្រង់ស្តេចចេញពីក្នុងការារដ្ឋខប្រាក់ ទ្រង់ទតទៅឃើញព្រះនាងសុភទ្ទាទេវី កំពុងតែទ្រង់ព្រះសណ្ឋិតតោងបង្ខារ លុះទតឃើញហើយ ទ្រង់មានព្រះរាជឱង្ការនឹងព្រះនាងសុភទ្ទាទេវីថា នែនាងទេវី ចូរនាងចង្អង់នៅទីនុះសិន នាងកុំអាលចូលមក ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់ត្រាស់ហៅបុរសម្នាក់មកថា ម្នាលបុរស អ្នកចូរមកនេះ ចូរទៅនាំយកបល្ល័ង្កមាស អំពីក្នុងការារដ្ឋខប្រាក់ ទៅតាំងក្នុងព្រៃតាលវ័ន (ព្រៃត្នោត) សុទ្ធតែមាស ។ ម្នាលអានន្ទ បុរសនោះ ក៏ទទួលព្រះរាជឱង្ការនៃព្រះបាទមហាសុទស្សនៈថា ព្រះករុណាថ្លៃវិសេស ដូច្នេះហើយ ក៏នាំយកបល្ល័ង្កមាស ចេញពីក្នុងការារដ្ឋខប្រាក់ ទៅតាំងក្នុងព្រៃតាលវ័ន សុទ្ធតែមាស ។ ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមហាសុទស្សនៈ ទ្រង់សម្រេចសីហ-សេយ្យា ដោយខាងស្តាំ ទ្រង់តម្រួតព្រះបាទលើគ្នា ទ្រង់មានព្រះសតិសម្បជញ្ញៈ ។

[២១] អថខោ អានន្ទ សុភទ្ទាយ ទេវិយា ឯតទ-ហោសិ វិប្បសន្នានិ ខោ រញ្ញោ មហាសុទស្សនស្ស ឥន្ទ្រិយានិ បរិសុទ្ធោ(១) ឆវិវណ្ណោ បរិយោទាតោ មា ហេវ ខោ រាជា មហាសុទស្សនោ កាលមកាសីតិ ។ រាជានំ មហាសុទស្សនំ ឯតទវោច ឥមានិ តេ(២) ទេវ ចតុរាសីតិនគរសហស្សានិ កុសាវតីរាជធានីបមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិបាសាទសហស្សានិ ធម្មបាសាទប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិកូដាគារស-ហស្សានិ មហាវ្យូហកូដាគារប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុ-រាសីតិបល្លង្កសហស្សានិ សោវណ្ណមយានិ រូបិយមយា-និ ទន្តមយានិ មសារគល្លមយានិ(៣) គោណកត្ថតានិ

១ ម. បរិសុទ្ធា ។ ២ ម. ឥមានិតេ ។ ៣ ម.សារមយានិ ។



(២១) ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា ឥន្ទ្រិយរបស់ព្រះបាទមហាសុទស្សនៈ ថ្លាស្អាតណាស់តើ ព្រះឆវីវណ្ណផូរផង់ សូមព្រះបាទមហាសុទស្សនៈ កុំទិវង្គតឡើយ ។ ទើបព្រះនាងសុភទ្ទាទេវី ក្រាបបង្គំទូលសេចក្តីនុ៎ះ នឹងព្រះបាទមហាសុទស្សនៈថា បពិត្រព្រះសម្មតិទេព នគរទាំង ៨៤.០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានី ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះនគរទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ប្រាសាទ ៨៤.០០០ របស់ព្រះអង្គនេះ មានធម្មប្រាសាទជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះប្រាសាទទាំងនោះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព កូដាគារប្រាសាទ ៨៤.០០០ របស់ព្រះអង្គ មានប្រាសាទឈ្មោះកូដាគារផ្លូនក្រោកជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះកូដាគារផ្លូនក្រោកទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព បល្ល័ង្ក ៨៤.០០០ របស់ព្រះអង្គនេះ ជាបល្ល័ង្កមាស ប្រាក់ ភ្លុក កែវមរកត ដែលក្រាល

បដិកត្ថតានិ(១) បដលិកត្ថតានិ កទលិមិគបវរបច្ចត្ថរណានិ សឧត្តរច្ឆទានិ(២) ឧភតោលោហិតកូបធានានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិ នាគសហស្សានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ ឧបោសថនាគរាជប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិ អស្សសហស្សានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វលាហកអស្សរាជប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ

១ ម. បដិកត្ថកានីតិ ទិស្សតិ ។ ២ ម. កទលិមិគបច្ចត្ថរណានិ សឧត្តរច្ឆទានិ ។



ដោយសំពត់ធ្វើដោយរោមសត្វ មានរូបសត្វសាហាវ ក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានពណ៌ស ក្រាលដោយសំពត់ ធ្វើដោយរោមសត្វ មានផ្កាចង្កោម ក្រាលដោយកម្រាលស្បែកប្រើសយ៉ាងល្អ មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងមានពិតាន ក៏ពណ៌ក្រហមដូចគ្នា បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះបល្ល័ង្កទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ដំរី ៨៤.០០០ របស់ព្រះអង្គនេះ មានដំរីឈ្មោះឧបោសថនាគរាជ ជាប្រធាន សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះដំរីទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព សេះ ៨៤.០០០ របស់ព្រះអង្គនេះ មានសេះឈ្មោះវលាហកអស្សរាជ ជាប្រធាន សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះសេះទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត

ឥមានិ តេ ទេវ ចតុរាសីតិរថសហស្សានិ សីហចម្មបរិវារានិ ព្យគ្ឃចម្មបរិវារានិ ទីបិចម្មបរិវារានិ បណ្ឌុកម្ពលបរិវារានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វេជយន្តរថប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិមណិសហស្សានិ មណិរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិឥត្ថីសហស្សានិ ឥត្ថីរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិគហបតិសហស្សានិ គហបតិរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិខត្តិយសហស្សានិ អនុយន្តានិ បរិណាយករតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ



បពិត្រព្រះសម្មតិទេព រថ ៨៤.០០០ របស់ព្រះអង្គនេះ មានវេជយន្តរថជាប្រធាន ដែលពាសដោយស្បែកសីហៈ ស្បែកខ្លាធំ ស្បែកខ្លាដំបង ពាសដោយសំពត់កម្ពល មានពណ៌លឿង មានអលង្ការមាស មានទង់មាស ហ៊ុមបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះរថទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព កែវមណី ៨៤.០០០ របស់ព្រះអង្គទាំងនេះ មានមណិរ័តន៍ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះមណិរ័តន៍ទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ស្ត្រី ៨៤.០០០ របស់ព្រះអង្គនេះ មានឥត្ថីរ័តន៍ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ ចំពោះស្ត្រីទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព គហបតី ៨៤.០០០ របស់ព្រះអង្គនេះ មានគហបតិរ័តន៍ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះគហបតីទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព ពួកក្សត្រិយ៍ ៨៤.០០០នេះ សុទ្ធតែជាអ្នកចុះចូលព្រះអង្គ មានបរិណាយករ័តន៍ជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្តីស្រឡាញ់ ចំពោះពួក

អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិធេនុស-
ហស្សានិ ទុកូលសន្ទានានិ កំសុបធារណានិ ឯត្ថ ទេវ
ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ
ចតុរាសីតិវត្ថកោដិសហស្សានិ ខោមសុខុមានំ កប្បា-
សិកសុខុមានំ កោសេយ្យសុខុមានំ កម្ពលសុខុមានំ
ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ
ឥមានិ តេ ទេវ ចតុរាសីតិថាលិបាកសហស្សានិ
សាយំ បាតំ ភត្តាភិហារោ អភិហរីយតិ ឯត្ថ ទេវ
ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហីតិ ។



ក្សត្រិយ៍ទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិត បពិត្រ
ព្រះសម្មតិទេព មេគោ ៨៤.០០០ សម្រាប់រីតបង្ហូរយកទឹកដោះ របស់
ព្រះអង្គនេះ មានកាដល់សំរឹទ្ធិ សម្រាប់ត្រង បពិត្រព្រះសម្មតិទេព សូម
ទ្រង់បង្កើតនូវសេចក្ដីស្រឡាញ់ ចំពោះមេគោទាំងនុ៎ះ សូមទ្រង់ធ្វើនូវ
សេចក្ដីអាល័យ ក្នុងព្រះជីវិត បពិត្រព្រះសម្មតិទេព សំពត់ ៨៤.០០០
កោដិ របស់ព្រះអង្គទាំងនេះ ជាសំពត់ដែលត្បាញ ដោយសំបកឈើ
មានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើ
ដោយសូត្រមានសាច់ដ៏ល្អិត សំពត់កម្ពលដ៏សិរក់ដែលត្បាញ ដោយរោម
សត្វ មានសាច់ដ៏ល្អិត បពិត្រព្រះសម្មតិទេព សូមទ្រង់បង្កើតនូវសេចក្ដី
ស្រឡាញ់ ចំពោះសំពត់ទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះ
ជីវិត បពិត្រព្រះសម្មតិទេព ភាជន៍ក្រយាស្ងោយ ៨៤.០០០ របស់ព្រះ
អង្គទាំងនេះ ដែលពួកពលសែងនាំយកមកថ្វាយ ទាំងល្ងាចទាំងព្រឹក បពិត្រ
ព្រះសម្មតិទេព សូមព្រះអង្គ បង្កើតនូវសេចក្ដីស្រឡាញ់ ចំពោះភាជន៍
ក្រយាស្ងោយទាំងនុ៎ះ សូមទ្រង់ធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិត ។

ឯវំ វុត្តេ អានន្ទ រាជា មហាសុទស្សនោ សុភទ្ទំ ទេវឹ ឯតទវោច ទីឃរត្តំ ខោ មំ ត្វំ ទេវិ ឥដ្ឋេហិ កន្តេហិ មនាបេហិ(១) សមុទាចរិត្ថ អថ ច បន មំ ត្វំ បច្ឆិមេ កាលេ អនិដ្ឋេហិ អកន្តេហិ អមនាបេហិ សមុទាចរសីតិ ។ កថញ្ចរហិ តំ ទេវ សមុទាចរាមីតិ ។ ឯវំ ខោ មំ ត្វំ ទេវិ សមុទាចរ សព្វេហេវ ទេវ បិយេហិ(២) មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ មា ខោ ត្វំ ទេវ សាបេក្ខោ កាលមកាសិ ទុក្ខា សាបេក្ខស្ស កាលកិរិយា គរហិតា ច សាបេក្ខស្ស កាលកិរិយា ឥមានិ តេ ទេវ ចតុរាសីតិនគរសហស្សានិ កុសាវតី-

---

១ ម. ឥដ្ឋេហិ បិយេហិ មនាបេហិ ។ ២ ឱ. សមុទាចរ សព្វេហេវ ទេវ បិយេហិ ។ ម. សមុទាចរសិ សព្វេហេវ ទេវ បិយេហិ ។





ម្នាលអានន្ទ កាលបើព្រះនាងសុភទ្ទាទេវី ក្រាបបង្គំទូល យ៉ាងនេះហើយ ព្រះរាជាមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការទៅនឹងព្រះនាងសុភទ្ទាទេវីថា ម្នាលនាងទេវី នាងថ្លែងរៀបរាប់ដោយវត្ថុតាំងឡាយ ជាទីស្រឡាញ់ ជាទីត្រេកអរ ជាទីពេញចិត្ត ចំពោះយើងអស់កាលយូរហើយ តទៅខាងក្រោយ នាងនឹងថ្លែងរៀបរាប់ ដោយវត្ថុតាំងឡាយ មិនជាទីស្រឡាញ់ មិនជាទីត្រេកអរ មិនជាទីពេញចិត្តចំពោះយើងវិញ ។ ព្រះនាងសុភទ្ទាទេវី ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ចុះខ្ញុំម្ចាស់រៀបរាប់ចំពោះព្រះអង្គដោយប្រការដូចម្ដេចវិញ ។ ព្រះរាជាមហាសុទស្សនៈទ្រង់ត្រាស់ថា ម្នាលនាងទេវី ចូរនាងថ្លែងរៀបរាប់នឹងយើង យ៉ាងនេះវិញថា សេចក្ដីរាស សេចក្ដីព្រាត់ប្រាស និងសេចក្ដីឃ្លៀងឃ្លាតចាកសត្វនិងសង្ខារទាំងពួង ដែលជាទីស្រឡាញ់ ជាទីពេញចិត្ត (រមែងមានដល់ព្រះអង្គ) បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំទិវង្គត ប្រកបដោយសេចក្ដីអាល័យឡើយ (ព្រោះថា) កាលកិរិយារបស់បុគ្គល ដែលមានសេចក្ដីអាល័យ តែងនាំមកនូវសេចក្ដីទុក្ខ មួយទៀត កាលកិរិយារបស់បុគ្គល ដែលមានសេចក្ដីអាល័យ អ្នកប្រាជ្ញតែងតិះដៀល បពិត្រព្រះសម្មតិទេព នគរ ៨៤.០០០ របស់ព្រះអង្គទាំងនេះ មាននគរកុសាវតី-

រាជធានីបមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ។ ឥមានិ តេ ទេវ ចតុរាសីតិបាសាទសហស្សានិ ។បេ។ មា អកាសិ ។ ឥមានិ តេ ទេវ ចតុរាសីតិកូដាគារសហស្សានិ ។បេ។ មា អកាសិ ។ ឥមានិ តេ ទេវ ចតុរាសីតិបល្លង្កសហស្សានិ សោវណ្ណមយានិ រូបិយមយានិ ទន្តមយានិ មសារគល្លមយានិ គោណកត្ថតានិ បដិកត្ថតានិ បដលិកត្ថតានិ កាទលិមិគបវរបច្ចត្ថរណានិ សឧត្តរច្ឆទានិ ឧភតោលោហិតកូបធានានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ



រាជធានី ជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ ចំពោះនគរទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ប្រាសាទ ៨៤.០០០ របស់ព្រះអង្គទាំងនេះ ។បេ។ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កូដាគារផ្ទះ ៨៤.០០០ របស់ព្រះអង្គនេះ ។បេ។ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព បល្ល័ង្ក ៨៤.០០០ របស់ព្រះអង្គនេះ សុទ្ធសឹងតែមាស ប្រាក់ ភ្លុក កែវមរកត ក្រាលដោយសំពត់ ធ្វើដោយរោមសត្វសកវែង ក្រាលដោយសំពត់ធ្វើដោយរោមសត្វមានពណ៌ស ក្រាលដោយសំពត់ធ្វើដោយរោមសត្វមានផ្កាដេរក្រាស់ ក្រាលដោយកម្រាលដ៏ល្អ ដែលធ្វើដោយស្បែកប្រើសមាន ខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងពិតាន ពណ៌ក្រហមទាំងសងខាង បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ ចំពោះបល្ល័ង្កទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ

ឥមានិ តេ ទេវ ចតុរាសីតិ នាគសហស្សានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ ឧបោសថនាគរាជប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិ អស្សសហស្សានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វលាហកអស្សរាជប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិ រថសហស្សានិ សីហចម្មបរិវារានិ ព្យគ្ឃចម្មបរិវារានិ ទីបិចម្មបរិវារានិ បណ្ឌុកម្ពលបរិវារានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វេជយន្តរថប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ



បពិត្រព្រះសម្មតិទេព ដំរី ៨៤.០០០ របស់ព្រះអង្គនេះ មានដំរីឈ្មោះឧបោសថនាគរាជ ជាប្រធាន សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្ដាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ក្នុងដំរីទាំងនុ៎ះចេញ សូមទ្រង់ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សេះ ៨៤.០០០ របស់ព្រះអង្គនេះ មានសេះ ឈ្មោះវលាហកអស្សរាជ ជាប្រធាន សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំង ដោយបណ្ដាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះសេះទាំងនុ៎ះចេញ សូមទ្រង់ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព រថ ៨៤.០០០ របស់ព្រះអង្គនេះ មានវេជយន្តរថ ជាប្រធាន ដែលរោលដោយស្បែកសីហៈ ដោយស្បែកខ្លាធំ ដោយស្បែកខ្លាដំបង ដោយសំពត់កម្ពល មានពណ៌លឿង សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំង ដោយបណ្ដាញមាស បពិត្រព្រះសម្មតិទេព សូមទ្រង់ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះរថទាំងនុ៎ះចេញ សូមទ្រង់ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ

ឥមានិ តេ ទេវ ចតុរាសីតិមណិសហស្សានិ មណិរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិឥត្ថីសហស្សានិ សុភទ្ទាទេវីបមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិគហបតិសហស្សានិ គហបតិរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិខត្តិយសហស្សានិ អនុយន្តានិ បរិណាយករតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ



បពិត្រព្រះសម្មតិទេព កែវមណី ៨៤.០០០ របស់ព្រះអង្គនេះ មានមណិរ័តន៍ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមទ្រង់លះបង់នូវសេចក្តីស្រឡាញ់ ចំពោះកែវមណីទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ស្ត្រី៨៤.០០០ របស់ព្រះអង្គនេះ មានព្រះនាងសុភទ្ទាទេវី ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះស្ត្រីទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព គហបតី ៨៤.០០០ របស់ព្រះអង្គនេះ មានគហបតិរ័តន៍ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះគហបតីទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកក្សត្រិយ៍ ៨៤.០០០ របស់ព្រះអង្គនេះ មានបរិណាយករ័តន៍ ជាប្រធាន ជាអ្នកចុះចូល បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះក្សត្រិយ៍ទាំងនុ៎ះចេញ

ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិ ធេនុសហស្សានិ ទុហសន្ធនានិ កំសុបធារណានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិវត្ថកោដិសហស្សានិ ខោមសុខុមានំ កប្បាសិកសុខុមានំ កោសេយ្យសុខុមានំ កម្ពលសុខុមានំ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិថាលិបាកសហស្សានិ សាយំ បាតំ ភត្តាភិហារោ អភិហរិយន្តិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសីតិ ។ អថ ខោ អានន្ទ សុភទ្ទា ទេវី បរោទិ អស្សូនិ បវត្តេសិ ។





សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព មេគោ ៨៤.០០០ របស់ព្រះអង្គនេះ សម្រាប់រឹតបន្ហូរ (យកទឹកដោះ) មានភាជន៍សំរឹទ្ធ សម្រាប់ត្រង បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះមេគោទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សំពត់ ៨៤.០០០ កោដិ របស់ព្រះអង្គនេះ គឺសំពត់ដែលត្បាញដោយសំបកឈើមានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់កម្ពលគឺសំពត់ ត្បាញដោយរោមសត្វ មានសាច់ដ៏ល្អិត បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះសំពត់ទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ភាជន៍ក្រយាស្ងោយ ៨៤.០០០ របស់ព្រះអង្គនេះ ដែលពួកពិសេស តែងនាំយកកត្តមកថ្វាយ ទាំងល្ងាច ទាំងព្រឹក បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះភាជន៍ ក្រយាស្ងោយ ទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ ។ ម្នាលអានន្ទ កាលបើព្រះបាទមហាសុទស្សនៈ ទ្រង់មានព្រះរាជឱង្ការបង្គាប់ឲ្យតាំងទៅ រៀបរាប់យ៉ាងនេះហើយ ព្រះនាងសុភទ្ទាទេវី ក៏ទ្រង់ព្រះកន្សែងសោយសោក ស្រក់ទឹកព្រះនេត្រ ។

អថខោ អានន្ទ សុភទ្ទា ទេវី អស្សូនិ បមជ្ជិត្វា រាជានំ មហាសុទស្សនំ ឯតទវោច សព្វេហេវ ទេវ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អញ្ញថាភាវោ មា ខោ ត្វំ ទេវ សាបេក្ខោ កាលមកាសិ ទុក្ខា សាបេក្ខស្ស កាលកិរិយា គរហិតា ច សាបេក្ខស្ស កាលកិរិយា ឥមានិ តេ ទេវ ចតុរាសីតិនគរសហស្សានិ កុសាវតីរាជធានិប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិបាសាទសហស្សានិ ធម្មបាសាទប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិកូដាគារសហស្សានិ មហាវិយូហកូដាគារប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ



ម្នាលអានន្ទ លំដាប់នោះ ព្រះនាងសុភទ្ទាទេវី ទ្រង់ជូតទឹកព្រះនេត្រហើយ ក្រាបបង្គំទូលព្រះបាទមហាសុទស្សនៈ យ៉ាងនេះថា បពិត្រព្រះសម្មតិទេព សេចក្តីនាសព្រាត់ប្រាស វៀរឃ្លាតចាកសត្វនិងសង្ខារទាំងពួង ដែលជាទីស្រឡាញ់ ជាទីពេញចិត្ត (កើតមានដល់ព្រះអង្គ) បពិត្រព្រះសម្មតិទេព សូមទ្រង់ កុំទិវង្គត ប្រកបដោយសេចក្តីអាល័យឡើយ (ព្រោះថា) កាលកិរិយារបស់បុគ្គល ដែលមានសេចក្តីអាល័យ តែងនាំមកនូវទុក្ខ មួយទៀត កាលកិរិយារបស់បុគ្គល ដែលមានសេចក្តីអាល័យ អ្នកប្រាជ្ញតែងតិះដៀល បពិត្រព្រះសម្មតិទេព ឯនគរទាំង ៨៤.០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានី ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីអាល័យ ចំពោះនគរទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ប្រាសាទ ៨៤.០០០ របស់ព្រះអង្គនេះ មានធម្មប្រាសាទ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះប្រាសាទទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កូដាគារ ៨៤.០០០ របស់ព្រះអង្គនេះ មានកូដាគារផ្ទះប្រាក់ ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះកូដាគារទាំងនុ៎ះចេញ

ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ច-តុរាសីតិបល្លង្កសហស្សានិ សោវណ្ណមយានិ រូបិយម-យានិ ទន្តមយានិ មសារគល្លមយានិ គោណកត្ថតានិ បដិកត្ថតានិ បដលិកត្ថតានិ កទលិមិគបវរបច្ចត្ថ-រណានិ សឧត្តរច្ឆទានិ ឧភតោលោហិតកូបធានានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិនាគសហស្សានិ សោ-វណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ ឧបោសថនាគរាជប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុ-រាសីតិអស្សសហស្សានិ សោវណ្ណាលង្ការានិ សោ-វណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វលាហកអស្សរា-ជប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិរថសហស្សានិ



សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិ-ទេព បល្ល័ង្ក ៨៤.០០០ របស់ព្រះអង្គនេះ សុទ្ធតែមាស ប្រាក់ ភ្លុក ខៃ បរកត ដែលក្រាលដោយសំពត់ធ្វើដោយរោមសត្វសាហាវ ក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានពណ៌ស ក្រាលដោយសំពត់ធ្វើដោយរោមសត្វមានផ្កាចង្កើម ក្រាលដោយកម្រាលដ៏ល្អ ដែលធ្វើដោយស្បែកប្រើស មានពិដានពណ៌ក្រហមទាំងសងខាង ព្រមទាំងពូកខ្នើយពណ៌ក្រហម ទាំងសងខាង បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះបល្ល័ង្កទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត ឡើយ បពិត្រព្រះសម្មតិទេព ដំរី ៨៤.០០០ មានឧបោសថនាគរាជ ជាប្រធានរបស់ព្រះអង្គនេះ សុទ្ធតែមានអលង្ការមាស មានទង់មាស មានបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ចំពោះដំរីទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព សេះ ៨៤.០០០ មានសេះឈ្មោះវលាហក-អស្សរាជ ជាប្រធានរបស់ព្រះអង្គនេះ សុទ្ធតែមានអលង្ការមាស មានទង់មាស មានបាំងដោយបណ្តាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះសេះទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព រថ៨៤.០០០របស់ព្រះអង្គ

សីហចម្មបរិវារានិ ព្យគ្ឃចម្មបរិវារានិ ទីបិចម្មបរិវារានិ បណ្ឌុកម្ពលបរិវារានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលបដិច្ឆន្នានិ វេជយន្តរថប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិមណិសហស្សានិ មណិរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិឥត្ថីសហស្សានិ ឥត្ថីរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិគហបតិសហស្សានិ គហបតិរតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ បជហ ជីវិតេ អបេក្ខំ មា អកាសិ ឥមានិ តេ ទេវ ចតុរាសីតិខត្តិយសហស្សានិ



នេះ មានវេជយន្តរថ ជាប្រធាន ដែលគេលាដោយស្បែកសីហៈ ដោយស្បែកខ្លាធំ ដោយស្បែកខ្លាដំបង ដោយសំពត់កម្ពល មានពណ៌លឿង មានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្ដាញមាស បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្ដីស្រឡាញ់ ចំពោះរថទាំងនុ៎ះចេញ សូមទ្រង់កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព កែវមណី ៨៤.០០០ មានមណីរ័ត្ន ជាប្រធាន របស់ព្រះអង្គនេះ បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះកែវមណីទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកស្ត្រី ៨៤.០០០ របស់ព្រះអង្គនេះ មានឥត្ថីរ័ត្ន ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះស្ត្រីទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកគហបតី ៨៤.០០០ របស់ព្រះអង្គនេះ មានគហបតិរ័ត្ន ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្ដីស្រឡាញ់ ចំពោះគហបតីទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្ដីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ពួកក្សត្រិយ៍ ៨៤.០០០ របស់ព្រះអង្គនេះ

អនុយន្តានិ បរិនាយករតនប្បមុខានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិធេនុសហស្សានិ ទុហសន្ទនានិ កំសុប-ធារណានិ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិវត្ថកោដិសហ-ស្សានិ ខោមសុខុមានំ កប្បាសិកសុខុមានំ កោ-សេយ្យសុខុមានំ កម្ពលសុខុមានំ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ឥមានិ តេ ទេវ ចតុរាសីតិថាលិបាកសហស្សានិ សាយំ បាតំ ភត្តាភិហារោ អភិហរិយិត្ថ ឯត្ថ ទេវ ឆន្ទំ ជនេហិ ជីវិតេ អបេក្ខំ ករោហិ ។





មានបរិនាយករតនៈ ជាប្រធាន ជាអ្នកចុះចូលព្រះអង្គ បពិត្រព្រះសម្មតិ-ទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះពួកក្សត្រិយ៍ទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព មេគោ ៨៤.០០០ សម្រាប់រកបន្ទុំ (យកទឹកដោះ) មានភាជន៍សំរិទ្ធ សម្រាប់ត្រង របស់ព្រះអង្គនេះ បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់ នូវសេចក្តីស្រឡាញ់ ចំពោះមេគោទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិ-ទេព សំពត់ ៨៤.០០០ កោដិ របស់ព្រះអង្គនេះ ជាសំពត់ដែលធ្វើដោយសំបកឈើ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់កម្ពលគឺសំពត់ធ្វើដោយរោមសត្វ មានសាច់ដ៏ល្អិត បពិត្រព្រះសម្មតិទេព សូមព្រះអង្គលះបង់នូវសេចក្តីស្រឡាញ់ ចំពោះសំពត់ទាំងនុ៎ះចេញ សូមព្រះអង្គកុំធ្វើនូវសេចក្តីអាល័យក្នុងព្រះជីវិតឡើយ បពិត្រព្រះសម្មតិទេព ភាជន៍ក្រយាស្ងោយ ៨៤.០០០ របស់ព្រះអង្គនេះ ដែលពួកពាសេស នាំយកភត្តមកថ្វាយ ទាំងល្ងាចទាំងព្រឹក បពិត្រព្រះសម្មតិទេព សូមព្រះអង្គ លះបង់នូវសេចក្តីស្រឡាញ់ ចំពោះភាជន៍ក្រយាស្ងោយ ទាំងនុ៎ះចេញ សូមព្រះអង្គ កុំធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិតឡើយ ។

(២២) អថ ខោ អានន្ទ រាជា មហាសុទស្សនោ ន ចិរំ យេវ(១) កាលមកាសិ ។ សេយ្យថាបិ អានន្ទ គហបតិស្ស វា គហបតិបុត្តស្ស វា មនុញ្ញំ ភោជនំ ភុត្តាវិស្ស ភត្តសម្មទោ ហោតិ ឯវមេវ ខោ អានន្ទ រញ្ញោ មហាសុទស្សនស្ស មារណន្តិកា វេទនា អហោសិ ។ កាលង្កតោ ច អានន្ទ រាជា មហាសុទស្សនោ សុគតឹ ព្រហ្មលោកំ ឧបបជ្ជិ ។ រាជា អានន្ទ មហាសុទស្សនោ ចតុរាសីតិវស្សសហស្សានិ កុមារកីឡំ កីឡិ ចតុរាសីតិវស្សសហស្សានិ ឱបរជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ រជ្ជំ ការេសិ ចតុរាសីតិវស្សសហស្សានិ គិហិ ភូតោ ធម្មេ បាសាទេ ព្រហ្មចរិយំ អចរិ(២) ។ សោ ចត្តារោ ព្រហ្មវិហារេ ភាវេត្វា កាយស្ស ភេទា បរំ មរណា ព្រហ្មលោកូបគោ អហោសិ ។

(២៣) សិយា ខោ បនានន្ទ(៣) ឯវមស្ស អញ្ញោ នូន តេន សមយេន រាជា មហាសុទស្សនោ អហោសីតិ ន ខោ បនេតំ អានន្ទ ឯវំ ទដ្ឋព្វំ

១ ម. ម. នចិរស្សេវ ។ ២ ម. អចរិ ។ ៣ ម. សិយា ខោ បន តេ អានន្ទ ។



(២២) ម្នាលអានន្ទ គ្រានោះឯង មិនយូរប៉ុន្មាន ព្រះបាទមហាសុទស្សនៈ ស្តេចក៏ទ្រង់ទិវង្គតទៅ ។ ម្នាលអានន្ទ គហបតីក្តី កូនគហបតីក្តី កាលបើបរិភោគភោជន ជាទីពេញចិត្តហើយ រមែងកើតសេចក្តីគ្រលប់ព្រាយចង់ដេក យ៉ាងណាមិញ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ព្រះអង្គក៏សោយទុក្ខវេទនា មានមរណៈជាទីបំផុត ប្រហែលប៉ុណ្ណោះឯង ។ ម្នាលអានន្ទ លុះដល់ព្រះបាទមហាសុទស្សនៈ ទ្រង់ទិវង្គតទៅ ហើយទ្រង់បានទៅកើត ឯសុគតិព្រហ្មលោក ។ ម្នាលអានន្ទ ព្រះបាទមហាសុទស្សនៈ ទ្រង់ក្រសាលល្បែង នៅយសភាពជាកុមារអស់ ៨៤.០០០ឆ្នាំ ទ្រង់ទទួលទីជាឧបរាជ្យ អស់៨៤.០០០ឆ្នាំ ទ្រង់សោយរាជ្យ អស់ ៨៤.០០០ឆ្នាំ ទ្រង់គេចចាកផ្ទះ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងធម្មប្រាសាទ អស់ ៨៤.០០០ឆ្នាំ ។ ព្រះអង្គចម្រើនព្រហ្មវិហារធម៌ទាំង ៤ លុះបែកធ្លាយរាងកាយ ខាងមុខអំពីមរណភាព ក៏ទៅកើតក្នុងព្រហ្មលោក ។

(២៣) ម្នាលអានន្ទ បើមានសេចក្តីជឿដល់ យ៉ាងនេះថា ក្នុងសម័យនោះ ព្រះបាទមហាសុទស្សនៈ ជាបុគ្គលដទៃ (ក្រៅពីតថាគត) ឬ ម្នាលអានន្ទ ដំណើរនេះ បុគ្គលមិនគប្បីយល់ឃើញ យ៉ាងនោះឡើយ

អហំ តេន សមយេន រាជា មហាសុទស្សនោ អហោសិំ មម តានិ ចតុរាសីតិនគរសហស្សានិ កុសាវតីរាជធានីបមុខានិ មម តានិ ចតុរាសីតិបាសាទសហស្សានិ ធម្មបាសាទប្បមុខានិ មម តានិ ចតុរាសីតិកូដាគារសហស្សានិ មហាវិយូហកូដាគារប្បមុខានិ មម តានិ ចតុរាសីតិបល្លង្កសហស្សានិ សោវណ្ណមយានិ រូបិយមយានិ ទន្តមយានិ មសារគល្លមយានិ គោណកត្ថតានិ បដិកត្ថតានិ បដលិកត្ថតានិ កទលិមិគបវរបច្ចត្ថរណានិ សឧត្តរច្ឆទានិ ឧភតោលោហិតកូបធានានិ មម តានិ ចតុរាសីតិនាគសហស្សានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ ឧបោសថនាគរាជប្បមុខានិ មម តានិ ចតុរាសីតិអស្សសហស្សានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វលាហកអស្សរាជប្បមុខានិ មម តានិ ចតុរាសីតិរថសហស្សានិ





តថាគត បានកើតជាព្រះបាទមហាសុទស្សនៈ ក្នុងសម័យនោះ នគរ ៨៤.០០០ មានកុសាវតីរាជធានី ជាប្រធាននោះ ជារបស់តថាគត ប្រាសាទ ៨៤.០០០ មានធម្មប្រាសាទ ជាប្រធាននោះ ជារបស់តថាគត កូដាគារដ្ឋម ៨៤.០០០ មានកូដាគារដ្ឋមប្រាក់ ជាប្រធាននោះ ជារបស់តថាគត បល្ល័ង្ក ៨៤.០០០ ដែលជាមាស ប្រាក់ ភ្លុក ខ្លឹមគគ ក្រាលដោយសំពត់ ធ្វើដោយរោមសត្វសាហាវ ក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានពណ៌ស ក្រាលដោយសំពត់ធ្វើដោយរោមសត្វ មានផ្កាចង្កោម ក្រាលដោយកម្រាលវិល្អ ដែលធ្វើអំពីស្បែកប្រើស មានខ្នើយពណ៌ក្រហម ទាំងសងខាង ទាំងពិតានក៏មានពណ៌ក្រហម ទាំងសងខាងនោះ ជារបស់តថាគត ដំរី ៨៤.០០០ មានដំរីឈ្មោះឧបោសថនាគរាជ ជាប្រធាន សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្ដាញមាសនោះ ជារបស់តថាគត សេះ ៨៤.០០០ មានសេះវលាហកអស្សរាជ ជាប្រធាន សុទ្ធតែមានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្ដាញមាសនោះ ជារបស់តថាគត រថ ៨៤.០០០ មានវេជយន្តរថ

សីហចម្មបរិក្ខតានិ ព្យគ្ឃចម្មបរិក្ខតានិ ទីបិចម្មបរិក្ខតានិ បណ្ឌុកម្ពលបរិក្ខតានិ សោវណ្ណាលង្ការានិ សោវណ្ណធជានិ ហេមជាលប្បដិច្ឆន្នានិ វេជយន្តរថប្បមុខានិ មម តានិ ចតុរាសីតិ មណិសហស្សានិ មណិរតនប្បមុខានិ មម តានិ ចតុរាសីតិ ឥត្ថីសហស្សានិ សុភទ្ទាទេវិប្បមុខានិ មម តានិ ចតុរាសីតិ គហបតិសហស្សានិ គហបតិរតនប្បមុខានិ មម តានិ ចតុរាសីតិ ខត្តិយសហស្សានិ អនុយន្តានិ បរិណាយករតនប្បមុខានិ មម តានិ ចតុរាសីតិ ធេនុសហស្សានិ ទុហសន្ទនានិ កំសុបធារណានិ មម តានិ ចតុរាសីតិ វត្ថកោដិសហស្សានិ ខោមសុខុមានំ កប្បាសិកសុខុមានំ កោសេយ្យសុខុមានំ កម្ពលសុខុមានំ មម តានិ ចតុរាសីតិ ថាលិបាកសហស្សានិ សាយំ បាតំ ភត្តាភិហារោ អភិហរិយិត្ថ តេសំ ខោ បានន្ទ ចតុរាសីតិនគរសហស្សានំ ឯកញ្ញេវ តំ នគរំ ហោតិ យំ តេន សមយេន អជ្ឈាវសាមិ



ជាប្រធាន ដែលពាសដោយស្បែកសីហៈ ដោយស្បែកខ្លាឃ្មុំ ដោយស្បែកខ្លាដំបង ដោយសំពត់កម្ពល មានពណ៌លឿង មានអលង្ការមាស មានទង់មាស បិទបាំងដោយបណ្ដាញមាសនោះ ជារបស់តថាគត កែវមណី ៨៤.០០០ មានមណិរ័តន៍ ជាប្រធាននោះ ជារបស់តថាគត ស្ត្រី ៨៤.០០០ មាននាងសុភទ្ទាទេវី ជាប្រធាននោះ ជារបស់តថាគត គហបតី ៨៤.០០០ មានគហបតិរ័តន៍ ជាប្រធាននោះ ជារបស់តថាគត ក្សត្រិយ៍ ៨៤.០០០ មានបរិណាយករ័តន៍ ជាប្រធាន ជាអ្នកចុះចូលនោះ ជារបស់តថាគត មេគោ ៨៤.០០០ សម្រាប់រឹតបន្ទុំ (យកទឹកដោះ) មានភាជន៍សំរិទ្ធ សម្រាប់ត្រងនោះ ជារបស់តថាគត សំពត់៨៤.០០០ កោដិ ជាសំពត់ធ្វើដោយសំបកឈើ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយកប្បាស មានសាច់ដ៏ល្អិត សំពត់ធ្វើដោយសូត្រ មានសាច់ដ៏ល្អិត សំពត់ធ្វើដោយរោមសត្វ មានសាច់ដ៏ល្អិតនោះ ជារបស់តថាគត ភាជន៍ក្រយាស្ងោយ ៨៤.០០០ ដែលពួកពិសេស នាំយកក្នុងកាលថ្ងៃដំណាច ទាំងព្រឹកនោះ ជារបស់តថាគត ម្នាលអានន្ទ បណ្ដានគរទាំង៨៤.០០០ នោះឯង នគរទាំងនោះទុកស្ងប់ជានគរមួយ សម័យនោះ តថាគតគ្រប់គ្រង

យទិទំ កុសាវតី រាជធានី តេសំ ខោ បនានន្ទ ចតុរា-
សីតិបាសាទសហស្សានំ ឯកោវាយំ សោ បាសា-
ទោ ហោតិ យំ តេន សមយេន អជ្ឈាវសាមិ យទិទំ
ធម្មោ បាសាទោ តេសំ ខោ បនានន្ទ ចតុរាសីតិ-
កូដាគារសហស្សានំ ឯកញ្ញេវ តំ កូដាគារំ ហោតិ យំ
តេន សមយេន អជ្ឈាវសាមិ យទិទំ មហាវិយូហំ
កូដាគារំ តេសំ ខោ បនានន្ទ ចតុរាសីតិបល្លង្កសហ-
ស្សានំ ឯកោវាយំ សោ បល្លង្កោ ហោតិ យំ តេន ស-
មយេន បរិភុញ្ជាមិ សោវណ្ណមយោ[1] វា រូបិយមយោ
វា ទន្តមយោ វា មសារគល្លមយោ វា តេសំ
ខោ បនានន្ទ ចតុរាសីតិនាគសហស្សានំ ឯកោវាយំ
សោ នាគោ ហោតិ យំ តេន សមយេន អភិរុហាមិ
យទិទំ ឧបោសថោ នាគរាជា តេសំ ខោ បនានន្ទ
ចតុរាសីតិអស្សសហស្សានំ ឯកោវាយំ សោ[2] អស្សោ
ហោតិ យំ តេន សមយេន អភិរុហាមិ យទិទំ វលា-
ហកោ អស្សរាជា តេសំ ខោ បនានន្ទ ចតុរាសីតិរ-
ថសហស្សានំ ឯកោវាយំ សោ រថោ ហោតិ យំ

១ ម. ម. បរិភុញ្ជាមិ បទទ្វយំ សោវណ្ណមយោ ។ ២ ម. ហោតិ បទំ នត្ថិ ។



កុសាវតីរាជធានី ម្នាលអានន្ទ ប្រាសាទទាំង ៨៤.០០០ នោះឯង ប្រាសាទ
ទាំងនោះ ទុកដូចជាប្រាសាទមួយ សម័យនោះ តថាគត គ្រប់គ្រងធម្ម-
ប្រាសាទ ម្នាលអានន្ទ បណ្ដាកូដាគារទាំង ៨៤.០០០ នោះឯង
កូដាគារទាំងនោះ ទុកដូចជាកូដាគារមួយ សម័យនោះ តថាគត
គ្រប់គ្រងកូដាគារមហាព្យូហៈ ម្នាលអានន្ទ បណ្ដាបល្ល័ង្កទាំង ៨៤.០០០
នោះឯង បល្ល័ង្កទាំងនោះ ទុកដូចជាបល្ល័ង្កមួយ សម័យនោះ តថាគត
គ្រប់គ្រងបល្ល័ង្កមាសផង ប្រាក់ផង ភ្លុកផង ខ្លឹមគគកផង ម្នាលអានន្ទ
បណ្ដាដំរីទាំង ៨៤.០០០ នោះឯង ដំរីទាំងនោះ ទុកដូចជាដំរីមួយ
សម័យនោះ តថាគត ជិះតែដំរីឧបោសថនាគរាជ ម្នាលអានន្ទ បណ្ដា
សេះទាំង ៨៤.០០០ នោះឯង សេះទាំងនោះ ទុកដូចជាសេះមួយ
សម័យនោះ តថាគត ជិះតែសេះវលាហកអស្សរាជ ម្នាលអានន្ទ បណ្ដា
រថទាំង ៨៤.០០០ នោះឯង រថទាំងនោះ ទុកដូចជារថមួយ

តេន សមយេន អភិរុហាមិ យទិទំ វេជយន្តរថោ តេសំ ខោ បនានន្ទ ចតុរាសីតិឥត្ថីសហស្សានំ ឯកាយេវ សា ឥត្ថី ហោតិ យា តេន(១) សមយេន បច្ចុបដ្ឋាតិ ខត្តិយាយិនី វា វេស្សាយិនី វា(២) តេសំ ខោ បនានន្ទ ចតុរាសីតិវត្ថកោដិសហស្សានំ ឯកំយេវ តំ វត្ថយុគំ ហោតិ យំ តេន សមយេន បរិទហាមិ ខោមសុខុមំ វា កប្បាសិកសុខុមំ វា កោសេយ្យសុខុមំ វា កម្ពលសុខុមំ វា តេសំ ខោ បនានន្ទ ចតុរាសីតិថាលិបាកសហស្សានំ ឯកោយេវ សោ ថាលិបាកោ ហោតិ យតោ នាឡិកោទនបរមំ ភុញ្ជាមិ តទុបិយញ្ច សូបេយ្យំ បស្សានន្ទ សព្វេ តេ សង្ខារា អតីតា និរុទ្ធា វិបរិណតា ឯវំ អនិច្ចា ខោ អានន្ទ សង្ខារា ឯវំ អទ្ធុវា ខោ អានន្ទ សង្ខារា ឯវំ អនស្សាសិកា ខោ អានន្ទ សង្ខារា យាវញ្ចិទំ អានន្ទ អលមេវ សព្វសង្ខារេសុ និព្វិន្ទិតុំ អលំ វិរជ្ជិតុំ អលំ

---

១ ម. យា មំ តេន ។ ២ ម. ខត្តិយានី វា វេលាមិកានី វា ។ ឱ. ខត្តិយានី វា វេស្សិនី វា ។



សម័យនោះ តថាគត ជិះតែរថវេជយន្តរថ ម្នាលអានន្ទ បណ្តាស្ត្រីទាំង ៨៤.០០០ នោះឯង ស្ត្រីទាំងនោះ ទុកដូចជាស្ត្រីម្នាក់ សម័យនោះ មានស្ត្រីខត្តិយាយិនី (ស្ត្រីក្សត្រិយ៍) ឬ ស្ត្រីវេស្សាយិនី (ស្ត្រីកស្ត្រ) ផងដែរ នៅចាំគាល់បម្រើ ម្នាលអានន្ទ បណ្តាសំពត់ទាំង ៨៤.០០០ កោដិនោះឯង គូសំពត់ទាំងនោះ ទុកដូចជាសំពត់ ១ គូ សម័យនោះ តថាគតស្លៀកពាក់តែសំពត់ដែលធ្វើដោយសំបកឈើ មានសាច់ម៉ដ្ឋ ឬសំពត់ធ្វើដោយកប្បាស មានសាច់ម៉ដ្ឋ សំពត់ធ្វើដោយសូត្រមានសាច់ម៉ដ្ឋ ឬសំពត់ធ្វើដោយរោមសត្វ មានសាច់ម៉ដ្ឋ ម្នាលអានន្ទ ភាជន៍ក្រយាស្ងោយទាំង ៨៤.០០០ នោះឯង ភាជន៍ក្រយាស្ងោយទាំងនោះ ទុកដូចជាភាជន៍មួយ គឺវេលាដែលតថាគតបរិភោគនូវបាយ ចំនួនអង្ករមួយនាឡិជាយ៉ាងក្រៃលែងផង សម្លមួយសមគួរដល់បាយនោះផង ម្នាលអានន្ទ អ្នកចូរមើលចុះ សង្ខារទាំងពួងនោះកន្លងទៅហើយ រលាយរលត់ទៅហើយ ប្រែប្រួលទៅហើយ ម្នាលអានន្ទ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះឯង មិនឋិតថេរយ៉ាងនេះឯង មិនស្កប់ចិត្តយ៉ាងនេះឯង ម្នាលអានន្ទ សេចក្តីនេះ មានផលប៉ុណ្ណេះ គួរដើម្បីនឿយណាយ គួរដើម្បីប្រាសចាកសេចក្តីត្រេកអរ

វិមុច្ចិតុំ ឆក្ខត្តុំ ខោ បនាហំ អានន្ទ អភិជានាមិ ឥមស្មឹ បទេសេ សរីរំ និក្ខិបិតំ យញ្ច[១] ខោ រាជា ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ អយំ សត្តមោ សរីរនិក្ខេបោ ។ ន ខោ បនាហំ អានន្ទ តំ បទេសំ សមនុបស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យត្ថ តថាគតោ អដ្ឋមំ សរីរំ និក្ខិបេយ្យាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

(៦៤) អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ ។

មហាសុទស្សនសុត្តំ ចតុត្ថំ និដ្ឋិតំ ។

---

១ ឱ. ម. តញ្ច ។



ប្រាំមួយដងក្នុងប្រទេសនេះ តថាគតស្គាល់ច្បាស់ ម្នាលអានន្ទ មួយទៀត កាលតថាគត ជាស្តេចចក្រពត្តិ ប្រកបដោយធម៌ សោយរាជ្យដោយធម៌ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម មានជនបទដ៏មាំមួន ប្រកបដោយរតនៈ ៧ ប្រការ ដឹងច្បាស់នូវសរីរៈដែលតថាគតដាក់ក្នុងប្រទេសនោះជាគម្រប់ ៦ដង ការដាក់ចុះនូវសរីរៈ (របស់តថាគត) ជាគម្រប់ ៧ដងនេះហើយ ម្នាលអានន្ទ ក្នុងលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគតមិនបានឃើញនូវប្រទេស ដែលជាទីដាក់ចុះនូវសរីរៈជាគម្រប់ ៨ ឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ការណ៍នេះចប់ហើយ កាលតទៅក្រោយមក ព្រះសុគតជាសាស្តា ទ្រង់ត្រាស់ពាក្យនេះទៀតថា

(៦៤) ពួកសង្ខារទាំងឡាយ មិនទៀង មានសភាពកើត
ឡើងហើយ តែងវិនាសទៅវិញជាធម្មតា លុះកើតឡើង
ហើយ តែងរលត់ទៅវិញ ការរម្ងាប់នូវសង្ខារទាំងនោះ
បាន ទើបនាំមកនូវសេចក្តីសុខ ។

ចប់ មហាសុទស្សនសូត្រទី ៤ ។

## ជនវសភសុត្តំ បញ្ចមំ

(២៥) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា នាតិកេ(១) វិហរតិ គិញ្ជកាវសថេ ។ តេន ខោ បន សមយេន ភគវា បរិតោ បរិតោ ជនបទេសុ បរិចារកេ អព្ភតីតេ កាលង្កតេ ឧបបត្តីសុ(២) ព្យាករោតិ កាសីកោសលេសុ វជ្ជីមល្លេសុ ចេតិវំសេសុ(៣) កុរុបញ្ចាលេសុ មជ្ឈសូរសេនេសុ(៤) អសុ អមុត្រ ឧបបន្នោ(៥) អសុ អមុត្រ ឧបបន្នោ បរោបញ្ញាសា(៦) នាតិកិយា បរិចារកា អព្ភតីតា កាលង្កតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា សាធិកា នវុតិ នាតិកិយា បរិចារកា អព្ភតីតា កាលង្កតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា

---

១ ម. នាតិកេ ។ ២ ឱ. ឧបបត្តីសុ ។ ៣ ម. ចេតិយវំសេសុ ។ ៤ ម. មជ្ឈសូរសេនេសុ ។ ៥ ឱ. ឧប្បន្នោ ។ ៦ ឱ., ម. បរោបញ្ញាស ។

## ជនវសភសូត្រ ទី ៥

(២៥) ខ្ញុំបានស្តាប់ហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងលំនៅដែលធ្វើដោយឥដ្ឋ ជិតនាទិកគ្រាម ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ព្យាករ ក្នុងកំណើតនៃបញ្ញាខិនីគតិ និងបុណ្យ ចំពោះពួកជនដែលជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ក្នុងជនបទទាំងឡាយជុំវិញ គឺកាសីជនបទ ១ កោសលជនបទ ១ វជ្ជីជនបទ ១ មល្លជនបទ ១ ចេតីជនបទ ១ វំសជនបទ ១ កុរុជនបទ ១ បញ្ចាលជនបទ ១ មច្ឆជនបទ ១ សូរសេនជនបទ ១ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាង ៥០ នាក់ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ មានសភាពជាឧបបាតិកសត្វ បរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់មកពីលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៩០ នាក់ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត

ទុក្ខស្សន្តំ ករិស្សន្តិ សាធិកានិ នវុតិ នាតិកិយា បរិចារកា អព្ភតីតា កាលកតា តិណ្ណំ សំយោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។

[២២] អស្សោសុំ ខោ នាតិកិយា បរិចារកា ភគវា កិរ បរិតោ បរិតោ ជនបទេសុ បរិចារកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ព្យាករោតិ កាសីកោសលេសុ វជ្ជីមល្លេសុ ចេតិវំសេសុ កុរុបញ្ចាលេសុ



ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ តែនៅមានរាគៈ ទោសៈ មោហៈ ដែលស្រាលស្តើង[១] ពួកជនអ្នកនៅក្នុងនាតិកគ្រាម ជាង ៩០ នាក់ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅ ក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ។

(២២) ពួកជនជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលនៅក្នុងនាតិកគ្រាម បានឮដំណឹងថា ព្រះមានព្រះភាគ ទ្រង់ព្យាករក្នុងកំណើតនៃបញ្ញាទិគតិនិងបុណ្យ ចំពោះពួកជនដែលជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ក្នុងជនបទទាំងឡាយជុំវិញ គឺ កាសីជនបទ ១ កោសលជនបទ ១ វជ្ជីជនបទ ១ មល្លជនបទ ១ ចេតីជនបទ ១ វំសជនបទ ១ កុរុជនបទ ១ បញ្ចាលជនបទ ១

---

១ រាគៈ ទោសៈ មោហៈ ដែលធ្ងន់ក្រាស់ក្រាស់ក្រាស ព្រះសោតាបន្ន លះបង់បាន អស់ហើយ នៅសល់ តែរាគៈ ទោសៈ មោហៈ ដែលល្អិតស្រាលស្តើង លោកលះមិន ទាន់អស់ ។

មជ្ឈសូរសេនេសុ អសុ អមុត្រ ឧបបន្នោ អសុ អមុត្រ ឧបបន្នោ(១) បរោបញ្ញាសា នាតិកិយា បរិចារកា អព្ភតីតា កាលង្កតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា សាធិកា នវុតិ នាតិកិយា បរិចារកា អព្ភតីតា កាលង្កតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ សាតិរេកានិ បញ្ចសតានិ នាតិកិយា បរិចារកា អព្ភតីតា កាលង្កតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។ តេន ច នាតិកិយា បរិចារកា អត្តមនា អហេសុំ បមុទិតា បីតិសោមនស្សជាតា ភគវតោ បញ្ហវេយ្យាករណំ សុត្វា ។

---

១ ម. ឧបបន្នោតិ ទិស្សតិ ។





មជ្ឈិមទេស ១ សូរសេនជនបទ ១ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាតិកគ្រាមជាង ៥០ នាក់ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ បានសភាពជាឧបបាតិកសត្វ បរិនិព្វានក្នុងលោកនោះ មានសភាវៈ មិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាតិកគ្រាមជាង៩០នាក់ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ៣ តែងនាំមាន រាគៈ ទោសៈ មោហៈ ស្រាលស្តើង ពួកជនអ្នកនៅក្នុងនាតិកគ្រាមជាង ៥០០ នាក់ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ៣ ។ ពួកជនអ្នកនៅក្នុងនាតិកគ្រាម ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានស្តាប់បញ្ហាព្យាករណ៍ របស់ព្រះមានព្រះភាគហើយ ក៏មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សឡើង ដោយដំណើរនៃអនាគាមិបុគ្គលជាដើមនោះ ។

[៤៧] អស្សោសិ ខោ អាយស្មា អានន្ទោ ភគវា កិរ បរិតោ បរិតោ ជនបទេសុ បរិចារកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ព្យាករោតិ កាសីកោសលេសុ វជ្ជីមល្លេសុ ចេតិវំសេសុ កុរុបញ្ចាលេសុ មច្ឆសូរសេនេសុ អសុ អមុត្រ ឧបបន្នោ អសុ អមុត្រ ឧបបន្នោ បរោបញ្ញាសា នាទិកិយា បរិចារកា អព្ភតីតា កាលកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា សាធិកា នវុតិ នាទិកិយា បរិចារកា អព្ភតីតា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ សាតិរេកានិ បញ្ចសតានិ នាទិកិយា បរិចារកា



[៤៧] ព្រះអានន្ទមានអាយុ បានឮថា ព្រះមានព្រះភាគ ទ្រង់ព្យាករនូវកំណើតនៃបញ្ហា និងគតិនិងបុណ្យ ចំពោះពួកជន ដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ក្នុងជនបទតាំងឆ្ងាយជុំវិញ គឺ កាសីជនបទ ១ កោសលជនបទ ១ វជ្ជីជនបទ ១ មល្លជនបទ ១ ចេតិជនបទ ១ វំសជនបទ ១ កុរុជនបទ ១ បញ្ចាលជនបទ ១ មច្ឆជនបទ ១ សូរសេនជនបទ ១ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៥០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ មានសភាពជាឧបបាតិកសត្វ បរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់ចាកលោកនោះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៩០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខ ព្រោះអស់ទៅនៃសំយោជនៈ ៣ តែនៅមានរាគៈ ទោសៈ មោហៈ ស្រាលស្តើង ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៥០០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើ

អត្តីតា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ។ តេន ច នាទិកិយា បរិចារកា អត្តមនា អហេសុំ បមុទិតា បីតិសោមនស្សជាតា ភគវតោ បញ្ហាវេយ្យាករណំ សុត្វា ។ អថ ខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ ឥមេ ខោ បនាតិ អហេសុំ ញាតិកា(១) បរិចារកា ពហូ ចេវ រត្តញ្ញូ ច អត្តីតា កាលកតា សុញ្ញា មញ្ញេ អង្គមគធា ញាតិកេហិ(២) បរិចារកេហិ អត្តីតេហិ កាលកតេហិ តេ ខោ បនាមិ អហេសុំ ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា សីលេសុ បរិបូរការិនោ(៣) តេ អត្តីតា កាលកតា ភគវតា អព្យាកតា តេសំបិស្ស សាធុ វេយ្យាករណំ ពហុជនោ បសីទេយ្យ តតោ គច្ឆេយ្យ សុគតឹ អយំ ខោ បនាមិ អហោសិ រាជា មាគធោ សេនិយោ ពិម្ពិសារោ

១ មានបាលិថា ញាតិ ។ ២ ម. អង្គមាគធកេហិ ។ ៣ ឱ. ម. បរិបូរការិនោ ។



មរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បានស្តាប់បញ្ហាព្យាករណ៍របស់ព្រះមានព្រះភាគ ហើយក៏មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សឡើង ដោយដំណើរដែលកាត់តាមបុគ្គលជាដើមនោះ ។ គ្រានោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះថា ពួកជនអ្នកនៅ ក្នុងមគធជនបទទាំងនេះ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានចំនួនច្រើនណាស់ផង ជាអ្នកដឹងរាត្រីយូរផង ធ្វើមរណកាល កន្លងទៅយូរហើយ ដែនអង្គៈ និងដែនមគធៈ ហាក់ដូចជាសូន្យ បាត់មនុស្សអ្នកមានគុណៈ ដែលជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជនទាំងនោះ សុទ្ធតែជាអ្នកជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទាំងធ្វើឲ្យការពេញលេញក្នុងសីល ជនទាំងនោះ ធ្វើមរណកាល កន្លងទៅយូរហើយ ព្រះមានព្រះភាគ មិនបានព្យាករឡើយ ប្រសិនបើទ្រង់ព្យាករនូវជនទាំងនោះដោយប្រពៃហើយ ជនច្រើននាក់ គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិ ដោយសេចក្តីជ្រះថ្លានោះ ចំណែកខាងព្រះបាទមាគធសេនិយពិម្ពិសារនេះ

ធម្មិកោ ធម្មរាជា ហិតោ ព្រាហ្មណគហបតិកានំ នេគមានញ្ចេវ ជានបទានញ្ច អបិស្សុទំ មនុស្សា កិត្តិយមានរូបា(១) វិហរន្តិ ឯវំ សោ នោ ធម្មិកោ ធម្មរាជា សុខាបេត្វា កាលកតោ ឯវំ មយំ តស្ស ធម្មិកស្ស ធម្មរញ្ញោ វិជិតេ ផាសុកំ(២) វិហរិម្ហាតិ សោ ខោ បនាសិ ភគវតិ បសន្នោ ធម្មេ បសន្នោ សង្ឃេ បសន្នោ សីលេសុ បរិបូរការី អបិស្សុទំ មនុស្សា ឯវមាហំសុ យាវ មរណកាលាបិ រាជា មាគធោ សេនិយោ ពិម្ពិសារោ ភគវន្តំ កិត្តិយមានរូបោ កាលកតោតិ សោ អព្ភតីតោ កាលកតោ ភគវតា អព្យាកតោ តស្សបិស្ស សាធុ វេយ្យាករណំ ពហុជនោ បសីទេយ្យ តតោ គច្ឆេយ្យ សុគតឹ ភគវតោ ខោ បន សម្ពោធិ មាគធេសុ យត្ថ ខោ បន ភគវតោ សម្ពោធិ មាគធេសុ កថំ តត្រ(៣) ភគវា មាគធកេ បរិចារកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ន ព្យាករេយ្យ

១ ម. កិត្តយមានរូបា ។ ២ ម. ឱ. ផាសុំ ។ ៣ ម. តត្ថ ។



ព្រះអង្គជាធម្មិកធម្មរាជ ទ្រង់បានធ្វើប្រយោជន៍ឲ្យដល់ពួកព្រាហ្មណ៍ និងគហបតី អ្នកនៅក្នុងនិគមនិងជនបទ បានឮថា ពួកមនុស្សនិយាយសរសើរព្រះរាជានោះថា ព្រះរាជានោះជាធម្មិកធម្មរាជ ទ្រង់ធ្វើសេចក្តីសុខឲ្យដល់យើង តាំងពីឡាយ ហ៊ឹងនេះហើយ ទ្រង់ទិវង្គតទៅ យើងតាំងពីឡាយគឺនៅជាសុខសប្បាយក្នុងដែនរបស់ព្រះរាជានោះជាធម្មិកធម្មរាជយ៉ាងនេះ ព្រះរាជានោះទ្រង់ជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទ្រង់ធ្វើឲ្យពេញលេញក្នុងសីល បានឮថា ពួកមនុស្សនាំគ្នានិយាយយ៉ាងនេះថា ព្រះបាទមាគធសេនិយពិម្ពិសារ ព្រះអង្គតែងមានព្រះរាជឫទ្ធិសរសើរព្រះមានព្រះភាគ ដរាបដល់មរណកាល ហើយទ្រង់ទិវង្គតទៅវិញ លុះព្រះរាជានោះ ទ្រង់ទិវង្គត កន្លងទៅហើយ ព្រះមានព្រះភាគ មិនទ្រង់ព្យាករសោះ ប្រសិនបើទ្រង់ព្យាករ នូវព្រះរាជានោះ ដោយប្រពៃហើយ ជនច្រើននាក់គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិដោយសេចក្តីជ្រះថ្លានោះ សម្ពោធិញ្ញាណរបស់ព្រះមានព្រះភាគ រមែងបាននៅក្នុងដែន ដែលនៅក្នុងដែនមគធៈ កាលបើសម្ពោធិញ្ញាណ របស់ព្រះមានព្រះភាគ មាននៅក្នុងដែនដែលនៅក្នុងដែនមគធៈណាហើយ ហេតុអ្វី ព្រះមានព្រះភាគមិនទ្រង់ព្យាករក្នុងកំណើតនៃបញ្ញា ទីកើតនិងទីបុណ្យ ចំពោះពួកជន អ្នកនៅក្នុងដែនមគធៈនោះ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល

ភគវា ចេ នោ បន មាគធកេ បរិចារកេ អព្ភតីតេ កាលង្កតេ ឧបបត្តីសុ ន ព្យាករេយ្យ ទិន្នមនា(១) តេនស្សុ មាគធិកា បរិចារកា យេន តេ បនស្សុ ទិន្នមនា មាគធិកា បរិចារកា កថំ តេ ភគវា ន ព្យាករេយ្យាតិ ។ ឥទំ វត្វា អាយស្មា អានន្ទោ មាគធកេ បរិចារកេ អារព្ភ ឯកោ រហោ អនុវិចិន្តេត្វា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សុតំ មេតំ ភន្តេ ភគវា តាវ បរិតោ បរិតោ ជនបទេសុ បរិចារកេ អព្ភតីតេ កាលង្កតេ ឧបបត្តីសុ ព្យា-

១ ម. ម. ទីនហតា ។



កន្លងទៅយូរហើយ បើព្រះមានព្រះភាគមិនទ្រង់ព្យាករ ក្នុងកំណើតនៃបញ្ញានិងគតិនិងបុណ្យ ចំពោះពួកជន អ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយនោះទេ ពួកជនដែលនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ គឺកើតមានសេចក្តីតូចចិត្ត ដោយហេតុនោះពុំខាន ពួកជនដែលនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតមានសេចក្តីតូចចិត្ត ដោយហេតុណា ហេតុអ្វី បានជាព្រះមានព្រះភាគ មិនទ្រង់ព្យាករចំពោះពួកជននោះ ដោយហេតុនោះសោះ ។ ព្រះអានន្ទមានអាយុប្រារព្ធ នូវពួកជន អ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយពិចារណានូវហេតុនេះ ក្នុងទីស្ងាត់តែម្នាក់ឯង លុះក្រោកឡើង ក្នុងបច្ចូសសម័យនៃរាត្រី ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានឮដូច្នេះថា ព្រះមានព្រះភាគ ទ្រង់ព្យាករ ក្នុងកំណើតនៃបញ្ញា និងគតិនិងបុណ្យ ចំពោះពួកជន ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ក្នុងជនបទទាំងឡាយជុំវិញ គឺ

ករោតិ កាសីកោសលេសុ វជ្ជីមល្លេសុ ចេតិវំសេសុ កុរុបញ្ចាលេសុ មជ្ឈសូរសេនេសុ អសុ អមុត្រ ឧបបន្នោ អសុ អមុត្រ ឧបបន្នោ បរោបញ្ញាសា នាតិកិយា បរិចារកា អព្ភតីតា កាលកតា បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា សាធិកា នវុតិ នាតិកិយា បរិចារកា អព្ភតីតា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ សាតិរេកានិ បញ្ចសតានិ នាតិកិយា បរិចារកា អព្ភតីតា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយនាតិ ពេទ ៥ នាតិកិយា បរិចារកា



កាសីជនបទ១ កោសលជនបទ១ វជ្ជីជនបទ១ មល្លជនបទ១ ចេតិជនបទ១ វំសជនបទ១ កុរុជនបទ១ បញ្ចាលជនបទ១ មច្ឆជនបទ១ សូរសេនជនបទ១ ថា ជនឯណោះ ទៅកើតក្នុងទីឯណោះ ជនឯណោះ ទៅកើតក្នុងទីឯណោះ ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៥០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ មានសភាពជាឱបបាតិកសត្វ ហើយបរិនិព្វានក្នុងលោកនោះ មានសភាពមិនត្រឡប់មកលោកនេះ ព្រោះអស់ទៅនៃសំយោជនៈ ៥ ជាចំណែកខាងក្រោម ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៩០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសកទាគាមិបុគ្គល នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់ទៅនៃសំយោជនៈ៣ តែនៅមានរាគៈទោសៈមោហៈស្រាលស្តើង ពួកជនអ្នកនៅក្នុងនាទិកគ្រាមជាង ៥០០ នាក់ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាពមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀងមានសម្ពោធិជាទីប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅ នៃសំយោជនៈ៣ ពួកជនអ្នកនៅក្នុងនាទិកគ្រាម ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

អត្តមនា អហេសុំ(១) បមុទិតា បីតិសោមនស្សជាតា
ភគវតោ បញ្ហាវេយ្យាករណំ សុត្វា(២) ឥមេ ខោ បនាបិ
ភន្តេ អហេសុំ មាគធិកា បរិចារកា ពហូ ចេវ រត្តញ្ញូ
ច អព្ភតីតា កាលកតា សុញ្ញា មញ្ញេ អង្គមគ-
ធា មាគធិកេហិ បរិចារកេហិ អព្ភតីតេហិ កាល-
កតេហិ តេ ខោ បនាបិ ភន្តេ អហេសុំ ពុទ្ធេ
បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា សីលេសុ
បរិបូរីការិនោ តេ អព្ភតីតា កាលកតា ភគវ-
តា អព្យាកតា តេសំបិស្ស សាធុ វេយ្យាករណំ
ពហុជនោ បសីទេយ្យ តតោ គច្ឆេយ្យ សុគតិំ
អយំ ខោ បនាបិ ភន្តេ អហោសិ រាជា មាគ-
ធោ សេនិយោ ពិម្ពិសារោ ធម្មិកោ ធម្មរាជា ហិតោ
ព្រាហ្មណគហបតិកានំ នេគមានញ្ចេវ ជានប-
ទានញ្ច អបិស្សុទំ មនុស្សា កិត្តយមានរូបា វិហ-
រន្តិ ឯវំ សោ នោ ធម្មិកោ ធម្មរាជា សុខាបេត្វា

១ ឱ. អហេសុន្តិ ឥ. វិស្សុតិ ។ ២ ម. សុត្វាតិ ។



បានស្ដាប់បញ្ហាព្យាករណ៍ របស់ព្រះមានព្រះភាគ ហើយក៏មានចិត្តត្រេក
អររីករាយ កើតបីតិសោមនស្សឡើង ដោយអំណាចនៃអនាគាមិបុគ្គល
ជាដើមនោះ បពិត្រព្រះអង្គដ៏ចម្រើន ពួកជនអ្នកនៅក្នុងដែនមគធជនបទទាំង
នេះ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានចំនួនច្រើនណាស់ផង
ជាអ្នកដឹងរាត្រីយូរផង ធ្វើមរណកាល កន្លងទៅយូរហើយ ដែនអង្គៈ
និងដែនមគធៈ ហាក់ដូចជាសូន្យចាកពួកជនអ្នកដែនមគធៈ ជាអ្នកបម្រើ
ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយ បពិត្រ
ព្រះអង្គដ៏ចម្រើន ពួកជននោះ សុទ្ធតែជាអ្នកជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌
ព្រះសង្ឃ តាំងធ្វើនូវការបំពេញក្នុងសីល ពួកជននោះ ធ្វើមរណកាល
កន្លងទៅយូរហើយ ព្រះមានព្រះភាគ មិនទាន់បានទ្រង់ព្យាករសោះ ប្រ-
សិនបើទ្រង់ព្យាករ នូវពួកជននោះ ដោយប្រពៃហើយ ជនច្រើននាក់
គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិ ដោយសេចក្ដីជ្រះថ្លានោះ បពិត្រព្រះអង្គ
ដ៏ចម្រើន ចំណែកព្រះបាទមាគធសេនិយពិម្ពិសារនេះ ព្រះអង្គជាធម្មិក
ធម្មរាជ ទ្រង់ធ្វើនូវប្រយោជន៍ឲ្យដល់ពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុង
និគមនិងជនបទទាំងផង បានឮថា ពួកមនុស្ស និយាយសរសើរព្រះរាជានោះ
ថា ព្រះរាជានោះជាធម្មិកធម្មរាជ ទ្រង់ធ្វើនូវសេចក្ដីសុខឲ្យដល់យើងទាំង-

កាលកតោ ឯវំ មយំ តស្ស ធម្មិកស្ស ធម្មរញ្ញោ វិជិតេ ផាសុកំ វិហារិម្ហាតិ សោ ច បនាយំ អហោសិ ពុទ្ធេ បសន្នោ ធម្មេ បសន្នោ សង្ឃេ បសន្នោ សីលេសុ បរិបូរការី អបិស្សុទំ មនុស្សា ឯវមាហំសុ យាវ មរណកាលាបិ រាជា មាគធោ សេនិយោ ពិម្ពិសារោ ភគវន្តំ កិត្តយមានរូបោ កាលកតោតិ សោ អព្ភតីតោ កាលកតោ ភគវតា អព្យាកតោ តស្សបិស្ស សាធុ វេយ្យាករណំ ពហុជនោ បសីទេយ្យ តតោ គច្ឆេយ្យ សុគតឹ ភគវតោ ខោ បន ភន្តេ សម្ពោធិ មាគធេសុ យត្ថ ខោ បន ភន្តេ ភគវតោ សម្ពោធិ មាគធេសុ កថំ តត្រ ភគវា





ឲ្យយើងទាំងនេះ ហើយទ្រង់ទិវង្គតទៅ យើងទាំងឡាយ គឺនៅជាសុខសប្បាយក្នុងដែនរបស់ព្រះរាជានោះ ជាធម្មិកធម្មរាជយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជានោះក៏ជ្រះថ្លា ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទ្រង់ធ្វើនូវការបំពេញក្នុងសីលផង ម្យាងទៀត មនុស្សទាំងឡាយ នាំគ្នានិយាយយ៉ាងនេះថា ព្រះរាជាមាគធសេនិយពិម្ពិសារ តែងមានព្រះរាជភក្តី សរសើរព្រះមានព្រះភាគ ដរាបដល់មរណកាល ហើយទ្រង់ទិវង្គតទៅដូច្នេះ លុះព្រះរាជានោះ ទ្រង់ទិវង្គតក្នុងទីទៅយូរហើយ ព្រះមានព្រះភាគ មិនបានទ្រង់ព្យាករឡើយ ប្រសិនបើទ្រង់ព្យាករព្រះរាជានោះ ដោយប្រពៃហើយ ជនច្រើននាក់ គប្បីជ្រះថ្លា គប្បីទៅកាន់សុគតិ ដោយសេចក្តីជ្រះថ្លានោះពុំខាន បពិត្រព្រះអង្គដ៏ចម្រើន សម្ពោធិញ្ញាណ របស់ព្រះមានព្រះភាគ រមែងមាននៅក្នុងពួកជនអ្នកនៅក្នុងដែនមគធៈ បពិត្រព្រះអង្គដ៏ចម្រើន កាលបើសម្ពោធិញ្ញាណ របស់ព្រះមានព្រះភាគ មាននៅក្នុងពួកជនអ្នកនៅក្នុងដែនមគធៈ ណាហើយ ហេតុអ្វី ក៏ព្រះមានព្រះភាគ

មាគធិកេ បរិចារកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ន ព្យាការេយ្យ ភគវា ចេ ខោ បន ភន្តេ មាគធិកេ បរិចារកេ អព្ភតីតេ កាលកតេ ឧបបត្តីសុ ន ព្យាការេយ្យ ខិន្នមនា តេនស្សុ មាគធិកា បរិចារកា យេន ខោ បនស្សុ ខិន្នមនា មាគធិកា បរិចារកា កថំ តេ(១) ភគវា ន ព្យាការេយ្យាតិ ។ ឥទមាយស្មា អានន្ទោ មាគធិកេ បរិចារកេ អារព្ភ ភគវតោ សម្មុខា បរិកថំ កត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(២៨) អថខោ ភគវា អចិរបក្កន្តេ អាយស្មន្តេ(២) អានន្ទេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរំ អាទាយ

១ ម. តិ ។ ២ ម. អាយស្មតោ ។



មិនទ្រង់ព្យាករ គតិការណ៍កើតនៃបញ្ញាទិគតិនិងបុណ្យ ចំពោះពួកជន អ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយនោះ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគទ្រង់ព្យាករ គតិការណ៍កើតនៃបញ្ញា និងគតិ និងបុណ្យ ចំពោះពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើមរណកាល កន្លងទៅយូរហើយនោះទេ ពួកជនអ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ក៏កើតមានសេចក្ដីខូចចិត្ត ដោយហេតុនោះណាមាន ពួកជន អ្នកនៅក្នុងដែនមគធៈ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កើតមានសេចក្ដីខូចចិត្ត ដោយហេតុណា ហេតុអ្វីបានជាព្រះមានព្រះភាគ មិនទ្រង់ព្យាករ ចំពោះពួកជននោះ ដោយហេតុនោះ ។ ព្រះអានន្ទមានអាយុ ក្រាបទូលពួកជន អ្នកនៅក្នុងដែនមគធៈជា អ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើនូវកថារៀបរាប់នេះ ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ហើយក្រោកអំពីអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។

(២៨) កាលព្រះអានន្ទមានអាយុ ចេញទៅមិនយូរប៉ុន្មាន លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្បង់និងបាត្រចីវរក្នុងបុព្វណ្ហសម័យ ទ្រង់

ញាតិកំ បិណ្ឌាយ បាវិសិ ញាតិកេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ បាទេ បក្ខាលេត្វា គិញ្ជកាវសថំ បវិសិត្វា មាគធកេ បរិចារកេ អារព្ភ អត្ថិកត្វា មនសិកត្វា សព្វំ ចេតសោ(១) សមន្នាហរិត្វា បញ្ញត្តេ អាសនេ និសីទិ គតឹ នេសំ(២) ជានិស្សាមិ អភិសម្បរាយំ យំគតិកា តេ ភវន្តោ យំអភិសម្បរាយាតិ ។ អទ្ទសា ខោ ភគវា មាគធកេ បរិចារកេ យំគតិកា តេ ភវន្តោ យំអភិសម្បរាយា ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ គិញ្ជកាវសថា និក្ខមិត្វា វិហារបច្ឆាយាយំ(៣) បញ្ញត្តេ អាសនេ និសីទិ ។

(២៨) អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ

១ ឱ. សព្វចេតសោ ។ ឱ សព្វំ ចេតសា ។ ២ ឱ. តេសំ ។ ៣ ឱ. ម. វិហារបច្ឆាយាយំ ។



ទៅកាន់នាតិកគ្រាម ដើម្បីបិណ្ឌបាត លុះស្តេចទៅបិណ្ឌបាតក្នុងនាតិកគ្រាមហើយ ទ្រង់ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលខាងក្រោយនៃភត្ត ទ្រង់លាងព្រះបាទ ហើយស្តេចចូលទៅកាន់លំនៅ ដែលធ្វើដោយឥដ្ឋ ទ្រង់ប្រារព្ធពួកជនអ្នកមគធៈ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើឲ្យជាប្រយោជន៍ ទ្រង់ធ្វើទុកក្នុងព្រះហឫទ័យ ទ្រង់ពិចារណានូវហេតុទាំងអស់ដោយព្រះហឫទ័យ ហើយគង់លើអាសនៈ ដែលគេក្រាលថ្វាយ ទ្រង់ព្រះចិន្តាថា ពួកជនដ៏ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈ (គតិខាងមុខ) យ៉ាងណា តថាគត គប្បីដឹងនូវញាណគតិ និងអភិសម្បរាយៈ របស់ជនទាំងនោះ យ៉ាងនោះដែរ ។ ពួកជនដ៏ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈ យ៉ាងណា ព្រះមានព្រះភាគ ទ្រង់បានឃើញ នូវពួកជនអ្នកមគធៈជាអ្នកបម្រើព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យ៉ាងនោះដែរ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ទ្រង់ចេញអំពីលំនៅ ដែលធ្វើដោយឥដ្ឋ ទៅគង់លើអាសនៈដែលគេក្រាលថ្វាយ នៅត្រង់ម្លប់នៃវិហារ ។

[២៨] លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរ

ភគវន្តំ ឯតទវោច ឧបសន្តបតិស្សោ(១) ភន្តេ ភគវា ភាតិរិវ ភគវតោ មុខវណ្ណោ វិប្បសន្នត្តា ឥន្ទ្រិយានំ សន្តេន នូនជ្ជ ភន្តេ ភគវា វិហារេន វិហាសីតិ ។ យទេវ ខោ មេ ត្វំ អានន្ទ មាគធកេ បរិចារកេ អារព្ភ សម្មុខា បរិកថំ កត្វា ឧដ្ឋាយាសនា បក្កន្តោ តទេវាហំ ញាតិកេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ បាទេ បក្ខាលេត្វា គិញ្ជកាវសថំ បវិសិត្វា មាគធកេ បរិចារកេ អារព្ភ អដ្ឋិំ កត្វា មនសិកត្វា សព្វំ ចេតសោ សមន្នាហរិត្វា បញ្ញត្តេ អាសនេ និសីទឹ គតឹ នេសំ ជានិស្សាមិ អភិសម្បរាយំ យំគតិកា តេ ភវន្តោ យំអភិសម្បរាយាតិ ។ អទ្ទសំ ខោ អហំ អានន្ទ មាគធកេ

១ ម. ឧបសន្តប្បទិស្សោ ។



ហើយ ទើបក្រាបបង្គំទូល ព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ឃើញដូចជាស្ងប់ស្ងាត់ សម្បុរព្រះភក្ត្រ នៃព្រះមានព្រះភាគ ទ្រង់រឿងរុងស្រស់ប្រិម ឥន្ទ្រិយក៏ជ្រះថ្លា យ៉ាងនេះពេស បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃនេះ ប្រហែលជា ព្រះមានព្រះភាគ ទ្រង់គង់នៅ ដោយវិហារធម៌ដ៏ស្ងប់ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកប្រារព្ធពួកជនអ្នកមគធៈ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើនូវកថាជៀវពាក់ ចំពោះមុខតថាគត រួចក្រោកអំពីអាសនៈ ចេញទៅក្នុងកាលណា កាលនោះ តថាគត ក៏ត្រាច់ទៅបិណ្ឌបាត ក្នុងនាទិកគ្រាម លុះត្រឡប់មកពីបិណ្ឌបាត ក្នុងកាលខាងក្រោយនៃភត្ត លាងនូវបាទា ហើយចូលទៅកាន់សាលា ដែលធ្វើដោយឥដ្ឋ បានប្រារព្ធពួកជនអ្នកមគធៈជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងចិត្ត ពិចារណាដោយហេតុទាំងអស់ដោយចិត្តដែរ ហើយអង្គុយលើអាសនៈដែលគេក្រាលគិតថា ពួកជនដ៏ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈយ៉ាងណា តថាគត ក៏ដឹងនូវគតិ និងអភិសម្បរាយៈ របស់ជនទាំងនោះ យ៉ាងនោះដែរ ម្នាលអានន្ទ ពួកជនដ៏ចម្រើននោះ មានគតិយ៉ាងណា មានអភិសម្បរាយៈ យ៉ាងណា តថាគត បានឃើញពួកជនអ្នកមគធៈ

បរិចារកោ យំគតិកា តេ ករិត្វា យំអភិសម្បរាយា អថខោ អានន្ទ អន្តរហិតោ យក្ខោ សទ្ទមនុស្សាវេសិ ជនវសភោ អហំ ភគវា ជនវសភោ អហំ សុគតាតិ អភិជានាសិ នោ ត្វំ អានន្ទ ឥតោ បុព្វេ ឯវរូបំ នាមធេយ្យំ សុតំ(១) យទិទំ ជនវសភោតិ ។ ន ខោ អហំ ភន្តេ អភិជានាមិ ឥតោ បុព្វេ ឯវរូបំ នាមធេយ្យំ សុតំ យទិទំ ជនវសភោតិ អបិច មេ ភន្តេ លោមានិ ហដ្ឋានិ ជនវសភោតិ នាមធេយ្យំ សុត្វា តស្ស មយ្ហំ ភន្តេ ឯតទហោសិ ន ហិ នូន សោ ឱរកោ យក្ខោ ភវិស្សតិ យទិទំ ឯវរូបំ នាមធេយ្យំ សុបញ្ញត្តំ យទិទំ ជនវសភោតិ ។ អន្តរ(២) ខោ អានន្ទ សទ្ទស្ស បាតុភាវេ(៣) ឧឡារវណ្ណោ មេ(៤) យក្ខោ សម្មុខេ បាតុរហោសិ ទុតិយម្បិ សទ្ទមនុស្សាវេសិ ពិម្ពិសារោ អហំ ភគវា ពិម្ពិសារោ

១ ម. សុតា ។ ២ ម. ម. អនន្តរា ។ ៣ ម. ម. សទ្ទបាតុភាវា ។ ៤ ម. សោ មេ ។



ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ យ៉ាងនោះដែរ ម្នាលអានន្ទ ស្រាប់តែមានយក្ស មានខ្លួនកំបាំងមិនច្បាស់ មកស្រែកបន្លឺសំឡេងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ឈ្មោះជនវសភៈ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ឈ្មោះជនវសភៈ ម្នាលអានន្ទ ក្នុងកាលមុនអំពីកាលនេះ អ្នកធ្លាប់បានឮឈ្មោះថា ជនវសភៈ យ៉ាងនេះដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុនអំពីកាលនេះ ខ្ញុំព្រះអង្គ មិនធ្លាប់បានឮឈ្មោះថា ជនវសភៈ យ៉ាងនេះទេ បពិត្រព្រះអង្គដ៏ចម្រើន តែរោមរបស់ខ្ញុំព្រះអង្គ ក៏ព្រឺព្រួចឡើង ព្រោះបានឮឈ្មោះថា ជនវសភៈ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះ ដូច្នេះថា យក្សនោះ មិនមែនជាយក្សទាបថោកឡើយ មានឈ្មោះថា ជនវសភៈ មានសភាពយ៉ាងនេះ ជាឈ្មោះដែលគេបញ្ញត្តហើយដោយល្អ ។ ម្នាលអានន្ទ សូរសព្ទសំឡេងកើតប្រាកដហើយក្នុងទីនោះ យក្សមានសម្បុរដ៏លើសលប់មកប្រាកដ ក្នុងទីចំពោះមុខតថាគត ស្រែកបន្លឺសំឡេងជាគម្រប់ពីរដងថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ ឈ្មោះពិម្ពិសារៈ

អហំ សុគត ឥតិ សត្តមំ ខោ អហំ ភន្តេ វេស្ស-វណស្ស មហារាជស្ស សហព្យតំ ឧបបន្នាមិ(១) សោ ឥតោ(២) ចុតោ មនុស្សេសុ រាជា ភវិតុំ បហោមិ(៣) ។

(៣០) ឥតោ សត្ត តតោ សត្ត
សំសារានិ(៤) ចតុទ្ទស
និវាសមភិជានាមិ
យត្ថ មេ វុសិតំ បុរេ ។

ទីឃរត្តំ ខោ អហំ ភន្តេ អវិនិបាតោ អវិនិបា-តំ សញ្ជានាមិ អាសា ច បន មេ សន្តិដ្ឋតិ

១ ឱ. ឧប្បន្នាម្ហិ ។ ២ ឱ. ម. ឥតោ ។ ៣ ឱ. មនុស្សរាជា អមនុស្សរាជា ទី ហោមិ ។ ៤ ឱ. ម. សំសារានិ ។



បពិត្រព្រះសុគត ខ្ញុំព្រះអង្គ ឈ្មោះជនវសភៈ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវ ខ្ញុំព្រះអង្គ បានទៅកើតជាគម្រប់៧នេះ ជាមួយនឹងមហារាជ ឈ្មោះវេស្សវណ លុះខ្ញុំព្រះអង្គ ច្យុតអំពីអត្តភាពនេះទៅហើយ ទៅកើតជាស្តេច ក្នុងពួកមនុស្ស ។

(៣០) ខ្ញុំព្រះអង្គ ច្យុតចាកទេវលោកនេះ៧ដង ច្យុតចាក
មនុស្សលោកនេះ ៧ ដង អន្ទោលទៅមកគ្រប់ជា ១៤ ដង
ពីដើមខ្ញុំព្រះអង្គ ធ្លាប់នៅក្នុងលំនៅណា ខ្ញុំព្រះអង្គ ក៏ស្គាល់
ច្បាស់នូវលំនៅនោះ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ជាបុគ្គលមិនធ្លាក់ចុះ ដឹងច្បាស់នូវដំណើរមិនធ្លាក់ចុះអស់កាលជាអង្វែង តាំងសេចក្តីប៉ុនប៉ង់របស់ខ្ញុំព្រះអង្គ

សកទាគាមិតាយាតិ ។ អច្ឆរិយមិទំ អាយស្មតោ ជនវសភស្ស យក្ខស្ស អព្ភុតមិទំ អាយស្មតោ ជនវសភស្ស យក្ខស្ស ទីឃរត្តំ ខោ អហំ ភន្តេ អវិនិបាតោ អវិនិបាតំ សញ្ជានាមីតិ បវេទេសិ(១) អាសា ច បន មេ សន្តិដ្ឋតិ សកទាគាមិតាយាតិ បវេទេសិ(២) កុតោនិទានំ បនាយស្មា ជនវសភោ យក្ខោ ឯវរូបំ ឧឡារំ វិសេសាធិគមំ សញ្ជានាតីតិ ។ ន អញ្ញត្រ ភគវតោ សាសនា

១-២ ម. ឱ. បវេទេសិ ។



ដើម្បីសកទាគាមិមគ្គ ក៏តាំងនៅល្អ ។ ជនវសភយក្សក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ជាបុគ្គលមិនធ្លាក់ចុះ ដឹងច្បាស់នូវដំណើរមិនធ្លាក់ចុះ អស់កាលជាអង្វែងដូច្នេះក្តី(១) ក្រាបទូលថា សេចក្តីប៉ុនប៉ងរបស់ខ្ញុំព្រះអង្គ ដើម្បីសកទាគាមិមគ្គ ក៏តាំងនៅល្អដូច្នេះក្តី(២) ជនវសភយក្សមានអាយុ ចុះឈ្មោះថា ស្គាល់នូវកិរិយាត្រាស់ដឹង នូវគុណវិសេសដ៏លើសលប់ មានសភាពយ៉ាងនេះ ព្រោះហេតុណា ហេតុនេះជាអស្ចារ្យ របស់ជនវសភយក្សមានអាយុ ហេតុនេះ ជាហេតុចំឡែករបស់ជនវសភយក្សមានអាយុ ។ ជនវសភយក្ស ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ មិនមែនជាខាងក្រៅសាសនា របស់ព្រះអង្គទេ

១ ពាក្យជនវសភយក្ស ក្រាបទូលអំពីព្រះជិនស្រីដែលខ្លួនបានសោតាបត្តិផល ជាអវិនិបាតបុគ្គល ជាបុគ្គលមិនធ្លាក់ទៅក្នុងអបាយ ។ ២ ពាក្យជនវសភយក្សក្រាបទូលព្រះអំពីការដែលខ្លួនបានសោតាបត្តិផលហើយ តែមិនប្រមាទលក់នៅក្នុងសោតាបត្តិផលនោះទេ មានព្យាយាមប្រាថ្នាដើម្បីបាននូវសកទាគាមិមគ្គតទៅទៀត ។

ន អញ្ញត្រ សុគត តវ សាសនា យទគ្គេ អហំ ភន្តេ ភគវតិ ឯកន្តគតោ(១) អភិប្បសន្នោ តទគ្គេ អហំ ភន្តេ ទីឃរត្តំ អវិនិបាតោ អវិនិបាតំ សញ្ជានាមិ អាសា ច បន មេ សន្តិដ្ឋតិ សកទាគាមិតាយ ឥទាហំ ភន្តេ វេស្សវណេន មហារាជេន បេសិតោ វិរូឡ្ហកស្ស មហា-រាជស្ស សន្តិកេ កេនចិទេវ ករណីយេន អទ្ទសំ ភ-គវន្តំ អន្តរាមគ្គេ គិញ្ជកាវសថំ បវិសិត្វា មាគធកេ បរិចារកេ អារព្ភ អដ្ឋិកត្វា មនសិកត្វា សព្វំ ចេត-សោ សមន្នាហរិត្វា និសិន្នំ គតឹ ទេសំ(២) ជានិស្សាមិ អភិសម្បរាយំ យំគតិកា តេ ភវន្តោ យំអភិសម្បរា-យាតិ អច្ឆរិយំ ចោ បនេតំ ភន្តេ យំ វេស្សវណស្ស ម-ហារាជស្ស តស្ស(៣) បរិសាយំ ភាសតោ សម្មុខា បដិគ្គ-ហិតំ(៤) យំគតិកា តេ ភវន្តោ យំអភិសម្បរាយាតិ

១ ឱ. ឯកន្តគតោ ។ ម ឯកន្តិកតោ ។ ២ ឱ. ទេសិ ។ ៣ ឱ. យំ ។ ៤ ឱ. សម្មុខា សុតំ សម្មុខា បដិគ្គហិតំ ។



បពិត្រព្រះសុគត ខ្ញុំព្រះអង្គមិនមែនជាអ្នកក្រៅសាសនា របស់ព្រះអង្គទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានជ្រះថ្លា ចំពោះព្រះមានព្រះភាគ ដោយពិតជាប់ចូលក្នុងថ្ងៃណា បពិត្រព្រះអង្គដ៏ចម្រើន តាំងតែពីថ្ងៃនោះជាដើម ខ្ញុំព្រះអង្គ ជាបុគ្គលមិនធ្លាក់ចុះ ដឹងច្បាស់នូវដំណើរមិនធ្លាក់ចុះអស់កាលជាអង្វែង តាំងសេចក្ដីប៉ុនប៉ង របស់ខ្ញុំព្រះអង្គ ដើម្បីសកទាគាមិមគ្គ ក៏តាំងនៅល្អ បពិត្រព្រះអង្គដ៏ចម្រើន វេស្សវណមហារាជ ប្រើខ្ញុំព្រះអង្គ ទៅក្នុងសម្នាក់វិរូឡ្ហកមហារាជ ដោយកិច្ចនីមួយក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គបាន ឃើញព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់លំនៅដែលធ្វើដោយឥដ្ឋ ត្រង់ពាក់កណ្ដាលផ្លូវ ទ្រង់ប្រារព្ធពួកជនអ្នកមគធៈ ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយធ្វើឲ្យជាប្រយោជន៍ ធ្វើទុកក្នុងព្រះហឫទ័យ ពិចារ-ណានូវហេតុទាំងអស់ ដោយព្រះហឫទ័យ ហើយទ្រង់គង់នៅ ទ្រង់ព្រះចិន្ដាថា អ្នកដ៏ចម្រើនទាំងនោះ មានគតិយ៉ាងណា មានអភិសម្បរាយៈយ៉ាងណា គឺជាជន ក៏ដឹងនូវគតិ និងអភិសម្បរាយៈ របស់ជនទាំងនោះយ៉ាងនោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យណា ដែលខ្ញុំព្រះអង្គ បានទទួល នឹងបានស្ដាប់ ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះវេស្សវណមហារាជ ទ្រង់មានព្រះបន្ទូល ក្នុងកណ្ដាលបរិស័ទនោះថា អ្នកដ៏ចម្រើនទាំងនោះ មានគតិយ៉ាងណា មានអភិសម្បរាយៈយ៉ាងណាដូច្នេះ ពាក្យនេះជាអស្ចារ្យដែរ

តស្ស មយ្ហំ ភន្តេ ឯតទហោសិ ភគវន្តញ្ច ទក្ខាមិ ឥទញ្ច ភគវតោ អារោចេស្សាមីតិ(១) ឥមេ ខោ មេ(២) ភន្តេ ទ្វេ បច្ចយា ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ បុរិមានិ ភន្តេ ទិវសានិ បុរិមតរានិ តទហុបោសថេ បណ្ណរសេ វស្សូបនាយិកាយ បុណ្ណមាយ(៣) រត្តិយា កេវលកប្បា ច ទេវា តាវតិំសា សុធម្មាយំ សភាយំ សន្និសិន្នា ហោន្តិ សន្និបតិតា មហតី ច ទិព្វបរិសា សមន្តតោ និសិន្នា(៤) ហោន្តិ ចត្តារោ ច មហារាជានោ(៥) ចតុទ្ទិសា និសិន្នា ហោន្តិ បុរត្ថិមាយ ទិសាយ ធតរដ្ឋោ មហារាជា បច្ឆិមាភិមុខោ និសិន្នោ ហោតិ ទេវេហិ(៦) បុរក្ខត្វា ទក្ខិណាយ ទិសាយ វិរូឡ្ហកោ មហារាជា ឧត្តរាភិមុខោ និសិន្នោ ហោតិ ទេវេហិ បុរក្ខត្វា បច្ឆិមាយ ទិសាយ វិរូបក្ខោ មហារាជា បុរត្ថិមាភិមុខោ និសិន្នោ ហោតិ ទេវេហិ បុរក្ខត្វា ឧត្តរាយ ទិសាយ វេស្សវណោ មហារាជា ទក្ខិណាភិមុខោ និសិន្នោ

១ ទ. អារោចេយ្យាមីតិ ។ ២ ទ. មេតិ ន ទិស្សតិ ។ ៣ ទ. ម. បុណ្ណាយ បុណ្ណមាយ ។ ៤ ម. សន្និសិន្នា ។ ៥ ទ. មហារាជា ។ ៦ ទ. ម. ទេវេ ។



បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញ នឹងបានឃើញ ព្រះមានព្រះភាគ នឹងបានក្រាបទូលពាក្យនេះ ចំពោះព្រះមានព្រះភាគផង បពិត្រព្រះអង្គដ៏ចម្រើន ហេតុទាំងពីរ(១) នេះឯង ដែលជាហេតុនាំឲ្យខ្ញុំព្រះអង្គ បានចូលមកឃើញ ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃពីមុន ១ មក ពួកទេវតាទាំងអស់ ដែលបានកើតក្នុងឋានតាវត្តិង្ស ក្នុងវេលាប្រជុំគ្នាក្នុងរោងសុធម្មា ក្នុងរាត្រី មានព្រះចន្ទពេញវង់ ជាថ្ងៃដែលចូលវស្សា គឺថ្ងៃឧបោសថទី ១៥ ទាំងទេវតាជាច្រើន អង្គុយព្រៀបត្រាជុំវិញ មហារាជទាំង ៤ គឺគង់នៅគ្រប់ទិសទាំង ៤ គឺ មហារាជ ឈ្មោះធតរដ្ឋៈ គង់ក្នុងទិសខាងកើត បែរព្រះភក្ត្រ ទៅទិសខាងលិច មានពួកទេវតា ហែហមជាបរិវារ មហារាជ ឈ្មោះវិរូឡ្ហកៈ គង់ក្នុងទិសខាងត្បូង បែរព្រះភក្ត្រ ទៅទិសខាងជើង មានពួកទេវតា ហែហមជាបរិវារ មហារាជ ឈ្មោះវិរូបក្ខៈ គង់ក្នុងទិសខាងលិច បែរព្រះភក្ត្រ ទៅទិសខាងកើត មានពួកទេវតា ហែហមជាបរិវារ មហារាជ ឈ្មោះវេស្សវណ្ណ គង់ក្នុងទិសខាងជើង បែរព្រះភក្ត្រ ទៅទិសខាងត្បូង

១ ហេតុដែលបានឃើញព្រះមានព្រះភាគជាទីពេញចិត្ត ១ ហេតុដែលមានប្រាថ្នា ដើម្បីក្រាបទូលពាក្យ ដែលបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះវេស្សវណ្ណមហារាជ ១ ។

ហោតិ ទេវេហិ បុរក្ខត្វា ។ យទា ភន្តេ កេវលកប្បា ច ទេវា តាវត្តិំសា សុធម្មាយំ សភាយំ និសិន្នា(១) ហោន្តិ សន្និបតិតា មហតី ច ទិព្វបរិសា សមន្តតោ និសិន្នា ហោន្តិ ចត្តារោ ច មហារាជានោ ចតុទ្ទិសា និសិន្នា ហោន្តិ ។ ឥទំ នេសំ ហោតិ អាសនស្មឹ អថ បច្ឆា អម្ហាកំ អាសនំ ហោតិ ។ យេ តេ ភន្តេ ទេវា ភគវតិ ព្រហ្មចរិយំ ចរិត្វា អធុនូបបន្នា(២) តាវត្តិំសកាយំ តេ អញ្ញេ ទេវេ អតិវិរោចន្តិ(៣) វណ្ណេន ចេវ យសសា ច ។ តេន សុទំ ភន្តេ ទេវា តាវត្តិំសា អត្តមនា ហោន្តិ បមុទិតា បីតិសោមនស្សជាតា ទិព្វា វត ភោ កាយា បរិបូរេន្តិ ហាយន្តិ អសុរកាយាតិ ។ អថ ខោ ភន្តេ សក្កោ ទេវានមិន្ទោ ទេវានំ តាវត្តិំសានំ សម្បសាទំ វិទិត្វា ឥមាហិ គាថាហិ អនុមោទិ

---

១ ឱ. ម. សន្និសិន្នា ។ ២ ឱ. អធុនុប្បន្នា ។ ៣ ឱ. ម. អតិរោចន្តិ ។



មានពួកទេវតា ចោមរោមជាបរិវារ បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតា ដែលនៅក្នុងឋានតាវត្តិង្សទាំងអស់ អង្គុយប្រជុំគ្នា ក្នុងរោងសុធម្មា ទាំងទេវបរិសទ្យជាច្រើន ក៏អង្គុយត្រៀបត្រាជុំវិញ មហារាជទាំង ៤ ក៏អង្គុយក្នុងទិសទាំង ៤ នេះជាអាសនៈ របស់មហារាជទាំង ៤ នោះ ឯអាសនៈរបស់យើងទាំងឡាយ នៅខាងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណា បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ នៃព្រះមានព្រះភាគ ហើយទៅកើតក្នុងពួកទេវតា ដែលនៅក្នុងឋានតាវត្តិង្ស ក្នុងកាលឥឡូវនេះ ពួកទេវតានោះ រមែងរុងរឿងជាងពួកទេវតាឯទៀត ដោយសម្បុរផង ដោយយសផង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានឮថា ពួកតាវត្តិង្សទេវតា មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សឡើងថា អើហ្ន៎ ពួកទិព្វកាយ នៅបរិបូណ៌ ពួកអសុរកាយ សាបសូន្យទៅ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ព្រះឥន្ទ្រជាធំជាងទេវតាទាំងឡាយ ជ្រាបនូវសេចក្តីជ្រះថ្លា របស់ពួកតាវត្តិង្សទេវតា ហើយ ក៏អនុមោទនា ដោយគាថាទាំងឡាយ នេះថា

ធនវិសេសសុត្តេ សក្កស្ស អនុមោទនគាថា

[៣១] មោទន្តិ វត ភោ ទេវា
តាវត្តិំសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតំ ។
នវេ ច ទេវេ បស្សន្តា
វណ្ណវន្តេ យសស្សិនោ(១)
សុគតស្មឹ ព្រហ្មចរិយំ
ចរិត្វាន ឥធាគតេ ។
តេ អញ្ញេ អតិរោចន្តិ
វណ្ណេន យសសាយុនា
សាវកា ភូរិបញ្ញស្ស
វិសេសូបគតា ឥធ ។
ឥទំ ទិស្វាន នន្ទន្តិ
តាវត្តិំសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតន្តិ ។

១ ម. យសស្សិនេ ។



ធនវិសេសសូត្រ អនុមោទនាគាថា របស់សក្កទេវរាជ

(៣១) អើហ្ន៎ ទេវតាទាំងឡាយ ដែលនៅក្នុងឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ នមស្ការ ចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង តែងធ្វើចិត្តឲ្យរីករាយ ។ ពួកតាវត្តិង្សទេវតា បានឃើញពួកទេវតាថ្មីៗដែលមានសម្បុរល្អ មានយស មកក្នុងទីនេះបាន ព្រោះប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ព្រះសុគត ។ ពួកទេវតានោះ រុងរឿងជាងពួកទេវតាឯទៀត ដោយសម្បុរល្អ ដោយយសនិងអាយុ ពួកសាវ័ករបស់ព្រះសម្ពុទ្ធ មានប្រាជ្ញាដូចជាផែនដី ជាសាវ័កវិសេស បានចូលមកហើយ ក្នុងទីនេះ ។ ពួកតាវត្តិង្សទេវតា ព្រមទាំងព្រះឥន្ទ នមស្ការ ចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង តែងធ្វើចិត្តឲ្យត្រេកអរ ព្រោះឃើញហេតុនេះ ។

[៣៦] តេន សុទំ ភន្តេ ទេវា តាវតឹសា ភិយ្យោសោ មត្តាយ អត្តមនា ហោន្តិ បមុទិតា បីតិសោមនស្សជាតា ទិព្វា វត ភោ កាយា បរិបូរេន្តិ ហាយន្តិ អសុរកាយាតិ អថខោ ភន្តេ យេនត្ថេន ទេវា តាវតឹសា សុធម្មាយំ សភាយំ សន្និសិន្នា ហោន្តិ សន្និបតិតា តំ អត្ថំ ចិន្តយិត្វា តំ អត្ថំ មន្តយិត្វា វុត្តវចនាបិ តំ(១) ចត្តារោ មហារាជានោ តស្មឹ អត្ថេ ហោន្តិ បច្ចនុសិដ្ឋវចនាបិ តំ(២) ចត្តារោ មហារាជានោ តស្មឹ អត្ថេ ហោន្តិ សកេសុ សកេសុ(៣) អាសនេសុ ឋិតា អវិបក្កន្តា(៤) ។

តេ វុត្តវាក្យា រាជានោ
បដិគ្គយ្ហានុសាសនឹ
វិប្បសន្នមនា សន្តា
អដ្ឋំសុ សម្ហិ អាសនេ ។

---

១ ម. វុត្តវចនា នាមិទំ ។ ២ ម. បច្ចានុសិដ្ឋវចនា នាមិទំ ។ ៣ ឱ. សកេសុ ។ ៤ ម. អវិបក្កន្តា ។



(៣៦) បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជា ពួកតាវត្តិង្សទេវតា ក៏រីករាយមានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សទ្វេដងថា អើហ្ន៎ ពួកទិព្វកាយនៅបរិបូណ៌ ពួកអសុរកាយសាបសូន្យទៅ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកតាវត្តិង្សទេវតា អង្គុយប្រជុំគ្នា ក្នុងរោងសុធម្មា ដោយប្រយោជន៍ណា ក៏គិតនូវប្រយោជន៍នោះ(១) ប្រឹក្សានូវប្រយោជន៍នោះ (ជាមួយនឹងមហារាជទាំង ៤) មហារាជទាំង ៤ ដែលពួកតាវត្តិង្សទេវតា បាននិយាយដាស់តឿន ក្នុងប្រយោជន៍នោះផង មហារាជទាំង ៤ ដែលពួកតាវត្តិង្សទេវតា បាននិយាយប្រៀនប្រដៅ ក្នុងប្រយោជន៍នោះផង ក៏ឋិតនៅលើអាសនៈទាំងឡាយរបស់ ៗ ខ្លួន មិនចៀសចេញទៅឡើយ ។

ស្ដេចទាំងនោះ ដែលទេវបុត្តទាំងនោះ បាននិយាយដាស់
តឿនហើយ ក៏មានចិត្តជ្រះថ្លា ទទួលយកនូវពាក្យប្រៀន
ប្រដៅ ហើយក៏ឋិតនៅលើអាសនៈរបស់ខ្លួន ។

---

១ អដ្ឋកថា ថា ពួកតាវត្តិង្សទេវតា បានគិតនូវប្រយោជន៍ គឺ ការរក្សានូវកិច្ចសង្ឃដែល នៅក្នុងលោក ហើយប្រឹក្សាគ្នាមួយនឹងមហារាជទាំង ៤ ថា អ្នកទាំងឡាយ ចូរយាងទៅចែងការរក្សា កិច្ចសង្ឃ ដែលនៅក្នុងទីនេះខ្លះ ក្នុងទីនុះខ្លះ ។

(៣៣) អថខោ ភន្តេ ឧត្តរាយ ទិសាយ ឧឡារោ អាលោកោ សញ្ជាយិ ឱភាសោ បាតុរហោសិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ អថ ភន្តេ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹសេ អាមន្តេសិ យថា ខោ មារិសា និមិត្តា ទិស្សន្តិ អាលោកោ សញ្ជាយតិ ឱភាសោ បាតុភវតិ ព្រហ្មា បាតុភវិស្សតិ ព្រហ្មុនោ ហេតំ បុព្វនិមិត្តំ បាតុភាវាយ យទិទំ អាលោកោ សញ្ជាយតិ ឱភាសោ បាតុភវតីតិ ។

យថា និមិត្តា ទិស្សន្តិ
ព្រហ្មា បាតុភវិស្សតិ
ព្រហ្មុនោ ហេតំ បុព្វនិមិត្តំ(១)
ឱភាសោ វិបុលោ មហាតិ ។

(៣៤) អថ(២) ភន្តេ ទេវា តាវតឹសា យថាសកេសុ(៣) អាសនេសុ និសីទឹសុ ឱភាសមេតំ ញស្សាម យំវិបាកោ ភវិស្សតិ សច្ឆិកត្វាវ នំ គមិស្សាមាតិ ។ ចត្តារោបិ មហារាជានោ យថាសកេសុ អាសនេសុ

១. ម. និមិត្តំ ។ ២. ម. អថខោ ។ ៣. ម. សកេសុ ។





(៣៣) បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ ពន្លឺដ៏ធំទូលាយ កើតឡើងក្នុងទិសខាងជើង រស្មីមានប្រាកដហើយ កន្លងនូវទេវានុភាពរបស់ពួកទេវតា បពិត្រព្រះអង្គដ៏ចំរើន លំដាប់នោះ ព្រះឥន្ទ្រជាធំ ជាងពួកទេវតា ត្រាស់ហៅនូវពួកតាវត្តិង្សទេវតាមកថា ម្នាលត្រាយ៉ន៍ទាំងឡាយ និមិត្តទាំងឡាយប្រាកដឡើង ពន្លឺកើតព្រម រស្មីមានប្រាកដដោយប្រការណា ព្រហ្មមុខជានឹងមានមកប្រាកដ ដោយប្រការនោះ ព្រោះថាពន្លឺកើតព្រម រស្មីមានប្រាកដដោយហេតុណា ហេតុនុ៎ះ ជាបុព្វនិមិត្តរបស់ព្រហ្មដើម្បីមានប្រាកដ ។

និមិត្តទាំងឡាយ ប្រាកដឡើង ដោយប្រការណា ព្រហ្មមុខ
ជានឹងមានមកប្រាកដ ដោយប្រការនោះ រស្មីដ៏ធំទូលាយ
មានប្រាកដ នេះជាបុព្វនិមិត្តរបស់ព្រហ្ម ។

(៣៤) បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ ពួកតាវត្តិង្សទេវតា អង្គុយលើអាសនៈទាំងឡាយ របស់ខ្លួនៗ ហើយគិតថា យើងទាំងឡាយនឹងដឹងនូវរស្មីនេះ ផលនឹងមានដោយហេតុណា យើងទាំងឡាយ ស្គាល់ច្បាស់នូវហេតុនោះហើយសឹមទៅ ។ ឯមហារាជទាំង ៤ ក៏គង់លើអាសនៈ

និសីទិំសុ ឱកាសមេតំ ញស្សាម យំ វិបាកោ ភវិស្ស-
តិ សច្ឆិកត្វា វ នំ គមិស្សាមាតិ ។ ឥទំ សុត្វា ទេវា
តាវត្តឹសា ឯកគ្គា សមាបជ្ជឹសុ ឱកាសមេតំ ញស្សាម
យំ វិបាកោ ភវិស្សតិ សច្ឆិកត្វា វ នំ គមិស្សាមាតិ
យទា ភន្តេ ព្រហ្មា សនង្កុមារោ ទេវេហិ តាវត្តឹសេហិ
ទិស្សតិ ឱឡារិកំ អត្តភាវំ អភិនិម្មិនិត្វា ទិស្សតិ
យោ ខោ បន ភន្តេ ព្រហ្មុនោ បកតិវណ្ណោ អនភិ-
សម្ភវនីយោ សោ ទេវានំ តាវត្តឹសានំ ចក្ខុបថស្មឹ
យទា ភន្តេ ព្រហ្មា សនង្កុមារោ ទេវេហិ តាវត្តឹសេហិ
ទិស្សតិ សោ អញ្ញេ ទេវេ អតិរោចតិ វណ្ណេន ចេវ
យសសា ច សេយ្យថាបិ ភន្តេ សោវណ្ណោ វិគ្គហោ
មានុសំ វិគ្គហំ(១) អតិរោចតិ ឯវមេវ ខោ ភន្តេ
យទា ព្រហ្មា សនង្កុមារោ ទេវេហិ តាវត្តឹសេហិ
ទិស្សតិ សោ អញ្ញេ ទេវេ អតិរោចតិ វណ្ណេន ចេវ

១ ម. មនុស្សវិគ្គហំ ។



ទាំងឡាយរបស់ខ្លួន ដោយគិតថា យើងទាំងឡាយ នឹងដឹងនូវសេចក្តីនេះ
ផលដែលនឹងមានដោយហេតុណា យើងទាំងឡាយ ស្គាល់ច្បាស់នូវហេតុនោះ
ហើយសឹមទៅ ។ ពួកតាវត្តិង្សទេវតា បានឮពាក្យនេះហើយ ក៏មូលគំនិត
គ្នា នាំគ្នាឈប់ស្ងៀមដោយគិតថា យើងទាំងឡាយ នឹងដឹងនូវសេចក្តីនេះ
ផលដែលនឹងមានដោយហេតុណា យើងទាំងឡាយ ស្គាល់ច្បាស់នូវហេតុនោះ
ហើយសឹមទៅ បពិត្រព្រះអង្គដ៏ចំរើន ព្រហ្មឈ្មោះសនង្កុមារ មានមក
ប្រាកដ ដល់ពួកតាវត្តិង្សទេវតា ក្នុងកាលណា ក៏និម្មិតអត្តភាពដ៏លើស
លប់ មានមកប្រាកដក្នុងកាលនោះ បពិត្រព្រះអង្គដ៏ចំរើន សម្បុរជាប្រ-
ក្រតីណា របស់ព្រហ្ម ដែលពួកទេវតាមិនអាចឃើញ សម្បុរជាប្រក្រតី
នោះ រមែងប្រាកដមក ក្នុងគន្លងចក្ខុ របស់ពួកតាវត្តិង្សទេវតា បពិត្រ
ព្រះអង្គដ៏ចំរើន ព្រហ្មឈ្មោះសនង្កុមារ មានមកប្រាកដដល់ពួកតាវត្តិង្ស-
ទេវតា ក្នុងកាលណា ព្រហ្មនោះរុងរឿងជាងពួកទេវតាដទៃ ដោយសម្បុរ-
ផង ដោយយសផង ក្នុងកាលនោះ បពិត្រព្រះអង្គដ៏ចំរើន រូបដែលធ្វើពី
មាស រមែងរុងរឿងជាងរាងកាយ របស់មនុស្សធម្មតាយ៉ាងណាមិញ បពិត្រ
ព្រះអង្គដ៏ចំរើន សនង្កុមារព្រហ្ម មានមកប្រាកដ ដល់ពួកតាវត្តិង្សទេវតា
ក្នុងកាលណា ព្រហ្មនោះ រុងរឿងជាងពួកទេវតាដទៃ ដោយសម្បុរផង

យសសា ច យទា ភន្តេ ព្រហ្មា សនង្កុមារោ ទេវានំ តាវត្តិសានំ បាតុភវតិ ។ តស្សំ បរិសាយំ(១) យោ ច ទេវោ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ សព្វេវ តុណ្ហីភូតា បញ្ជលិកា បល្លង្កេ(២) និសីទន្តិ យស្សទានិ ទេវស្ស ឥច្ឆិស្សតិ ព្រហ្មា សនង្កុមារោ តស្ស ទេវស្ស បល្លង្កេ និសីទិស្សតិ(៣) យស្ស ខោ បន ភន្តេ ទេវស្ស ព្រហ្មា សនង្កុមារោ បល្លង្កេ និសីទតិ ឧឡារំ សោ លភតិ ទេវោ វេទប្បដិលាភំ ឧឡារំ សោ លភតិ ទេវោ សោមនស្សប្បដិលាភំ សេយ្យថាបិ ភន្តេ រាជា ខត្តិយោ មុទ្ធាវសិត្តោ អធុនាវសិត្តោ(៤) រជ្ជេន ឧឡារំ សោ លភតិ វេទប្បដិលាភំ ឧឡារំ សោ លភតិ សោមនស្សប្បដិលាភំ ឯវមេវ ខោ ភន្តេ យស្ស ទេវស្ស ព្រហ្មា សនង្កុមារោ បល្លង្កេ និសីទតិ ឧឡារំ សោ លភតិ ទេវោ វេទប្បដិលាភំ ឧឡារំ សោ លភតិ ទេវោ សោមនស្សប្បដិលាភំ អថ ភន្តេ ព្រហ្មា សនង្កុមារោ ឱឡារិកំ អត្តភាវំ អភិនិម្មិនិត្វា កុមារវណ្ណី ហុត្វា

១ ម. តស្ស បរិសាយំ ។ ២ ឱ. ម. បល្លង្កេន ។ ៣ ឱ. ម. និសីទិស្សតីតិ ។ ៤ ម. អធុនាភិសិត្តោតិបិ បាឋោ ។



ដោយយសផង ក្នុងកាលនោះដូច្នោះឯង បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម តែងមកប្រាកដ ដល់ពួកតាវត្តិង្សទេវតាក្នុងកាលណា ឥតមានទេវតាណាមួយ ក្នុងបរិស័ទនោះ សំពះ ឬក្រោកទទួល ឬអញ្ជើញដោយអាសនៈក្នុងកាលនោះឡើយ ពួកទេវតាទាំងអស់ស្ងៀមព្រងើយ ទាំងផ្គងអញ្ជលីអង្គុយលើបល្ល័ង្ក សនង្កុមារព្រហ្ម ប្រាថ្នាគង់អង្គុយលើបល្ល័ង្ក របស់ទេវតាណា ក៏គង់អង្គុយលើបល្ល័ង្ក របស់ទេវតានោះតាម បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មអង្គុយលើបល្ល័ង្ករបស់ទេវតាណា ទេវតានោះ រមែងបាននូវសេចក្តីត្រេកអរដ៏លើសលប់ ទេវតានោះ រមែងបាននូវសេចក្តីសោមនស្សដ៏លើសលប់ បពិត្រព្រះអង្គដ៏ចម្រើន ក្សត្រជាស្តេចដែលបានមុទ្ធាភិសេកហើយ ទើបនឹងអភិសេកហើយថ្មីៗ ស្តេចនោះរមែងបាននូវសេចក្តីត្រេកអរដ៏លើសលប់ ដោយរាជសម្បត្តិ ស្តេចនោះ រមែងបាននូវសេចក្តីសោមនស្សដ៏លើសលប់ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម អង្គុយលើបល្ល័ង្ករបស់ទេវតាណា ទេវតានោះ រមែងបាននូវសេចក្តីត្រេកអរ ដ៏លើសលប់ ទេវតានោះ រមែងបាននូវសេចក្តីសោមនស្សដ៏លើសលប់ មានឧបមេយ្យដូច្នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ សនង្កុមារព្រហ្ម បាននិម្មិតអត្តភាពដ៏លើសលប់ ជាភេទនៃកុមារ

បញ្ចសិខោ ទេវានំ តាវត្តឹសានំ បាតុរហោសិ សោ វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ បល្លង្កេន និសីទិ ។ សេយ្យថាបិ ភន្តេ ពលវា បុរិសោ សុបច្ចត្ថតេ វា បល្លង្កេ សមេ វា ភូមិភាគេ បល្លង្កេន និសីទេយ្យ ឯវមេវ ខោ ភន្តេ ព្រហ្មា សនង្កុមារោ វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ បល្លង្កេន និសីទិត្វា ទេវានំ តាវត្តឹសានំ សម្បសាទំ វិទិត្វា ឥមាហិ គាថាហិ អនុមោទិ

[៣៨] មោទន្តិ វត ភោ ទេវា
តាវត្តឹសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតំ ។
នវេ ច ទេវេ បស្សន្តា
វណ្ណវន្តេ យសស្សិនោ
សុគតម្ហិ(១) ព្រហ្មចរិយំ
ចរិត្វាន ឥធាគតេ ។

១ ម. ប. សុគតស្មឹ ។



ប្រហែលគ្នា នឹងបញ្ចសិខទេវបុត្ត(១) ហើយមកប្រាកដ ដល់ពួកតាវត្តិង្សទេវតា ព្រហ្មនោះហោះឡើងទៅកាន់អាកាស អង្គុយពែនភ្នែនក្នុងអាកាសវេហាស ។ បពិត្រព្រះអង្គដ៏ចំរើន បុរសមានកម្លាំង អង្គុយពែនភ្នែនលើបល្ល័ង្ក ដែលគេក្រាលល្អហើយ ឬលើភូមិភាគដ៏ស្មើ មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចំរើន សនង្កុមារព្រហ្ម ហោះទៅកាន់អាកាស អង្គុយពែនភ្នែន ក្នុងអាកាស វេហាស មានឧបមេយ្យដូច្នោះ ហើយជ្រាបច្បាស់សេចក្តីជ្រះថ្លា របស់ពួកតាវត្តិង្សទេវតា ក៏អនុមោទនា ដោយគាថាទាំងឡាយនេះថា

[៣៨] អើហ្ន៎ ពួកតាវត្តិង្សទេវតាព្រមទាំងព្រះឥន្ទ្រ នមស្ការ
ចំពោះព្រះតថាគតផង ចំពោះព្រះធម៌ដ៏ល្អផង ហើយរីក-
រាយ ។ ពួកតាវត្តិង្សទេវតា បានឃើញពួកទេវតា
ថ្មី ៗ ដែលមានសម្បុរល្អ មានយស មកក្នុងទីនេះបាន
ព្រោះប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ នៃព្រះសុគត ។

១ អដ្ឋកថា ថា ពួកទេវបុត្តទាំងអស់ រាប់អានចូលចិត្តនឹងអត្តភាពបញ្ចសិខទេវបុត្រណាស់ ព្រោះហេតុនោះ បានជាព្រហ្មនិម្មិតអត្តភាពដូច្នោះ ។

ជនវសភសុត្តំ សនង្កុមារអដ្ឋង្គសរកថា

តេ អញ្ញេ អតិរោចន្តិ
វណ្ណេន យសសាយុនា
សាវកា ភូរិបញ្ញស្ស
វិសេសូបគតា ឥធ ។
ឥទំ ទិស្វាន នន្ទន្តិ
តាវតឹសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតន្តិ ។

(៣៦) ឥមមត្ថំ ភន្តេ ព្រហ្មា សនង្កុមារោ អភាសិត្ថ[១] ។ ឥមមត្ថំ ភន្តេ ព្រហ្មុនោ សនង្កុមារស្ស ភាសតោ អដ្ឋង្គសមន្នាគតោ សរោ ហោតិ វិស្សដ្ឋោ ច វិញ្ញេយ្យោ ច មញ្ជុ ច សវនីយោ ច ពិន្ទុ ច អវិសារី ច គម្ភីរោ ច និន្នាទី ច ។ យថាបរិសំ ខោ បន ភន្តេ ព្រហ្មា សនង្កុមារោ សរេន ច វិញ្ញាបេតិ

១ ម. ភាសិត្ថ ។



ជនវសភសូត្រ ពោលអំពីសំឡេងមានអង្គ ៨ របស់សនង្កុមារព្រហ្ម

ពួកទេវតាថ្មីទាំងនោះ រមែងរុងរឿង ជាងពួកទេវតាឯទៀត ដោយសម្បុរកាយ ដោយយសនិងអាយុ ពួកទេវតាថ្មីទាំងនោះ ជាសាវ័ករបស់ព្រះសម្ពុទ្ធ មានប្រាជ្ញាដូចផែនដី ជាសាវ័កវិសេស បានចូលមកហើយក្នុងទីនេះ ។ ពួកតាវត្តិង្ស-ទេវតា ព្រមទាំងព្រះឥន្ទ្រ នមស្ការ ចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង ហើយធ្វើចិត្តឲ្យត្រេកអរ ព្រោះឃើញនូវហេតុនេះ ។

(៣៦) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះ មានសំឡេងប្រកបដោយអង្គ ៨ គឺ សំឡេងក្បោះក្បាយ ១ សំឡេងងាយយល់ ១ សំឡេងទន់ពីរោះ ១ សំឡេងគួរស្តាប់ ១ សំឡេងក្រលួច ១ សំឡេងមិនគ្រាវ ១ សំឡេងក្រអួន[១] ១ សំឡេងរំពង[២] ១ ។ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារ-ព្រហ្ម ញ៉ាំងបរិស័ទចំនួនប៉ុន្មានក៏ដោយ ឲ្យដឹងច្បាស់ដោយសំឡេងបាន

១ អដ្ឋកថា ថា សំឡេងឮកាន់តែជ្រៅឡើងទៅ ។ ២ សំឡេងលាន់ឮខ្ទរបស់សំឡេងផ្គរលាន់ និងសំឡេងសំពោរ ។

ន ចស្ស ពហិទ្ធា បរិសាយ ឃោសោ និច្ឆរតិ ។ យស្ស ខោ បន ភន្តេ ឯវំ អដ្ឋង្គសមន្នាគតោ សរោ ហោតិ សោ វុច្ចតិ ព្រហ្មស្សរោតិ ។ អថខោ ភន្តេ ព្រហ្មា សនង្កុមារោ តេត្តឹសេ អត្តភាវេ អភិនិម្មិនិត្វា ទេវានំ តាវតឹសានំ បច្ចេកបល្លង្កេ[១] និសីទិត្វា ទេវេ តាវតឹសេ អាមន្តេសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវតឹសា យាវញ្ចសោ ភគវា ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ យេ ហិ កេចិ ភោន្តោ[២] ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា សីលេសុ បរិបូរការិនោ តេ កាយស្ស ភេទា បរំ មរណា អប្បេកច្ចេ បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជន្តិ[៣] អប្បេកច្ចេ និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជន្តិ អប្បេកច្ចេ តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជន្តិ អប្បេកច្ចេ យាមានំ ទេវានំ សហព្យតំ ឧបបជ្ជន្តិ អប្បេកច្ចេ

១ ឱ. ម. បច្ចេកបល្លង្កេសុ ។ ២ ឱ. ម. ភោ ។ ៣ ឱ. ឧប្បជ្ជន្តិ ។



ឯសំឡេងរបស់ព្រហ្មនោះ មិនលាន់ឮចេញទៅខាងក្រៅបរិស័ទឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលណាមានសំឡេង ប្រកបដោយអង្គ ៨ យ៉ាងនេះ បុគ្គលនោះហៅថា មានសំឡេងដូចសំឡេងព្រហ្ម ។ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ សនង្កុមារព្រហ្ម និម្មិតអត្តភាពចំនួន ៣៣ គង់លើបល្ល័ង្កមួយ ៗ របស់ពួកតាវត្តិង្សទេវតា ហើយហៅពួកតាវត្តិង្សទេវតាមកថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ពួកតាវត្តិង្សទេវតា សម្គាល់ហេតុនោះ ដូចម្តេច ព្រះមានព្រះភាគ គង់ទ្រង់ប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអ្នកទាំងឡាយដ៏ចំរើន ពួកជនឯណាមួយដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ ជាទីពឹង ដល់នូវព្រះសង្ឃ ជាទីពឹង ធ្វើនូវការបំពេញក្នុងសីលទាំងឡាយ ហើយពួកជននោះ លុះទំលាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតាជាន់និម្មានរតី ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតា ជាន់តុសិត ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតា ជាន់យាមៈ

តាវតឹសានំ ទេវានំ សហព្យតំ ឧបបជ្ជន្តិ អប្បេក-ច្ចេ ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជន្តិ យេ សព្វនិហីនំ កាយំ បរិបូរេន្តិ តេ គន្ធព្វកាយំ បរិបូរេន្តីតិ ។

(៣៧) ឥទមត្ថំ ភន្តេ ព្រហ្មា សនង្កុមារោ អភា-សិត្ថ ។ ឥទមត្ថំ ភន្តេ ព្រហ្មស្ស សនង្កុមារស្ស ភាសតោ ឃោសោយេវ ទេវា មញ្ញន្តិ យ្វាយំ មម បល្លង្កេ ស្វាយំ ឯកោ ច ភាសតីតិ ។

ឯកស្មឹ ភាសមានស្មឹ
សព្វេ ភាសន្តិ និម្មិតា
ឯកស្មឹ តុណ្ហិមាសិនេ
សព្វេ តុណ្ហី ភវន្តិ តេ ។
តទស្សុ(១) ទេវា មញ្ញន្តិ
តាវតឹសា សហិន្ទកា
យ្វាយំ មម បល្លង្កស្មឹ ស្វាយំ(២)
ឯកោ ច(៣) ភាសតីតិ ។

១ ឱ. ម. តទាសុ ។ ២ ឱ. យោ អយំ. មម បល្លង្កេ សោយំ ។ ៣ ឱ. ម. វ ។



ខ្លះក៏មកកើតជាមួយនឹងពួកទេវតា ជាន់តាវត្តិង្ស ខ្លះក៏ទៅកើតជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិកា ពួកជនណាញ៉ាំងកាយទេវតា ដែលទន់ទាបជាងទេវតាទាំងអស់ឲ្យបរិបូណ៌ ពួកជនទាំងនោះ ក៏ញ៉ាំងពួកគន្ធព្វ(១)ឲ្យបរិបូណ៌ ។

(៣៧) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះ មានសំឡេងពីរោះ ពួកទេវតាសម្គាល់ថា ព្រហ្មណា អង្គុយលើបល្ល័ង្ករបស់អាត្មាអញ ព្រហ្មនោះ និយាយតែម្នាក់ឯង ។

កាលបើសនង្កុមារព្រហ្ម និយាយតែម្នាក់ឯង ព្រហ្មនិម្មិត(២)
ទាំងអស់ ក៏និយាយដែរ កាលបើសនង្កុមារព្រហ្មអង្គុយស្ងៀម
តែម្នាក់ឯង ព្រហ្មនិម្មិតទាំងអស់នោះ ក៏ស្ងៀមដែរ ។ ពួក
តាវត្តិង្សទេវតា ព្រមទាំងព្រះឥន្ទ្រ សម្គាល់សេចក្តីនោះថា
ព្រហ្មណា អង្គុយលើបល្ល័ង្ករបស់អាត្មាអញ ព្រហ្មនោះ
និយាយតែម្នាក់ឯង ។

១ បានសេចក្តីថា ជនដែលទៅកើតជាទេវបុត្តទន់ទាបជាងគេបំផុត ត្រឹមគន្ធព្វ ។
២ ព្រហ្មឯទៀតៗ សនង្កុមារព្រហ្ម បាននិម្មិតហើយ ។

(៣៨) អថខោ ភន្តេ ព្រហ្មា សនង្កុមារោ ឯកត្តេន(១) អត្តានំ ឧបសំហរិត្វា(២) ឯកត្តេន អត្តានំ ឧបសំហរិត្វា សក្កស្ស ទេវានមិន្ទស្ស បល្លង្កេ និសីទិត្វា ទេវេ តាវតិំសេ អាមន្តេសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវតិំសា យាវ សុបញ្ញត្តា-បីមេ(៣) តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ឥទ្ធិបាទា ឥទ្ធិពហុលី-ការាយ(៤) ឥទ្ធិវិសេវិតាយ(៥) ឥទ្ធិវិកុព្វនតាយ កតមេ ចត្តារោ ឥធ ភោ ភិក្ខុ ឆន្ទសមាធិប្បធានសង្ខារស-មន្នាគតំ ឥទ្ធិបាទំ ភាវេតិ វិរិយសមាធិប្បធានសង្ខារ-សមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ចិត្តសមាធិប្បធានសង្ខារ-សមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធាន-សង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ ឥមេ ខោ ភោ តេន

១ ម. ឯកត្តេ ។ ២ ម. ឧបសំហរិ ។ ៣ ម. សុបញ្ញត្តាវិមេ ។ ម. សុបញ្ញត្តាទិ-មេ ។ ៤ ម. ឥទ្ធិបហុតាយាតិ បាឋោ ភវិតព្វំ ។ ៥ ឥទ្ធិវិសេវិតាយាតិ វា ឥទ្ធិវិសវិតាយា-តិ វា ឥទ្ធិវិសវិតាយាតិ វា បាឋោ ។



(៣៨) បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្ម ប្រ-មូលខ្លួនដែលច្រើន ឲ្យមកជាខ្លួនតែមួយវិញ លុះប្រមូលខ្លួនដែលច្រើន ឲ្យមកជាខ្លួនតែមួយវិញហើយ ក៏អង្គុយលើបល្ល័ង្ក របស់ព្រះឥន្ទ្រ ជាធំជាងពួកទេវតា ហើយត្រាស់ហៅពួកតាវត្តិង្សទេវតា មកថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតា សម្គាល់សេចក្តីនោះ ដូចម្តេច ឥទ្ធិបាទទាំង៤នេះ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយដោយល្អ ដែលប្រព្រឹត្តទៅ ដើម្បីធ្វើឫទ្ធិឲ្យច្រើន ដើម្បីធ្វើឫទ្ធិឲ្យវិសេសឡើង ដើម្បីធ្វើឫទ្ធិឲ្យប្លែក ៗ ឥទ្ធិបាទទាំង៤នោះ តើដូចម្តេច ម្នាលអ្នកដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ចម្រើននូវឥទ្ធិបាទ ប្រកបដោយឆន្ទសមាធិ(១) និងបធាន-សង្ខារ(២) ចម្រើននូវឥទ្ធិបាទ ប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិបាទ ប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ចម្រើននូវឥទ្ធិ-បាទ ប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ម្នាលអ្នកដ៏ចម្រើន

១ សមាធិ មានឆន្ទៈជាហេតុ ។ ២ បធានសង្ខារ បានដល់សម្មប្បធានទាំង៤ ។

ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ ឥទ្ធិបាទា បញ្ញត្តា ឥទ្ធិពហុលីកតាយ ឥទ្ធិវិសវិតាយ ឥទ្ធិវិកុព្វនតាយ ។ យេ ហិ(១) កេចិ ភោ អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោសុំ សព្វេ តេ ឥមេសញ្ញេវ(២) ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភោ អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោស្សន្តិ សព្វេ តេ ឥមេសញ្ញេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ យេ ហិ កេចិ ភោ ឯតរហិ សមណា វា ព្រាហ្មណា វា អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោន្តិ សព្វេ តេ ឥមេសញ្ញេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ។ បស្សន្តិ នោ ភោន្តោ តេវ តាវត្តឹសា មមយិទំ ឯវរូបំ ឥទ្ធានុភាវន្តិ ។ ឯវំ មហាព្រហ្មេតិ(៣) ។ អហំបិ

១ ឱ. យេហិ ។ ២ ឱ. ឥមេសំយេវ ។ ៣ ឱ. ព្រហ្មេតិ ។



ឥទ្ធិបាទទាំង ៤ នេះឯង ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយ រមែងប្រព្រឹត្តទៅ ដើម្បីធ្វើឫទ្ធិឲ្យច្រើន ដើម្បីធ្វើឫទ្ធិឲ្យវិសេសឡើង ដើម្បីធ្វើឫទ្ធិឲ្យប្លែកៗ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកជនណានីមួយ ទោះបីជាសមណៈឬព្រាហ្មណ៍ បានសំដែងនូវឥទ្ធិវិធៈ(១)មានច្រើនប្រការ ក្នុងអតីតកាល ពួកជនទាំងអស់នោះបានហើយ ព្រោះបានចម្រើននូវឥទ្ធិបាទទាំង៤នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង៤នេះឯង ឲ្យច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកជនណានីមួយ ទោះបីជាសមណៈឬព្រាហ្មណ៍ ដែលនឹងបាននូវឥទ្ធិវិធៈ មានច្រើនប្រការ ក្នុងអនាគតកាល ពួកជនទាំងអស់នោះក៏នឹងបាន ព្រោះបានចម្រើននូវឥទ្ធិបាទទាំង ៤ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ៤ នេះឯង ឲ្យច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកជនណានីមួយ ទោះបីជាសមណៈឬព្រាហ្មណ៍ រមែងបាននូវឥទ្ធិវិធៈ មានច្រើនប្រការ ក្នុងបច្ចុប្បន្ននេះ ពួកជនទាំងអស់នោះក៏រមែងបាន ព្រោះបានចម្រើននូវឥទ្ធិបាទទាំង ៤ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ៤ នេះឯង ឲ្យច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតាឃើញឫទ្ធានុភាព មានសភាពដូច្នេះ របស់យើងដែរឬទេ ។ ពួកទេវតាឆ្លើយតបថា បពិត្រមហាព្រហ្ម អើ ឃើញដែរ ។ សនង្កុមារព្រហ្ម និយាយថា

១ ចំណែកនៃឫទ្ធិ ។

ទោ ភោ ឥមេសំយេវ ចតុន្នំ ឥទ្ធិបាទានំ ភាវិតត្តា ពហុលីកតត្តា ឯវំមហិទ្ធិកោ ឯវំមហានុភាវោតិ ។

(៣៩) ឥទមត្ថំ ភន្តេ ព្រហ្មា សនង្កុមារោ អភាសិត្ថ ។ ឥទមត្ថំ ភន្តេ ព្រហ្មា សនង្កុមារោ ភាសិត្វា ទេវេ តាវត្តឹសេ អាមន្តេសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវត្តឹសា យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តយោ ឱកាសាធិគមា អនុពុទ្ធា សុខស្សាធិគមាយ ។ កតមេ តយោ ។

(៤០) ឥធ ភោ ឯកច្ចោ សំសដ្ឋោ វិហរតិ កាមេហិ សំសដ្ឋោ អកុសលេហិ ធម្មេហិ ។ សោ អបរេន សមយេន អរិយធម្មំ សុណាតិ យោនិសោ មនសិករោតិ ធម្មានុធម្មំ បដិបជ្ជតិ ។ សោ អរិយធម្មស្សវនំ(១) អាគម្ម យោនិសោ មនសិការំ

១ ឱ. ម. អរិយធម្មសវនំ ។



ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ឯខ្ញុំបានជាមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ព្រោះបានចម្រើននូវឥទ្ធិបាទទាំង ៤ នេះឯង ព្រោះបានធ្វើនូវឥទ្ធិបាទទាំង ៤ នេះឯង ឲ្យច្រើន ។

(៣៩) ជនវសភយក្ស ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះហើយ ក៏ពោលនឹងពួកតាវត្តិង្ស-ទេវតាថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិង្សទេវតា សំគាល់សេចក្តីនោះដូចម្តេច ត្រង់ដែលថា ការបាននូវឱកាស ៣ យ៉ាង ដើម្បីបាននូវសេចក្តីសុខ(១) ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់ដឹងហើយ ។ ការបាននូវឱកាស ៣ យ៉ាង តើដូចម្តេច ។

(៤០) ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះជាប់ចំពាក់ដោយកាមទាំងឡាយ ជាប់ចំពាក់ដោយអកុសលធម៌ទាំងឡាយ ។ សម័យជាខាងក្រោយមក បុគ្គលនោះ បានស្តាប់នូវអរិយធម៌ ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ។ លុះបុគ្គលនោះអាស្រ័យការស្តាប់អរិយធម៌ អាស្រ័យការធ្វើទុកក្នុងចិត្តដោយឧបាយ

១ អដ្ឋកថា ថា សេចក្តីសុខក្នុងឈាន សេចក្តីសុខក្នុងមគ្គ សេចក្តីសុខក្នុងផល ។

ធម្មានុធម្មំ បដិបន្នោ(១) អសំសដ្ឋោ វិហរតិ កាមេហិ អសំសដ្ឋោ អកុសលេហិ ធម្មេហិ ។ តស្ស អសំសដ្ឋស្ស កាមេហិ អសំសដ្ឋស្ស អកុសលេហិ ធម្មេហិ ឧប្បជ្ជតិ សុខំ សុខា ភិយ្យោ សោមនស្សំ ។ សេយ្យថាបិ ភោ បមុទា បាមោជ្ជំ(២) ជាយេថ ឯវមេវ ខោ ភោ អសំសដ្ឋស្ស កាមេហិ អសំសដ្ឋស្ស អកុសលេហិ ធម្មេហិ ឧប្បជ្ជតិ សុខំ សុខា ភិយ្យោ សោមនស្សំ ។ អយំ ខោ ភោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន បឋមោ ឱកាសាធិគមោ អនុពុទ្ធោ សុខស្សាធិគមាយ ។

(៤១) បុន ចបរំ ភោ ឥធេកច្ចស្ស ឱឡារិកា កាយសង្ខារា អប្បដិប្បស្សទ្ធា ហោន្តិ ឱឡារិកា

១ ឱ. ម. ធម្មានុធម្មប្បដិបន្នោ ។ ២ ឱ. មុទា បាមុជ្ជំ ។ ឱ. បាមុជ្ជំ ។



នៃប្រាជ្ញា ប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ក៏ជាបុគ្គលលែងជាប់ចំពាក់ ដោយកាមទាំងឡាយ លែងជាប់ចំពាក់ ដោយអកុសលធម៌ទាំងឡាយ ។ កាលដែលបុគ្គលនោះ លែងជាប់ចំពាក់ ដោយកាមទាំងឡាយហើយ លែងជាប់ចំពាក់ ដោយអកុសលធម៌ទាំងឡាយហើយ សេចក្តីសុខ ក៏កើតឡើង សោមនស្ស ក៏កើតឡើង ដោយក្រៃលែង ព្រោះសេចក្តីសុខជាបច្ច័យ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្តីរីករាយមានកម្លាំងខ្លាំង កើតឡើង ព្រោះសេចក្តីរីករាយមានកម្លាំងទន់ ដូចម្តេចមិញ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ កាលដែលបុគ្គលលែងជាប់ចំពាក់ ដោយកាមទាំងឡាយហើយ លែងជាប់ចំពាក់ដោយអកុសលធម៌ទាំងឡាយហើយ សេចក្តីសុខក៏កើតឡើង សោមនស្ស ក៏កើតឡើង ដោយក្រៃលែង ព្រោះសេចក្តីសុខ (ជាបច្ច័យ) ដូច្នោះដែរ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ នេះឯងជាការបាននូវឱកាសជាបឋម ដើម្បីបាននូវសេចក្តីសុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។

(៤១) ម្នាលអ្នកដ៏ចម្រើនទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មានកាយសង្ខារ(១) ដ៏គ្រោតគ្រាត មិនទាន់ស្ងប់ស្ងាត់ មាន

១ កាយសង្ខារ បានដល់អស្សាសបស្សាសៈ គឺដង្ហើមចេញចូល ។

វចីសង្ខារា អប្បដិប្បស្សទ្ធា ហោន្តិ ចិត្តសង្ខារា អប្បដិប្បស្សទ្ធា ហោន្តិ ។ សោ អបរេន សមយេន អរិយធម្មំ សុណាតិ យោនិសោ មនសិករោតិ ធម្មានុធម្មំ បដិបជ្ជតិ ។ តស្ស អរិយធម្មស្សវនំ អាគម្ម យោនិសោ មនសិការំ ធម្មានុធម្មំ បដិបត្តិស្ស(១) ឱឡារិកា កាយសង្ខារា បដិប្បស្សម្ភន្តិ ឱឡារិកា វចីសង្ខារា បដិប្បស្សម្ភន្តិ ឱឡារិកា ចិត្តសង្ខារា បដិប្បស្សម្ភន្តិ ។ តស្ស ឱឡារិកានំ កាយសង្ខារានំ បដិប្បស្សទ្ធិយា ឱឡារិកានំ វចីសង្ខារានំ បដិប្បស្សទ្ធិយា ឱឡារិកានំ ចិត្តសង្ខារានំ បដិប្បស្សទ្ធិយា ឧប្បជ្ជតិ សុខំ សុខា ភិយ្យោ សោមនស្សំ ។ សេយ្យថាបិ ភោ បមុទា បាមោជ្ជំ ជាយេថ ឯវមេវ ខោ ភោ ឱឡារិកានំ កាយសង្ខារានំ បដិប្បស្សទ្ធិយា ឱឡារិកានំ វចីសង្ខារានំ បដិប្បស្សទ្ធិយា ឱឡារិកានំ ចិត្តសង្ខារានំ បដិប្បស្សទ្ធិយា ឧប្បជ្ជតិ សុខំ សុខា ភិយ្យោ

១ ម. ឆ. ធម្មានុធម្មប្បដិបត្តិំ ។



វចីសង្ខារ(១) ដ៏គ្រោតគ្រាត មិនទាន់ស្ងប់រម្ងាប់ មានចិត្តសង្ខារ(២) ដ៏គ្រោតគ្រាត មិនទាន់ស្ងប់រម្ងាប់ ។ សម័យតទៅក្រោយមក បុគ្គលនោះ ស្តាប់នូវអរិយធម៌ ធ្វើទុកក្នុងចិត្តដោយឧបាយ ប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ។ លុះបុគ្គលនោះ អាស្រ័យការស្តាប់អរិយធម៌ អាស្រ័យការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញ ប្រតិបត្តិនូវធម៌សមគួរដល់ធម៌ហើយ កាយសង្ខារគ្រោតគ្រាត ក៏ស្ងប់រម្ងាប់ទៅ វចីសង្ខារគ្រោតគ្រាត ក៏ស្ងប់រម្ងាប់ទៅ ចិត្តសង្ខារគ្រោតគ្រាត ក៏ស្ងប់រម្ងាប់ទៅ ។ សេចក្តីសុខរមែងកើតឡើងដល់បុគ្គលនោះ ព្រោះការស្ងប់រម្ងាប់នៃកាយសង្ខារគ្រោតគ្រាត ព្រោះការស្ងប់រម្ងាប់នៃវចីសង្ខារគ្រោតគ្រាត ព្រោះការស្ងប់រម្ងាប់ នៃចិត្តសង្ខារគ្រោតគ្រាត ឯសោមនស្សក៏កើតឡើង ដោយក្រៃលែងព្រោះសេចក្តីសុខ (នោះជាបច្ច័យ) ។ ម្នាលអ្នកដ៏ចំរើនទាំងឡាយ សេចក្តីរីករាយមានកម្លាំងកើតឡើង ព្រោះសេចក្តីរីករាយមានកម្លាំងទន់ ដូចម្តេចមិញ ម្នាលអ្នកដ៏ចំរើនទាំងឡាយ សេចក្តីសុខរមែងកើតឡើង ព្រោះស្ងប់រម្ងាប់នៃកាយសង្ខារគ្រោតគ្រាត ព្រោះការស្ងប់រម្ងាប់នៃវចីសង្ខារគ្រោតគ្រាត ព្រោះការស្ងប់រម្ងាប់នៃចិត្តសង្ខារគ្រោតគ្រាត ឯសោមនស្ស ក៏កើតឡើងដោយក្រៃលែង ព្រោះ

១ វចីសង្ខារ បានដល់វិតក្កៈ វិចារៈ គឺការត្រិះរិះអារម្មណ៍និងការពិចារណា ។ ២ ចិត្តសង្ខារ បានដល់សញ្ញានិងវេទនា គឺការចាំអារម្មណ៍និងការទទួលអារម្មណ៍ ។

សោមនស្សំ ។ អយំ ខោ ភោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទុតិយោ ឱកាសាធិគមោ អនុពុទ្ធោ សុខស្សាធិគមាយ ។

(៤៤) បុន ចបរំ ភោ ឥធេកច្ចោ ឥទំ កុសលន្តិ យថាភូតំ នប្បជានាតិ ឥទំ អកុសលន្តិ យថាភូតំ នប្បជានាតិ ឥទំ សាវជ្ជន្តិ យថាភូតំ នប្បជានាតិ ឥទំ អនវជ្ជន្តិ យថាភូតំ នប្បជានាតិ ឥទំ សេវិតព្វន្តិ យថាភូតំ នប្បជានាតិ ឥទំ ន សេវិតព្វន្តិ យថាភូតំ នប្បជានាតិ ឥទំ ហីនន្តិ យថាភូតំ នប្បជានាតិ ឥទំ បណីតន្តិ យថាភូតំ នប្បជានាតិ ឥទំ កណ្ហសុក្កសប្បដិភាគន្តិ យថាភូតំ នប្បជានាតិ[១] ។ សោ អបរេន សមយេន អរិយធម្មំ សុណាតិ យោនិសោ មនសិការោតិ ធម្មានុធម្មំ បដិបជ្ជតិ ។ សោ អរិយធម្មស្សវនំ អាគម្ម យោនិសោ មនសិការំ ធម្មានុធម្មំ បដិបជ្ជតិ

១ ឱ. ម. ឥទំ សាវជ្ជំ ។ ឥទំ អនវជ្ជំ ។ ឥទំ សេវិតព្វំ ។ ឥទំ ន សេវិតព្វំ ។ ឥទំ ហីនំ ឥទំ បណីតំ ។ ឥទំ កណ្ហសុក្កសប្បដិភាគន្តិ យថាភូតំ នប្បជានាតីតិ ទិស្សន្តិ ។



សេចក្ដីសុខ (នោះជាបច្ច័យ) ក៏ផុសផ្ចោះដែរ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ នេះឯង ជាការបាននូវឱកាសជាគម្រប់ពីរ ដើម្បីបាននូវសេចក្ដីសុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។

(៤៤) ម្នាលអ្នកដ៏ចម្រើនទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនដឹងច្បាស់តាមពិតថា នេះ ជាកុសល មិនដឹងច្បាស់តាមពិតថា នេះ ជាអកុសល មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើប្រកបដោយទោស មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើមិនមានទោស មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើគួរសេព មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើមិនគួរសេព មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើថោកទាប មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើខ្ពង់ខ្ពស់ មិនដឹងច្បាស់តាមពិតថា នេះ ជាអំពើខ្មៅ ជាអំពើស ជាអំពើមានចំណែកប្រៀបផ្ទឹមគ្នា ។ សម័យជាខាងក្រោយមក បុគ្គលនោះ ស្ដាប់នូវអរិយធម៌ ធ្វើទុកក្នុងចិត្តដោយឧបាយ ប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ។ បុគ្គលនោះ លុះអាស្រ័យការស្ដាប់អរិយធម៌ អាស្រ័យការធ្វើទុកក្នុងចិត្តដោយឧបាយ ប្រតិបត្តិនូវធម៌ ដ៏សមគួរ

ឥទំ កុសលន្តិ យថាភូតំ បជានាតិ ឥទំ អកុសលន្តិ យថាភូតំ បជានាតិ ឥទំ សាវជ្ជន្តិ យថាភូតំ បជានាតិ ឥទំ អនវជ្ជន្តិ យថាភូតំ បជានាតិ ឥទំ សេវិតព្វន្តិ យថាភូតំ បជានាតិ ឥទំ ន សេវិតព្វន្តិ យថាភូតំ បជានាតិ ឥទំ ហីនន្តិ យថាភូតំ បជានាតិ ឥទំ បណីតន្តិ យថាភូតំ បជានាតិ ឥទំ កណ្ហសុក្កសប្បដិភាគន្តិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ អវិជ្ជា បហីយតិ វិជ្ជា ឧប្បជ្ជតិ ។ តស្ស អវិជ្ជាវិរាគា វិជ្ជុប្បាទា ឧប្បជ្ជតិ សុខំ សុខា ភិយ្យោ សោមនស្សំ ។ សេយ្យថាបិ ភោ បមុទា បាមោជ្ជំ ជាយេថ ឯវមេវ ខោ ភោ អវិជ្ជាវិរាគា វិជ្ជុប្បាទា ឧប្បជ្ជតិ សុខំ សុខា ភិយ្យោ សោមនស្សំ ។ អយំ ខោ ភោ



ដល់ធម៌ គឺដឹងច្បាស់តាមពិតថា នេះ ជាកុសល ដឹងច្បាស់តាមពិតថា នេះ ជាអកុសល ដឹងច្បាស់តាមពិតថា នេះ ជាអំពើប្រកបដោយទោស ដឹងច្បាស់តាមពិតថា នេះ ជាអំពើមិនមានទោស ដឹងច្បាស់តាមពិតថា នេះ ជាអំពើគួរសេព ដឹងច្បាស់តាមពិតថា នេះ ជាអំពើមិនគួរសេព ដឹងច្បាស់តាមពិតថា នេះ ជាអំពើថោកទាប ដឹងច្បាស់តាមពិតថា នេះ ជាអំពើខ្ពង់ខ្ពស់ ដឹងច្បាស់តាមពិតថា នេះ ជាអំពើខ្មៅ ជាអំពើស ជាអំពើមានចំណែកប្រៀបផ្ទឹមគ្នា ។ កាលដែលបុគ្គលនោះ ដឹងច្បាស់យ៉ាងនេះ ឃើញច្បាស់យ៉ាងនេះហើយ អវិជ្ជាក៏សាបសូន្យទៅ វិជ្ជាក៏កើតឡើង ។ សេចក្ដីសុខ រមែងកើតឡើង ដល់បុគ្គលនោះ ព្រោះការសាបសូន្យទៅនៃអវិជ្ជា ព្រោះការកើតឡើងនៃវិជ្ជា ឯសោមនស្ស ក៏កើតឡើង ដោយក្រៃលែង ព្រោះសេចក្ដីសុខ (នោះជាបច្ច័យ) ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្ដីរីករាយមានកម្លាំងខ្លាំង រមែងកើតឡើង ព្រោះសេចក្ដីរីករាយមានកម្លាំងទន់ខ្សោយមុនមិញ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សេចក្ដីសុខ រមែងកើតឡើង ព្រោះការសាបសូន្យទៅនៃអវិជ្ជា ព្រោះការកើតឡើងនៃវិជ្ជា ឯសោមនស្ស ក៏រមែងកើតឡើង ដោយក្រៃលែង ព្រោះសេចក្ដីសុខ (នោះជាបច្ច័យ) ដូច្នោះដែរ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ នេះឯងជា

តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តតិយោ ឱកាសាធិគមោ អនុពុទ្ធោ សុខស្សាធិគមាយ ។ ឥមេ ខោ ភោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន តយោ ឱកាសាធិគមា អនុពុទ្ធា សុខស្សាធិគមាយាតិ ។

[៤៣] ឥទមវោច ភន្តេ ព្រហ្មា សនង្កុមារោ ឥទំ វត្វា ។ ឥទំ វត្វា ភន្តេ ព្រហ្មា សនង្កុមារោ ទេវេ តាវតិំសេ អាមន្តេសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវតិំសា យាវ សុបញ្ញត្តាមិមេ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ សតិប្បដ្ឋានា កុសលស្សាធិគមាយ ។ កតមេ ចត្តារោ ។ ឥធ ភោ ភិក្ខុ អជ្ឈត្តំ កាយេ កាយានុបស្សី វិហរតិ



ការបាននូវឱកាសជាគម្រប់ ៣ ដើម្បីបាននូវសេចក្តីសុខ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ការបាននូវឱកាស ដើម្បីបាននូវសេចក្តីសុខ ៣ ប្រការនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់ដឹងហើយ ។

(៤៣) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះហើយទើបពោលនឹងពួកទេវតាក្នុងត្រៃត្រិង្សថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកទេវតាក្នុងត្រៃត្រិង្ស សម្គាល់សេចក្តីនោះដូចម្តេច គ្រឿងដែលជា សតិប្បដ្ឋានទាំង ៤ នេះ ដើម្បីបាននូវកុសល(១) ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយ ល្អ ៗ សតិប្បដ្ឋានទាំង ៤ តើដូចម្តេច ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង

១ សំដៅយកមគ្គនិងផល ។

អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អជ្ឈត្តំ កាយេ កាយានុបស្សី វិហរន្តោ តត្ថ សម្មា សមាធិយតិ សម្មា វិប្បសីទតិ ។ សោ តត្ថ សម្មាសមាហិតោ សម្មាវិប្បសន្នោ ពហិទ្ធា បរកាយេ ញាណទស្សនំ អភិនិព្វត្តេតិ ។ អជ្ឈត្តំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អជ្ឈត្តំ វេទនាសុ វេទនានុបស្សី វិហរន្តោ តត្ថ សម្មា សមាធិយតិ សម្មា វិប្បសីទតិ ។ សោ តត្ថ សម្មាសមាហិតោ សម្មាវិប្បសន្នោ ពហិទ្ធា បរវេទនាសុ ញាណទស្សនំ អភិនិព្វត្តេតិ ។ អជ្ឈត្តំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី



មានព្យាយាម ជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក[១] ភិក្ខុកាលពិចារណាឃើញរឿយ ៗ នូវកាយជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងកាយជាខាងក្នុងនោះ ។ ភិក្ខុនោះលុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងកាយជាខាងក្នុងនោះហើយ រមែងញុំាងញាណទស្សនៈ (ការដឹង និងការឃើញ) ឲ្យកើតក្នុងកាយ របស់បុគ្គលដទៃ ជាខាងក្រៅបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនា ក្នុងវេទនាទាំងឡាយ ជាខាងក្នុង មានព្យាយាម ជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ភិក្ខុ កាលពិចារណាឃើញរឿយ ៗ នូវវេទនា ក្នុងវេទនាទាំងឡាយ ជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងវេទនា ជាខាងក្នុងនោះ ។ ភិក្ខុនោះ លុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងវេទនាជាខាងក្នុងនោះហើយ រមែងញុំាងញាណទស្សនៈ ឲ្យកើតក្នុងវេទនាទាំងឡាយ របស់បុគ្គលដទៃ ជាខាងក្រៅបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្ត ក្នុងចិត្តជាខាងក្នុង មានព្យាយាម ជាគ្រឿងដុតកម្តៅនូវកិលេស

១ សំដៅយកកាយ ឬឧបាទានក្ខន្ធទាំង៥ ។

សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អជ្ឈត្តំ ចិត្តេ ចិត្តានុបស្សី វិហរន្តោ តត្ថ សម្មា សមាធិយតិ សម្មា វិប្បសីទតិ ។ សោ តត្ថ សម្មាសមាហិតោ សម្មាវិប្បសន្នោ ពហិទ្ធា បរចិត្តេ ញាណទស្សនំ អភិនិព្វត្តេតិ ។ អជ្ឈត្តំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អជ្ឈត្តំ ធម្មេសុ ធម្មានុបស្សី វិហរន្តោ តត្ថ សម្មា សមាធិយតិ សម្មា វិប្បសីទតិ ។ សោ តត្ថ សម្មាសមាហិតោ សម្មាវិប្បសន្នោ ពហិទ្ធា បរធម្មេសុ ញាណទស្សនំ អភិនិព្វត្តេតិ ។ ឥមេ ខោ ភោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ចត្តារោ សតិប្បដ្ឋានា បញ្ញត្តា កុសលស្សាភិសមយាយាតិ ។





មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ភិក្ខុកាលពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្ត ជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងចិត្តជាខាងក្នុងនោះ ។ ភិក្ខុនោះ លុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងចិត្តជាខាងក្នុងនោះហើយ រមែងញុំាងញាណទស្សនៈ ឲ្យកើតក្នុងចិត្តរបស់បុគ្គលដទៃ ជាខាងក្រៅបាន ។ ភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង មានព្យាយាម ជាគ្រឿងដុតកម្ដៅនូវកិលេស មានសេចក្ដីដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ភិក្ខុកាលពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាខាងក្នុងហើយ ក៏រមែងតាំងចិត្តខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងធម៌ជាខាងក្នុងនោះ ។ ភិក្ខុនោះ លុះមានចិត្តតាំងខ្ជាប់ដោយប្រពៃ ជ្រះថ្លាដោយប្រពៃ ក្នុងធម៌ជាខាងក្នុងនោះហើយ ក៏រមែងញុំាងញាណទស្សនៈ ឲ្យកើតក្នុងធម៌ទាំងឡាយ របស់បុគ្គលដទៃជាខាងក្រៅបាន ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សតិប្បដ្ឋានទាំង ៤ នេះឯង ដើម្បីបាននូវកុសលផល ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយ ។

(៦៦) ឥធមត្ថុំ ភន្តេ ព្រហ្មា សនង្កុមារោ អភា-សិត្ថ(១) ។ ឥធមត្ថុំ ភន្តេ ព្រហ្មា សនង្កុមារោ ភាសិត្វា ទេវេ តាវតិំសេ អាមន្តេសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវតិំសា យាវ សុបញ្ញត្តាចិមេ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សត្ត ស-មាធិបរិក្ខារា សម្មាសមាធិស្ស ភាវនាយ(២) សម្មាស-មាធិស្ស(៣) បារិបូរិយា ។ កតមេ សត្ត(៤) ។ សម្មា-ទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មា-អាជីវោ សម្មាវាយាមោ សម្មាសតិ ។ យា ខោ ភោ ឥមេហិ សត្តហង្គេហិ(៥) ចិត្តស្ស ឯកគ្គតា បរិក្ខតា អយំ វុច្ចតិ ភោ អរិយោ សម្មាសមាធិ សឧបនិសោ

១ ឱ. ភាសិត្ថ ។ ២ ឱ. សមាធិស្ស បរិភាវនាយ ។ ៣ ម. សមាធិស្ស ។ ៤ ម. សត្ត សេយ្យថីទំ ។ ៥ ម. សត្ត អង្គេហិ ។



(៦៦) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះសនង្កុមារព្រហ្ម ពោលសេចក្តីនេះហើយ ទើបពោលនឹងពួកតាវត្តិំសទេវតាថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកតាវត្តិំសទេវតា សម្គាល់សេចក្តីនោះដូចម្តេច គ្រឿងដែលជាធម៌ជាបរិក្ខារនៃសមាធិ ៧ យ៉ាងនេះ ដើម្បីចម្រើននៃសម្មាសមាធិ ដើម្បីបរិបូណ៌នៃសម្មាសមាធិ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់បញ្ញត្តហើយដោយល្អ ។ ធម៌ជាបរិក្ខារនៃសមាធិ ៧ យ៉ាង តើដូចម្តេច ។ សម្មាទិដ្ឋិ (សេចក្តីយល់ត្រូវ)១ សម្មាសង្កប្បៈ (សេចក្តីត្រិះរិះត្រូវ)១ សម្មាវាចា (សម្តីត្រូវ)១ សម្មាកម្មន្តៈ (ការងារត្រូវ)១ សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ)១ សម្មាវាយាមៈ (សេចក្តីព្យាយាមត្រូវ)១ សម្មាសតិ (សេចក្តីរលឹកត្រូវ)១ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សភាវៈនៃចិត្ត មានអារម្មណ៍មួយតែមួយណា ដែលអង្គទាំង ៧ នេះ ហែហមហើយ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សភាវៈនៃចិត្ត មានអារម្មណ៍តែមួយនេះ លោកហៅថា សម្មាសមាធិ ដ៏ប្រសើរ ប្រកបដោយឧបនិស្ស័យផង ជា ប្រកប

ឥតិបិ សមរិត្តាកេ ឥតិបិ សម្មាទិដ្ឋិស្ស ភោ សម្មា-
សង្កប្បោ បហោតិ សម្មាសង្កប្បស្ស សម្មាវាចា បហោ-
តិ សម្មាវាចស្ស សម្មាកម្មន្តោ បហោតិ សម្មាកម្ម-
ន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវស្ស សម្មា-
វាយាមោ បហោតិ សម្មាវាយាមស្ស សម្មាសតិ បហោ-
តិ សម្មាសតិស្ស សម្មាសមាធិ បហោតិ សម្មាសមា-
ធិស្ស សម្មាញាណំ បហោតិ សម្មាញាណស្ស សម្មា-
វិមុត្តិ បហោតិ ។ យញ្ហិ តំ ភោ សម្មា វទមានោ
វទេយ្យ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកា-
លិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិ-
តព្វោ វិញ្ញូហីតិ អបារុតា តេ(១) អមតស្ស ទ្វារាតិ ។

១ ម. ឫ. តេតិ ន ទិស្សតិ ។



ដោយធម៌ជាបរិកេផនី ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សម្មាសង្កប្បៈ រមែង
មានដល់បុគ្គល ដែលឋិតនៅក្នុងសម្មាទិដ្ឋិ សម្មាវាចា រមែងមានដល់បុគ្គល
ដែលឋិតនៅក្នុងសម្មាសង្កប្បៈ សម្មាកម្មន្តៈ រមែងមានដល់បុគ្គល ដែល
ឋិតនៅក្នុងសម្មាវាចា សម្មាអាជីវៈ រមែងមានដល់បុគ្គល ដែលឋិតនៅក្នុង
សម្មាកម្មន្តៈ សម្មាវាយាមៈ រមែងមានដល់បុគ្គល ដែលឋិតនៅក្នុងសម្មា-
អាជីវៈ សម្មាសតិ រមែងមានដល់បុគ្គល ដែលឋិតនៅក្នុងសម្មាវាយាមៈ
សម្មាសមាធិ រមែងមានដល់បុគ្គល ដែលឋិតនៅក្នុងសម្មាសតិ សម្មា-
ញាណៈ(១) រមែងមានដល់បុគ្គល ដែលឋិតនៅក្នុងសម្មាសមាធិ សម្មា-
វិមុត្តិ(២) រមែងមានដល់បុគ្គល ដែលឋិតនៅក្នុងសម្មាញាណៈ ។ ម្នាលអ្នក
ដ៏ចម្រើនទាំងឡាយ បុគ្គលកាលបើពោលដោយប្រពៃ គប្បីពោលនូវពាក្យ
ថា ព្រះបរិយត្តិធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយ
ល្អ ព្រះនពលោកុត្តរធម៌ ដែលព្រះអរិយបុគ្គលទាំងពួង មិនគិត ឃើញពិត
ជាធម៌ឲ្យផល មិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សិកៈ ជាធម៌ដែល
ព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំង-
ឡាយ គប្បីដឹងច្បាស់ក្នុងចិត្តនៃខ្លួន ទ្វារនៃព្រះនិព្វាននោះបើកហើយ ។

១ សេចក្ដីដឹងដោយប្រពៃ បានដល់មគ្គញាណ និងផលញាណ ។ ២ ការរួចស្រឡះចាក
អាសវៈ បានដល់មគ្គវិមុត្តិ និងផលវិមុត្តិ ។

ឥទមេវ តំ សម្មាសម្ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតំ សម្មា វទមានោ(1) វទេយ្យ ស្វាក្ខាតោ ហិ(2) ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ អបារុតា តេ អមតស្ស ទ្វារានិ ។ យេ ហិ កេចិ ភោ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ធម្មេ អវេច្ចប្បសាទេន សមន្នាគតា សង្ឃេ អវេច្ចប្បសាទេន សមន្នាគតា អរិយកន្តេហិ សីលេហិ សមន្នាគតា យេ ចិមេ(3) ឱបបាតិកា ធម្មេ វិនីតា(4) សាតិរេកានិ ចតុវីសតិសតសហស្សានិ មាគធិកា បរិចារកា

១ ម. ឥទមេវ តំ សម្មាវទមានោ ។ ឱ. ឥទមេវ តំ . . . ។ ២ ម. ឱ. ហិ ភោ ។ ៣ ម. យេ ហិ កេចិមេ ។ ៤ ម. ឱ. ឧទ្ធីតា ។



បុគ្គលកាលពោលដោយប្រពៃ គប្បីពោល នូវពាក្យដែលប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រ ចំពោះព្រះសម្មាសម្ពុទ្ធថា មែនពិត ព្រះបរិយត្តិធម៌ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងហើយដោយល្អ ព្រះនវលោកុត្តរធម៌ ដែលព្រះអរិយបុគ្គលតាំងខ្លួន ដឹងពិត ឃើញពិត ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជាធម៌ដែលព្រះអរិយបុគ្គល គប្បីបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ ក្នុងចិត្តរបស់ខ្លួន ទ្វារនៃព្រះនិព្វានគេបានបើកហើយ ។ ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ព្រោះថាជនទាំងឡាយណាមួយប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រចំពោះព្រះពុទ្ធប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រចំពោះព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លា មិនញាប់ញ័រចំពោះព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ជាទីស្រឡាញ់របស់ព្រះអរិយៈ មួយទៀត ជនទាំងឡាយណា ជាឱបបាតិកៈ ជាអ្នកទៀងក្នុងធម៌ ទំនាបត់អំពីមុខសាក់ទ មិនកាចនឹងកប់ផងទាំងអម្បាលនោះ ផ្ទុយថា ពួកជនទៅក្នុងដែនមគធៈ ច្រើនជាង ២ លាន ៤ សែន ជាអ្នកបម្រើ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

អតិក្កន្តា កាលកតា តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណា ។ អត្ថិ ចេវេត្ថ សកទាគាមិនោ អត្ថាយំ ឥតរា បជា បុញ្ញាភាគាតិ មេ មនោ សង្ខាតុំ នោបិ សក្កោមិ(1) មុសាវាទស្ស ឱត្តប្បន្តិ ។

(២៨) ឥទមត្ថំ ភន្តេ ព្រហ្មា សនង្កុមារោ អភាសិត្ថ ។ ឥទមត្ថំ ភន្តេ ព្រហ្មុនោ សនង្កុមារស្ស ភាសតោ វេស្សវណស្ស មហារាជស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ឯវរូបោបិ នាម ឧឡារោ សត្ថា ភវិស្សតិ ឯវរូបំ ឧឡារំ ធម្មក្ខានំ ឯវរូបា ឧឡារា វិសេសាធិគមា បញ្ញាយិស្សន្តីតិ ។ អថ ភន្តេ ព្រហ្មា សនង្កុមារោ វេស្សវណស្ស មហារាជស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ វេស្សវណំ មហារាជានំ ឯតទវោច តំ កឹ មញ្ញតិ ភវំ វេស្សវណោ មហារាជា អតីតម្បិ អទ្ធានំ ឯវរូបោ ឧឡារោ សត្ថា អហោសិ

១ ម. យ. នោបិ សក្កោមិ ។



ធ្វើមរណកាល កន្លងទៅយូរហើយ ជាសោតាបន្នបុគ្គល មានសភាវៈមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិជាទីប្រព្រឹត្តទៅ ក្នុងខាងមុខ ព្រោះអស់ទៅនៃសំយោជនៈ ៣ ។ ពួកសកទាគាមិបុគ្គល ក៏មានក្នុងទីនុ៎ះដែរ ឯពួកសត្វក្រៅពីនេះ(1) ជាអ្នកមានចំណែកបុណ្យ (ក៏មានច្រើនដែរ) ។

(២៨) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលសនង្កុមារព្រហ្ម ពោលនូវសេចក្តីនេះហើយ វេស្សវណមហារាជ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា អើហ្ន៎ អស្ចារ្យណាស់ អើហ្ន៎ ចម្លែកពេកណាស់ ព្រះសាស្តាដ៏ប្រសើរ មានសភាពយ៉ាងនេះ មុខជានឹងមានតទៅមិនខាន ការសម្តែងនូវធម៌ដ៏ថ្លៃថ្លា មានសភាពយ៉ាងនេះនឹងប្រាកដឡើង ការត្រាស់ដឹងនូវគុណវិសេសដ៏លើសលប់ មានសភាពយ៉ាងនេះ ក៏នឹងប្រាកដឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្ម ដឹងសេចក្តីត្រិះរិះក្នុងចិត្តរបស់វេស្សវណមហារាជ ដោយចិត្ត (របស់ខ្លួន) ហើយ ទើបពោលពាក្យនេះ នឹងវេស្សវណមហារាជថា វេស្សវណមហារាជដ៏ចម្រើន សម្គាល់សេចក្តីនោះដូចម្តេច ព្រះសាស្តាដ៏ប្រសើរ មានសភាពយ៉ាងនេះ ក៏មាន

១ សំដៅយកឥតរាបុគ្គល ។

ឯវរូបំ ឧឡារំ ធម្មក្ខានំ ឯវរូបា ឧឡារា វិសេសាធិគមា បញ្ញាយិំសុ អនាគតម្បិ អទ្ធានំ ឯវរូបោ ឧឡារោ សត្ថា ភវិស្សតិ ឯវរូបំ ឧឡារំ ធម្មក្ខានំ ឯវរូបា ឧឡារា វិសេសាធិគមា បញ្ញាយិស្សន្តីតិ ។

(៦៦) អថខោ ភន្តេ ព្រហ្មា សនង្កុមារោ ទេវានំ តាវតឹសានំ អភាសិ ។ អថខោ ភន្តេ វេស្សវណោ មហារាជា ព្រហ្មុនោ សនង្កុមារស្ស ទេវានំ តាវតឹសានំ ភាសតោ សម្មា សុតំ សម្មា បដិគ្គហិតំ សាយំ បរិសាយំ(១) អារោចេសិ ។ អថខោ ជនវសភោ យក្ខោ វេស្សវណស្ស មហារាជស្ស សាយំ(២) បរិសាយំ ភាសតោ សម្មា សុតំ សម្មា បដិគ្គហិតំ ភគវតោ អារោចេសិ ។ អថខោ ភគវា

១ ម. សុត្វា សម្មា បដិគ្គហេត្វា សបរិសាយំ ។ ២ ម. សាយន្តិ ន ទិស្សតិ ។



មកហើយ ការសម្តែងធម៌ដ៏ថ្លៃថ្លា មានសភាពយ៉ាងនេះ ក៏ប្រាកដហើយ ការត្រាស់ដឹងនូវគុណវិសេសដ៏លើសលប់ មានសភាពយ៉ាងនេះ ក៏ប្រាកដហើយក្នុងអតីតកាល ព្រះសាស្តាដ៏ប្រសើរ មានសភាពយ៉ាងនេះ នេះ មុខជានឹងមានតទៅ ការសម្តែងធម៌ដ៏ថ្លៃថ្លា មានសភាពយ៉ាងនេះ នឹងប្រាកដឡើង ការត្រាស់ដឹងនូវគុណវិសេសដ៏លើសលប់ មានសភាពយ៉ាងនេះ ក៏នឹងប្រាកដឡើង ក្នុងអនាគតកាល ។

(៦៦) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះ នឹងពួកតាវត្តិង្សទេវតាហើយ ។ កាលសនង្កុមារព្រហ្ម ពោលសេចក្តីនេះ នឹងតាវត្តិង្សទេវតា វេស្សវណមហារាជ បានប្រាប់សេចក្តីនេះ ដែលខ្លួនបានឮហើយ ក្នុងទីចំពោះមុខ ដែលខ្លួនបានទទួលហើយក្នុងទីចំពោះមុខ ក្នុងបរិស័ទរបស់ខ្លួន ។ កាលវេស្សវណមហារាជ ពោលសេចក្តីនេះ ក្នុងបរិស័ទរបស់ខ្លួន ជនវសភយក្ស ក៏ក្រាបទូលសេចក្តី ដែលខ្លួនបានឮហើយ ក្នុងទីចំពោះមុខ ដែលខ្លួនបានទទួលហើយ ក្នុងទីចំពោះមុខ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ

### ជនវសភសុត្តំ បាឡ្យាភាគបនកថា

ជនវសភស្ស យក្ខស្ស សម្មុខា សុត្វា សម្មុខា
បដិគ្គហេត្វា សាមញ្ញ អភិញ្ញាយ អាយស្មតោ អា-
នន្ទស្ស អារោចេសិ ។ ឥទមត្តំ អាយស្មា អា-
នន្ទោ ភគវតោ សម្មុខា សុត្វា សម្មុខា បដិគ្គ-
ហេត្វា អារោចេសិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ
ឧបាសិកានំ ។ តយិទំ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច
វិត្ថារិកំ ពហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ
សុប្បកាសិតន្តិ ។

ជនវសភសុត្តំ បញ្ចមំ និដ្ឋិតំ ។

---



### ជនវសភសូត្រ ពោលអំពីការតំណាលប្រាប់ត ៗ គ្នា

បានទ្រង់ព្រះសណ្ដាប់សេចក្ដីនេះ ទទួលសេចក្ដីនេះ ក្នុងទីចំពោះមុខនៃ
ជនវសភយក្ស ទ្រង់បញ្ជាក់ដោយព្រះអង្គឯងហើយ ទើបត្រាស់ប្រាប់
ដល់ព្រះអានន្ទមានអាយុ ។ លុះព្រះអានន្ទមានអាយុ បានឮ បាន
ទទួលក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគហើយ ទើបប្រាប់សេចក្ដី
នេះដល់ពួកភិក្ខុ ភិក្ខុនី ពួកឧបាសក ឧបាសិកា ។ សាសនព្រហ្មចរិ-
យធម៌នេះទាំងមូល ដល់នូវសេចក្ដីចម្រើន ផ្សាយទៅសព្វទិស អ្នកផង
បានដឹងច្រើនគ្នាហើយ កើតមានក្រាស់ក្រែល ត្រាតែពួកទេវតា និង
មនុស្សបានសម្ដែងដោយស្រួលបាន ។

ចប់ ជនវសភសូត្រទី ៥ ។

## មហាគោវិន្ទសុត្តំ ឆដ្ឋំ

[៤៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ បញ្ចសិខោ គន្ធព្វបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ គិជ្ឈកូដំ បព្វតំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ បញ្ចសិខោ គន្ធព្វបុត្តោ ភគវន្តំ ឯតទវោច យំ ខោ មេ(១) ភន្តេ ទេវានំ តាវតឹសានំ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ អារោចេមិ(២) តំ ភគវតោតិ ។ អារោចេហិ មេ ត្វំ បញ្ចសិខាតិ ភគវា អវោច ។ បុរិមានិ ភន្តេ ទិវសានិ បុរិមតរានិ តទហុ ឧបោសថេ បណ្ណរសេ បវារណាយ បុណ្ណមាយ រត្តិយា កេវលកប្បា ច ទេវា តាវតឹសា សុធម្មាយំ

១ ម. យម្ហេ ។ ម. យំ ខោ មេ ។ ២ អារោចេមិ ភន្តេ ។

## មហាគោវិន្ទសូត្រ ទី ៦

(៤៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង បញ្ចសិខគន្ធព្វបុត្រ កាលរាត្រីកន្លងទៅហើយ (កន្លងបឋមយាម) បញ្ចេញរស្មីព្រោល ញុំាងភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺស្វាងហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំ ព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះបញ្ចសិខគន្ធព្វបុត្រ ឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូល ព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ សូមក្រាបបង្គំទូលព្រះមានព្រះភាគ នូវសេចក្តីដែលខ្ញុំព្រះអង្គ បានស្តាប់ក្នុងទីចំពោះមុខ បានទទួលក្នុងទីចំពោះមុខនៃពួកទេវតាជាន់តាវត្តិង្ស ។ ព្រះមានព្រះភាគ បានត្រាស់ថា ម្នាលបញ្ចសិខៈ អ្នកចូរប្រាប់តថាគតចុះ ។ បញ្ចសិខគន្ធព្វបុត្រ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃមុន ៗ ក្នុងតិថីទី ១៥ ដែលជាថ្ងៃឧបោសថ ត្រូវនឹងថ្ងៃបវារណា ក្នុងរាត្រីមានព្រះចន្ទពេញវង់ ពួកទេវតា ជាន់តាវត្តិង្សទាំងអស់ កំពុងអង្គុយប្រជុំក្នុងទេវសភា(១) ឈ្មោះសុធម្មា

១ សាលប្រជុំទេវតា ។

សភាយំ សន្និសិន្នា ហោន្តិ សន្និបតិតា មហតី ច ទិព្វបរិសា សមន្តតោ និសិន្នា ហោន្តិ ចត្តារោ ច មហារាជានោ(១) ចតុទ្ទិសា និសិន្នា ហោន្តិ បុរត្ថិមាយ ទិសាយ ធតរដ្ឋោ មហារាជា បច្ឆាភិមុខោ និសិន្នោ ហោតិ ទេវេ បុរក្ខត្វា(២) ទក្ខិណាយ ទិសាយ វិរូឡ្ហកោ មហារាជា ឧត្តរាភិមុខោ និសិន្នោ ហោតិ ទេវេ បុរក្ខត្វា បច្ឆិមាយ ទិសាយ វិរូបក្ខោ មហា-រាជា បុរត្ថាភិមុខោ និសិន្នោ ហោតិ ទេវេ បុរក្ខត្វា ឧត្តរាយ ទិសាយ វេស្សវណោ មហារាជា ទក្ខិណា-ភិមុខោ និសិន្នោ ហោតិ ទេវេ បុរក្ខត្វា យទា(៣) ភន្តេ ទេវលោកប្បា ច ទេវា តាវតឹសា សុធម្មាយំ សភាយំ សន្និសិន្នា ហោន្តិ សន្និបតិតា មហតី ច ទិព្វបរិសា សមន្តតោ និសិន្នា ហោន្តិ ចត្តារោ ច មហារាជានោ ចតុទ្ទិសា និសិន្នា ហោន្តិ ឥទំ នេសំ(៤) ហោតិ អាសនស្មឹ អថ បច្ឆា អម្ហាកំ អាសនំ ហោតិ យេ តេ ភន្តេ ទេវា ភគវតិ ព្រហ្មចរិយំ ចរិត្វា

១ ម. មហារាជា ។ ២ ម. ទេវេ បុរក្ខត្វា ។ ម. ទេវេ បុរក្ខិត្វា ។ ៣ ម. យទា បន ។ ៤ ម. នេសំ ។



ទាំងទេពបរិស័ទជាច្រើន ក៏អង្គុយនៅជុំវិញ ឯមហារាជទាំង ៤ អង្គ ក៏គង់ក្នុងទិសទាំង ៤ គឺ ធតរដ្ឋមហារាជ គង់ក្នុងទិសខាងកើត បែរព្រះភក្ត្រទៅទិសខាងលិច មានពួកទេវតា ចោមរោមគ្រៀបគ្រា វិរុឡ្ហកមហារាជ គង់ក្នុងទិសខាងត្បូង បែរព្រះភក្ត្រ ទៅទិសខាងជើង មានពួកទេវតា ចោមរោមគ្រៀបគ្រា វិរូបក្ខមហារាជ គង់ក្នុងទិសខាងលិច បែរព្រះភក្ត្រទៅទិសខាងកើត មានពួកទេវតា ចោមរោមគ្រៀបគ្រា វេស្សវណមហា-រាជ គង់ក្នុងទិសខាងជើង បែរព្រះភក្ត្រទៅទិសខាងត្បូង មានពួកទេវតា ចោមរោមគ្រៀបគ្រា បពិត្រព្រះអង្គដ៏ចំរើន កាលណាពួកទេវតា ជាន់តាវត្តិង្សទាំងឡាយ អង្គុយប្រជុំគ្នាក្នុងសាលា ឈ្មោះសុធម្មា ទាំងទេ-ពបរិស័ទជាច្រើនអង្គុយនៅជុំវិញ ឯមហារាជទាំង ៤ ក៏គង់ក្នុងទិសទាំង ៤ នេះជាអាសនៈ របស់មហារាជទាំង ៤ នោះ ក្នុងកាលនោះ អាសនៈរបស់ពួកយើងខ្ញុំ នៅខាងក្រោយ បពិត្រព្រះអង្គដ៏ចំរើន ពួកទេវតាណា បានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់ នៃព្រះមានព្រះភាគ ហើយមក

អនុប្បបន្នា(១) តាវតឹ្តសកាយំ(២) តេ អញ្ញេ ទេវេ អតិរោចន្តិ វណ្ណេន ចេវ យសសា ច តេន សុទំ ភន្តេ ទេវា តាវតឹ្តសា អត្តមនា ហោន្តិ បមុទិតា បីតិសោមនស្សជាតា ទិព្វា វត ភោ កាយា បរិបូរេន្តិ ហាយន្តិ អសុរកាយាតិ អថខោ ភន្តេ សក្កោ ទេវានមិន្ទោ ទេវានំ តាវតឹ្តសានំ សម្បសាទំ(៣) វិទិត្វា ឥមាហិ គាថាហិ អនុមោទិ

(២៨) មោទន្តិ វត ភោ ទេវា
តាវតឹ្តសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតំ ។
នវេ ច ទេវេ បស្សន្តា
វណ្ណវន្តេ យសស្សិនោ(៤)
សុគតស្មឹ ព្រហ្មចរិយំ
ចរិត្វាន ឥធាគតេ ។

១ ម. អនុប្បន្នា ។ ២ ម. តាវតឹ្តសកាយោ ។ ៣ ម. បាសាទំ ។ ឱ. សំបសាទំ ។ ៤ ម. យសស្សិនេ ។



កើតថ្មី ក្នុងជាន់តាវត្តិង្ស ពួកទេវតាទាំងនោះ ក៏រុងរឿង កន្លងលើសពួកទេវតាឯទៀត ដោយសម្បុរផង ដោយយសផង បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ ទើបពួកទេវតាជាន់តាវត្តិង្ស មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្សថា អើហ្ន៎ ពួកកាយទិព្វទៅពេញព្រៀបព្រា ពួកអសុរ-កាយ បាត់ទៅអស់ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា ជ្រាបនូវសេចក្តីជ្រះថ្លា របស់ពួកទេវតាជាន់តាវត្តិង្ស ហើយ ក៏បានអនុមោទនា ដោយនូវគាថាទាំងឡាយនេះថា

(២៨) អើហ្ន៎ ពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ រីករាយ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ដ៏ល្អផង ។ ពួកទេវតាជាន់តាវត្តិង្ស ក៏បានឃើញពួកទេវតាថ្មីៗ មានសម្បុរ មានយសដែលបានប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះសុគត ហើយមកកើតក្នុងទេវលោកនេះ ។

តេ អញ្ញេ អតិរោចន្តិ
វណ្ណេន យសសាយុនា
សាវកា ភូរិបញ្ញស្ស
វិសេសូបគតា ឥធ ។
ឥទំ ទិស្វាន នន្ទន្តិ
តាវតិំសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតំ ។

[៤៨] តេន សុទំ ភន្តេ ទេវា តាវតិំសា ភិយ្យោសោមត្តាយ អត្តមនា ហោន្តិ បមុទិតា បីតិសោមនស្សជាតា ទិព្វា វត ភោ កាយា បរិបូរេន្តិ ហាយន្តិ អសុរកាយាតិ ។ អថ(១) ភន្តេ សក្កោ ទេវានមិន្ទោ ទេវានំ តាវតិំសានំ សម្បសាទំ វិទិត្វា ទេវេ តាវតិំសេ អាមន្តេសិ ឥច្ឆេយ្យាថ នោ តុម្ហេ មារិសា តស្ស ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ សោតុន្តិ ។ ឥច្ឆាម(២) មយំ មារិសា តស្ស ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ

១ ឱ. អថខោ ។ ២ ឱ. ឥច្ឆេយ្យាម ។





ពួកទេវតាទាំងនោះ រុងរឿងកន្លង នូវពួកទេវតា ឯទៀត ដោយសម្បុរ ដោយយសនិងអាយុ ពួកសាវ័ក របស់ព្រះសម្ពុទ្ធ ព្រះអង្គមានព្រះប្រាជ្ញាដូចជាផែនដី ជាសាវ័កដល់នូវសេចក្ដីវិសេស ក្នុងទេវលោកនេះ ។ ពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ លុះឃើញហេតុនេះហើយ ក៏ត្រេកអរ ក្រាបថ្វាយបង្គំ ចំពោះព្រះតថាគតផង ចំពោះព្រះធម៌ដែលជាធម៌ល្អផង ។

(៤៨) បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជាពួកទេវតាជាន់តាវត្តិង្ស មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ដោយក្រៃលែង លើសប្រមាណថា អើហ្ន៎ ពួកកាយទិព្វ នៅពេញព្រៀបព្រា ពួកអសុរកាយ ថយទៅអស់ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា ជ្រាបនូវសេចក្ដីជ្រះថ្លា របស់ពួកទេវតាជាន់តាវត្តិង្សហើយ ទើបមានព្រះបន្ទូលនឹងពួកទេវតា ជាន់តាវត្តិង្សថា ម្នាលគ្នាយើង អ្នកទាំងឡាយ ចង់ស្ដាប់គុណ ជារបស់ពិត ៨ ប្រការ របស់ព្រះមានព្រះភាគនោះ ដែរឬ ។ ពួកទេវតាក្រាបទូលថា បពិត្រព្រះអង្គនិរទុក្ខ យើងខ្ញុំចង់ស្ដាប់គុណ ជារបស់ពិត ៨ ប្រការ របស់ព្រះ

សោត្ថិំ ។ អដ្ឋ ភន្តេ សក្កោ ទេវានមិន្ទោ ទេវានំ តាវតិំសានំ ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ បយិរុទាហាសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវតិំសា យាវញ្ចសោ(១) ភគវា ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ ឯវំ ពហុជនហិតាយ បដិបន្នំ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ ស្វាក្ខាតោ ខោ បន តស្ស ភគវតា(២) ធម្មោ សន្ទិដ្ឋិកោ អកាលិកោ

១ ឱ. យាវិទញ្ច សោ ។ ម. យាវញ្ចសោ ។ ២ ឱ. ម. តេន ភគវតា ។



មានព្រះភាគនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា ពោលសរសើរគុណ ជារបស់ពិត ៨ ប្រការ របស់ព្រះមានព្រះភាគ ដល់ពួកទេវតាជាន់តាវត្តិង្សថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ពួកទេវតាជាន់តាវត្តិង្ស សម្គាល់ហេតុនោះ ដូចម្តេច ព្រះមានព្រះភាគអង្គនោះទ្រង់ប្រតិបត្តិ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយរហូតមក ។ យើងពិចារណាមើលនូវគ្រូ ដែលជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ហើយនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាល ដែលកន្លងទៅហើយ មិនឃើញមានក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ១) ។ ធម៌ ដែលព្រះមានព្រះភាគអង្គនោះ ត្រាស់សំដែងហើយដោយល្អ ជាធម៌ដែលបុគ្គល គប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យនូវផលមិនរង់ចាំកាល ជាធម៌ដែល

ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ។ ឯវំ ឱបនយិកស្ស ធម្មស្ស ទេសេតារំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាមិ ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ ឥទំ កុសលន្តិ ខោ បន តេន ភគវតា សុប្បញ្ញត្តំ ឥទំ អកុសលន្តិ សុប្បញ្ញត្តំ ។ ឥទំ សាវជ្ជំ ។ ឥទំ អនវជ្ជំ ។ ឥទំ សេវិតព្វំ ។ ឥទំ ន សេវិតព្វំ ។ ឥទំ ហីនំ ។ ឥទំ បណីតំ ។ ឥទំ កណ្ហសុក្កសប្បដិភាគន្តិ សុប្បញ្ញត្តំ ។ ឯវំ កុសលាកុសលសាវជ្ជានវជ្ជសេវិតព្វាសេវិតព្វហីនប្បណីតកណ្ហសុក្កសប្បដិភាគានំ ធម្មានំ បញ្ញបេតារំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាមិ ន បនេតរហិ អញ្ញត្រ



ហើយបុគ្គល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងចិត្តបាន ជាធម៌ដែលវិញ្ញូជនគំនិតទូលាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ។ យើងពិចារណារកមើលសាស្ត្រ ដែលជាអ្នកសំដែងនូវធម៌ គួរបង្អោនចូលមកទុកក្នុងចិត្តបាន យ៉ាងនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ៦) ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តដោយប្រពៃហើយថា នេះជាកុសល ទ្រង់បញ្ញត្តហើយ ដោយប្រពៃថា នេះជាអកុសល ។ នេះប្រកបដោយទោស ។ នេះមិនប្រកបដោយទោស ។ នេះគួរសេព ។ នេះមិនគួរសេព ។ នេះជាអំពើថោកទាប ។ នេះជាអំពើថ្លៃថ្លា ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្ត ដោយប្រពៃហើយថា នេះ ធម៌ខ្មៅ ធម៌ស មិនមែនជាសប្បដិភាគ (លាយខ្មៅ លាយស) ។ យើងពិចារណារកមើលសាស្ត្រ ដែលជាអ្នកបញ្ញត្តនូវធម៌ទាំងឡាយ ដែលជាកុសល ជាអកុសល ប្រកបដោយទោស មិនប្រកបដោយទោស គួរសេពនិងមិនគួរសេព ថោកទាបនិងថ្លៃថ្លា ធម៌ខ្មៅ ធម៌ស និងសប្បដិភាគយ៉ាងនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមាន ក្នុងកាលឥឡូវនេះ

តេន ភគវតា ។ សុប្បញ្ញត្តា ខោ បន តេន ភគវតា សាវកានំ និព្វានគាមិនី បដិបទា សំសន្ទតិ និព្វានញ្ច បដិបទា ច ។ សេយ្យថាបិ នាម គង្គោទកំ យមុនោទកេន សំសន្ទតិ សមេតិ ឯវមេវ សុប្បញ្ញត្តា តេន ភគវតា សាវកានំ និព្វានគាមិនី បដិបទា សំសន្ទតិ និព្វានញ្ច បដិបទា ច ។ ឯវំ និព្វានគាមិនិយា បដិបទាយ(១) បញ្ញាបេតារំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ លទ្ធសហាយោ ខោ បន សោ ភគវា សេក្ខានញ្ចេវ បដិបន្នានំ ខីណាសវានញ្ច វុសិតវតំ តេន ភគវា អបនុជ្ជ ឯការាមតំ អនុយុត្តោ វិហរតិ ។ ឯវំ ឯការាមតំ អនុយុត្តំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ

១ ឱ. និព្វានគាមិនីបដិបទាយ ។



ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះជាគុណទី ៣) ។ បដិបទា ជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តល្អហើយ ដល់សាវកទាំងឡាយ តាំងពីព្រះនិព្វាន ទាំងបដិបទា ក៏ប្រៀបធៀបគ្នាបាន ។ ទឹកក្នុងទន្លេគង្គា ប្រៀបស្មើនឹងទឹកក្នុងទន្លេយមុនា ដូចម្តេចមិញ បដិបទា ជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តល្អហើយ ដល់សាវកទាំងឡាយ តាំងពីព្រះនិព្វាន ទាំងបដិបទា ក៏ប្រៀបធៀបគ្នាបានដូច្នោះដែរ ។ យើងពិចារណាគេមើលនូវគ្រូ ជាអ្នកបញ្ញត្ត នូវបដិបទា ជាទីទៅកាន់ព្រះនិព្វាន យ៉ាងនេះ ជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះ ជាគុណទី ៤) ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់បានពួកសេក្ខបុគ្គល ដែលឋិតនៅក្នុងបដិបទាហើយ និងពួកព្រះខីណាស្រព ដែលមានព្រហ្មចរិយធម៌អប់រំស្រេចហើយជាគ្នីគ្នា តែព្រះមានព្រះភាគ ទ្រង់មិនជាប់ព្រះទ័យក៏និងពួកគ្នានោះទេ ទ្រង់ប្រកបខ្ជាប់សេចក្តីត្រេកអរ តែមួយព្រះអង្គឯង ។ យើងពិចារណាគេមើលនូវគ្រូ ជាអ្នកប្រកបខ្ជាប់សេចក្តីត្រេកអរ តែម្នាក់ឯងយ៉ាងនេះ ដែលជាអ្នកប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លង

សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ អភិនិប្ផន្នោ(១) ខោ បន តស្ស ភគវតោ លាភោ អភិនិប្ផន្នោ(២) សិលោកោ យាវ មញ្ញេ ខត្តិយា សម្បិយាយមានរូបា(៣) វិហរន្តិ វិគតមទោ ខោ បន សោ ភគវា អាហារំ អាហារេតិ ។ ឯវំ វិគតមទំ អាហារំ អាហារយមានំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ យថាវាទី ខោ បន សោ ភគវា តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី ។ ឯវំ ធម្មានុធម្មប្បដិបន្នំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។

១-២ អភិនិប្បន្នោតិ ក បាឋ ។ ៣ ម. សម្បិយាយមានរូបា ។





ទៅហើយ ក៏មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះ ជាគុណទី ៥) ។ លាភសម្រេចហើយ សេចក្តីសរសើរ ក៏សម្រេចហើយ ដល់ព្រះមានព្រះភាគអង្គនោះ ទាំងពួកក្សត្រ ក៏មានសភាពជាអ្នកស្រឡាញ់ គប់រក (ព្រះអង្គ) ប៉ុន្តែព្រះមានព្រះភាគអង្គនោះ ប្រាសចាកសេចក្តីស្រវឹង (ក្នុងលាភជាដើមនោះ) ហើយ រមែងសោយនូវអាហារ (តាមធម្មតា) ។ យើងពិចារណាមើលនូវគ្រូ ជាអ្នកប្រាសចាកសេចក្តីស្រវឹង បរិភោគនូវអាហារយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ ក៏មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះ ជាគុណទី ៦) ។ ព្រះមានព្រះភាគនោះ ទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ដោយប្រការយ៉ាងនេះឯង ។ យើងពិចារណាមើលនូវគ្រូ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយក៏មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះ ជាគុណទី ៧) ។

តិណ្ណវិចិកិច្ឆោ ខោ បន សោ ភគវា វិគតកថំកថោ បរិយោសិតសង្កប្បោ អជ្ឈាសយំ អាទិព្រហ្មចរិយំ ។ ឯវំ តិណ្ណវិចិកិច្ឆំ វិគតកថំកថំ បរិយោសិតសង្កប្បំ អជ្ឈាសយំ អាទិព្រហ្មចរិយំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ ឥមេ ខោ ភន្តេ សក្កោ ទេវានមិន្ទោ ទេវានំ តាវតឹសានំ ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ បយិរុទាហាសិ ។

(៨០) តេន សុទំ ភន្តេ ទេវា តាវតឹសា ភិយ្យោសោមត្តាយ អត្តមនា ហោន្តិ បមុទិតា បីតិសោមនស្សជាតា



ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្លងផុតសេចក្តីសង្ស័យអស់ហើយ ប្រាសចាកសេចក្តីងឿងឆ្ងល់ហើយ ទ្រង់មានព្រះតម្រិះដល់ទីបំផុត(១) ហើយ ដោយព្រហ្មចរិយធម៌ខាងដើម ជាទីអាស្រ័យដ៏ឧត្តម ។ យើងពិចារណារកមើលនូវគ្រូ ជាអ្នកឆ្លងផុតសេចក្តីសង្ស័យ ប្រាសចាកសេចក្តីងឿងឆ្ងល់ មានតម្រិះដល់ទីបំផុត ដោយព្រហ្មចរិយធម៌ខាងដើម ជាទីអាស្រ័យដ៏ឧត្តម យ៉ាងនេះ ដែលប្រកបដោយគុណនេះ គឺក្នុងអតីតកាលដែលកន្លងទៅ ហើយក៏មិនឃើញមាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគនោះចេញហើយ ក៏មិនឃើញមានដែរ (នេះ ជាគុណទី ៨) ។ បពិត្រព្រះអង្គដ៏ចំរើន សក្កទេវរាជ ជាធំជាងពួកទេវតា បានសំដែងនូវគុណ ជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគនេះឯង ដល់ពួកទេវតា ជាន់តាវត្តិង្ស ។

(៨០) បពិត្រព្រះអង្គដ៏ចំរើន ព្រោះហេតុនោះ បានជាពួកទេវតា ជាន់តាវត្តិង្ស ជាអ្នកមានចិត្តត្រេកអរ មានចិត្តទន់ កើតបីតិសោមនស្ស

១ អដ្ឋកថា ថា ពួកព្រះមានសេចក្តីត្រិះរិះអស់ត្រឹមអរហត្ត ត្រឹមបឋមជ្ឈាន ។ល។ ត្រឹមសាវកបារមីញាណ ត្រឹមបច្ចេកពោធិញ្ញាណ តែព្រះមានព្រះភាគមានសេចក្តីត្រិះរិះរហូតដល់សព្វញ្ញុតញ្ញាណ ។

ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ សុត្វា ។ តត្រ[១] ភន្តេ ឯកច្ចេ ទេវា ឯវមាហំសុ អហោ វត មារិសា ចត្តារោ សម្មាសម្ពុទ្ធា លោកេ ឧប្បជ្ជេយ្យុំ ធម្មញ្ច ទេសេយ្យុំ យថរិវ ភគវា តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ ឯកច្ចេ ទេវា ឯវមាហំសុ តិដ្ឋន្តុ មារិសា ចត្តារោ សម្មាសម្ពុទ្ធា អហោ វត មារិសា តយោ សម្មាសម្ពុទ្ធា លោកេ ឧប្បជ្ជេយ្យុំ ធម្មញ្ច ទេសេយ្យុំ យថរិវ ភគវា តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ ឯកច្ចេ ទេវា ឯវមាហំសុ តិដ្ឋន្តុ មារិសា តយោ សម្មាសម្ពុទ្ធា អហោ វត មារិសា ទ្វេ សម្មាសម្ពុទ្ធា លោកេ ឧប្បជ្ជេយ្យុំ ធម្មញ្ច ទេសេយ្យុំ យថរិវ

១ ម. តត្ថ ។



ពីក្រៃលែងលើសប្រមាណ ព្រោះបានស្តាប់គុណ ជារបស់ពិតទាំង ៨ ប្រការ របស់ព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាទេវតាទាំងនោះ ទេវតាពួកខ្លះ នាំគ្នាពោលយ៉ាងនេះថា ម្នាលគ្នាយើង ធ្វើម្តេចហ្ន៎ បានព្រះសម្មាសម្ពុទ្ធ ៤ ព្រះអង្គត្រាស់ឡើងក្នុងលោក សម្តែងធម៌ឲ្យដូចព្រះមានព្រះភាគ ការសម្តែងធម៌នោះសមជាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ទេវតាពួកខ្លះ នាំគ្នាពោលយ៉ាងនេះថា នែគ្នាយើង ព្រះសម្មាសម្ពុទ្ធ ៤ ព្រះអង្គលើកទុកសិនចុះ នែគ្នាយើង ធ្វើម្តេចហ្ន៎ ឲ្យតែព្រះសម្មាសម្ពុទ្ធ ៣ ព្រះអង្គត្រាស់ឡើងក្នុងលោក សម្តែងធម៌ឲ្យដូចព្រះមានព្រះភាគ ការណ៍នោះសមជាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ទេវតាពួកខ្លះ នាំគ្នាពោលយ៉ាងនេះថា នែគ្នាយើង ព្រះសម្មាសម្ពុទ្ធ ៣ ព្រះអង្គលើកទុកសិនចុះ នែគ្នាយើង ធ្វើម្តេចហ្ន៎ ឲ្យតែព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គត្រាស់ឡើងក្នុងលោក សម្តែងធម៌ឲ្យដូច

ភគវា តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ ឯវំ វុត្តេ ភន្តេ សក្កោ ទេវានមិន្ទោ ទេវេ តាវតិំសេ ឯតទវោច អដ្ឋានំ ខោ ឯតំ(១) មារិសា អនវកាសោ យំ ឯកិស្សា លោកធាតុយា ទ្វេ អរហន្តោ សម្មាសម្ពុទ្ធា អបុព្ពំ អចរិមំ ឧប្បជ្ជេយ្យុំ នេតំ ឋានំ វិជ្ជតិ អហោ វត មារិសា សោ ច(២) ភគវា អប្បាពាធោ អប្បាតង្កោ ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ តទស្ស ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។ អថ ខោ(៣) ភន្តេ យេនត្ថេន ទេវា តាវតិំសា សុធម្មាយំ សភាយំ សន្និសិន្នា ហោន្តិ សន្និបតិតា

១ ។. ឯតំ ។ ២ ។. បសត្ថេន វិសុទ្ធិ ។ ៣ ។. អថ ។



ព្រះមានព្រះភាគ ការណ៍នោះគួរជាប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលពួកទេវតាពោលយ៉ាងនេះហើយ សក្កទេវរាជជាធំជាងពួកទេវតា បានពោលពាក្យនេះនឹងពួកទេវតាជាន់តាវត្តិង្សថា ម្នាលគ្នាយើង ដំណើរនេះមិនមែនជាហេតុ មិនមែនជាឱកាសឡើយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ២ ព្រះអង្គមុខក្រោយ ក្នុងលោកធាតុតែមួយ នឹងកើតព្រមគ្នា ដោយហេតុណា ហេតុនុ៎ះមិនដែលមានទេ ម្នាលគ្នាយើង សូមឲ្យតែព្រះមានព្រះភាគអង្គនោះ កុំឲ្យមានអាពាធ កុំឲ្យមានទុក្ខ គង់នៅអស់កាលជាយូរអង្វែង ការណ៍នោះ គង់តែប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយដែរហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ពួកទេវតាជាន់តាវត្តិង្ស អង្គុយប្រជុំគ្នាក្នុងរោងសភាឈ្មោះសុធម្មា ដោយប្រយោជន៍ណា

តំ អត្ថំ ចិន្តយិត្វា តំ អត្ថំ មន្តយិត្វា វុត្តវចនាបិ តំ(១) ចត្តារោ មហារាជានោ តស្មិំ អត្ថេ ហោន្តិ បច្ចនុសិដ្ឋវចនាបិ តំ(២) ចត្តារោ មហារាជានោ តស្មិំ អត្ថេ ហោន្តិ សកេសុ សកេសុ អាសនេសុ ឋិតា អវិបក្កន្តា(៣) ។

(៨១) តេ វុត្តវាក្យា រាជានោ
បដិគ្គយ្ហានុសាសនឹ
វិប្បសន្នមនា សន្តា
អដ្ឋំសុ សម្ហិ អាសនេតិ ។

(៨២) អថខោ(៤) ភន្តេ ឧត្តរាយ ទិសាយ ឧឡារោ អាលោកោ សញ្ជាយតិ ឱភាសោ បាតុរហោសិ អតិក្កម្មេវ ទេវានំ ទេវានុភាវំ ។ អថ ភន្តេ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹសេ អាមន្តេសិ យថា ខោ មារិសា និមិត្តា ទិស្សន្តិ អាលោកោ សញ្ជាយតិ ឱភាសោ បាតុភវតិ ព្រហ្មា បាតុភវិស្សតិ ព្រហ្មុនោ ហេតំ បុព្វនិមិត្តំ បាតុភាវាយ យទិទំ អាលោកោ សញ្ជាយតិ ឱភាសោ បាតុភវតីតិ ។

១ ម. វុត្តវចនា តាបិ តំ ។ ២ ម. បច្ចានុសិដ្ឋវចនា តាបិ តំ ។ ៣ ម. អវិបក្កន្តា ។ ៤ ឱ. អថ ។



មហារាជទាំង ៤ អង្គនោះ គិតគន់ប្រយោជន៍នោះ ប្រឹក្សាប្រយោជន៍នោះ ហើយតាំងនៅក្នុងប្រយោជន៍នោះ តាមពាក្យដែលតាវត្តិំសទេវតាប្រាប់ហើយផង មហារាជទាំង ៤ អង្គនោះ តម្កល់នៅក្នុងប្រយោជន៍នោះ តាមពាក្យដែលតាវត្តិំសទេវតា ប្រៀនប្រដៅហើយផង ឋិតនៅលើអាសនៈរបស់ខ្លួន ៗ មិនចៀសចេញទៅឡើយ ។

(៨១) ព្រះរាជាទាំងនោះ ទទួលពាក្យប្រៀនប្រដៅ តាម
ពាក្យដែលតាវត្តិំសទេវតា ប្រាប់ហើយ ក៏មានចិត្តជ្រះថ្លា
មានចិត្តស្ងប់រម្ងាប់ ឋិតនៅលើអាសនៈរបស់ខ្លួន ។

(៨២) បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ពន្លឺដ៏លើសលុបក៏កើតឡើង រស្មីរុងរឿងលើសលែងនូវទេវានុភាព របស់ពួកទេវតា ក៏កើតប្រាកដឡើងក្នុងទិសខាងជើង ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ សក្កទេវរាជជាធំជាងពួកទេវតា មានព្រះបន្ទូលនឹងពួកទេវតាជាន់តាវត្តិំសថា ម្នាលពួកយើង និមិត្តទាំងឡាយប្រាកដឡើង ពន្លឺកើតឡើង រស្មីរុងរឿងកើតប្រាកដ ក្នុងកាលណា ព្រហ្មនឹងមានប្រាកដ ក្នុងកាលនោះ នេះ ជាបុព្វនិមិត្តដែលព្រហ្មមានប្រាកដ បានជាពន្លឺកើតឡើង រស្មីកើតឡើងជាក់ស្តែង ។

(៥៣) យថា និមិត្តា ទិស្សន្តិ
ព្រហ្មា បាតុភវិស្សតិ
ព្រហ្មុនោ ហេតំ បុព្វនិមិត្តំ
ឱភាសោ វិបុលោ មហាតិ ។

(៥៤) អថ ខោ ភោ តាវតឹសា យថាសកេសុ អាសនេសុ និសីទឹសុ ឱភាសមេតំ ញស្សាម យំវិបាកោ ភវិស្សតិ សច្ឆិកត្វា វ នំ គមិស្សាមាតិ ។ ចត្តារោបិ មហារាជានោ(១) យថាសកេសុ អាសនេសុ និសីទឹសុ ឱភាសមេតំ ញស្សាម យំវិបាកោ ភវិស្សតិ សច្ឆិកត្វា វ នំ គមិស្សាមាតិ ។ ឥទំ សុត្វា ទេវា តាវតឹសា ឯកគ្គា(២) សមាបជ្ជឹសុ ឱភាសមេតំ ញស្សាម យំវិបាកោ ភវិស្សតិ សច្ឆិកត្វា វ នំ គមិស្សាមាតិ ។ យទា ភោ ព្រហ្មា សនង្កុមារោ ទេវានំ តាវតឹសានំ បាតុភវតិ ឱឡារិកំ អត្តភាវំ អភិនិម្មិនិត្វា បាតុភវតិ ។ យោ ខោ បន ភោ ព្រហ្មុនោ បកតិវណ្ណោ អនភិសម្ភវនីយោ

១ ឱ. ចត្តារោ ច មហារាជា ។ ២ ឱ. ឯកគ្គា ។



(៥៣) និមិត្តទាំងឡាយប្រាកដឡើង ក្នុងកាលណា ព្រហ្ម គង់មានប្រាកដ (ក្នុងកាលនោះ) ពន្លឺរុងរឿងដ៏ធំទូលាយ នេះឯង ជាបុព្វនិមិត្ត របស់ព្រហ្ម ។

(៥៤) បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ ពួកទេវតាជាន់តាវត្តិង្ស អង្គុយលើអាសនៈទាំងឡាយតាមសមគួរដល់ខ្លួន ហើយគិតថា វិបាកនឹងមានប្រាកដ ព្រោះអាស្រ័យនូវពន្លឺណា យើងទាំងឡាយ នឹងដឹងនូវពន្លឺនុ៎ះ ធ្វើឲ្យច្បាស់នូវពន្លឺនោះសិនហើយសឹមទៅ ។ ចំណែកមហារាជទាំង ៤ អង្គ គង់លើអាសនៈទាំងឡាយតាមសមគួរដល់ខ្លួន គិតថា វិបាកនឹងមានប្រាកដ ព្រោះអាស្រ័យពន្លឺណា យើងទាំងឡាយ នឹងដឹងនូវពន្លឺនុ៎ះ ធ្វើឲ្យច្បាស់នូវពន្លឺនោះសិនហើយសឹមទៅ ។ ពួកទេវតាជាន់តាវត្តិង្ស លុះឮពាក្យនេះហើយ ក៏មានចិត្តមូលតែមួយ ប្រជុំគ្នាគិតថា វិបាកនឹងមានប្រាកដ ព្រោះអាស្រ័យពន្លឺណា យើងទាំងឡាយ នឹងដឹងនូវពន្លឺនុ៎ះ ធ្វើឲ្យច្បាស់នូវពន្លឺនោះសិនហើយសឹមទៅ ។ បពិត្រព្រះអង្គដ៏ចំរើន កាលណា សនង្កុមារព្រហ្ម មានប្រាកដដល់ពួកទេវតាជាន់តាវត្តិង្សហើយ និមិត្តអត្តភាពដ៏លើសលប់ឲ្យកើតប្រាកដ ។ បពិត្រព្រះអង្គដ៏ចំរើន សម្បុរជាប្រក្រតីរបស់ព្រហ្មណា ដែលពួកទេវតាមិនទាន់

សោ ទេវានំ តាវត្តឹសានំ ចក្ខុបថស្មឹ ។ យទា ភន្តេ ព្រហ្មា សនង្កុមារោ ទេវេហិ តាវត្តឹសេហិ បាតុភវតិ សោ អញ្ញេ ទេវេ អតិរោចតិ(១) វណ្ណេន ចេវ យសសា ច ។ សេយ្យថាបិ ភន្តេ សោវណ្ណោ វិគ្គ-ហោ មានុសំ វិគ្គហំ អតិរោចតិ ឯវមេវ ខោ ភន្តេ យទា ព្រហ្មា សនង្កុមារោ ទេវេហិ តាវត្តឹសេហិ បាតុភ-វតិ សោ អញ្ញេ ទេវេ អតិរោចតិ វណ្ណេន ចេវ យសសា ច ។ យទា ភន្តេ ព្រហ្មា សនង្កុមារោ ទេវេហិ តាវត្តឹសេហិ បាតុភវតិ ន តស្សំ ប-រិសាយំ(២) កោចិ ទេវោ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ ។ សព្វេវ(៣) តុណ្ហីភូតា បញ្ជលិកា បល្លង្កេ(៤) និសីទន្តិ យស្សទានិ ទេវស្ស ឥច្ឆិស្សតិ ព្រហ្មា សនង្កុមារោ តស្ស ទេវស្ស បល្លង្កេ និសីទិស្សតីតិ ។ យស្ស ខោ បន ភន្តេ ទេវស្ស ព្រហ្មា សនង្កុមា-រោ បល្លង្កេ និសីទតិ ឧឡារំ សោ លភតិ ទេវោ

១ ម. អតិរោចតិ ។ ២ ម. តស្សំ បរិសាយំ ។ ៣ ឱ. សព្វេច ទេវា ។ ៤ ម. បល្លង្កេន ។



ឃើញ សម្បុរជាប្រក្រតីនោះ (កុំប្រាកដ) ក្នុងគន្លងចក្ខុរបស់ពួកទេវតាជាន់តាវត្តិង្ស ។ បពិត្រព្រះអង្គដ៏ចម្រើន កាលណាសនង្កុមារព្រហ្ម មានប្រាកដ ដល់ពួកទេវតាជាន់តាវត្តិង្ស ព្រហ្មនោះ ក៏រុងរឿងកន្លងនូវពួកទេវតាឯទៀតដោយសម្បុរផង ដោយយសផង ។ បពិត្រព្រះអង្គដ៏ចម្រើន រូបដែលធ្វើដោយមាស រមែងរុងរឿងកន្លងនូវកាយ របស់មនុស្សដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន កាលណា សនង្កុមារព្រហ្ម មានប្រាកដ ដល់ពួកទេវតាជាន់តាវត្តិង្ស ព្រហ្មនោះ ក៏រុងរឿងកន្លងនូវពួកទេវតាឯទៀតដោយសម្បុរផង ដោយយសផង ដូច្នោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលណាសនង្កុមារព្រហ្ម មានប្រាកដដល់ពួកទេវតាជាន់តាវត្តិង្ស មិនមានទេវតាណាមួយក្នុងបរិស័ទនោះសំពះ ឬក្រោកទទួល ឬគឺអញ្ជើញដោយអាសនៈឡើយ ។ ពួកទេវតាទាំងអស់ស្ងៀមព្រងើយ ទាំងផ្គងអញ្ជលីលើបល្ល័ង្ក គិតគ្នាថា ឥឡូវនេះ សនង្កុមារព្រហ្ម ប្រាថ្នានឹងគង់លើបល្ល័ង្ករបស់ទេវតាណា ក៏គង់លើបល្ល័ង្ក របស់ទេវតានោះចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្មគង់លើបល្ល័ង្ករបស់ទេវតាណា ទេវតានោះ ក៏បាននូវសេចក្តីត្រេកអរដ៏លើសលប់ ទេវតា

វេទប្បដិលាភំ ឧឡារំ សោ លភតិ ទេវោ សោ-
មនស្សប្បដិលាភំ ។ សេយ្យថាបិ ភន្តេ រាជា ខត្តិ-
យោ មុទ្ធាវសិត្តោ អធុនាភិសិត្តោ(១) រជ្ជេន ឧឡារំ សោ
លភតិ វេទប្បដិលាភំ ឧឡារំ សោ លភតិ សោ-
មនស្សប្បដិលាភំ ឯវមេវ ខោ ភន្តេ យស្ស ទេវស្ស
ព្រហ្មា សនង្កុមារោ បល្លង្កេ និសីទតិ ឧឡារំ សោ
លភតិ ទេវោ វេទប្បដិលាភំ ឧឡារំ សោ លភតិ
ទេវោ សោមនស្សប្បដិលាភំ ។ អថ ភន្តេ ព្រហ្មា
សនង្កុមារោ ទេវានំ តាវតឹសានំ សម្បសាទំ វិទិត្វា
អន្តរហិតោ ឥមាហិ គាថាហិ អនុមោទិ

(៨៨) មោទន្តិ វត ភោ ទេវា
តាវតឹសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតំ ។
នវេ ច ទេវេ បស្សន្តា

១ ម. អធុតាភិសិត្តោ ។



នោះក៏បាននូវសេចក្ដីត្រេកអរចិត្តដ៏លើសលប់ ៗ បពិត្រព្រះអង្គដ៏ចំរើន ក្សត្រជាស្ដេចដែលបានមុទ្ធាភិសេកហើយ អភិសេកហើយថ្មីៗ ដោយរាជសម្បត្តិ ព្រះរាជានោះ តែងបាននូវសេចក្ដីត្រេកអរដ៏លើសលប់ ព្រះរាជានោះ តែងបាននូវសេចក្ដីត្រេកអរព្រោះចិត្តដ៏លើសលប់ ដោយរាជសម្បត្តិ មានឧបមាដូចម្ដេចមិញ បពិត្រព្រះអង្គដ៏ចំរើន សនង្កុមារព្រហ្ម គង់លើបល្ល័ង្ករបស់ទេវតាណា ទេវតានោះ ក៏បាននូវសេចក្ដីត្រេកអរដ៏លើសលប់ ទេវតានោះ ក៏បាននូវសេចក្ដីត្រេកអរចិត្តដ៏លើសលប់ មានឧបមេយ្យដូច្នោះដែរ ។ បពិត្រព្រះអង្គដ៏ចំរើន ក្នុងកាលនោះ សនង្កុមារព្រហ្មដឹងនូវសេចក្ដីជ្រះថ្លារបស់ពួកទេវតា ជាន់តាវត្តិង្សហើយ ក៏អនុមោទនាដោយគាថាទាំងនេះ ហើយក៏បាត់ទៅ

(៨៨) អើហ្ន៎ ពួកទេវតាជាន់តាវត្តិង្សព្រមទាំងព្រះឥន្ទ្រ រមែងត្រេកអរ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ជាធម៌ដ៏ល្អផង ៗ ពួកទេវតាជាន់តាវត្តិង្ស បានឃើញពួកទេវតាថ្មីៗ

វណ្ណវន្តេ យសស្សិនោ
សុគតស្មឹ ព្រហ្មចរិយំ
ចរិត្វាន ឥធាគតេ ។
តេ អញ្ញេ អតិរោចន្តិ
វណ្ណេន យសសាយុនា
សាវកា ភូរិបញ្ញស្ស
វិសេសូបគតា ឥធ ។
ឥទំ ទិស្វាន នន្ទន្តិ
តាវតិំសា សហិន្ទកា
តថាគតំ នមស្សន្តា
ធម្មស្ស ច សុធម្មតន្តិ ។

(៨៦) ឥទមត្ថំ ភន្តេ ព្រហ្មា សនង្កុមារោ អភាសិត្ថ ។ ឥទមត្ថំ ភន្តេ ព្រហ្មុនោ សនង្កុមារស្ស ភាសតោ អដ្ឋង្គសមន្នាគតោ សរោ ហោតិ វិស្សដ្ឋោ ច វិញ្ញេយ្យោ ច មញ្ជុ ច សវនីយោ ច ពិន្ទុ ច អវិសារី ច គម្ភីរោ ច និន្នាទី ច ។ យថាបរិសំ ខោ បន ភន្តេ ព្រហ្មា សនង្កុមារោ សរេន វិញ្ញាបេតិ ន





មានសម្បុរ មានយស ដែលបានប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់នៃព្រះសុគត ហើយមកកើតក្នុងទេវលោកនេះ ។ ពួកទេវតាដទៃនោះ រុងរឿងកន្លងនូវពួកទេវតាឯទៀត ដោយសម្បុរ ដោយយសនិងអាយុ ពួកសាវ័ក របស់ព្រះសម្ពុទ្ធព្រះអង្គមានព្រះប្រាជ្ញាដូចផែនដី ជាសាវ័ក ដល់នូវសេចក្តីវិសេសក្នុងទេវលោកនេះ ។ លុះពួកទេវតាជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ឃើញហេតុនេះហើយ ទើបរីករាយ នមស្ការចំពោះព្រះតថាគតផង ចំពោះព្រះធម៌ ជាធម៌ល្អផង ។

(៨៦) បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម បានពោលនូវសេចក្តីនេះហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលសនង្កុមារព្រហ្មពោលនូវសេចក្តីនេះ ក៏មានសំឡេងប្រកបដោយអង្គ ៨ គឺសំឡេងក្បោះក្បាយ ១ ងាយយល់ ១ ទន់ពិរោះ ១ គួរស្តាប់ ១ មូល ១ មិនគ្រាំ ១ ក្រអួន ១ លាន់ឮ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម ញុំាងបរិស័ទ

ចស្ស ពហិទ្ធា បរិសាយ ឃោសោ និច្ឆរតិ ។ យស្ស ខោ បន ភន្តេ ឯវំ អដ្ឋង្គសមន្នាគតោ សរោ ហោតិ សោ វុច្ចតិ ព្រហ្មស្សរោតិ ។ អថខោ ភន្តេ ទេវា តាវត្តឹសា ព្រហ្មានំ សនង្កុមារំ(១) ឯតទវោចុំ សាធុ មហាព្រហ្មេ ឯតទេវ មយំ សង្ខាយ មោទាម អត្ថិ ច សក្កេន ទេវានមិន្ទេន តស្ស ភគវតោ អដ្ឋ យថាភុច្ចា វណ្ណា ភាសិតា តេ ច មយំ សង្ខាយ មោទាមាតិ ។ អថខោ ភន្តេ ព្រហ្មា សនង្កុមារោ សក្កំ ទេវានមិន្ទំ ឯតទវោច សាធុ ទេវានមិន្ទ មយម្បិ តស្ស ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ សុណេយ្យាមាតិ ។ ឯវំ មហាព្រហ្មាតិ ខោ ភន្តេ សក្កោ ទេវានមិន្ទោ ព្រហ្មុនោ សនង្កុមារស្ស បដិស្សុត្វា ភគវតោ(២) អដ្ឋ យថាភុច្ចេ វណ្ណេ បយិរុទាហាសិ ។ តំ កឹ មញ្ញតិ ភវំ មហាព្រហ្មា

១ ឱ. ព្រហ្មសនង្កុមារំ ។ ២ ឱ. ម. ព្រហ្មសនង្កុមារស្ស ភគវតោ ។ ព្រហ្មសនង្កុមារស្សាតិ ឃាលេន ភវិតព្វំ ។



ចំនែកសំឡេងដ៏ច្បាស់ដោយសំឡេងនេះ សំឡេងក្រោកក្រៅរបស់ព្រហ្មនោះ មិនបានផ្សាយចេញទៅខាងក្រៅបរិស័ទឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលណា មានសំឡេងប្រកបដោយអង្គ ៨ យ៉ាងនេះ បុគ្គលនោះ គេហៅថា អ្នកមានសំឡេងដូចសំឡេងព្រហ្ម ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះ ពួកទេវតាជាន់តាវត្តិង្ស បានពោលពាក្យនេះនឹងសនង្កុមារព្រហ្មថា បពិត្រមហាព្រហ្ម ប្រពៃហើយ ពួកយើងរីករាយ ព្រោះបានដឹងសេចក្តីនុ៎ះឯង មួយទៀត សក្កទេវិន្ទ ជាធំជាងពួកទេវតា បានសំម្តែងគុណ ជារបស់ពិត ទាំង ៨ ប្រការ របស់ព្រះមានព្រះភាគនោះហើយវិញ ពួកយើងរីករាយ ព្រោះបានដឹងនូវគុណទាំងនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង សនង្កុមារព្រហ្ម បាននិយាយសេចក្តីនេះនឹងសក្កទេវិន្ទ ជាធំជាងពួកទេវតាថា បពិត្រទេវានមិន្ទ ប្រពៃហើយ ពួកយើងគួរស្តាប់នូវគុណ ជារបស់ពិត ទាំង ៨ ប្រការ របស់ព្រះមានព្រះភាគនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សក្កទេវិន្ទ ជាធំជាងពួកទេវតា ទទួលពាក្យ របស់សនង្កុមារព្រហ្មថា បពិត្រមហាព្រហ្ម យ៉ាងហ្នឹងហើយ ទើបថ្លែងនូវគុណ ជារបស់ពិត ទាំង ៨ ប្រការ របស់ព្រះមានព្រះភាគថា មហាព្រហ្មដ៏ចម្រើន សម្គាល់នូវហេតុនោះដូចម្តេច ព្រះ

យាវញ្ចេសោ(១) ភគវា ពហុជនហិតាយ បដិបន្នោ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ ឯវំ ពហុជនហិតាយ បដិបន្នំ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ ស្វាក្ខាតោ ខោ បន តស្ស ភគវតោ ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ ។ ឯវំ ឱបនយិកស្ស ធម្មស្ស ទេសេតារំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សម-

១ ម. យាវទេសោ ។ ឱ. យាវញ្ចេសោ ។



មានព្រះភាគនោះ ទ្រង់ប្រតិបត្តិ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ហេតុមក ។ យើងពិចារណាមើល នូវសាស្តាជាអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាល ដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ធម៌ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់សម្តែងហើយ ដោយល្អ ជាធម៌ដែលអរិយបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌ដែលអរិយបុគ្គល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន ជាធម៌ដែលអរិយបុគ្គល គួរបង្អោនចូលមកទុកក្នុងចិត្តបាន ជាធម៌ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ក្នុងចិត្តរបស់ខ្លួន ។ យើងពិចារណាមើលនូវគ្រូ ជាអ្នកសម្តែងធម៌ ដែលគួរបង្អោនចូលមកទុកក្នុងចិត្តបានយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិន

នុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ ឥទំ កុសលន្តិ ខោ បន តេន ភគវតា សុបញ្ញត្តំ ឥទំ អកុសលន្តិ សុបញ្ញត្តំ ។ ឥទំ សាវជ្ជំ ។ ឥទំ អនវជ្ជំ ។ ឥទំ សេវិតព្វំ ។ ឥទំ ន សេវិតព្វំ ។ ឥទំ ហីនំ ។ ឥទំ បណីតំ ។ ឥទំ កណ្ហសុក្កសប្បដិភាគន្តិ សុបញ្ញត្តំ ។ ឯវំ កុសលាកុសលសាវជ្ជានវជ្ជសេវិតព្វាសេវិតព្វហីនបណីតកណ្ហសុក្កសប្បដិភាគានំ ធម្មានំ បញ្ញាបេតារំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ សុបញ្ញត្តា ខោ បន តេន ភគវតា សាវកានំ និព្វានគាមិនី បដិបទា សំសន្ទតិ និព្វានញ្ច បដិបទា ច ។ សេយ្យថាបិ នាម គង្គោទកំ យមុនោទកេន សំសន្ទតិ សមេតិ ឯវមេវ សុបញ្ញត្តា តេន ភគវតា សាវកានំ និព្វានគាមិនី បដិបទា



ឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តហើយថា នេះ ជាកុសល ទ្រង់បញ្ញត្តប្រពៃហើយថា នេះ ជាអកុសល ។ នេះ ប្រកបដោយទោស ។ នេះ មិនប្រកបដោយទោស ។ នេះ គួរសេព ។ នេះ មិនគួរសេព ។ នេះ ជាធម៌ថោកទាប ។ នេះ ជាធម៌ថ្លៃថ្លា ។ ព្រះមានព្រះភាគ ទ្រង់បញ្ញត្តប្រពៃហើយថា នេះ ធម៌ខ្មៅ ធម៌-ស និងជាសប្បដិភាគ ។ យើងពិចារណាមើលនូវសាស្តា ជាអ្នកបញ្ញត្តនូវធម៌ទាំងឡាយ ដែលជាកុសល ជាអកុសល ប្រកបដោយទោស មិនប្រកបដោយទោស គួរសេព មិនគួរសេព ថោកទាប និងថ្លៃថ្លា ធម៌ខ្មៅ ធម៌-ស និងជាសប្បដិភាគយ៉ាងនេះ ដែលប្រកបដោយអង្គនេះ ក្នុងអតីតកាល ដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះ ទ្រង់បញ្ញត្តល្អហើយដល់សាវកទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា រមែងប្រៀបធៀបគ្នាបាន ។ ទឹកក្នុងទន្លេគង្គា ប្រៀបបាននឹងទឹកក្នុងទន្លេយមុនា ដូចម្តេចមិញ បដិបទាជាទីទៅកាន់ព្រះនិព្វាន ដែលព្រះមានព្រះភាគអង្គនោះបញ្ញត្តល្អហើយ ដល់សាវក

សំសន្ទតិ និព្វានញ្ច បដិបទា ច ។ យំ និព្វានគាមិនិ-
យា បដិបទាយ បញ្ញាបេតារំ(១) ឥមិនាបង្គេន សមន្នាគតំ
សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ
អញ្ញត្រ តេន ភគវតា ។ លទ្ធសហាយោ ខោ បន
សោ ភគវា សេក្ខានញ្ចេវ បដិបន្នានំ ខីណាសវានញ្ច
វុសិតវតំ តេន ភគវា អបនុជ្ជ ឯការាមតំ អនុយុត្តោ
វិហរតិ ។ យំ ឯការាមតំ អនុយុត្តំ ឥមិនាបង្គេន
សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន
បនេតរហិ អញ្ញត្រ តេន ភគវតា ។ អភិនិប្ផន្នោ(២) ខោ
បន តស្ស ភគវតោ លាភោ អភិនិប្ផន្នោ សិលោកោ
យាវ មញ្ញេ ខត្តិយា សម្បិយាយមានរូបា វិហរន្តិ វិគ-
តមទោ ខោ បន សោ ភគវា អាហារំ អាហារេតិ ។

១. ម. និព្វានគាមិនីបដិបទាយ បញ្ញាបេតារំ ។ ២. ម. អភិនិប្បន្នោ ។





ទាំងឡាយ ទាំងព្រះនិព្វាន ទាំងបដិបទា រមែងប្រៀបផ្ទៀបស្មើគ្នា
បាន ដូច្នោះដែរ ។ យើងពិចារណាកមើលនូវសាស្តា ជាអ្នកបញ្ញត្តិ
នូវបដិបទាជាទីទៅកាន់ព្រះនិព្វានយ៉ាងនេះ ដែលប្រកបដោយគុណនេះ
ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវ
នេះ ក្រៅអំពីព្រះមានព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមាន
ឡើយ ។ ព្រះមានព្រះភាគ ទ្រង់បានពួកសេក្ខបុគ្គល ដែលឋិតនៅ
ក្នុងបដិបទា ហើយនិងព្រះខីណាស្រព ដែលមានព្រហ្មចរិយធម៌អប់រំ
ស្រេចហើយជាគ្នា តែព្រះមានព្រះភាគ ទ្រង់មិនជាប់ព្រះទ័យនឹងគ្នា
នោះទេ ទ្រង់ប្រកបសេចក្តីត្រេកអរ តែមួយអង្គឯង ។ យើងពិចារណាក
មើលនូវសាស្តា ជាអ្នកប្រកបនូវសេចក្តីត្រេកអរតែម្នាក់ឯងយ៉ាងនេះ ដែល
ប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញ
មាន ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគ អង្គនោះចេញហើយ
ក៏មិនឃើញមានឡើយ ។ លាភសម្រេចហើយ សេចក្តីសរសើរក៏សម្រេច
ហើយ ដល់ព្រះមានព្រះភាគអង្គនោះ ទាំងពួកក្សត្រ ក៏មានសភាពជា
អ្នកស្រឡាញ់រាប់រកព្រះអង្គ ព្រះមានព្រះភាគ អង្គនោះ ប្រាសចាក
សេចក្តីស្រវឹងហើយ រមែងសោយ នូវអាហារ (តាមធម្មតា) ។

ឯវំ វិគតមទំ អាហារំ អាហារយមានំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ យថាវាទី ខោ បន សោ ភគវា តថាការី យថាការី តថាវាទី ឥតិ យថាវាទី តថាការី យថាការី តថាវាទី ។ ឯវំ ធម្មានុធម្មប្បដិបន្នំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា ។ តិណ្ណវិចិកិច្ឆោ ខោ បន សោ ភគវា វិគតកថំកថោ បរិយោសិតសង្កប្បោ អជ្ឈាសយំ អាទិព្រហ្មចរិយំ ។ ឯវំ តិណ្ណវិចិកិច្ឆំ វិគតកថំកថំ បរិយោសិតសង្កប្បំ អជ្ឈាសយំ អាទិព្រហ្មចរិយំ ឥមិនាបង្គេន សមន្នាគតំ សត្ថារំ នេវ អតីតំសេ



យើងពិចារណាមើលនូវសាស្ដា ជាអ្នកប្រាសចាកសេចក្ដីស្រវឹង ហើយបរិភោគនូវអាហារយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាល ដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគ អង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងណា ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ទ្រង់ត្រាស់យ៉ាងនោះ ដោយប្រការយ៉ាងនេះ ។ យើងពិចារណាមើលនូវសាស្ដា ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌យ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាលដែលកន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមានព្រះភាគ អង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្លងផុតសេចក្ដីសង្ស័យអស់ហើយ ព្រះអង្គប្រាសចាកសេចក្ដីងឿងឆ្ងល់អស់ហើយ ទ្រង់មានព្រះតម្រិះ ដល់ទីបំផុតហើយ ដោយព្រហ្មចរិយធម៌ខាងដើម ជាទីស្រ័យដ៏ឧត្តម ។ យើងពិចារណាមើលនូវសាស្ដា ជាអ្នកឆ្លងផុតសេចក្ដីសង្ស័យ ប្រាសចាកសេចក្ដីងឿងឆ្ងល់ មានតម្រិះដល់នូវទីបំផុត ដោយព្រហ្មចរិយធម៌ខាងដើម ជាទីស្រ័យដ៏ឧត្តមយ៉ាងនេះ ដែលប្រកបដោយគុណនេះ ក្នុងចំណែកកាល ដែល

សមនុបស្សាម ន បនេតរហិ អញ្ញត្រ តេន ភគវតា-
តិ ។ ឥមេ ខោ ភន្តេ សក្កោ ទេវានមិន្ទោ ព្រហ្មុនោ
សនង្កុមារស្ស ភគវតោ អដ្ឋ យថាភុច្ចេ វណ្ណេ បយិរុ-
ទាហាសិ ។

(៥៧) តេន សុទំ ភន្តេ ព្រហ្មា សនង្កុមារោ
អត្តមនោ ហោតិ បមុទិតោ បីតិសោមនស្សជាតោ ភគ-
វតោ អដ្ឋ យថាភុច្ចេ វណ្ណេ សុត្វា ។ អថ ភន្តេ
ព្រហ្មា សនង្កុមារោ ឱឡារិកំ អត្តភាវំ អភិនិម្មិនិត្វា
កុមារវណ្ណី(១) ហុត្វា បញ្ចសិខោ ទេវានំ តាវតិំសានំ
បាតុរហោសិ ។ សោ(២) វេហាសំ អព្ភុគ្គន្ត្វា អាកាសេ
អន្តលិក្ខេ បល្លង្កេន និសីទិ ។ សេយ្យថាបិ ភន្តេ
ពលវា បុរិសោ សុបច្ចត្ថតេ វា បល្លង្កេ សមេ វា
ភូមិភាគេ បល្លង្កេន និសីទេយ្យ ឯវមេវ ខោ ភន្តេ
ព្រហ្មា សនង្កុមារោ វេហាសំ អព្ភុគ្គន្ត្វា អាកាសេ
អន្តលិក្ខេ បល្លង្កេន និសីទិត្វា ទេវេ តាវតិំសេ
អាមន្តេសិ តំ កឹ មញ្ញន្តិ ភោន្តោ ទេវា តាវតិំសា

១ ម. ឧ. កុមារវណ្ណិ ។ ២ ម. សោតិ ន ទិស្សតិ ។





កន្លងទៅហើយ មិនឃើញមានទេ ក្នុងកាលឥឡូវនេះ ក្រៅអំពីព្រះមាន
ព្រះភាគអង្គនោះចេញហើយ ក៏មិនឃើញមានឡើយ ។ បពិត្រព្រះអង្គដ៏
ចម្រើន សក្កទេវរាជ ជាធំជាងពួកទេវតា បានសំដែងគុណជារបស់ពិត
តាំង ៨ ប្រការ របស់ព្រះមានព្រះភាគនេះឯង ដល់សនង្កុមារព្រហ្ម ។

(៥៧) បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ បានជាសនង្កុមារ-
ព្រហ្ម មានចិត្តត្រេកអរ រីករាយ កើតបីតិសោមនស្ស ព្រោះបានស្តាប់
គុណជារបស់ពិតតាំង ៨ ប្រការ របស់ព្រះមានព្រះភាគ ។ បពិត្រ
ព្រះអង្គដ៏ចម្រើន គ្រានោះ សនង្កុមារព្រហ្ម និម្មិតអត្តភាពដ៏លើសលប់
ដូចជាទេវកុមារ មានផ្នួង ៥ ប្រាកដហើយ ដល់ពួកទេវតាជាន់
តាវត្តិង្ស ។ ព្រហ្មនោះ ក៏ហោះឡើងទៅកាន់អាកាស អង្គុយពែនភ្នែន
លើផ្ទៃអាកាសវាលវេហាស ។ បពិត្រព្រះអង្គដ៏ចម្រើន បុរសមានកម្លាំង
អង្គុយពែនភ្នែនលើបល្ល័ង្កដែលគេក្រាលល្អហើយ ឬលើភូមិភាគដ៏រាបស្មើ
មានឧបមាដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន សនង្កុមារព្រហ្ម ហោះ
ឡើងទៅកាន់អាកាស អង្គុយពែនភ្នែនលើផ្ទៃអាកាស វាលវេហាស ក៏មាន
ឧបមេយ្យដូច្នោះដែរ ហើយនិយាយនឹងពួកទេវតាជាន់តាវត្តិង្សថា នែអ្នក
ដ៏ចម្រើនទាំងឡាយ ពួកទេវតាជាន់តាវត្តិង្សសម្គាល់សេចក្តីនោះដូចម្តេច

យាវំ ទីឃរត្តំ មហាបញ្ញោ វ(១) សោ ភគវា អហោសិ ។ ភូតបុព្វំ ភោ រាជា ទិសម្បតិ(២) នាម អហោសិ ។ ទិសម្បតិស្ស រញ្ញោ គោវិន្ទោ នាម ព្រាហ្មណោ បុរោហិតោ អហោសិ ។ ទិសម្បតិស្ស រញ្ញោ រេណុ នាម កុមារោ បុត្តោ អហោសិ ។ គោវិន្ទស្ស ព្រាហ្មណស្ស ជោតិបាលោ នាម មាណវោ បុត្តោ អហោសិ ។ ឥតិ រេណុ ច រាជបុត្តោ ជោតិបាលោ ច មាណវោ អញ្ញេ ច ឆ ខត្តិយា ឥច្ចេតេ អដ្ឋ សហាយា អហេសុំ ។ អថខោ ភោ(៣) អហោរត្តានំ អច្ចយេន គោវិន្ទោ ព្រាហ្មណោ កាលមកាសិ ។ គោវិន្ទេ ព្រាហ្មណេ កាលកតេ រាជា ទិសម្បតិ បរិទេវេសិ យស្មឹ វត ភោ មយំ សមយេ គោវិន្ទេ ព្រាហ្មណេ សព្វកិច្ចានិ សម្មាវោស្សជ្ជិត្វា(៤) បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គិភូតា បរិចារេម តស្មឹ នោ បន(៥) សមយេ គោវិន្ទោ ព្រាហ្មណោ កាលកតោតិ ។ ឯវំ វុត្តេ ភោ រេណុ រាជបុត្តោ

១ ម. ច ។ ២ ម. ទិសម្បតី ។ ៣ ម. ភោតិ ន ទិស្សតិ ។ ៤ ម. សម្មាវោស្សជ្ជិត្វា ។ ៥ ម. នោ បទំ ន ទិស្សតិ ។



ព្រះមានព្រះភាគនោះ ជាបុគ្គលមានបញ្ញាច្រើន អស់កាលអង្វែងមកហើយ ។ ម្នាលអ្នកដ៏ចម្រើន រឿងធ្លាប់មានមកហើយថា មានស្តេចមួយព្រះអង្គ ទ្រង់ព្រះនាមទិសម្បតិ ។ មានព្រាហ្មណ៍ឈ្មោះគោវិន្ទៈ ជាបុរោហិតរបស់ព្រះបាទទិសម្បតិ ។ ព្រះបាទទិសម្បតិ មានព្រះរាជបុត្រ ១ ព្រះអង្គ ទ្រង់ព្រះនាមរេណុកុមារ ។ គោវិន្ទព្រាហ្មណ៍ មានកូនប្រុសម្នាក់ ឈ្មោះជោតិបាលមាណព ។ ជនទាំង ៨ នាក់នេះ គឺ រេណុរាជបុត្រ ១ ជោតិបាលមាណព ១ និងក្សត្រ(១) ៦ ព្រះអង្គទៀត សុទ្ធតែជាសំឡាញ់នឹងគ្នា ។ ម្នាលអ្នកដ៏ចម្រើន លុះវេលាថ្ងៃនិងយប់ កន្លងទៅហើយ គោវិន្ទព្រាហ្មណ៍ ក៏ធ្វើមរណកាលទៅ ។ ម្នាលអ្នកដ៏ចម្រើន កាលដែលគោវិន្ទព្រាហ្មណ៍ ធ្វើមរណកាលទៅហើយ ព្រះបាទទិសម្បតិ ទ្រង់ព្រះកន្សែងសោកស្តាយថា នែអ្នកដ៏ចម្រើន ក្នុងសម័យណា យើងបានប្រគល់កិច្ចទាំងពួងដោយស្រួលបួល ដល់គោវិន្ទព្រាហ្មណ៍ហើយ ក៏គួរតែស្កប់ស្កល់ មូលមិត្រ ផ្គត់ផ្គង់ដោយកាមគុណទាំង ៥ សម័យនោះឯង គោវិន្ទព្រាហ្មណ៍ ក៏ធ្វើមរណកាលទៅ ។ ម្នាលអ្នកដ៏ចម្រើន កាលព្រះបាទទិសម្បតិ ទ្រង់ព្រះកន្សែងសោកស្តាយយ៉ាងនោះហើយ រេណុរាជបុត្ត

១ អដ្ឋកថា ថា ស្តេច ៦ អង្គទៀតនោះ គឺ សត្តភូ ១ ព្រហ្មទត្ត ១ វេស្សភូ ១ ភរតៈ ១ ធតរដ្ឋ ១ ធតរដ្ឋមួយទៀត ១ ។

រាជានំ ទិសម្បតឹ ឯតទវោច មា ខោ ត្វំ ទេវ គោ-វិន្ទេ ព្រាហ្មណេ កាលកតេ អតិពាឡ្ហំ បរិទេវេសិ អត្ថិ ទេវ គោវិន្ទស្ស ព្រាហ្មណស្ស ជោតិបាលោ នាម មា-ណវោ បុត្តោ បណ្ឌិតតរោ ចេវ បិតរា អលមត្ថទស-តរោ ចេវ បិតរា យេបិ តស្ស(១) បិតា អត្ថេ អនុសាសិ តេបិ ជោតិបាលស្សេវ មាណវស្ស អនុសាសនីយាតិ ។ ឯវំ កុមារាតិ ។ ឯវំ ទេវាតិ ។ អថខោ ភោ រាជា ទិសម្បតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេន ជោតិបាលោ នាម មាណវោ តេនុ-បសង្កម ឧបសង្កមិត្វា ជោតិបាលំ មាណវំ ឯវំ វទេហិ ភវមត្ថុ ភវន្តំ ជោតិបាលំ មាណវំ រាជា ទិសម្បតិ ភវន្តំ ជោតិបាលំ មាណវំ អាមន្តយតិ រាជា ទិសម្បតិ ភោតោ ជោតិបាលស្ស មាណវស្ស ទស្សនកាមោតិ ។ ឯវំ ទេវាតិ ខោ(២) ភោ សោ បុរិសោ ទិសម្បតិស្ស រញ្ញោ បដិស្សុត្វា យេន ជោតិបាលោ មាណវោ តេនុបសង្កមិ ឧបសង្កមិត្វា

១ ម. ម. យេបិស្ស ។ ២ ម. ទេវាតិ ខ ទិស្សតិ ។



ក៏ក្រាបបង្គំទូលព្រះបាទទិសម្បតិ យ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំទ្រង់ព្រះកន្សែង នឹងគោវិន្ទព្រាហ្មណ៍ ដែលធ្វើមរណកាល ទៅនោះខ្លាំងពេកឡើយ បពិត្រព្រះសម្មតិទេព គោវិន្ទព្រាហ្មណ៍ មានកូនប្រុសម្នាក់ ឈ្មោះជោតិបាលមាណព ជាបណ្ឌិតវិសេសជាងបិតាផង ជាអ្នកមុះមុត គាប់គាត់សេចក្តីបានជាងបិតាផង បិតារបស់ជោតិបាល-មាណពនោះ ប្រៀនប្រដៅនូវសេចក្តីទាំងឡាយណា សេចក្តីទាំងឡាយនោះ សុទ្ធតែជាពាក្យប្រៀនប្រដៅ របស់ជោតិបាលមាណព ។ ព្រះបាទទិសម្បតិ មានព្រះរាជឱង្ការថា ម្នាលកុមារ យ៉ាងហ្នឹងមែនឬ ។ ព្រះរេណុរាជកុមារ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព យ៉ាងហ្នឹងមែន ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះ ព្រះបាទទិសម្បតិ មានព្រះរាជឱង្ការឲ្យហៅបុរសម្នាក់ថា នែបុរសដ៏ចម្រើន ឯងចូរមកនេះ ឯងចូរចូលទៅរកជោតិ-បាលមាណព លុះចូលទៅដល់ហើយ ចូរនិយាយនឹងជោតិបាលមាណព យ៉ាងនេះថា សូមសេចក្តីចម្រើនមាន ដល់ជោតិបាលមាណពដ៏ចម្រើនចុះ ព្រះបាទទិសម្បតិ មានព្រះរាជឱង្ការ ឲ្យហៅជោតិបាលមាណពដ៏ចម្រើន ព្រះបាទទិសម្បតិ ចង់ជួបនឹងជោតិបាលមាណពដ៏ចម្រើន ។ ម្នាលអ្នកដ៏ចម្រើន រាជបុរសនោះទទួលព្រះរាជឱង្ការព្រះបាទទិសម្បតិថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស រួចចូលទៅរកជោតិបាលមាណព លុះចូល

ជោតិបាលំ មាណវំ ឯតទវោច ភវមត្ថុ ភវន្តំ ជោតិបាលំ មាណវំ រាជា ទិសម្បតិ ភវន្តំ ជោតិបាលំ មាណវំ អាមន្តយតិ រាជា ទិសម្បតិ ភោតោ ជោតិបាលស្ស មាណវស្ស ទស្សនកាមោតិ ។ ឯវំ ភោតិ ខោ ភោ ជោតិបាលោ មាណវោ តស្ស បុរិសស្ស បដិស្សុត្វា យេន រាជា ទិសម្បតិ តេនុបសង្កមិ ឧបសង្កមិត្វា ទិសម្បតិនា រញ្ញា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ភោ ជោតិបាលំ មាណវំ រាជា ទិសម្បតិ ឯតទវោច អនុសាសតុ ភោ ភវំ ជោតិបាលោ មាណវោ មា ភោ[១] ភវំ ជោតិបាលោ មាណវោ[២] អនុសាសនិយា បច្ចព្យាហាសិ[៣] បេត្តិកេ តំ ឋានេ ឋបេស្សាមិ[៤] គោវិន្ទិយេ អភិសិញ្ចិស្សាមីតិ ។ ឯវំ ភោតិ ខោ[៥] ជោតិបាលោ មាណវោ ទិសម្បតិស្ស រញ្ញោ បច្ចស្សោសិ ។

១ ឱ. ភោតិ ន ទិស្សតិ ។ ២ ឱ. ម. មាណវោតិ ន ទិស្សតិ ។ ៣ ម. បច្ចព្យាហាសិ ។ ៤ ឱ. តំ ឋានេ បតិដ្ឋបេស្សាមិ ។ ម. តំ ឋានេ ។ ៥ ឱ. ខោ ភោ ។ ម. ភោ ខោ ។



ទៅដល់ហើយ បានថ្លែងព្រះឱង្ការនេះ នឹងជោតិបាលមាណពថា សូមសេចក្តីចម្រើនមាន ដល់ជោតិបាលមាណពដ៏ចម្រើនចុះ ព្រះបាទទិសម្បតិ មានព្រះឱង្ការឲ្យហៅជោតិបាលមាណពដ៏ចម្រើន ព្រះបាទទិសម្បតិចង់ជួបនឹងជោតិបាលមាណពដ៏ចម្រើន ។ ម្នាលអ្នកដ៏ចម្រើន ជោតិបាលមាណពទទួលតបពាក្យរបស់បុរសនោះថា អើអ្នកដ៏ចម្រើន យ៉ាងនេះហើយ ទើបចូលទៅគាល់ព្រះបាទទិសម្បតិ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះបាទទិសម្បតិ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអ្នកដ៏ចម្រើនលុះជោតិបាលមាណព អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះបាទទិសម្បតិ មានព្រះបន្ទូលយ៉ាងនេះថា ជោតិបាលមាណពដ៏ចម្រើន ចូរអ្នកប្រៀនប្រដៅយើងចុះ ជោតិបាលមាណពដ៏ចម្រើន កុំលះបង់យើងអំពីការប្រៀនប្រដៅឡើយ យើងនឹងតាំងអ្នកក្នុងតំណែងដែលជាតំណែងបិតាអ្នក យើងនឹងស្រោចទឹកអ្នកក្នុងទីជារបស់គោវិន្ទព្រាហ្មណ៍ ។ ជោតិបាលមាណព ទទួលព្រះបន្ទូលព្រះបាទទិសម្បតិថា ព្រះករុណាវិសេស ។

អថខោ ភោ(១) រាជា ទិសម្បតិ ជោតិបាលំ មាណវំ គោវិន្ទិយេ អភិសិញ្ចិ(២) បេត្តិកេ ឋានេ ឋបេសិ ។ អភិសិត្តោ ជោតិបាលោ មាណវោ គោវិន្ទិយេ បេត្តិកេ ឋានេ ឋបិតោ យេបិស្ស បិតា អត្ថេ អនុសាសិ តេបិ(៣) អត្ថេ អនុសាសតិ យេបិស្ស បិតា អត្ថេ នានុសាសិ តេបិ អត្ថេ អនុសាសតិ យេបិស្ស បិតា កម្មន្តេ អភិសម្ភោសិ តេបិ កម្មន្តេ អភិសម្ភោតិ យេបិស្ស បិតា កម្មន្តេ នាភិសម្ភោសិ តេបិ កម្មន្តេ អភិសម្ភោតិ ។ តមេនំ មនុស្សា ឯវមាហំសុ គោវិន្ទោ វត ភោ ព្រាហ្មណោ មហាគោវិន្ទោ វត ភោ ព្រាហ្មណោតិ ។ ឥមិនា ខោ ឯវំ(៤) ភោ បរិយាយេន ជោតិបាលស្ស មាណវស្ស មហាគោវិន្ទោត្វេវ(៥) សមញ្ញា ឧទបាទិ ។

១ ម. ភោតិ ន ទិស្សតិ ។ ២ ម. អភិសិញ្ចតិ ។ ៣ ម. តេ ។ ៤ ម. ឯតំ ។ ៥ ម. មហាគោវិន្ទោ មហាគោវិន្ទោត្វេវ ។ ម. គោវិន្ទោ . . . . ។





ម្នាលអ្នកដ៏ចម្រើន ទើបព្រះបាទទិសម្បតិ ទ្រង់ស្រោចទឹកជោតិបាល-មាណព ក្នុងតំណែងនៃគោវិន្ទព្រាហ្មណ៍ ទ្រង់តាំងជោតិបាលមាណព ក្នុងតំណែងនៃជាន់តំណែងបិតា ។ ជោតិបាលមាណព ដែលព្រះរាជាទ្រង់ស្រោចទឹក ក្នុងទីជារបស់គោវិន្ទព្រាហ្មណ៍ ទ្រង់តាំងទុកក្នុងតំណែងបិតាហើយ តែងប្រៀនប្រដៅនូវសេចក្តីទាំងឡាយ ដែលបិតាបានប្រៀនប្រដៅហើយ ដល់ព្រះរាជានោះផង មិនបានប្រៀនប្រដៅ នូវសេចក្តីទាំងឡាយ ដែលបិតាមិនបានប្រដៅដល់ព្រះរាជានោះផង បានចាត់ចែងការងារទាំងឡាយ ដែលបិតាបានចាត់ចែងហើយ ដល់ព្រះរាជានោះផង មិនបានចាត់ចែងនូវការងារទាំងឡាយ ដែលបិតាមិនបានចាត់ចែងហើយ ដល់ព្រះរាជានោះផង ។ មនុស្សទាំងឡាយ ក៏ពោលគ្នានិយាយតែដំណើរនោះថា អើហ្ន៎ មើលចុះគោវិន្ទព្រាហ្មណ៍ អើហ្ន៎ មើលចុះមហាគោវិន្ទ-ព្រាហ្មណ៍ ។ ម្នាលអ្នកដ៏ចម្រើន ជោតិបាលមាណព ក៏បានឈ្មោះថា មហាគោវិន្ទព្រាហ្មណ៍ ដោយបរិយាយនេះ យ៉ាងនេះឯង ។

[៥៨] អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ យេន តេ ឆ ខត្តិយា តេនុបសង្កមិ ឧបសង្កមិត្វា តេ ឆ ខត្តិយេ ឯតទវោច ទិសម្បតិ ខោ(១) ភោ រាជា ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ កោ នុ ខោ បន ភោ ជានាតិ ជីវិតានំ(២) ឋានំ ខោ បនេតំ វិជ្ជតិ យំ ទិសម្បតិម្ហិ រញ្ញេ កាលកតេ រាជ-កត្តារោ រេណុំ រាជបុត្តំ រជ្ជេ អភិសិញ្ចេយ្យុំ អាយន្តុ ភោន្តោ យេន រេណុ រាជបុត្តោ តេនុបសង្កមថ ឧប-សង្កមិត្វា រេណុំ រាជបុត្តំ ឯវំ វទេថ មយំ ខោ(៣) ភោតោ រេណុស្ស សហាយា បិយា មនាបា អប្បដិកូលា យំសុខោ ភវំ តំសុខា មយំ យំទុក្ខោ ភវំ តំទុក្ខា មយំ

១ ខ. ភោតិ ន ទិស្សតិ ។ ២ ម. ជីវិតំ ។ ៣ ខ. ភោតិ ន ទិស្សតិ ។



[៥៨] ម្នាលអ្នកដ៏ចម្រើន គ្រានោះ មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រតាំង ៦ អង្គនោះ លុះចូលទៅដល់ហើយ បានក្រាបបង្គំទូលក្សត្រតាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គម្ចាស់ដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម កន្លងចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គម្ចាស់ដ៏ចម្រើន នរណាហ្ន៎ នឹងដឹងនូវជីវិតបាន កាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅ ពួកអ្នកធ្វើការតំឡើងអភិសេកព្រះរេណុរាជបុត្រ ក្នុងរាជសម្បត្តិ ហេតុនេះ រមែងមាន សូមព្រះអង្គម្ចាស់ទាំងឡាយដ៏ចម្រើនស្តេចមក សូមព្រះអង្គម្ចាស់ទាំងឡាយ ទៅគាល់ព្រះរេណុរាជបុត្រ លុះចូលទៅដល់ហើយ ក្រាបទូលសេចក្តីចំពោះព្រះរេណុរាជបុត្រ យ៉ាងនេះថា ពួកយើងជាសំឡាញ់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីខ្ពើមរអើម នៃព្រះរេណុរាជបុត្រដ៏ចម្រើនឡើយ ព្រះអង្គដ៏ចម្រើនមានសុខយ៉ាងណា ពួកយើងមានសុខយ៉ាងនោះ ព្រះអង្គដ៏ចម្រើនមានទុក្ខយ៉ាងណា ពួកយើងមានទុក្ខយ៉ាងនោះ

ទិសម្បតិ ភោ(១) រាជា ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ កោ នុ ខោ បន ភោ ជានាតិ ជីវិតំ ឋានំ ខោ បនេតំ វិជ្ជតិ យំ ទិសម្បតិម្ហិ រញ្ញេ កាលង្កតេ រាជកត្តារោ រេណុំ រជ្ជេ អភិសិញ្ចេយ្យុំ សចេ ភវំ រេណុ រជ្ជំ លភេថ សំវិភជេថ នោ រជ្ជេនាតិ ។ ឯវំ ភោ ខោ(២) តេ ឆ ខត្តិយា មហាគោវិន្ទស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន រេណុ រាជបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា រេណុំ រាជបុត្តំ ឯតទវោចុំ មយំ ខោ (៣) ភោតោ រេណុស្ស សហាយា បិយា មនាបា អប្បដិកូលា យំសុខោ ភវំ តំសុខា មយំ យំទុក្ខោ ភវំ តំទុក្ខា មយំ ទិសម្បតិ ខោ ភោ រាជា ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ

១ ម. ភោតិ ឥត្ថិ ។ ២ ម. ភោ ភោ ។ ៣ ម. ភោតិ ខត្តិ ។





បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម ក៏ត្រូវលះចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន នរណាហ្ន៎ ដឹងជីវិតបាន កាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ពួកអ្នករាជការ នឹងអភិសេកព្រះរេណុរាជបុត្រដ៏ចំរើនក្នុងរាជសម្បត្តិ ហេតុនេះបើមិនបាន បើព្រះរេណុរាជបុត្រដ៏ចំរើន ត្រូវបានរាជសម្បត្តិ សូមព្រះអង្គចែករាជសម្បត្តិដល់យើងខ្ញុំទាំងឡាយផង ។ ក្សត្រទាំង ៦ អង្គនោះ ទទួលពាក្យរបស់មហាគោវិន្ទព្រាហ្មណ៍ថា ម្នាលអ្នកដ៏ចំរើន អើមែនហើយ ទើបចូលទៅគាល់រេណុរាជបុត្រ លុះចូលទៅដល់ហើយ ក្រាបទូលរេណុរាជបុត្រ យ៉ាងនេះថា យើងទាំងឡាយ ជាសំឡាញ់ ជាទីស្រឡាញ់ ជាទីពេញចិត្ត មិនជាទីខ្ពើមហើយ នៃព្រះរេណុរាជកុមារដ៏ចំរើនឡើយ ព្រះអង្គដ៏ចំរើន មានសុខយ៉ាងណា ពួកយើងមានសុខ យ៉ាងនោះ ព្រះអង្គដ៏ចំរើន មានទុក្ខយ៉ាងណា ពួកយើងមានទុក្ខ យ៉ាងនោះ បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ព្រះជរាចាស់គ្រាំគ្រា ទ្រង់ព្រះជន្មមកយូរឆ្នាំហើយ មានព្រះជន្ម ក៏ត្រូវលះចូលមកក្នុងបច្ឆិមវ័យហើយ បពិត្រព្រះ

កោ នុ ខោ បន ភោ ជានាតិ ជីវិតានំ ឋានំ ខោ បនេតំ វិជ្ជតិ យំ ទិសម្បតិម្ហិ រញ្ញេ កាលកតេ រាជកត្តារោ ភវន្តំ រេណុំ រជ្ជេ អភិសិញ្ចេយ្យុំ សចេ ភវំ រេណុ រជ្ជំ លភេថ សំវិភជេថ នោ រជ្ជេនាតិ ។ កោ នុ ខោ ភោ អញ្ញោ មម វិជិតេ សុខំ ភវេយ្យាថ(១) អញ្ញត្រ ភវន្តេហិ សចាហំ ភោ រជ្ជំ លភិស្សាមិ សំវិភជិស្សាមិ វោ រជ្ជេនាតិ ។ អថខោ ភោ អហោរត្តានំ អច្ចយេន រាជា ទិសម្បតិ កាលមកាសិ ។ ទិសម្បតិម្ហិ រញ្ញេ កាលកតេ រាជកត្តារោ រេណុំ រាជបុត្តំ រជ្ជេ អភិសិញ្ចឹសុ ។ អភិសិត្តោ រេណុ រជ្ជេន បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ។ អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ យេន តេ ឆ ខត្តិយា តេនុបសង្កមិ ឧបសង្កមិត្វា តេ ឆ ខត្តិយេ ឯតទវោច

១ ឱ. សុខមេធេយ្យាថ ។ ម. សុខា ភវេយ្យាថ ។



អ្នកម្ចាស់ដ៏ចម្រើន នរណាហ្ន៎ ដឹងនូវជីវិតបាន កាលបើព្រះបាទទិសម្បតិទ្រង់ទិវង្គតទៅហើយ ពួកអ្នករាជការ គប្បីអភិសេកព្រះរេណុរាជបុត្រដ៏ចម្រើន ក្នុងរាជសម្បត្តិ ហេតុនេះរមែងមាន បើព្រះរេណុរាជបុត្រដ៏ចម្រើន ត្រូវបានរាជសម្បត្តិហើយ សូមព្រះអង្គចែករាជសម្បត្តិដល់យើងខ្ញុំទាំងឡាយផង ។ រេណុរាជបុត្រ ទ្រង់តបថា ម្នាលអ្នកដ៏ចម្រើន បើក្រៅអំពីអ្នកដ៏ចម្រើនទាំងឡាយហើយ អ្នកដទៃណា នឹងដល់នូវសេចក្ដីសុខឲ្យកើតឡើង ក្នុងដែនរបស់យើងបាន ម្នាលអ្នកដ៏ចម្រើន បើយើងនឹងបានរាជសម្បត្តិ យើងនឹងចែករាជសម្បត្តិ ដល់អ្នកទាំងឡាយផងដែរ ។ ម្នាលអ្នកដ៏ចម្រើន លុះវេលាទិវាយប់ទាំងឡាយ កន្លងទៅហើយ ព្រះបាទទិសម្បតិ ក៏ទ្រង់ទិវង្គតទៅ ។ កាលបើព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ពួកអ្នករាជការ ក៏បានអភិសេកព្រះរេណុរាជបុត្រក្នុងរាជសម្បត្តិ ។ លុះព្រះរេណុរាជបុត្រ បានអភិសេកដោយរាជសម្បត្តិហើយ ទ្រង់ស្កប់ស្កល់ម្ហូលម៉ៅត្រេកត្រអាលដោយកាមគុណទាំង ៥ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅគាល់ហើយ ទើបក្រាបទូលក្សត្រទាំង ៦ អង្គនោះ យ៉ាងនេះថា

ទិសម្បតិ ខោ ភោ រាជា កាលង្កតោ អភិសិត្តោ រេណុ រជ្ជេន បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គិភូតោ បរិចារេតិ កោ នុ ខោ ជានាតិ មទនិយា កាមា អាយន្តុ ភោន្តោ យេន រេណុ រាជា តេនុបសង្កមថ ឧបសង្កមិត្វា រេណុំ រាជានំ ឯវំ វទេថ ទិសម្បតិ ខោ ភោ រាជា កាលង្កតោ អភិសិត្តោ ភវំ រេណុ រជ្ជេន សរតិ ភវំ តំ វចនន្តិ ។ ឯវំ ភោតិ ខោ(១) តេ ខត្តិយា មហាគោវិន្ទស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន រេណុ រាជា តេនុបសង្កមឹសុ ឧបសង្កមិត្វា រេណុំ រាជានំ ឯតទវោចុំ ទិសម្បតិ ខោ ភោ រាជា កាលង្កតោ អភិសិត្តោ ភវំ រេណុ រជ្ជេន សរតិ ភវំ តំ វចនន្តិ ។ សរាមហំ ភោ តំ វចនន្តិ(២) ។

---
១ ឱ. ម. ភោ ភោ ។ ២ ឱ. វចនំ ។



បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតទៅហើយ ព្រះបាទរេណុដែលបានអភិសេកដោយរាជសម្បត្តិហើយ ព្រះអង្គក៏ស្កប់ស្កល់ ម្ចាលមិត្រផ្គត់ផ្គង់ ដោយកាមគុណទាំង ៥ បពិត្រព្រះអង្គម្ចាស់ដ៏ចំរើន នរណាហ្ន៎នឹងដឹង (រឿងនេះបាន ព្រោះ)កាមារម្មណ៍ទាំងឡាយ សុទ្ធតែជាសភាវៈនាំឲ្យស្រវឹង សូមឲ្យព្រះអង្គម្ចាស់ដ៏ចម្រើនទាំងឡាយ ស្តេចមកនឹងចូលទៅគាល់ព្រះបាទរេណុ លុះចូលទៅដល់ហើយ ចូរក្រាបទូលព្រះបាទរេណុយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតហើយ ព្រះបាទរេណុដ៏ចម្រើនបានទទួលអភិសេកដោយរាជសម្បត្តិហើយ ព្រះអង្គដ៏ចម្រើនរលឹកឃើញពាក្យនោះដែរឬ ។ ពួកក្សត្រទាំង៦អង្គនោះទទួលពាក្យមហាគោវិន្ទព្រាហ្មណ៍ថា ម្នាលអ្នកដ៏ចម្រើន មែនហើយ រួចក៏ចូលទៅគាល់ព្រះបាទរេណុ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទរេណុយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទទិសម្បតិ ទ្រង់ទិវង្គតហើយ ព្រះបាទរេណុដ៏ចម្រើនបានទទួលអភិសេកដោយរាជសម្បត្តិហើយ តើព្រះអង្គដ៏ចម្រើន រលឹកឃើញពាក្យនោះដែរឬ ។ ព្រះបាទរេណុមានព្រះរាជឱង្ការថា ម្នាលអ្នកដ៏ចម្រើន យើងរលឹកឃើញពាក្យនោះដែរ ។

កោ នុ ខោ ភោ បហោតិ ឥមំ មហាបថវឹ ឧត្តរេន អាយតំ ទក្ខិណេន សកដមុខំ សត្តធា សមំ សុវិភត្តំ វិភជិតុន្តិ ។ កោ នុ ខោ ភោ អញ្ញត្រ មហាគោវិន្ទេន ព្រាហ្មណេនាតិ ។ អថខោ ភោ រេណុ រាជា អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ អម្ភោ បុរិស យេន មហាគោវិន្ទោ ព្រាហ្មណោ តេនុបសង្កម ឧបសង្កមិត្វា មហាគោវិន្ទំ ព្រាហ្មណំ ឯវំ វទេហិ រាជា តំ ភន្តេ រេណុ អាមន្តេតីតិ ។ ឯវំ ទេវាតិ ខោ សោ បុរិសោ រេណុស្ស រញ្ញោ បដិស្សុត្វា យេន មហាគោវិន្ទោ ព្រាហ្មណោ តេនុបសង្កមិ ឧប-សង្កមិត្វា មហាគោវិន្ទំ ព្រាហ្មណំ ឯតទវោច រាជា តំ ភន្តេ រេណុ អាមន្តេតីតិ ។ ឯវំ ភោតិ ខោ ម-ហាគោវិន្ទោ ព្រាហ្មណោ តស្ស បុរិសស្ស បដិស្សុត្វា



ពួកក្សត្រទាំង ៦ អង្គ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ ល្មមនឹងចែកមហាប្រឹថពីនេះ ដែលមានបណ្តោយទៅខាងទិសឧត្តរ មានមុខដូចជាមុខរទេះ ទៅខាងទិសទក្សិណ ឲ្យមានចំណែកស្មើគ្នា ជា ៧ ភាគបាន ។ ព្រះបាទរេណុ មានព្រះរាជឱង្ការថា ម្នាលអ្នកដ៏ចម្រើន វៀរលែងតែមហាគោវិន្ទព្រាហ្មណ៍ចេញ អ្នកដទៃណាហ្ន៎ ល្មមនឹងចែកបាន ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ព្រះបាទរេណុ មានព្រះរាជឱង្ការហៅបុរសម្នាក់មកថា ម្នាលអ្នកដ៏ចម្រើន ឯងចូរមកនេះ ឯងចូរទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ ចូរជម្រាបមហា-គោវិន្ទព្រាហ្មណ៍ យ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ព្រះបាទរេណុ មានព្រះរាជឱង្ការឲ្យហៅលោក ។ ម្នាលអ្នកដ៏ចម្រើន បុរសនោះ ទទួលព្រះរាជឱង្ការ នៃព្រះបាទរេណុថា បពិត្រព្រះសម្មតិទេព ព្រះករុណាវិសេស ហើយចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ បានជម្រាបមហាគោវិន្ទព្រាហ្មណ៍ យ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ព្រះបាទរេណុ មានព្រះរាជឱង្ការឲ្យហៅលោក ។ ម្នាលអ្នកដ៏ចម្រើន មហាគោវិន្ទព្រាហ្មណ៍ ទទួលពាក្យរបស់បុរសនោះថា អើអ្នកដ៏ចម្រើន

យេន រេណុ រាជា តេនុបសង្កមិ ឧបសង្កមិត្វា រេណុនា រញ្ញា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ភោ(១) មហាគោវិន្ទំ ព្រាហ្មណំ រេណុ រាជា ឯតទវោច ឯតុ ភវំ គោវិន្ទោ ឥមំ មហាបថវឹ ឧត្តរេន អាយតំ ទក្ខិណេន សកដមុខំ សត្តធា សមំ សុវិភត្តំ វិភជេតូតិ ។ ឯវំ ភោតិ ខោ ភោ(២) មហាគោវិន្ទោ ព្រាហ្មណោ រេណុស្ស រញ្ញោ បដិស្សុត្វា ឥមំ មហាបថវឹ ឧត្តរេន អាយតំ ទក្ខិណេន សកដមុខំ សត្តធា សមំ សុវិភត្តំ វិភជិ សព្វានិ សកដមុខានិ អដ្ឋបេសិ(៣) ។ តត្រ សុទំ មជ្ឈេ រេណុស្ស រញ្ញោ ជនបទោ ហោតិ

(៤៩) ទន្តបុរំ កលិង្គានំ

អស្សកានញ្ច បោតនំ

១-២ ឱ. ភោតិ ខ្លះ ។ ៣ ឱ. អដ្ឋបេសិ ។





ហើយចូលទៅគាល់ព្រះបាទរេណុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យពីរាក់ទាក់ សំណេះសំណាលទៅនឹងព្រះបាទរេណុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលអ្នកដ៏ចម្រើន លុះមហាគោវិន្ទព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ព្រះបាទរេណុមានព្រះរាជឱង្ការយ៉ាងនេះថា គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ចូរអញ្ជើញមកចែកមហាប្រឹថពីនេះ ដែលមានបណ្តោយទៅខាងទិសឧត្តរ មានមុខដូចជាមុខរទេះ ទៅខាងទិសទក្សិណ ឲ្យមានចំណែកស្មើគ្នាជា ៧ ភាគ ។ ម្នាលអ្នកដ៏ចម្រើន មហាគោវិន្ទព្រាហ្មណ៍ ទទួលព្រះបន្ទូលព្រះបាទរេណុថា បពិត្រព្រះសម្មតិទេព ព្រះករុណាថ្លៃវិសេស ហើយក៏ចែកមហាប្រឹថពីនេះ ដែលមានបណ្តោយទៅខាងទិសឧត្តរ មានមុខដូចជាមុខរទេះ ទៅខាងទិសទក្សិណ ឲ្យមានចំណែកស្មើគ្នាជា ៧ ភាគ ហើយតម្កល់មុខរទេះនៃដែនទាំងអស់ ឲ្យមានមុខដូចជាមុខរទេះ ។ មានសេចក្តីតំណាលក្នុងរឿងនោះថា ជនបទ របស់ព្រះបាទរេណុ នៅត្រង់កណ្តាល ។

(៤៩) គោវិន្ទព្រាហ្មណ៍ បានសាងទីក្រុងទាំង ៧ នេះ គឺ ក្រុងទន្តបុរៈ សម្រាប់ពួកអ្នកដែនកាលិង្គៈ ១ ក្រុងពោតនៈ

មាហិស្សតិ(១) អវន្តីនំ
សោចិកណ្ណេ វេរុកំ(២)
មិថិលា ច វិទេហានំ
ចម្បា អង្គេសុ មាបិតា
ពារាណសី ច កាសីនំ
ឯតេ គោវិន្ទមាបិតាតិ ។

[៦០] អថខោ តេ ច ខត្តិយា យថាសកេន លាភេន អត្តមនា អហេសុំ បរិបុណ្ណសង្កប្បា យំ វត នោ អហោសិ ឥច្ឆិតំ យំ អាកង្ខិតំ(៣) អធិប្បេតំ យំ អភិបត្ថិតំ តំ នោ លទ្ធន្តិ ។

[៦១] សត្តត្វា ព្រហ្មលោកេ ច
វេស្សន្ត ការេតា សមា
វេណុ ទ្វេ ធនរដ្ឋា ច
តទាសុំ សត្ត ការកា(៤) ។

ឆដ្ឋភាណវារំ និដ្ឋិតំ ។

---

១ ម. មាហេស្សតិ ។ ២ ម. សោរិកណ្ណេ ហេរុកំ ។ ឱ. សោវីរកំ ច ហេរុកំ ។ ៣ ម. យ. អាកង្ខិតំ យំ ។ ៤ ម. ការកោ ។ យ. ការកាតិ ។





សម្រាប់ពួកអ្នកដែនអស្សកៈ ១ ក្រុងមាហិស្សតិ សម្រាប់ពួកអ្នកដែនអវន្តិ ១ ក្រុងវេរុកៈ សម្រាប់ពួកអ្នកដែនសោចិរៈ ១ ក្រុងមិថិលា សម្រាប់ពួកអ្នកដែនវិទេហៈ ១ ក្រុងចម្បា ដែលគេសាងក្នុងដែនឈ្មោះអង្គៈ ១ ក្រុងពារាណសី សម្រាប់ពួកអ្នកដែនកាសី ១ ។

[៦០] ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ ក្សត្រិយ៍ទាំង ៦ អង្គនោះ ទ្រង់សព្វព្រះទ័យ មានសេចក្ដីប្រាថ្នាពេញបរិបូណ៌ហើយ ដោយលាភគួរដល់ព្រះអង្គថា ឱហ្ន៎ របស់ណា ដែលពួកយើងប្រាថ្នាហើយ របស់ណា ដែលពួកយើងប៉ុនប៉ងសំដៅយកហើយ របស់ណា ដែលពួកយើងគត់សម្គាល់ទុកហើយ របស់នោះ ៗ គឺពួកយើងបានអស់ហើយ ។

[៦១] ព្រះធាតុសត្តក អង្គ១ ព្រះធាតុព្រហ្មទត្ត អង្គ១ ព្រះធាតុវេស្សភូ អង្គ១ ព្រមទាំងព្រះធាតុកេតកៈ អង្គ១ ព្រះធាតុវេណុ អង្គ១ ព្រះធាតុធនរដ្ឋ ២ ព្រះអង្គទៀត រួមបានជាសេចក្ដីគ្រប់គ្រងដែលនៅ មាន ៧ ព្រះអង្គ ក្នុងគ្រានោះ ។

ចប់ ឆដ្ឋមភាណវារៈ ។

[៦៦] អថខោ ភោតោ ឆ ខត្តិយា យេន មហាគោវិន្ទោ ព្រាហ្មណោ តេនុបសង្កមឹសុ ឧបសង្កមិត្វា មហាគោវិន្ទំ ព្រាហ្មណំ ឯតទវោចុំ យថា ខោ(១) ភវំ ភោ គោវិន្ទោ រេណុស្ស រញ្ញោ សហាយោ បិយោ មនាបោ អប្បដិក្កូលោ ឯវមេវ ខោ ភវំ គោវិន្ទោ ព្រាហ្មណោ(២) អម្ហាកំបិ សហាយោ បិយោ មនាបោ អប្បដិក្កូលោ អនុសាសតុ នោ ភវំ គោវិន្ទោ ព្រាហ្មណោ(៣) ន នោ ភវំ គោវិន្ទោ ព្រាហ្មណោ(៤) អនុសាសនិយា បច្ចព្យាហាសីតិ ។ ឯវំ ភោតិ ខោ ភោ(៥) មហាគោវិន្ទោ ព្រាហ្មណោ តេសំ ឆន្នំ ខត្តិយានំ មុទ្ធាភិសិត្តានំ(៦) បច្ចស្សោសិ ។ អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ អនុសាសនិយា(៧) សត្ត ច រាជានោ ខត្តិយេ មុទ្ធាភិសិត្តេ រជ្ជេ(៨) អនុសាសិ សត្ត ច ព្រាហ្មណមហាសាលេ សត្ត ច ន្ហាតកសតានិ មន្តេ វាចេសិ ។ អថខោ ភោ(៩)

១ ឧ. ភោតិ នត្ថិ ។ ២-៣-៦ ឧ. ម. ព្រាហ្មណោតិ នត្ថិ ។ ៤ ឧ. ឃោ ។ ៥ ឧ ម. មុទ្ធាភិសិត្តានន្តិ នត្ថិ ។ ៧ ឧ. ម. អនុសាសនិយាតិ នត្ថិ ។ ៨ ឧ. ម. រជ្ជេ ។ ៩ ម. ភោតិ នត្ថិ ។



[៦៦] ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ក្សត្រទាំង ៦ អង្គនោះ ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏មានព្រះបន្ទូលទៅនឹងមហាគោវិន្ទព្រាហ្មណ៍ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ជាសំឡាញ់ ជាទីស្រឡាញ់ពេញព្រះទ័យ មិនជាទីខ្ពើមរអើម នៃព្រះបាទរេណុ យ៉ាងណាមិញ គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ក៏ជាសំឡាញ់ ជាទីស្រឡាញ់ ពេញចិត្ត មិនជាទីខ្ពើម នៃពួកយើង យ៉ាងនោះដែរ គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន ចូរប្រៀនប្រដៅពួកយើង គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន កុំលះបង់ពួកយើងអំពីការប្រៀនប្រដៅឡើយ ។ ម្នាលអ្នកដ៏ចម្រើន មហាគោវិន្ទព្រាហ្មណ៍ ទទួលស្តាប់ព្រះឱង្ការ នៃក្សត្រទាំង ៦ ព្រះអង្គនោះ ដែលបានមុទ្ធាភិសេកហើយថា ព្រះករុណាពិសេស ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ក៏ប្រៀនប្រដៅពួកក្សត្រទាំង ៧ ព្រះអង្គ ដែលបានមុទ្ធាភិសេក ដោយរាជសម្បត្តិ ដោយអនុសាសនីផង បានបង្រៀនមន្តដល់ព្រាហ្មណមហាសាល ៧ នាក់ផង និងន្ហាតកព្រាហ្មណ៍ ៧០០ នាក់ផង ។ ម្នាលអ្នកដ៏ចម្រើន

មហាគោវិន្ទស្ស ព្រាហ្មណស្ស អបរេន សមយេន ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គញ្ឆិ(១) សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆតិ សល្លបតិ មន្តេតីតិ ។ អថខោ មហាគោវិន្ទស្ស ព្រាហ្មណស្ស ឯតទហោសិ មយ្ហំ ខោ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបេមិ(២) ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិសល្លីយតិ ករុណំ ឈានំ ឈាយតិ សោ ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆតិ

១ ឱ. អព្ភុគ្គញ្ឆិ ។ ២ ឱ. ម. សល្លបាមិ ។



កាលជាខាងក្រោយមក កិត្តិសព្ទដ៏ពីរោះ របស់មហាគោវិន្ទព្រាហ្មណ៍ ល្បីខ្ចរខ្ចាយថា មហាគោវិន្ទព្រាហ្មណ៍ តែងឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ តែងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ មានសេចក្ដីត្រិះរិះយ៉ាងនេះថា កិត្តិសព្ទដ៏ពីរោះរបស់អាត្មាអញ ល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ តែងឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ តែងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន តែអាត្មាអញមិនបានឃើញព្រហ្មសោះ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ប៉ុន្តែអាត្មាអញធ្លាប់ឮពាក្យនេះរបស់ព្រាហ្មណ៍ចាស់ៗ មានអាយុច្រើន ជាអាចារ្យប្រចាំលើអាចារ្យ និយាយថា បុគ្គលណា សម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ហើយពិចារណានូវករុណាឈាន បុគ្គលនោះ នឹងឃើញព្រហ្ម នឹងសាកសួរ

សល្លបតិ មន្តេតីតិ យន្នូនាហំ វស្សិកេ ចត្តារោ មាសេ បដិសល្លីយេយ្យំ ករុណំ ឈានំ ឈាយេយ្យន្តិ ។ អថខោ(១) មហាគោវិន្ទោ ព្រាហ្មណោ យេន រេណុ រាជា តេនុបសង្កមិ ឧបសង្កមិត្វា រេណុំ រាជានំ ឯតទវោច មយ្ហំ ខោ ភោ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ ភោ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបាមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិសល្លីយតិ ករុណំ ឈានំ ឈាយតិ សោ ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ

១ ឱ. ម. អថខោ តៃ ។



និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន បើដូច្នោះ គួរតែអាត្មាអញសម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ពិចារណានូវករុណាឈាន ។ គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ព្រះបាទរេណុ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទរេណុ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំព្រះអង្គ លឺឮខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ អាចសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន បពិត្រព្រះអង្គដ៏ចម្រើន តែខ្ញុំព្រះអង្គមិនបានឃើញព្រហ្មសោះទេ មិនបានសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ប៉ុន្តែ ខ្ញុំព្រះអង្គបានឮពាក្យព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រមានលើអាចារ្យ និយាយតគ្នាថា បុគ្គលណា សម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ពិចារណានូវករុណាឈាន បុគ្គលនោះ នឹងឃើញព្រហ្មបាន សាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយ

មន្តេតីតិ ឥច្ឆាមហំ ភោ វស្សិកេ ចត្តារោ មាសេ បដិសល្លីយិតុំ ករុណំ ឈានំ ឈាយិតុំ នម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន ភត្តាហារេនាតិ(១) ។ យស្សទានិ ភវំ គោវិន្ទោ កាលំ មញ្ញតីតិ ។ អថខោ មហាគោវិន្ទោ ព្រាហ្មណោ យេន តេ ឆ ខត្តិយា តេនុបសង្កមិ ឧបសង្កមិត្វា តេ ឆ ខត្តិយេ ឯតទវោច មយ្ហំ ខោ ភោ(២) ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ ភោ(៣) ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបាមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិសល្លីយតិ ករុណំ ឈានំ ឈាយតិ សោ

១ ម. ភត្តាភិហារេនាតិ ។ ២–៣ ម. ភោន្តោ ។



នឹងព្រហ្មបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ប្រាថ្នាដើម្បីនឹងសម្ងំនៅក្នុងផ្ទះភ្លៀងអស់ ៤ ខែ ដើម្បីពិចារណា នូវករុណាឈាន មិនត្រូវឲ្យអ្នកណាមួយ ចូលទៅរកខ្ញុំព្រះអង្គឡើយ វៀរលែងតែបុគ្គលម្នាក់ជាអ្នកនាំអាហារទៅឲ្យ ។ ព្រះរាជាទាំងឡាយ មានព្រះបន្ទូលថា គោវិន្ទ-ព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរក្នុងកាលឥឡូវនេះចុះ ។ គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅគាល់ហើយ បានក្រាបទូលក្សត្រទាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំព្រះអង្គ ល្បីខ្ចរខ្ចាយទៅយ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ តែងឃើញព្រហ្មដោយផ្ទាល់ខ្លួន មហា-គោវិន្ទព្រាហ្មណ៍ តែងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន បពិត្រព្រះអង្គដ៏ចម្រើន តែខ្ញុំព្រះអង្គ មិនបានឃើញព្រហ្មសោះ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្ញុំព្រះអង្គគ្រាន់តែឮសេចក្តីពោលនេះ របស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យប្រធានលើអាចារ្យ និយាយថា បុគ្គលណា សម្ងំនៅក្នុងផ្ទះភ្លៀងអស់ ៤ ខែ ពិចារណា នូវករុណាឈាន បុគ្គលនោះ

ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ឥច្ឆាមហំ ភោ វស្សិកេ ចត្តារោ មាសេ បដិសល្លីយិតុំ ករុណំ ឈានំ ឈាយិតុំ នម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន ភត្តាភិហារេនាតិ ។ យស្សទានិ ភវំ គោវិន្ទោ កាលំ មញ្ញតីតិ ។ អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ យេន សត្ត ច ព្រាហ្មណមហាសាលា សត្ត ច ន្ហាតកសតានិ តេនុបសង្កមិ ឧបសង្កមិត្វា សត្ត ច ព្រាហ្មណមហាសាលេ សត្ត ច ន្ហាតកសតានិ ឯតទវោច មយ្ហំ ខោ ភោ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ ភោ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបាមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន



អាចឃើញនូវព្រហ្មបាន សាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ប្រាថ្នាដើម្បីនឹងសម្ងំនៅក្នុងវស្សានរដូវ ៤ ខែ ពិចារណា នូវករុណាឈាន មិនត្រូវឲ្យអ្នកណាមួយ ចូលទៅរកខ្ញុំព្រះអង្គឡើយ វៀរលែងតែបុគ្គលម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ក្សត្រទាំង ៦ អង្គ មានព្រះបន្ទូលថា លោកគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកព្រាហ្មណមហាសាលទាំង ៧ នាក់ និងន្ហាតកព្រាហ្មណ៍ទាំង ៧០០ នាក់ លុះចូលទៅដល់ហើយ ក៏បាននិយាយទៅនឹងព្រាហ្មណមហាសាលទាំង ៧ នាក់ និងន្ហាតកព្រាហ្មណ៍ទាំង ៧០០ នាក់ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំ ល្បីខ្ចរខ្ចាយទៅ យ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍ អាចឃើញព្រហ្មដោយផ្ទាល់ខ្លួន ពោលសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មដោយផ្ទាល់ខ្លួនបាន ម្នាលអ្នកដ៏ចម្រើន តែខ្ញុំមិនបានឃើញព្រហ្មសោះ មិនបានសាកសួរជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លងជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្ញុំគ្រាន់តែឮ

មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិ-
យានំ ភាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិ-
សល្លីយតិ ករុណំ ឈានំ ឈាយតិ សោ ព្រហ្មានំ
បស្សតិ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ តេនហិ
ភោ យថាសុតេ យថាបរិយត្តេ មន្តេ វិត្ថារេន សជ្ឈាយំ
ករោថ អញ្ញមញ្ញញ្ច មន្តេ វាចេថ ឥច្ឆាមហំ ភោ
វស្សិកេ ចត្តារោ មាសេ បដិសល្លីយិតុំ ករុណំ ឈានំ
ឈាយិតុំ នម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯ-
កេន ភត្តាភិហារេនាតិ ។ យស្សទានិ ភវំ គោវិន្ទោ
កាលំ មញ្ញតីតិ ។ អថខោ ភោ មហាគោវិន្ទោ
ព្រាហ្មណោ យេន ចត្តារីសា ភរិយា សាទិសិយោ តេ-
នុបសង្កមិ ឧបសង្កមិត្វា ចត្តារីសា ភរិយា សាទិសិ-
យោ ឯតទវោច មយ្ហំ ខោ ភោតិ ឯវំ កល្យាណោ កិត្តិ-
សទ្ទោ អព្ភុគ្គតោ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ



ឮសេចក្តីតំណាលនេះ របស់ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ មានអាយុច្រើន
ជាអាចារ្យប្រាចារ្យលើកពាក្យ និយាយថា បុគ្គលណា សម្ងំនៅក្នុងផ្ទះ
ភ្លៀងអស់ ៤ ខែ ពិចារណា នូវករុណាឈាន បុគ្គលនោះ នឹងឃើញ
ព្រហ្មបាន នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន
ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ស្វាធ្យាយនូវមន្តទាំង-
ឡាយ តាមដែលបានស្តាប់មកហើយ បានរៀនមកហើយ ដោយពិស្តារ
ចុះ ចូរប្រាប់មន្តទាំងឡាយ ដល់គ្នានឹងគ្នាផងចុះ ម្នាលអ្នកដ៏ចម្រើន ខ្ញុំ
ប្រាថ្នាដើម្បីនឹងសម្ងំនៅក្នុងរដូវភ្លៀងអស់ ៤ ខែ ដើម្បីនឹងពិចារណានូវ
ករុណាឈាន មិនត្រូវឲ្យអ្នកណាមួយចូលទៅរកខ្ញុំឡើយ វៀរតែបុគ្គល
ម្នាក់ ជាអ្នកនាំអាហារទៅឲ្យ ។ ព្រាហ្មណមហាសាល និង[illegible]
ទាំងនោះ និយាយតបថា លោកគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ
ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទ-
ព្រាហ្មណ៍ ចូលទៅរកប្រពន្ធទាំង ៤០ នាក់ ដែលមានត្រកូលនិងជាតិ
ស្មើគ្នា លុះចូលទៅដល់ហើយ បាននិយាយទៅនឹងប្រពន្ធទាំង ៤០ នាក់
ដែលមានត្រកូលនិងជាតិស្មើគ្នា យ៉ាងនេះថា នែនាងដ៏ចម្រើន កិត្តិសព្ទដ៏
ពីរោះបែបនេះ ល្បីខ្ចរខ្ចាយទៅ យ៉ាងនេះថា មហាគោវិន្ទព្រាហ្មណ៍

ព្រហ្មានំ បស្សតិ សក្ខិ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ បនាហំ ភោតិ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ ន ព្រហ្មុនា សល្លបេមិ ន ព្រហ្មុនា មន្តេមិ សុតំ ខោ បន មេតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិសល្លីយតិ ករុណំ ឈានំ ឈាយតិ សោ ព្រហ្មានំ បស្សតិ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ឥច្ឆាមហំ ភោតិ វស្សិកេ ចត្តារោ មាសេ បដិសល្លីយិតុំ ករុណំ ឈានំ ឈាយិតុំ ន ម្ហិ កេនចិ ឧបសង្កមិតព្វោ អញ្ញត្រ ឯកេន ភត្តាភិហារេនាតិ ។ យស្សទានិ ភវំ គោវិន្ទោ កាលំ មញ្ញតីតិ ។ អថខោ សោ មហាគោវិន្ទោ ព្រាហ្មណោ បុរត្ថិមេន នគរស្ស នវំ សណ្ឋាគារំ ការាបេត្វា វស្សិកេ ចត្តារោ មាសេ បដិសល្លីយិ ករុណំ ឈានំ ឈាយិ ។ នាស្សុ(១) កោចិ ឧបសង្កមតិ(២) អញ្ញត្រ

១ ឱ. នាស្សុទ ។ ម. នាស្សុធ ។ ២ ឱ. ឧបសង្កមិ ។



បានឃើញព្រហ្មដោយផ្ទាល់ខ្លួន មហាគោវិន្ទព្រាហ្មណ៍ បានសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្ម ដោយផ្ទាល់ខ្លួនបាន តែខានដឹងចម្រើន តែខ្ញុំអញ មិនបានឃើញព្រហ្មសោះ មិនបានសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លង ជាមួយនឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្មទេ ខ្ញុំអញ គ្រាន់តែបានឮសេចក្ដីតំណាលនេះ របស់ពួកព្រាហ្មណ៍ចាស់ៗ មានអាយុច្រើន ជាអាចារ្យប្រមាចារ្យ និយាយថា បុគ្គលណា សម្ងំនៅក្នុងវស្សារដូវអស់ ៤ ខែ ពិចារណានូវករុណាឈាន បុគ្គលនោះ នឹងឃើញនូវព្រហ្ម នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជាមួយនឹងព្រហ្មបាន តែខានដឹងចម្រើន អញត្រូវតែប្រាថ្នា ដើម្បីសម្ងំនៅក្នុងវស្សារដូវអស់ ៤ ខែ ដើម្បីនឹងពិចារណា នូវករុណាឈាន មិនត្រូវឲ្យអ្នកណា មួយចូលទៅរកអញឡើយ វៀរលែងតែបុគ្គលម្នាក់ជាអ្នកនាំអាហារទៅឲ្យ ។ ប្រពន្ធទាំង ៤០ នាក់ ឆ្លើយតបថា គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ឲ្យសាងរោងស្រមថ្មី នាទិសខាងកើតព្រះនគរ ហើយសម្ងំនៅក្នុងវស្សារដូវអស់ ៤ ខែ ពិចារណានូវករុណាឈាន ។ មិនមានអ្នកណាចូលទៅរកគាត់ឡើយ វៀរលែងតែ

ឯកេន ភត្តាហារេនាតិ(១) ។ អថ ខោ មហាគោ-
វិន្ទស្ស ព្រាហ្មណស្ស ចតុន្នំ មាសានំ អច្ចយេន អហុទេវ
ឧក្កណ្ឋនា អហុ បរិតស្សនា សុតំ ខោ បន មេតំ
ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ
ភាសមានានំ យោ វស្សិកេ ចត្តារោ មាសេ បដិ-
សល្លីយតិ ករុណំ ឈានំ ឈាយតីតិ សោ ព្រហ្មានំ
បស្សតិ ព្រហ្មុនា សាកច្ឆេតិ សល្លបតិ មន្តេតីតិ ន ខោ
បនាហំ ព្រហ្មានំ បស្សាមិ ន ព្រហ្មុនា សាកច្ឆេមិ
ន ព្រហ្មុនា សល្លបាមិ ន ព្រហ្មុនា មន្តេមីតិ ។ អថ-
ខោ ព្រហ្មា សនង្កុមារោ មហាគោវិន្ទស្ស ព្រាហ្ម-
ណស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ

---

១ ម. ឆ. ភត្តាភិហារេន ។



បុគ្គលម្នាក់ ជាអ្នកនាំភោជនទៅឲ្យ ។ ម្នាលអ្នកដ៏ចំរើន គ្រានោះឯង
កាលកន្លងទៅ ៤ ខែហើយ មហាគោវិន្ទព្រាហ្មណ៍ កើតសេចក្ដីអផ្សុក
អន្ទះអន្ទែងថា អាត្មាអញ ធ្លាប់ឮសេចក្ដីពណ៌នានេះ របស់ពួកព្រាហ្មណ៍
ព្រឹទ្ធាចារ្យ មានអាយុច្រើន ជាអាចារ្យបង្រៀនលើអាចារ្យ និយាយថា
បុគ្គលណា សម្ងំនៅក្នុងផ្ទះភ្លៀងអស់ ៤ ខែ ពិចារណា នូវករុណាឈាន
បុគ្គលនោះ នឹងឃើញព្រហ្ម នឹងសាកសួរ និយាយឆ្លើយឆ្លង ប្រឹក្សាជា
មួយនឹងព្រហ្មបាន តែ (ឥឡូវនេះ) អាត្មាអញ មិនបានឃើញព្រហ្មសោះ
មិនបានសាកសួរ ជាមួយនឹងព្រហ្ម មិនបាននិយាយឆ្លើយឆ្លង ជាមួយ
នឹងព្រហ្ម មិនបានប្រឹក្សាជាមួយនឹងព្រហ្ម ។ ម្នាលអ្នកដ៏ចំរើន គ្រានោះ
ឯង សនង្កុមារព្រហ្ម បានដឹងច្បាស់នូវសេចក្ដីត្រិះរិះក្នុងចិត្ត របស់មហា-
គោវិន្ទព្រាហ្មណ៍ ដោយចិត្តរបស់ខ្លួនហើយ ក៏ស្រាប់តែបាត់អំពីព្រហ្ម-
លោក មកប្រាកដក្នុងទីចំពោះមុខ មហាគោវិន្ទព្រាហ្មណ៍ ប្រៀបដូចជា

ពាហំ ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសា-រេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ ព្រហ្មលោកេ អន្តរហិតោ មហាគោវិន្ទស្ស ព្រាហ្ម-ណស្ស សម្មុខេ បាតុរហោសិ ។ អថខោ ភោ មហា-គោវិន្ទស្ស ព្រាហ្មណស្ស អហុទេវ ភយំ អហុ ឆម្ភិតត្តំ អហុ លោមហំសោ យថាតំ អទិដ្ឋបុព្វំ រូបំ ទិស្វា ។ អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ ភីតោ សំវិគ្គោ លោមហដ្ឋជាតោ ព្រហ្មំ សនង្កុមារំ គាថាយ អជ្ឈ-ភាសិ

(៦៣) វណ្ណវា យសវា សិរីមា
កោ នុ ត្វមសិ មារិស
អជានន្តា តំ បុច្ឆាម
កថំ ជានេមុ តំ មយន្តិ(១) ។
មំ វេ កុមារំ ជានន្តិ
ព្រហ្មលោកេ សនន្តនំ(២)

១ ឱ. មយំ ។ ២ ម. សនន្តិ ។



បុរសមានកម្លាំងលាដៃ ដែលខ្លួនបត់ចូល ឬបត់ដៃដែលខ្លួនលាចេញ ។ ម្នាលអ្នកដ៏ចម្រើន លំដាប់នោះឯង សេចក្តីភ័យ សេចក្តីតក់ស្លុត និងការព្រឺរោម ក៏កើតឡើង ដល់មហាគោវិន្ទព្រាហ្មណ៍ ព្រោះបានឃើញរូបដែលខ្លួនមិនធ្លាប់ឃើញសោះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហា-គោវិន្ទព្រាហ្មណ៍ និយាយទៅនឹងសនង្កុមារព្រហ្ម ដ៏ភិតភ័យ តក់ស្លុត ព្រឺរោម ដោយគាថា ថា

(៦៣) បពិត្រលោកនិទ្ទុក្ខ លោកជាអ្វីហ្ន៎ ទើបមានសម្បុរ
មានយស មានសិរី (យ៉ាងនេះ) យើងមិនស្គាល់ បាន
ជាសូមសួរលោក ធ្វើដូចម្តេចហ្ន៎ យើងនឹងស្គាល់លោក ។
សនង្កុមារព្រហ្មឆ្លើយថា ពួកជន តែងស្គាល់ខ្ញុំថា
ជាកុមារ ក្នុងព្រហ្មលោក ជាអស់កាលយូរហើយ

សច្ចំ ជានន្តិ មំ ទេវា

ឯវំ គោវិន្ទ ជានាហិ(១) ។

អាសនំ ឧទកំ បជ្ជំ

មធុសាកញ្ច(២) ព្រហ្មុនោ

អគ្ឃេ ភវន្តំ បុច្ឆាម

អគ្ឃំ កុរុតុ នោ ភវំ ។

បដិគ្គណ្ហាម តេ អគ្ឃំ

យំ ត្វំ គោវិន្ទ ភាសសិ

ទិដ្ឋេ ធម្មេ ហិតត្ថាយ(៣)

សម្បរាយសុខាយ ច

កតាវកាសោ បុច្ឆស្សុ

យង្កិញ្ចិ អភិបត្ថិតំ ។

[២៤] អថខោ ភោ មហាគោវិន្ទស្ស ព្រាហ្មណស្ស ឯតទហោសិ កតាវកាសោ ខោម្ហិ ព្រហ្មុនា សនង្កុមារេន កិន្នុ ខោ អហំ ព្រហ្មានំ សនង្កុមារំ បុច្ឆេយ្យំ ទិដ្ឋធម្មិកំ វា អត្ថំ សម្បរាយិកំ វាតិ ។ អថខោ ភោ

១ ម. ជានាហិ ។ ២ ម. មធុសាកញ្ច ។ ៣ ឱ. ម. ទិដ្ឋធម្មហិតត្ថាយ ។



ពួកទេវតាជាន់ក្នុងលោក ក៏ស្គាល់ខ្ញុំដែរ ម្នាលគោវិន្ទ អ្នកចូរដឹងយ៉ាងនេះចុះ ។

មហាគោវិន្ទព្រាហ្មណ៍និយាយថា អាសនៈ ទឹក ប្រេងសម្រាប់លាបជើង និងទឹកឃ្មុំ ដែលមានផលព្រៃ យើងសូមទទួលលោកដ៏ចម្រើន ដោយគ្រឿងទទួលភ្ញៀវ សូមលោកដ៏ចម្រើន ទទួលគ្រឿងទទួលភ្ញៀវ របស់យើងចុះ ។

សនង្កុមារព្រហ្មឆ្លើយថា ម្នាលគោវិន្ទ អ្នកពោលចំពោះគ្រឿងទទួលភ្ញៀវ ណា យើងព្រមទទួលគ្រឿងទទួលភ្ញៀវនោះ របស់អ្នក យើងបើកឱកាសឲ្យអ្នកសួរហើយ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង អ្នកប្រាថ្នាប្រយោជន៍ណាមួយ ចូរសួរប្រយោជន៍នោះចុះ ។

[២៤] ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ មានសេចក្តីត្រិះរិះយ៉ាងនេះថា សនង្កុមារព្រហ្ម បានបើកឱកាសដល់អញ ហើយ តើអញ គួរសួរនឹងសនង្កុមារព្រហ្ម គួរសួរប្រយោជន៍ក្នុងបច្ចុប្បន្ន ឬប្រយោជន៍ក្នុងបរលោក ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះ

មហាគោវិន្ទស្ស ព្រាហ្មណស្ស ឯតទហោសិ កុសលោ ខោ អហំ ទិដ្ឋធម្មិកានំ អត្ថានំ អញ្ញេបិ មំ ទិដ្ឋធម្មិកំ អត្ថំ បុច្ឆន្តិ យន្នូនាហំ ព្រហ្មានំ សនង្កុមារំ សម្បរាយិកញ្ចេវ[1] អត្ថំ បុច្ឆេយ្យន្តិ ។ អថខោ សោ មហាគោវិន្ទោ ព្រាហ្មណោ ព្រហ្មានំ សនង្កុមារំ គាថាយ អជ្ឈភាសិ

(៦៥) បុច្ឆាមិ ព្រហ្មានំ សនង្កុមារំ
កង្ខី អកង្ខី បរវេទិយេសុ
កត្ថដ្ឋិតោ កិម្ហិ ច[2] សិក្ខមានោ
បប្បោតិ មច្ចោ អមតំ ព្រហ្មលោកន្តិ ។
ហិត្វា មមត្តំ មនុជេសុ ព្រហ្មេ
ឯកោទិភូតោ ករុណាធិមុត្តោ[3]
និរាមគន្ធោ វិរតោ មេថុនស្មា
ឯត្ថដ្ឋិតោ ឯត្ថ ច សិក្ខមានោ
បប្បោតិ មច្ចោ អមតំ ព្រហ្មលោកន្តិ ។

១ សម្បរាយិកំយេវ ។ ២ ម. ចិ ។ ៣ ម. ករុណេធិមុត្តោ ។



មហាគោវិន្ទព្រាហ្មណ៍ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា អាត្មាអញ ជាមនុស្សឈ្លាសវៃ ចំពោះប្រយោជន៍ ក្នុងបច្ចុប្បន្នស្រាប់ហើយ ទាំងពួកជនដទៃ ក៏តែងសួរនូវប្រយោជន៍ ក្នុងបច្ចុប្បន្ន នឹងអាត្មាអញដែរ បើដូច្នោះ គួរតែអាត្មាអញ សួរសនង្កុមារព្រហ្ម ចំពោះប្រយោជន៍ ក្នុងបរលោក តែមួយយ៉ាងប៉ុណ្ណោះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ក៏ពោលនិយាយនឹងសនង្កុមារព្រហ្ម ដោយគាថា ថា

(៦៥) ខ្ញុំមានសេចក្ដីសង្ស័យ សូមសួរសនង្កុមារព្រហ្ម
ដែលជាអ្នកមិនមានសេចក្ដីសង្ស័យ ក្នុងប្រស្នាទាំងឡាយ
ដែលបុគ្គលដទៃគួរដឹងថា សត្វឋិតនៅក្នុងធម៌អ្វី សិក្សាក្នុងធម៌អ្វី ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ។

សនង្កុមារព្រហ្មតបថា ម្នាលព្រាហ្មណ៍ សត្វលះបង់នូវសេចក្ដីប្រកាន់ថារបស់អញ ក្នុងពួកសត្វទេញ ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង មានចិត្តមូលទៅរកករុណាឈាន ព្រោះចាកក្លិនគួលគឺកិលេស វៀរចាកមេថុនធម្ម ឋិតនៅក្នុងធម៌ទាំងនេះ លុះសិក្សាក្នុងធម៌ទាំងនេះហើយ ទើបដល់នូវព្រហ្មលោក ដែលមិនស្លាប់ ។

(៦៦) ហិត្វា មមត្តន្តិ អហំ(១) ភោតោ អាជានាមិ ។ ឥធេកច្ចោ អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ឥតិ ហិត្វា មមត្តន្តិ អហំ(២) ភោតោ អាជានាមិ ។ ឯកោទិភូតោតិ អហំ(៣) ភោតោ អាជានាមិ ។ ឥធេកច្ចោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ បដិសល្លីយតិ(៤) ឥតិ ឯកោទិភូតោតិ អហំ ភោតោ អាជានាមិ ។ ករុណាធិមុត្តោតិ អហំ ភោតោ អាជានាមិ ។ ឥធេកច្ចោ

១-២ ឱ. មមត្តំតាហំ ។ មមត្តំតិបហត្តិ បន បាឋោ ភវិតព្វំ ។ ៣ ម. ឯកោទិភូតោតិ អហំ ។ ឯកោទិភូតោតិបហត្តិ បាឋោ ភវិតព្វំ ។ ៤ ឱ. ម. បដិសល្លីយតីតិ ន ទិស្សតិ ។



(៦៦) មហាគោវិន្ទព្រាហ្មណ៍ និយាយតបថា (ក្រាបទូល) របស់លោកដ៏ចម្រើនថា លះបង់នូវសេចក្ដីប្រកាន់ ថា របស់អញចេញ ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់នូវគំនរទ្រព្យតិចក្ដី លះបង់នូវគំនរទ្រព្យច្រើនក្ដី លះបង់នូវញាតិវង្សតិចក្ដី លះបង់នូវញាតិវង្សច្រើនក្ដី ហើយកោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស (ក្រាបទូល) របស់លោកដ៏ចម្រើន ថា លះបង់នូវសេចក្ដីប្រកាន់ ថា របស់អញចេញ ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ (ក្រាបទូល) របស់លោកដ៏ចម្រើនថា ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ គប់រកសេនាសនៈស្ងាត់ស្ងៀម គឺចូលទៅនៅតាមព្រៃ ម្លប់ឈើ ភ្នំ ជ្រោះ គុហាភ្នំ ទីស្មសាន ព្រៃស្រោង ទីវាល គំនរស្លឹកឈើ (ក្រាបទូល) របស់លោកដ៏ចម្រើនថា ជាបុគ្គលប្រព្រឹត្តតែម្នាក់ឯង ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការដូច្នេះឯង ។ (ក្រាបទូល) របស់លោកដ៏ចម្រើនថា មានចិត្តចុះទៅរក នូវករុណាឈាន ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ។ បុគ្គលពួកខ្លះ ក្នុងលោកនេះ

ករុណាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរ-តិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ករុណាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ឥតិ ករុណាធិមុត្តោតិ សហំ ភោតោ អាជានាមិ ។ អាម-គន្ធេ ច ខោ អហំ ភោតោ ភាសមានស្ស ន ន(១) អាជានាមិ ។

[២៧] កេ អាមគន្ធា មនុជេសុ ព្រហ្មេ
ឯតេ អវិទ្វា ឥធ ព្រូហិ ធីរ
កេនាវុដា(២) វាតិ បជា កុរុត្ថុ(៣)
អាបាយិកា និវុតព្រហ្មលោកា ។

១ ឱ. ម. បជានាមិ នត្ថិ ។ ២ ឱ. ម. កេនាវដា ។ ៣ ឱ. កុរុត្ថុ ។ ម. កុរុកុ ។



មានចិត្តប្រកបដោយករុណា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយករុណា ដ៏ទូលាយ ដល់នូវភាពធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វទាំងអស់ ដោយយកខ្លួនឯង ទៅប្រៀបនឹងសត្វទាំងពួង គ្រប់ទិស គឺ ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺ ទិសតូច ៗ ក៏ដូច្នោះដែរ (ត្រង់ពាក្យ) របស់លោកដ៏ចម្រើនថា មានចិត្តចុះទៅកាន់ករុណាឈាន ដូច្នេះ ខ្ញុំយល់ច្បាស់ហើយ ដោយប្រការ ដូច្នេះឯង ។ តែថា ខ្ញុំមិនយល់សោះ នូវពាក្យ របស់លោកដ៏ចម្រើន ដែលនិយាយពីរឿងក្លិនកុណប (នោះ) ។

[២៧] បពិត្រព្រហ្ម ពួកក្លិនកុណបក្នុងពួកសត្វ ខ្ញុំមិន
ស្គាល់ នូវក្លិនកុណបទាំងនុ៎ះឡើយ បពិត្រលោកជាអ្នកប្រាជ្ញ
សូមលោកមេត្តាប្រាប់ឲ្យបាន ក្នុងទីនេះ គឺពួកសត្វដូចម្តេច
ដែលរួបរឹត ពក់ព័ន្ធពួកសត្វ ឲ្យមានក្លិនអាក្រក់ នាំមុខ
ទៅកាន់អបាយ បិទទ្វារផ្លូវទៅកាន់ព្រហ្មលោក ។

កោធោ មោសវជ្ជំ និកតិ ច ទុព្ភោ(១)

កទរិយតា អតិមានោ ឧសូយា(២)

ឥច្ឆា វិចិកិច្ឆា បរហេឋនា ច(៣)

លោភោ ច ទោសោ ច មទោ ច មោហោ

ឯតេសុ យុត្តា អនិរាមគន្ធា

អាបាយិកា និវុតព្រហ្មលោកាតិ ។

(២៨) យថា ខោ អហំ ភោតោ អាមគន្ធេ ភាសមានស្ស អាជានាមិ តេ ន សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា(៤) អនគារិយន្តិ ។ យស្សទានិ ភវំ គោវិន្ទោ កាលំ មញ្ញតីតិ ។ អថ ខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ យេន រេណុ រាជា តេនុបសង្កមិ ឧបសង្កមិត្វា រេណុំ រាជានំ ឯតទវោច

១ ឱ. ទោភោ ។ ម. ទុព្ភោ ។ ២ ឱ. ម. ឧសូយា ។ ៣ ម. បរិហេឋនា ច ។ ៤ ឱ. ម. អគារស្មា ។



សនង្កុមារព្រហ្មធ្វើយតបថា សេចក្តីក្រោធ ១ ការនិយាយកុហក ១ ការបញ្ឆោតបន្លំ ១ ការប្រទូស្តមិត្រ ១ សេចក្តីកំណាញ់ស្វិតស្វាញ ១ សេចក្តីមើលងាយគេ ១ សេចក្តីច្រណែន ១ សេចក្តីប្រាថ្នា ១ សេចក្តីសង្ស័យ ១ ការបៀតបៀនអ្នកដទៃ ១ លោភៈ ១ ទោសៈ ១ សេចក្តីស្រវឹង ១ សេចក្តីវង្វេង ១ ពួកសត្វ ដែលប្រកបដោយកិលេសទាំង ១៤ នេះ ឈ្មោះថា ជាអ្នកមានក្លិនពុល មិនទាន់អស់ រមែងទៅកាន់អបាយ ដែលបិទបាំងផ្លូវទៅកាន់ព្រហ្មលោក ។

(២៨) មហាគោវិន្ទព្រាហ្មណ៍ និយាយថា ខ្ញុំយល់ច្បាស់ហើយនូវក្លិនពុលទាំងឡាយ ដែលលោកដ៏ចម្រើននិយាយ តែក្លិនពុលទាំងនោះ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រលោកដ៏ចម្រើន ខ្ញុំនឹងចេញចាកផ្ទះទៅបួស ។ សនង្កុមារព្រហ្ម និយាយតបថា គោវិន្ទព្រាហ្មណ៍ដ៏ចម្រើន សម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅគាល់ព្រះបាទរេណុ លុះចូលទៅដល់ហើយ បានក្រាបទូលព្រះបាទរេណុយ៉ាងនេះ

អញ្ញំ ទានិ ភវំ បុរោហិតំ បរិយេសតុ យោ ភោតោ រជ្ជំ អនុសាសិស្សតិ ឥច្ឆាមហំ ភោ អគារស្មា អនគារិយំ បព្វជិតុំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិគ្គហា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។

(៦៨) អាមន្តយាមិ រាជានំ
រេណុំ ភូមិបតឹ អហំ
ត្វំ បជានស្សុ រជ្ជេន
នាហំ បោរោហិច្ចេ រមេ ។
សចេ តេ ឩនំ កាមេហិ(១)
អហំ បរិបូរយាមិ តេ
យោ តំ ហឹសតិ វារេមិ
ភូមិសេនាបតី អហំ
ត្វំ បិតា អហំ បុត្តោ ច(២)
មា នោ គោវិន្ទ បាជហិ ។
ន មត្ថិ ឩនំ កាមេហិ

---

១ ឱ. ម. ឩនំ កាមេហិ ។ ២ ម. បិតាសិ អហំ បុត្តោ ។



ថា ឥឡូវនេះ សូមព្រះអង្គដ៏ចម្រើន ស្វែងរកបុរោហិតឯទៀត សម្រាប់នឹងប្រើក្នុងការរាជការ របស់ព្រះអង្គដ៏ចម្រើនចុះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រាថ្នា ដើម្បីនឹងចេញចាកផ្ទះទៅបួស ព្រោះខ្ញុំព្រះអង្គឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ តែក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានទេ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។

(៦៨) មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា ខ្ញុំព្រះអង្គសូមក្រាបទូលព្រះបាទរេណុ ជាម្ចាស់ផែនដី សូមព្រះអង្គទ្រង់ជ្រាបដោយកិច្ចរាជការចុះ ខ្ញុំព្រះអង្គ លែងត្រេកអរក្នុងតំណែងបុរោហិតហើយ ។

ព្រះបាទរេណុ ត្រាស់ថា បើអ្នកខ្វះខាត ដោយវត្ថុកាមទាំងឡាយ ដែលត្រូវការ យើងនឹងបំពេញឲ្យអ្នក បើបុគ្គលណាបៀតបៀនអ្នក យើងជាម្ចាស់ នៃសេនាលើផែនដីនឹងហាមឃាត់បុគ្គលនោះ អ្នកទុកដូចជាបិតា យើងទុកដូចជាបុត្រ ម្នាលគោវិន្ទ សូមអ្នកកុំលះបង់យើងឡើយ ។

មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា ការខ្វះខាតដោយវត្ថុកាមទាំងឡាយ ដែលត្រូវការ (នៃខ្ញុំព្រះអង្គ) មិនមានទេ.

ហីសិកោ(១) មេ ន វិជ្ជតិ
អមនុស្សវចោ សុត្វា
តស្មាហំ ន គេហេ រមេ ។
អមនុស្សោ កថំវណ្ណោ
កន្តេ អត្ថំ អភាសថ
យញ្ច សុត្វា ជហាសិ នោ(២)
គេហេ អម្ហេ ច កេវលី ។
ឧបវុត្ថស្ស មេ បុព្វេ
យិដ្ឋកាមស្ស មេ សតោ
អគ្គិ បជ្ជលិតោ អាសិ
កុសបត្តបរិត្ថតោ ។
តតោ មេ ព្រហ្មា ពាតុរហុ(៣)
ព្រហ្មលោកា សនន្តនោ
សោ មេ បញ្ហំ វិយាកាសិ
តំ សុត្វា ន គេហេ រមេ ។
សទ្ទហាមិ អហំ ភោតោ
យំ ត្វំ គោវិន្ទ ភាសសិ

១ ម. ឱ. ហីសិកា ។ ២ ម. យំ សុត្វា បជហាសិ តោ ។ ៣ ឱ. ពាតុរហុ ។



បុគ្គលអ្នកបៀតបៀនខ្ញុំព្រះអង្គ ក៏មិនមានដែរ ប៉ុន្តែ ខ្ញុំព្រះអង្គ បានស្តាប់ពាក្យរបស់អមនុស្សហើយ ហេតុនោះ បានជាខ្ញុំព្រះអង្គ មិនត្រេកអរក្នុងផ្ទះទេ ។

ព្រះបាទរេណុ ត្រាស់ថា អមនុស្សមានភេទដូចម្តេច បាននិយាយសេចក្តីដូចម្តេចនឹងអ្នក ដែលអ្នកបានស្តាប់ហើយ នឹងលះបង់ នូវផ្ទះទាំងឡាយ របស់យើងផង នូវយើងផង នូវជនទាំងអស់ផង ។

មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា កាលពីដើម ខ្ញុំព្រះអង្គ បួសនៅក្នុងសម្ងំនៅតែម្នាក់ឯង កាលដែលខ្ញុំព្រះអង្គប្រាថ្នា ដើម្បីបូជាយញ្ញ ខ្ញុំព្រះអង្គ ក៏ប្រមូលស្បូវនិងស្លឹកឈើ មកគរ បញ្ឆេះភ្លើងឲ្យឆេះឡើង ។ លំដាប់នោះ ស្រាប់តែសនន្តនព្រហ្ម មកអំពីព្រហ្មលោក ប្រាកដ (នៅមុខ) នៃខ្ញុំព្រះអង្គ ព្រហ្មនោះ បានដោះស្រាយប្រស្នានឹងខ្ញុំព្រះអង្គ ឯខ្ញុំព្រះអង្គ ក៏បានស្តាប់នូវសេចក្តីនោះហើយ ទើបរលែងត្រេកអរក្នុងផ្ទះ ។

ព្រះបាទរេណុ មានព្រះរាជឱង្ការថា ម្នាលគោវិន្ទ អ្នកនិយាយពាក្យណា យើងក៏ជឿពាក្យនោះ របស់អ្នក

អមនុស្សវចោ សុត្វា
កថំ វក្ខថ អញ្ញថា
តេ តំ អនុវត្តិស្សាម(១)
សត្ថា គោវិន្ទ នោ ភវំ ។
មណិ យថា វេឡុរិយោ
អកាចោ(២) វិមលោ សុភោ
ឯវំ សុទ្ធា(៣) ចរិស្សាម
គោវិន្ទស្សានុសាសនេតិ ។

(៧០) សចេ ភវំ គោវិន្ទោ អគារស្មា អនគារិយំ បព្វជិស្សតិ មយម្បិ អគារស្មា អនគារិយំ បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ ភវិស្សតីតិ ។ អថ ខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ យេន តេ ឆ ខត្តិយា តេនុបសង្កមិ ឧបសង្កមិត្វា តេ ឆ ខត្តិយេ ឯតទវោច អញ្ញំ ទានិ ភោ(៤) ភវន្តោ បុរោហិតំ បរិយេសន្តុ យោ ភវន្តានំ រជ្ជំ អនុសាសិស្សតិ ឥច្ឆាមហំ

១ អនុព្វត្តិស្សាមាតិបិ បាឋោ ។ ២ ឧ. ម. អកាចោ ។ ៣ ឧ. ម. សុទ្ធា ។ ៤ ឧ. ម. ភោន្តោ ។





ដ៏ចម្រើន អ្នកបានស្តាប់ពាក្យអមនុស្សហើយ នឹងប្រព្រឹត្តទៅយ៉ាងដទៃឡើតដូចម្តេច យើងនោះ នឹងប្រព្រឹត្តតាមអ្នកដែរ ម្នាលគោវិន្ទ (ព្រោះថា) អ្នកដ៏ចម្រើន ជាគ្រូរបស់យើងស្រាប់ហើយ ។ អ្នក ប្រៀបដូចកែវមណីជាតិវៃទូរ្យ មិនមានប្រេះឆា ថ្លាស្អាត យើងបានល្អ យ៉ាងនេះហើយ នឹងប្រព្រឹត្តតាមពាក្យប្រដៅរបស់អ្នកគោវិន្ទ ។

(៧១) ព្រះបាទរេណុ មានព្រះរាជឱង្ការថា ប្រសិនបើគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន នឹងចេញចាកផ្ទះហើយបួសទៅកាន់ផ្នួស យើងនឹងចេញចាកផ្ទះទៅបួសដែរ គតិរបស់អ្នកយ៉ាងណា គតិរបស់យើងនឹងទៅជាយ៉ាងនោះដែរ ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ចូលទៅគាល់ក្សត្រទាំង ៦ អង្គនោះ លុះចូលទៅដល់ហើយ បានក្រាបទូលក្សត្រទាំង ៦ អង្គនោះ យ៉ាងនេះថា បពិត្រព្រះអង្គ ឥឡូវនេះ សូមព្រះអង្គទាំងឡាយដ៏ចម្រើន ស្វែងរកបុរោហិតដទៃទៀត សម្រាប់នឹងប្រឹក្សាកិច្ចការរជ្ជ របស់ព្រះអង្គទាំងឡាយដ៏ចម្រើនចុះ បពិត្រព្រះអង្គ ខ្ញុំ

ភោ អគារស្មា អនគារិយំ បព្វជិតុំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ អថខោ ភោ តេ ឆ(១) ខត្តិយា ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ ឥមេ ខោ ភោ ព្រាហ្មណា(២) នាម ធនលុទ្ធា យន្នូន មយំ មហាគោវិន្ទំ ព្រាហ្មណំ ធនេន សិក្ខេយ្យាមាតិ ។ តេ មហាគោវិន្ទំ ព្រាហ្មណំ ឧបសង្កមិត្វា ឯវមាហំសុ សំវិជ្ជតិ ខោ ភោ ឥមេសុ សត្តសុ រជ្ជេសុ បហុតំ សាបតេយ្យំ តតោ ភោតោ យាវតកេន អត្ថោ តាវតកំ អាហរីយតន្តិ(៣) ។ អលំ ភោ មមបិទំ បហុតំ សាបតេយ្យំ ភវន្តានំយេវ តថា សាបតេយ្យំ អហំ សព្វំ បហាយ អគារស្មា អនគារិយំ បព្វជិស្សាមិ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ

១ ម. ភេ ន ។ ២ ម. ឱ. (?) ព្រាហ្មណា ។ ៣ ម. អាហរិយតន្តិ ។



ព្រះអង្គម្ចាស់ ដើម្បីនឹងចេញចាកផ្ទះទៅបួស ព្រោះខ្ញុំព្រះអង្គបានឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គនឹងចេញចាកផ្ទះទៅបួស ។ ម្នាលអ្នកដ៏ចម្រើន គ្រានោះឯង ក្សត្រទាំង ៦ អង្គនោះ បៀសចេញទៅក្នុងទីដ៏សមគួរ ហើយគិតព្រមគ្នាថា ធម្មតាពួកព្រាហ្មណ៍ទាំងនេះ ជាបុគ្គលលោភនឹងទ្រព្យ បើដូច្នោះ គួរយើងល្បួងមហាគោវិន្ទព្រាហ្មណ៍ដោយទ្រព្យ ។ ក្សត្រទាំង៦អង្គនោះ ក៏ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ ហើយថ្លែងសេចក្ដីយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សម្បត្តិក្នុងនគរទាំង ៧ នេះមានច្រើន ព្រោះហេតុនោះ អ្នកដ៏ចម្រើនត្រូវការដោយសម្បត្តិប៉ុន្មាន ចូរយកសម្បត្តិប៉ុណ្ណោះចុះ ។ មហាគោវិន្ទព្រាហ្មណ៍ក្រាបទូលថា កុំឡើយព្រះអង្គ សម្បត្តិរបស់ខ្ញុំព្រះអង្គនេះប៉ុណ្ណឹងហើយ ជាសម្បត្តិដែលព្រះអង្គដ៏ចម្រើនទាំងឡាយប្រទានឲ្យ ខ្ញុំព្រះអង្គ លះបង់សម្បត្តិទាំងអស់ ហើយនឹងចេញចាកផ្ទះទៅបួស តាមពាក្យដែលខ្ញុំព្រះអង្គ បានឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ

កោ អគារស្មា អនគារិយន្តិ ។ អថខោ តេ ឆ ខត្តិយា ឯកមន្តំ អបក្កម្ម ឯវំ សមចិន្តេសុំ ឥមេ ខោ ព្រាហ្មណា នាម ឥត្ថីលុទ្ធា យន្នូន មយំ មហាគោវិន្ទំ ព្រាហ្មណំ ឥត្ថីហិ សិក្ខេយ្យាមាតិ តេ មហាគោវិន្ទំ ព្រាហ្មណំ ឧបសង្កមិត្វា ឯវមាហំសុ សំវិជ្ជន្តិ ខោ ភោ ឥមេសុ សត្តសុ រជ្ជេសុ បហូតា ឥត្ថិយោ តតោ ភោតោ យាវតិកាហិ អត្ថោ តាវតិកា អានីយន្តំ(១) ។ អលំ ភោ មមបិមា ចត្តារីសា ភរិយា សាទិសិយោ តាបហំ(២) សព្វា បហាយ អគារស្មា អនគារិយំ បព្វជិស្សាមិ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ សចេ ភវំ គោវិន្ទោ អគារស្មា អនគារិយំ បព្វជិស្សតិ មយម្បិ អគារស្មា អនគារិយំ បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ ភវិស្សតីតិ ។

១ ម. ឧ. អានីយន្តុ ។ ២ ម. តាបហំ ។ ឧ. តាបហំ ។





បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ម្នាលអ្នកដ៏ចម្រើន ព្រោះនោះឯង ក្សត្រទាំង ៦ អង្គនោះ ចៀសចេញទៅក្នុងទីដ៏សមគួរ ហើយគិតព្រមគ្នា យ៉ាងនេះថា ធម្មតាពួកព្រាហ្មណ៍ទាំងនេះ ជាបុគ្គលល្មោភនឹងស្ត្រី បើដូច្នោះ គួរតែយើងល្បួងលោកមហាគោវិន្ទព្រាហ្មណ៍ ដោយពួកស្ត្រី ។ ក្សត្រទាំង ៦ អង្គនោះ ចូលទៅរកមហាគោវិន្ទព្រាហ្មណ៍ ហើយថ្លែងសេចក្តីយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើនពួកស្ត្រីក្នុងដែនទាំង ៧ នេះ មានច្រើន ព្រោះហេតុនោះ អ្នកដ៏ចម្រើនត្រូវការដោយពួកស្ត្រីចំនួនប៉ុន្មាននាក់ ចូរនាំយកពួកស្ត្រីប៉ុណ្ណោះចុះ ។ មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា កុំឡើយព្រះអង្គ អម្បាលដូចជា ភរិយាទាំង ៤០ នាក់ របស់ខ្ញុំព្រះអង្គនេះ សុទ្ធតែមានជាតិនិងត្រកូលស្មើគ្នា (ស្មួចកឹ) ខ្ញុំព្រះអង្គ នឹងលះបង់ភរិយាទាំងអស់នោះ ហើយចេញចាកផ្ទះទៅបួស តាមដែលខ្ញុំព្រះអង្គ បានឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ ដែលថា ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានទេ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ក្សត្រទាំង ៦ អង្គ ត្រាស់ថា បើគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន នឹងចេញចាកផ្ទះទៅបួស ពួកយើង ក៏ចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។

[៧១] សចេ ជហាថ(១) កាមានិ
យត្ថ សត្តោ បុថុជ្ជនោ
អារទ្ធា(២) ទឡ្ហា ហោថ
ខន្តិពលសមាហិតា ។
ឯស មគ្គោ ឧជុមគ្គោ
ឯស មគ្គោ អនុត្តរោ
សទ្ធម្មោ សព្ភិ រក្ខិតោ
ព្រហ្មលោកូបបត្តិយាតិ ។

[៧២] តេនហិ ភវំ មហាគោវិន្ទោ(៣) សត្ត វស្សានិ អាគមេតុ សត្តន្នំ វស្សានំ អច្ចយេន មយម្បិ អគារស្មា អនគារិយំ បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ ភវិស្សតីតិ ។ អតិចិរំ ខោ ភោ សត្ត វស្សានិ នាហំ សក្កោមិ ភវន្តេ សត្ត វស្សានិ អាគមេតុំ កោ នុ ខោ(៤) បន ភោ ជានាតិ ជីវិតានំ គមនីយោ សម្បរាយោ មន្តាយ ពោទ្ធព្វំ

១ ឱ. ជហាថ ។ ម. ជហិថ ។ ២ ឱ. ម. អារព្ភា ។ ម. អាំ ។ ៣ ឱ. ម. គោវិន្ទោ ។ ៤ ឱ. ភោ ខោ ។



(៧១) មហាគោវិន្ទព្រាហ្មណ៍ ទូលថា បុថុជ្ជនតែងជាប់នៅ ក្នុងកាមទាំងឡាយណា បើព្រះអង្គទាំងឡាយ នឹងលះបង់នូវកាមទាំងឡាយនោះចេញ សូមព្រះអង្គប្រារព្ធនូវការព្យាយាមឲ្យមាំ ប្រកបដោយកម្លាំងនៃខន្តិធម៌ (ផង) ។ នេះជាផ្លូវត្រង់ នេះជាផ្លូវប្រសើរ ដែលពួកសប្បុរស តែងរក្សាព្រះសទ្ធម្ម ដើម្បីទៅកើតក្នុងព្រហ្មលោក ។

(៧២) ក្សត្រទាំង ៦ អង្គ ត្រាស់ថា បើដូច្នោះ សូមមហាគោវិន្ទ ចាំបង្អង់ ទំរាំអស់ ៧ ឆ្នាំ (សិន) លុះកន្លង ៧ ឆ្នាំហើយ ពួកយើងនឹង ចេញចាកផ្ទះទៅបួស បើគតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។ មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គ ដ៏ចម្រើន ៧ ឆ្នាំយូរណាស់ ខ្ញុំព្រះអង្គ មិនអាចនឹងនៅចាំព្រះអង្គដល់ ៧ ឆ្នាំបានទេ បពិត្រព្រះអង្គដ៏ចម្រើន នរណាឡើយ នឹងអាចដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរលោក បុគ្គលត្រូវយល់ដោយប្រាជ្ញា

កត្តព្វំ(១) កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស នេ ន សុករំ អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ តេនហិ ភវំ គោវិន្ទោ ឆ វស្សានិ អាគមេតុ ។ បេ ។ បញ្ច វស្សានិ អាគមេតុ ។ ចត្តារិ វស្សានិ អាគមេតុ ។ តីណិ វស្សានិ អាគមេតុ ។ ទ្វេ វស្សានិ អាគមេតុ ។ ឯកំ វស្សំ អាគមេតុ ឯកស្ស វស្សស្ស អច្ចយេន មយម្បិ អគារស្មា អនគារិយំ បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ ភវិស្សតីតិ ។ អតិចិរំ ខោ ភោ ឯកំ វស្សំ នាហំ សក្កោមិ ភវន្តេ ឯកំ វស្សំ អាគមេតុំ កោ នុ ខោ បន ភោ ជានាតិ ជីវិតានំ គមនីយោ សម្បរាយោ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស នេ ន សុករំ អគារំ អជ្ឈាវសតា

១ ម. ឧ ពោទ្ធព្វមកត្តព្វំ ។ ម. ពោទ្ធព្វំ ..... ។



ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ សត្វ ដែលកើតមកហើយ ឈ្មោះថា មិនស្លាប់ គ្មានទេ តាមដែលខ្ញុំព្រះអង្គបានឮព្រហ្មនិយាយអំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ក្សត្រទាំង ៦ អង្គ មានព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំអស់ ៦ ឆ្នាំសិន ។ បេ ។ រង់ចាំអស់ ៥ ឆ្នាំសិន ។ រង់ចាំអស់ ៤ ឆ្នាំសិន ។ រង់ចាំអស់ ៣ ឆ្នាំសិន ។ រង់ចាំអស់ ២ ឆ្នាំសិន ។ រង់ចាំអស់ ១ ឆ្នាំសិន លុះផុតកន្លង ១ ឆ្នាំហើយ ពួកយើងនឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។ មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ១ ឆ្នាំយូរណាស់ ខ្ញុំព្រះអង្គមិនអាច នឹងរង់ចាំព្រះអង្គ អស់ ១ ឆ្នាំបានទេ បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ ការដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរលោក បុគ្គលត្រូវយល់ដោយប្រាជ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតហើយ ឈ្មោះថា មិនស្លាប់ គ្មានទេ ព្រោះខ្ញុំព្រះអង្គ បានឮព្រហ្មនិយាយអំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ

បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ តេន-
ហិ ភវំ គោវិន្ទោ សត្ត មាសានិ អាគមេតុ សត្តន្នំ
មាសានំ អច្ចយេន មយម្បិ អគារស្មា អនគារិយំ
បព្វជិស្សាម យា តេ គតិ សា នោ គតិ
ភវិស្សតីតិ ។ អតិចិរំ ខោ ភោ សត្ត មាសានិ
នាហំ សក្កោមិ ភវន្តេ សត្ត មាសានិ អាគមេតុំ
កោ នុ ខោ បន ភោ ជានាតិ ជីវិតានំ គមនីយោ
សម្បរាយោ មន្តាយ ពោទ្ធព្វំ កត្តព្វំ កុសលំ ចរិ-
តព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អមរណំ យថា
ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមា-
នស្ស តេ ន សុនិម្មទយា អគារំ អជ្ឈាវសតា បព្វ-
ជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ តេនហិ
ភវំ គោវិន្ទោ ឆ មាសានិ អាគមេតុ ។ បញ្ច មាសានិ
អាគមេតុ ។ ចត្តារិ មាសានិ អាគមេតុ ។ តីណិ
មាសានិ អាគមេតុ ។ ទ្វេ មាសានិ អាគមេតុ ។ ឯកំ
មាសំ អាគមេតុ ។ អឌ្ឍមាសំ(១) អាគមេតុ អឌ្ឍមា-
សស្ស អច្ចយេន មយម្បិ អគារស្មា អនគារិយំ

១ ឱស្សមាសន្តិបិ បាឋោ ។

១៩៨

សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ក្សត្រទាំង៦
អង្គ មានព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំ
អស់៧ខែសិន លុះកន្លង៧ខែហើយ ពួកយើង នឹងចេញចាកផ្ទះទៅ
បួស គតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។
មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ៧ ខែយូរ
ណាស់ ខ្ញុំព្រះអង្គ មិនអាចនឹងចាំព្រះអង្គអស់ ៧ ខែបានទេ បពិត្រព្រះអង្គ
ដ៏ចម្រើន នរណាហ្ន៎ ដែលនឹងដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវតែទៅកាន់បរ-
លោក បុគ្គលត្រូវយល់ដោយប្រាជ្ញា ត្រូវធ្វើកុសល ត្រូវប្រព្រឹត្តព្រហ្ម-
ចរិយធម៌ សត្វដែលកើតហើយ ឈ្មោះថា មិនស្លាប់ គ្មានទេ ព្រោះខ្ញុំព្រះ
អង្គបានឮព្រហ្មនិយាយ នូវក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ
បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ បពិត្រព្រះអង្គដ៏
ចម្រើន ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ក្សត្រទាំង ៦ អង្គមាន
ព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន រង់ចាំអស់ ៦ ខែ
សិន ។ រង់ចាំអស់ ៥ ខែសិន ។ រង់ចាំអស់ ៤ ខែសិន ។ រង់ចាំអស់ ៣
ខែសិន ។ រង់ចាំអស់ ២ ខែសិន ។ រង់ចាំអស់ ១ ខែសិន ។ រង់ចាំ
អស់កន្លះខែសិន លុះកន្លងកន្លះខែទៅហើយ ពួកយើងនឹងចេញចាកផ្ទះ

បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ ភវិស្សតី-
តិ ។ អតិចិរំ ខោ ភោ អឌ្ឍមាសោ នាហំ សក្កោមិ ភវន្តេ
អឌ្ឍមាសំ អាគមេតុំ កោ នុ ខោ បន ភោ ជានាតិ
ជីវិតានំ គមនីយោ សម្បរាយោ មន្តាយ ពោទ្ធព្វំ កត្ត-
ព្វំ កុសលំ ចរិតព្វំ ព្រហ្មចរិយំ នត្ថិ ជាតស្ស អម-
រណំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ
ភាសមានស្ស តេ ន សុនិម្មទយា អគារំ អជ្ឈាវ-
សតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។
តេនហិ ភវំ គោវិន្ទោ សត្តាហំ អាគមេតុ យាវ មយំ
សកេ បុត្តភាតរេ រជ្ជេ(១) អនុសាសិស្សាម(២) សត្តា-
ហស្ស អច្ចយេន មយម្បិ អគារស្មា អនគារិយំ
បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ
ភវិស្សតីតិ ។ ន ចិរំ ខោ ភោ សត្តាហំ អាគ-
មិស្សាមហំ ភវន្តេ សត្តាហន្តិ ។ អថខោ ភោ

១ ម. រជ្ជេ ។ ២ ម. អនុសាសាម ។



ទៅបួស គតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។
មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កន្លះខែ
យូរណាស់ ខ្ញុំព្រះអង្គ មិនអាចនឹងនៅចាំព្រះអង្គ អស់កន្លះខែបានទេ
បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ អាចដឹងនូវជីវិតបាន ព្រោះបុគ្គលត្រូវ
តែទៅកាន់បរលោក បុគ្គលត្រូវយល់ដោយប្រាជ្ញា ត្រូវធ្វើកុសល ត្រូវ
ប្រព្រឹត្តព្រហ្មចរិយធម៌ សត្វដែលកើតមកហើយ ឈ្មោះថាមិនស្លាប់គ្មាន
ទេ ព្រោះខ្ញុំព្រះអង្គ បានឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ
ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ
បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ នឹងចេញចាកផ្ទះទៅបួស ។ ក្សត្រ
ទាំង ៦ អង្គ មានព្រះរាជឱង្ការថា បើដូច្នោះ សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន
នៅចាំអស់ ៧ ថ្ងៃសិន ទម្រាំពួកយើងប្រៀនប្រដៅកូន និងបងប្អូនរបស់ខ្លួន
ក្នុងរាជសម្បត្តិ លុះកន្លង ៧ ថ្ងៃហើយ ពួកយើង នឹងចេញចាកផ្ទះ
ទៅបួស គតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។
មហាគោវិន្ទព្រាហ្មណ៍ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ៧ ថ្ងៃមិនយូរ
ប៉ុន្មានទេ ខ្ញុំព្រះអង្គនឹងនៅចាំព្រះអង្គអស់ ៧ ថ្ងៃបាន ។ ម្នាលអ្នកដ៏ចម្រើន

មហាគោវិន្ទោ ព្រាហ្មណោ យេន តេ សត្ត ច ព្រាហ្មណមហាសាលា សត្ត ច ន្ហាតកសតានិ តេនុបសង្កមិ ឧបសង្កមិត្វា សត្ត ច ព្រាហ្មណមហាសាលេ សត្ត ច ន្ហាតកសតានិ ឯតទវោច អញ្ញំ ទានិ ភវន្តោ អាចរិយំ បរិយេសន្តុ យោ ភវន្តានំ មន្តេ វាចេស្សតិ ឥច្ឆាមហំ ភោ អគារស្មា អនគារិយំ បព្វជិតុំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស តេ ន សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ មា ភវំ គោវិន្ទោ អគារស្មា អនគារិយំ បព្វជិ បព្វជ្ជា ភោ អប្បេសក្ខា ច អប្បលាភា ច ព្រហ្មញ្ញំ មហេសក្ខញ្ច មហាលាភញ្ចាតិ ។ មា ភវន្តោ ឯវំ អវចុត្ថ មា ភវន្តោ ឯវំ អវចុត្ថ បព្វជ្ជា អប្បេសក្ខា ច អប្បលាភា ច ព្រហ្មញ្ញំ មហេសក្ខញ្ច មហាលាភញ្ចាតិ កោ នុ ខោ ភោ អញ្ញត្រ(១) មយា មហេសក្ខតរោ វា មហាលាភតរោ វា

១ អញ្ញោតិ ក ចាហោ ។



គ្រានោះឯង មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកព្រាហ្មណមហាសាល ទាំង ៧ នាក់ និងនាយហ្មាត់ព្រះវេទ ៧០០ នាក់ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រាហ្មណមហាសាលទាំង ៧ នាក់ និងនាយហ្មាត់ព្រះវេទ ទាំង ៧០០ នាក់ យ៉ាងនេះថា ឥឡូវនេះ សូមអ្នកដ៏ចម្រើនទាំងឡាយ រកអាចារ្យឯទៀត ឲ្យបង្រៀនមន្តដល់អ្នកទាំងឡាយដ៏ចម្រើនចុះ ម្នាលអ្នកដ៏ចម្រើន យើង ប្រាថ្នានឹងចេញចាកផ្ទះទៅបួស តាមដែលខ្ញុំបានឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ ម្នាលអ្នកដ៏ចម្រើន ខ្ញុំនឹងចេញចាកផ្ទះទៅបួស ។ ព្រាហ្មណមហាសាល និងនាយហ្មាត់ព្រះវេទ និយាយតបថា សូមគោវិន្ទព្រាហ្មណ៍ដ៏ចម្រើន កុំអាលចេញចាកផ្ទះទៅបួសឡើយ បពិត្រអ្នកដ៏ចម្រើន ផ្នួសបព្វជ្ជាមានសក្តិតូច មានលាភតិច ឯភាពជាព្រហ្ម មានសក្តិធំ មានលាភច្រើន ។ មហាគោវិន្ទព្រាហ្មណ៍តបថា អ្នកដ៏ចម្រើនទាំងឡាយ កុំនិយាយយ៉ាងនេះឡើយ អ្នកដ៏ចម្រើនទាំងឡាយ កុំនិយាយយ៉ាងនេះថា បព្វជ្ជាមានសក្តិតូច មានលាភតិច ឯភាពជាព្រហ្ម មានសក្តិធំ មានលាភច្រើន ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បុគ្គលណាម្នាក់ ក្រៅពីខ្ញុំចេញ ដែលមានសក្តិធំ មានលាភច្រើនជាង

អហំ ហិ ភោ(១) ឯតរហិ រាជា(២) រញ្ញំ ព្រហ្មា(៣) ព្រាហ្មណានំ ទេវតា(៤) គហបតិកានំ តមហំ(៥) សព្វំ បហាយ អគារស្មា អនគារិយំ បព្វជិស្សាមិ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស ន តេ សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោ អគារស្មា អនគារិយន្តិ ។ សចេ ភវំ គោវិន្ទោ អគារស្មា អនគារិយំ បព្វជិស្សតិ មយម្បិ អគារស្មា អនគារិយំ បព្វជិស្សាម យា តេ គតិ សា នោ គតិ ភវិស្សតីតិ ។ អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ យេន ចត្តារីសា ភរិយា សាទិសិយោ តេនុបសង្កមិ ឧបសង្កមិត្វា ចត្តា-រីសា ភរិយា សាទិសិយោ ឯតទវោច យា ភោតី-នំ ឥច្ឆតិ សកានិ វា(៦) ញាតិកុលានិ គច្ឆតុ អញ្ញំ វា ភត្តារំ បរិយេសតុ ឥច្ឆាមហំ ភោតិ អគារស្មា អនគារិយំ បព្វជិតុំ យថា ខោ បន មេ សុតំ ព្រហ្មុនោ អាមគន្ធេ ភាសមានស្ស ន តេ សុនិម្មទយា អគារំ អជ្ឈាវសតា បព្វជិស្សាមហំ ភោតិ អគារស្មា អនគារិយន្តិ ។

១ ម. ឆ. អហំ ហិ ភោ ។ ២-៣-៤ ម. ប ។ ៥ ម. តំបហំ ។ ៦ ម. វ ។





ម្នាលអ្នកដ៏ចំរើនទាំងឡាយ ឥឡូវនេះ ខ្ញុំដូចជាស្តេច របស់ស្តេចទាំងឡាយ ដូចជាព្រហ្ម របស់ព្រាហ្មណ៍ទាំងឡាយ ដូចជាទេវតា របស់គហបតីទាំងឡាយ ខ្ញុំនឹងលះបង់នូវការៈជាធំនោះទាំងអស់ ហើយចេញចាកផ្ទះទៅបួស តាមដែលខ្ញុំបានឮព្រហ្មនិយាយ អំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គល នៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ ម្នាលអ្នកដ៏ចំរើនទាំងឡាយ ខ្ញុំនឹងចេញចាកផ្ទះទៅបួស ។ ពួកព្រាហ្មណមហាសាលទាំងនោះ ឆ្លើយតបថា បើលោកគោវិន្ទព្រាហ្មណ៍ ចេញចាកផ្ទះទៅបួស យើងទាំងឡាយ នឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់អ្នក យ៉ាងណា គតិរបស់ពួកយើង ក៏យ៉ាងនោះដែរ ។ ម្នាលអ្នកដ៏-ចំរើន គ្រានោះ មហាគោវិន្ទព្រាហ្មណ៍ ចូលទៅរកភរិយាទាំង ៤០ នាក់ ដែលមានជាតិនិងត្រកូលស្មើគ្នា លុះចូលទៅដល់ហើយ បាននិយាយនឹងភរិយាទាំង ៤០ នាក់ ដែលមានជាតិនិងត្រកូលស្មើគ្នា យ៉ាងនេះថា ម្នាលនាងដ៏ចំរើន នាងណាចង់ទៅ នាងនោះចូរទៅកាន់ត្រកូលញាតិទាំង-ឡាយនៃខ្លួនចុះ ឬចូររកស្វាមីដទៃទៀតចុះ ឱនាងដ៏ចំរើន អញប្រាថ្នានឹងចេញចាកផ្ទះទៅបួស ព្រោះអញ បានឮព្រហ្មនិយាយអំពីក្លិនពុលទាំងឡាយហើយ ក្លិនពុលទាំងនោះ បុគ្គលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងលះបង់បានឡើយ ឱនាងដ៏ចំរើន អញនឹងចេញចាកផ្ទះទៅបួស ។

ត្វញ្ញេវ(១) ភោ ញាតិ ញាតិកាមានំ ភត្តា ភត្តុ-
កាមានំ សចេ ភវំ ភោ(២) គោវិន្ទោ អគារស្មា អនគា-
រិយំ បព្វជិស្សតិ មយម្បិ ភោ អគារស្មា អនគារិយំ
បព្វជិស្សាម អថ យា តេ គតិ សា នោ គតិ ភវិស្ស-
តីតិ ។ អថខោ ភោ មហាគោវិន្ទោ ព្រាហ្មណោ តស្ស
សត្តាហស្ស អច្ចយេន កេសមស្សុំ ឱហារេត្វា កាសា-
យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិ ។
បព្វជិតញ្ច បន(៣) មហាគោវិន្ទំ ព្រាហ្មណំ សត្ត ច
រាជានោ ខត្តិយា មុទ្ធាវសិត្តា សត្ត ច ព្រាហ្មណមហា-
សាលា សត្ត ច ន្ហាតកសតានិ ចត្តារីសា ច ភរិយា
សាទិសិយោ អនេកានិ ច ខត្តិយសហស្សានិ អនេ-
កានិ ច ព្រាហ្មណសហស្សានិ អនេកានិ ច គហ-
បតិសហស្សានិ អនេកា ច ឥត្ថាគារា ឥត្ថិយោ កេ-
សមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា
មហាគោវិន្ទំ ព្រាហ្មណំ អគារស្មា អនគារិយំ បព្វជិតំ

១ ឱ. ត្វំយេវ ។ ២ ឱ. ម. ភោតិ នត្ថិ ។ ៣ ម. បព្វជិតំ ខ ។



ពួកភរិយាជម្រាបថា ខ្ញុំលោកម្ចាស់ហើយជាញាតិរបស់ពួកយើងដែល
ជាអ្នកប្រាថ្នាខ្ញុំញាតិ មួយទៀត ខ្ញុំលោកម្ចាស់ហើយជាភស្តារបស់ពួក
យើងដែលជាអ្នកប្រាថ្នាខ្ញុំភស្តា បើលោកគោវិន្ទនឹងចម្រើននឹងចេញចាកផ្ទះ
ទៅបួស ពួកយើងនឹងចេញចាកផ្ទះទៅបួសដែរ បើគតិរបស់លោកយ៉ាង
ណា គតិរបស់ពួកយើងក៏យ៉ាងនោះដែរ ។ ពួកអ្នកដ៏ចម្រើន លុះកន្លង ៧ ថ្ងៃ
ទៅហើយ មហាគោវិន្ទព្រាហ្មណ៍ ក៏កោរសក់និងពុកមាត់ ហើយស្លៀក
ពាក់សំពត់កាសាយវត្ថ ចេញចាកផ្ទះទៅបួស ជាបុគ្គលគ្មានប្រយោជន៍
ដោយកិច្ចក្នុងផ្ទះ ។ ក្សត្រិយ៍ ៧ ព្រះអង្គដែលបានមុទ្ធាភិសេកហើយផង
ព្រាហ្មណមហាសាល ៧ នាក់ផង នាយហ្មត់ព្រះកេស ៧០០ នាក់
ផង ភរិយា ៤០ នាក់ ដែលមានជាតិនិងត្រកូលស្មើគ្នាផង ពួកក្សត្រ
ច្រើនពាន់ផង ពួកព្រាហ្មណ៍ច្រើនពាន់ផង ពួកគហបតីច្រើនពាន់ផង
ពួកស្រីស្នំជាច្រើនផង ស្ត្រីក្នុងប្រកត់នឹងឡាយជាច្រើនផង (បានឃើញ)
មហាគោវិន្ទព្រាហ្មណ៍ បួសរួចហើយ ក៏កោរសក់ និងពុកមាត់ស្លៀក
ពាក់សំពត់កាសាយវត្ថ ចេញចាកផ្ទះទៅបួសតាមមហាគោវិន្ទព្រាហ្មណ៍

អនុប្បត្តានីសុ ។ តាយ សុទំ ភោ បរិសាយ បរិវុតោ មហាគោវិន្ទោ ព្រាហ្មណោ គាមនិគមរាជធានីសុ ចារិកំ ចរតិ ។ យំ ខោ បន ភោ តេន សមយេន មហាគោវិន្ទោ ព្រាហ្មណោ គាមំ វា និគមំ វា ឧបសង្កមតិ តត្ថ រាជាវ ហោតិ រញ្ញំ ព្រហ្មាវ ព្រាហ្មណានំ ទេវតាវ គហបតិកានំ ។ យេ ខោ បន ភោ តេន សមយេន[១] មនុស្សា ខិបន្តិ វា ឧបក្ខលន្តិ វា តេ ឯវមាហំសុ នមត្ថុ មហាគោវិន្ទស្ស ព្រាហ្មណស្ស នមត្ថុ សត្តបុរោហិតស្សាតិ ។ មហាគោវិន្ទោ ព្រាហ្មណោ[២] មេត្តាសហគតេន ចេតសា អវេរេន អព្យាបជ្ជេន ឯកំ ទិសំ ផរិត្វា វិហាសិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហាសិ ករុណាសហគតេន ចេតសា ។ បេ ។

១ ឱ. យេ ច ខោ បន ភោ តេន សមយេន ។ ម. តេន ខោ បន សមយេន ។
២ ឱ. មហាគោវិន្ទោ ភោ ព្រាហ្មណោ ។



ដែលបួសជាបុគ្គលគ្មានប្រយោជន៍ដោយផ្ទះហើយដែរ ។ ម្នាលអ្នកដ៏ចម្រើន សេចក្តីគំណាលថា មហាគោវិន្ទព្រាហ្មណ៍ មានបរិស័ទនោះហែហមចោមរោម ត្រាច់ទៅកាន់ចារិកក្នុងស្រុក និគម និងរាជធានីទាំងឡាយ ។ ម្នាលអ្នកដ៏ចម្រើន សម័យនោះ មហាគោវិន្ទព្រាហ្មណ៍ ចូលទៅកាន់ស្រុកណា ឬនិគមណា ដូចជាស្តេចរបស់ស្តេចទាំងឡាយ ដូចជាព្រហ្មរបស់ព្រាហ្មណ៍ទាំងឡាយ ដូចជាទេវតារបស់គហបតីទាំងឡាយ ក្នុងស្រុកនោះ ឬនិគមនោះ ។ ម្នាលអ្នកដ៏ចម្រើន ក៏សម័យនោះ ពួកមនុស្សណាកណ្តាស់ ឬរអិលភ្លាត់ ពួកមនុស្សនោះ ក៏លាន់មាត់យ៉ាងនេះថា សូមនមស្ការ ចំពោះមហាគោវិន្ទព្រាហ្មណ៍ សូមនមស្ការ ចំពោះបុរោហិតទាំង ៧ ។ មហាគោវិន្ទព្រាហ្មណ៍មានចិត្តប្រកបដោយមេត្តា មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ ដល់នូវភាវៈជាធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់លោក ដែលមានសត្វទាំងអស់ ដោយយកខ្លួនឯងនឹង ទៅប្រៀបនឹងសត្វទាំងអស់ គ្រប់ទិស គឺ ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង គឺទិសតូច ៗ ក៏ដូច្នោះដែរ មានចិត្តប្រកបដោយករុណា ។ បេ ។

មុទិតាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា ។ បេ ។ សាវកានញ្ច ព្រហ្មលោកសហព្យតាយ មគ្គំ ទេសេសិ ។ យេ ខោ បន ភោ តេន សមយេន មហាគោវិន្ទស្ស ព្រាហ្មណស្ស សាវកា សព្វេន សព្វំ សាសនំ អាជានឹសុ តេ កាយស្ស ភេទា បរំ មរណា សុគតឹ ព្រហ្មលោកំ ឧបបជ្ជឹសុ ។ យេ ន សព្វេន សព្វំ សាសនំ អាជានឹសុ តេ កាយស្ស ភេទា បរំ មរណា អប្បេកច្ចេ បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អប្បេកច្ចេ និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អប្បេកច្ចេ តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អប្បេកច្ចេ យាមានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អប្បេកច្ចេ តាវត្តឹសានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ អប្បេកច្ចេ ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជឹសុ ។ យេ



មានចិត្តប្រកបដោយមុទិតា ។ បេ ។ មានចិត្តប្រកបដោយឧបេក្ខា ។ បេ ។ មិនតែប៉ុណ្ណោះ បានសំដែងផ្លូវ ដើម្បីឲ្យកើតជាមួយនឹងព្រហ្ម ក្នុងព្រហ្មលោក ដល់សាវ័កទាំងឡាយ ។ ម្នាលអ្នកដ៏ចំរើន សម័យនោះឯង ពួកសាវ័កណា របស់មហាគោវិន្ទព្រាហ្មណ៍ ដឹងច្បាស់នូវពាក្យប្រៀនប្រដៅសព្វគ្រប់ហើយ ពួកសាវ័កនោះ លុះរំលាយខន្ធ បន្ទាប់អំពីមរណកាលទៅ ក៏បានទៅកើតក្នុងសុគតិព្រហ្មលោក(១) ។ ពួកសាវ័កណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅសព្វគ្រប់ទេ ពួកសាវ័កនោះ លុះរំលាយខន្ធ បន្ទាប់អំពីមរណកាលទៅ ពួកខ្លះទៅកើតជាមួយនឹងទេវតា ជាន់បរនិម្មិតវសវត្តី(២) ពួកខ្លះទៅកើតជាមួយនឹងទេវតាជាន់និម្មានរតី ពួកខ្លះទៅកើតជាមួយនឹងទេវតា ជាន់តុសិត ពួកខ្លះទៅកើតជាមួយនឹងទេវតា ជាន់យាមៈ ពួកខ្លះទៅកើតជាមួយនឹងទេវតា ជាន់តាវត្តិង្ស ពួកខ្លះទៅកើតជាមួយនឹងទេវតា ជាន់ចាតុម្មហារាជិកៈ ។ ពួកជនណា

---

១ អដ្ឋកថា ថា ពួកមនុស្សណាញុំាងសមាបត្តិទាំង ៨ និងអភិញ្ញាទាំង ៥ ឲ្យកើតឡើងបាន ពួកមនុស្សនោះ បានទៅកើតឯព្រហ្មលោក ។ ២ អដ្ឋកថា ថា ពួកមនុស្សណាមិនដឹងច្បាស់ ពិតជាមិនអាចញុំាងសមាបត្តិទាំង ៨ សមាបត្តិណាមួយឲ្យកើតបានទេ ពួកមនុស្សនោះ ទៅកើតតែត្រឹមជាន់ទេវលោក តាំងពីជាន់បរនិម្មិតវសវត្តីចុះមកជាលំដាប់ ។

សព្វនិហីនកាយំ(១) បរិបូរេសុំ ។ តេ គន្ធព្វកាយំ បរិបូរេ-
សុំ ។ ឥតិ ខោ ភោ(២) សព្វេសំយេវ តេសំ កុល-
បុត្តានំ អមោឃា បព្វជ្ជា អហោសិ អវញ្ឈា(៣) សផលា ស-
ឧទ្រយាតិ(៤) ។ សរតិ តំ ភគវាតិ ។ សរាមហំ ភោ បញ្ច-
សិខ អហន្តេន សមយេន មហាគោវិន្ទោ ព្រាហ្មណោ
អហោសឹ អហំ តំ(៥) សាវកានំ ព្រហ្មលោកសហព្យ-
តាយ មគ្គំ ទេសេសឹ តំ ខោ បន បញ្ចសិខ ព្រហ្មចរិ-
យំ ន និព្វិទាយ ន វិរាគាយ ន និរោធាយ ន
ឧបសមាយ ន អភិញ្ញាយ ន សម្ពោធាយ ន និព្វា-
នាយ សំវត្តតិ យាវទេវ ព្រហ្មលោកុបបត្តិយា ឥទំ
ខោ បន មេ បញ្ចសិខ ព្រហ្មចរិយំ ឯកន្តនិព្វិទាយ
វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោ-
ធាយ និព្វានាយ សំវត្តតិ ។ កតមញ្ច តំ បញ្ចសិខ
ព្រហ្មចរិយំ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ

១ ឱ. យេ ឈ្មោ សព្វនិហីនកាយំ ។ ម. យេ សព្វនិហីនំ កាយំ ។ ២ ឱ. ខោ ភោ ។ ៣ អវញ្ឈាតិ វា អវញ្ឈាតិ វា បាឋោ ។ ៤ ឱ. សឧទ្រយាតិ ។ ៥ តេសំ ។



បំពេញនូវពួកដ៏ទាបជាង ជាន់ទាបជាងគេ ពួកជនទាំងនោះ ទៅកើតក្នុង
ពួកគន្ធព្វ ។ ឯបព្វជ្ជារបស់កុលបុត្រទាំងអស់នោះ មិនសោះសូន្យ មិន
ប្រកបដោយទោសទេ ប្រកបតែដោយផល ប្រកបតែដោយសេចក្តី
ចម្រើន (គឺបានកើតក្នុងព្រហ្មលោកជាដើម) ដោយប្រការដូច្នេះឯង ។
បញ្ចសិខគន្ធព្វបុត្រ ក្រាបទូលថា ព្រះមានព្រះភាគ ទ្រង់រលឹកឃើញ
ដំណើរនោះដែរឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបញ្ចសិខៈ
តថាគតរលឹកឃើញដែរថា សម័យនោះ តថាគតបានកើតជាមហាគោវិន្ទ-
ព្រាហ្មណ៍ តថាគតសម្តែងផ្លូវប្រាប់ ដើម្បីឲ្យកើតជាព្រហ្ម នាព្រហ្មលោក
នោះ ដល់ពួកសាវកទាំងឡាយ ម្នាលបញ្ចសិខៈ ឯព្រហ្មចរិយធម៌នោះ
ឯង មិនមែនប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បី
រលត់ (កិលេស) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង
ដើម្បីព្រះនិព្វាន បានទេ (គ្រាន់តែឲ្យបានទៅ)កើត ក្នុងព្រហ្មលោក
ប៉ុណ្ណោះ ម្នាលបញ្ចសិខៈ ព្រហ្មចរិយធម៌របស់តថាគតនេះឯង ទើប
ប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរលត់ (កិ-
លេស) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះ
និព្វាន តែមួយយ៉ាង ។ ម្នាលបញ្ចសិខៈ ព្រហ្មចរិយធម៌នោះ តើដូចម្តេច
ទើបប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីរលត់

ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ(១) អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ឥទំ ខោ តំ បន បញ្ចសិខ ព្រហ្មចរិយំ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ យេ ខោ បន មេ បញ្ចសិខ សាវកា សព្វេន សព្វំ សាសនំ អាជានន្តិ តេ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ យេ ន សព្វេន សព្វំ សាសនំ អាជានន្តិ តេ(២) បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ(៣) បរិក្ខយា ឱបបាតិកា ហោន្តិ តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា ។ យេ ន សព្វេន សព្វំ សាសនំ អាជានន្តិ អប្បេកច្ចេ

១ ឱ. ម. កតមញ្ច តំ បញ្ចសិខ ព្រហ្មចរិយំ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ន ទិស្សតិ ។ ២ ឱ. អប្បេកច្ចេ ។ ៣ ឱ. ម. សំយោជនានំ ។



ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន តែមួយយ៉ាង គឺផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នេះឯង ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ នោះ គឺ សេចក្ដីយល់ត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ សម្ដីត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ម្នាលបញ្ចសិខៈ នេះឯង ជាព្រហ្មចរិយៈដែលប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីរលត់ (កិលេស) ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន តែមួយយ៉ាង ។ ម្នាលបញ្ចសិខៈ ចំណែកពួកសាវ័កណា របស់តថាគត ដឹងនូវពាក្យប្រៀនប្រដៅសព្វគ្រប់ ពួកសាវ័កនោះអស់អាសវៈហើយ ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញាខ្លួនឯង ក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយអរិយាបថ ។ ពួកសាវ័កណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅដោយសព្វគ្រប់(១) ពួកសាវ័កនោះ ត្រាប់តែអស់ពួកសំយោជនៈ ជាចំណែកខាងក្រោម ៥ តែងទៅកើតជាឱបបាតិកៈកំណើត តែងបរិនិព្វានក្នុងភពនោះ មិនត្រឡប់ពីលោកនោះមកវិញ ជាធម្មតា ។ ពួកសាវ័កណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅ ដោយសព្វគ្រប់ ពួកខ្លះគ្រាន់

១ អដ្ឋកថា ថា ពួកសាវ័កណា មិនធ្វើនូវអរិយមគ្គទាំង ៤ ឲ្យកើតឡើងគ្រប់គ្រាន់បាន គ្រាន់តែឲ្យបាននូវត្រឹមអរិយមគ្គ ៣ អរិយមគ្គ ២ ឬអរិយមគ្គ១ប៉ុណ្ណោះ ។

តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ ហោន្តិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ(១) ។ យេ ច សព្វេន សព្វំ សាសនំ អាជានន្តិ អប្បេកច្ចេ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា ហោន្តិ អវិនិបាតធម្មា និយតា សម្ពោធិបរាយណា ។ ឥតិ ខោ បញ្ចសិខ សព្វេសញ្ញេវ(២) ឥមេសំ កុលបុត្តានំ អមោឃា បព្វជ្ជា អវញ្ឈា សផលា សឧទ្រយាតិ ។ ឥទមវោច ភគវា ។ អត្តមនោ បញ្ចសិខោ គន្ធព្វបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

មហាគោវិន្ទសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

១ ម. ករេន្តិ ។ ២ ម. សព្វេសំយេវ ។



នៃក្ស័យសំយោជនៈទាំង ៣ និងស្រាលស្តើងរាគៈ ទោសៈ មោហៈ ជាសកទាគាមិបុគ្គល ត្រឡប់មកកាន់កាមលោកនេះម្តងទៀត ទើបធ្វើនូវទីបំផុតទុក្ខបាន ។ ពួកសាវកណា មិនដឹងច្បាស់នូវពាក្យប្រៀនប្រដៅដោយសព្វគ្រប់ ពួកខ្លះ ព្រោះនៃក្ស័យសំយោជនៈទាំង ៣ ជាសោតាបន្នបុគ្គលមានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងនៃនឹងបានត្រាស់ដឹងនូវធម៌ខាងមុខ ។ ម្នាលបញ្ចសិខៈ បព្វជ្ជា របស់កុលបុត្រទាំងអស់គ្នានេះ មិនសោះសូន្យ មិនប្រកបដោយទោសទេ ប្រកបតែដោយផល ប្រកបតែដោយសេចក្តីចម្រើន ដោយប្រការដូច្នេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះសូត្រនេះចប់ហើយ ។ បញ្ចសិខគន្ធព្វបុត្រ ក៏ពេញចិត្ត ត្រេកអរ អនុមោទនា ចំពោះភាសិត របស់ព្រះមានព្រះភាគហើយ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ក៏បាត់អំពីទីនោះទៅ ។

ចប់ មហាគោវិន្ទសូត្រ ទី ៦ ។

# មហាសមយសុត្តំ សត្តមំ

[៧៣] ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ។ ទសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច ។ អថខោ ចតុន្នំ សុទ្ធាវាសកាយិកានំ ទេវានំ ឯតទហោសិ អយំ ខោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្វេហេវ អរហន្តេហិ ។ ទសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ទស្សនាយ ភិក្ខុសង្ឃញ្ច យន្នូន មយម្បិ យេន ភគវា តេនុបសង្កមេយ្យាម ឧបសង្កមិត្វា ភគវតោ សន្តិកេ បច្ចេកគាថំ ភាសេយ្យាមាតិ ។

# មហាសមយសូត្រ ទី ៧

[៧៣] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងមហាវ័ន(១) ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។ ទេវតាទាំងឡាយ ក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគនិងភិក្ខុសង្ឃ ។ គ្រានោះឯង ទេវតាទាំងឡាយ ដែលនៅក្នុងជាន់សុទ្ធាវាស(២) ៤អង្គ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះភាគនេះ ព្រះអង្គគង់នៅក្នុងមហាវ័ន ជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន៥០០រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។ ទេវតាទាំងឡាយ ក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគនិងភិក្ខុសង្ឃ បើដូច្នេះ គួរយើងទាំងអស់គ្នា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ គប្បីពោលនូវគាថាមួយម្នាក់ៗ ក្នុងសំណាក់នៃព្រះមានព្រះភាគ ។

---

១ ព្រៃធំ គឺព្រៃដុះឯង ជាប់ទាក់ទងគ្នាមកពីព្រៃហេមពាន្ត ។ ២ ព្រហ្មលោក៥ជាន់គឺ អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា ជាទីនៅនៃព្រះអនាគាមី និងព្រះអនាគាមី ដែលបានសម្រេចជាព្រះអរហន្តក្នុងទីនោះ ជាអ្នកបរិសុទ្ធ ហៅថា សុទ្ធាវាស ។

អថ ខោ តា ទេវតា សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ សុទ្ធាវាសេសុ ទេវេសុ អន្តរហិតា ភគវតោ បុរតោ បាតុរហំសុ(១) ។ អថ ខោ តា ទេវតា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

១ ម. បាតុរហេសុំ ។





លំដាប់នោះ ទេវតាទាំងនោះឯង ក៏បាត់អំពីសុទ្ធាវាសព្រហ្មលោក មកប្រាកដ ក្នុងទីចំពោះព្រះភក្ត្រ(១) នៃព្រះមានព្រះភាគ (ដោយឆាប់រហ័ស) ដូចជាបុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ គ្រានោះ ពួកទេវតានោះ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះទេវតាទាំងនោះឋិតនៅក្នុងទីដ៏សមគួរហើយ ទើបទេវតា ១ អង្គ ពោលនូវគាថានេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគថា

១ ក្នុងបាលីថា ពួកព្រហ្មចុះមកប្រតិស្ឋាន ចំពោះព្រះមានព្រះភាគ ។ តែក្នុងអដ្ឋកថាថា ពួកព្រហ្មទាំងនោះ ឋិតនៅក្នុងព្រហ្មលោកនូវដដែល គ្រាន់តែធ្វើឫទ្ធិ ហើយសម្រេចនូវព្រះកាយដែលខ្លួនសម្រេចហើយប៉ុណ្ណោះ គឺព្រហ្ម ១ អង្គ ចុះមកឋិតនៅក្នុងកណ្ដាប់ចក្រវាឡខាងកើត ព្រហ្ម ១ អង្គ ... ចក្រវាឡខាងត្បូង ព្រហ្ម ១ អង្គ ... ចក្រវាឡខាងលិច ព្រហ្ម ១ អង្គ ... ចក្រវាឡខាងជើង ។ ទើបព្រហ្មក្នុងចក្រវាឡខាងកើតក៏ចូលនីលកសិណ បញ្ចេញរស្មីខៀវ បីដូចជាពាក់ស្បែករលោងដោយកែវមណី ហើយបង្ហាញខ្លួនដល់ទេវតាក្នុង ១ ម៉ឺនចក្រវាឡថា ខ្លួនមកហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ឋិតនៅក្នុងទីដ៏សមគួរ ពោលនូវគាថាដែលខ្លួនគាប់ចិត្ត ។ ព្រហ្មក្នុងចក្រវាឡខាងត្បូង ក៏ចូលបីតកសិណ បញ្ចេញរស្មីមាស គន្លឹបដោយមាសសុទ្ធជាគណ្ដាប់នៃមាស បង្ហាញខ្លួនដល់ពួកទេវតាក្នុង ១ ម៉ឺនចក្រវាឡថា ខ្លួនមក ហើយឋិតនៅទីដូច្នោះដែរ ។ ព្រហ្មក្នុងចក្រវាឡខាងលិចក៏ចូលលោហិតកសិណបញ្ចេញរស្មីក្រហម បីដូចជាស្រោបកាយដោយសំពត់កម្ពលមានសម្បុរក្រហមខ្ចៅ បង្ហាញខ្លួនដល់ពួកទេវតាក្នុង ១ ម៉ឺនចក្រវាឡ ឲ្យដឹងថាខ្លួនមក ហើយឋិតនៅទីដូច្នោះដែរ ។ ព្រហ្មក្នុងចក្រវាឡខាងជើងក៏ចូលឱទាតកសិណបញ្ចេញរស្មី-ស បីដូចជាគណ្ដាប់នៃផ្កាម្លិះ បង្ហាញខ្លួនដល់ពួកទេវតាក្នុង ១ ម៉ឺនចក្រវាឡឲ្យដឹងថាខ្លួនមក ហើយឋិតនៅទីដូច្នោះដែរ ។ សរុបថា ព្រហ្មទាំងនោះមកឡើតគ្នា តែក្នុងពេលជាមួយគ្នា ។

[៧៦] មហាសមយោ បវនស្មិំ
ទេវកាយា សមាគតា
អាគតម្ហ(១) ឥមំ ធម្មសមយំ
ទក្ខិតាយេ អបរាជិតសង្ឃន្តិ ។

[៧៧] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

តត្រ ភិក្ខវោ សមាទហំសុ
ចិត្តំ អត្តនោ ឧជុកមកំសុ(២)
សារថីវ នេត្តានិ គហេត្វា
ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតា ។

[៧៨] អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

ឆេត្វា ខីលំ ឆេត្វា បលិឃំ
ឥន្ទខីលំ ឩហច្ចមនេជា

១ ម. អាគតម្ហា ។ ២ ម. ឧជុំ អកំសុ ។



(៧៦) ព្រៃនេះ ជាទីប្រជុំធំ ក្នុងវនព្រៃ ពួកទេវតាក៏មក ប្រជុំគ្នាហើយ យើងទាំងឡាយ (លុះឃើញពួកទេវតាប្រជុំគ្នាយ៉ាងនេះហើយ) ក៏នាំគ្នាមក កាន់ទីប្រជុំប្រកបដោយធម៌ នេះ ដើម្បីឃើញនូវអបរាជិតសង្ឃ គឺសង្ឃដែលមារផ្ចាញ់ មិនបាន ។

(៧៧) លំដាប់នោះ ទេវតា ១ អង្គទៀត ក៏ពោលនូវគាថានេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ថា

ពួកភិក្ខុក្នុងទីប្រជុំនោះ ប្រកបដោយសមាធិ ធ្វើចិត្តរបស់ខ្លួន (ដែលវៀចវេរ) ឲ្យជាចិត្តត្រង់ ភិក្ខុជាបណ្ឌិតទាំង-ឡាយ តែងរក្សានូវឥន្ទ្រិយ (ដោយល្អ) ដូចជានាយសារថី ដែលកាន់ចាប់នូវខ្សែប្រទុកផ្ចុះព្នាះឯង ។

(៧៨) លំដាប់នោះ ទេវតា ១ អង្គទៀត ក៏ពោលនូវគាថានេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ថា

ពួកភិក្ខុទាំងនោះ កាត់បង់នូវដែកគោល (រាគៈ ទោសៈ មោហៈ) កាត់បង់នូវរនុកទ្វារ (រាគៈ ទោសៈ មោហៈ) គាស់រំលើងនូវសសរគោល (រាគៈ ទោសៈ មោហៈ) ជាអ្នក

តេ ចរន្តិ សុទ្ធា វិមលា
ចក្ខុមតា សុទន្តា សុសុនាគា ។

(៧៧) អថខោ អបរា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ

យេ កេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ[១]
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

(៧៨) អថខោ ភគវា ភិក្ខូ អាមន្តេសិ យេភុយ្យេន ភិក្ខវេ ទសសុ លោកធាតូសុ ទេវតា សន្និបតិតា ហោន្តិ[២] តថាគតំ ទស្សនាយ ភិក្ខុសង្ឃញ្ច យេបិ តេ ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មា-សម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតបរមាយេវ ទេវតា សន្និបតិតា អហេសុំ សេយ្យថាបិ មយ្ហំ ឯតរហិ

១ អបាយន្តិ យេភុយ្យេន ទិស្សតិ ។ ២ ម. ហោន្តីតិ ទិស្សតិ ។



មិនមានគន្លាក់ជាគ្រឿងជាប់ជំពាក់ ជាអ្នកបរិសុទ្ធស្អាត ប្រាសចាកមន្ទិល ជានាគកំលោះ ដែលព្រះពុទ្ធជាម្ចាស់ ប្រកបដោយចក្ខុ ៥ ទ្រង់ទូន្មានល្អហើយ តែងត្រាច់ទៅបានក្នុងទិសទាំង ៤ មិនមានទើសទាល់ ៗ

(៧៧) លំដាប់នោះ ទេវតា ១ អង្គទៀត ក៏ពោលនូវគាថានេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ថា

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធ ជាទីពឹងទីរលឹកហើយ
ពួកជនទាំងនោះ នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះ
បង់នូវកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពួក
នៃទេវតាមិនខាន ៗ

(៧៨) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅនូវភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនអង្គ ក្នុងលោកធាតុទាំង ១០ មកប្រជុំគ្នា ដើម្បីឃើញនូវតថាគតនិងភិក្ខុសង្ឃ ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្ត សម្មាសម្ពុទ្ធ ដែលបានត្រាស់ដឹងហើយក្នុងអតីតកាល ពួកទេវតាមានប្រមាណប៉ុណ្ណេះដូចគ្នា មកប្រជុំគ្នា ដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចជាពួកទេវតា ដែលមកប្រជុំគ្នា ដើម្បីឃើញតថាគត ក្នុងកាលឥឡូវនេះដែរ

យេ តេ ភិក្ខវេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតបរមាយេវ ទេវតា សន្និបតិតា ភវិស្សន្តិ សេយ្យថាបិ មយ្ហំ ឯតរហិ ។ អាចិក្ខិស្សាមិ ភិក្ខវេ ទេវកាយានំ នាមានិ កិត្តយិស្សាមិ ភិក្ខវេ ទេវកាយានំ នាមានិ ទេសេស្សាមិ ភិក្ខវេ ទេវកាយានំ នាមានិ តំ សុណាថ សាធុកំ មនសិការោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច

(៧៩) សិលោកមនុកស្សាមិ

យត្ថ ភុម្មា តទស្សិតា

យេ សិតា គិរិគព្ភរំ

បហិតត្តា សមាហិតា ។



ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្មាសម្ពុទ្ធ នឹងបានត្រាស់ដឹងក្នុងអនាគតកាល ពួកទេវតា មានប្រមាណប៉ុណ្ណេះដូចគ្នា នឹងមកប្រជុំគ្នា ដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចពួកទេវតាដែលមកប្រជុំគ្នា ដើម្បីឃើញតថាគត ក្នុងកាលឥឡូវនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់ នូវនាមនិងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងពោល នូវនាមនិងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវនាមនិងគោត្រ របស់ពួកទេវតាទាំងឡាយ ចូរអ្នកទាំងឡាយ ប្រុងស្តាប់រឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់សំដែងនូវពាក្យនេះថា

(៧៩) តថាគតនឹងធ្វើនូវស្លោក[១] គួរទេវតា (ថ្លែងទៅ) ក្នុងទីណា ពួកភិក្ខុក៏អាស្រ័យនូវទីនោះ ពួកភិក្ខុណា ដែលនៅអាស្រ័យនឹងផ្ទៃភ្នំ បញ្ជូនចិត្តទៅកាន់អារម្មណ៍ល្អ មានចិត្តតម្កល់នឹង (តថាគតនឹងសំដែងនូវគុណនៃភិក្ខុទាំងនោះ) ។

---

១ ពាក្យដែលចំណងដោយអក្ខរៈនិងបទ ហៅថា ស្លោក ឬ គាថា ។

ពហូ សីហាវ សល្លីនា
លោមហំសាភិសម្ភុនោ
ឱទាតមនសា សុទ្ធា
វិប្បសន្នមនាវិលា ។
ភិយ្យោ បញ្ចសតេ ញត្វា
វនេ កាបិលវត្ថវេ
តតោ អាមន្តយិ សត្ថា
សាវកេ សាសនេ រតេ
ទេវកាយា អភិក្កន្តា
តេ វិជានាថ ភិក្ខវោ
តេ ច អាតប្បមការុំ
សុត្វា ពុទ្ធស្ស សាសនំ ។
តេសំ បាតុរហុ ញាណំ(១)
អមនុស្សាន ទស្សនំ
អប្បេកេ សតមទ្ទក្ខុំ
សហស្សំ អថ សត្តរី(២) ។

១ ម. សំពាតុរហុ ញាណំ ។ ម. សំបាតុភហុញ្ញាណំ ។ ២ ម. សត្តរិំ ។





ពួកភិក្ខុច្រើនរូប សម្ងំនៅក្នុងទីកម្រងឈូក គ្របសង្កត់នូវការព្រឺរោមព្រឺស្យុក (ឥតមានភ័យខ្លាច) ដូចសត្វសីហៈ មានចិត្តផូរផង់ ជាសុទ្ធ ជ្រះថ្លាឥតមានល្អក់ឡើយ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ជ្រាបនូវពួកព្រះអរហន្តចំនួន៥០០រូប (១) នៅក្នុងព្រៃជិតក្រុងកបិលវត្ថុ ទើបទ្រង់ត្រាស់ នឹងពួកភិក្ខុជាសាវ័ក ដែលត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកនៃទេវតាមានពន្លឺរស្មីដ៏រុងរឿង (មកហើយ) អ្នកទាំងឡាយ ចូរស្គាល់នូវពួកទេវតាទាំងនោះ (ដោយទិព្វចក្ខុញ្ញាណ) ចំណែកពួកភិក្ខុទាំងនោះ បានស្ដាប់នូវពាក្យប្រដៅ នៃព្រះពុទ្ធជាម្ចាស់ ហើយក៏ធ្វើនូវការព្យាយាម (ដើម្បីទិព្វចក្ខុញ្ញាណនោះ) ។ ទិព្វចក្ខុញ្ញាណ សម្រាប់មើលឃើញនូវពួកអមនុស្ស (ទេវតា) ក៏កើតមានប្រាកដ ដល់ពួកភិក្ខុទាំងនោះ ពួកភិក្ខុខ្លះ បានឃើញនូវអមនុស្ស ១០០ ខ្លះបានឃើញនូវអមនុស្ស ១.០០០ ខ្លះបានឃើញនូវអមនុស្ស ៧០ ពាន់ ។

១ អដ្ឋកថា ថា ជាង ៥០០ រូប ព្រោះរាប់ព្រះសម្មាសម្ពុទ្ធបញ្ចូលផង ។

សតំ ឯកោ សហស្សានំ
អមនុស្សានមទ្ទសំ
អប្បេកេនន្តមទ្ទក្ខុំ
ទិសា សព្វា ផុដា អហុំ(១) ។
តញ្ច សព្វំ អភិញ្ញាយ
វវត្ថិត្វាន(២) ចក្ខុមា
តតោ អាមន្តយិ សត្ថា
សាវកេ សាសនេ រតេ
ទេវកាយា អភិក្កន្តា
តេ វិជានាថ ភិក្ខវោ
យេ វោហំ កិត្តយិស្សាមិ
គិរាហិ អនុបុព្វសោ ។
សត្តសហស្សា វ យក្ខា
ភុម្មា កាបិលវត្ថវា
ឥទ្ធិមន្តោ ជុតិមន្តោ(៣)
វណ្ណវន្តោ យសស្សិនោ

១ ម. អហុ ។ ២ ឱក្កិត្វាតិ វា បាឋោ ។ ៣ ម. ជុតិមន្តោ ។ ឯវំ សព្វត្ថ ។



ពួកភិក្ខុខ្លះ បានឃើញនូវអមនុស្ស ១ សែន(១០០.០០០) ខ្លះ បានឃើញនូវអមនុស្សច្រើន (មិនមានកំណត់) អមនុស្សទាំងនោះ ក៏ផ្សាយទៅកាន់សព្វទិសទាំងពួង ។ លំដាប់នោះ ព្រះសាស្តាប្រកបដោយចក្ខុ ៥ ទ្រង់ពិចារណាហើយ ជ្រាបនូវហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់ នឹងពួកភិក្ខុជាសាវ័ក អ្នកត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាមានពន្លឺរស្មីរុងរឿង (មកហើយ) អ្នកផងគ្នា ចូរស្គាល់នូវពួកទេវតាទាំងនោះចុះ តថាគតនឹងប្រាប់ (នូវទេវតាទាំងនោះ) ដល់អ្នកផងគ្នា ដោយពាក្យតាមលំដាប់តទៅ ។

យក្សទាំង ៧ ពាន់ ជាភូមទេវតា អាស្រ័យនៅនាក្រុងកបិល-វត្ថុ មានឫទ្ធិ មានអានុភាព មានសម្បុរកាយ មានយស

មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
ឆសហស្សា ហេមវតា
យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
សាតាគិរា តិសហស្សា
យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
ឥច្ចេតេ សោឡសសហស្សា
យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ





មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំង-
ឡាយ ។ ពួកយក្ស ៦ ពាន់ ដែលកើតនៅភ្នំហិមវន្ត
មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី
មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវន ជាទី
ប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកយក្ស ៣ ពាន់ ដែលនៅ
ត្រើយនឹងភ្នំសាតាគិរៈ មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ
មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នា
មកកាន់មហាវន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកយក្ស
១៦ ពាន់នេះ មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព

វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
វេស្សាមិត្តា បញ្ចសតា
យក្ខា នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
កុម្ភីរោ រាជគហិកោ
វេបុល្លស្ស និវេសនំ
ភិយ្យោ(១) នំ សតសហស្សំ
យក្ខានំ បយិរុបាសតិ
កុម្ភីរោ រាជគហិកោ
សោបាគ សមិតឹ វនំ ។

១ ភីយោតិបិ បាឋោ ។



មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ដោយប្រការដូច្នេះ ។ ពួកយក្ស ដែលកើតនៅនាវេស្សាមិត្តបព៌ត មានសម្បុរផ្សេងៗគ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំ នៃភិក្ខុទាំងឡាយ ។ កុម្ភីរយក្ស ដែលកើតនៅនគររាជគ្រឹះ ឯភ្នំឈ្មោះវេបុល្ល ជាទីនៅរបស់កុម្ភីរយក្សនោះ មានយក្សជាង ១ សែននាក់ តែងចូលទៅសេពគប់នឹងកុម្ភីរយក្សនោះ កុម្ភីរយក្សដែលកើតក្នុងនគររាជគ្រឹះនោះ (ព្រមទាំងបរិវារ) ក៏មកកាន់មហាវ័ន ជាទីប្រជុំ (នៃភិក្ខុទាំងឡាយដែរ) ។

[៨០] បុរិមញ្ច ទិសំ រាជា
ធតរដ្ឋោ បសាសតិ
គន្ធព្វានំ អធិបតិ
មហារាជា យសស្សិ សោ ។
បុត្តាបិ តស្ស ពហវោ
ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតិំ វនំ ។
ទក្ខិណញ្ច ទិសំ រាជា
វិរូឡ្ហោ តប្បសាសតិ(១)
កុម្ភណ្ឌានំ អធិបតិ
មហារាជា យសស្សិ សោ ។
បុត្តាបិ តស្ស ពហវោ

១ ម. ឋ. តំ បសាសតិ ។





(៨០) ព្រះបាទធតរដ្ឋៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងកើត ទ្រង់ជាធំលើគន្ធព្វ(១)ទាំងឡាយ ព្រះអង្គជាមហារាជ មានយស ។ ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទធតរដ្ឋៈនោះ មានច្រើនរូប មាននាមថា ឥន្ទ្រៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ព្រះបាទវិរុឡ្ហៈ ទ្រង់ប្រៀនប្រដៅ ក្នុងទិសខាងត្បូង ជាធំលើពួកកុម្ភណ្ឌ(២) ព្រះអង្គជាមហារាជ មានយស ។ ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទវិរុឡ្ហៈនោះ មានច្រើនរូប មាននាមថា

១ ពួកទេវតាអ្នកប្រគំ ឬអ្នកលេងភ្លេង អ្នករាំ ។ ល ។ ២ ពួកទេវតាមានរូបប្រហែល ក្អមនិងពោះធំ ឬពួកមានអណ្ដុះប៉ុនក្អម ។

ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតិំ វនំ ។
បច្ឆិមញ្ច ទិសំ រាជា
វិរូបក្ខោ បសាសតិ
នាគានំ(១) អាធិបតិ
មហារាជា យសស្សិ សោ ។
បុត្តាបិ តស្ស ពហវោ
ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតិំ វនំ ។
ឧត្តរញ្ច ទិសំ រាជា
កុវេរោ តប្បសាសតិ

១ ឱ. នាគានំ ។ ម. នាគានញ្ច ។



ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ព្រះបាទវិរូបក្ខៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងលិច ទ្រង់ជាធំលើពួកនាគ ព្រះអង្គជាមហារាជមានយសធំ ។ ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទវិរូបក្ខៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំ នៃភិក្ខុទាំងឡាយ ។ ព្រះបាទកុវេរៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងជើង

យក្ខានំ អាធិបតិ
មហារាជា យសស្សិ សោ ។
បុត្តាបិ តស្ស ពហវោ
ឥន្ទនាមា មហព្វលា
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
បុរិមញ្ច ទិសំ(១) ធតរដ្ឋោ
ទក្ខិណេន វិរូឡ្ហកោ
បច្ឆិមេន វិរូបក្ខោ
កុវេរោ ឧត្តរំ ទិសំ
ចត្តារោ តេ មហារាជា
សមន្តា ចតុរោ ទិសា
ទទ្ទល្លមានា(២) អដ្ឋំសុ
វនេ កាបិលវត្ថវេ ។

១ ឱ. ម. បុរិមំ ទិសំ ។ ២ ទទ្ទល្លមានាតិបិ បាឋោ ។





នោះ ទ្រង់ជាធំលើពួកយក្ស ព្រះរាជាជាមហារាជ មានយសធំ ។ ព្រះរាជបុត្រទាំងឡាយ របស់ព្រះបាទកុវេរនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ព្រះបាទធតរដ្ឋៈ ជាធំក្នុងទិសខាងកើត ព្រះបាទវិរូឡ្ហកៈ ជាធំក្នុងទិសខាងត្បូង ព្រះបាទវិរូបក្ខៈ ជាធំក្នុងទិសខាងលិច ព្រះបាទកុវេរៈ ជាធំក្នុងទិសខាងជើង មហារាជទាំង ៤ ព្រះអង្គនោះ បានញ៉ាំងទិសទាំង ៤ ដោយជុំវិញឲ្យភ្លឺព្រោងព្រាត (ដោយរស្មីរបស់ខ្លួន) ឋិតនៅក្នុងមហាវ័ន ជិតក្រុងកបិលវត្ថុ ។

[៨១] តេសំ មាយាវិនោ ទាសា
អាគុំ វញ្ចនិកា(១) សហ
មាយា កុដេណ្ឌុ វេដេណ្ឌុ
វិដូ ច វិដុចោ(២) សហ
ចន្ទនោ កាមសេដ្ឋោ ច
កិន្នុឃណ្ឌុ និឃណ្ឌុ ច ។
បនាទោ ឱបមញ្ញោ ច
ទេវសូតោ ច មាតលិ
ចិត្តសេនោ ច គន្ធព្វោ
នឡោ រាជា ជនេសភោ
អាគុ(៣) បញ្ចសិខោ ចេវ
តិម្ពរូ សុរិយវច្ចសា ។
ឯតេ ចញ្ញេ ច រាជានោ
គន្ធព្វា សហ រាជុភិ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។

១ ឱ. អាគុ វញ្ចនិកា ។ ម. អាគុំ វញ្ចនិកា ។ ២ ឱ. វិដ្ឋូ វិដុច្ចោ ។ ម. អាគុំ ។
ម. អាគុ ។



[៨១] ពួកទាសៈ នៃមហារាជ ទាំង ៤ ព្រះអង្គនោះ គឺ កុដេណ្ឌុ ១ វេដេណ្ឌុ ១ វិដូ ១ វិដុដៈ ១ ចន្ទនៈ ១ កាមសេដ្ឋៈ ១ កិន្នុឃណ្ឌុ ១ និឃណ្ឌុ ១ សុទ្ធតែជាអ្នកមានមាយា ជាអ្នកល្បិចបញ្ឆោត ជាអ្នកអួតអាង តែងធ្វើខ្លួនមាយាមកជាមួយគ្នាដែរ ។ ទាំងទេវរាជកម្ពុលនេះ គឺបនាទៈ ១ ឱបមញ្ញៈ ១ ទេវសូត ១ មាតលិ ១ ចិត្តសេនគន្ធព្វ ១ សេនគន្ធព្វ ១ នឡរាជៈ ១ ជនេសភៈ ១ បញ្ចសិខៈ ១ តិម្ពរូ ១ នាងសុរិយវច្ចសា (ជាធីតារបស់តិម្ពរូនោះ) ១ ក៏នាំគ្នាមកដែរ ។ គន្ធព្វជាតិឯទៀតនេះផង ពួកដទៃផង ព្រមទាំងទេវរាជទាំងឡាយ មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

អថាគូ(១) នាភសា(២) នាគា

វេសាលា សហ តច្ឆកា

កម្ពលស្សតរា អាគូ

បាយាគា សហ ញាតិភិ

យាមុនា ធតរដ្ឋា ច

អាគូ នាគា យសស្សិនោ

ឯរាវណោ មហានាគោ

សោបាគា សមិតឹ វនំ ។

(៨៦) យេ នាគរាជេ សហសា ហរន្តិ

ទិព្វា ទិជា បក្ខី វិសុទ្ធចក្ខូ

វេហាយសា(៣) តេ វនមជ្ឈបត្តា

ចិត្រា សុបណ្ណា ឥតិ តេសំ នាមំ

អភយន្តទា នាគរាជានមាសិ

១ ឱ. អថាគុ ។ ម. អថាគុំ ។ ២ ឱ. តាគសោ ។ ៣ ឱ. វេហាសយា ។



មួយទៀត នាគទាំងឡាយនៅក្នុងស្រះឈ្មោះនាភសៈ និងនាគនៅក្នុងក្រុងវេសាលី ក៏នាំគ្នាមកជាមួយនឹងនាគបរិស័ទឈ្មោះតច្ឆកៈ កម្ពលនាគនិងអស្សតរនាគ (ដែលនៅតាមជើងភ្នំសិនេរុ) ក៏នាំគ្នាមក នាគទាំងឡាយនៅក្នុងទីកំពង់បយាគៈព្រមដោយពពួកញាតិ ក៏បាននាំគ្នាមកដែរ ពួកនាគដែលនៅក្នុងទន្លេយមុនាក្តី នាគដែលកើតក្នុងត្រកូលស្តេចធតរដ្ឋៈមានបរិវារដ៏ច្រើនក្តី ក៏បាននាំគ្នាមក ស្តេចឯរាវណទេវបុត្តជាដំរីធំនោះសោត ក៏បានមកកាន់មហាវ័ន ជាទីប្រជុំនៃពួកទាំងឡាយដែរ ) ។

[៨៦] ពួកគ្រុឌណា ជាសត្វស្លាបមានកំណើតដ៏ទិព្វ មានអានុភាពជាទិព្វ មានភ្នែកដ៏បរិសុទ្ធ (អាចមើលឃើញនូវពួកនាគអំពីចម្ងាយ ចំនួន ១០០ យោជន៍ ១០០០ យោជន៍) តែងចាប់យកនូវស្តេចនាគ ទៅដោយឆាប់រហ័ស គ្រុឌទាំងនោះ ក៏ហើរមកតាមអាកាស បានមកដល់ពាក់កណ្តាលនៃមហាវ័ន គ្រុឌទាំងនោះមានឈ្មោះថា ចិត្រសុបណ្ណៈ ដូច្នេះគ្រានោះ ស្តេចនាគទាំងឡាយ ក៏មិនមានសេចក្តីភ័យខ្លាច

សុបណ្ណោ ខេមមកាសិ ពុទ្ធោ
សណ្ហាហិ វាចាហិ ឧបវ្ហយន្តា
នាគា សុបណ្ណា សរណមកំសុ ពុទ្ធំ ។
ជិតា វជិរហត្ថេន
សមុទ្ទំ អសុរា សិតា
ភាតរោ វាសវស្សេតេ
ឥទ្ធិមន្តោ យសស្សិនោ ។
កាលកញ្ជា មហាភិស្មា
អសុរា ទានវេឃសា
វេបចិត្តិ សុចិត្តិ ច
បហារាទោ នមុចី សហ ។
សតញ្ច ពលិបុត្តានំ
សព្វេ វេរោចនាមកា
សន្នយ្ហិត្វា ពលឹ សេនំ
រាហុភទ្ទមុបាគមុំ
សមយោទានិ ភទ្ទន្តេ
ភិក្ខូនំ សមិតឹ វនំ ។



ឡើយ ព្រះសម្ពុទ្ធជាម្ចាស់ ក៏បានធ្វើ(ស្តេចនាគ)ឲ្យក្សេមក្សាន្តអំពីគ្រុឌ នាគនឹងគ្រុឌទាំងឡាយ ក៏ត្រឡប់និយាយរកគ្នា ដោយសម្តីដ៏ពីរោះ (ហាក់ដូចជាមិត្តសំឡាញ់នឹងគ្នា) បានធ្វើនូវព្រះពុទ្ធឲ្យជាទីពឹងទីរលឹក ។ ពួកអសុរ (ណា) ដែលព្រះឥន្ទ្រឈ្នះហើយ ក៏អាស្រ័យនៅក្នុងសមុទ្រ ពួកអសុរទាំងនោះ ជាបងប្អូន (ជាបងប្អូន) នឹងព្រះឥន្ទ្រ ជាអ្នកមានឫទ្ធិ មានយស ។ កាលកញ្ជអសុរទាំងឡាយមានកាយដ៏សម្បើមក្តី ទានវេឃសអសុរទាំងឡាយក្តី វេបចិត្តិអសុរក្តី សុចិត្តិអសុរក្តី បហារាទអសុរក្តី នមុចិទេវបុត្តមារក្តី ក៏មកជាមួយគ្នាដែរ ។ កូនរបស់ពលិអសុរទាំង ១០០ នាក់ មានឈ្មោះជាវេរោចនៈ(១) ទាំងអស់ ចងសៀតខ្សែគ្រឿងពលសេនា ចូលមកគាល់រាហុអសុរដ៏ចម្រើន ដោយពាក្យថា ឥឡូវនេះ ជាសម័យគួរនឹងប្រជុំគ្នា សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ដូច្នេះហើយ ទៅកាន់ទីនោះ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

---

១ កូនរបស់ពលិអសុរទាំងអស់ បានជាឲ្យឈ្មោះវេរោចនៈ ព្រោះឲ្យតាមនាមរបស់រាហុជាអាពុកធំ ។

[៨៣] អាបោ ច ទេវា បឋវី ច(១)
តេជោ វាយោ តទាគមុំ
វរុណា វារុណា ទេវា
សោមោ ច យសសា សហ ។
មេត្តា ករុណា កាយិកា
អាគូ ទេវា យសស្សិនោ
ទសេតេ ទសធា កាយា
សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតី វនំ ។
វេណ្ហូ(២) ច ទេវា សហលី ច
អសមា ច ទុវេ យមា
ចន្ទស្សូបនិសា ទេវា

១ ម. ឱ. បោត្ថកេសុ នត្ថិ ។ ២ ម. វេណ្ឌូ ច ។ ឱ. វេណ្ឌុ ។ បោត្ថកេ ន វិញ្ញាយតិ ។





[៨៣] អាបោទេវតា(១)ក្តី បឋវីទេវតា(២)ក្តី តេជោទេវតា(៣)ក្តី វាយោទេវតា(៤)ក្តី វរុណទេវតាក្តី វារុណទេវតាក្តី សោមទេវតា ព្រមទាំងយសទេវតាក្តី ក៏បាននាំគ្នាមក គឺកាលនោះ ។ ទេវតាទាំងឡាយ ដែលកើតដោយអំណាចមេត្តាឈាន និងករុណាឈាន ជាអ្នកមានយស ក៏បាននាំគ្នាមក ទេវតាទាំង ១០ ពួកនេះ មិនទៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗគ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកទេវតា ឈ្មោះវេណ្ឌុក្តី ឈ្មោះសហលីក្តី ឈ្មោះអសមាក្តី និងឈ្មោះយមៈទាំងពីរពួកក្តី ពួកទេវតា ដែលអាស្រ័យនូវព្រះចន្ទក្តី

១ ទេវតាកើតដោយការបរិកម្មអាបោកសិណ ។ ២ ទេវតាកើតដោយការបរិកម្មនូវបឋវីកសិណ ។ ៣ ទេវតាកើតដោយការបរិកម្មនូវតេជោកសិណ ។ ៤ ទេវតាកើតដោយការបរិកម្មនូវវាយោកសិណ ។

ចន្ទមាគូ បុរក្ខតា ។
សុរិយស្សូបនិសា ទេវា
សុរិយមាគូ បុរក្ខតា
នក្ខត្តានិ បុរក្ខិត្វា
អាគូ មន្ទវលាហកា
វសូនំ វាសវោ សេដ្ឋោ
សក្កោ ទាគ(១) បុរិន្ទទោ ។
ទសេតេ ទសធា កាយា
សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
អថាគូ សហភូ ទេវា
ជលមគ្គិសិខារិវ
អរិដ្ឋកា ច រោជា ច
ឧមាបុប្ផនិភាសិនោ

១ ម. បាគា ។





បាននាំហែហមព្រះចន្ទមកដែរ ។ ពួកទេវតាដែលអាស្រ័យនូវព្រះអាទិត្យ បាននាំហែហមព្រះអាទិត្យមក ពួកទេវតាដែលអាស្រ័យនូវផ្កាយ ក៏ហែហមផ្កាយមក ទាំងមន្ទវលាហកទេវតា(១) ទាំងឡាយក៏មក សូម្បីសក្កទេវរាជ ទ្រង់ព្រះនាមវា-សវបុរិន្ទទៈដ៏ប្រសើរជាងពួកទេវតា ក៏មកដែរ ។ ទេវតាទាំង ១០ ពួកនេះ មិនទៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ មួយទៀត ទេវតាទាំងឡាយឈ្មោះសហភូដ៏រុងរឿង បីដូចជាអណ្ដាតភ្លើង ក៏បានមក ពួកទេវតាឈ្មោះអរិដ្ឋកៈក្ដី រោជៈក្ដី ឧមាបុប្ផនិភាសៈ(២)ក្ដី

---

១ អដ្ឋកថា ថា មន្ទវលាហកទេវតា ចែកចេញ ជា ៣ ពួក គឺ វាតវលាហកៈ ទេវតាជាអ្នកបណ្ដាលខ្យល់ ១ អព្ភវលាហកៈ ទេវតាជាអ្នកបណ្ដាលពពក ១ ឧណ្ហវលាហកៈ ទេវតាជាអ្នកបណ្ដាលកម្ដៅ ១ ។ ២ ទេវតាមានរស្មីដូចផ្កាកប្បាស ។

មហាសមយសុត្តំ ទេវតាយានំ គាថា

វេណ្ហុ សហលិ ច
អច្ចុតា ច អនេជកា
សូលេយ្យរុចិរា អាគុំ
អាគុំ វាសវនេសិនោ ។
ឆ សេតេ ទេវនិកាយា
សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតិំ វនំ ។
សមានា មហាសមានា
មានុសា មានុសុត្តមា
ខិឌ្ឌាបទូសិកា អាគុំ
អាគុំ មនោបទូសិកា
អថាគុំ ហរយោ ទេវា
យេ ច លោហិតវាសិនោ
បារគា មហាបារគា



មហាសមយសូត្រ ឈ្មោះនៃពួកទេវតា

វេណ្ហុកៈក្តី សហលិកៈក្តី អច្ចុតកៈក្តី អនេជកៈក្តី សូលេយ្យៈ
ក្តី រុចិរៈក្តី ក៏បានមក តាំងពួកទេវតាឈ្មោះវាសវនេសី
ក៏បានមក ។ ទេវតា ទាំង ១០ ពួកនេះ បីកនៅដោយ
ចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មាន
ឫទ្ធិ មានតេជានុភាព មានរស្មី មានយស មានចិត្ត
រីករាយ ក៏នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំ នៃភិក្ខុទាំង
ឡាយ ។ ទេវតាទាំងឡាយ ឈ្មោះសមានៈក្តី មហា-
សមានៈក្តី មានុសៈក្តី មានុសុត្តមៈក្តី ខិឌ្ឌាបទូសិកៈក្តី
ក៏បានមក ពួកទេវតា ឈ្មោះមនោបទូសិកៈ ក៏បានមក
តាំងពួកទេវតាឈ្មោះហរិក្តី ឈ្មោះលោហិតវាសីក្តី ក៏បាន
មក ទេវតាទាំងឡាយ ឈ្មោះបារគៈក្តី ឈ្មោះមហាបារគៈក្តី

អាគូ ទេវា យសស្សិនោ ។
ទសេតេ ទសធា កាយា
សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
សុក្កា ករម្ភា អរុណា
អាគូ វេឃនសា សហ ។
ឱទាតគយ្ហា បាមោក្ខា
អាគូ ទេវា វិចក្ខណា
សទាមត្តា ហារគជា
មិស្សកា ច យសស្សិនោ
ថនយំ អាគ បជ្ជុន្នោ
យោ ទិសា អភិវស្សតិ ។
ទសេតេ ទសធា កាយា
សព្វេ នានត្តវណ្ណិនោ



ជាអ្នកមានយសក៏បានមក ។ ទេវតាទាំង ១០ ពួកនេះ បែកចេញជាចំណែក ១០ សុទ្ធតែមានសម្បុរផ្សេង ៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ទេវតាទាំងឡាយ ឈ្មោះសុក្កៈក្តី ករម្ភៈក្តី អរុណៈក្តី ក៏បានមកជាមួយនឹងវេឃនទេវតា ។ ពួកទេវតាឈ្មោះឱទាតគយ្ហៈជាប្រធានក្តី ឈ្មោះវិចក្ខណៈក្តី ក៏បានមក ពួកទេវតាឈ្មោះសទាមត្តៈក្តី ឈ្មោះហារគជៈក្តី ឈ្មោះមិស្សកៈក្តី សុទ្ធតែជាអ្នកមានយស (ក៏បានមក) បជ្ជុន្នទេវរាជ ដែលញុំាងមេឃឲ្យគ្រហឹម ក្តួរ ហើយបង្អុរភ្លៀង ឲ្យធ្លាក់ចុះគ្រប់ទិស ក៏បានមក ។ ទេវតាទាំង ១០ ពួកនេះ បែកចេញជាចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗគ្នាទាំងអស់ មានឫទ្ធិ

មហាសមយសុត្តំ ទេវកាយានំ នាមានិ

ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
ខេមិយា តុសិតា យាមា
កដ្ឋកា ច យសស្សិនោ
លម្ពិតកា លាមសេដ្ឋា
ជោតិនាមា ច អាសវា
និម្មានរតិនោ អាគុំ
អថាគូ បរនិម្មិតា ។
ឥមេ ទសធា កាយា
សព្វេ នានត្តវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ
វណ្ណវន្តោ យសស្សិនោ
មោទមានា អភិក្កាមុំ
ភិក្ខូនំ សមិតឹ វនំ ។
សដ្ឋេតេ ទេវនិកាយា

១៨៧

មហាសមយសូត្រ ឈ្មោះនៃពួកទេវតា

មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាន នាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំងឡាយ ។ ពួកខេមិយទេវតា ដែលកើតនៅក្នុងតុសិតបុរក្តី ពួកទេវតាក្នុងយាម-ទេវលោកក្តី ពួកកដ្ឋកទេវតាដែលមានយសក្តី ពួកលម្ពិតក-ទេវតាក្តី ពួកលាមសេដ្ឋទេវតាក្តី ពួកទេវតាឈ្មោះជោតិក្តី ឈ្មោះអាសវៈក្តី ពួកនិម្មានរតីទេវតាក្តី ក៏បានមក ទាំងពួកបរនិម្មិតទេវតា ក៏បានមក ។ ទេវតាទាំង ១០ ពួកនេះ ចែកទៅជាចំណែក ១០ សុទ្ធតែមានសម្បុរផ្សេង ៗ គ្នា ទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មាន ចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវ័ន ជាទីប្រជុំនៃភិក្ខុទាំង-ឡាយ ។ ពួកទេវតាទាំង ៦០ មានអាបោទេវតាជាដើមនេះ

សព្វេ នានត្តវណ្ណិនោ
នាមន្វយេន អាគញ្ឆុំ
យេ ចញ្ញេ សមនា សហ
បវុដ្ឋជាតិមខីលំ
ឱឃតិណ្ណមនាសវំ
ទក្ខេមោឃតរំ នាគំ
ចន្ទំវ អសិតាតិគំ(១) ។

(៨៤) សុព្រហ្មា បរមត្តោ ច
បុត្តា ឥទ្ធិមតោ សហ
សនង្កុមារោ តិស្សោ ច
សោបាគ សមិតី វនំ ។
សហស្សព្រហ្មលោកានំ
មហាព្រហ្មាភិតិដ្ឋតិ
ឧបបន្នោ ជុតិមន្តោ
ភិស្មាកាយោ យសស្សិ សោ
ទសេត្ថ ឥស្សរា អាគូ

១ អសិតាតិគន្តិ ក ជាយោ ។





សុទ្ធតែមានសម្បុរផ្សេង ៗ គ្នាទាំងអស់ មកហើយដោយ ចំណែកនាម សូម្បីពួកទេវតាណាក្រៅពីនោះ ដែលមាន ស្មើប្រហែលគ្នា ក៏មកព្រមគ្នាដោយគិតថា យើងទាំងឡាយ នឹងទៅមើលព្រះអរិយសង្ឃ ដែលប្រាសចាកជាតិ ឥតមាន កិលេស ដូចជាដែកគោល លោកឆ្លងចាកឱឃទាំង ៤ ហើយ មិនមានកិលេសជាគ្រឿងត្រាំ រួចស្រឡះចាកឱឃៈ ទាំង ៤ ហើយ លោកមិនបានធ្វើនូវបាប មួយទៀតយើង នឹងបានឃើញនូវព្រះទសពល ដែលរុងរឿងដោយសារ ដូច ព្រះចន្ទរួចផុតពីពពក ។

(៨៤) ឯពួកព្រហ្មទាំងឡាយ គឺ សុព្រហ្ម និងបរមត្តព្រហ្ម ជាបុត្ររបស់ព្រហ្មសម្ពុទ្ធ ទ្រង់មានឫទ្ធិ ក៏មកជាមួយគ្នា សនង្កុមារមហាព្រហ្ម តិស្សមហាព្រហ្ម ក៏នាំគ្នាមកកាន់ មហាវ័ន ជាទីប្រជុំនៃពួកទាំងឡាយ ។ មហាព្រហ្មទាំង ១ ពាន់ ក៏មកហើយ មហាព្រហ្ម ១ អង្គ គ្របសង្កត់នូវព្រហ្ម ឯទៀតបាន មហាព្រហ្មនោះ កើតក្នុងព្រហ្មលោក មាន អានុភាព មានកាយសម្បូរ មានយស ក៏មកដែរ ។ មហា-ព្រហ្មទាំង ១០ ជាឥស្សរៈលើព្រហ្មទាំង ១ ពាន់នេះ តែង

បច្ចេកវសវត្តិនោ
តេសញ្ច មជ្ឈតោ អាគា(១)
ហារិតោ បរិវារិតោ ។
តេ ច សព្វេ អភិក្កន្តេ
សិន្ទេ ទេវេ(២) សព្រហ្មកេ
មារសេនា អភិក្កាមិ
បស្ស កណ្ហស្ស មន្ទិយំ ។
ឯថ គណ្ហថ ពន្ធថ
រាគេន ពទ្ធមត្ថុ វោ(៣)
សមន្តា បរិវារេថ
មា វោ មុញ្ចិត្ថ កោចិ នំ ។
ឥតិ តត្ថ មហាសេនោ
កណ្ហោ សេនំ(៤) អបេសយិ
បាណិនា តលមាហច្ច
សរំ កត្វាន ភេរវំ
យថា បាវុស្សកោ មេឃោ

១ បាឡិយា អាគូតិ បាឋោ ទិស្សតិ ។ ២. ម. សឥន្ទេទេវេ ។ ឱ. សឥន្ទេ ទេវេ ។ ៣ ម. វេ ។ ៤ ម. កណ្ហសេនំ ។





ផ្ទាយអំណាចផ្សេងៗ ក៏បានមក ហារិតមហាព្រហ្ម (ដែលមានព្រហ្មចំនួន ១ សែន) ហែហមក្នុងកណ្តាលនៃពួកព្រហ្មទាំងនោះ ក៏បានមក ។ សេនារបស់មារបានឃើញនូវពួកទេវតា ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្មទាំងអស់នោះ មកជួបជុំហើយ ក៏បានមក ហើយពោលថា អ្នកទាំងឡាយចូរមើលនូវសេចក្តីល្ងង់នៃមារ ។ (តែសេនារបស់មារក៏ពោលថា) អ្នកទាំងឡាយចូរមក ចូរចាប់ចងពួកទេវតាទាំងនេះទុកដោយចំណងគឺរាគៈ ចូរមានដល់អ្នកទាំងឡាយ(១) អ្នកទាំង-ឡាយ ចូរព័ទ្ធឡោមព័ទ្ធ បណ្តាអ្នកទាំងអស់គ្នា អ្នកណាមួយកុំបណ្តោយឲ្យទេវតា ១ អង្គរួចទៅបានឡើយ ។ មារជាសេនាធំក្នុងទីប្រជុំនោះ ក៏ទះនូវផ្ទៃផែនដីដោយបាតដៃធ្វើនូវសំឡេងគួរខ្លាច ដូចជាមហាមេឃ គ្រហឹម

១ អដ្ឋកថា ថា បណ្តោលនៃទេវតាទាំងអស់នេះ ជាប់ដោយរាគៈ ចូរមានដល់អ្នកទាំងឡាយ បានសេចក្តីថា មារសេនាបង្គាប់បរិស័ទ ឲ្យចងទេវមណ្ឌល ក៏ពួកទេវតាទាំងអស់ឲ្យជាប់ដោយរាគៈ ។

ថនយន្តោ សវិជ្ជុកោ
តទា សោ បច្ចុទាវត្តិ
សង្កុទ្ធោ អសយំ វសេ(១) ។
តញ្ច សព្វំ អភិញ្ញាយ
វវត្ថិត្វាន ចក្ខុមា
តតោ អាមន្តយិ សត្ថា
សាវកេ សាសនេ រតេ
មារសេនា អភិក្កន្តា
តេ វិជានាថ ភិក្ខវោ
តេ ច អាតប្បមករុំ
សុត្វា ពុទ្ធស្ស សាសនំ ។
វីតរាគេហិ បក្កាមុំ
នេសំ លោមម្បិ(២) ឥញ្ជយុំ
សព្វេ វិជិតសង្គាមា
ភយាតីតា យសស្សិនោ
មោទន្តិ សហ ភូតេហិ
សាវកា តេ ជនេសុតាតិ ។

មហាសមយសុត្តំ សត្តមំ និដ្ឋិតំ ។

១ ម. វសី ។ ២ ម. នេសំ លោមាបិ ។





បន្លឺរគ្រឹមមានផ្លេកបន្ទោរ ក្នុងកាលនោះ មារនោះមិនអាចនឹងធ្វើ (ទេវតាណាមួយ) ឲ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនបាន ក៏ក្រេវក្រោធថយចេញបាត់ទៅ ។ លំដាប់នោះ ព្រះសាស្តា ទ្រង់មានចក្ខុពិចារណាហើយ ជ្រាបហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់នឹងភិក្ខុជាសាវ័កទាំងឡាយ ដែលត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកមារសេនាមកដល់ហើយ អ្នកទាំងឡាយ ចូរស្គាល់នូវមារសេនាទាំងនោះចុះ ពួកភិក្ខុទាំងនោះ លុះបានស្តាប់ពាក្យប្រដៅព្រះពុទ្ធ ជាម្ចាស់ហើយ ក៏ធ្វើព្យាយាម(ដើម្បីចូលកាន់ផលសមាបត្តិ) ។ មារព្រមទាំងពួកសេនារបស់មារ ក៏ចៀសចេញឆ្ងាយទៅ អំពីពួកអរិយសាវ័កដែលប្រាសចាករាគៈ សូម្បីតែរោមរបស់ព្រះអរិយៈទាំងនោះ ក៏មិនបានញាប់ញ័រឡើយ (ទើបមារពោលសរសើរភិក្ខុសង្ឃថា) ពួកសាវ័កទាំងនោះ ឈ្នះសង្គ្រាមហើយ កន្លងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយសល្បីខ្ទរខ្ទារទៅក្នុងប្រជុំជន តែងរីករាយ ជាមួយនឹងព្រះអរិយៈដែលកើតហើយ (ក្នុងសាសនាព្រះទសពល) ។

ចប់ មហាសមយសូត្រ ទី ៧ ។

## សក្កបញ្ហសុត្តំ អដ្ឋមំ

(៨៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ វិហរតិ បាចីនតោ រាជគហស្ស អម្ពសណ្ឌា នាម ព្រាហ្មណគ្គាមោ តស្សុត្តរតោ វេទិយកេ បព្វតេ ឥន្ទសាលគុហាយំ ។ តេន ខោ បន សមយេន សក្កស្ស ទេវានមិន្ទស្ស ឧស្សុក្កំ ឧទបាទិ ភគវន្តំ ទស្សនាយ ។ អថ ខោ សក្កស្ស ទេវានមិន្ទស្ស ឯតទហោសិ កហំ នុ ខោ ភគវា ឯតរហិ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។ អទ្ទសា ខោ សក្កោ ទេវានមិន្ទោ ភគវន្តំ មគធេសុ វិហរន្តំ បាចីនតោ រាជគហស្ស អម្ពសណ្ឌា នាម ព្រាហ្មណគ្គាមោ តស្សុត្តរតោ វេទិយកេ បព្វតេ ឥន្ទសាលគុហាយំ ទិស្វាន ទេវេ តាវតឹសេ អាមន្តេសិ

## សក្កបញ្ហសូត្រ ទី ៨

(៨៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា(១) ជិតភ្នំវេទិយកៈ (តាំងនៅ) ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ។ ក៏សម័យនោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា មានសេចក្តីខ្វល់ខ្វាយកើតឡើង ដើម្បីនឹងទៅគាល់ព្រះមានព្រះភាគ ។ វេលានោះឯង សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ព្រិះរិះក្នុងព្រះទ័យថា ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់គង់នៅក្នុងទីណាហ្ន៎ ។ សក្កទេវរាជជាធំជាងពួកទេវតា បានទតឃើញព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយកៈ ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ លុះឃើញហើយ ក៏ត្រាស់ហៅពួកទេវតា ដែលនៅក្នុងឋានតាវត្តិង្សមក

១ គុហាមានដើមពោធិ៍ដុះក្បែរមាត់ទ្វារ ។

អយំ មារិសា ភគវា មគធេសុ វិហរតិ បាចីនតោ រាជគហស្ស អម្ពសណ្ឌា នាម ព្រាហ្មណគាមោ តស្សុត្តរតោ វេទិយកេ បព្វតេ ឥន្ទសាលគុហាយំ យន្នូន មយំ មារិសា តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យាម អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯវំ ភទ្ទន្តវាតិ ខោ ទេវា តាវតឹសា សក្កស្ស ទេវានមិន្ទស្ស បច្ចស្សោសុំ ។ អថខោ សក្កោ ទេវានមិន្ទោ បញ្ចសិខំ គន្ធព្វបុត្តំ(១) អាមន្តេសិ អយំ តាត បញ្ចសិខ ភគវា មគធេសុ វិហរតិ បាចីនតោ រាជគហស្ស អម្ពសណ្ឌា នាម ព្រាហ្មណគាមោ តស្សុត្តរតោ វេទិយកេ បព្វតេ ឥន្ទសាលគុហាយំ យន្នូន មយំ(២) តាត បញ្ចសិខ មយំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យាម អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯវំ ភទ្ទន្តវាតិ ខោ បញ្ចសិខោ គន្ធព្វបុត្តោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា ពេលុវបណ្ឌុវីណំ អាទាយ សក្កស្ស ទេវានមិន្ទស្ស អនុចរិយំ ឧបាគមិ ។ អថខោ សក្កោ ទេវានមិន្ទោ

១ ម. គន្ធព្វទេវបុត្តំ ។ ២ ឱ. ម. យទិ មយំ ។



ក្រាបថា ម្នាលគ្នាយើងទាំងឡាយ ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់អង្គនេះ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយកៈ ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ម្នាលគ្នាយើងទាំងឡាយ បើដូច្នោះ គួរយើងទាំងអស់គ្នា ចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ។ ពួកទេវតាដែលកើតនៅក្នុងឋានតាវត្តិង្ស ក៏ទទួលព្រះរាជឱង្ការ នៃសក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ។ លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ទ្រង់ត្រាស់ហៅបញ្ចសិខគន្ធព្វបុត្តថា ម្នាលអ្នកបញ្ចសិខៈ ឥឡូវនេះ ព្រះមានព្រះភាគអង្គនេះ ទ្រង់គង់នៅក្នុងឥន្ទសាលគុហា ជិតភ្នំវេទិយកៈ ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ម្នាលអ្នកបញ្ចសិខៈ បើដូច្នោះ គួរយើងចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ បញ្ចសិខគន្ធព្វបុត្ត ក៏ទទួលព្រះរាជឱង្ការនៃសក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ ហើយក៏កាន់ពិណ មានសម្បុរលឿងដូចផ្លែព្នៅទុំ ដើរតាមក្រោយនៃសក្កទេវរាជ ជាធំជាងពួកទេវតា ។ ក្នុងខណៈនោះឯង សក្កទេវរាជជាធំជាងពួកទេវតា មានពួកទេវតាដែលកើត

ទេវេហិ តាវត្តិំសេហិ បរិវុតោ បញ្ចសិខេន គន្ធព្វបុត្តេន បុរក្ខតោ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ខោ[1] ទេវេសុ តាវត្តិំសេសុ អន្តរហិតោ មគធេសុ បាចីនតោ រាជគហស្ស អម្ពសណ្ឌា នាម ព្រាហ្មណគ្គាមោ តស្សុត្តរតោ វេទិយកេ បព្វតេ បច្ចុដ្ឋាសិ ។ តេន ខោ បន សមយេន វេទិយកោ បព្វតោ អតិវិយ ឱភាសជាតោ ហោតិ អម្ពសណ្ឌា ច ព្រាហ្មណគ្គាមោ យថា តំ ទេវានំ ទេវានុភាវេន ។ អបិស្សុទំ បរិតោ គាមេសុ មនុស្សា ឯវមាហំសុ អាទិត្តស្សុ នាមជ្ជ វេទិយកោ បព្វតោ ឈាយតិស្សុ នាមជ្ជ វេទិយកោ បព្វតោ ជលតិស្សុ នាមជ្ជ វេទិយកោ បព្វតោ កឹ សុ នាមជ្ជ វេទិយកោ បព្វតោ អតិវិយ ឱភាសជាតោ អម្ពសណ្ឌា ច ព្រាហ្មណគ្គាមោតិ ។ សំវិគ្គា លោមហដ្ឋជាតា អហេសុំ ។ អថ ខោ សក្កោ ទេវានមិន្ទោ បញ្ចសិខំ គន្ធព្វបុត្តំ

១ ម. ឯវមេវ ។



ទេវតាក្នុងជាន់តាវត្តិង្សហោមរោមហែហម មានបញ្ចសិខគន្ធព្វបុត្តជាអ្នកនាំមុខ ក៏បាត់អំពីពួកទេវតា ដែលឋិតនៅក្នុងឋានតាវត្តិង្ស មកប្រាកដស្ថាននៅលើភ្នំវេទិយកៈ ជាខាងកើតនៃក្រុងរាជគ្រឹះ ជាខាងជើងនៃព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក្នុងដែនមគធៈ ([illegible]) ប្រៀបដូចបុរសមានកម្លាំងលាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលលាចេញដូច្នោះឯង ។ ក្នុងសម័យនោះឯង ភ្នំវេទិយកៈ និងព្រាហ្មណគ្រាម ឈ្មោះអម្ពសណ្ឌៈ ក៏មានរស្មីភ្លឺព្រោងព្រាត ដោយទេវានុភាពនៃពួកទេវតា ។ បានឮថា ពួកមនុស្សក្នុងស្រុកជិតខាងនិយាយគ្នាយ៉ាងនេះថា ថ្ងៃនេះ ភ្នំវេទិយកៈឆេះឡើង ថ្ងៃនេះ ភ្លើងឆេះភ្នំវេទិយកៈ ថ្ងៃនេះ ភ្នំវេទិយកៈ ភ្លឺព្រោងព្រាត ភ្នំវេទិយកៈ និងព្រាហ្មណគ្រាមឈ្មោះអម្ពសណ្ឌៈ ហេតុអ្វីបានជាមានពន្លឺភ្លឺក្រៃពេកក្នុងថ្ងៃនេះ ។ ពួកមនុស្សទាំងនោះ ក៏មានសេចក្ដីតក់ស្លុតព្រឺរោម ។ គ្រានោះ សក្កទេវរាជ ជាធំជាងពួកទេវតា ត្រាស់ហៅបញ្ចសិខ-

អាមន្តេសិ ទុរុបសង្កមា ខោ តាត បញ្ចសិខ តថាគតា មាទិសេន ឈាយី ឈានរតា តទន្តរំ បដិសល្លីនា យទិ បន ត្វំ តាត(១) បញ្ចសិខ ភគវន្តំ បឋមំ បសាទេយ្យាសិ តយា តាត បឋមំ បសាទិតំ បច្ឆា មយំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យាម អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ ឯវំ ភទ្ទន្តវាតិ ខោ បញ្ចសិខោ គន្ធព្វបុត្តោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា វេឡុវបណ្ឌុវីណំ អាទាយ យេន ឥន្ទសាលគុហា តេនុបសង្កមិ ឧបសង្កមិត្វា ឯត្តាវតា មេ ភគវា នេវ អតិទូរេ ខោ ភវិស្សតិ(២) នាច្ចាសន្នេ សទ្ទញ្ច មេ(៣) សោស្សតីតិ ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ បញ្ចសិខោ គន្ធព្វបុត្តោ វេឡុវបណ្ឌុវីណំ អាទាយ អស្សាវេសិ ឥមា ច គាថា អភាសិ ពុទ្ធូបសញ្ហិតា ធម្មូបសញ្ហិតា សង្ឃូបសញ្ហិតា អរហន្តូបសញ្ហិតា កាមូបសញ្ហិតា

---

១ ម. បឋមំ តាត ។ ២ ម. ម. អតិទូរេ ភវិស្សតិ ។ ៣ ម. ន អច្ចាសន្នេ សទ្ទញ្ច ខោ ។



គន្ធព្វបុត្តថា ម្នាលអ្នកបញ្ចសិខៈ ព្រះតថាគតទាំងឡាយ ព្រះអង្គមានឈាន ត្រេកអរក្នុងឈាន ព្រះអង្គសម្ងំនៅដោយកម្មដ្ឋានបាទក្ខម ។ (ព្រោះហេតុនោះ) ក្ដារ ដូចយ៉ាងយើង ដែលជាអ្នកមានរាគៈ ទោសៈ មោហៈ នឹងចូលទៅគាល់បានដោយលំបាក ម្នាលអ្នកបញ្ចសិខៈ បើដូច្នោះ អ្នកធ្វើឲ្យព្រះមានព្រះភាគពេញព្រះហឫទ័យ (បើកឱកាស ឲ្យ) ជាមុនសិន ម្នាលអ្នក បើអ្នក បានធ្វើឲ្យព្រះអង្គពេញព្រះហឫទ័យជាមុនហើយ សឹមយើងទាំងឡាយចូលទៅគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ក្នុងកាលជាខាងក្រោយ ។ បញ្ចសិខគន្ធព្វបុត្ត ទទួលព្រះឱង្ការរបស់សក្កទេវរាជ ជាធំជាងពួកទេវតាថា ព្រះករុណាថ្លៃវិសេស សេចក្ដីចម្រើនចូរមានដល់ព្រះអង្គ ហើយក៏កាន់នូវពិណមានសម្បុរលឿងដូចផ្លែព្នៅទុំ ចូលសំដៅទៅត្រង់ឥន្ទសាលគុហា លុះចូលទៅដល់ហើយ ក៏ឋិតនៅក្នុងទីសមគួរ ដោយគិតថា ទីត្រឹមប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់នៅ មិនឆ្ងាយពេក មិនជិតពេកអំពីអញ ទាំងព្រះអង្គក៏ទ្រង់ឮសំឡេងអញបានផង ។ លុះបញ្ចសិខគន្ធព្វបុត្ត ឋិតនៅក្នុងទីសមគួរហើយ ក៏ចាប់ដេញពិណមានសម្បុរលឿងដូចជាផ្លែព្នៅទុំ ហើយច្រៀងនូវគាថាទាំងនេះ ដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត ព្រមទាំងប្រកបដោយកាម ថា

[៨២] វន្ទេ តេ បិតរំ ភទ្ទេ
តិម្ពរុំ សុរិយវច្ឆសេ
យេន ជាតាសិ កល្យាណី
អានន្ទជននី មម ។
វាតោវ សេទតំ កន្តោ
បានីយំវ បិបាសតោ(១)
អង្គីរសី បិយា មេសិ
ធម្មោ អរហតំ វិយ(២) ។
អាតុរស្សេវ ភេសជ្ជំ
ភោជនំវ ជិឃច្ឆតោ
បរិនិព្វាបយ(៣) ភទ្ទេ
ជលន្តមិវ វារិនា ។
សីតោទកំ(៤) បោក្ខរណឹ
យុត្តំ កិញ្ជក្ខរេណុនា

១ ម. បិបាសិតោ ។ ២ ម. ឱ. អរហតាមិវ ។ ៣ ឱ. បរិនិព្វាបយ ។ ម. បរិនិព្វុបយ មំ ។ ៤ ម. សីតោទកំ ។





(៨២) ម្នាលនាងសុរិយវច្ឆសា(១) ដ៏ចម្រើន បងសូមថ្វាយបង្គំ ឪពុកនៃនាងព្រះនាមតិម្ពរុ ជាបិតារបស់នាង ដោយហេតុដែលនាងកើតមកហើយ មានលម្អជាទីញុំាងសេចក្ដីត្រេកអរឲ្យកើតដល់បង ។ ដូចខ្យល់ជាទីត្រេកអរ របស់បុគ្គលអ្នកមានញើស ក៏ដូចទឹកសម្រាប់ផឹក ជាទីត្រេកអរ របស់បុគ្គលអ្នកស្រេកទឹក នាងមានរស្មីស្មើនឹងអង្គីរសៈ ជាទីស្រឡាញ់ពេញចិត្តនៃបង ដូចនៃលោកុត្តរធម៌ ជាទីស្រឡាញ់ របស់ពួកព្រះអរហន្តទាំងឡាយ ។ ម្នាលនាងដ៏ចម្រើន ចូរនាងជួយរលត់ (សេចក្ដីក្ដៅក្រហាយរបស់បង) ចេញ ដូចគេដាក់ថ្នាំដល់អ្នកជំងឺ ក៏ដូចគេឲ្យភោជនដល់អ្នកកំពុងឃ្លាន ក៏ដូចគេរលត់ភ្លើងកំពុងឆេះដោយទឹក ។ សូមឲ្យបងបានបៀតបៀនបញ្ជ្រាំងដោះស្ដន ដ៏និទ្ធរបស់នាង ដូចដំរីមានសេចក្ដីក្ដៅក្រហាយ ក្នុងថ្ងៃក្ដៅ បានចុះកាន់ស្រះបោក្ខរណីមានទឹកដ៏ត្រជាក់ ប្រកបដោយលម្អង

១ ទេវធីតានោះ មានពន្លឺស្មើផ្សាយចេញ ពីខ្លួនកើតឡើងដោយបុណ្យ ប្រាកដដូចជា មណ្ឌលនៃព្រះអាទិត្យស្រទន់ ហេតុនោះ ទើបឈ្មោះថា សុរិយវច្ឆសា ។

នាគោ ឃម្មាភិតត្តោវ
ឱគាហេ តេ ថនូទរំ ។
អច្ចង្កុសោវ នាគោ ច
ជិតំ មេ តុត្តតោមរំ
ការណំ នប្បជានាមិ
សម្មត្តោ លក្ខណូរុយា(១)
តយិ គេធិតចិត្តោស្មិ(២)
ចិត្តំ វិបរិណាមិតំ
បដិគន្តុំ ន សក្កោមិ
វង្កឃស្តោវ(៣) អម្ពុជោ ។
វាមូរុ(៤) សជ មំ ភទ្ទេ
សជ មំ មន្ទលោចនេ
បលិស្សជ មំ កល្យាណិ
ឯតំ មេ អភិបត្ថិតំ ។
អប្បកោ វត មេ សន្តោ

១ ឱ. លក្ខណូរុសា ។ ២ ម. គេធិតចិត្តោស្មិ ។ ៣ វង្កឃស្តោតិបិ វង្កឃសោតិបិ បាឋោ ។ ៤ ឱ. វាមូរុ ។ ម. វាមូរូ ។



នៃកេសរផ្កាឈូកជាលំអងនី ៗ បងនឹងចុះទៅក្រោះភ្លៅ របស់នាង ដែលបរិបូណ៌ដោយលក្ខណៈ ក៏រែងស្គាល់ហេតុ (ដែលគំឡូក្រាសតាកកគ:) ដូចជាដំរី (ចុះប្រេង) ហួសវិស័យកន្ទ្រៃ និងជា អញឈ្នះផ្លែកន្ទ្រៃនិងលំពែង ៗ បងមានចិត្តស្រលាញ់ជាប់ហើយក្នុងនាង បងមិនអាចនឹងទាញចិត្តដែលជាប់ចិត្តហើយ ឲ្យត្រឡប់វិញបានឡើយ ដូចជាត្រីលេបសន្ទូច ៗ ម្នាលនាង មានភ្លៅដូចបណ្ដូលចេក ដំបម្រើនចូរនាងឱបបង ម្នាលនាង មានភ្នែកស្រទន់ ចូរនាងមកកៀកបង ម្នាលនាងមានរូបឆោមល្អ ចូរនាងមកឱបកបង ការឱបកនេះ បងប្រាថ្នាណាស់ ៗ កាមរបស់បងមានតិចវែងទេ តែព្រោះនាងមានសក់ក្រសាយ-ទីឡើង

សព្វបត្តិសុត្តំ បញ្ចសិខានុព្ពុទ្ធគាថា

កាមោ បេស្សិតកោសិយា
អនេកកការា(១) សមាតានិ(២)
អរហន្តេ ឧក្កិណ្ណា ។
យំ មេ អត្ថិ កតំ បុញ្ញំ
អរហន្តេសុ តាទិសុ
តំ មេ សព្វន្តកល្យាណំ
តយា សទ្ធឹ វិបច្ចតុ ។
យំ មេ អត្ថិ កតំ បុញ្ញំ
អស្មឹ ឧបវិមណ្ឌលេ(៣)
តំ មេ សព្វន្តកល្យាណំ
តយា សទ្ធឹ វិបច្ចតុ ។
សក្យបុត្តោវ ញាណេន
ឯកោតិ ថិរោតោ សរេតោ
អមតំ មុចិ ជិតីសាពោ
គមហំ សុរិយទ្ធសេ ។
យថាបិ មុនិ នន្ទេយ្យ
បត្វា សម្ពោធិមុត្តមំ

១ អនេកការកោតិបិ បាឋោ ។ ២ ស. សមុប្បាទិ ។ ម. សមុប្បាទិ ។ ៣ ម. ពុទ្ធិមណ្ឌលេ ។



សព្វបត្តិសូត្រ គាថាបេសបញ្ចសិខានុព្ពុទ្ធ

សេចក្តីប្រាថ្នាថែបធី គឺកើតមានផងអនេក ដូចទក្ខិណាទាន ដែលខានថ្វាយ ចំពោះព្រះអរហន្ត ។ ម្នាលនាងមានលម្អ សព្វសពាង្គ បុណ្យណាដែលបងបានធ្វើហើយ ចំពោះព្រះអរហន្តទាំងឡាយ ជាអ្នកនឹងធឹង បុណ្យរបស់បងនោះ សូមជួយបងឲ្យបានគប់ប្រសព្វនឹងនាង ។ ម្នាលនាងមានលម្អគប់អង្គ បុណ្យណាដែលបងបានធ្វើហើយ ក្នុងមណ្ឌលនៃប្រឹថពីនេះ បុណ្យរបស់បងនោះ សូមជួយបងឲ្យបានគប់ប្រសព្វនឹងនាង ។ ព្រះមុនីជាសក្យបុត្រ ទ្រង់ប្រកបដោយឈាន គង់នៅតែមួយព្រះអង្គឯង មានព្រះប្រាជ្ញាស្មារតី ព្រះអង្គទ្រង់ស្វែងរកព្រះនិព្វាន យ៉ាងណា ម្នាលនាងសុរិយវច្ចសា បងក៏ទំស្វែងរកនាង យ៉ាងនោះដែរ ។ មួយទៀត សម្តេចព្រះមុនី ព្រះអង្គបានសម្រេច នូវសម្ពោធិញ្ញាណ ដ៏ឧត្តម

ឯវំ នន្ទេយ្យំ កល្យាណិ
មិស្សីភាវំ(១) គតោ តយា ។
សក្កោ ចេ(២) មេ វរំ ទជ្ជា
តាវតឹសានមិស្សរោ
តាហំ ភទ្ទេ វរេយ្យាហេ
ឯវំ កាមោ ទឡ្ហោ មម ។
សាលំវ ន ចិរំ ផុល្លំ
បិតរំ តេ សុមេធសេ
វន្ទមានោ នមស្សាមិ
យស្ស(៣) សេតាទិសី បជា ។

(៨៧) ឯវំ វុត្តេ ភគវា បញ្ចសិខំ គន្ធព្វបុត្តំ ឯតទវោច សំសន្ទតិ ខោ តេ(៤) បញ្ចសិខ តន្តិស្សរោ គីតស្សរេន គីតស្សរោ ច តន្តិស្សរេន ន ច បន(៥) តេ បញ្ចសិខ តន្តិស្សរោ គីតស្សរំ អតិវត្តតិ

១ ម. ឧ. មិស្សីភាវំ ។ ២ ម. ឧ. ។ ៣ ឱ. យស្សា ។ ៤ ម. ខោ បន តេ ។ ៥ ម. ឱ. ន ច បន ។



ហើយ ទ្រង់ត្រេកអរព្រះហឫទ័យ យ៉ាងណាមិញ ម្នាលនាងកល្យាណី ខ្ញុំបងបើបានមូលមិត្តនឹងនាងហើយ ក៏នឹងត្រេកអរក្នុងចិត្ត យ៉ាងនោះដែរ ។ ម្នាលនាងដ៏ចម្រើន បើសក្កទេវរាជជាធំជាងពួកទេវតា ក្នុងជាន់តាវត្តិង្ស ទ្រង់ប្រទានពរដល់បង បងគប្បីប្រាថ្នានាង សេចក្តីប្រាថ្នាដែលមាំមួន (ក្នុងចិត្ត) របស់បងយ៉ាងនេះ ។ ម្នាលនាងទេវធីតា មានប្រាជ្ញាឈ្លាសវៃ នាងមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា បងសូមថ្វាយបង្គំចំពោះអ្នកនោះ ជាបិតារបស់នាង ដូចឈើដែលទើបនឹងមានផ្កា ។

[៨៧] កាលបើបញ្ចសិខគន្ធព្វបុត្ត ច្រៀងគាថាទាំងនោះយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរបញ្ចសិខគន្ធព្វបុត្តយ៉ាងនេះថា ម្នាលបញ្ចសិខៈ សំឡេងខ្សែពិណរបស់អ្នក សមល្មមគ្នានឹងសំឡេងច្រៀង ចំណែកសំឡេងច្រៀងក៏សមល្មមគ្នានឹងសំឡេងខ្សែពិណ ម្នាលបញ្ចសិខៈ មួយទៀតសំឡេងខ្សែពិណរបស់អ្នកមិនប្រព្រឹត្តកន្លងសំឡេងច្រៀង

ន តិតស្សរោ ច គន្ថស្សរំ(១) កទា សំយូឡ្ហា បន តេ បញ្ចសិខ ឥមា គាថា ពុទ្ធូបសញ្ហិតា ធម្មូបសញ្ហិតា សង្ឃូបសញ្ហិតា អរហន្តូបសញ្ហិតា កាមូបសញ្ហិតាតិ ។ ឯកមិទាហំ ភន្តេ សមយំ ភគវា ឧរុវេលាយំ វិហរតិ នជ្ជា នេរញ្ជរាយ តីរេ អជបាលនិគ្រោធេ(២) បឋមាភិសម្ពុទ្ធោ ។ តេន ខោ បនាហំ ភន្តេ សមយេន ភទ្ទា នាម សុរិយវច្ចសា តិម្ពរុនោ គន្ធព្វរញ្ញោ ធីតា តមាភិកង្ខាមិ(៣) ។ សា ខោ បន ភន្តេ ភគិនី បរកាមិនី ហោតិ សិខណ្ឌី នាម(៤) មាតលិស្ស សង្គាហកស្ស បុត្តោ តមាភិកង្ខតិ ។ យតោ ខោ អហំ ភន្តេ តំ ភគិនី នាលត្ថំ កេនចិ បរិយាយេន អថាហំ បេឡុវបណ្ឌុវីណំ អាទាយ យេន តិម្ពរុនោ គន្ធព្វរញ្ញោ និវេសនំ តេនុបសង្កមឹ ឧបសង្កមិត្វា បេឡុវបណ្ឌុវីណំ អស្សាវេសឹ ឥមា គាថា(៥) អភាសឹ ពុទ្ធូបសញ្ហិតា ធម្មូបសញ្ហិតា សង្ឃូបសញ្ហិតា អរហន្តូបសញ្ហិតា កាមូបសញ្ហិតា

១ ម. គន្ធស្សរោ អតិវត្តតិ គីតស្សរំ គីតស្សរោ វា គន្ធស្សរន្តិ ។ ២ ម. អជបាលនិគ្រោធមូលេ ។ ៣ ម. ឱ. តមភិកង្ខាមិ ។ ៤ ម. សិខទ្ធិ នាម ។ ៥ ម. ឥមា ប គាថា ។ ៦ ម. ឥមា ច គាថាយោ ។



តាំងសំឡេងច្រៀង គឺមិនប្រព្រឹត្តកន្លងសំឡេងនៃរត្តិណាឡើយ ម្នាលបញ្ចសិខៈ គាថាទាំងនេះ ដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះអរហន្ត ទាំងប្រកបដោយកាម តើអ្នកចងក្រងទុកតាំងពីកាលណាមក ។ បញ្ចសិខគន្ធព្វបុត្ត ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ បានចងក្រងទុកមក តាំងអំពីសម័យ ដែលព្រះមានព្រះភាគ ទ្រង់បានត្រាស់ដឹងជាដំបូង ហើយទ្រង់គង់នៅ ក្រោមដើមអជបាលនិគ្រោធ ក្បែរឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ឯណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះ ខ្ញុំព្រះអង្គ ប្រាថ្នាចង់បានខ្លួននាងសុរិយវច្ចសាឋីតា ដែលជាធីតានៃព្រះបាទតិម្ពរុគន្ធព្វរាជ ។ បពិត្រព្រះអង្គដ៏ចម្រើន តែនាងនោះឯង មានសេចក្តីស្រឡាញ់ចំពោះបុរសដទៃវិញ គឺចង់បានសិខណ្ឌីទេវបុត្រ ជាបុត្ររបស់មាតលីសង្គាហកទេវបុត្ត ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលដែលខ្ញុំព្រះអង្គ មិនបាននាងនោះ ដោយអាការយ៉ាងណាមួយហើយ ទើបខ្ញុំព្រះអង្គកាន់ពិណ មានសម្បុរលឿងដូចផ្លែព្នៅ ចូលទៅកាន់ទីលំនៅ របស់ព្រះបាទតិម្ពរុគន្ធព្វរាជ លុះចូលទៅដល់ហើយ ក៏ដេញពិណមានសម្បុរលឿង ដូចផ្លែព្នៅ ហើយច្រៀងនូវគាថាទាំងនេះ ដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃ ព្រះអរហន្ត ទាំងប្រកបដោយកាម ថា

វន្ទេ តេ បិតរំ ភទ្ទេ
តិម្ពរុំ សុរិយវច្ចសេ
យេន ជាតាសិ កល្យាណី
អានន្ទជននី មម ។
។ បេ ។ សាលំវ ន ចិរំ ផុល្លំ
បិតរំ តេ សុមេធសេ
វន្ទមានោ នមស្សាមិ
យស្ស សេតាទិសី បជាតិ ។

(៨៨) ឯវំ វុត្តេ ភន្តេ ភទ្ទា សុរិយវច្ចសា មំ ឯតទវោច ន ខោ មេ មារិស សោ ភគវា សម្មុខា ទិដ្ឋោ អបិច សុតោយេវ មេ សោ ភគវា ទេវានំ តាវតឹសានំ សុធម្មាយ សភាយ(១) ឧបនច្ចន្តិយា យតោ ខោ ត្វំ មារិស តំ ភគវន្តំ កិត្តេសិ ហោតុ នោ អជ្ជ សមាគមោតិ ។ សោយេវ នោ ភន្តេ តាវតកេន សមាគមោ អហោសិ ន ច ទានិ(២) តតោ បច្ឆាតិ ។ អថខោ សក្កស្ស

១ ឱ. ម. សុធម្មាយំ សភាយំ ។ ២ ឱ. ម. ន បច្ឆិ ។



ម្នាលនាងទេវធីតា ឈ្មោះសុរិយវច្ចសាដ៏ចម្រើន នាងកើតមកហើយមានរូបល្អ បងសូមថ្វាយបង្គំនូវទេវរាជ ព្រះនាមតិម្ពរុ ជាបិតារបស់នាង ដោយហេតុដែលនាងកើតមកហើយ មានលំអជាទីញ៉ាំងសេចក្តីត្រេកអរ ឲ្យកើតដល់បង ។ បេ ។ ម្នាលនាងទេពធីតា មានប្រាជ្ញាឈ្លាសវៃ នាងមានរូបប្រាកដដូច្នេះ ជាធីតារបស់អ្នកណា បងសូមថ្វាយបង្គំ បិតារបស់អ្នកនោះ ជាបិតារបស់នាង ដូចឈើដែលទើបនឹងមានផ្កា ។

(៨៨) បពិត្រព្រះអង្គដ៏ចម្រើន កាលបើខ្ញុំព្រះអង្គ ច្រៀងគាថាយ៉ាងនេះហើយ នាងសុរិយវច្ចសាដ៏ចម្រើន បាននិយាយ នឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលអ្នកនិទ្ទុក ខ្ញុំមិនដែលបានឃើញ ព្រះមានព្រះភាគអង្គនោះ ក្នុងទីចំពោះព្រះភក្ត្រសោះឡើយ ប៉ុន្តែកាលខ្ញុំចូលទៅកាន់រោងឈ្មោះសុធម្មារបស់ទេវតាជាន់តាវត្តិង្ស ក៏បានឮពុទ្ធគុណ របស់ព្រះមានព្រះភាគនោះ ម្នាលអ្នកនិទ្ទុក កាលណាបើ អ្នកនិយាយសរសើរព្រះមានព្រះភាគអង្គនោះ ការជួបគ្នាក្នុងថ្ងៃនេះ ចូរមានដល់យើងទាំងពីរនាក់ ។ បពិត្រព្រះអង្គដ៏ចម្រើន ការជួបគ្នាសមាគមជាមួយនឹងនាងនោះ ក៏មានដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គក៏លែងច្រៀង (ចំពុកនេះ) តាំងពីក្រោយនោះមក ។ លំដាប់នោះ សក្កទេវរាជ ជាធំជាង

ទេវានមិន្ទស្ស ឯតទហោសិ បដិសម្មោទតិ ខោ បញ្ចសិ-ខោ គន្ធព្វបុត្តោ ភគវតា ភគវា ច បញ្ចសិខេនាតិ ។ អថខោ សក្កោ ទេវានមិន្ទោ បញ្ចសិខំ គន្ធព្វបុត្តំ អាមន្តេសិ អភិវាទេហិ មេ ត្វំ តាត បញ្ចសិខ ភគវន្តំ សក្កោ ភន្តេ ទេវានមិន្ទោ សាមច្ចោ សបរិជនោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ ឯវំ ភទ្ទន្តវាតិ ខោ បញ្ចសិខោ គន្ធព្វបុត្តោ សក្កស្ស ទេវានមិន្ទស្ស បដិស្សុត្វា ភគវន្តំ អភិវាទេសិ សក្កោ ភន្តេ ទេវានមិន្ទោ សាមច្ចោ សបរិជនោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ ឯវំ សុខី(១) ហោតុ បញ្ចសិខ សក្កោ ទេវានមិន្ទោ សាមច្ចោ សបរិជនោ សុខកាមា ហិ ទេវា មនុស្សា(២) អសុរា នាគា គន្ធព្វា យេ ចញ្ញេ សន្តិ បុថុកាយាតិ ។

១ ម. សុខី ។ ២ ម. ទេវមនុស្សា ។



ក្នុងវេលា ទ្រង់ត្រិះរិះ យ៉ាងនេះថា បញ្ចសិខគន្ធព្វបុត្ត សាទរជាមួយនឹងព្រះមានព្រះភាគ ចំណែកព្រះមានព្រះភាគ ក៏ទ្រង់សាទរជាមួយនឹងបញ្ច-សិខគន្ធព្វបុត្ត ។ ទើបសក្កទេវរាជ ជាធំជាងពួកទេវតា ត្រាស់ហៅបញ្ចសិខគន្ធព្វបុត្តមកថា នែអ្នកបញ្ចសិខៈ អ្នកចូរទៅថ្វាយបង្គំ ព្រះមានព្រះភាគ តាមពាក្យរបស់យើងថា បពិត្រព្រះអង្គដ៏ចំរើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិស័ទ សូមក្រាបថ្វាយបង្គំ នូវព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយត្បូង ។ បញ្ចសិខគន្ធព្វបុត្ត ក៏ទទួលព្រះបន្ទូលសក្កទេវរាជ ជាធំជាងពួកទេវតា ដោយពាក្យថា ព្រះករុណាវិសេស សេចក្តីចំរើន ចូរមានដល់ព្រះអង្គ ហើយថ្វាយបង្គំព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិស័ទ សូមក្រាបថ្វាយបង្គំ នូវព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយត្បូង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលបញ្ចសិខៈ សូមឲ្យសក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិស័ទ បានសេចក្តីសុខតាមសេចក្តីប្រាថ្នាចុះ ព្រោះពួកទេវតានិងមនុស្ស អសុរ នាគ គន្ធព្វ និងសត្វដទៃ ៗ ជាច្រើនពួក តែងប្រាថ្នាសេចក្តីសុខ ។

(៨៩) ឯវញ្ច បន តថាគតា ឯវរូបេ មហេសក្ខេ យក្ខេ អភិវទន្តិ(១) ។ អភិនន្ទិតោ សក្កោ ទេវានមិន្ទោ ភគវតោ ឥន្ទសាលគុហំ បវិសិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ទេវាបិ តាវតិំសា ឥន្ទសាលគុហំ បវិសិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ បញ្ចសិខោបិ គន្ធព្វបុត្តោ ឥន្ទសាលគុហំ បវិសិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ តេន ខោ បន សមយេន ឥន្ទសាលគុហា វិសមា សន្តី សមា សមបាទិ សម្ពាធា សន្តី ឧរុន្ទា សមបាទិ អន្ធការោ គុហាយំ(២) អន្តរធាយិ អាលោកោ ឧទបាទិ យថា តំ ទេវានំ ទេវានុភាវេន ។

(៩០) អថខោ ភគវា សក្កំ ទេវានមិន្ទំ ឯតទវោច អច្ឆរិយមិទំ អាយស្មតោ កោសិយស្ស អព្ភុតមិទំ អាយស្មតោ កោសិយស្ស តាវ(៣) ពហុកិច្ចស្ស ពហុករណីយស្ស យទិទំ ឥធាគមនន្តិ ។

១ ម. ឆ. មហេសក្ខេ អភិវទន្តិ ។ ២ ម. វិសមា យន្តី សមា សមបាទិ សម្ពាធា យន្តី ឧរុន្ទា សមបាទិ អន្ធការោ គុហាយំ ។ ៣ ម. ឆ. កាវ ។



(៨៩) ធម្មតាព្រះតថាគតកាលព្រះអង្គ តែងមានព្រះបន្ទូលដោយស្មោះ ចំពោះទៅរកពួកយក្សដែលមានសក្តិធំ មានសភាពយ៉ាងនេះ ដូច្នេះឯង ។ ឯសក្កទេវរាជ ជាធំជាងពួកទេវតា លុះព្រះមានព្រះភាគមានព្រះបន្ទូល ដោយស្មោះចំពោះហើយ ក៏ចូលទៅកាន់ឥន្ទសាលគុហា ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ទាំងពួកទេវតានៅក្នុងឋានតាវត្តិង្ស ក៏ចូលទៅកាន់ឥន្ទសាលគុហា ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ឯបញ្ចសិខគន្ធព្វបុត្ត ក៏ចូលទៅកាន់ឥន្ទសាលគុហា ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ ក្នុងសម័យនោះឯង ឥន្ទសាលគុហា ដែលមានផ្ទៃមិនរាបស្មើ ក៏ប្រែជាមានផ្ទៃរាបស្មើវិញ មានទីចង្អៀត ក៏ប្រែជាមានទីទូលាយវិញ ទាំងងងឹតក្នុងគុហាក៏បាត់ទៅ មានពន្លឺភ្លឺច្រាលច្រាសឡើង ដោយទេវានុភាព របស់ពួកទេវតានោះឯង ។

(៩០) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងសក្កទេវរាជជាធំជាងពួកទេវតា ដូច្នេះថា នេះជាហេតុគួរអស្ចារ្យ របស់កោសិយៈមានអាយុ នេះជាហេតុមិនធ្លាប់កើតមាន របស់កោសិយៈមានអាយុ នេះជាដំណើរស្តេចមកក្នុងទីនេះ របស់ទេវរាជ ដែលមានកិច្ចច្រើន មានការកិច្ចច្រើន ។

ចិរបដិកាហំ ភន្តេ ភគវន្តំ ទស្សនាយ ឧបសង្កមិតុកាមោ អបិច ទេវានំ តាវតិំសានំ កេហិចិ(១) កិច្ចករណីយេហិ ព្យាវដោ(២) ឯវាហំ នាសក្ខឹ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ ។ ឯកមិទំ ភន្តេ សមយំ ភគវា សាវត្ថិយំ វិហរតិ សលឡាគារកេ ។ អថខ្វាហំ(៣) ភន្តេ សាវត្ថឹ អគមាសឹ ភគវន្តំ ទស្សនាយ ។ តេន ខោ បន ភន្តេ សមយេន ភគវា អញ្ញតរេន សមាធិនា និសិន្នោ ហោតិ ។ ភុជតី ច នាម(៤) វេស្សវណស្ស មហារាជស្ស បរិចារិកា ភគវន្តំ បញ្ជលិកា ហោតិ

១ ម. ឆ. កេហិចិ កេហិចិ ។ ២ ឆ. ព្យាវដោ ។ ៣ ម. អថខ្វាហំ ។ ៤ ម. ភុញ្ជតិ ច នាម ។ ឆ. ភុជតិ នាម ។





សក្កទេវរាជក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មានបំណងនឹងចូលមកគាល់ព្រះមានព្រះភាគ ជាយូរណាស់ហើយ តែខ្ញុំព្រះអង្គមានសេចក្ដីខ្វល់ខ្វាយដោយកិច្ចការនីមួយ(១) របស់ពួកទេវតាតាវត្តិង្ស ព្រោះហេតុនោះ ខ្ញុំព្រះអង្គ ក៏មិនអាចនឹងចូលមកគាល់ព្រះមានព្រះភាគបាន ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងសលឡាគារកុដិ ជិតក្រុងសាវត្ថី ។ បពិត្រព្រះអង្គដ៏ចម្រើន សម័យនោះឯង ខ្ញុំព្រះអង្គបានមកកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចម្រើន តែក្នុងវេលានោះ ព្រះមានព្រះភាគ កំពុងគង់សម្ងំដោយសមាធិណាមួយ ។ ឯនាងទេវធីតាឈ្មោះភុជតី ជាបរិចារិការបស់វេស្សវណមហារាជ កំពុងតែឈរប្រណម្យ

១ មានសេចក្ដីក្នុងអដ្ឋកថាពន្យល់ថា ទេវតាជាកូនស្រីឬកូនប្រុស តែងកើតលើភ្លៅនៃទេវតា។ ស្រីជាបាទបរិចារិកា តែងកើតលើទំនោកទេវតា ។ ទេវតាអ្នកធ្វើគ្រឿងប្រដាប់ដល់ស្រីជាបាទបរិចារិកានេះ តែងកើតក្នុងទីជុំវិញទំនោក ។ ទេវតាជាអ្នកបម្រើ តែងកើតក្នុងវិមាន ។ ទេវតាទាំងនេះ គតមានដំណើរកាត់ក្ដីនឹងគ្នាដល់ទៅក្ដីក្ដាំឡើយ លុះតែទេវតាណាកើតត្រង់ទីព្រំប្រទល់នៃ ទេវតាទាំងពួងក៏មិនអាចនឹងកាត់សេចក្ដីទេវតានោះ ថាជារបស់អ្នកណាឡើយ ហើយនាំគ្នាទៅជាក្ដីក្ដាំនឹងគ្នា ក្រាបទូលដល់សក្កទេវរាជ ឯសក្កទេវរាជ កាត់ក្ដីឲ្យសេចក្ដីថា បើវិមាននៃអ្នកណាជិតជាង ត្រូវបានជារបស់អ្នកនោះ បើវិមានទាំងពីរស្មើគ្នា សក្កទេវរាជកាត់ក្ដីឲ្យថា កាលទេវបុត្រក្រឡេកមើលទៅរកវិមានអ្នកណា ត្រូវជាខាងរបស់អ្នកនោះ បើគតសំឡឹងមើលទៅក្នុងទីណាទេ ក៏សក្កទេវរាជ ទ្រង់យកទេវបុត្រនេះមកទុកជារបស់ព្រះអង្គ ។ សក្កទេវរាជតែងរវល់ដោយការកាត់ក្ដីនេះផង ដោយកិច្ចផ្សេង ៗ មានក្រសាលល្បែងជាដើមផង ហេតុនោះបានជាសក្កទេវរាជក្រាបបង្គំទូលព្រះអង្គថា ខ្ញុំព្រះអង្គមានសេចក្ដីខ្វល់ខ្វាយដោយការងារនីមួយ ។

បញ្ជលិកា នមស្សមានា តិដ្ឋតិ ។ អថខោហំ ភន្តេ កុជ្ជតឹ ឯតទវោចំ អភិវាទេហិ មេ ត្វំ ភគិនិ ភគវន្តំ សក្កោ ភន្តេ ទេវានមិន្ទោ សាមច្ចោ សបរិជនោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ ឯវំ វុត្តេ ភន្តេ សា កុជ្ជតី(១) មំ ឯតទវោច អកាលោ ខោ មារិស ភគវន្តំ ទស្សនាយ បដិសល្លីនោ(២) ភគវាតិ ។ តេនហិ ភគិនិ យទា ភគវា តម្ហា សមាធិម្ហា វុដ្ឋិតោ ហោតិ អថ មម វចនេន ភគវន្តំ អភិវាទេហិ សក្កោ ភន្តេ ទេវានមិន្ទោ សាមច្ចោ សបរិជនោ ភគវតោ បាទេ សិរសា វន្ទតីតិ ។ កច្ចិ មេ សា ភន្តេ ភគិនី ភគវន្តំ អភិវាទេសិ សរតិ ភគវា

១ ឱ. សី ភុជ្ជតី ។ ២ ឱ. បដិសល្លីនោ ។



អញ្ជលី នមស្ការ គោរពព្រះមានព្រះភាគ ។ បពិត្រព្រះអង្គដ៏ចំរើន គ្រានោះ ខ្ញុំព្រះអង្គ ផ្តាំផ្ញើនឹងនាងទេវធីតា ឈ្មោះកុជ្ជតី ដូច្នេះថា ម្នាលប្អូនស្រី នាងចូរថ្វាយបង្គំព្រះមានព្រះភាគ តាមពាក្យយើងថា បពិត្រព្រះអង្គដ៏ចំរើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិស័ទ សូមថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយត្បូង ។ បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំព្រះអង្គផ្តាំផ្ញើ យ៉ាងនេះហើយ នាងទេវធីតា ឈ្មោះកុជ្ជតីនោះ ឆ្លើយតបមកនឹងខ្ញុំព្រះអង្គ ដូច្នេះថា បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ វេលានេះ ជាកាលមិនគួរនឹងចូលទៅគាល់ព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគ កំពុងសម្ងំនៅដោយព្រះអង្គឯង ។ ខ្ញុំព្រះអង្គបាននិយាយថា បើដូច្នោះ កាលណាបើ ព្រះមានព្រះភាគ ទ្រង់ចេញចាកសមាធិនោះហើយ ចូរនាងថ្វាយបង្គំ ព្រះមានព្រះភាគ តាមពាក្យរបស់យើងថា បពិត្រព្រះអង្គដ៏ចំរើន សក្កទេវរាជ ជាធំជាងពួកទេវតា ព្រមទាំងអាមាត្យ ព្រមទាំងបរិស័ទ សូមថ្វាយបង្គំព្រះបាទទាំងគូ របស់ព្រះមានព្រះភាគ ដោយត្បូង ។ បពិត្រព្រះអង្គដ៏ចំរើន នាងនោះបានថ្វាយបង្គំព្រះមានព្រះភាគ តាមពាក្យខ្ញុំព្រះអង្គដែរឬ ព្រះមានព្រះភាគ ទ្រង់

តស្សា ភគិនិយា វចនន្តិ ។ អភិវាទេសិ មំ សា ទេវានមិន្ទ ភគិនី សរាមហំ តស្សា ភគិនិយា វចនំ អបិចាហំ អាយស្មតោ នេមិសទ្ទេន(១) តម្ហា សមាធិម្ហា វុដ្ឋិតោតិ ។ យេ តេ ភន្តេ ទេវា អម្ហេហិ បឋមតរំ តាវតិំសកាយំ ឧបបន្នា(២) តេសំ មេ សម្មុខា សុតំ សម្មុខា បដិគ្គហិតំ យទា តថាគតា លោកេ ឧប្បជ្ជន្តិ អរហន្តោ សម្មាសម្ពុទ្ធា ទិព្វា កាយា បរិបូរេន្តិ ហាយន្តិ អសុរកាយាតិ ។ តំ មេ ភន្តេ សក្ខិទិដ្ឋំ យតោ តថាគតោ លោកេ ឧប្បន្នោ អរហំ សម្មាសម្ពុទ្ធោ ទិព្វា កាយា បរិបូរេន្តិ ហាយន្តិ អសុរកាយាតិ ។ ឥធេវ ភន្តេ កបិលវត្ថុស្មិំ គោបិកា នាម សក្យធីតា អហោសិ ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា សីលេសុ បរិបូរការិនី(៣) សា ឥត្ថិចិត្តំ(៤) វិរាជេត្វា បុរិសចិត្តំ(៥) ភាវេត្វា កាយស្ស ភេទា

១ ឱ. អាយស្មតោ ច នេមិសទ្ទេន ។ ម. អាយស្មតោ ... ។ ២ ឱ. ឧប្បន្នា ។ ៣ ឱ. ម. បរិបូរការិនី ។ ៤ ម. ឥត្ថិត្តំ ។ ៥ ម. បុរិសត្តំ ។



រលឹកឃើញពាក្យនាងនោះដែរឬ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រទេវានមិន្ទ នាងនោះ បានថ្វាយបង្គំតថាគតហើយ តថាគត ក៏រលឹកឃើញពាក្យនោះបាន តែតថាគត ចេញចាកសមាធិនោះ ព្រោះសូរនៃខ្នងកង់ (កង់រថ) របស់លោកដ៏មានអាយុ ។ សក្កទេវរាជ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកទេវតាណា បានទៅកើតក្នុងពួកទេវតា នៅក្នុងឋានតាវត្តិង្ស មុនជាងខ្ញុំព្រះអង្គ ។ បានឮចំពោះមុខ បានទទួល (ដំណឹងនោះ) ចំពោះមុខ នៃទេវតាពួកនោះថា កាលណា ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់កើតឡើងក្នុងលោក កាលនោះ ពួកទេវតាក៏កុះករ ពួកអសុរក៏សាបសូន្យទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះឯង ខ្ញុំព្រះអង្គបានឃើញជាក់ហើយ តាំងពីដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយ ក្នុងលោក ពួកទេវតាក៏កុះករ ពួកអសុរក៏សាបសូន្យទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងក្រុងកបិលព័ស្តុនេះឯង មានសក្យធីតាម្នាក់ ឈ្មោះគោបិកា ជាស្ត្រីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តែងធ្វើនូវការបំពេញកិច្ច ក្នុងសីលទាំងឡាយ នាងនឿយណាយចិត្ត ក្នុងភេទនៃខ្លួនជាស្ត្រី ចំរើនសេចក្តីពេញចិត្ត ក្នុងភេទនៃខ្លួនជាបុរស លុះបែកធ្លាយរាងកាយ

បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា ទេវានំ តាវត្តឹសានំ សហព្យតំ អម្ហាកំ បុត្តត្តំ អជ្ឈុបគតា តត្រាប់(១) នំ ឯវំ ជានន្តិ គោបកោ ទេវបុត្តោ គោបកោ ទេវបុត្តោតិ ។ អញ្ញេបិ ភន្តេ តយោ ភិក្ខូ ភគវតិ ព្រហ្មចរិយំ ចរិត្វា ហីនំ គន្ធព្វកាយំ ឧបបន្នា តេ បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារយមានា អម្ហាកំ ឧបដ្ឋានំ អាគច្ឆន្តិ អម្ហាកំ បារិចរិយំ ។ តេ អម្ហាកំ ឧបដ្ឋានំ អាគតេ អម្ហាកំ បារិចរិយំ គោបកោ(២) ទេវបុត្តោ បដិចោទេសិ កុតោមុខា នាម តុម្ហេ មារិសា តស្ស ភគវតោ ធម្មំ អាយូហិត្ថ(៣) អហំ ហិ នាម ឥត្ថិកា(៤) សមានា ពុទ្ធេ បសន្នា ធម្មេ បសន្នា សង្ឃេ បសន្នា សីលេសុ បរិបូរការិនី ឥត្ថិចិត្តំ វិរាជេត្វា បុរិសចិត្តំ ភាវេត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា ទេវានំ តាវត្តឹសានំ សហព្យតំ

១ ឱ. ម. តត្រាបិ ។ ២ ម. គោបកោ នាម ។ ៣ ឱ. អស្សុត្ថ ។ ម. អសុត្ថ ។
៤ ឱ. អហំ ហិ ឥត្ថិកា ។



ខាងមុខអំពីសេចក្តីស្លាប់ទៅ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយនឹងទេវតា ដែលឋិតនៅក្នុងជាន់តាវត្តិង្ស បានមកជាបុត្ររបស់ខ្ញុំព្រះអង្គ ពួកទេវតាដែលនៅក្នុងជាន់តាវត្តិង្សនោះ ស្គាល់ទេវបុត្តនោះយ៉ាងនេះថា គោបកទេវបុត្ត គោបកទេវបុត្ត ដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន មានភិក្ខុ ៣ រូបដទៃទៀត ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ (លុះទម្លាយរាងកាយ) ក៏ទៅកើត ក្នុងពួកគន្ធព្វដ៏ថោកទាប គន្ធព្វទាំង ៣ រូបនោះ ឲ្យគេបម្រើផ្គត់ស្កប់ស្កល់ដោយកាមគុណទាំង ៥ តែងមកកាន់ទីបម្រើរបស់ខ្ញុំព្រះអង្គ មកកាន់ទីគោរពប្រណិបត្តន៍ខ្ញុំព្រះអង្គ លុះគន្ធព្វទាំង ៣ នោះ មកកាន់ទីបម្រើរបស់ខ្ញុំព្រះអង្គ មកកាន់ទីគោរពប្រណិបត្តន៍ខ្ញុំព្រះអង្គ គោបកទេវបុត្ត ក៏និយាយដាស់តឿនពួកថា ម្នាលអ្នកនិទ្ទុក្ខទាំងឡាយ អ្នកទាំងឡាយ យកមុខទៅទុកក្នុងទីណា បានជាឃ្លាតនឹងធម៌របស់ព្រះមានព្រះភាគអង្គនោះ អម្បាលយ៉ាងខ្លួនខ្ញុំជាស្ត្រីសោះទេ ម្តងគង់ជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធព្រះធម៌ព្រះសង្ឃ បានធ្វើនូវការបំពេញកិច្ចក្នុងសីលទាំងឡាយទៅកើត (មិនតែប៉ុណ្ណោះ) ក៏នឿយណាយចិត្តក្នុងភេទនៃស្ត្រី កើតសេចក្តីពេញចិត្តក្នុងភេទនៃបុរស លុះដល់បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ក៏មកកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយនឹងទេវតាដែលឋិតនៅក្នុងជាន់តាវត្តិង្ស បានមក

សក្កស្ស ទេវានមិន្ទស្ស បុត្តត្តំ អជ្ឈុបគតា ឥធាបិ(១) នំ ឯវំ ជានន្តិ គោបកោ ទេវបុត្តោ គោបកោ ទេវបុត្តោតិ ភិក្ខូ បន មារិសា ភគវតិ ព្រហ្មចរិយំ ចរិត្វា ហីនំ គន្ធព្វកាយំ ឧបបន្នា ទុទ្ទិដ្ឋរូបំ វត ភោ អទ្ទសាម យេ មយំ អទ្ទសាម សហធម្មិកេ ហីនំ គន្ធព្វកាយំ ឧបបន្នេតិ ។ តេសំ តត្រ គោបកេន ទេវបុត្តេន បដិចោ-ទិតានំ ទ្វេ ទេវា ទិដ្ឋេវ ធម្មេ សតឹ បដិលភឹសុ កាយំ ព្រហ្មបុរោហិតំ ។ ឯកោ បន ទេវោ កាមេ(២) អជ្ឈាវសិ ។

(៤១) ឧបាសិកា ចក្ខុមតោ អហោសឹ
នាមំបិ មយ្ហំ អហុ គោបិកាតិ
ពុទ្ធេ ច ធម្មេ ច អភិប្បសន្នា

១ ឱ. ឥធបិ ។ ២ ឱ. ទេវោ ហីនកាយំ ។



ជាបុត្តរបស់សក្កទេវរាជ ចាំពីជាន់ពួកទេវតា ឯពួកទេវតាដែលនៅក្នុងជាន់តាវត្តិង្សនេះ នាំគ្នាហៅខ្ញុំយ៉ាងនេះថា គោបកទេវបុត្ត គោបកទេវបុត្តដូច្នេះ ម្នាលអ្នកនិទ៌ុក្ខទាំងឡាយ ចំណែកអ្នកទាំងឡាយ ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសម្នាក់នៃព្រះមានព្រះភាគ តែបែរជាមកកើត ក្នុងពួកគន្ធព្វ ដ៏ថោកទាបវិញ ខ្ញុំ យើងទាំងឡាយណា បានឃើញពួកសហធម្មិក(១)ដែលកើតក្នុងគន្ធព្វដ៏ថោកទាប យើងទាំងឡាយនោះ ឈ្មោះថាបានឃើញរូបដែលមិនគួរឃើញ ។ ចាំត្រូវព្រះអង្គបីរូបនោះ បណ្ដាទេវតាទាំង ៣ អង្គ ដែលគោបកទេវបុត្ត និយាយរំលឹកដាស់តឿននោះ ទេវតាពីរអង្គ ក៏ត្រឡប់បានស្មារតី ប្រកបដោយឈាន ក្នុងបច្ចុប្បន្ន (លុះច្យុតចាកអត្តភាពនោះហើយ) ក៏បានទៅកាយជាព្រហ្មបុរោហិត ។ ឯទេវតា ១ អង្គទៀត អាស្រ័យនៅក្នុងកាមគុណ ។

[៤១] ខ្ញុំបានជាឧបាសិកា របស់ព្រះសម្មាសម្ពុទ្ធ ទ្រង់
មានចក្ខុ ឯឈ្មោះ របស់ខ្ញុំប្រាកដថា គោបិកា ជាស្ត្រី
មានចិត្តជ្រះថ្លាស៊ប់ ក្នុងព្រះពុទ្ធ និង ព្រះធម៌ លុះមានចិត្ត

១ ពួកជនដែលប្រព្រឹត្តធម៌ស្មើគ្នា ក្នុងពុទ្ធសាសនាតែមួយ ។

សង្ឃញ្ចុបដ្ឋាសឹ បសន្នចិត្តា ។
តស្សេវ ពុទ្ធស្ស សុធម្មតាយ
សក្កស្ស បុត្តោម្ហិ មហានុភាវោ
មហាជុតិកោ តិទិវូបបន្នោ
ជានន្តិ មំ ឥធាបិ(១) គោបកោតិ ។
អទ្ទសំ(២) ភិក្ខវោ ទិដ្ឋបុព្វេ
គន្ធព្វកាយូបគតេ វសីនេ
ឥមេ ហិ តេ គោតមសាវកាសេ
យេ ច មយំ បុរេ មនុស្សភូតា ។
អន្នេន បានេន ឧបដ្ឋហិម្ហា
បាទូបសង្គយ្ហ សកេ និវេសនេ
កុតោមុខា នាម ឥមេ ភវន្តោ
ពុទ្ធស្ស ធម្មំ ន បដិគ្គហេសុំ(៣)
បច្ចត្តំ វេទិតព្វោ ហិ ធម្មោ
សុទេសិតោ ចក្ខុមតានុពុទ្ធោ

១ ឱ. ជានន្តិបិ មំ ឥធ ។ ២ ឱ. ម. អបទ្ទសំ ។ ៣ ម. អម្ហាតិ បដិគ្គហេសុំ ។



ជ្រះថ្លាហើយ បានចាំបំរើព្រះសង្ឃផង ។ ដោយកំណាច នៃព្រះពុទ្ធជាម្ចាស់នោះ និងព្រះធម៌ដ៏ប្រពៃ ខ្ញុំក៏បានមកកើតក្នុងបុរីនៃទេវតា បានជាបុត្រ របស់សក្កទេវរាជ ជាអ្នកមានអានុភាពច្រើន មានរស្មីច្រើន ពួកទេវតាដែលនៅក្នុងទេវលោកនេះ តែងស្គាល់ខ្ញុំថា គោបកទេវបុត្ត ដូច្នេះ ។ ខ្ញុំបានឃើញ នូវពួកភិក្ខុដែលធ្លាប់ឃើញហើយ មកកើតក្នុងពួកគន្ធព្វ នៅក្នុងពួកគន្ធព្វនោះ ឯភិក្ខុទាំងនោះ សុទ្ធតែជាសាវ័ករបស់ព្រះគោតម មួយទៀត យើងទាំងឡាយណា បានកើតជាមនុស្សក្នុងកាលមុន យើងទាំងឡាយនោះ បានចាត់ចែងកិច្ច គឺ លាង លាបបាទាហើយ បានទំនុកបម្រុង ដោយម្ហូបចំណីនិងទឹក ក្នុងលំនៅរបស់ខ្លួន អ្នកទាំងឡាយដ៏ចំរើនទាំងនេះ យកមុខទៅក្នុងទីណា បានជាមិនទទួលយកព្រះធម៌ របស់ព្រះពុទ្ធជាម្ចាស់ ។ ឯធម៌ដែលវិញ្ញូជន គប្បីដឹងច្បាស់ដោយខ្លួនឯង ក៏ព្រះសម្មាសម្ពុទ្ធមានចក្ខុ ត្រាស់ដឹងហើយ សំដែងដោយប្រពៃហើយ

អហំបិ តុម្ហេ(១) ឧបាសមានា
សុត្វាន(២) អរិយានំ សុភាសិតានិ ។
សក្កស្ស បុត្តោម្ហិ មហានុភាវោ
មហាជុតិកោ តិទិវូបបន្នោ
តុម្ហេ បន សេដ្ឋមុបាសមានា
អនុត្តរេ(៣) ព្រហ្មចរិយំ ចរិត្វា ។
ហីនកាយំ(៤) ឧបបន្នា ភវន្តោ
អនានុលោមា ភវតូបបត្តិ
ទុទ្ទិដ្ឋរូបំ វត អទ្ទសាម
សហធម្មិកេ(៥) ហីនកាយូបបន្នេ ។
គន្ធព្វកាយូបគតា ភវន្តោ
ទេវានមាគច្ឆថ បារិចរិយំ
អគារេ វសតោ មយ្ហំ ឥមំ បស្ស វិសេសតំ ។
ឥត្ថី ហុត្វា ស្វាជ្ជ(៦) បុមោម្ហិ ទេវោ(៧)
ទិព្វេហិ កាមេហិ សមង្គិភូតោ

---

១ ឱ. អហម្បិ តុម្ហេ ច ។ ម. អហំបិ ។ ២ ម. សុត្វា ។ ៣ ម. អនុត្តរំ ។ ៤ ម ហីនំ កាយំ ។ ៥ ឱ សហធម្មិកេ ។ ៦ ឱ. ម. ស្វជ្ជ ។ ៧ ឱ. ម. ទេវា ។





ឯខ្ញុំបានចូលទៅអង្គុយស្ដាប់សុភាសិត របស់ព្រះអរិយៈទាំង-ឡាយ ដូចអ្នកទាំងឡាយដែរ ។ ខ្ញុំបានមកកើតក្នុងបុរីនៃទេវ-តា បានជាបុត្ត របស់សក្កទេវរាជ ជាអ្នកមានអានុភាពច្រើន មានជុតិច្រើន ឯអ្នកទាំងឡាយ បានចូលទៅអង្គុយជិតព្រះពុទ្ធដ៏ប្រសើរ ទាំងប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងព្រះពុទ្ធសាស-នាដ៏ប្រសើរ ។ អ្នកទាំងឡាយដ៏ចម្រើន បានមកកើតក្នុងពួកគន្ធព្វ ជាអ្នកថោកទាប ការកើតរបស់អ្នកទាំងឡាយដ៏ចម្រើន (នេះ) មិនសមគួរសោះឡើយ យើងបានឃើញ នូវពួកសហធម្មិក ដែលមកកើតក្នុងពួកគន្ធព្វ អ្នកថោកទាប (នេះ) ខុស្មី ឈ្មោះថាបានឃើញរូបដែលមិនគួរឃើញ ។ ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយ កើតក្នុងពួកគន្ធព្វ មកកាន់ទីបម្រើនៃទេវតាទាំងឡាយ ចូរមើលនូវគុណវិសេសនេះ របស់ខ្ញុំដែលនៅក្នុងផ្ទះ ។ ពីដើមខ្ញុំជាស្រី ឥឡូវនេះ ខ្ញុំបានជាទេវបុត្ត បរិបូណ៌ដោយកាមជាទិព្វទាំងឡាយ

តេ ចោទិតា គោតមសាវកេន

សំវេគមាបាទុ សមេច្ច(១) គោបកំ ។

ហន្ទ វ្យាយាមាម វាយាមាម(២)

មា នោ មយំ បរបេស្សា អហុម្ហា

តេសំ ទុវេ វីរិយមារភឹសុ

អនុស្សរំ(៣) គោតមសាសនានិ ។

ឥធេវ ចិត្តានិ វិរាជយិត្វា

កាមេសុ អាទីនវមទ្ទសំសុ

តេ កាមសញ្ញោជនពន្ធនានិ

បាបិមតោ យោគានិ(៤) ទុរច្ចយានិ ។

នាគោវ សន្នានិ គុណានិ ឆេត្វា(៥)

ទេវេ តាវតឹសេ អតិក្កមឹសុ

---

១ ម. សំវេគមាបាទុំ សមច្ច ។ ២ ឱ. ហន្ទ វីតាយាម វ៉ាយមាម ។ ម. ហន្ទ វីយាយាម វាយាម ។ ៣ ឱ. អនុស្សរា ។ ៤ ឱ. ម. បាបិមយោគានិ ។ ៥ ឱ. សន្ទានិ គុណានិ ឆេត្វា ។ ម. សន្ទានិ គុណានិ ឆេត្វា ។



នូវទេវបុត្តទាំងនោះ លុះគោបកទេវបុត្ត ជាសាវ័ករបស់ព្រះគោតមបានរំលឹកដាស់តឿនហើយ ក៏ដល់នូវសេចក្តីសង្វេគថា យើងទាំងឡាយ បានមកជួបនឹងគោបកទេវបុត្ត ហើយម្នាះ យើងព្យាយាម ទំព្រើនប្រឹងព្យាយាមទៅ កុំឲ្យបានមកជាអ្នកបម្រើគេទៀតឡើយ បណ្តាទេវបុត្តទាំង៣ រូបនោះ ទេវបុត្ត ២ រូប បានរលឹកនូវសាសនា(១) នៃព្រះគោតមហើយ ប្រារព្ធនូវសេចក្តីព្យាយាមដាំងឹង ធ្វើចិត្តឲ្យនឿយណាយ ក្នុងទេវលោកនេះ បានឃើញទោសក្នុងកាមហើយ ទេវបុត្តទាំង ២ រូបនោះ បានកាត់នូវកាមសំយោជនៈ និងកាមពន្ធនៈ ជាចំណងរបស់មារ ដែលសត្វប្រព្រឹត្តកន្លងបានដោយកម្រ ។ ទេវបុត្តទាំងពីរអង្គនោះ បានកាត់នូវចំណងដ៏ល្អិត ដូចជាដំរី ( ផ្តាច់ខ្នើង ) ហើយប្រព្រឹត្តកន្លងនូវពួកទេវតាដែលនៅក្នុង

---

១ សំដៅយកឱវាទបដ្ឋាន ។

សឥន្ទា ទេវា សបជាបតិកា
សព្វេ សុធម្មាយ សភាយុបវិដ្ឋា ។
តេសន្និសិន្នាន(១) អតិក្កមឹសុ
វីរា(២) វិរាគា វិរជំ ករោន្តា
តេ ទិស្វា សំវេគមកាសិ វាសវោ
ទេវាភិភូ ទេវគណស្ស មជ្ឈេ ។
ឥមេ ហិ តេ ហីនកាយូបបន្នា
ទេវេ តាវតឹសេ អតិក្កមន្តិ
សំវេគជាតស្ស វចោ និសម្ម(៣)
សោ គោបកោ វាសវំ អជ្ឈភាសិ ។
ពុទ្ធោ ជនិន្ទត្ថិ(៤) មនុស្សលោកេ
កាមាភិភូ សក្យមុនីតិ ញាយតិ
តស្សេវ តេ(៥) បុត្តា សតិយា វិហីនា
ចោទិតា(៦) មយា តេ សតិ បច្ចលត្ថុំ(៧) ។

១ ម. តេសំ និសិន្នានំ ។ ២ ម. វីរ ។ ៣ ម. ឱ. សំវេគជាតស្ស វិហោ និសម្ម សោ ។ ៤ ម. ជនិន្ទត្ថិ ។ ៥ ម. តស្សេវ តេ ។ ៦ ម. ចុតា ។ ឱ. ចោទិតា ។ ៧ ម. សតិ បច្ចលត្ថុំ ។





ជាន់តាវត្តិង្ស ពួកទេវតាទាំងអស់ ព្រមទាំងព្រះឥន្ទ្រាធិរាជ និងបជាបតីទេវរាជ បានចូលទៅកាន់រោងធំ ឈ្មោះសុធម្មា ។ ទេវតាទាំងនោះ លុះប្រជុំគ្នាហើយ ក៏មិនប្រព្រឹត្តកន្លងនូវទេវបុត្រទាំងពីររូបនោះបានឡើយ ទេវបុត្រទាំងពីររូបនោះ ជាអ្នកក្លៀវក្លា ប្រាសចាករាគៈ ធ្វើនូវអនាគាមិមគ្គដែលប្រាសចាកធូលី ចំពោះទេវរាជជាធំជាងពួកទេវតា វាសវៈឃើញនូវទេវបុត្រ ទាំងពីររូបនោះហើយ ក៏ធ្វើនូវសេចក្តីសង្វេគ ក្នុងកណ្តាលនៃពួកទេវតាថា ។ ទេវបុត្រទាំងនេះ គឺ ទេវបុត្រដែលកើតក្នុងពួកគន្ធព្វ ជាអ្នកថោកទាបនោះឯង ប្រព្រឹត្តកន្លងនូវពួកទេវតា ដែលនៅក្នុងជាន់តាវត្តិង្ស ឯគោបកទេវបុត្រ លុះបានស្តាប់នូវព្រះបន្ទូល នៃវាសវទេវរាជ ដែលទ្រង់កើតសេចក្តីសង្វេគហើយ ក៏ក្រាបទូលវាសវទេវរាជថា ។ បពិត្រព្រះឥន្ទ្រ ជាធំជាងជន ព្រះពុទ្ធ ទ្រង់កើតក្នុងមនុស្សលោក ទ្រង់គ្របសង្កត់ នូវកាមបាន អ្នកផង តែងស្គាល់ព្រះនាមថា សក្យមុនី ទេវបុត្រទាំងពីររូបនោះ ជាបុត្ររបស់ព្រះអង្គ សាបសូន្យចាកឈានសតិ លុះខ្ញុំព្រះអង្គ រំលឹកដាស់តឿនហើយ ទេវបុត្រទាំងពីររូបនោះ ក៏ត្រឡប់បាន នូវឈានសតិវិញ ។

តិណ្ណំ តេសំ អាវសិនេត្ថ ឯកោ
គន្ធព្វកាយូបគតោ យសីតោ
ទ្វេ ច សម្ពោធិបថានុសារិនោ(១)
ទេវេបិ ហីឡេន្តិ សមាហិតត្តា ។
ឯតាទិសី ធម្មបកាសនេត្ថ
ន តត្ថ កឹ កង្ខតិ កោចិ សាវកោ
និត្តិណ្ណោឃំ វិចិកិច្ឆច្ឆិន្នំ
ពុទ្ធំ នមស្សាម ជិនំ ជនិន្ទំ ។
យំ តេ(២) ធម្មំ ឥធញ្ញាយ
វិសេសំ អជ្ឈគំសុ(៣) តេ
កាយំ ព្រហ្មបុរោហិតំ
ទុវេ តេសំ វិសេសគូ ។
តស្ស ធម្មស្ស បត្តិយា
អាគតម្ហាសេ(៤) មារិស
កតាវកាសា(៥) ភគវតា
បញ្ហំ បុច្ឆេមុ មារិសាតិ ។

---

១ ឱ. ទ្វេ ចេវ សម្ពោធិបថានុសារិនោ ។ ម. ទ្វេ ច សម្ពោធិបថានុសារិនោ ។ ២ ឱ. យេនេត្ថ ។ ៣ ឱ. ម. អជ្ឈគំសុ ។ ៤ ឱ. អាគតម្ហសេ ។ ម. ...សេ ។ ៥ ម. កតោកាសា ។



បណ្ដាជនទាំង ៣ នាក់នោះ ជនម្នាក់អាស្រ័យនៅក្នុងពួក ដ៏មានយស បានចូលទៅរួមក្នុងពួកគន្ធព្វ នៅក្នុងពួកគន្ធព្វនោះ ជនពីរនាក់ទៀត រលឹកឃើញនូវផ្លូវនៃសម្ពោធិញាណ គឺអនាគាមិមគ្គ ក៏ធុញទ្រាន់នឹងទេវលោក ព្រោះខ្លួនមានចិត្តប្រកបដោយសមាធិ ។ ការប្រកាសនូវធម៌ ក្នុងសាសនានេះមានសភាពដូច្នេះ បណ្ដាសាវ័កទាំងនោះ សូម្បីសាវ័កណាមួយ ក៏មិនសង្ស័យនឹងធម៌ឡើយ យើងទាំងឡាយសូមនមស្ការ នូវព្រះពុទ្ធ ព្រះអង្គឈ្នះមារ ព្រះអង្គជាធំជាងជន ទ្រង់ឆ្លងនូវឱឃៈបានហើយ កាត់បង់នូវសេចក្ដីសង្ស័យបានហើយ ។ ទេវបុត្រទាំងនោះ បានដឹងច្បាស់ នូវធម៌ណា របស់ព្រះអង្គក្នុងសាសនានេះហើយ បាននូវគុណវិសេស បណ្ដាគន្ធព្វទាំង ៣ នាក់នោះ គន្ធព្វពីរនាក់បាននូវកាយជាព្រហ្មបុរោហិត បានដល់នូវគុណវិសេស គឺមគ្គនិងផល ។ បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ យើងខ្ញុំព្រះអង្គនាំគ្នាមក ដើម្បីដល់នូវធម៌នោះ បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ បើព្រះមានព្រះភាគ ទ្រង់បើកឱកាសហើយ យើងខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរនូវប្រស្នា ។

សប្បញ្ញាសុត្តំ ភគវតោ បរិកម្មំ

[៩២] អថខោ ភគវតោ ឯតទហោសិ ធីយន្តិ វិសុទ្ធោ ខោ អយំ សក្កោ(១) យំ ការុំ មំ បញ្ញំ ពុទ្ធិ-ស្សតិ សព្វត្ថំ(២) អត្ថសញ្ញិតំយេវ ពុទ្ធិស្សតិ នោ អនត្ថ-សញ្ញិតំ យន្នូនាហំ(៣) ពុទ្ធោ ព្យាកាសេយ្យន្តិ តំ ទិព្វ-មេវ អាជានិស្សតីតិ ។ អថខោ ភគវា សក្កំ ទេវានំ-មិន្ទំ គាថាយ អជ្ឈភាសិ

ពុច្ឆ វាសវ មំ បញ្ហំ យង្កិញ្ចិ មនសិច្ឆសិ

តស្ស តស្សេវ បញ្ហស្ស អហំ អន្តំ ករោមិ តេតិ ។

បឋមភាណវារំ ។

---

១ ឱ. យក្ខោ ។ ២ ឱ. សព្វំ តំ ។ ៣ ឱ. យាគស្សាហំ ។



សក្កបញ្ហសូត្រ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះ

(៩២) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា សក្កទេវរាជនេះ ទ្រង់មានព្រះទ័យជំរះស្អាត(១) មកអស់កាលយូរ ហើយ នឹងសួរនូវប្រស្នាណាមួយ ចំពោះតថាគត ក៏សួរតែប្រស្នាដែល មានប្រយោជន៍តែម្យ៉ាង មិនមែនសួរនូវប្រស្នាដែលមិនមានប្រយោជន៍ ឡើយ មួយទៀត សក្កទេវរាជ បានសួរតថាគត ។ នឹងដោះស្រាយចំ-ពោះប្រស្នាណា សក្កទេវរាជ ក៏នឹងយល់ច្បាស់នូវប្រស្នានោះ ឆាប់ រហ័សបាន ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងសក្កទេវរាជ ជាធំជាង ទេវតាដោយបទគាថា ថា

បពិត្រ វាសវៈ មហាបពិត្រព្រះហឫទ័យ ប្រាថ្នានឹងសួរនូវ ប្រស្នាណា ចូរសួរនូវប្រស្នានោះ ចំពោះតថាគតចុះ តថាគត នឹងធ្វើនូវទីបំផុតនៃប្រស្នាទាំងនោះ ៗ ថ្វាយមហាបពិត្របាន ៗ

ចប់ បឋមភាណវារៈ ។

---

១ សក្កទេវរាជ មានចិត្តបរិសុទ្ធស្អាត តាំងពីកាលដែលយកកំណើតជាមាណពឈ្មោះ មាឃៈ ក្នុងមចលគ្រាម ក្នុងដែនមគធៈ មុនព្រេងនាល ។

(៩៣) កតាវកាសោ សក្កោ ទេវានមិន្ទោ ភគវតា ឥមំ ភគវន្តំ បឋមំ បញ្ហំ អបុច្ឆិ(១) កឹ សំយោជនា នុ ខោ មារិស ទេវា មនុស្សា អសុរា នាគា គន្ធព្វា យេ ចញ្ញេ សន្តិ បុថុកាយា តេ អវេរា អទណ្ឌា អសបត្តា អព្យាបជ្ឈា(២) វិហរេមុ អវេរិនោតិ ឥតិ ច(៣) នេសំ ហោតិ អថ ច បន សវេរា សទណ្ឌា សសបត្តា សព្យាបជ្ឈា វិហរន្តិ សវេរិនោតិ(៤) ។ ឥត្ថំ សក្កោ ទេវានមិន្ទោ ភគវន្តំ បញ្ហំ អបុច្ឆិ(៥) ។ តស្ស ភគវា បញ្ហំ បុដ្ឋោ ព្យាកាសិ ឥស្សាមច្ឆរិយសំយោជនា ខោ ទេវានមិន្ទ ទេវា មនុស្សា អសុរា នាគា គន្ធព្វា យេ ចញ្ញេ សន្តិ បុថុកាយា តេ អវេរា អទណ្ឌា

---

១ ឱ. ទេវានមិន្ទោ ភគវន្តំ ឥមំ បឋមំ បញ្ហំ បុច្ឆិ ។ ២ ឱ. អព្យាបជ្ជា ។ ម. អព្យាបជ្ជា ។ ៣ ឱ. ម. ចេ ។ ៤ ឱ. វេរិនោតិ ។ ៥ ឱ. ភគវន្តំ ឥទំ បឋមំ បញ្ហំ អបុច្ឆិ ។



(៩៣) លុះព្រះមានព្រះភាគ ទ្រង់ប្រទានឱកាសហើយ សក្កទេវរាជ ជាធំជាងពួកទេវតា ក្រាបបង្គំទូលសួរប្រស្នាជាដំបូងនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ ពួកទេវតា មនុស្ស អសុរ នាគ គន្ធព្វ ទាំងពួកជនច្រើនដទៃ ៗ មានធម៌អ្វីជាគ្រឿងចងរឹតរួបរឹតទុក បានជាពួកសត្វទាំងនោះ សូមប្រាថ្នាថា សូមឲ្យយើងទាំងឡាយ ជាអ្នកមិនមានពៀរ មិនមានអាជ្ញា មិនមានសត្រូវ មិនមានព្យាបាទ នៅដោយមិនមានពៀរនឹងគ្នា ពួកសត្វទាំងនោះ តែងមានសេចក្ដីប្រាថ្នា យ៉ាងនេះ ឯដ៏ ទោះបីមានសេចក្ដីប្រាថ្នាដូច្នោះ ក៏គង់សត្វទាំងនោះ នៅតែជាអ្នកមានពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទ នៅដោយមានពៀរនឹងគ្នាដដែល ។ សក្កទេវរាជ ជាធំជាងពួកទេវតា បានទូលសួរប្រស្នាចំពោះព្រះមានព្រះភាគហើយ ដោយប្រការដូច្នេះ ។ លុះសក្កទេវរាជនោះ បានទូលសួរប្រស្នាហើយ ព្រះមានព្រះភាគ ក៏ទ្រង់ព្យាករ ថា បពិត្រទេវានមិន្ទ ពួកទេវតា មនុស្ស អសុរ នាគ គន្ធព្វ ទាំងពួកជនច្រើនដទៃ ៗ មានឥស្សា (សេចក្ដីច្រណែន) និងមច្ឆរិយៈ (សេចក្ដីកំណាញ់) ជាគ្រឿងចងរឹតរួបរឹតទុក បានជាពួកសត្វទាំងនោះ សូមប្រាថ្នាថា សូមឲ្យយើងទាំងឡាយ ជាអ្នកមិនមានពៀរ មិនមានអាជ្ញា

អសបត្តា អព្យាបជ្ជា វិហរេមុ អវេរិនោតិ ឥតិ ច នេសំ ហោតិ អថ ច បន សវេរា សទណ្ឌា សសបត្តា សព្យាបជ្ជា វិហរន្តិ សវេរិនោតិ ។ ឥត្ថំ ភគវា សក្កស្ស ទេវានមិន្ទស្ស បញ្ហំ បុដ្ឋោ ព្យាកាសិ ។ អត្តមនោ សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ អភិនន្ទិ អនុមោទិ ឯវមេតំ ភគវា ឯវមេតំ សុគត តិណ្ណា មេត្ថ កង្ខា វិគតា កថំកថា ភគវតោ បញ្ហវេយ្យាករណំ(១) សុត្វាតិ ។

(៩៦) ឥតិហ សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ ឥស្សាមច្ឆរិយំ បន មារិស កឹនិទានំ កឹសមុទយំ កឹជាតិកំ កឹបភវំ កិស្មឹ ហិ(២) សតិ ឥស្សាមច្ឆរិយំ ហោតិ កិស្មឹ ហិ(៣) អសតិ

១ ម. បញ្ហស្ស វេយ្យាករណំ ។ ២-៣ ម. កើតិ ន្តិ ។



មិនមានសត្រូវ មិនមានព្យាបាទ នៅដោយមិនមានពៀរនឹងគ្នា ក្តី សត្វទាំងនោះ តែងមានសេចក្តីប្រាថ្នាដូច្នេះឯង ទោះបើមានសេចក្តីប្រាថ្នាដូច្នោះ ក៏គង់សត្វទាំងនោះ នៅតែជាអ្នកមានពៀរ មានអាជ្ញា មានសត្រូវ មានព្យាបាទ នៅដោយមានពៀរនឹងគ្នាដដែល ។ លុះព្រះមានព្រះភាគទ្រង់ព្យាករនូវប្រស្នា ដែលសក្កទេវេន្ទជាធំជាងទេវតាក្រាបទូលសួរដោយប្រការដូច្នេះហើយ ។ សក្កទេវេន្ទ ជាធំជាងទេវតា ក៏មានព្រះហឫទ័យត្រេកអរ រីករាយ នឹងភាសិត របស់ព្រះមានព្រះភាគ ថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ សេចក្តីសង្ស័យក្នុងប្រស្នានុ៎ះ ខ្ញុំព្រះអង្គឆ្លងផុតហើយ សេចក្តីងឿងឆ្ងល់ ក៏អស់ហើយ ព្រោះបានស្តាប់នូវបញ្ហាវេយ្យាករណ៍ របស់ព្រះមានព្រះភាគ ។

(៩៦) លុះសក្កទេវេន្ទ ជាធំជាងទេវតា ទ្រង់ត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ដូច្នោះហើយ ទើបសួរនូវប្រស្នាចំពោះព្រះមានព្រះភាគ តទៅទៀត ថា បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ សេចក្តីប្រច័ណ្ឌនិងសេចក្តីកំណាញ់ មានអ្វីជាហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ ទើបសេចក្តីប្រច័ណ្ឌ និងសេចក្តីកំណាញ់ កើតមាន កាលបើអ្វីមិនមាន

ឥស្សាមច្ឆរិយំ ន ហោតីតិ ។ ឥស្សាមច្ឆរិយំ ខោ ទេវាន-
មិន្ទ បិយាប្បិយនិទានំ បិយាប្បិយសមុទយំ បិ-
យាប្បិយជាតិកំ បិយាប្បិយបភវំ បិយាប្បិយេ សតិ(១)
ឥស្សាមច្ឆរិយំ ហោតិ បិយាប្បិយេ អសតិ ឥស្សាមច្ឆ-
រិយំ ន ហោតីតិ ។ បិយាប្បិយំ បន មារិស
កិំនិទានំ កិំសមុទយំ កិំជាតិកំ កិំបភវំ កិស្មិំ សតិ
បិយាប្បិយំ ហោតិ កិស្មិំ អសតិ បិយាប្បិយំ ន
ហោតីតិ ។ បិយាប្បិយំ ខោ ទេវានមិន្ទ ឆន្ទនិទានំ
ឆន្ទសមុទយំ ឆន្ទជាតិកំ ឆន្ទបភវំ ឆន្ទេ សតិ
បិយាប្បិយំ ហោតិ ឆន្ទេ អសតិ បិយាប្បិយំ

---

១ ម. បិយាប្បិយេហិ សតិ ។



ហើយ ទើបសេចក្តីប្រច័ណ្ឌនិងសេចក្តីកំណាញ់ ក៏មិនមានដែរ ។
ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា បពិត្រទេវានមិន្ទ សេចក្តីប្រច័ណ្ឌ
និងសេចក្តីកំណាញ់ មានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ ជាដើម
ហេតុ មានសេចក្តីស្រឡាញ់ និងសេចក្តីស្អប់នាំឲ្យកើត មានសេចក្តី
ស្រឡាញ់ និងសេចក្តីស្អប់ជាកំណើត មានសេចក្តីស្រឡាញ់និងសេចក្តី
ស្អប់បណ្តាលឲ្យកើត កាលបើសេចក្តីស្រឡាញ់ និងសេចក្តីស្អប់មាន
ហើយ ទើបសេចក្តីប្រច័ណ្ឌនិងសេចក្តីកំណាញ់ ក៏មានដែរ កាល
បើសេចក្តីស្រឡាញ់និងសេចក្តីស្អប់មិនមានហើយ សេចក្តីប្រច័ណ្ឌនិង
សេចក្តីកំណាញ់ ក៏មិនមានដែរ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះសេចក្តី
ស្រឡាញ់និងសេចក្តីស្អប់ មានអ្វីជាដើមហេតុ មានអ្វីនាំឲ្យកើត មានអ្វី
ជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ ទើបសេចក្តី
ស្រឡាញ់និងសេចក្តីស្អប់ ក៏មានដែរ កាលបើអ្វី មិនមានហើយ
សេចក្តីស្រឡាញ់និងសេចក្តីស្អប់ ក៏មិនមានដែរ ។ បពិត្រទេវានមិន្ទ
សេចក្តីស្រឡាញ់និងសេចក្តីស្អប់ មានឆន្ទៈ(សេចក្តីពេញចិត្ត) ជាដើម
ហេតុ មានឆន្ទៈនាំឲ្យកើត មានឆន្ទៈជាកំណើត មានឆន្ទៈបណ្តាល
ឲ្យកើត កាលបើឆន្ទៈមានហើយ សេចក្តីស្រឡាញ់និងសេចក្តីស្អប់ក៏មាន
ដែរ កាលបើឆន្ទៈមិនមានហើយ សេចក្តីស្រឡាញ់និងសេចក្តីស្អប់

ន ហោតីតិ ។ ឆន្ទោ បន[១] មារិស កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ កិស្មឹ សតិ ឆន្ទោ ហោតិ កិស្មឹ អសតិ ឆន្ទោ ន ហោតីតិ ។ ឆន្ទោ ខោ ទេវានមិន្ទ វិតក្កនិទានោ វិតក្កសមុទយោ វិតក្កជាតិកោ វិតក្កប្បភវោ វិតក្កេ សតិ ឆន្ទោ ហោតិ វិតក្កេ អសតិ ឆន្ទោ ន ហោតីតិ ។ វិតក្កោ បន[២] មារិស កឹនិទានោ កឹសមុទយោ កឹជាតិកោ កឹបភវោ កិស្មឹ សតិ វិតក្កោ ហោតិ កិស្មឹ អសតិ វិតក្កោ ន ហោតីតិ ។ វិតក្កោ ខោ ទេវានមិន្ទ បបញ្ចសញ្ញាសង្ខានិទានោ បបញ្ចសញ្ញាសង្ខាសមុទយោ បបញ្ចសញ្ញាសង្ខាជាតិកោ បបញ្ចសញ្ញាសង្ខាបភវោ បបញ្ចសញ្ញាសង្ខាយ សតិ វិតក្កោ ហោតិ បបញ្ចសញ្ញាសង្ខាយ អសតិ វិតក្កោ ន ហោតីតិ ។

១ ម. ឆន្ទោ ខោ បន ។ ២ ម. វិតក្កោ ខោ បន ។



ក៏មិនមានដែរ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះឆន្ទៈ មានអ្វីជាដើមហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ ឆន្ទៈក៏មានដែរ កាលបើអ្វីមិនមានហើយ ឆន្ទៈក៏មិនមានដែរ ។ បពិត្រទេវានមិន្ទ ឆន្ទៈ មានវិតក្កៈ (សេចក្តីត្រិះរិះ) ជាដើមហេតុ មានវិតក្កៈនាំឲ្យកើត មានវិតក្កៈជាកំណើត មានវិតក្កៈបណ្តាលឲ្យកើត កាលបើវិតក្កៈមានហើយ ឆន្ទៈក៏មានដែរ កាលបើវិតក្កៈមិនមានហើយ ឆន្ទៈក៏មិនមានដែរ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ ចុះវិតក្កៈ មានអ្វីជាដើមហេតុ មានអ្វីនាំឲ្យកើត មានអ្វីជាកំណើត មានអ្វីបណ្តាលឲ្យកើត កាលបើអ្វីមានហើយ វិតក្កៈក៏មានដែរ កាលបើអ្វីមិនមានហើយ វិតក្កៈក៏មិនមានដែរ ។ បពិត្រទេវានមិន្ទ វិតក្កៈ មានចំណែកនៃបបញ្ចសញ្ញា (សេចក្តីសម្គាល់ប្រកបដោយធម៌ជាគ្រឿងឲ្យយឺតយូរ[១]) ជាដើមហេតុ មានចំណែកនៃបបញ្ចសញ្ញានាំឲ្យកើត មានចំណែកនៃបបញ្ចសញ្ញាជាកំណើត មានចំណែកនៃបបញ្ចសញ្ញាបណ្តាលឲ្យកើត កាលបើចំណែកនៃបបញ្ចសញ្ញាមានហើយ វិតក្កៈក៏មានដែរ កាលបើចំណែកនៃបបញ្ចសញ្ញា មិនមានហើយ វិតក្កៈក៏មិនមានដែរ ។

១ សំរាយមើលក្នុងលើកទាំង ១០៨ ។

(៩៨) កថំបដិបន្នោ បន មារិស ភិក្ខុ បបញ្ចសញ្ញាសង្ខានិរោធសារុប្បគាមិនីបដិបទំ បដិបន្នោ ហោតីតិ ។ សោមនស្សំ បាហំ(១) ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ ទោមនស្សំ បាហំ(២) ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ ឧបេក្ខំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ ។ សោមនស្សំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ។ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា សោមនស្សំ ឥមំ ខោ មេ សោមនស្សំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ សោមនស្សំ ន សេវិតព្វំ ។ តត្ថ

១-២ ម. បហំ ។ ឱ. បាហំ ។



(៩៨) បពិត្រព្រះអង្គ ព្រះនិទ្ទុក្ខ ចុះភិក្ខុប្រតិបត្តិយ៉ាងណា ទើបឈ្មោះថា ជាអ្នកប្រតិបត្តិ នូវបដិបទាជាដំណើរដ៏សមគួរដល់សេចក្តីរលត់នូវចំណែកនៃបបញ្ចសញ្ញា ។ បពិត្រទេវានមិន្ទ តថាគតសំដែង ថា សោមនស្ស មាន ២ យ៉ាង គឺ សោមនស្ស គួរសេពគប់ ក៏មាន មិនគួរសេពគប់ ក៏មាន បពិត្រទេវានមិន្ទ តថាគតសំដែងថា ទោមនស្ស មាន ២ យ៉ាង គឺ ទោមនស្ស គួរសេពគប់ ក៏មាន មិនគួរសេពគប់ ក៏មាន បពិត្រទេវានមិន្ទ តថាគតសំដែងថា ឧបេក្ខា មាន ២ យ៉ាង គឺ ឧបេក្ខា គួរសេពគប់ ក៏មាន មិនគួរសេពគប់ ក៏មាន ។ ចុះពាក្យថា បពិត្រទេវានមិន្ទ តថាគត សំដែងថា សោមនស្ស មាន ២ យ៉ាង គឺ សោមនស្ស គួរសេពគប់ ក៏មាន មិនគួរសេពគប់ ក៏មាន ដូច្នេះ តថាគតបាននិយាយហើយ ពាក្យដែលតថាគតនិយាយមកយ៉ាងនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាសោមនស្សទាំងពីរប្រការនោះ ភិក្ខុដឹងច្បាស់ នូវសោមនស្សណាថា កាលបើអាត្មាអញ សេពគប់នូវសោមនស្សនេះ អកុសលធម៌ទាំងឡាយ រមែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ ដូច្នេះ សោមនស្សបែបនេះ(១) ភិក្ខុមិនគួរសេពគប់ ។ បណ្តា

១ សំដៅយកគេហសិតសោមនស្ស គឺសោមនស្សអាស្រ័យនូវផ្ទះ គឺ កាមគុណទាំង ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

យំ ជញ្ញា សោមនស្សំ ឥមំ ខោ មេ សោមនស្សំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ សោមនស្សំ សេវិតព្វំ ។ តត្ថ យញ្ចេ សវិតក្កំ សវិចារំ យញ្ចេ អវិតក្កំ អវិចារំ យេ អវិតក្កា អវិចារា បណីតតរា(១) ។ សោមនស្សំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ទោមនស្សំ បាហំ(២) ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ។ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

១ ឱ. អវិចារេ តេ បណីតតរេ ។ ម. អវិចារេ តេ បណីតតរេ ។ ២ ឱ. បហំ ។ ម. បាហំ ។



សោមនស្សទាំងពីរប្រការនោះ តថាគតដឹងច្បាស់នូវសោមនស្សណាថា កាលបើតថាគត សេពគប់នូវសោមនស្សនេះហើយ អកុសលធម៌ទាំងឡាយរិតតែសាបសូន្យទៅ កុសលធម៌ទាំងឡាយ រិតតែចំរើនឡើង ដូច្នេះ សោមនស្សបែបនេះ(១) តថាគតគួរសេពគប់ ។ ក្នុងសោមនស្សគួរសេពគប់នោះ សោមនស្សដែលមានវិតក្កៈ វិចារៈក៏មាន(២) សោមនស្សដែលមិនមានវិតក្កៈ មិនមានវិចារៈក៏មាន(៣) សោមនស្សណា ដែលមិនមានវិតក្កៈ មិនមានវិចារៈ សោមនស្សនោះ ប្រសើរជាង ។ ពាក្យដែលថា បពិត្រទេវានមិន្ទ តថាគតសំដែងថា សោមនស្ស មាន ២ យ៉ាង គឺ សោមនស្ស គួរសេពគប់ក៏មាន មិនគួរសេពគប់ក៏មាន ដូច្នេះ តថាគតបានពោលហើយ ពាក្យនោះដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា ទោមនស្សមានពីរយ៉ាង គឺ ទោមនស្សគួរសេពក៏មាន មិនគួរសេពក៏មាន ដូច្នេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមកយ៉ាងនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ?

១ សំដៅយកនេក្ខម្មសិតសោមនស្ស គឺសេចក្ដីត្រេកអរអាស្រ័យនូវនេក្ខម្មៈ គឺការចេញចាកកាមគុណទាំង៥ របស់បុគ្គលដែលប្រកបដោយវិបស្សនា ។ ២ បានដល់សោមនស្សដែលកើតដោយអំណាចនេក្ខម្មៈ វិបស្សនា អនុស្សតិ និងបឋមជ្ឈាន ។ ៣ បានដល់សោមនស្សដែលកើតដោយអំណាចទុតិយជ្ឈាន និងតតិយជ្ឈាន ។

តត្ថ យំ ជញ្ញា ទោមនស្សំ ឥមំ ខោ មេ ទោមនស្សំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ ទោមនស្សំ ន សេវិតព្វំ ។ តត្ថ យំ ជញ្ញា ទោមនស្សំ ឥមំ ខោ មេ ទោមនស្សំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបំ ទោមនស្សំ សេវិតព្វំ ។ តត្ថ យញ្ចេ[១] សវិតក្កំ សវិចារំ យញ្ចេ[២] អវិតក្កំ អវិចារំ យេ អវិតក្កា អវិចារា តេ បណីតតរា ។

១-២ ឱ. យំ ចេ ។



ព្រោះថា បណ្ដាទោមនស្សទាំងពីរនោះ ភិក្ខុគប្បីដឹងច្បាស់នូវទោមនស្សណាថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុសលធម៌ទាំងឡាយតែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅដូច្នេះ ទោមនស្សបែបនេះ[១] ភិក្ខុមិនគួរសេព ។ បណ្ដាទោមនស្សទាំងពីរប្រការនោះ ភិក្ខុក៏ដឹងច្បាស់ នូវទោមនស្សណាថា កាលបើអាត្មាអញសេពនូវទោមនស្សនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង ដូច្នេះ ទោមនស្សបែបនេះ[២] ភិក្ខុគួរសេព ។ ក្នុងទោមនស្សដែលគួរសេពនោះ ទោមនស្សដែលមានវិតក្កៈវិចារៈ[៣] ក៏មាន ទោមនស្សដែលមិនមានវិតក្កៈវិចារៈ[៤] ក៏មាន ទោមនស្សណា ដែលមានវិតក្កៈវិចារៈ ទោមនស្សនោះប្រសើរជាង ។

១ សំដៅយកគេហសិតទោមនស្ស គឺទោមនស្សអាស្រ័យនូវផ្ទះ គឺ កាមគុណទាំង ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ របស់បុគ្គលដែលមិនបានទទួលនូវអារម្មណ៍ជាទីគាប់ចិត្ត ។ ២ សំដៅយកនេក្ខម្មសិតទោមនស្ស គឺទោមនស្សដែលអាស្រ័យនូវនេក្ខម្មៈ ដែលកើតឡើងដល់បុគ្គលដែលទទួលគន់ចិត្ត ព្រោះហេតុតែប្រាថ្នាសម្រេចនូវអរិយភូមិ ។ ៣ បានដល់ទោមនស្សដែលកើតដោយអំណាចនេក្ខម្មៈ វិបស្សនា អនុស្សតិ និងបឋមជ្ឈាន ។ ៤ បានដល់ទោមនស្សដែលកើតឡើងដល់បុគ្គលដែលប្រកបដោយវិបស្សនា ប្រាថ្នានូវអរហត្តផល បើទុកជាប្រឹងប្រែងប៉ុនណា ក៏នៅតែមិនសម្រេចនូវបំណង ។

ទោមនស្សំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិ-
តព្វម្បិ អសេវិតព្វម្បីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច
វុត្តំ ។ ឧបេក្ខំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិ-
តព្វម្បិ អសេវិតព្វម្បីតិ ។ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ
បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា ឧបេក្ខំ ឥមំ ខោ មេ
ឧបេក្ខំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា
ធម្មា បរិហាយន្តីតិ ឯវរូបា ឧបេក្ខា ន សេវិតព្វា ។
តត្ថ យំ ជញ្ញា ឧបេក្ខំ ឥមំ ខោ មេ ឧបេក្ខំ
សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា
ធម្មា អភិវឌ្ឍន្តីតិ ឯវរូបា ឧបេក្ខា សេវិតព្វា ។



ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគត សំដែងថា ទោមនស្ស មាន ២ យ៉ាង គឺ ទោមនស្ស គួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគត សំដែងថា ឧបេក្ខា មាន ២ យ៉ាង គឺ ឧបេក្ខា គួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមក យ៉ាងនេះ តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាឧបេក្ខាទាំងពីរប្រការនោះ ភិក្ខុដឹងច្បាស់នូវឧបេក្ខាណា ថា កាលបើអាត្មាអញ សេពនូវឧបេក្ខានេះ អកុសលធម៌ទាំងឡាយ រមែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ ដូច្នេះ ឧបេក្ខាបែបនេះ ភិក្ខុមិនគួរសេព(១) ។ បណ្តាឧបេក្ខាទាំងពីរប្រការនោះ ភិក្ខុដឹងច្បាស់នូវឧបេក្ខាណា ថា កាលបើអាត្មាអញសេពនូវឧបេក្ខានេះ អកុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ រមែងចម្រើនដុះដាលឡើង ដូច្នេះ ឧបេក្ខាបែបនេះ ភិក្ខុគួរសេព(២) ។

១ បានដល់គេហសិតឧបេក្ខា គឺឧបេក្ខាដែលអាស្រ័យនូវផ្ទះគឺកាមគុណ កើតឡើងដល់បុគ្គលដែលល្ងង់ខ្លៅ ក៏ដាប់ស្អិតក្នុងអារម្មណ៍ មិនមានត្រឡប់ចិត្តក្រោយវិញ ដូចរុយដែលជាប់ចិត្តនឹងស្ករអំពៅ ។ ២ បានដល់នេក្ខម្មសិតឧបេក្ខា គឺ ឧបេក្ខាដែលសម្បយុត្តដោយវិបស្សនាញាណ មិនត្រេកអរនឹងឥដ្ឋារម្មណ៍ មិនស្អប់អនិដ្ឋារម្មណ៍ ។

តត្ថ យញ្ចេ សវិតក្កំ សវិចារំ យញ្ចេ អវិតក្កំ អវិចារំ

យេ អវិតក្កេ អវិចារេ តេ បណីតតរេ ។ ឧបេក្ខំ បាហំ

ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្ពម្បិ អសេវិតព្ពម្បីតិ ។

ឥតិ យំ តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឯវំ បដិបន្នោ

ខោ ទេវានមិន្ទ ភិក្ខុ បបញ្ចសញ្ញាសង្ខានិរោធសា-

រុប្បគាមិនីបដិបទំ បដិបន្នោ ហោតីតិ ។ ឥត្ថំ ភគវា

សក្កស្ស ទេវានមិន្ទស្ស បញ្ហំ បុដ្ឋោ ព្យាកាសិ ។

អត្តមនោ សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ

អភិនន្ទិ អនុមោទិ ឯវមេតំ ភគវា ឯវមេតំ សុគត

តិណ្ណា មេត្ថ កង្ខា វិគតា កថំកថា ភគវតោ

បញ្ហាព្យាករណំ សុត្វាតិ ។



ក្នុងឧបេក្ខាដែលគួរសេពនោះ ឧបេក្ខាដែលមានវិតក្កៈ វិចារៈ(១) ក៏មាន ឧបេក្ខាដែលមិនមានវិតក្កៈ វិចារៈ(២) ក៏មាន ឧបេក្ខាណា ដែលមិនមានវិតក្កៈវិចារៈ ឧបេក្ខានោះប្រសើរជាង ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា ឧបេក្ខា មាន ២ យ៉ាង គឺ ឧបេក្ខាគួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ បពិត្រទេវានមិន្ទ ភិក្ខុ លុះតែប្រតិបត្តិយ៉ាងនេះឯង ទើបឈ្មោះថា ជាអ្នកប្រតិបត្តិនូវបដិបទា ជាដំណើរដ៏សមគួរ ដល់សេចក្ដីរលត់ នូវចំណែកនៃបបញ្ចសញ្ញា ។ ព្រះមានព្រះភាគ ទ្រង់ព្យាករនូវប្រស្នា ដែលសក្កទេវិន្ទ ជាធំជាងពួកទេវតា ទូលសួរហើយ ដោយប្រការដូច្នេះ ។ សក្កទេវិន្ទ ជាធំជាងពួកទេវតា ក៏មានព្រះហឫទ័យ ត្រេកអរ រីករាយ នូវភាសិតរបស់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ សេចក្ដីសង្ស័យក្នុងប្រស្នានុ៎ះ ខ្ញុំព្រះអង្គបានឆ្លងផុតហើយ សេចក្ដីងឿងឆ្ងល់ក៏អស់ហើយ ព្រោះបានស្ដាប់នូវបញ្ហាព្យាករណ៍របស់ព្រះមានព្រះភាគ ។

---

១ បានដល់ឧបេក្ខា ដែលកើតដោយសម្មសនវិបស្សនា អនុស្សតិ និងបឋមជ្ឈាន ។

២ បានដល់ឧបេក្ខា ដែលកើតដោយគំណាបលាភ មានទុតិយជ្ឈានជាដើម ។

[៩២] ឯត្តាវតា សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ កថំ បដិបន្នោ បន មារិស ភិក្ខុ បាតិមោក្ខសំវរាយ បដិបន្នោ ហោតីតិ ។ កាយសមាចារំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ វចីសមាចារំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ បរិយេសនំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបិ ។ កាយសមាចារំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា កាយសមាចារំ ឥមំ ខោ មេ កាយសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ



[៩៦] លុះសក្កទេវរាជ ជាធំជាងពួកទេវតា ត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ដូច្នេះហើយ ទើបក្រាបទូលសួរនូវប្រស្នាតទៅទៀត ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គ ដ៏និទ្ទុក្ខ ចុះភិក្ខុប្រតិបត្តិដូចម្តេច ឈ្មោះថាអ្នកប្រតិបត្តិ ដើម្បីសង្រួមក្នុងបាតិមោក្ខ ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា កាយសមាចារ (មារយាទផ្លូវកាយ) មាន២ យ៉ាង គឺ កាយសមាចារ គួរសេព ក៏មាន មិនគួរសេព ក៏មាន បពិត្រទេវានមិន្ទ តថាគតសំដែងថា វចីសមាចារ (មារយាទផ្លូវវាចា) មាន២ យ៉ាង គឺ វចីសមាចារ ដែលគួរសេព ក៏មាន មិនគួរសេព ក៏មាន បពិត្រទេវានមិន្ទ តថាគតសំដែងថា បរិយេសនា (ការស្វែងរក) មាន ២ យ៉ាង គឺ បរិយេសនា គួរសេព ក៏មាន មិនគួរសេព ក៏មាន ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា កាយសមាចារ មាន២ យ៉ាង គឺ កាយសមាចារ គួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះ តថាគតបានពោលហើយ ពាក្យដែលតថាគត ពោលមកយ៉ាងនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាកាយសមាចារ ទាំង ២ ប្រការនោះ ភិក្ខុពឹងដឹងច្បាស់ នូវកាយសមាចារណា ថា កាលបើអាត្មាអញ សេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែង

កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ កាយសមាចារោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា កាយសមាចារំ ឥមំ ខោ មេ កាយសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ កាយសមាចារោ សេវិតព្វោ ។ កាយសមាចារំ តាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ វចីសមាចារំ តាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ។ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។





សាបសូន្យទៅ ដូច្នេះ កាយសមាចារបែបនេះ ភិក្ខុមិនគួរសេព(១) ។ បណ្ដាកាយសមាចារ ទាំង ២ ប្រការនោះ ភិក្ខុដឹងច្បាស់ នូវកាយសមាចារណាថា កាលបើអាត្មាអញសេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ រមែងចំរើនដុះដាលឡើង ដូច្នេះ កាយសមាចារបែបនេះ ភិក្ខុគួរសេព(២) ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា កាយសមាចារ មាន ២ យ៉ាង គឺ កាយសមាចារ គួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ចុះត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា វចីសមាចារ មាន ២ យ៉ាង គឺ វចីសមាចារ ដែលគួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះនេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមក យ៉ាងនេះ តើព្រោះអាស្រ័យហេតុអ្វី ។

១ ការប្រព្រឹត្តនូវបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ និងការប្រព្រឹត្តល្មើសសិក្ខាបទដែលបញ្ញត្តិទុក ចំពោះកាយទ្វារ ហៅថា កាយសមាចារ ដែលមិនគួរសេព ។ ២ ការវៀរចាកអំពើមិនល្អ មានបាណាតិបាតជាដើម ចំពោះកាយទ្វារ ហៅថា កាយសមាចារ គួរសេព ។

តត្ថ យំ ជញ្ញា កាយសមាចារំ ឥមំ ខោ មេ កាយសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ កាយសមាចារោ ន សេវិតព្វោ ។ តត្ថ យំ ជញ្ញា កាយសមាចារំ ឥមំ ខោ មេ កាយសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបោ កាយសមាចារោ សេវិតព្វោ ។ កាយសមាចារំ ពាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ បរិយេសនំ ពាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វំបិ អសេវិតព្វំបីតិ ។ ឥតិ ខោ បនេតំ





ព្រោះថា បណ្ដាកាយសមាចារ ទាំងពីរប្រការនោះ ភិក្ខុដឹងច្បាស់ នូវកាយសមាចារណាថា កាលបើអាត្មាអញ សេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយ តែងចំរើន ផុះផុលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ កាយសមាចារបែបនេះ ភិក្ខុមិនគួរសេព(១) ។ បណ្ដាកាយសមាចារទាំង២ប្រការនោះ ភិក្ខុដឹងច្បាស់ នូវកាយសមាចារណាថា កាលបើអាត្មាអញ សេពនូវកាយសមាចារនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចំរើនផុះផុលឡើង ដូច្នេះ កាយសមាចារបែបនេះ ភិក្ខុគួរសេព(២) ។ ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា កាយសមាចារ មាន២យ៉ាង គឺ កាយសមាចារគួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះ តថាគតពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា បរិយេសនា មាន ២យ៉ាង គឺ បរិយេសនា គួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះ

---

១ កាយទុច្ចរិត ៣ យ៉ាង មានបាណាតិបាតជាដើម និងការប្រព្រឹត្តខុសក្នុងសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តហើយ ចំពោះភិក្ខុ ហៅថា កាយសមាចារដែលមិនគួរសេព ។ ២ ការវៀរចាកកាយទុច្ចរិត ៣ យ៉ាង មិនប្រព្រឹត្តខុសក្នុងសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តហើយចំពោះភិក្ខុ ហៅថា កាយសមាចារដែលគួរសេព ។

វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្ថ យំ ជញ្ញា បរិយេសនំ ឥមំ ខោ មេ បរិយេសនំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបា បរិយេសនា ន សេវិតព្វា ។ តត្ថ យំ ជញ្ញា បរិយេសនំ ឥមំ ខោ មេ បរិយេសនំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបា បរិយេសនា សេវិតព្វា ។ បរិយេសនំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឯវំ បដិបន្នោ ខោ ទេវានមិន្ទ ភិក្ខុ បាតិមោក្ខសំវរាយ បដិបន្នោ ហោតីតិ ។



នេះ តថាគតបានពោលហើយ ពាក្យដែលតថាគតពោលមក យ៉ាងនុ៎ះ តើព្រោះអាស្រ័យហេតុអ្វី ។ ព្រោះថា បណ្តាបរិយេសនាទាំងពីរប្រការនោះ ភិក្ខុដឹងច្បាស់ នូវបរិយេសនាណាថា កាលបើអាត្មាអញ សេព នូវបរិយេសនានេះ អកុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ ដូច្នេះ បរិយេសនាបែបនេះ ភិក្ខុមិនគួរសេព(១) ។ បណ្តាបរិយេសនាទាំងពីរប្រការនោះ ភិក្ខុដឹងច្បាស់ នូវបរិយេសនាណា ថា កាលបើអាត្មាអញ សេព នូវបរិយេសនានេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចម្រើនដុះដាលឡើង ដូច្នេះ បរិយេសនាបែបនេះ ភិក្ខុគួរសេព(២) ។ ក៏ត្រង់ពាក្យថា បពិត្រទេវានមិន្ទ តថាគតសំដែងថា បរិយេសនា មានពីរយ៉ាង គឺ បរិយេសនា គួរសេព ក៏មាន មិនគួរសេព ក៏មាន ដូច្នេះ នេះ តថាគតបានពោលហើយ ពាក្យនោះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះឯង ។ បពិត្រទេវានមិន្ទ ភិក្ខុអ្នកប្រតិបត្តិយ៉ាងនេះ ទើបឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីសេចក្តីសង្រួមក្នុងបាតិមោក្ខ ។

---

១ បានដល់អនរិយបរិយេសនា ការស្វែងរកមិនប្រសើរ គឺការស្វែងរកបុត្រ ភរិយា ប្រាក់ ជាដើម ។ ២ បានដល់អរិយបរិយេសនា ការស្វែងរកដ៏ប្រសើរ គឺការស្វែងរកព្រះនិព្វាន ។

(៤៧) កថំ បដិបន្នោ(១) បន មារិស ភិក្ខុ ឥន្ទ្រិយសំវរាយ បដិបន្នោ ហោតីតិ ។ ចក្ខុវិញ្ញេយ្យំ រូបំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ(២) ។ សោតវិញ្ញេយ្យំ សទ្ទំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ ។ ឃានវិញ្ញេយ្យំ គន្ធំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ ។ ជិវ្ហាវិញ្ញេយ្យំ រសំ បាហំ ទេវានមិន្ទ ។ បេ ។ កាយវិញ្ញេយ្យំ ផោដ្ឋព្វំ បាហំ ទេវានមិន្ទ ។ បេ ។ មនោវិញ្ញេយ្យំ ធម្មំ បាហំ ទេវានមិន្ទ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បីតិ ។ ឯវំ វុត្តេ សក្កោ ទេវានមិន្ទោ ភគវន្តំ ឯតទវោច ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ

១ ម. កថំ ភគវា សក្កស្ស ទេវានមិន្ទស្ស បញ្ហំ បុដ្ឋោ វ្យាកាសិ ។ អត្ថតោ សព្វោ ... អបុព្វំ ។ កថំបដិបន្នោតិ ទិស្សតិ ។ ឧ. កថំ ភគវា ។ បេ ។ កថំបដិបន្នោតិ ទិស្សតិ ។ ២ ម. សព្វត្ថ អសេវិតព្វម្បីតិ ទិស្សតិ ។





(៤៧) បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ ចុះភិក្ខុប្រតិបត្តិដូចម្តេច ទើបឈ្មោះថាជាអ្នកប្រតិបត្តិ ដើម្បីសេចក្តីសង្រួមនូវឥន្ទ្រិយ ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា រូបារម្មណ៍ ដែលគួរដឹងច្បាស់ដោយភ្នែក មាន ២ យ៉ាង គឺរូបារម្មណ៍ ដែលគួរសេពក៏មាន មិនគួរសេពក៏មាន ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា សទ្ទារម្មណ៍ ដែលគួរដឹងច្បាស់ដោយត្រចៀក មាន ២ យ៉ាង គឺ សទ្ទារម្មណ៍ ដែលគួរសេព ក៏មាន មិនគួរសេព ក៏មាន ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា គន្ធារម្មណ៍ ដែលគួរដឹងច្បាស់ដោយច្រមុះ មាន ២ យ៉ាង គឺ គន្ធារម្មណ៍ ដែលគួរសេព ក៏មាន មិនគួរសេព ក៏មាន ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា រសារម្មណ៍ ដែលគួរដឹងច្បាស់ដោយអណ្តាត ។ បេ ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា ផោដ្ឋព្វារម្មណ៍ ដែលគួរដឹងច្បាស់ដោយកាយ ។ បេ ។ បពិត្រទេវានមិន្ទ តថាគតសំដែងថា ធម្មារម្មណ៍ ដែលគួរដឹងច្បាស់ដោយចិត្ត មាន ២ យ៉ាង គឺ ធម្មារម្មណ៍ ដែលគួរសេព ក៏មាន មិនគួរសេព ក៏មាន ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សក្កទេវានមិន្ទ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះមានព្រះភាគទ្រង់សំដែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គ តាមដឹងសេចក្តីច្បាស់ ដោយពិស្តារយ៉ាងនេះបាន

អាជានាមិ យថារូបំ ភន្តេ ចក្ខុវិញ្ញេយ្យំ រូបំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបំ ចក្ខុវិញ្ញេយ្យំ រូបំ ន សេវិតព្វំ ។ យថារូបញ្ច ខោ ភន្តេ ចក្ខុវិញ្ញេយ្យំ រូបំ ន សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តីតិ ឯវរូបំ ចក្ខុវិញ្ញេយ្យំ រូបំ សេវិតព្វំ ។ យថារូបញ្ច ខោ ភន្តេ[១] សោតវិញ្ញេយ្យំ សទ្ទំ សេវតោ ។ បេ ។ ឃានវិញ្ញេយ្យំ គន្ធំ សេវតោ ។ បេ ។ ជិវ្ហាវិញ្ញេយ្យំ រសំ សេវតោ ។ បេ ។ កាយវិញ្ញេយ្យំ ផោដ្ឋព្វំ សេវតោ ។ បេ ។ មនោវិញ្ញេយ្យំ ធម្មំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តីតិ ឯវរូបោ មនោវិញ្ញេយ្យោ ធម្មោ ន សេវិតព្វោ ។

១ ម. យថារូបំ ច ខោ ភន្តេ ។



បពិត្រព្រះអង្គដ៏ចំរើន កាលបើភិក្ខុសេព រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកបែបណា អកុសលធម៌ទាំងឡាយ រមែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ រូបារម្មណ៍ ដែលគួរដឹងច្បាស់ដោយភ្នែកបែបនេះ ភិក្ខុមិនគួរសេពទេ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កាលបើភិក្ខុសេព រូបារម្មណ៍ដែលគួរដឹងច្បាស់ដោយភ្នែកបែបណា អកុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ រមែងចំរើនដុះដាលឡើង រូបារម្មណ៍ ដែលគួរដឹងច្បាស់ដោយភ្នែកបែបនេះ ភិក្ខុគួរសេព ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កាលបើភិក្ខុសេព សទ្ទារម្មណ៍ដែលគួរដឹងច្បាស់ដោយត្រចៀកបែបណា ។ បេ ។ កាលបើភិក្ខុសេពគន្ធារម្មណ៍ដែលគួរដឹងច្បាស់ដោយច្រមុះ ។ បេ ។ កាលបើភិក្ខុសេពរសារម្មណ៍ដែលគួរដឹងច្បាស់ដោយអណ្តាត ។ បេ ។ កាលបើបើភិក្ខុសេពផោដ្ឋព្វារម្មណ៍ដែលគួរដឹងច្បាស់ដោយកាយ ។ បេ ។ កាលបើភិក្ខុសេពធម្មារម្មណ៍ដែលគួរដឹងច្បាស់ដោយចិត្ត អកុសលធម៌ទាំងឡាយ រមែងចំរើនដុះដាលឡើង កុសលធម៌ទាំងឡាយ រមែងសាបសូន្យទៅ ធម្មារម្មណ៍ដែលគួរដឹងច្បាស់ដោយចិត្តបែបនេះ ភិក្ខុមិនគួរសេពទេ ។

យថារូបញ្ច ខោ ភន្តេ មនោវិញ្ញេយ្យំ ធម្មំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ មនោវិញ្ញេយ្យោ ធម្មោ សេវិតព្វោ ។ ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ(១) តិណ្ណា មេត្ថ កង្ខា វិគតា កថំកថា ភគវតោ បញ្ហាវេយ្យាករណំ សុត្វាតិ ។

[៤៨] ឥតិហ សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ អបុច្ឆិ សព្វេវ នុ ខោ មារិស សមណព្រាហ្មណា ឯកន្តវាទា ឯកន្តសីលា ឯកន្តច្ឆន្ទា ឯកន្តអជ្ឈោសានាតិ ។ ន ខោ ទេវានមិន្ទ សព្វេ សមណព្រាហ្មណា ឯកន្តវាទា ឯកន្តសីលា ឯកន្តច្ឆន្ទា ឯកន្តអជ្ឈោសានាតិ ។ កស្មា បន មារិស

១ ឱ. ម. អាជានោ ។



បពិត្រព្រះអង្គដ៏ចំរើន មួយវិញទៀត កាលបើភិក្ខុសេព នូវធម្មារម្មណ៍ ដែលគួរដឹងច្បាស់ដោយចិត្តបែបណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យទៅ កុសលធម៌ទាំងឡាយ តែងចំរើនដុះដាលឡើង ធម្មារម្មណ៍ ដែលគួរដឹងច្បាស់ដោយចិត្តបែបនេះ ភិក្ខុគួរសេព ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេបនេះ ខ្ញុំព្រះអង្គ តែងដឹងសេចក្ដីច្បាស់ដោយពិស្ដារ យ៉ាងនេះបាន សេចក្ដីសង្ស័យក្នុងប្រស្នានុះ ខ្ញុំព្រះអង្គ បានឆ្លងផុតហើយ សេចក្ដីងឿងឆ្ងល់ ក៏អស់ហើយ ព្រោះបានស្ដាប់នូវបញ្ហាវេយ្យាករណ៍ របស់ព្រះមានព្រះភាគ ។

[៤៨] លុះសក្កទេវរាជ ជាធំជាងទេវតាទាំងឡាយ ត្រេកអររីករាយ នឹងភាសិត របស់ព្រះមានព្រះភាគ យ៉ាងនេះហើយ ក៏ក្រាបបង្គំទូលសួរនូវប្រស្នាតទៅ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ ចុះពួកសមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែជាអ្នកមានវាទៈដូចគ្នា មានមារយាទដូចគ្នា មានឆន្ទៈគឺលទ្ធិដូចគ្នា មានសេចក្ដីចូលចិត្តដូចគ្នាឬ ។ បពិត្រទេវរាជ ពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនមានវាទៈដូចគ្នាទេ មិនមែនមានមារយាទដូចគ្នាទេ មិនមែនមានឆន្ទៈគឺលទ្ធិដូចគ្នាទេ មិនមែនមានសេចក្ដីចូលចិត្តដូចគ្នាទេ ។ បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ ចុះហេតុអ្វី

ន សព្វេ សមណព្រាហ្មណា ឯកន្តវាទា ឯកន្តសីលា ឯកន្តច្ឆន្ទា ឯកន្តអជ្ឈោសានាតិ ។ អនេកធាតុ នានាធាតុ ខោ ទេវានមិន្ទ លោកោ តស្មឹ អនេកធាតុនានាធាតុស្មឹ(១) លោកេ យំ យទេវ សត្តា ធាតុំ អភិនិវិសន្តិ តំ តទេវ ថាមសា បរាមាសា(២) អភិនិវិស្ស វោហរន្តិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ តស្មា ន សព្វេ សមណព្រាហ្មណា ឯកន្តវាទា ឯកន្តសីលា ឯកន្តច្ឆន្ទា ឯកន្តអជ្ឈោសានាតិ(៣) ។ បេ ។

(៩៩) សព្វេ វ នុ ខោ មារិស សមណព្រាហ្មណា អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានាតិ ។ ន ខោ ទេវានមិន្ទ សព្វេ សមណព្រាហ្មណា អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមី

១ ម. ឧ. អនេកធាតុ នានាធាតុស្មឹ ។ ២ ម. បរាមស្ស ។ ៣ ឧ. ម. ឯកន្តអជ្ឈោសានាតិ ។ បេ ។ ន ទិស្សតិ ។



ពុំមែនជាពួកសមណព្រាហ្មណ៍ទាំងអស់ មានវាទៈមិនខុសគ្នា មានមារយាទមិនខុសគ្នា មានឆន្ទៈគឺលទ្ធិមិនខុសគ្នា មានសេចក្ដីចូលចិត្តមិនខុសគ្នា ។ បពិត្រទេវានមិន្ទ លោកគឺពពួកសត្វ មានធាតុ គឺអធ្យាស្រ័យច្រើនពន់ពេក មានធាតុផ្សេងៗគ្នា ក្នុងលោក ដែលមានធាតុច្រើន មានធាតុផ្សេងៗគ្នានោះ សត្វទាំងឡាយ ប្រកាន់មាំនូវធាតុគឺអធ្យាស្រ័យណាៗ ក៏ប្រកាន់មាំ នូវធាតុគឺអធ្យាស្រ័យនោះៗ ដោយកម្លាំងនៃទិដ្ឋិនិងការស្ទាបអង្អែល រមែងពោលនូវពាក្យនេះ ថាជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ឥតប្រយោជន៍ ព្រោះហេតុនោះ ពុំមែនជាពួកសមណព្រាហ្មណ៍ទាំងអស់ មានវាទៈមិនខុសគ្នា មានមារយាទមិនខុសគ្នា មានឆន្ទៈគឺលទ្ធិមិនខុសគ្នា មានសេចក្ដីចូលចិត្តមិនខុសគ្នា ។ បេ ។

(៩៩) បពិត្រព្រះអង្គ ដ៏និទ្ទុក្ខ ចុះពួកសមណព្រាហ្មណ៍ទាំងអស់ សុទ្ធតែមានសេចក្ដីសម្រេច គឺព្រះនិព្វានទៀងប្រាកដ មានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ប្រសើរ គឺអរិយមគ្គទៀងប្រាកដ ជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀងប្រាកដឬ ។ បពិត្រទេវានមិន្ទ សមណព្រាហ្មណ៍ ទាំងអស់ មិនមែនសុទ្ធតែមានសេចក្ដីសម្រេចគឺព្រះនិព្វានទៀងប្រាកដទេ មិនមែនមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀងប្រាកដទេ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ប្រសើរ គឺអរិយមគ្គ

អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានាតិ ។ តស្មា ឥធ មារិស ន សព្វេ សមណព្រាហ្មណា អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានាតិ ។ យេ ខោ តេ(១) ទេវានមិន្ទ ភិក្ខូ(២) តណ្ហាសង្ខយវិមុត្តា តេ អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានា តស្មា ន សព្វេ សមណព្រាហ្មណា អច្ចន្តនិដ្ឋា អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី

១ ម. តេតិ នត្ថិ ។ ២ ម. សមណព្រាហ្មណា ។



ទៀតប្រាកដទេ មិនមែនជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀតប្រាកដទេ ។ បពិត្រព្រះអង្គ ទ្រង់និទ្ទុក្ខ ចុះពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀតប្រាកដ មិនមែនជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀតប្រាកដ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀតប្រាកដ មិនមែនជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀតប្រាកដ ទាំងអស់គ្នា តើព្រោះហេតុអ្វី ។ បពិត្រទេវានមិន្ទ ភិក្ខុទាំងឡាយណា ដែលមានចិត្តផុតស្រឡះ ក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហាហើយ ភិក្ខុទាំងឡាយនោះ ឈ្មោះថាជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀតប្រាកដ ជាអ្នកមានធម៌ជាគ្រឿងអស់ទៅនៃយោគៈទៀតប្រាកដ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ គឺអរិយមគ្គទៀតប្រាកដ ជាអ្នកមានទីបំផុត គឺព្រះនិព្វានទៀតប្រាកដ ព្រោះហេតុនោះឯង បានជាពួកសមណព្រាហ្មណ៍ទាំងអស់ មិនមែនសុទ្ធតែជាអ្នកមានសេចក្តីសម្រេច គឺព្រះនិព្វានទៀតប្រាកដ មិនមែនជាអ្នកមានធម៌ជាគ្រឿងអស់ទៅ នៃយោគៈទៀតប្រាកដ មិនមែនជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរទៀតប្រាកដ

អត្ថុបបរិយោសាចាតិ ។ ឥត្ថំ ភគវា សក្កស្ស ទេវា-
នមិន្ទស្ស បញ្ហំ បុដ្ឋោ ព្យាកាសិ ។ អត្តមនោ
សក្កោ ទេវានមិន្ទោ ភគវតោ ភាសិតំ អភិនន្ទិ
អនុមោទិ ឯវមេតំ ភគវា ឯវមេតំ សុគត តិណ្ណា
មេត្ថ កង្ខា វិគតា កថំកថា ភគវតោ បញ្ហា-
វេយ្យាករណំ សុត្វាតិ ។

[១០០] ឥតិហ សក្កោ ទេវានមិន្ទោ ភគវតោ
ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឯតទវោច
ឯជា ភន្តេ រោគោ ឯជា គណ្ឌោ ឯជា សល្លំ ឯជា ឥមំ
បុរិសំ បរិកឌ្ឍតិ តស្ស តស្សេវ ភវស្ស អភិនិព្វត្តិ-
យា(១) តស្មា អយំ បុរិសោ ឧច្ចាវចមាបជ្ជតិ ។
យេសាហំ(២) ភន្តេ បញ្ហានំ ឥតោ ពហិទ្ធា អញ្ញេ-
សុ សមណព្រាហ្មណេសុ ឱកាសកម្មម្បិ(៣) នា-

១ អភិនិព្វត្តិយាតិ វា បាឋោ ។ ២ យេ សាហំ ។ ៣ ឱ. ទិកាសកម្មម្បិ ។



មិនមែនជាអ្នកមានទីបំផុតនូវព្រះនិព្វានទៀតឡើយ ព្រោះហេតុ តាំងគុណគ្នាឡើយ ។ ព្រះមានព្រះភាគ ទ្រង់ព្យាករ នូវប្រស្នា ដែលសក្កទេវរាជជាធំជាងពួកទេវតាទូលសួរហើយ ដោយប្រការដូច្នេះ ។ សក្កទេវរាជជាធំជាងពួកទេវតា ក៏ពេញព្រះហឫទ័យ ត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ បពិត្រព្រះសុគត ដំណើរនុ៎ះ យ៉ាងហ្នឹងហើយ សេចក្តីសង្ស័យ ក្នុងប្រស្នានុ៎ះ ខ្ញុំព្រះអង្គឆ្លងផុតហើយ សេចក្តីងឿងឆ្ងល់ ក៏អស់ហើយ ព្រោះបានស្តាប់ នូវបញ្ហាព្យាករណ៍ របស់ព្រះមានព្រះភាគ ។

(១០០) សក្កទេវរាជ ជាធំជាងពួកទេវតា លុះត្រេកអរ រីករាយ នឹងភាសិត របស់ព្រះមានព្រះភាគ ដូច្នេះហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីញាប់ញ័រគឺតណ្ហាទុកដូចជារោគ សេចក្តីញាប់ញ័រគឺតណ្ហាទុកដូចជាបូស សេចក្តីញាប់ញ័រគឺតណ្ហាទុកដូចជាកូនសរ សេចក្តីញាប់ញ័រគឺតណ្ហាតែងតែទាញនូវបុរសនេះឲ្យកើតក្នុងភពនោះៗ ព្រោះហេតុនោះឯង បុរសនេះ រមែងដល់នូវសភាពខ្ពស់ទាប ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបាននូវឱកាស-កម្មនៃប្រស្នាណា អំពីសមណព្រាហ្មណ៍ដទៃ ខាងក្រៅព្រះពុទ្ធសាសនា

ហេត្តុំ តេ មេ ភគវតា ព្យាកតា ទីឃរត្តានុសយិ-តា(១) យញ្ច បន(២) មេ វិចិកិច្ឆាកថំ កថាសល្លំ តញ្ច ភគវតា អព្ពុឡ្ហន្តិ ។ អភិជានាសិ នោ ត្វំ ទេវានមិន្ទ ឥមេ បញ្ហេ អញ្ញេ សមណព្រាហ្មណេ បុច្ឆិតាតិ(៣) ។ អភិជានាមហំ ភន្តេ ឥមេ បញ្ហេ អញ្ញេ សមណព្រាហ្មណេ បុច្ឆិតាតិ(៤) ។ យថា កថំ បន តេ ទេវានមិន្ទ ព្យាករឹសុ(៥) សចេ តេ អគរុ ភាសស្សូតិ ។ ន ខោ មេ ភន្តេ គរុ យត្ថស្ស ភគវា និសិន្នោ ភគវន្តរូបោ វាតិ(៦) ។ តេនហិ ទេវានមិន្ទ ភាសស្សូតិ ។ យេសាហំ(៧) ភន្តេ មញ្ញាមិ សមណ-ព្រាហ្មណេ(៨) អារញ្ញកា បន្តសេនាសនាតិ ត្យាហំ ឧបសង្កមិត្វា ឥមេ បញ្ហេ បុច្ឆាមិ តេ

១ ឱ. ទីឃរត្តានុសយិតោ ។ ម. ទីឃរត្តានុសយិតំ ។ ២ កត្ថ បនតិ កំ បាឋោ ។ ៣ ម. បុច្ឆិតាតិ ។ ៤ ឱ. ម. បុច្ឆិតាតិ ។ ៥ ឱ. វ្យាករឹសុ ។ ម. ព្យាកំសុ ។ ៦ ឱ. ភគវន្តរូបោ វាតិ ។ ៧ ម. យេស្វាហំ ។ ៨ ឱ. សមណព្រាហ្មណេ ។



នេះ ប្រស្នានោះ ព្រះមានព្រះភាគ ជាអ្នកឃើញនូវការណ៍ដ៏វិសេស បានព្យាករដល់ខ្ញុំព្រះអង្គហើយ មួយទៀត ព្រះមានព្រះភាគ បានទាំងដកនូវសរ គឺសេចក្ដីសង្ស័យ និងសេចក្ដីងឿងឆ្ងល់ អំពីខ្ញុំព្រះអង្គចេញបានហើយ ។ បពិត្រទេវានមិន្ទ មហាបពិត្រ ធ្លាប់យកប្រស្នានេះទៅសួរចំពោះពួកសមណព្រាហ្មណ៍ដទៃ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ធ្លាប់យកប្រស្នានេះ ទៅសួរចំពោះសមណព្រាហ្មណ៍ដទៃដែរ ។ បពិត្រទេវានមិន្ទ ពួកសមណព្រាហ្មណ៍ទាំងនោះ បានព្យាករថ្វាយមហាបពិត្រ ដូចម្ដេចខ្លះ បើមហាបពិត្រ មិនទើសទាល់ព្រះទ័យទេ សូមមហាបពិត្រមានព្រះបន្ទូលទៅមើល ។ បពិត្រព្រះអង្គដ៏ចំរើន ព្រះមានព្រះភាគក្ដី បុគ្គលដែលមានរូបប្រហែលព្រះមានព្រះភាគក្ដី អង្គុយក្នុងទីណា ទីនោះ មិនទើសទាល់ចិត្តនៃខ្ញុំព្រះអង្គឡើយ ។ បពិត្រទេវានមិន្ទ បើដូច្នោះ សូមមហាបពិត្រ មានព្រះបន្ទូលទៅមើល ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ សម្គាល់នូវពួកសមណព្រាហ្មណ៍ណាថា សមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកនៅក្នុងអរញ្ញប្រទេស មានសេ-នាសនៈដ៏ស្ងាត់ ដូច្នេះ ខ្ញុំព្រះអង្គ ក៏ចូលទៅរកសមណព្រាហ្មណ៍ទាំងនោះ ហើយសួរនូវប្រស្នាទាំងនេះ ពួកសមណព្រាហ្មណ៍នោះ លុះ

មយា បុដ្ឋា ន សម្បាយន្តិ អសម្បាយន្តា មមំយេវ បដិបុច្ឆន្តិ កោ នាមោ អាយស្មាតិ តេសាហំ បុដ្ឋោ ព្យាករោមិ អហំ ខោ មារិស សក្កោ ទេវានមិន្ទោតិ តេ មមំយេវ ឧត្តរឹ បដិបុច្ឆន្តិ កឹ បនាយស្មា(១) ទេវានមិន្ទ(២) កម្មំ កត្វា ឥមំ ឋានំ បត្តោតិ តេសាហំ យថាសុតំ យថាបរិយត្តំ ធម្មំ ទេសេមិ តេ តាវតកេនេវ អត្តមនា ហោន្តិ សក្កោ ច នោ ទេវានមិន្ទោ ទិដ្ឋោ យញ្ច នោ អបុច្ឆិម្ហា តញ្ច នោ ព្យាកាសីតិ តេ អញ្ញទត្ថុ(៣) មមំយេវ សាវកា សម្បជ្ជន្តិ ន ចាហំ តេសំ អហំ ខោ បន ភន្តេ ភគវតោ សាវកោ សោតាបន្នោ

---

១ ឱ. ប. កិច្ចាយស្មា ។ ២ ឱ. ទេវានមិន្ទោ ។ ៣ ឱ. ម. អញ្ញទត្ថុ ។



ខ្ញុំព្រះអង្គសួរហើយ ក៏មិនអាចនឹងដោះស្រាយបាន កាលមិនអាចនឹងដោះស្រាយហើយ ក៏ត្រឡប់សួរមកខ្ញុំព្រះអង្គវិញ ថា អ្នកមានអាយុឈ្មោះអ្វី លុះពួកសមណព្រាហ្មណ៍នោះ សួរខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គបានប្រាប់ថា បពិត្រអ្នកនិទ៌ុក្ខ ខ្ញុំឯង ជាសក្កទេវេន្ទ ជាធំជាងពួកទេវតា ពួកសមណព្រាហ្មណ៍នោះ ក៏ត្រឡប់សួរមកខ្ញុំព្រះអង្គតទៅទៀត ថា បពិត្រទេវេន្ទដ៏មានអាយុ ចុះព្រះអង្គសាងនូវអំពើដូចម្តេច បានជាដល់នូវឋាននេះ ដូច្នេះ ខ្ញុំព្រះអង្គក៏សម្តែងធម៌(១) ប្រាប់ដល់ពួកសមណព្រាហ្មណ៍នោះ តាមដែលបានស្តាប់មក បានរៀនមក ពួកសមណព្រាហ្មណ៍នោះ ក៏មានសេចក្តីត្រេកអរ ដោយធម៌មានប្រមាណប៉ុណ្ណោះ ថា សក្កទេវេន្ទ ជាធំជាងពួកទេវតា គឺយើងទាំងឡាយបានឃើញហើយផង យើងទាំងឡាយ បានសួរនូវប្រស្នាណា លោកក៏បានដោះស្រាយនូវប្រស្នានោះ ដល់យើងទាំងឡាយផង. ពួកសមណព្រាហ្មណ៍នោះ ក៏ត្រឡប់ទៅជាសាវក របស់ខ្ញុំព្រះអង្គវិញ ឯខ្ញុំព្រះអង្គ មិនមែនជាសាវក របស់ពួកសមណព្រាហ្មណ៍នោះទេ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គ ជាសាវក របស់ព្រះមានព្រះភាគ ជាសោតាបន្នបុគ្គល

---

១ វត្តបទ ពី យ៉ាង ។

អវិនិបាតធម្មោ និយតោ សម្ពោធិបរាយណោតិ ។ អភិជានាសិ នោ ត្វំ ទេវានមិន្ទ ឥតោ បុព្វេ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភន្តិ ។ អភិជានាមហំ ភន្តេ ឥតោ បុព្វេ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភន្តិ ។ យថាកថំ បន ត្វំ ទេវានមិន្ទ អភិជានាសិ ឥតោ បុព្វេ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភន្តិ ។

(១០១) ភូតបុព្វំ ភន្តេ ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ(១) អហោសិ ។ តស្មឹ ខោ បន ភន្តេ សង្គាមេ ទេវា ជិនឹសុ អសុរា បរាជយឹសុ(២) ។ តស្ស មយ្ហំ ភន្តេ តំ សង្គាមំ អភិវិជិនិត្វា អភិវិជិតសង្គាមស្ស ឯតទហោសិ យា ចេវ ទានិ ទិព្វា ឱជា យា ច(៣) អសុរា ឱជា ឧភយមេតំ ទេវា បរិភុញ្ជិស្សន្តីតិ ។ សោ(៤) ខោ បន មេ ភន្តេ វេទបដិលាភោ សោមនស្សបដិលាភោ សទណ្ឌាវចរោ សសត្ថាវចរោ ន និព្វិទាយ

១ ឱ. សមុបព្វូឡ្ហោ ។ ២ ឱ. អសុរា បរាជិំសុ ។ ម. អសុរា បរាជយឹសុ ។ ៣ ឱ. វា ៤ ឱ. យោ ។



មានសេចក្ដីមិនធ្លាក់ទៅក្នុងអបាយ ជាបុគ្គលទៀង មានប្រាជ្ញាជាគ្រឿងត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ បពិត្រទេវានមិន្ទ ក្នុងកាលពីមុនអំពីកាលនេះ មហាបពិត្រធ្លាប់ ទទួលការបាននូវសេចក្ដីត្រេកអរ និងការបាននូវសោមនស្ស បែបនេះ ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលមុនអំពីកាលនេះ ខ្ញុំព្រះអង្គ ធ្លាប់ទទួលការបាននូវសេចក្ដីត្រេកអរ និងការបាននូវសោមនស្ស បែបនេះដែរ ។ បពិត្រទេវានមិន្ទ ចុះក្នុងកាលមុនអំពីកាលនេះ មហាបពិត្រ ធ្លាប់ទទួលការបាននូវសេចក្ដីត្រេកអរ និងការបាននូវសោមនស្ស បែបនេះ តើដូចម្ដេច ។

(១០១) បពិត្រព្រះអង្គដ៏ចម្រើន រឿងធ្លាប់មានមកហើយ សង្គ្រាមនៃពួកទេវតានិងអសុរបានតតាំងគ្នាហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងសង្គ្រាមនោះ ពួកទេវតាឈ្នះ ពួកអសុរចាញ់ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គឈ្នះសង្គ្រាមនោះហើយ បានឈ្នះជា មានសង្គ្រាមឈ្នះស្រេចហើយ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ពួកទេវតាទាំងឡាយ នឹងបរិភោគនូវឱជារសទាំងពីរ គឺឱជារសរបស់ទេវតានិងឱជារសរបស់អសុរ ក្នុងវេលានោះ បពិត្រព្រះអង្គដ៏ចម្រើន ការបាននូវសេចក្ដីត្រេកអរនិងការបាននូវសេចក្ដីសោមនស្ស របស់ខ្ញុំព្រះអង្គនោះ សឹងប្រកបដោយគ្រឿងដំបង ប្រកបដោយគ្រឿងសាស្ត្រា មិនប្រព្រឹត្តទៅដើម្បី

ន វិរាគាយ ន និរោធាយ ន ឧបសមាយ ន អភិញ្ញា-យ ន សម្ពោធាយ ន និព្វានាយ សំវត្តតិ ។ យោ ច ខោ មេ អយំ ភន្តេ ភគវតោ ធម្មំ សុត្វា វេទបដិលាភោ សោមនស្សបដិលាភោ សោ អទណ្ឌាវចរោ អសត្ថា-វចរោ ឯកន្តនិព្វិទាយ វិរាគាយ និរោធាយ ឧបស-មាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ កតិ បន(១) ត្វំ ទេវានមិន្ទ អត្ថវសេ សម្បស្សមានោ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភំ បវេទេ-សីតិ ។ ឆ ខោ អហំ ភន្តេ អត្ថវសេ សម្បស្សមា-នោ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភំ បវេទេមិ ។

[១០៦] ឥធេវ តិដ្ឋមានស្ស
ទេវភូតស្ស មេ សតោ
បុនរាយុ ច មេ(២) លទ្ធោ
ឯវំ ជានាហិ មារិសាតិ(៣)

ឥទំ ខោ អហំ ភន្តេ បឋមំ អត្ថវសំ

១ ម. កិម្ហេ ។ ២ ម. ពុនរាយុ ច មេ ។ ៣ ឱ. មារិស ។



សេចក្តីនឿយណាយ ដើម្បីការប្រាសចាករាគៈ ដើម្បីការរលត់ទុក្ខ ដើម្បីការស្ងប់រម្ងាប់ ដើម្បីការដឹងចំពោះ ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វានឡើយ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងឯ ការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្សណា របស់ខ្ញុំព្រះអង្គ ព្រោះស្តាប់ធម៌របស់ព្រះមានព្រះភាគ ការបាននោះ មិនប្រកបដោយគ្រឿងវាយដំ មិនប្រកបដោយគ្រឿងកាប់ចាក់ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដើម្បីការប្រាសចាករាគៈ ដើម្បីការរលត់ទុក្ខ ដើម្បីការស្ងប់រម្ងាប់ ដើម្បីការដឹងចំពោះ ដើម្បីការត្រាស់ដឹង ដើម្បីព្រះនិព្វាន តែមួយយ៉ាង ។ បពិត្រទេវានមិន្ទ ចុះមហាបពិត្រ ទ្រង់ឃើញនូវអំណាច នៃប្រយោជន៍ដូច-ម្តេច ទើបសំដែង នូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឃើញនូវអំណាចនៃប្រយោជន៍ ៦ យ៉ាង ទើបសំដែងនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

[១០៦] បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឃើញនូវអំណាចនៃប្រយោជន៍ ជាដំបូងដូច្នេះថា

កាលអាត្មាអញកើតជាទេវតា ឋិតនៅក្នុងស្ថានសួគ៌នេះ អាត្មា
អញបាននូវអាយុថែមទៀត ម្នាលតាយើង អ្នកចូរដឹងយ៉ាងនេះចុះ

សម្បស្សមានោ លភាមិ វេទប្បដិលាភំ
សោមនស្សប្បដិលាភំ ឧបេមិ ។

(១០៣) ចុតាហំ ទិព្វា កាយា
អាយុំ ហិត្វា អមានុសំ
អមូឡ្ហោ គព្ភមេស្សាមិ
យត្ថ មេ រមតី មនោតិ
ឥទំ ខោ អហំ ភន្តេ ទុតិយំ អត្ថវសំ
សម្បស្សមានោ លភាមិ វេទប្បដិលាភំ
សោមនស្សប្បដិលាភំ ឧបេមិ ។

(១០៤) ស្វាហំ(១) អប្បដិបុគ្គលស្ស
វិហរំ សាសនេ រតោ
ញាយេន វិហរិស្សាមិ
សម្បជានោ បតិស្សតោតិ(២)
ឥទំ ខោ អហំ ភន្តេ តតិយំ អត្ថវសំ សម្បស្សមានោ លភាមិ វេទប្បដិលាភំ សោមនស្សប្បដិលាភំ ឧបេមិ ។

១ ម. សោហំ ។ ២ ម. បតិស្សតោ ។





ជួបប្រទះហើយ រមែងសម្រេចនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

(១០៣) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ពីរនេះថា

ចិត្តរបស់ខ្ញុំព្រះអង្គ ត្រេកអរក្នុងត្រកូលណា ខ្ញុំព្រះអង្គ ច្យុត
ចាកកាយជារបស់ទេវតា លះបង់នូវអាយុ មិនមែនជារបស់
មនុស្ស ហើយជាអ្នកមិនវង្វេងចូលទៅកាន់គភ៌ក្នុងត្រកូលនោះ

ជួបប្រទះហើយ រមែងសម្រេចនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

(១០៤) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ ៣ នេះថា

ខ្ញុំព្រះអង្គ ជាអ្នកត្រេកអរក្នុងសាសនា របស់ព្រះពុទ្ធជាម្ចាស់
ដែលប្រសើរមានប្រាជ្ញាមិនគាប់ប្រៀប ហើយជាអ្នកមានសេចក្តី
ដឹងខ្លួន មានស្មារតីតម្កល់ខ្ជាប់ នៅជាមួយសេចក្តីដឹងខ្លួនស្រួល

ជួបប្រទះហើយ រមែងសម្រេចនូវការបាននូវសេចក្តីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

(១០៥) ញាយេន ច មេ ចរតោ(១)

សម្ពោធិ មេ ភវិស្សតិ

អញ្ញាតា វិហរិស្សាមិ

ស្វេវ អន្តោ ភវិស្សតីតិ(២)

ឥមំ ខោ អហំ ភន្តេ ចតុត្ថំ អត្ថវសំ សម្បស្សមានោ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភំ បវេទេមិ ។

(១០៦) ចុតាហំ មានុសា កាយា

អាយុំ ហិត្វាន មានុសំ

បុន ទេវោ ភវិស្សាមិ

ទេវលោកស្មិមុត្តមោតិ(៣)

ឥមំ ខោ អហំ ភន្តេ បញ្ចមំ អត្ថវសំ សម្បស្សមានោ ឯវរូបំ វេទបដិលាភំ សោមនស្សបដិលាភំ បវេទេមិ ។

១ ម. ញាយេន ច មេ ចរតោ ។ ឱ. ញាយេន មេ ចរតោ ច ។ ២ ម. ស្វេវ មន្តោ ភវិស្សតិ ។ ៣ ម. ទេវលោកស្មិំ ឧត្តមោតិ ។ ឱ. ទេវលោកស្មិំ ឧត្តមោ ។



(១០៥) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ ៤ នេះហើយ

បើសម្មាទិដ្ឋិញាណ(១) នឹងមានដល់ខ្ញុំព្រះអង្គ ក្នុងកាលមុខ ដោយសេចក្ដីនឹងចុះត្រូវ ខ្ញុំព្រះអង្គ ជាអ្នកប្រាជ្ញាដើម្បីនឹងចុះត្រូវ សេចក្ដីនឹងចុះត្រូវនោះឯង ជាការសំខាន់របស់ខ្ញុំព្រះអង្គ (ក្នុងមនុស្សលោក)

ដូច្នេះហើយ ទើបសម្ដែងនូវការបាននូវសេចក្ដីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

(១០៦) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ឃើញនូវអំណាចនៃប្រយោជន៍ ជាគម្រប់ ៥ នេះហើយ

ខ្ញុំព្រះអង្គ ច្យុតចាកកាយជារបស់នៃមនុស្ស លះបង់នូវអាយុជារបស់នៃមនុស្ស ហើយគួរនឹងទៅកើត ជាទេវតាដ៏ឧត្តម ក្នុងទេវលោកវិញ

ដូច្នេះហើយ ទើបសម្ដែងនូវការបាននូវសេចក្ដីត្រេកអរ និងការបាននូវសោមនស្ស មានសភាពយ៉ាងនេះ ។

១ សម្មាទិដ្ឋិញាណ សំដៅយកសកទាគាមិមគ្គ (អដ្ឋកថា) ។

សក្កបញ្ហសុត្តំ ៨ អដ្ឋមំ

[១០៧] តេ បណីតតរា ទេវា
អកនិដ្ឋា យសស្សិនោ
អន្តិមេ វត្តមានម្ហិ
សោ និវាសោ ភវិស្សតិ

ឥទំ ខោ អហំ ភន្តេ ឆដ្ឋំ អត្ថវសំ សម្បស្សមានោ ឯវរូបំ វេទប្បដិលាភំ សោមនស្សប្បដិលាភំ បវេទេមិ ។ ឥមេ ខោ អហំ ភន្តេ ឆ អត្ថវសេ សម្បស្ស-មានោ ឯវរូបំ វេទប្បដិលាភំ សោមនស្ស-ប្បដិលាភំ បវេទេមិ ។

[១០៨] អបរិយោសិតសង្កប្បោ
វិចិកិច្ឆោ កថំកថី(១)
វិចរឹ(២) ទីឃមទ្ធានំ
អន្វេសន្តោ តថាគតំ ។
យស្សុ(៣) មញ្ញាមិ សមណេ
បវិវិត្តវិហារិនោ

១ ម. វិចិកិច្ឆី ។ ឱ. វិចិកិច្ឆោ ។ ២ ម. វិចរិ ។ ៣ ម. ឱ. យស្សុ ។



សក្កបញ្ហសូត្រ អំណាចនៃប្រយោជន៍ ៦ ប្រការ

(១០៧) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញនូវអំណាចនៃប្រយោជន៍ជាគម្រប់ ៦ នេះថា ពួកទេវតានោះ ឧត្តមជាងទេវតាទាំងពួង ជាពួកមិនថោកថយ ជាអ្នកមានយសបរិវារ នៅក្នុងលំនៅណា លំនៅនោះមុខជានឹងមាន ដល់ខ្ញុំព្រះអង្គ ក្នុងកាលជាទីបំផុតមិនខាន(១) ដូច្នេះហើយសំដែងនូវការបាន នូវសេចក្តីត្រេកអរ និងការបាន នូវសោមនស្សមានសភាពយ៉ាងនេះ ។

បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គឃើញ នូវអំណាចនៃប្រយោជន៍ទាំង ៦ ប្រការហ្នឹងឯង ទើបសំដែងនូវការបាន នូវសេចក្តីត្រេកអរ និងការបាន នូវសោមនស្ស មានសភាពយ៉ាងនេះ ។

(១០៨) ខ្ញុំព្រះអង្គមានសេចក្តីប្រាថ្នាមិនទាន់សម្រេច នៅមានសេចក្តីសង្ស័យ ងឿងឆ្ងល់ តែងត្រាច់ស្វះស្វែងរកព្រះតថាគត អស់កាលជាយូរអង្វែងមកហើយ ។ ខ្ញុំព្រះអង្គសម្គាល់នូវពួកសមណៈណា ដែលជាអ្នកនៅក្នុងទីស្ងាត់

១ អដ្ឋកថា ថា ព្រះឥន្ទ្រមុខជានឹងបាននូវអនាគាមិផល លុះច្យុតអំពីអត្តភាពនេះទៅនឹងបានទៅកើតក្នុងសុទ្ធាវាស មានអវិហាជាដើម មានអកនិដ្ឋភពជាទីបំផុត ។

សម្ពុទ្ធា ឥតិ មញ្ញមានោ(១)
គច្ឆាមិ តេ ឧបាសិតុំ ។
កឹ អាបន្នា ហោតិ
កឹ ហោតិ វិរាធនា
ឥតិ បុដ្ឋា ន សក្កោន្តិ(២)
មគ្គេ បដិបទាសុ ច ។
ត្យាស្សុ(៣) យទា មំ ជានន្តិ
សក្កោ ទេវានមាគតោ
ត្យាស្សុ(៤) មមេវ បុច្ឆន្តិ
កឹ កត្វា បាបុណី ឥទំ ។
តេសំ យថាសុតំ ធម្មំ
ទេសយាមិ ជនេ សុតំ
តេន(៥) អត្តមនា ហោន្តិ
ទិដ្ឋោ នោ វាសវោតិ ច ។
យទា ច សម្ពុទ្ធមទ្ទក្ខឹ(៦)

១ ឱ. ម. បញ្ញានោ ។ ២ ឱ. សំបាយន្តិ ។ ៣-៤ ឱ. ត្យាស្សុ ។ ម. ត្យស្សុ ។ ៥ ឱ. តេនស្សុ ។ ៦ ឱ. ពុទ្ធំ អទ្ទក្ខឹ ។ ម. ពុទ្ធមទ្ទក្ខឹ ។



ក៏នឹកស្មានថាជាព្រះសម្ពុទ្ធ ដូច្នេះហើយ ក៏ចូលទៅអង្គុយជិតពួកសមណៈនោះ ។ ពួកសមណៈនោះ សួរខ្ញុំព្រះអង្គសួរថា សេចក្តីជ្រះថ្លា កើតដូចម្តេច សេចក្តីមិនជ្រះថ្លាកើតដូចម្តេច ដូច្នេះហើយ មិនអាចនឹងដោះស្រាយ ក្នុងមគ្គនិងបដិបទាទាំងឡាយបានឡើយ ។ កាលណាដែលពួកសមណៈទាំងនោះ ស្គាល់ខ្ញុំព្រះអង្គថាជាសក្កទេវរាជ មកពីឋានទេវតា ពួកសមណៈទាំងនោះ បានសួរខ្ញុំព្រះអង្គថា ទេវ-រាជ បានសាងនូវកុសលដូចម្តេច ទើបបាននូវសម្បត្តិនេះ ។ ខ្ញុំព្រះអង្គ ក៏សម្តែងធម៌តាមដែលបានស្តាប់មក ប្រាប់ដល់សមណៈទាំងនោះ ឲ្យប្រាកដក្នុងទីប្រជុំជន ពួកសមណៈទាំងនោះ នាំគ្នាពេញចិត្ត និយាយនៅក្នុងចិត្តថា យើងទាំងឡាយ បានឃើញសក្កទេវរាជហើយ ។ មួយវិញទៀត កាលណាដែលខ្ញុំព្រះអង្គ បានឃើញនូវព្រះសម្ពុទ្ធ

ទ្រង់ឆ្លងផុតចាកសេចក្តីសង្ស័យហើយ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គ ជាអ្នកប្រាសចាកភ័យហើយ បានចូលមកអង្គុយជិតព្រះសម្ពុទ្ធ ។ ខ្ញុំព្រះអង្គ សូមថ្វាយបង្គំ នូវព្រះសម្ពុទ្ធទ្រង់ដកចោលនូវសរគឺតណ្ហាចេញបានហើយ រកបុគ្គលប្រៀបផ្ទឹមគ្មាន ទ្រង់មានព្យាយាមច្រើន ទ្រង់ត្រាស់ដឹង (នូវចតុរារិយសច្ច) ព្រះអង្គជាផៅពង្សនៃព្រះអាទិត្យ ។ បពិត្រព្រះអង្គទ្រង់និទ្ទុក្ខ (ក្នុងកាលមុន) ខ្ញុំព្រះអង្គព្រមទាំងទេវតា បានធ្វើនូវការនមស្ការណាចំពោះព្រហ្ម ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គ សូមថ្វាយនមស្ការនោះចំពោះព្រះអង្គវិញ ខ្ញុំព្រះអង្គ សូមធ្វើនូវការថ្វាយបង្គំចំពោះព្រះអង្គដោយខ្លួនឯង ។ ព្រះអង្គជាព្រះសម្ពុទ្ធពិតមែន ព្រះអង្គជាសាស្តាប្រសើរ ក្នុងលោកនេះព្រមទាំងទេវលោក និងរកបុគ្គលណាមួយ មកប្រៀបផ្ទឹមនឹងព្រះអង្គគ្មានឡើយ ។



វិចិកិច្ឆា វិតារណំ
សោត្ថិ វីតរាគោ អជ្ជ
សម្ពុទ្ធំ បយិរុបាសយិ(១) ។
តណ្ហាសល្លស្ស ហន្តារំ
ពុទ្ធំ អប្បដិបុគ្គលំ(២)
អហំ វន្ទេ មហាវីរំ
ពុទ្ធមាទិច្ចពន្ធុនំ(៣)
យំ ករោមសេ ព្រហ្មុនោ
សមំ ទេវេហិ មារិស
តទជ្ជ តុយ្ហំ ទស្សាម(៤)
ហន្ទ សាមំ ករោម តេ ។
តុវមេវាសិ(៥) សម្ពុទ្ធោ
តុវំ សត្ថា អនុត្តរោ
សទេវកស្មិំ លោកស្មិំ
នត្ថិ តេ បដិបុគ្គលោ ។

១ ឱ. បយិរុបាសយ ។ ២ ឱ. ពុទ្ធមប្បដិបុគ្គលំ ។ ៣ ឱ. វន្ទាមាទិច្ចពន្ធុនំ ។ ៤ ឱ. ម. ទស្សេម ។ ៥ ឱ. តុវមេវសិ ។ ម. តុវមសិ ។

(១០៩) អថខោ សក្កោ ទេវានមិន្ទោ បញ្ចសិខំ គន្ធព្វបុត្តំ អាមន្តេសិ ពហូបការោ ខោ មេសិ ត្វំ តាត បញ្ចសិខ យំ ត្វំ ភគវន្តំ បឋមំ បសាទេសិ តយា តាត បឋមំ បសាទិតំ បច្ឆា មយំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមិម្ហា(១) អរហន្តំ សម្មាសម្ពុទ្ធំ បេត្តិកេ ឋានេ(២) ឋបេស្សាមិ គន្ធព្វរាជា ភវិស្សសិ ភទ្ទញ្ច តេ សុរិយវច្ឆសំ ទម្មិ សា ហិ តេ អភិបត្ថិតាតិ។ អថខោ សក្កោ ទេវានមិន្ទោ បាណិនា បថវឹ បរាម-សិត្វា តិក្ខត្តុំ ឧទានេសិ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

---

១ ឱ. ឧបសង្កមិម្ហ ។ ២ ម. បេត្តិកេ ឋានេ ។



(១០៩) លំដាប់នោះ សក្កទេវរាជ ជាធំជាងពួកទេវតា ត្រាស់ហៅនូវបញ្ចសិខគន្ធព្វបុត្តថា នែអ្នកបញ្ចសិខៈ អ្នកជាបុគ្គលមានឧបការៈច្រើនដល់យើងពិត ដោយហេតុអ្នកបានធ្វើព្រះមានព្រះភាគ ឲ្យជ្រះថ្លាជាមុន ម្នាលអ្នក លុះអ្នកបានធ្វើព្រះមានព្រះភាគ ឲ្យជ្រះថ្លាជាមុនហើយ ទើបយើងបានចូលមកគាល់ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ក្នុងកាលជាខាងក្រោយ យើងនឹងតាំងអ្នកទុកក្នុងទីស្មើដោយបិតា អ្នកនឹងបានជាស្តេចនៃពួកគន្ធព្វ មួយវិញទៀត យើងនឹងឲ្យនាងភទ្ទាសុរិយវច្ឆសាដល់អ្នក ព្រោះថានាងភទ្ទាសុរិយវច្ឆសានោះ អ្នកក៏បានប្រាថ្នាយូរហើយ ។ គ្រានោះ សក្កទេវរាជជាធំជាងពួកទេវតា ទ្រង់យកព្រះហស្តស្ទាបផែនដី ហើយបន្លឺឧទានអស់វារៈ៣ ដងថា

សូមនមស្ការ ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ អរហន្ត
សម្មាសម្ពុទ្ធ អង្គនោះ ។

សូមនមស្ការ ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ អរហន្ត
សម្មាសម្ពុទ្ធ អង្គនោះ ។

សូមនមស្ការ ថ្វាយបង្គំ ចំពោះព្រះមានព្រះភាគ អរហន្ត
សម្មាសម្ពុទ្ធ អង្គនោះ ។

## សក្កបញ្ហសុត្តំ សុត្តបរិយោសានំ

(១១០) ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ សក្កស្ស ទេវានមិន្ទស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ អញ្ញាសញ្ច អសីតិយា ទេវតាសហស្សានំ ។ ឥតិ យេ(១) សក្កេន ទេវានមិន្ទេន អជ្ឈិដ្ឋបញ្ហា(២) បុដ្ឋា តេ ភគវតា ព្យាកតា ។ តស្មា ឥមស្ស វេយ្យាករណស្ស សក្កបញ្ហាត្វេវ អធិវចនន្តិ ។

សក្កបញ្ហសុត្តំ អដ្ឋមំ និដ្ឋិតំ ។

---

១ ម. ឥតិ ហ ។ ២ ម. អជ្ឈិដ្ឋា បញ្ហា ។



## សក្កបញ្ហសូត្រ ពាក្យជាទីបំផុតនៃសូត្រ

(១១០) ក៏កាលដែលព្រះមានព្រះភាគ កំពុងសំដែងនូវវេយ្យាករណ៍នេះ ធម្មចក្ខុ (សោតាបត្តិមគ្គ) ដ៏ប្រាសចាកធូលីគឺរាគាទិក្កិលេស ប្រាសចាកមន្ទិលគឺទិដ្ឋិនិងវិចិកិច្ឆា ក៏បានកើត ដល់សក្កទេវរាជ ជាធំជាងពួកទេវតាផង ដល់ពួកទេវតា ៨ ម៉ឺនទៀតផងថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា ។ ប្រស្នាណា ដែលសក្កទេវរាជ ជាធំជាងពួកទេវតា បានអារាធនា បានទូលសួរហើយ ប្រស្នានោះ ព្រះមានព្រះភាគ ទ្រង់បានព្យាករហើយ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ ពាក្យថា សក្កបញ្ហា ដូច្នេះ ជាឈ្មោះនៃវេយ្យាករណ៍នេះឯង ។

ចប់ សក្កបញ្ហសូត្រ ទី ៨ ។

# មហាសតិប្បដ្ឋានសុត្តំ នវមំ

(១១១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ(១) នាម កុរូនំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ(២) សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិប្បដ្ឋានា ។ កតមេ ចត្តារោ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយា-

១ កម្មាសធម្មន្តិបិ បាឋោ ។ ២ ម. សោកបរិទ្ទវានំ ។

# មហាសតិប្បដ្ឋានសូត្រ ទី ៩

(១១១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងកម្មាសធម្មនិគម របស់អ្នកកុរុ ក្នុងដែនកុរុ ។ កាលព្រះមានព្រះភាគ ទ្រង់គង់នៅ ក្នុងកម្មាសធម្មនិគមនោះឯង បាន ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួល ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋាន ទាំង ៤ នេះ ជាផ្លូវមួយនៃមួយ(១) (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃ សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួល ដើម្បី រំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវញាយធម៌ប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ សតិប្បដ្ឋានទាំង ៤ តើ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណា

១ ក្នុងអដ្ឋកថាមានសេចក្តីពន្យល់ពាក្យថា ផ្លូវមួយនៃមួយនោះច្រើនន័យ។ ន័យមួយលោកថាជាផ្លូវមួយតែមួយ ព្រោះជាផ្លូវប្រតិបត្តិ ដើម្បីចេញចាកសង្សារទៅកាន់ព្រះនិព្វាន មិនមានបែកទៅជាផ្លូវ ២ ឬជាផ្លូវ ៣ឡើយ ។ ន័យមួយទៀត លោកថាជាផ្លូវដែលត្រូវដើរបានតែខ្លួនម្នាក់ ព្រោះសតិប្បដ្ឋានទាំង ៤ នេះ បានដល់ព្រះយោគាវចរលះបង់ពួកពេញហើយទៅសម្ងំនៅក្នុងទីស្ងាត់ម្នាក់ឯង ទើបប្រតិបត្តិកើត ។ មួយទៀតលោកថាជាផ្លូវរបស់មនុស្សប្រសើរ គឺថាជាផ្លូវរបស់ព្រះសម្មាសម្ពុទ្ធ ព្រោះព្រះអង្គប្រសើរជាងសត្វទាំងពួងផង ហើយទ្រង់បានចម្រើនផ្លូវគឺសតិប្បដ្ឋានឲ្យកើតមានឡើងផង ។

នុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។

ឧទ្ទេសវារកថា និដ្ឋិតា(១) ។

១ ម. ឧទ្ទេសវារកថា និដ្ឋិតាតិ ន ទិស្សតិ ។ យ. ឧទ្ទេសោ និដ្ឋិតោ ។



ឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់ នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក(១)ចេញ ១ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ១ ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី (ជាគ្រឿងកំណត់) កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ១ ។

ចប់ ឧទ្ទេសវារកថា ។

១ អដ្ឋកថាថា លោកក្នុងទីនេះ សំដៅយកកាយ ព្រោះកាយនោះ ជាសភាវៈវិនាសទ្រុឌទ្រោម វិនាសទៅតាមធម្មតា ម្យ៉ាងទៀត អភិជ្ឈានិងទោមនស្សដែលលះក្នុងកាយនោះ មិនមែនត្រឹមតែក្នុងកាយប៉ុណ្ណោះទេ សូម្បីតែអភិជ្ឈានិងទោមនស្សក្នុងពួកវេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏ត្រូវលះបង់ដែរ ព្រោះហេតុនោះបានជាក្នុងគម្ពីរវិភង្គលោកប្រាប់ថា ឧបាទានក្ខន្ធទាំង ៥ ក៏ហៅថា លោកដែរ ។

(១១២) កថញ្ច ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា(១) ឧជុំ កាយំ បណិធាយ បរិមុខំ សតិំ ឧបដ្ឋបេត្វា ។ សោ សតោ វ អស្សសតិ សតោ(២) បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ

១ អាភុជិត្វាតិ ក្វចិ បោត្ថកេ ទិស្សតិ ។ ២ ម. សតោ ។



(១១២) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី គ្រប់សំរាប់បទទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តាំងសតិឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី (ភិក្ខុ) សិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយគឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយគឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរំងាប់កាយសង្ខារ (អស្សាសបស្សាសៈ) ហើយដកដង្ហើមចេញ

បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ ភមការោ វា ភមការន្តេវាសី វា ទីឃំ វា អញ្ឆន្តោ(១) ទីឃំ អញ្ឆាមីតិ បជានាតិ រស្សំ វា អញ្ឆន្តោ រស្សំ អញ្ឆាមីតិ បជានាតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ

១ អញ្ឆន្តោតិបិ អញ្ជន្តោតិបិ បាឋោ ។





សិក្សាថា អាត្មាអញ នឹងរម្ងាប់កាយសង្ខារ ដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹងក្តី កូនសិស្សនៃជាងក្រឡឹងក្តី ដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងវែង ឬកាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែក្រឡឹងខ្លី មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី (ភិក្ខុ) សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់នូវកាយ គឺខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញ នូវកាយក្នុងកាយជាខាងក្នុង (កាយរបស់ខ្លួន) ជាប្រក្រតី ត្រង់ឥរិយាបថ ទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅ (កាយរបស់បុគ្គលដទៃ) ជាប្រក្រតី

អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មា-នុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ(១) ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ(២) ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

អានាបានបព្វំ និដ្ឋិតំ(៣) ។

១ ម. បតិស្សតិមត្តាយ ។ ២ ម. ឯវំបិ ខោ ។ ៣ ម. អានាបានបព្វំ និដ្ឋិតន្តិ ច វិសុទ្ធិ ។



គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវកាយក្នុងកាយខាងក្នុង និងកាយខាងក្រៅ (កាយរបស់ខ្លួននិងកាយរបស់បុគ្គលដទៃ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ(១) គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយ(២) គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ ទាំងធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ អានាបានបព្វៈ ។

១-២ អដ្ឋកថាប្រាប់ថា ខ្យល់អស្សាសបស្សាសៈអាស្រ័យនៅក្នុងករជកាយផង ចុងច្រមុះផង ចិត្តផង ទើបសញ្ចរទៅមកបាន ព្រោះហេតុនោះ ធម៌ទាំងនេះឈ្មោះថា ធម៌ប្រជុំកើតឡើងក្នុងកាយ លុះផុតធម៌ទាំងនោះរលត់ទៅវិញ ឈ្មោះថា ធម៌សូន្យទៅក្នុងកាយ ។

[១១៣] បុន ចបរំ ភិក្ខវេ ភិក្ខុ គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ ឋិតោ វា ឋិតោម្ហីតិ បជានាតិ និសិន្នោ វា និសិន្នោម្ហីតិ បជានាតិ សយានោ វា សយានោម្ហីតិ បជានាតិ យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នប្បជា-នាតិ(១) ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ

១ ឱ. ម. នំ បជានាតិ ។



[១១៣] ម្នាលភិក្ខុទាំងឡាយ ពាក្យនៅមានមួយទៀត ភិក្ខុ កាលដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ។ មួយទៀត ភិក្ខុនោះតាំងនូវកាយ ដោយអាការយ៉ាងណា ៗ ក៏ដឹងច្បាស់នូវកាយនោះ ដោយអាការយ៉ាងនោះ ៗ ។ ភិក្ខុពិចារណាឃើញ នូវកាយក្នុងកាយខាងក្នុងយ៉ាងនេះជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញ នូវកាយក្នុងកាយខាងក្រៅ គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណា ឃើញនូវកាយក្នុងកាយ ជាខាងក្នុងនិងខាងក្រៅ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ ឥរិយាបថ ទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្តង់ឡើង ចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា

បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

ឥរិយាបថបព្វំ និដ្ឋិតំ [១] ។

(១០៤) បុន ចបរំ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ

១ ម. ឥរិយាបថបព្វំ និដ្ឋិតំ ទុតិយំ ។



ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ ឥរិយាបថបព្វៈ ។

(១៩៤) ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខ នៅមានទៀត ភិក្ខុ ធ្វើនូវសម្បជញ្ញៈ[១] គឺសេចក្ដីដឹងខ្លួន ក្នុងកាលដើរទៅមុខ ឬថយក្រោយ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលក្រឡេកមើលទៅមុខ ឬក្រឡេកមើលទៅទិសផ្សេងៗ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលបត់ដៃជើង ឬលាដៃជើង ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលប្រើប្រាស់នូវសង្ឃាដី បាត្រនិងចីវរ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលបរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយៈ ជញ្ជាប់ (នូវភេសជ្ជៈមានសប្បិជាដើម) ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាល

១ សម្បជញ្ញៈ មាន ៤ គឺសាត្ថកសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវកម្មដែលមានប្រយោជន៍និងកម្មឥតប្រយោជន៍ ១ សប្បាយសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវអារម្មណ៍ដែលជាទីសប្បាយ ១ គោចរសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវកម្មដ្ឋានដែលត្រូវចិត្ត ១ អសម្មោហសម្បជញ្ញៈ កិរិយាដឹងច្បាស់នូវហេតុដែលមិនវង្វេងឡើយ ១ ។ (អដ្ឋកថា) ទីឃនិកាយសីលក្ខន្ធវគ្គ ។

គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

សម្បជញ្ញបព្វំ និដ្ឋិតំ (១) ។

១ ឱ. សម្បជញ្ញបព្វំ និដ្ឋិតន្តិ ន ទិស្សតិ ។ ម. សម្បជានបព្វំ និដ្ឋិតំ ។



បន្ទោបង់នូវឧច្ចារៈបស្សាវៈ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងកាលដែលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ស្ងៀម ។ ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវកាយក្នុងកាយជាខាងក្នុងនិងខាងក្រៅ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើត ទាំងធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ សម្បជញ្ញបព្វៈ ។

(១១៨) បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស(១) អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា(២) លសិកា មុត្តន្តិ ។ សេយ្យថាបិ ភិក្ខវេ ឧភតោមុខា មូតោឡី(៣) បូរា នានាវិហិតស្ស ធញ្ញស្ស សេយ្យថីទំ សាលីនំ វីហីនំ មុគ្គានំ មាសានំ តិលានំ តណ្ឌុលានំ តមេនំ ចក្ខុមា បុរិសោ មុញ្ចិត្វា បច្ចវេក្ខេយ្យ ឥមេ សាលី ឥមេ វីហី ឥមេ មុគ្គា ឥមេ មាសា ឥមេ តិលា ឥមេ តណ្ឌុលាតិ ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា

១ ឱ. ម. បូរំ នានប្បការស្ស ។ ២ ឱ. ម. សិង្ឃាណិកា ។ ៣ មូតោឡីតិបិ បាឋោ ។





(១១៨) ម្នាលភិក្ខុទាំងឡាយ ពាក្យតទៅមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់ នូវកាយនេះឯង ខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងនោម បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ថង់ដែលមានមាត់ទាំងពីរខាង ពេញដោយធញ្ញជាតិ មានប្រការផ្សេងៗ ធញ្ញជាតិទាំងនោះ គឺស្រូវខ្សាយ-ស ស្រូវខ្សាយក្រហម សណ្តែកបាយ សណ្តែកជាមាស ល្ង អង្ករ បុរសដែលមានចក្ខុ គប្បីស្រាយនូវថង់នោះ ហើយពិចារណាមើលដូច្នេះថា នេះស្រូវខ្សាយ-ស នេះស្រូវខ្សាយក្រហម នេះសណ្តែកបាយ នេះសណ្តែកជាមាស នេះល្ង នេះអង្ករ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះ មានសក់

លោមា នខា ទន្តា តចោ មំសំ ន្ហារុ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃា-ណិកា លសិកា មុត្តន្តិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយា-នុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយា-នុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទ-យវយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ



រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងនោមស្អាត: បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ មានឧបមេយ្យដូច្នោះ ឯង ។ (ភិក្ខុ) ពិចារណាឃើញនូវកាយខាងក្នុងជាប្រក្រតី គ្រប់ឥរិ-យាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយខាង ក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថ ទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើត ទាំងធម៌ដែលសូន្យ ទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់

យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

បដិក្កូលមនសិការបព្វំ និដ្ឋិតំ(1) ។

[១១៦] បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា(2) គាវឹ វធិត្វា ចាតុម្មហាបថេ វិលសោ(3) បដិវិភជិត្វា(4) និសិន្នោ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ

១ ឱ. បដិក្កូលមនសិការបព្វំ និដ្ឋិតន្តិ ន ទិស្សតិ ។ ២ គោឃាតកោ វា គោឃាតកន្តេវាសី វាតិ កត្ថចិ បោត្ថកេ ទិស្សន្តិ ។ ៣ ឱ. ម. ពិលសោ ។ ៤ វិភជិត្វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ដើម្បីឲ្យជាគ្រឿងប្រាជ្ញា ដើម្បីឲ្យជាគ្រឿងស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ បដិក្កូលមនសិការបព្វៈ ។

(១១៦) ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខ នៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយចំណែកជា គ្រាន់តែជាធាតុថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។ ម្នាលភិក្ខុទាំងឡាយ ពុំសេ អ្នកពិឃាតគោក្តី កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់ គប្បីពិឃាតគោ ហើយពុះចែកជាចំណែកៗ អង្គុយនៅទៀបផ្លូវធំ បែកជាបួន មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅ

យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ ឥតិ អជ្ឈត្តំ វា ។ បេ ។ វិហរតិ ។

ធាតុមនសិការបព្វំ និដ្ឋិតំ (១) ។

(១១៧) បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំ(២) អនតីតោតិ ។ ឥតិ អជ្ឈត្តំ វា ។ បេ ។ វិហរតិ ។

១ ឱ. ធាតុមនសិការបព្វំ និដ្ឋិតំ ន ទិស្សតិ ។ ២ ឱ. ឯតំ ។



យ៉ាងណា ដោយកំណត់ថាគ្រាន់តែជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញ នូវកាយក្នុងកាយជាខាងក្នុង (ដោយការកំណត់ថាជាធាតុ ៤) ជាប្រក្រតី គ្រប់តាំងបដ្ឋានទាំង ៤ យ៉ាងនេះឯង ។ បេ ។

ចប់ ធាតុមនសិការបព្វៈ ។

(១១៧) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមួយទៅទៀត ភិក្ខុឃើញនូវសរីរៈស្លាប់ ដែលគេបោះបង់ចោលក្នុងព្រៃស្មសាន គេស្លាប់អស់១ថ្ងៃក្តី ស្លាប់អស់២ថ្ងៃក្តី ស្លាប់អស់៣ថ្ងៃក្តី ដែលកំពុងហើមមានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេង ៗ ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបធៀបនឹងកាយនេះឯងថា សូម្បីកាយ(១)នេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវអសុភ មានអសុភកំពុងហើមជាដើម) គ្រប់តាំងបដ្ឋានទាំង ៤ យ៉ាងនេះឯង ។ បេ ។

១ អដ្ឋកថា ថា បានដល់កាយដែលនៅមានធម៌ ៣ យ៉ាង គឺ អាយុ ១ កម្តៅភ្លើងធាតុ ១ វិញ្ញាណ ១ ។

[១១៨] បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ កុលលេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ សុវានេហិ វា ខជ្ជមានំ សិគាលេហិ វា ខជ្ជមានំ(១) វិវិធេហិ វា បាណកជាតេហិ ខជ្ជមានំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ(២) ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ

១ ម. សុបាណេហិ វា ខជ្ជមានំ សិគាលេហិ វា ខជ្ជមានំ ។ ឥ. កង្កេហិ វា ខជ្ជមានំ សុនខេហិ វា ខជ្ជមានំ ទីបីហិ វា ខជ្ជមានំ សិគាលេហិ វា ខជ្ជមានំ ។ ២ ម. អយំបិ ។



(១១៨) ម្នាលភិក្ខុទាំងឡាយ ពាក្យតទៅមុខទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេបោះចោលទៅក្នុងព្រៃស្មសាន ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ក្រដក់ក្រដេវទាំងឡាយ កំពុងចឹកស៊ីក្តី ត្មាតទាំងឡាយ កំពុងចឹកស៊ីក្តី សត្វស្វានទាំងឡាយ កំពុងកកេរស៊ីក្តី ចចកទាំងឡាយ កំពុងកកេរស៊ីក្តី ពួកពាណកជាតិ (សត្វល្អិត ១ មានដង្កូវជាដើម ) ទាំងឡាយផ្សេង ៗ កំពុងរូងរាញ់ស៊ីក្តី ដូចម្តេចមិញ ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបនឹងកាយនេះផងថា សូម្បីកាយនេះសោត ក៏មានធម៌មានសភាវៈដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុ ពិចារណាឃើញ នូវកាយក្នុងកាយជាខាងក្នុងជាប្រក្រតី ដោយការកំណត់ នូវសរុក មានសរុក ដែលពួកសត្វកំពុងចឹកស៊ីជាដើម គ្រប់អរិយាបថទាំង ៤ យ៉ាងនេះខ្លះ ពិចារណាឃើញនូវកាយ ក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ខ្លះ ពិចារណាឃើញនូវកាយ ក្នុងកាយ ជាខាងក្នុងផងខាងក្រៅផងជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ខ្លះ ពិចារណាឃើញ នូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងកាយជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ខ្លះ

វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយ-ធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណ-មត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

(១១៩) បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិសង្ខលិកំ សមំសលោហិតំ ន្ហារុសម្ពន្ធំ ។ បេ ។

(១២០) អដ្ឋិសង្ខលិកំ និមំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ ។ បេ ។



ពិចារណាឃើញ នូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយា-បថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ចូលទៅតាំងឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

(១១៩) ម្នាលភិក្ខុទាំងឡាយ ពាក្យតាំងមុខទៅមានទៀត ភិក្ខុ គប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោល ក្នុងព្រៃស្មសាន សល់ទៅតែកង់ឆ្អឹង ប្រកបដោយសាច់និងឈាម មានសរសៃជាគ្រឿងចងជាប់ម្ហួចម៉ិញ ។ បេ ។

(១២០) សរីរៈនៅសល់តែកង់ឆ្អឹង ឥតមានសាច់ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។ បេ ។

(១៦១) អដ្ឋិកសង្ខលិកំ អបគតមំសលោហិតំ ន្ហារុសម្ពន្ធំ ។ បេ ។

(១៦២) អដ្ឋិកានិ អបគតសម្ពន្ធានិ ទិសាវិទិសាវិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដដ្ឋិកំ អញ្ញេន បិដ្ឋិដ្ឋិកំ អញ្ញេន កណ្ដកដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន ឧរដ្ឋិកំ អញ្ញេន អំសដ្ឋិកំ អញ្ញេន ពាហុដ្ឋិកំ អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុកដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហំ(១) ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ

១ ម. អបគតសម្ពន្ធានិ ទិសាវិទិសាសុ វិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរដ្ឋិកំ អញ្ញេន កដដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកំ អញ្ញេន សីសកដាហន្តិ ឯវំ បាឋក្កមោ ទិស្សតិ ។ ម. អបគតសម្ពន្ធានិ ទិសាវិទិសា វិក្ខិត្តានិ ។ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន គោប្ផដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន បិដ្ឋិដ្ឋិកំ អញ្ញេន ខន្ធដ្ឋិកំ អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុកដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហន្តិ ឯវំ បាឋក្កមោ ទិស្សតិ ។



(១៦១) សរីរៈនៅសល់តែរាងឆ្អឹង មិនមានសាច់និងឈាម មានតែសរសៃចងក្រៀវទេ ។ បេ ។

(១៦២) សរីរៈនៅសល់តែឆ្អឹងទទេ មិនមានសរសៃចងប្រឹត ខ្ចាត់ខ្ចាយរាត់រាយទៅគ្រប់ទិសធំទិសតូចនិងទិសសព្វ ឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក ឆ្អឹងព្រុយខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកំភួនដៃទៅដោយឡែក ឆ្អឹងករទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ធ្មេញទៅដោយឡែក លលាដ៍ក្បាលទៅដោយឡែក (ដូចម្តេចមិញ) ។ ភិក្ខុនោះ (កំពង្អោនសរីរៈស្លាប់នោះ) មកប្រៀបធៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ

ឯវំភាវី ឯវំអនតីតោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។



ធម៌នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយ ក្នុងកាយជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវសរីរៈខ្មោចដែលសល់តែឆ្អឹងជាដើម) គ្រប់សរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុងផង ខាងក្រៅជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងនិងធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុ ក៏ផ្ចង់ឡើងចំពោះថា កាយនេះ មានមែន ត្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់សរិយាបថទាំង ៤ ផង មិនជ្រៀតប្រកាន់នូវអ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់សរិយាបថទាំង ៤ យ៉ាងនេះឯង ។

(១៦៣) បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ(១) ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិភាគានិ(២) ។ បេ ។

(១៦៤) អដ្ឋិកានិ បុញ្ជកិតានិ តេរោវស្សិកានិ ។ បេ ។

(១៦៥) អដ្ឋិកានិ បូតីនិ ចុណ្ណកជាតានិ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ

១ ឱ. សីវថិកាយ ។ ២ ឱ. សង្ខវណ្ណូបនិភានិ ។ ម. សង្ខវណ្ណបដិភាគានិ ។



(១៦៣) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមួយទៀត ភិក្ខុ គប្បីឃើញនូវសរីរៈស្លាប់ដែលគេបោះចោលក្នុងព្រៃស្មសាន សល់នៅតែឆ្អឹងខាវ មានសម្បុរស ដូចជាសម្បុរនៃស័ង្ខ ។ បេ ។

(១៦៤) សរីរៈសល់នៅតែឆ្អឹងខាវ គេយកគរជាគំនរ ៗ កន្លងហួសទៅមួយឆ្នាំហើយ ។ បេ ។

(១៦៥) សរីរៈសល់នៅតែឆ្អឹងខាវ ពុកផុយខ្ទិចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេង ៗ (ដូចម្ដេចមិញ) ។ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀប នឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់មានធម៌មាន សភាវៈដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបាន ឡើយ ។ ភិក្ខុ ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងនិងធម៌ដែលសូន្យទៅ ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថ

វិហរតិ ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។

នវសិវថិកាបព្វំ និដ្ឋិតំ ។

កាយានុបស្សនា និដ្ឋិតា(១) ។

(១៤៦) កថញ្ច(២) ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ សុខំ វា(៣) វេទនំ វេទយមានោ(៤) សុខំ វេទនំ វេទយាមីតិ បជានាតិ ទុក្ខំ វា វេទនំ វេទយមានោ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ អទុក្ខមសុខំ វា វេទនំ វេទយមានោ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជា-

---

១ ម. នវសិវថិកាបព្វំ និដ្ឋិតំ ។ កាយានុបស្សនា និដ្ឋិតានិ ៤ ទិស្សតិ ។ ម នវសិវថិកាបព្វំ និដ្ឋិតំ ។ ចុទ្ទស កាយានុបស្សនា និដ្ឋិតា ។ ២ ម. កថញ្ច បន ។ ៣ ម. ភិក្ខុ ។ ៤ ម. វេទិយមានោ ។



ទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់កិរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់នូវអ្វីបន្តិចបន្តួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយ ក្នុងកាយជាប្រក្រតី គ្រប់កិរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ នវសិវថិកបព្វៈ ។

ចប់ កាយានុបស្សនា ។

(១៤៦) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់កិរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា

ជាតិ សាមិសំ វា សុខំ វេទនំ វេទយមានោ សាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា សុខំ វេទនំ វេទយមានោ និរាមិសំ សុខំ វេទនំ វេទយាមីតិ បជានាតិ សាមិសំ វា ទុក្ខំ វេទនំ វេទយមានោ សាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា ទុក្ខំ វេទនំ វេទយមានោ និរាមិសំ ទុក្ខំ វេទនំ វេទយាមីតិ បជានាតិ សាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ សាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ និរាមិសំ វា អទុក្ខមសុខំ វេទនំ វេទយមានោ និរាមិសំ អទុក្ខមសុខំ វេទនំ វេទយាមីតិ បជានាតិ ។ ឥតិ អជ្ឈត្តំ វា វេទនាសុ វេទនានុបស្សី



កាលទទួលសុខវេទនាប្រកបដោយអាមិសៈក្តី(១) ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលសុខវេទនា ប្រកបដោយអាមិសៈ កាលទទួលសុខវេទនាដែលឥតអាមិសៈ(២)ក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលសុខវេទនាដែលឥតអាមិសៈ កាលទទួលទុក្ខវេទនាប្រកបដោយអាមិសៈ(៣) ក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលទុក្ខវេទនាប្រកបដោយអាមិសៈ កាលទទួលទុក្ខវេទនាដែលឥតអាមិសៈ(៤)ក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលទុក្ខវេទនាដែលឥតអាមិសៈ កាលទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិសៈ(៥)ក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិសៈ កាលទទួលអទុក្ខមសុខវេទនាដែលឥតអាមិសៈ(៦)ក្តី ក៏ដឹងច្បាស់ថា អាត្មាអញ ទទួលអទុក្ខមសុខវេទនាដែលឥតអាមិសៈ ។ (ឥតិ) ពិចារណាឃើញ នូវវេទនា ក្នុងវេទនាទាំងឡាយជាខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវវេទនា មានសុខវេទនាជាដើម) យ៉ាងនេះ

---

១ អដ្ឋកថា ថា សោមនស្សវេទនា ដែលអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ហៅថា សាមិសសុខ ។ ២ អដ្ឋកថា ថា បានខាងសោមនស្សវេទនាដែលអាស្រ័យនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។ ៣ បានខាងទោមនស្សវេទនាដែលអាស្រ័យកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ ៤ បានខាងទោមនស្សវេទនាដែលអាស្រ័យនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ ៥ បានខាងឧបេក្ខាវេទនាដែលអាស្រ័យកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ។ ៦ បានខាងឧបេក្ខាវេទនាដែលអាស្រ័យនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ។

វិហរតិ ពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា វេទនាសុ វិហរតិ វយធម្មានុបស្សី វា វេទនាសុ វិហរតិ សមុទយវយធម្មានុបស្សី វា វេទនាសុ វិហរតិ ។ អត្ថិ វេទនាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវំ(១) ខោ ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ។

វេទនានុបស្សនា និដ្ឋិតា(២) ។

១ ម. ឯវំបិ ។ ២ ម. វេទនានុបស្សនា និដ្ឋិតាតិ ន ទិស្សតិ ។



គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញ នូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់នូវវេទនា) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថាវេទនាទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះ ។ (ភិក្ខុ) មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

ចប់ វេទនានុបស្សនា ។

(១៤៧) កថញ្ច ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ



(១៤៧) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ទោះចិត្តរួញ ក៏ដឹងច្បាស់ថា ចិត្តរួញ ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ទោះចិត្តដល់នូវភាវៈជាធំ (រូបាវចរនិងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវៈជាធំ ទោះចិត្តមិនដល់នូវភាវៈជាធំ (ជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈជាធំ (ជាកាមាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈជាធំ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង (នៅជាកាមាវចរ) ក៏ដឹងច្បាស់ថាចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃ ប្រសើរជាង (ជារូបាវចរនិងអរូបាវចរ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ទោះចិត្តតាំងនៅមាំ (ជាអប្បនាសមាធិនិងឧបចារសមាធិ) ក៏ដឹងច្បាស់ថា ចិត្តតាំងនៅមាំ ទោះចិត្តមិនតាំងនៅមាំ (ប្រាសចាកសមាធិ

អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ ឥតិ អជ្ឈត្តំ វា ចិត្តេ ចិត្តានុបស្សី វិហរតិ ពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ វយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ ។ អត្ថិ ចិត្តន្តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ



តាំង ៦) ក៏ដឹងច្បាស់ថា ចិត្តមិនតាំងនៅមាំ ពោះចិត្តរួចស្រឡះ(១) ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ពោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ (ភិក្ខុ) ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើត ទាំងធម៌ដែលសូន្យទៅក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី(ជាគ្រឿងកំណត់នូវចិត្ត) របស់ភិក្ខុនោះ ក៏តំរង់ឡើងចំពោះថា ចិត្តមានមែន គ្រាន់តែជាទីកំណត់

១ ពាក្យថា ចិត្តរួចស្រឡះក្នុងទីនេះ សំដៅយកចិត្តដែលប្រកបដោយវិមុត្តិ ២ ប្រការគឺ តទង្គវិមុត្តិ ១ វិក្ខម្ភនវិមុត្តិ ១ ។ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ហៅថា តទង្គ-វិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកនិច្ចសញ្ញា និងសេចក្តីសម្គាល់ថាទៀង តាមទំនងដែលយោគីបានកំណត់នូវអង្គនៃធម៌ ជាគ្រឿងផ្ទុយនៃធម៌នោះៗ ។ សមាបត្តិ ៨ ហៅថាវិក្ខម្ភន-វិមុត្តិ ព្រោះជាធម្មជាតិ រួចស្រឡះចាកពួកអកុសលធម៌មាននីវរណៈជាដើម តាមទំនងដែលយោគីបានសង្កត់សង្កិនដោយខ្លួនឯង ។ អដ្ឋកថា មហាបទានសូត្រទំព័រ ៦៦ ។

ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។

ចិត្តានុបស្សនា និដ្ឋិតា[1] ។

(១២៨) កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ។ ឥធ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ

១ ម. ចិត្តានុបស្សនា និដ្ឋិតានិ ឆ និស្សតិ ។



ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ (ភិក្ខុមានចិត្តមិនអាស្រ័យដោយតណ្ហានិងទិដ្ឋិ) ទ្រង់សំដែងបទទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី ទ្រង់សំដែងបទទាំង ៤ យ៉ាងនេះឯង ។

ចប់ ចិត្តានុបស្សនា ។

(១២៨) ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី ទ្រង់សំដែងបទទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង ៥ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង ៥ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោះកាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះកាមច្ឆន្ទៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង[1] គឺការយល់របស់នូវកាមច្ឆន្ទៈ ដែល

១ អយោនិសោមនសិការ ជា ការធ្វើទុកក្នុងចិត្តដោយមិនត្រូវតាមប្រាជ្ញា ចំពោះអសុភនិមិត្ត ឬចំពោះសភាវៈមិនទៀងថាទៀង ទុក្ខថាសុខ មិនមែនខ្លួនថាខ្លួន ដូច្នេះជាហេតុនាំឲ្យកើតកាមច្ឆន្ទៈ ។

តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ព្យាបាទំ(១) អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ យថា ច អនុប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស

១ ម. វ្យាបាទំ ។



កើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង(១) កាមច្ឆន្ទៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(២) ។ ពោះព្យាបាទ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្ត របស់អាត្មាអញ ពោះព្យាបាទដែលមិនទាន់កើតឡើងហើយ កើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(៣) ការលះបង់នូវព្យាបាទ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(៤) ព្យាបាទ ដែលលះបង់បានហើយ

១ អដ្ឋកថា ថា ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះសភាវៈមិនទៀងថាមិនទៀងមែន ទុក្ខថាទុក្ខមែន មិនមែនខ្លួនថា មិនមែនខ្លួនពិត ឈ្មោះជាហេតុលះបង់នូវកាមច្ឆន្ទៈ ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការ គឺកំណត់ឲ្យរៀននូវអសុភនិមិត្តក្នុងអារម្មណ៍ជាមិនល្អ ១ ការប្រកបរឿយៗ នូវការចម្រើនអសុភ ១ ការជាអ្នកមានទ្វារគ្រប់គ្រងល្អក្នុងឥន្ទ្រិយទាំងប្រាំមួយ ១ ការជាអ្នកដឹងប្រមាណក្នុងការបរិភោគភោជន ១ ការជាអ្នកកាន់កល្យាណមិត្ត ១ ការជាអ្នករៀន ឬនិយាយតែពាក្យដែលជាទីសប្បាយ ១ ។ ២ កាមច្ឆន្ទៈមិនកើតតទៅទៀត ដោយសារអរហត្តមគ្គ ។ ៣ ការធ្វើទុកក្នុងចិត្ត តែមិនដោយឧបាយប្រាជ្ញា ចំពោះបដិឃនិមិត្តគឺអារម្មណ៍ដែលខ្ទាំងខ្ទប់ចិត្ត ជាហេតុនាំឲ្យកើតព្យាបាទ ។ ៤ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះមេត្តាជាចេតោវិមុត្តិ គឺមេត្តាចិត្តដែលដល់នូវអប្បនាឈាន ជាហេតុឲ្យលះបង់នូវព្យាបាទបាន ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការ គឺ រៀនមេត្តានិមិត្ត ១ ការប្រកបរឿយៗ នូវការចម្រើនមេត្តា ១ ពិចារណាឃើញនូវភាវៈនៃសត្វ ដែលមានកម្មជារបស់ខ្លួន ១ ការជាអ្នកច្រើនដោយការពិចារណា ១ ការជាអ្នកកាន់កល្យាណមិត្ត ១ ការជាអ្នកនិយាយនូវពាក្យជាទីសប្បាយ ១ ។

ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ យថា ច អនុប្បន្នស្ស ថីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ថីនមិទ្ធស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ថីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ យថា ច



មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(១) ។ ពោះថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តអាត្មាអញ ពោះថីនមិទ្ធៈ មិនមានក្នុងសន្តានចិត្ត នៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះថីនមិទ្ធៈដែលមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(២) ការលះបង់នូវថីនមិទ្ធៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង(៣) ថីនមិទ្ធៈ ដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង(៤) ។ ពោះឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ពោះឧទ្ធច្ចកុក្កុច្ចៈ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាន

---

១ អដ្ឋកថា ថា ព្យាបាទមិនកើតតទៅទៀតដោយអនាគាមិមគ្គ ។ ២ ហេតុដែលនាំឲ្យកើតថីនមិទ្ធៈ មាន ៥ ប្រការ គឺ មិនត្រេកអរ ១ ក្រមួល ឬប្រមូលកាយ ១ បិតពត់កាយ ១ ពុលកាយ ១ រួញចិត្ត ១ ។ ៣ ហេតុដែលលះបង់ថីនមិទ្ធៈដោយព្យាយាម ៣ យ៉ាង គឺ ព្យាយាមដែលប្រារព្ធផ្តើមឡើងជាដំបូង ១ ព្យាយាមយ៉ាងកណ្តាលដែលត្រៀងចេញចាកកោសជ្ជៈ (សេចក្តីខ្ជិល) ១ ព្យាយាមយ៉ាងក្រៃលែងដែលតទ្រាំងរួចចាកកោសជ្ជៈ ១ ។ ម្យ៉ាងទៀតថា លះបង់ដោយធម៌ ៦ ប្រការ គឺ កាន់យកនិមិត្តក្នុងការបរិភោគច្រើនប្រមាណ ១ ការកែកិរិយាផ្លាស់ប្តូរឥរិយាបថ ១ ការធ្វើទុកក្នុងចិត្តចំពោះអាលោកសញ្ញា ១ នៅក្នុងទីវាលដែលស្រឡះ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ភាពជាអ្នកនិយាយនូវពាក្យជាទីសប្បាយ ១ ។ ៤ ថីនមិទ្ធៈមិនកើតតទៅទៀត ដោយសារអរហត្តមគ្គ ។

អនុប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ឧទ្ធច្ចកុក្កុច្ចស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ



នៅក្នុងសន្ដានចិត្តរបស់អាត្មាអញ ឯឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ហើយកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(១)ផង ការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(២)ផង ឧទ្ធច្ចកុក្កុច្ចៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(៣)ផង ។ កាលបើវិចិកិច្ឆាមាននៅក្នុងសន្ដានចិត្តខាងក្នុង ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ កាលបើវិចិកិច្ឆាមិនមាននៅក្នុងសន្ដានចិត្តខាងក្នុង ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងសន្ដានចិត្តរបស់អាត្មាអញ វិចិកិច្ឆាមិនទាន់កើតឡើង ហើយកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(៤)ផង ការលះបង់នូវវិចិកិច្ឆាដែលកើតឡើងហើយ ដោយហេតុណា

---

១ អដ្ឋកថា ថា ការធ្វើទុកក្នុងចិត្តដោយឥតឧបាយប្រាជ្ញា ចំពោះធម៌ដែលមិនមែនជាគ្រឿងស្ងប់ចិត្ត ជាហេតុនាំឲ្យកើតឧទ្ធច្ចកុក្កុច្ចៈ ។ ២ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះធម៌ដែលជាគ្រឿងស្ងប់ចិត្ត ជាហេតុលះបង់នូវឧទ្ធច្ចកុក្កុច្ចៈបាន ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការ គឺ ភាវៈជាអ្នកចេះដឹងឬស្ដាប់ច្រើន១ ភាវៈជាអ្នកសួរសាកសួរ១ ភាវៈជាអ្នកចេះដឹងស្ទាត់ក្នុងវិន័យ១ ភាវៈជាអ្នកសេពគប់បុគ្គលដែលចាស់ទុំ១ ភាវៈជាអ្នកមានកល្យាណមិត្ត១ ភាវៈជាអ្នកនិយាយនូវពាក្យដែលជាទីសប្បាយ១ ។ ៣ ឧទ្ធច្ចៈមិនកើតតទៅទៀត ដោយសារអរហត្តមគ្គ កុក្កុច្ចៈមិនកើតតទៅទៀត ដោយសារអនាគាមិមគ្គ ។ ៤ ការធ្វើទុកក្នុងចិត្តដោយឥតឧបាយប្រាជ្ញា ចំពោះធម៌ដែលជាទីតាំងនៃសេចក្ដីសង្ស័យ ជាហេតុនាំឲ្យកើតវិចិកិច្ឆា ។

តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ ។ អត្ថិ ធម្មាតិ វា បនស្ស សតិ



ក៏ដឹងច្បាស់នូវហេតុនោះ(១)ផង វិចិកិច្ឆាដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(២)ផង ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី (ដោយការកំណត់នូវនីវរណធម៌ ៥ យ៉ាង) គ្រប់សំរាយបទតាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់សំរាយបទតាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់សំរាយបទតាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់សំរាយបទតាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់សំរាយបទតាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើត ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់សំរាយបទតាំង ៤ ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ

---

១ អដ្ឋកថា ថា ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ចំពោះកុសលធម៌ជាដើម ជាហេតុឲ្យលះបង់វិចិកិច្ឆាបាន ។ មួយទៀតថា លះបង់ដោយធម៌ ៦ ប្រការ គឺ ភាវៈជាអ្នកចេះដឹងឬស្តាប់ច្រើន ១ ភាវៈជាអ្នកសួរសាកសួរ ១ ភាវៈជាអ្នកចេះដឹងស្ទាត់ក្នុងវិន័យ ១ ភាវៈជាអ្នកច្រើនទៅដោយចិត្តដែលជឿស៊ប់ ១ ភាវៈជាអ្នកគប់រកកល្យាណមិត្រ ១ ជាអ្នកនិយាយនូវពាក្យគួរទីសប្បាយ ១ ។ ២ វិចិកិច្ឆាមិនកើតតទៅទៀត ដោយសារសោតាបត្តិមគ្គ ។

បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ(១) ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ។

នីវរណបព្វំ និដ្ឋិតំ(២) ។

(១៦៨) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ(៣) ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ។ ឥធ ភិក្ខវេ ភិក្ខុ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា

១ ម. ឯវំ ។ ម. ឯវម្បិ ។ ២ ម. នីវរណបព្វំ និដ្ឋិតន្តិ ន ទិស្សតិ ។ ៣ ម. បញ្ចសុបាទានក្ខន្ធេសុ ។



គឺស្មារតីចូលទៅតាំងមាំថា ធម៌ទាំងឡាយ មានមែន ត្រឹមតែជាទីកំណត់ ដើម្បីឲ្យបរិបូណ៌ប្រាជ្ញា ដើម្បីឲ្យបរិបូណ៌ស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិងទិដ្ឋិ) គ្រប់គ្រងឥរិយាបថទាំង៤ផង មិនប្រកាន់ប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈទាំង៥ ជាប្រក្រតី គ្រប់គ្រងឥរិយាបថទាំង៤ យ៉ាងនេះឯង ។

ចប់ នីវរណបព្វៈ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ពាក្យតាំងមុខទៅមានតទៅទៀត ភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង៥ ជាប្រក្រតី គ្រប់គ្រងឥរិយាបថទាំង៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង៥ ជាប្រក្រតី គ្រប់គ្រងឥរិយាបថទាំង៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ (ពិចារណាឃើញដូច្នេះថា) រូប មានប្រមាណប៉ុណ្ណេះ(១) ធម៌ដែលជាទីកើតឡើងនៃរូប មានប្រមាណប៉ុណ្ណេះ(២) ធម៌ដែលជាដែនវិនាសទៅនៃរូប មានប្រមាណប៉ុណ្ណេះ(៣) វេទនា មាន

១-២-៣ មានសេចក្តីពន្យល់ក្នុងសតិប្បដ្ឋានសូត្រ មជ្ឈិមនិកាយមូលបណ្ណាសកៈ ត្រង់ខ្ទង់ ខន្ធបព្វៈនោះហើយ ។

ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ



ប្រមាណប៉ុណ្ណេះ(១) ធម៌ដែលជាដែនកើតឡើងនៃវេទនា មានប្រមាណប៉ុណ្ណេះ(២) ធម៌ដែលជាដែនវិនាសទៅនៃវេទនា មានប្រមាណប៉ុណ្ណេះ(៣) សញ្ញា មានប្រមាណប៉ុណ្ណេះ(៤) ធម៌ដែលជាដែនកើតឡើងនៃសញ្ញា មានប្រមាណប៉ុណ្ណេះ(៥) ធម៌ដែលជាដែនវិនាសទៅនៃសញ្ញា មានប្រមាណប៉ុណ្ណេះ(៦) សង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ(៧) ធម៌ដែលជាដែនកើតឡើងនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ(៨) ធម៌ដែលជាដែនវិនាសទៅនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ(៩) វិញ្ញាណ មានប្រមាណប៉ុណ្ណេះ(១០) ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ(១១) ធម៌ដែលជាដែនវិនាសទៅនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ(១២) ។ ភិក្ខុ ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើត ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង

១-២-៣-៤-៥-៦-៧-៨-៩-១០-១១-១២ មានសេចក្ដីពណ៌នា ក្នុងសតិប្បដ្ឋានសូត្រ មជ្ឈិមនិកាយ មូលបណ្ណាសកៈ ព្រះអង្គទ្រង់ពន្យល់រួចហើយ ។

វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយ-
វយធម្មានុបស្សី វា ធម្មេសុ វិហរតិ ។ អត្ថិ ធម្មាតិ
វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណ-
មត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ
ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ខោ ភិក្ខវេ
ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបា-
ទានក្ខន្ធេសុ ។

ខន្ធបព្វំ និដ្ឋិតំ(១) ។

(១៣០) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មា-
នុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេ-
សុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី
វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។

---

១ ម. ឥទំ បទ្វយំ នត្ថិ ។



ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់
នរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងនិង
ធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់នរិយាបថទាំង ៤
ផង ។ មួយទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ផ្ចង់
ឡើងចំពោះថា ធម៌មានមែន គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា
ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយ
តណ្ហានិងទិដ្ឋិ) គ្រប់នរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច
ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុង
ធម៌ទាំងឡាយ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់នរិយាបថទាំង ៤
យ៉ាងនេះឯង ។

ចប់ ខន្ធបព្វៈ ។

(១៣០) ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុ
ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុងទាំង
ខាងក្រៅជាប្រក្រតី គ្រប់នរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះ
ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង
ទាំងខាងក្រៅជាប្រក្រតី គ្រប់នរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ រូបេ ច បជា-
នាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ(១)
តញ្ច បជានាតិ យថា ច អនុប្បន្នស្ស សញ្ញោជនស្ស
ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស
សញ្ញោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា
ច បហីនស្ស សញ្ញោជនស្ស អាយតឹ អនុប្បាទោ
ហោតិ តញ្ច បជានាតិ ។ សោតញ្ច បជានាតិ សទ្ទេ ច
បជានាតិ ។ ឃានញ្ច បជានាតិ គន្ធេ ច បជានា-
តិ ។ ជិវ្ហញ្ច បជានាតិ រសេ ច បជានាតិ ។
កាយញ្ច បជានាតិ ផោដ្ឋព្វេ ច បជានាតិ ។
មនញ្ច បជានាតិ ធម្មេ ច បជានាតិ យញ្ច តទុភយំ
បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ តញ្ច បជានាតិ យថា
ច អនុប្បន្នស្ស សញ្ញោជនស្ស ឧប្បាទោ ហោតិ

១ ម. ក. សំយោជនំ ។



ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវភ្នែកផង ដឹង
ច្បាស់នូវរូបទាំងឡាយផង មួយវិញទៀត សញ្ញោជនៈណា អាស្រ័យ
នូវភ្នែកនិងរូបទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈ
នោះ(១)ផង សញ្ញោជនៈដែលមិនទាន់កើតឡើងហើយកើតឡើង ដោយ
ហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈ
ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោ-
ជនៈដែលលះបង់បានហើយមិនកើតតទៅទៀត ដោយហេតុណា ក៏ដឹង
ច្បាស់នូវហេតុនោះផង ។ ភិក្ខុ ដឹងច្បាស់នូវត្រចៀកផង ដឹងច្បាស់នូវ
សំឡេងទាំងឡាយផង ។ ដឹងច្បាស់នូវច្រមុះផង ដឹងច្បាស់នូវក្លិនទាំង-
ឡាយផង ។ ដឹងច្បាស់នូវអណ្តាតផង ដឹងច្បាស់នូវរសទាំងឡាយផង ។
ដឹងច្បាស់នូវកាយផង ដឹងច្បាស់នូវផោដ្ឋព្វៈទាំងឡាយផង ។ ដឹងច្បាស់
នូវចិត្តផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង សញ្ញោជនៈណា អា-
ស្រ័យនូវចិត្តនិងធម្មារម្មណ៍ទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវ
សញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើងហើយកើតឡើង

១ អដ្ឋកថា ថា កិលេសជាគ្រឿងចងសត្វទុក ហៅថា សញ្ញោជនៈ មាន ១០ យ៉ាង គឺ កាមរាគៈ ១ បដិឃៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ភវរាគៈ ១ ឥស្សា ១ មច្ឆរិយៈ ១ អវិជ្ជា ១ ។

តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សញ្ញោ-

ជនស្ស បហានំ ហោតិ តញ្ច បជានាតិ

យថា ច បហីនស្ស សញ្ញោជនស្ស អាយតឹ

អនុប្បាទោ ហោតិ តញ្ច បជានាតិ ។

ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ



ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(១)ផង កិរិយាលះបង់បាន នូវសញ្ញោជនៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ (២) ផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(៣) ផង ។ ភិក្ខុ ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ ខាងក្នុង ជាប្រក្រតី

១ អដ្ឋកថា ថា សំយោជនៈទាំង ១០ កើតឡើងព្រោះអាស្រ័យហេតុផ្សេងគ្នា គឺកាម-រាគសំយោជនៈ គឺការត្រេកត្រអាលដោយអំណាចកាមចំពោះអារម្មណ៍គួរប្រាថ្នា ដែលមកកាន់គន្លងចក្ខុទ្វារ ។ បដិឃសំយោជនៈ គឺសេចក្តីក្រេវក្រោធចំពោះអារម្មណ៍ដែលមិនគួរប្រាថ្នា ។ មានសំយោជនៈ គឺសេចក្តីសម្គាល់ថា វៀរលែងតែអាត្មាអញ មិនមានអ្នកណាមួយ អាចប្រើនូវអារម្មណ៍នុះបានឡើយ ។ ទិដ្ឋិសំយោជនៈ គឺសេចក្តីប្រកាន់នូវរូបារម្មណ៍នុះថាទៀង ថាឋិតថេរ ។ វិចិកិច្ឆាសំយោជនៈ គឺសេចក្តីសង្ស័យចំពោះរូបារម្មណ៍នុះ ថាជាសត្វ ឬថាជារបស់សត្វ ។ ភវ-រាគសំយោជនៈ គឺសេចក្តីប្រាថ្នានូវភពថា ភពនេះយើងនឹងបានដោយងាយក្នុងសម្បត្តិភព ។ សីលព្វតបរាមាសសំយោជនៈ គឺសេចក្តីប្រកាន់នូវសីលព្វតថា សីលព្វតយ៉ាងនេះ យើងអាចសមាទានកាន់យកបាន ។ ឥស្សាសំយោជនៈ គឺសេចក្តីប្រណែនថា សូមកុំឲ្យជនដទៃបានរូបារម្មណ៍នេះឡើយ ។ មច្ឆរិយសំយោជនៈ គឺសេចក្តីកំណាញ់លាក់លៀមរូបារម្មណ៍ដែលខ្លួនបានហើយ នឹងបុគ្គលដទៃ ។ អវិជ្ជាសំយោជនៈ គឺសេចក្តីមិនដឹងនូវសហជាតធម៌ទាំងអស់ ។ ២ លះបង់ដោយបហានៈ ២ យ៉ាងគឺ តទង្គប្បហានៈ ១ វិក្ខម្ភនប្បហានៈ ១ ។ ៣ សំយោជនៈទាំង ៥ ប្រការគឺ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ ដែលមិនកើតទៅទៀត ដោយសារសោតាបត្តិមគ្គ ។ កាមរាគៈ បដិឃៈ ទាំងពីរ ដែលនៅគ្រោតគ្រាត មិនកើតទៅទៀត ដោយសារសកទាគាមិមគ្គ ។ ដែលល្អិតល្អន់ មិនកើតទៅទៀត ដោយសារអនាគាមិមគ្គ ។ មានៈ ១ ភវរាគៈ ១ អវិជ្ជា ១ ដែលមិនកើតទៅទៀត ដោយសារអរហត្ត-មគ្គ ។ ឯសំយោជនៈដែលកើតអាស្រ័យ នូវទ្វារឯទៀត ច្រមុះ អណ្តាត កាយ ចិត្ត ក៏ត្រូវតាមន័យនេះដែរ ។

ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្ត-
ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទ-
យធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុ-
បស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មា-
នុបស្សី វា ធម្មេសុ វិហរតិ ។ អត្ថិ ធម្មាតិ វា
បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណ-
មត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ
ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ខោ
ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ
អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។

អាយតនបព្វំ និដ្ឋិតំ(១) ។

១ ម. អាយតនបព្វំ និដ្ឋិតន្តិ ន ទិស្សតិ ។



គ្រប់អាយតនៈទាំង ៦ យ៉ាងនេះខ្លះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំង-
ឡាយខាងក្រៅជាប្រក្រតី គ្រប់អាយតនៈទាំង ៦ ខ្លះ ពិចារណាឃើញ
នូវធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់អា-
យតនៈទាំង ៦ ខ្លះ ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុង
ធម៌ទាំងឡាយជាប្រក្រតី គ្រប់អាយតនៈទាំង ៦ ខ្លះ ពិចារណាឃើញនូវ
ធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់អាយតនៈទាំង ៦ ខ្លះ
ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង និងធម៌ដែលសូន្យទៅ
ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់អាយតនៈទាំង ៦ ខ្លះ ។ មួយទៀត
ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏តាំងឡើងចំពោះថា ធម៌
ទាំងឡាយមានមែន ត្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បី
ឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយតណ្ហា
និងទិដ្ឋិ) គ្រប់អាយតនៈទាំង ៦ ខ្លះ មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុង
លោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌
ទាំងឡាយគឺអាយតនៈ ៦ ទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់
អាយតនៈទាំង ៦ យ៉ាងនេះឯង ។

ចប់ អាយតនបព្វៈ ។

[១៣១] បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាបារិបូរី(១) ហោតិ តញ្ច បជានាតិ ។

១ ម. ឱ. ភាវនាយ បារិបូរី ។



(១៣១) ម្នាលភិក្ខុទាំងឡាយ ពាក្យដទៃមួយទៀតមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ប្រការជាប្រក្រតី គ្រប់អរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ៧ ប្រការជាប្រក្រតី គ្រប់អរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលសតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ កាលសតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ កាលសតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ(១)ផង កិរិយាចម្រើនពេញបរិបូណ៌ នៃសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះ(២)ផង ។

១-២ អដ្ឋកថា ថា ការធ្វើយោនិសោមនសិការៈឲ្យច្រើនក្នុងសម្ពោជ្ឈង្គនោះ ជាហេតុនាំឲ្យសតិសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ឬដែលកើតឡើងហើយ រីឯរីកតែប្រព្រឹត្តទៅមិនរសាយ ចម្រើនឡើង ពេញបរិបូណ៌ដោយភាវនា ។ មួយទៀត ធម៌ដែលជាហេតុនាំឲ្យកើតសតិសម្ពោជ្ឈង្គនោះ មាន ៤ យ៉ាង គឺ ត្រូវឲ្យមានសតិសម្បជញ្ញៈក្នុងទីទាំង ៧ មានដើរទៅមុខជាដើម ១ វៀរចាកបុគ្គលភ្លេចស្មារតី ១ គប់រកបុគ្គលដែលមានស្មារតីខ្ជាប់ខ្ជួន ១ បង្អោនចិត្តទៅដើម្បីតម្កល់សតិគ្រប់ឥរិយាបថ ១ ។

សន្តំ វា អជ្ឈត្តំ ធម្មវិចយសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ វីរិយសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ បីតិសម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ បស្សទ្ធិ-សម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ សមាធិ-



ពោះធម្មវិចយសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ(១) ។ ពោះវីរិយ-សម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ(២) ។ ពោះបីតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ(៣) ។ ពោះបស្សទ្ធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ(៤) ។ ពោះសមាធិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្ត

---

១ អដ្ឋកថា ថា ធម៌ដែលជាហេតុនាំឲ្យកើតធម្មវិចយសម្ពោជ្ឈង្គមាន ៧ គឺ សាកសួរ ១ ធ្វើវត្ថុខាងក្នុងគឺសក់ រោមជាដើម និងវត្ថុខាងក្រៅគឺ បរិក្ខារ សេនាសនៈជាដើមឲ្យស្អាត ១ ប្រមូលឥន្ទ្រិយទាំង ៥ មានសទ្ធិន្ទ្រិយជាដើមឲ្យស្មើគ្នា ១ វៀរចាកបុគ្គលដែលសាប់ឥតប្រាជ្ញា ១ រាប់រកបុគ្គលដែលមានប្រាជ្ញា ១ ពិចារណាចំពោះបញ្ហាធម៌ជ្រៅដោយញាណចរិយា ១ បង្អោនចិត្តទៅដើម្បីកំណត់ធម្មវិចយសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ ២ ធម៌ដែលជាហេតុនាំឲ្យកើតវីរិយសម្ពោជ្ឈង្គមាន ១១ គឺ ពិចារណាឃើញនូវភ័យក្នុងអបាយ ១ ឃើញនូវអានិសង្ស(នៃការព្យាយាម)១ ពិចារណាឃើញនូវផ្លូវដែលខ្លួនទៅ ១ គោរពក្រែងចំពោះបិណ្ឌបាត ១ ពិចារណាឃើញនូវអរិយទ្រព្យទាំង ៧ ថាជាទ្រព្យធំ ១ នូវព្រះសាស្ដាជាធំ ១ នូវជាតិជាធំ ១ នូវសព្រហ្មចារីបុគ្គលជាធំ ១ វៀរចាកបុគ្គលខ្ជិលច្រអូស ១ រាប់រកបុគ្គលមានព្យាយាម ១ បង្អោនចិត្តទៅដើម្បីកំណត់នូវវីរិយសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ ៣ ធម៌ដែលជាហេតុនាំឲ្យកើតបីតិសម្ពោជ្ឈង្គមាន ១១ គឺ រលឹក ចំពោះព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ សីល ១ បរិច្ចាគ ១ ធម៌នាំឲ្យកើតជាទេវតា ១ ព្រះនិព្វាន ១ វៀរចាកបុគ្គលមិនស្អាត ១ រាប់រកបុគ្គលស្អាត ១ ពិចារណាតាមបសាទនីយសូត្រ ១ បង្អោនចិត្តទៅដើម្បីតម្កល់បីតិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ ៤ ធម៌ដែលជាហេតុនាំឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គមាន ៧ គឺ ត្រូវការភោជនថ្លៃថ្លា ១ ត្រូវការរដូវសប្បាយ ១ ត្រូវការឥរិយាបថសប្បាយ ១ ប្រកបខ្លួនឲ្យតាំងនៅជាកណ្ដាល ១ វៀរចាកបុគ្គលអ្នករសូនច្រែកកាយ ១ រាប់រកបុគ្គលដែលមានកាយស្ងប់ស្ងាត់ ១ បង្អោនចិត្តទៅដើម្បីតម្កល់បស្សទ្ធិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

សម្ពោជ្ឈង្គំ ។ បេ ។ សន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧបេក្ខាសម្ពោជ្ឈង្គស្ស ភាវនាបារិបូរី(១) ហោតិ តញ្ច បជានាតិ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ

១ ម. ម. ភាវនាយ បារិបូរី ។



នៃខ្លួន ។ បេ(១) ។ កាលឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ កាលឧបេក្ខាសម្ពោជ្ឈង្គ មិនមានក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គ មិនមានក្នុងសន្តានចិត្តរបស់អាត្មាអញ កាលឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ហើយកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់ នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូណ៌នៃឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ(២)ផង ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់

អដ្ឋកថា ថា ធម៌ជាហេតុនាំឲ្យកើតសមាធិសម្ពោជ្ឈង្គ មាន ១១ គឺ ធ្វើវត្ថុខាងក្នុងនិងខាងក្រៅឲ្យស្អាត ១ ប្រមូលឥន្ទ្រិយទាំង ៥ ឲ្យស្មើគ្នា ១ ឈ្លាសក្នុងកសិណនិមិត្ត ១ ផ្គងចិត្តឡើងតាមសម័យ ១ សង្កត់សង្កិនចិត្តតាមសម័យ ១ ធ្វើចិត្តឲ្យរីករាយ (ចំពោះសំវេគវត្ថុ ៨ ប្រការ) តាមសម័យ ១ ធ្វើចិត្តឲ្យសម្ងំ (ផ្លូវអារម្មណ៍) ១ វៀរចាកបុគ្គលដែលមានចិត្តមិនខ្ជាប់ខ្ជួន ១ គប់រកបុគ្គលដែលមានចិត្តខ្ជាប់ខ្ជួន ១ ពិចារណានូវឈានវិមោក្ខ ១ បង្អោនចិត្តទៅ ដើម្បីឲ្យកើតបស្សទ្ធិសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។ ២ ធម៌ដែលជាហេតុនាំឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គ មាន ៥ គឺ ធ្វើចិត្តឲ្យតាំងនៅជាកណ្តាលចំពោះសត្វ ១ ធ្វើចិត្តឲ្យតាំងនៅកណ្តាលចំពោះសង្ខារ ១ វៀរចាកបុគ្គលដែលមានការទំនុកបម្រុងចំពោះសត្វនិងសង្ខារ ១ គប់រកបុគ្គលដែលមានចិត្តជាកណ្តាលចំពោះសត្វនិងសង្ខារ ១ បង្អោនចិត្តទៅដើម្បីឲ្យកើតឧបេក្ខាសម្ពោជ្ឈង្គគ្រប់ឥរិយាបថ ១ ។

សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មា-
នុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី
វា ធម្មេសុ វិហរតិ ។ អត្ថិ ធម្មាតិ វា បនស្ស សតិ
បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិ-
មត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ
លោកេ ឧបាទិយតិ ។ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ
ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។

ពោជ្ឈង្គបព្វំ និដ្ឋិតំ ។

បឋមភាណវារំ(១) ។

១ ឱ. ម. បឋមភាណវារំ និដ្ឋិតំ ។



ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង
ក្នុងធម៌ទាំងឡាយ ជាប្រក្រតី ត្រង់ឥរិយាបថទាំង ៤ ផង ពិចារណា
ឃើញនូវធម៌ដែលសូន្យទៅ ក្នុងធម៌ទាំងឡាយ ជាប្រក្រតី ត្រង់ឥរិយា-
បថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលទាំងជាទីប្រជុំកើតទាំងសូន្យ
ទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី ត្រង់ឥរិយាបថទាំង ៤ ផង ។ មួយ
ទៀត ស្មារតី (ជាគ្រឿងកំណត់) របស់ភិក្ខុនោះ ក៏ដំកល់ឡើងចំពោះថា
ធម៌ទាំងឡាយមានមែន ត្រាន់តែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា
ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (ដោយ
តណ្ហានិងទិដ្ឋិ) ត្រង់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីមួយ
ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុង
ធម៌ទាំងឡាយ គឺ ពោជ្ឈង្គទាំង ៧ ជាប្រក្រតី ត្រង់ឥរិយាបថទាំង ៤
យ៉ាងនេះឯង ។

ចប់ ពោជ្ឈង្គបព្វៈ ។

ចប់ បឋមភាណវារៈ ។

(១៣៤) បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។ កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ កតមញ្ច ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោបិ ទុក្ខោ បិយេហិ វិប្បយោគោបិ



(១៣៤) ម្នាលភិក្ខុទាំងឡាយ ពាក្យតអំពីនុះទៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ អរិយសច្ចទាំង ៤ គ្រប់អរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ គ្រប់អរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះទុក្ខអរិយសច្ចតើដូចម្តេច ។ ជាតិគឺកំណើតដែលកើតជាដំបូង ក៏ជាទុក្ខ ជរាគឺសេចក្តីចាស់គ្រាំគ្រា ក៏ជាទុក្ខ មរណៈគឺសេចក្តីស្លាប់ ក៏ជាទុក្ខ សោកៈគឺសេចក្តីស្តាយស្រណោះ បរិទេវៈគឺសេចក្តីខ្សឹកខ្សួល ទុក្ខៈគឺសេចក្តីលំបាកកាយ ទោមនស្សគឺសេចក្តីអាក់អន់តូចចិត្ត ឧបាយាសៈគឺសេចក្តីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ អប្បិយេហិសម្បយោគៈគឺដំណើរជួបប្រសព្វដោយសត្វនិងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ ក៏ជាទុក្ខ បិយេហិវិប្បយោគៈ គឺសេចក្តីព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយដែល

ទុក្ខា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា(១) ។

(១៣៣) កតមា ច ភិក្ខវេ ជាតិ ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ(២) អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភិក្ខវេ ជាតិ ។ កតមា ច ភិក្ខវេ ជរា ។ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិតចតា(៣) អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ភិក្ខវេ ជរា ។ កតមញ្ច ភិក្ខវេ មរណំ ។ យា(៤) តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្សុបច្ឆេទោ

១ ម. ជាតិបិ ទុក្ខា ជរាបិ ទុក្ខា ព្យាធិបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខាតិ បាឋន្តរោ ទិស្សតិ ។ ២ ម. និព្វត្តិ ន ទិស្សតិ ។ ៣ វលិត្តចតាតិបិ បាឋោ ។ ៤ ម. យាទិសំ ។ ម. ជុំ ។



ជាទីស្រឡាញ់ ក៏ជាទុក្ខ ការប្រាថ្នាមិនបានសម្រេចតាមបំណង កាលបើប្រាថ្នានូវរបស់ណា តែមិនបាន ឯការមិនបានរបស់នោះ ក៏ជាទុក្ខ ហើយដោយសេចក្តីបំព្រួញ ឧបាទានក្ខន្ធទាំង៥ មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ ។

(១៣៣) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ជាតិ ។ កិរិយាកើតជាដំបូង កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការវិលត្រឡប់មកកើត ការកើតប្រាកដនៃខន្ធ ការបាននូវអាយតនៈ ណា របស់សត្វនោះៗ ក្នុងសត្វនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ជាតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ជរា ។ ជរា គឺសេចក្តីចាស់គ្រាំគ្រាឬការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយារ ការរួញថយនៃអាយុ ការទ្រុឌទ្រោមនៃឥន្ទ្រិយទាំងឡាយ ណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្វនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ជរា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា មរណៈ ។ ការរះនៃចិត្តដែលឃ្លាតចេញ ភាពការរះនៃចិត្តដែលឃ្លាតទៅ ការបែកធ្លាយទៅ ការបាត់បង់ទៅ សេចក្តីខាតជីវិត សេចក្តីស្លាប់ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិលនូវជីវិតិន្ទ្រិយ ណា របស់សត្វទាំងឡាយនោះៗ ចាកសត្វនិកាយ

ឥទំ វុច្ចតិ ភិក្ខវេ មរណំ ។ កតមោ ច ភិក្ខវេ សោកោ ។ យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ អយំ វុច្ចតិ ភិក្ខវេ សោកោ ។ កតមោ ច ភិក្ខវេ បរិទេវោ ។ យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ អយំ វុច្ចតិ ភិក្ខវេ បរិទេវោ ។ កតមញ្ច ភិក្ខវេ ទុក្ខំ ។ យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ ។ កតមញ្ច ភិក្ខវេ





ទោះ ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា មរណៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សោកៈ ។ ម្នាលភិក្ខុទាំងឡាយ សោកៈ គឺសេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោកសៅ សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្ត ណា របស់សត្វ ដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ (ឬ) ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា សោកៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈខ្សឹករក (បិយជនមានកូនជាដើម) សភាវៈខ្សឹករៀបរាប់ (សរសើរគុណ) កិរិយាយំអណ្តឺតអណ្តក កិរិយាយំបម្រះខ្សឹកខ្សៀល ភាវៈនៃការយំអណ្តឺតអណ្តក ភាវៈនៃការយំបម្រះខ្សឹកខ្សៀល ណា របស់សត្វដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ (ឬ) ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា បរិទេវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកកាយ សេចក្តីមិនសប្បាយកាយ សេចក្តីលំបាកដែលកើតអំពីកាយសម្ផស្ស ការទទួលនូវសេចក្តីមិនស្រួល ណា ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ទុក្ខៈ ។ ម្នាលភិក្ខុទាំង-

ទោមនស្សំ ។ យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សំ ។ កតមោ ច ភិក្ខវេ ឧបាយាសោ ។ យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ ភិក្ខវេ ឧបាយាសោ ។ កតមោ ច ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ ឥធ យស្ស តេ ហោន្តិ អនិដ្ឋា អកន្តា អមនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកកាមា អយោគក្ខេមកាមា តេហិ សទ្ធឹ សង្គតិ សមាគមោ សមោធានំ មិស្សីភាវោ



ឡាយ ចុះម្តេចក៏ហៅថា ទោមនស្ស ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកក្នុងចិត្ត សេចក្តីមិនសប្បាយក្នុងចិត្ត សេចក្តីលំបាកដែលកើតអំពីមនោសម្ផស្ស ការទទួលអារម្មណ៍មិនស្រួល ណា ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ទោមនស្ស ។ ម្នាលភិក្ខុទាំងឡាយ ចុះម្តេចក៏ហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីតានតឹងក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ភាពនៃសេចក្តីតានតឹងក្នុងចិត្ត ភាពនៃសេចក្តីចង្អៀតចង្អល់ចិត្ត ណា របស់សត្វ ដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ ( ឬ ) ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ឧបាយាសៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះម្តេចក៏ហៅថា អប្បិយេហិសម្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មានដល់បុគ្គលណាក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយ ណា ប្រាថ្នានូវសេចក្តីមិនចម្រើន ប្រាថ្នានូវអំពើឥតប្រយោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវអំពើដែលមិនក្សេមចាកយោគៈ ចំពោះបុគ្គលនោះ កិរិយាបានជួបគ្នា កិរិយាជួបជុំគ្នា កិរិយាប្រជុំគ្នា ការនៅច្រឡូកច្រឡំគ្នា នឹងអារម្មណ៍ទាំងឡាយនោះ ១ នឹងជនទាំងឡាយនោះ ១

អយំ វុច្ចតិ ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ កតមោ ច ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ ។ ឥធ យស្ស តេ ហោន្តិ ឥដ្ឋា កន្តា មនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតា វា ភគិនី វា មិត្តា វា អមច្ចា វា ញាតិសាលោហិតា វា តេហិ អសង្គតិ អសមាគមោ អសមោធានំ អមិស្សីភាវោ អយំ វុច្ចតិ ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ(១) ។ កតមញ្ច ភិក្ខវេ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ជាតិធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន ជាតិធម្មា អស្សាម ន ច វត នោ ជាតិ

១ ឧភោបិយបោត្ថកេ កតមោ ច ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ។ ឥធ យស្ស តេ ហោន្តិ ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោតិ បាឋោ ៦ ទិស្សន្តិ ។



ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា អប្បិយេហិសម្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា បិយេហិវិប្បយោគទុក្ខ ។ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានដល់បុគ្គលណា ក្តីណោះនេះ ពុំនោះសោត ជនទាំងឡាយណា ពោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្រក្តី អមាត្យក្តី ញាតិសាលោហិតក្តី ដែលជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសប្បាយ ប្រាថ្នានូវសេចក្តីក្សេមចាកយោគៈ ចំពោះបុគ្គលនោះ ការមិនបានជួបគ្នា ការមិនបានជួបជុំគ្នា ក៏ឬការមិនបានប្រជុំគ្នា ការមិនទៅច្រឡូកច្របល់ នឹងអារម្មណ៍ទាំងឡាយនោះ ៗ នឹងជនទាំងឡាយនោះ ៗ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា បិយេហិវិប្បយោគទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា យម្បិច្ឆំនលភតិតម្បិទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលមានជាតិជាធម្មតា កើតមានសេចក្តីប្រាថ្នាកើតឡើង យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ខ្លួនយើងទាំងឡាយ កុំគប្បីមានជាតិជាធម្មតា ពុំនោះសោត ជាតិ កុំ

អាគច្ឆេយ្យាតិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ ជរាធម្មានំ ភិក្ខវេ សត្តានំ ។ ព្យាធិធម្មានំ ភិក្ខវេ សត្តានំ ។ មរណធម្មានំ ភិក្ខវេ សត្តានំ ។ សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា អស្សាម ន ច វត នោ សោកបរិទេវទុក្ខទោមនស្សុបាយាសា អាគច្ឆេយ្យុន្តិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ កតមេ ច ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា



កុំបីមកដល់យើងទាំងឡាយ សេចក្តីនេះ ពួកសត្វ ក៏មិនបានសម្រេចតាមប្រាថ្នាសោះឡើយ នេះឯង ឈ្មោះថា យម្បិច្ឆំនលភតិតម្បិទុក្ខំ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលមានសេចក្តីគ្រាំគ្រា ឬប្រែប្រួលជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលមានសេចក្តីឈឺថ្កាត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលមានសេចក្តីស្លាប់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វ ដែលមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតាក់តែងទូលចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ជាធម្មតា តែងមានសេចក្តីប្រាថ្នាកើតឡើង យ៉ាងនេះថា ធ្វើម្តេចហ្ន៎ ឲ្យយើងទាំងឡាយកុំគប្បីមានសេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតាក់តែងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ជាធម្មតា កុំនោះសោក សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីតាក់តែងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត កុំគប្បីមកដល់យើងទាំងឡាយឡើយ សេចក្តីនេះ ពួកសត្វ ក៏មិនបានសម្រេចតាមប្រាថ្នាឡើយ នេះឯង ក៏ឈ្មោះថា យម្បិច្ឆំនលភតិតម្បិទុក្ខំ ដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចឧបាទានក្ខន្ធទាំង ៥ ដោយសេចក្តីបង្រួញ

ទុក្ខា ។ សេយ្យថីទំ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។

[១៣៦] កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។

[១៣៧] សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ ។



ដែលជាទុក្ខ ។ ឧបាទានក្ខន្ធទាំង ៥ នោះគឺអ្វីខ្លះ គឺ រូប ជាឧបាទានក្ខន្ធ១ វេទនា ជាឧបាទានក្ខន្ធ១ សញ្ញា ជាឧបាទានក្ខន្ធ១ សង្ខារ ជាឧបាទានក្ខន្ធ១ វិញ្ញាណ ជាឧបាទានក្ខន្ធ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះ តថាគតហៅថា ឧបាទានក្ខន្ធទាំង ៥ ដោយសេចក្តីបង្រួញ ជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ទុក្ខអរិយសច្ច ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា ទុក្ខសមុទយអរិយសច្ច ។ តណ្ហាណា ជាធម្មជាតិនាំសត្វឲ្យកើតទៀត ប្រកបដោយតម្រេករីករាយ ជាធម្មជាតិនាំសត្វឲ្យត្រេកត្រអាលនៅ ក្នុងភពនោះ ៗ ឬក្នុងអារម្មណ៍នោះ ៗ តណ្ហានោះ គឺអ្វីខ្លះ គឺ កាមតណ្ហា (សេចក្តីប្រាថ្នាក្នុងកាមគុណ)១ ភវតណ្ហា[១] (សេចក្តីប្រាថ្នាក្នុងរូបភពនិងអរូបភព)១ វិភវតណ្ហា (សេចក្តីប្រាថ្នាក្នុងកិលេសសូន្យ[២])១ ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានុ៎ះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា ។

---

១ អដ្ឋកថា ថា ភវតណ្ហានេះ ជាឈ្មោះនៃរាគក្នុងរូបភពនិងអរូបភព ដែលប្រកបដោយសស្សតទិដ្ឋិ គឺយល់ឃើញថាសត្វទៀងលោកទៀង កើតឡើងព្រោះសេចក្តីប្រាថ្នាចំពោះភព ។

២ ពាក្យនេះ អដ្ឋកថានិងដីកាថា តម្រេកប្រកបដោយឧច្ឆេទទិដ្ឋិ គឺយល់ថា សត្វស្លាប់ទៅសូន្យ ហៅថា វិភវតណ្ហា ។

យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ កិញ្ច លោកេ បិយរូបំ សាតរូបំ ។ ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ សោតំ លោកេ ។ ឃានំ លោកេ ។ ជិវ្ហា លោកេ ។ កាយោ លោកេ ។ មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបា លោកេ ។ សទ្ទា លោកេ ។ គន្ធា លោកេ ។ រសា លោកេ ។ ផោដ្ឋព្វា លោកេ ។ ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ចក្ខុវិញ្ញាណំ លោកេ ។ សោតវិញ្ញាណំ លោកេ ។ ឃានវិញ្ញាណំ លោកេ ។



អារម្មណ៍ណា ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងអារម្មណ៍នុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងអារម្មណ៍នុ៎ះ ។ អារម្មណ៍អ្វីមួយ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុនុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងចក្ខុនុ៎ះ ។ សោតៈ ក្នុងលោក ។ ឃានៈ ក្នុងលោក ។ ជិវ្ហា ក្នុងលោក ។ កាយ ក្នុងលោក ។ មនោ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោនុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងមនោនុ៎ះ ។ រូបារម្មណ៍ទាំងឡាយ ក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយ ក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយ ក្នុងលោក ។ រសារម្មណ៍ទាំងឡាយ ក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងធម្មារម្មណ៍នុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងធម្មារម្មណ៍នុ៎ះ ។ ចក្ខុវិញ្ញាណ ក្នុងលោក ។ សោតវិញ្ញាណ ក្នុងលោក ។ ឃានវិញ្ញាណ ក្នុងលោក ។

ជិវ្ហាវិញ្ញាណំ លោកេ ។ កាយវិញ្ញាណំ លោកេ ។ មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ចក្ខុសម្ផស្សោ លោកេ ។ សោតសម្ផស្សោ លោកេ ។ ឃានសម្ផស្សោ លោកេ ។ ជិវ្ហាសម្ផស្សោ លោកេ ។ កាយសម្ផស្សោ លោកេ ។ មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ចក្ខុសម្ផស្សជា វេទនា លោកេ ។ សោតសម្ផស្សជា វេទនា លោកេ ។ ឃានសម្ផស្សជា វេទនា លោកេ ។ ជិវ្ហាសម្ផស្សជា វេទនា លោកេ ។ កាយសម្ផស្សជា វេទនា លោកេ ។ មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបសញ្ញា លោកេ ។ សទ្ទសញ្ញា



ជិវ្ហាវិញ្ញាណ ក្នុងលោក ។ កាយវិញ្ញាណ ក្នុងលោក ។ មនោវិញ្ញាណ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោវិញ្ញាណនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុសម្ផស្ស ក្នុងលោក ។ សោតសម្ផស្ស ក្នុងលោក ។ ឃានសម្ផស្ស ក្នុងលោក ។ ជិវ្ហាសម្ផស្ស ក្នុងលោក ។ កាយសម្ផស្ស ក្នុងលោក ។ មនោសម្ផស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោសម្ផស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោសម្ផស្សនុ៎ះ ។ វេទនាកើតអំពីចក្ខុសម្ផស្ស ក្នុងលោក ។ វេទនាកើតអំពីសោតសម្ផស្ស ក្នុងលោក ។ វេទនាកើតអំពីឃានសម្ផស្ស ក្នុងលោក ។ វេទនាកើតអំពីជិវ្ហាសម្ផស្ស ក្នុងលោក ។ វេទនាកើតអំពីកាយសម្ផស្ស ក្នុងលោក ។ វេទនាកើតអំពីមនោសម្ផស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងវេទនា ដែលកើតអំពីមនោសម្ផស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនុ៎ះ ។ សេចក្តីសម្គាល់នូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍

លោកេ ។ គន្ធសញ្ញា លោកេ ។ រសសញ្ញា លោកេ ។ ផោដ្ឋព្វសញ្ញា លោកេ ។ ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបសញ្ចេតនា លោកេ ។ សទ្ទសញ្ចេតនា លោកេ ។ គន្ធសញ្ចេតនា លោកេ ។ រសសញ្ចេតនា លោកេ ។ ផោដ្ឋព្វសញ្ចេតនា លោកេ ។ ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបតណ្ហា លោកេ ។ សទ្ទតណ្ហា លោកេ ។ គន្ធតណ្ហា លោកេ ។ រសតណ្ហា លោកេ ។ ផោដ្ឋព្វតណ្ហា លោកេ ។ ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា



ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើង ក្នុងសេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍នុ៎ះ កាលដែលជាប់នៅក៏ជាប់នៅក្នុងសេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍នុ៎ះ ។ ការគិតសន្សំនូវរូបារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវគន្ធារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវរសារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងធម្មារម្មណ៍នុ៎ះ ។ សេចក្តីប្រាថ្នានូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែល

ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបវិតក្កោ លោកេ ។ សទ្ទវិតក្កោ លោកេ ។ គន្ធវិតក្កោ លោកេ ។ រសវិតក្កោ លោកេ ។ ផោដ្ឋព្វវិតក្កោ លោកេ ។ ធម្មវិតក្កោ លោកេ បិយរូបំ សាត-រូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ រូបវិចារោ លោកេ ។ សទ្ទវិចារោ លោកេ ។ គន្ធវិចារោ លោកេ ។ រសវិចារោ លោកេ ។ ផោដ្ឋព្វវិចារោ លោកេ ។ ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។





កើតឡើង ក៏កើតឡើងក្នុងសេចក្តីប្រាថ្នាក្នុងធម្មារម្មណ៍នុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងសេចក្តីប្រាថ្នាក្នុងធម្មារម្មណ៍នុ៎ះ ។ សេចក្តីត្រិះរិះក្នុងរូបារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះក្នុងសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះក្នុងគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះក្នុងរសារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះក្នុងផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះក្នុងធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីត្រិះរិះក្នុងធម្មារម្មណ៍នុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងសេចក្តីត្រិះរិះក្នុងធម្មារម្មណ៍នុ៎ះ ។ ការពិចារណាក្នុងរូបារម្មណ៍ ក្នុងលោក ។ ការពិចារណាក្នុងសទ្ទារម្មណ៍ ក្នុងលោក ។ ការពិចារណាក្នុងគន្ធារម្មណ៍ ក្នុងលោក ។ ការពិចារណាក្នុងរសារម្មណ៍ ក្នុងលោក ។ ការពិចារ-ណាក្នុងផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការពិចារណាក្នុងធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការពិចារណាក្នុងធម្មារម្មណ៍នុ៎ះ កាលដែលតាំងនៅ ក៏តាំងនៅក្នុងការពិចារណា ក្នុងធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ទុក្ខសមុទយអរិយសច្ច ។

(១៣៦) កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយ-សច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគ-និរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។ សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ បហីយមានា បហីយតិ កត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ កិញ្ច លោកេ បិយរូបំ សាតរូបំ ។ ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ សោតំ លោកេ ។ ឃានំ លោកេ ។ ជិវ្ហា លោកេ ។ កាយោ លោកេ ។ មនោ លោកេ បិយរូបំ



(១៣៦) ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា ទុក្ខនិរោធ-អរិយសច្ច ។ ការរលស់ទៅនិងការរលត់ទៅ ដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការផុតស្រឡះចោល ការមិនមានអាល័យ ចំពោះតណ្ហានោះឯង (ហៅថា ទុក្ខនិរោធអរិយសច្ច) ។ ម្នាលភិក្ខុទាំង-ឡាយ ចុះតណ្ហានោះឯង កាលដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ។ អារម្មណ៍ណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ តែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលដែលរលត់ទៅ តែងរលត់ទៅក្នុងអារម្មណ៍នុ៎ះ ។ ចុះអារម្មណ៍អ្វី ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុនុ៎ះ ។ សោតៈ ក្នុងលោក ។ ឃានៈ ក្នុងលោក ។ ជិវ្ហា ក្នុងលោក ។ កាយ ក្នុងលោក ។ មនោ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់

សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបា លោកេ ។ សទ្ទា លោកេ ។ គន្ធា លោកេ ។ រសា លោកេ ។ ផោដ្ឋព្វា លោកេ ។ ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ចក្ខុវិញ្ញាណំ លោកេ ។ សោតវិញ្ញាណំ លោកេ ។ ឃានវិញ្ញាណំ លោកេ ។ ជិវ្ហាវិញ្ញាណំ លោកេ ។ កាយវិញ្ញាណំ លោកេ ។ មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ចក្ខុសម្ផស្សោ លោកេ ។ សោតសម្ផស្សោ លោកេ ។ ឃានសម្ផស្សោ លោកេ ។ ជិវ្ហាសម្ផស្សោ លោកេ ។ កាយសម្ផស្សោ លោកេ ។ មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ



មានសភាវៈគួរត្រេកអរ តណ្ហានុះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោនោះ ។ រូបារម្មណ៍ទាំងឡាយ ក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយ ក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយ ក្នុងលោក ។ រសារម្មណ៍ទាំងឡាយ ក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងធម្មារម្មណ៍នុះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងធម្មារម្មណ៍នុះ ។ ចក្ខុវិញ្ញាណ ក្នុងលោក ។ សោតវិញ្ញាណ ក្នុងលោក ។ ឃានវិញ្ញាណ ក្នុងលោក ។ ជិវ្ហាវិញ្ញាណ ក្នុងលោក ។ កាយវិញ្ញាណ ក្នុងលោក ។ មនោវិញ្ញាណ ក្នុងលោក ដែលមានសភាពគួរ ស្រឡាញ់ មានសភាពគួរ ត្រេកអរ តណ្ហានុះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោវិញ្ញាណនុះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោវិញ្ញាណនុះ ។ ចក្ខុសម្ផ័ស្ស ក្នុងលោក ។ សោតសម្ផ័ស្ស ក្នុងលោក ។ ឃានសម្ផ័ស្ស ក្នុងលោក ។ ជិវ្ហាសម្ផ័ស្ស ក្នុងលោក ។ កាយសម្ផ័ស្ស ក្នុងលោក ។ មនោសម្ផ័ស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ

ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ចក្ខុសម្ផស្សជា វេទនា លោកេ ។ សោតសម្ផស្សជា វេទនា លោកេ ។ ឃាន-សម្ផស្សជា វេទនា លោកេ ។ ជិវ្ហាសម្ផស្សជា វេទនា លោកេ ។ កាយសម្ផស្សជា វេទនា លោកេ ។ មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបសញ្ញា លោកេ ។ សទ្ទសញ្ញា លោកេ ។ គន្ធសញ្ញា លោកេ ។ រសសញ្ញា លោកេ ។ ផោដ្ឋព្វសញ្ញា លោកេ ។ ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបសញ្ចេតនា លោកេ ។ សទ្ទសញ្ចេតនា លោកេ ។ គន្ធសញ្ចេតនា លោកេ ។



តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផស្សនុ៎ះ ។ វេទនាដែលកើតអំពីចក្ខុសម្ផស្ស ក្នុងលោក ។ វេទនាដែលកើតអំពីសោតសម្ផស្ស ក្នុងលោក ។ វេទនាដែលកើតអំពីឃានសម្ផស្ស ក្នុងលោក ។ វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ក្នុងលោក ។ វេទនាដែលកើតអំពីកាយសម្ផស្ស ក្នុងលោក ។ វេទនាដែលកើតអំពីមនោសម្ផស្ស ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផស្សនុ៎ះ ។ សេចក្តីសម្គាល់នូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធា-រម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មា-រម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេក-អរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។ ការគិតសន្សំនូវរូបារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវគន្ធារម្មណ៍ ក្នុងលោក ។

រសសញ្ចេតនា លោកេ ។ ផោដ្ឋព្វសញ្ចេតនា លោកេ ។ ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបតណ្ហា លោកេ ។ សទ្ទតណ្ហា លោកេ ។ គន្ធតណ្ហា លោកេ ។ រសតណ្ហា លោកេ ។ ផោដ្ឋព្វតណ្ហា លោកេ ។ ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបវិតក្កោ លោកេ ។ សទ្ទវិតក្កោ លោកេ ។ គន្ធវិតក្កោ លោកេ ។ រសវិតក្កោ លោកេ ។ ផោដ្ឋព្វវិតក្កោ លោកេ ។ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា



ការគិតសន្សំនូវរសារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ ។ សេចក្តីប្រាថ្នានូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ទៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ។ សេចក្តីត្រិះរិះនូវរូបារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវគន្ធារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវរសារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានភាពគួរត្រេកអរ តណ្ហានុ៎ះ

បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ រូបវិតក្កោ លោកេ ។ សទ្ទវិតក្កោ លោកេ ។ គន្ធវិតក្កោ លោកេ ។ រសវិតក្កោ លោកេ ។ ផោដ្ឋព្វវិតក្កោ លោកេ ។ ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។

[១៣៧] កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ



កាលដែលបុគ្គលលះបង់ ក៏លះបង់ ក្នុងសេចក្ដីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅ ក្នុងសេចក្ដីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ ។ ការពិចារណានូវរូបារម្មណ៍ ក្នុងលោក ។ ការពិចារណានូវសទ្ទារម្មណ៍ ក្នុងលោក ។ ការពិចារណានូវគន្ធារម្មណ៍ ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ ក្នុងលោក ។ ការពិចារណានូវផោដ្ឋព្វារម្មណ៍ ក្នុងលោក ។ ការពិចារណានូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ ក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅ ក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ទុក្ខនិរោធអរិយសច្ច ។

[១៣៧] ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការនេះឯង (ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច) អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការ តើដូចម្ដេច គឺ សម្មាទិដ្ឋិ (សេចក្ដីយល់ឃើញត្រូវ) ១ សម្មាសង្កប្បៈ (សេចក្ដីត្រិះរិះត្រូវ) ១ សម្មាវាចា (ការនិយាយពាក្យត្រូវ) ១ សម្មាកម្មន្តៈ (ការងារត្រូវ) ១ សម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ១ សម្មាវាយាមៈ (សេចក្ដីព្យាយាមត្រូវ) ១ សម្មាសតិ (សេចក្ដី

សម្មាសមាធិ ។ កតមា ច ភិក្ខវេ សម្មាទិដ្ឋិ ។
យំ ខោ ភិក្ខវេ ទុក្ខេ ញាណំ ទុក្ខសមុទយេ
ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា
បដិបទាយ ញាណំ អយំ វុច្ចតិ ភិក្ខវេ សម្មាទិដ្ឋិ ។
កតមោ ច ភិក្ខវេ សម្មាសង្កប្បោ ។ នេក្ខម្ម-
សង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ
វុច្ចតិ ភិក្ខវេ សម្មាសង្កប្បោ ។ កតមា ច ភិក្ខវេ
សម្មាវាចា ។ មុសាវាទា វេរមណី បិសុណាយ វាចាយ
វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា
វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា ។ កតមោ
ច ភិក្ខវេ សម្មាកម្មន្តោ ។ បាណាតិបាតា វេរមណី
អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី





ចំរលឹកត្រូវ) ១ សម្មាសមាធិ (ការតម្កល់ចិត្តឲ្យនឹងត្រូវ) ១ ។
ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុ
ទាំងឡាយ ប្រាជ្ញាដឹងច្បាស់ ក្នុងកងទុក្ខ ប្រាជ្ញាដឹងច្បាស់ ក្នុងធម៌ដែល
ជាទីប្រជុំឲ្យកើតទុក្ខ ប្រាជ្ញាដឹងច្បាស់ ក្នុងធម៌ដែលជាទីរលត់ទៅនៃទុក្ខ
ប្រាជ្ញាដឹងច្បាស់ ក្នុងបដិបទាទៅកាន់ធម៌ជាទីរលត់នៃទុក្ខ ណា ម្នាល
ភិក្ខុទាំងឡាយ នេះ តថាគតហៅថា សម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ
ចុះដូចម្ដេច ហៅថា សម្មាសង្កប្បៈ ។ សេចក្ដីត្រិះរិះ ដើម្បីចេញចាក
កាម សេចក្ដីត្រិះរិះ ដើម្បីការមិនព្យាបាទ សេចក្ដីត្រិះរិះ ដើម្បីការមិន
បៀតបៀន ម្នាលភិក្ខុទាំងឡាយ នេះ តថាគត ហៅថា សម្មាសង្កប្បៈ ។
ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា សម្មាវាចា ។ ចេតនា
វៀរចាកកិរិយានិយាយពាក្យមិនពិត ១ ចេតនាវៀរចាកសម្ដីញុះញង់ស៊ក
សៀត ១ ចេតនាវៀរចាកសម្ដីទ្រគោះបោះបោក ១ ចេតនាវៀរចាកការ
ពោលពាក្យរោយរាយឥតប្រយោជន៍ ១ ម្នាលភិក្ខុទាំងឡាយ នេះ តថា-
គត ហៅថា សម្មាវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅ
ថា សម្មាកម្មន្តៈ ។ ចេតនាវៀរចាកកិរិយាញ៉ាំងសត្វមានជីវិតឲ្យធ្លាក់ចុះ
កន្លង (សម្លាប់សត្វ) ១ ចេតនាវៀរចាកកិរិយាកាន់យករបស់ដែលគេមិន
បានឲ្យ ១ ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ម្នាល

អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ ។ កតមោ ច ភិក្ខវេ សម្មាអាជីវោ ។ ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ ភិក្ខវេ សម្មាអាជីវោ ។ កតមោ ច ភិក្ខវេ សម្មាវាយាមោ ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។



ភិក្ខុទាំងឡាយ នេះ តថាគតហៅថា សម្មាកម្មន្តៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា សម្មាអាជីវៈ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស ហើយរស់នៅដោយការចិញ្ចឹមជីវិតត្រូវ ម្នាលភិក្ខុទាំងឡាយ នេះ តថាគត ហៅថា សម្មាអាជីវៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ. ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសល ដែលមិនទាន់កើតឡើងហើយ ឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយ ជាកុសល ដែលកើតឡើងហើយ ឲ្យឋិតថេរ មិនឲ្យវិនាស ឲ្យចម្រើនទូលាយ ពេញបរិបូណ៌ ក្រៃលែងឡើង ។

អយំ វុច្ចតិ ភិក្ខវេ សម្មាវាយាមោ ។ កតមា ច ភិក្ខវេ សម្មាសតិ ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ ។ បេ ។ ចិត្តេ ។ បេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ ។ កតមោ ច ភិក្ខវេ សម្មាសមាធិ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា



ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា សម្មាវាយាមៈ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានការព្យាយាមដាក់គ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ពិចារណាឃើញនូវវេទនា ក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ បេ ។ ក្នុងចិត្ត ។ បេ ។ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានការព្យាយាមដាក់គ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា សម្មាសតិ ។ ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសល ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ព្រោះភិក្ខុចូលទៅជិតរម្ងាប់នូវវិតក្កៈនិងវិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈាន

អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ។ បេ[១] ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ

១ ម. ឧ. ឈានានិ វិត្ថារិតានិ ។



ដែលកើតមានក្នុងសន្តាន ជាទីផូរផង់ មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈគ្មានវិចារៈ មានតែបីតិនិងសុខៈ ដែលកើតអំពីសមាធិ ។ បេ ។ ចូលកាន់តតិយជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថ ៤ ចូលកាន់ចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ឥតទុក្ខ ឥតសុខ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរលត់ទៅនៃសោមនស្សនិងទោមនស្ស អំពីមុនផង ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះ តថាគតហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ភិក្ខុ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់

វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ ។ អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បដិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។

សច្ចបព្វំ និដ្ឋិតំ ។

ធម្មានុបស្សនា និដ្ឋិតា(១) ។

(១៣៨) យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ

១ ម. ឆ. សច្ចបព្វំ និដ្ឋិតំ ។ ធម្មានុបស្សនា និដ្ឋិតាតិ ន ទិស្សតិ ។



អរិយសច្ចទាំង ៤ ផង គឺពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើង និងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយជាប្រក្រតី ក្នុងអរិយសច្ចទាំង ៤ ផង ដោយប្រការដូច្នេះឯង ។ មួយទៀត ស្មារតីជាគ្រឿងកំណត់នូវសច្ចៈ ៤ របស់ភិក្ខុនោះ ក៏ចូលទៅតាំងឡើងចំពោះថា ធម៌ទាំងឡាយមានមែន ក៏ត្រឹមតែជាទីកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យនៅ (ដោយតណ្ហានិងទិដ្ឋិ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចទាំង ៤ ជាប្រក្រតី ក្នុងអរិយសច្ចទាំង ៤ យ៉ាងនេះឯង ។

ចប់ សច្ចបព្វៈ ។

ចប់ ធម្មានុបស្សនា ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ឆ្នាំ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលហើយ យ៉ាងនេះ បណ្ដាផលទាំងឡាយពីរ ផលណាមួយ គឺគង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត

ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ តិដ្ឋន្តុ ភិក្ខវេ សត្ត វស្សានិ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ ឆ វស្សានិ ។ បញ្ច វស្សានិ ។ ចត្តារិ វស្សានិ ។ តីណិ វស្សានិ ។ ទ្វេ វស្សានិ ។ ឯកំ វស្សំ ។ បេ ។ តិដ្ឋតុ ភិក្ខវេ ឯកំ វស្សំ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្ត មាសានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។



គឺជា នឹងបានសម្រេចខ្លួនទៅជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់នៃភព កុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចខ្លួនទៅជាអនាគាមិបុគ្គលពុំខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ កុំថាវល់ទៅអស់ ៧ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៦ ឆ្នាំ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ ។ អស់ ៥ ឆ្នាំ ។ អស់ ៤ ឆ្នាំ ។ អស់ ៣ ឆ្នាំ ។ អស់ ២ ឆ្នាំ ។ អស់ ១ ឆ្នាំ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កុំថាវល់ទៅ អស់ ១ ឆ្នាំឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់ ៧ ខែ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ បណ្ដាផលទាំងពីរ ផលណាមួយ ក៏គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមសេចក្ដីប្រាថ្នាដោយពិត គឺជា នឹងបានសម្រេចខ្លួនទៅជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់នៃភព កុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេច ខ្លួនទៅជាអនាគាមិបុគ្គលពុំខានឡើយ ។

តិដ្ឋន្តុ ភិក្ខវេ សត្ត មាសានិ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ ឆ មាសានិ ។ បញ្ច មាសានិ ។ ចត្តារិ មាសានិ ។ តីណិ មាសានិ ។ ទ្វេ មាសានិ ។ ឯកំ មាសំ ។ អឌ្ឍមាសំ ។ បេ ។ តិដ្ឋតុ ភិក្ខវេ អឌ្ឍមាសោ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិប្បដ្ឋានេ ឯវំ ភាវេយ្យ សត្តាហំ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។ ឯកាយនោ អយំ ភិក្ខវេ មគ្គោ



ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ ៧ ខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចម្រើននូវសតិប្បដ្ឋានទាំង ៤ នេះ អស់ ៦ ខែ តាមលំដាប់នៃវិធីចម្រើន ដែលតថាគត បានពោលមកហើយ យ៉ាងនេះ ។ អស់ ៥ ខែ ។ អស់ ៤ ខែ ។ អស់ ៣ ខែ ។ អស់ ២ ខែ ។ អស់ ១ ខែ ។ អស់កន្លះខែ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់កន្លះខែឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នេះ អស់៧ថ្ងៃ តាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលមកហើយយ៉ាងនេះ បណ្ដាផលទាំងឡាយពីរ ផលណាមួយ គប្បីនឹងបានសម្រេច ដល់បុគ្គលនោះ តាមប្រាថ្នាដោយពិត គឺថា នឹងបានសម្រេចនូវភាវៈជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គប្បីនឹងបានសម្រេចនូវភាវៈជាអនាគាមិបុគ្គល ពុំខានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ផ្លូវនៃសតិប្បដ្ឋានទាំងឡាយ ៤ នេះ ជាផ្លូវមូលតែមួយ

សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្ពានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិបដ្ឋានាតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាសតិបដ្ឋានសុត្តំ នវមំ និដ្ឋិតំ ។

---



ប្រព្រឹត្តទៅ ដើម្បីសេចក្តីបរិសុទ្ធរបស់ពួកសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្តីសោកនិងសេចក្តីខ្សឹកខ្សួលផ្តូលចិត្តទាំងឡាយ ដើម្បីការរលត់ទៅនៃទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយមគ្គជាធម៌សម្រាប់ស្រោចស្រង់ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ពាក្យណា ដែលតថាគតបានពោលហើយថា (សោតនារបស់តថាគត ជាគុណសម្រាប់ស្រោចស្រង់សត្វ) ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រសើរ គឺសតិប្បដ្ឋានទាំង ៤ នេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងសតិប្បដ្ឋានសូត្រនេះចប់ហើយ ។ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរ ត្រេកអរ ចំពោះភាសិតនៃព្រះមានព្រះភាគ ។

ចប់ មហាសតិប្បដ្ឋានសូត្រ ទី ៩ ។

## បាយាសិរាជញ្ញសុត្តំ ទសមំ

(១៣៩) ឯវម្មេ សុតំ ។ ឯកំ សមយំ អាយស្មា កុមារកស្សបោ កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ យេន សេតព្យា(១) នាម កោសលានំ នគរំ តទវសរិ ។ តត្រ សុទំ អាយស្មា កុមារកស្សបោ សេតព្យាយំ វិហរតិ ឧត្តរេន សេតព្យំ សីសបាវនេ(២) ។ តេន ខោ បន សមយេន បាយាសិ រាជញ្ញោ សេតព្យំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា បសេនទិនា កោសលេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ។ តេន ខោ បន សមយេន បាយាសិស្ស រាជញ្ញស្ស(៣) ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ(៤) កម្មានំ ផលំ វិបាកោតិ ។ អស្សោសុំ ខោ សេតព្យកា ព្រាហ្មណគហបតិកា

១ ម. សេតព្យា ។ ២ ម. ឱ. សីសបាវនេ ។ ៣ ម. បាយាសិរាជញ្ញស្ស ។ ៤ ម. សុក្កដ សុកតទុក្កដានំ វិបាកោ ។

## បាយាសិរាជញ្ញសូត្រ ទី ១០

(១៣៩) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះកុមារកស្សបមានអាយុ ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប បានទៅដល់សេតព្យនគរ របស់អ្នកកោសលទាំងឡាយ ។ បានឮថា ព្រះកុមារកស្សបមានអាយុ គង់នៅក្នុងព្រៃធ្នង់ ខាងជើងក្រុងសេតព្យៈ ជិតក្រុងសេតព្យៈនោះ ។ សម័យនោះឯង ព្រះបាទបាយាសិរាជញ្ញៈ(១) គ្រប់គ្រងសេតព្យនគរ ដែលជាទីកកុះករ ដោយសត្វនិងមនុស្ស បរិបូណ៌ដោយស្មៅ ឧស និងទឹក បរិបូណ៌ដោយស្រូវ អង្ករ ជាស្រុកព្រះរាជទ្រព្យ ដែលព្រះបាទបសេនទិកោសលទ្រង់ប្រទាន ជារាជទាន ជារង្វាន់ដ៏ប្រសើរ ។ សម័យនោះឯង ព្រះបាទបាយាសិរាជញ្ញៈ កើតមានទិដ្ឋិអាក្រក់យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អនិងធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ពួកព្រាហ្មណ៍និងគហបតីអ្នកក្រុងសេតព្យៈ បានឮដំណឹងហើយ (គឺនិយាយគ្នា) ថា ម្នាលគ្នាយើង

១ អដ្ឋកថា ថា ស្ដេចប្រទេសរាជ្យ មិនទាន់បានអភិសេកនៅឡើយ ។

សមណោ ខលុ ភោ កុមារកស្សបោ សមណស្ស គោតមស្ស សាវកោ កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សេតព្យំ អនុប្បត្តោ សេតព្យាយំ វិហរតិ ឧត្តរេន សេតព្យំ សីសបាវនេ ។ តំ ខោ បន ភវន្តំ កុមារកស្សបំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ បណ្ឌិតោ ព្យត្តោ មេធាវី ពហុស្សុតោ ចិត្តកថី កល្យាណប្បដិភាណោ(១) វុឌ្ឍោ ចេវ អរហា ច សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ សេតព្យកា ព្រាហ្មណគហបតិកា សេតព្យាយ និក្ខមិត្វា សង្ឃសង្ឃីគណីភូតា(២) ឧត្តរេនមុខា គច្ឆន្តិ យេន សីសបាវនំ(៣) ។

(១៦០) តេន ខោ បន សមយេន បាយាសិរាជញ្ញោ ឧបរិបាសាទេ ទិវាសេយ្យំ ឧបគតោ ហោតិ ។ អទ្ទសា ខោ បាយាសិរាជញ្ញោ

១ ឱ. ម. កល្យាណប្បដិភានោ ។ ២ ឱ. ម. សង្ឃសង្ឃីគណីភូតា ។ ៣ ឱ. សីសបាវនំ តេនុបសង្កមន្តិ ។



សមណៈឈ្មោះកុមារកស្សប ជាសាវ័ករបស់ព្រះសមណគោតម ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប មកដល់ក្រុងសេតព្យៈ ហើយគង់នៅក្នុងព្រៃធ្នង់ ដែលប៉ែក ខាងជើងក្រុងសេតព្យៈ ជិតក្រុងសេតព្យៈ ។ កិត្តិស័ព្ទសរសើរព្រះកុមារកស្សបដ៏ពីរោះនោះ ក៏ខ្ចរខ្ចាយទៅ យ៉ាងនេះថា លោក ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ជាពហុស្សូត មានសម្ដីវិចិត្រ មានបដិភាណដ៏ល្អ ជាអ្នកចាស់ទុំផង ជាព្រះអរហន្តផង ក៏ការដែលបានជួបនឹងព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃណាស់ ។ លំដាប់នោះ ពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈ ក៏ចេញពីក្រុងសេតព្យៈ ទៅជាពួកជាគណៈ មានមុខត្រង់ទៅកាន់ទិសខាងជើង ដើរទៅកាន់ព្រៃធ្នង់ ។

(១៦០) សម័យនោះឯង ព្រះបាទបាយាសិរាជញ្ញៈ ស្ដេចចូលទៅកាន់ក្រឡាបន្ទំក្នុងវេលាថ្ងៃ ខាងលើប្រាសាទ ។ ព្រះបាទបាយាសិរាជញ្ញៈ

សេតព្យកេ ព្រាហ្មណគហបតិកេ សេតព្យាយ និក្ខមិត្វា សង្ឃសង្ឃីគណីភូតេ ឧត្តរេនមុខេ គច្ឆន្តេ[១] ទិស្វា ខត្តំ អាមន្តេសិ កិំ នុ ខោ ភោ ខត្តេ សេតព្យកា ព្រាហ្មណគហបតិកា សេតព្យាយ និក្ខមិត្វា សង្ឃសង្ឃីគណីភូតា ឧត្តរេនមុខា គច្ឆន្តិ យេន សីសបាវនន្តិ ។ អត្ថិ ខោ ភោ សមណោ កុមារកស្សបោ សមណស្ស គោតមស្ស សាវ-កោ កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធិំ បញ្ចមត្តេហិ ភិក្ខុសតេហិ សេតព្យំ អនុប្បត្តោ សេតព្យាយំ វិហរតិ ឧត្ត-រេន សេតព្យំ សីសបាវនេ ។ តំ ខោ បន ភវន្តំ កុមារកស្សបំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គ-តោ បណ្ឌិតោ វិយត្តោ មេធាវី ពហុស្សុតោ ចិត្ត-កថី កល្យាណបដិភាណោ វុឌ្ឍោ ចេវ អរហា ច តមេនំ[២] ភវន្តំ កុមារកស្សបំ ទស្សនាយ ឧបសង្កមន្តីតិ ។ តេនហិ ភោ ខត្តេ យេន សេតព្យកា ព្រាហ្មណគហបតិកា តេនុបសង្កម-

១ ឱ. ម. សង្ឃេ សង្ឃីគណីភូតេ ឧត្តរេនមុខេ គច្ឆន្តេ យេន សីសបាវនំ តេនុបសង្កមន្តេ ។
២ ឱ. អរហា ចាតិ តមេនំ ។



បានទតឃើញពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈ កំពុងចេញពីក្រុងសេតព្យៈ ជាពួកជាគណៈ មានមុខឆ្ពោះទៅកាន់ទិសខាងជើង លុះទតឃើញហើយ ទ្រង់ត្រាស់សួរខត្តាមាត្យ[១]ថា ម្នាលខត្តៈដ៏ចម្រើន ពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈ ចេញទៅពីក្រុងសេតព្យៈ ជាពួកជាគណៈ មានមុខឆ្ពោះទៅទិសខាងជើង ដើរទៅកាន់ព្រៃធ្នង់ ធ្វើអ្វីហ្ន៎ ។ ខត្តាមាត្យក្រាបទូលថា សូមទ្រង់មេត្តាប្រោស ឥឡូវមានសមណៈឈ្មោះកុមារកស្សប ជាសាវ័កនៃព្រះសមណគោតម ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប មកដល់ក្រុងសេត-ព្យៈ ដោយលំដាប់ ហើយគង់នៅក្នុងព្រៃធ្នង់ ខាងជើងក្រុងសេតព្យៈ ជិតក្រុងសេតព្យៈ កិត្តិស័ព្ទសរសើរកុមារកស្សបដ៏ចម្រើននោះ ពីរោះឮខ្ចរខ្ចាយទៅយ៉ាងនេះថា លោក ជាបណ្ឌិត ឈ្លាសវៃ មានប្រាជ្ញា ជាពហុ-ស្សុត មានសម្តីវិចិត្រ មានបដិភាណដ៏ល្អ ជាអ្នកត្រាស់ដឹងផង ជាព្រះអរហន្តផង ឯព្រាហ្មណ៍និងគហបតីទាំងនុ៎ះ នឹងចូលទៅគាល់ព្រះកុមារ-កស្សបដ៏ចម្រើននោះ ។ ព្រះបាទបាយាសិរាជញ្ញៈមានព្រះបន្ទូលថា ម្នាលខត្តៈដ៏ចម្រើន បើដូច្នោះ ចូរអ្នកចូលទៅរកពួកព្រាហ្មណ៍និងគហបតី អ្នក

១ អមាត្យឈ្លាសអាចដោះស្រាយប្រស្នាដែលគេសួរបាន ។

ឧបសង្កមិត្វា សេតព្យកេ ព្រាហ្មណគហបតិកេ ឯវំ វទេហិ បាយាសិ ភោ រាជញ្ញោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ បាយាសិ រាជញ្ញោ សមណំ កុមារកស្សបំ ទស្សនាយ ឧបសង្កមិស្សតីតិ បុរា សមណោ កុមារកស្សបោ សេតព្យកេ ព្រាហ្មណគហបតិកេ ពាលេ អព្យត្តេ សញ្ញាបេតិ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ នត្ថិ ហិ ភោ ខត្តេ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ ឯវំ ភោតិ ខោ សោ ខត្តា បាយាសិស្ស រាជញ្ញស្ស បដិស្សុត្វា យេន សេតព្យកា ព្រាហ្មណគហបតិកា តេនុបសង្កមិ ឧបសង្កមិត្វា សេតព្យកេ ព្រាហ្មណគហបតិកេ ឯតទវោច បាយាសិ ភោ រាជញ្ញោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ បាយាសិ រាជញ្ញោ សមណំ កុមារកស្សបំ ទស្សនាយ ឧបសង្កមិស្សតីតិ ។



ក្រុងសេតព្យៈ លុះចូលទៅដល់ហើយ និយាយនឹងពួកព្រាហ្មណ៍គហបតី អ្នកក្រុងសេតព្យៈយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ព្រះបាទបាយាសិរាជញ្ញៈ បានត្រាស់យ៉ាងនេះថា អ្នកដ៏ចម្រើនទាំងឡាយ ចូររង់ចាំសិន ព្រះបាទបាយាសិរាជញ្ញៈ នឹងចូលទៅដើម្បីជួបសមណកុមារកស្សបដែរ ហើយត្រាស់ផ្ដាំថា ពីមុនមក សមណកុមារកស្សប តែងញុំាងពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈ ដែលល្ងង់ មិនឆ្លាស ឲ្យកាន់តែចូលចិត្តច្បាស់ថា លោកដទៃមាន សត្វជាឱបបាតិកៈមាន ផលនិងវិបាករបស់កម្មទាំងឡាយដែលពួកសត្វធ្វើល្អធ្វើអាក្រក់ មាន ព្រោះហេតុនោះ ម្នាលខត្តៈដ៏ចម្រើន តែបើតាមពិតនោះ លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលពួកសត្វធ្វើល្អធ្វើអាក្រក់ មិនមានទេ ។ ខត្តាមាត្យនោះ ទទួលព្រះឱង្ការព្រះបាទបាយាសិរាជញ្ញៈថា ករុណាវិសេស ហើយក៏ចូលទៅរកពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈ លុះចូលទៅដល់ហើយ បាននិយាយនឹងពួកព្រាហ្មណ៍គហបតី អ្នកក្រុងសេតព្យៈ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន ព្រះបាទបាយាសិរាជញ្ញៈត្រាស់យ៉ាងនេះថា ចូរអ្នកដ៏ចម្រើនទាំងឡាយរង់ចាំសិន ឮថា ព្រះបាទបាយាសិរាជញ្ញៈ នឹងចូលទៅជួបសមណកុមារកស្សបដែរ ។

អថខោ បាយាសិ រាជញ្ញោ សេតព្យកេហិ ព្រាហ្មណ-គហបតិកេហិ បរិវុតោ យេន សីសបាវនំ យេនា-យស្មា កុមារកស្សបោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា កុមារកស្សបេន សទ្ធឹ សម្មោទិ សម្មោ-ទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ សេតព្យកាបិ ខោ ព្រាហ្មណគហបតិកា អប្បេកច្ចេ អាយស្មន្តំ កុមារកស្សបំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ អាយស្មតា កុមា-រកស្សបេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេ-កច្ចេ យេនាយស្មា កុមារកស្សបោ តេនញ្ជលឹ បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ នាម-គោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ បាយាសិ រាជញ្ញោ អាយស្មន្តំ កុមារកស្សបំ ឯតទវោច អហញ្ហិ ភោ កស្សប ឯវំវាទី ឯវំទិដ្ឋី



លំដាប់នោះ ព្រះបាទបាយាសិរាជញ្ញៈ ដែលមានពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈចោមរោមអមអង្គ ក៏ចូលទៅរកព្រះកុមារកស្សបមានអាយុ ដែលគង់នៅក្នុងព្រៃក្ទម្ពី លុះចូលទៅដល់ហើយ ក៏មានបន្ទូលរាក់ទាក់សំ-ណេះសំណាល ជាមួយនឹងព្រះកុមារកស្សបមានអាយុ លុះបញ្ចប់ពាក្យសំ-ណេះសំណាលនិងពាក្យគួររលឹកហើយ ក៏គង់ក្នុងទីដ៏សមគួរ ។ ចំណែកពួកព្រាហ្មណ៍និងគហបតី អ្នកក្រុងសេតព្យៈ ពួកខ្លះ ថ្វាយបង្គំព្រះកុមារ-កស្សបមានអាយុ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ និយាយពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះកុមារកស្សបមានអាយុ លុះបញ្ចប់ពាក្យរាក់ទាក់សំណេះសំណាលនិងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ អង្គុយក្នុងទីសមគួរ ប្រណម្យអញ្ជលីចំពោះព្រះកុមារក-ស្សបមានអាយុ ពួកខ្លះ ប្រកាសនាមនិងគោត្រ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះ អង្គុយស្ងៀមក្នុងទីសមគួរ ។ ព្រះបាទបាយាសិរាជញ្ញៈ លុះគង់ក្នុងទីសមគួរហើយ ទើបមានព្រះឱង្ការនឹងព្រះកុមារកស្សបមានអាយុយ៉ាងនេះថា បពិត្រព្រះកស្សបដ៏ចំរើន ខ្ញុំតែងនិយាយយ៉ាងនេះ យល់ឃើញ

ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ នាហំ(១) រាជញ្ញ ឯវំវាទឹ ឯវំទិដ្ឋឹ អទ្ទសំ វា អស្សោសឹ វា កថញ្ហិ នាម ឯវំ វទេយ្យ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ តេនហិ រាជញ្ញ តញ្ញេវេត្ថ(២) បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ រាជញ្ញ ឥមេ ចន្ទិមសុរិយា ឥមស្មឹ វា(៣) លោកេ បរស្មឹ វា ទេវា វា(៤) មនុស្សា វាតិ ។ ឥមេ ភោ កស្សប ចន្ទិមសុរិយា បរស្មឹ លោកេ ន ឥមស្មឹ ទេវា តេ ន មនុស្សាតិ ។ ឥមិនាបិ(៥) ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

---

១ ឱ. ម. នាហំ ។ ២ ឱ. តំយេវេត្ថ ។ ៣ ឱ. ឥមស្មឹ លោកេ ។ ៤ ឱ. តេ ។ ម. ទេវា វា តេ ៖ ៥ ឱ. ឥមិនា ។



យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ ។ ព្រះកុមារកស្សប ថ្វាយព្រះពរថា បពិត្ររាជញ្ញៈ អាត្មាភាពបានឃើញបានឮបុគ្គលដែលប្រកាន់និយាយយ៉ាងនេះ យល់យ៉ាងនេះហើយ តែមិនសមបើបុគ្គលនោះ និយាយយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដូច្នេះសោះ បពិត្ររាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងទូលសួរបពិត្រ ក្នុងដំណើរនេះ ប្រស្នានេះ គាប់ព្រះហឫទ័យនៃបពិត្រ យ៉ាងណា សូមមហាបពិត្រ ព្យាករប្រស្នានោះ យ៉ាងនោះចុះ បពិត្ររាជញ្ញៈ ចុះទ្រង់សំគាល់ដំណើរនោះដូចម្ដេច ព្រះចន្ទនិងព្រះអាទិត្យនេះ នៅក្នុងលោកនេះ ឬនៅក្នុងលោកដទៃ ជាទេវតា ឬជាមនុស្ស ។ ព្រះបាទបាយាសិរាជញ្ញៈតបថា បពិត្រព្រះកស្សបដ៏ចម្រើន ព្រះចន្ទនិងព្រះអាទិត្យនេះ នៅក្នុងលោកដទៃ មិនមែននៅក្នុងលោកនេះទេ ជាទេវតា មិនមែនជាមនុស្សទេ ។ ព្រះកុមារកស្សប ថ្វាយព្រះពរថា ៗ រាជញ្ញៈ ដោយបរិយាយនេះ សូមមហាបពិត្រទ្រង់ព្រះយោបល់យល់យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ។

(១៤៧) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ ឯវំ មេ(១) ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយាយោ យេន តេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ មេ ភោ កស្សប មិត្តាមច្ចា ញាតិសាលោហិតា បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចា ផរុសាវាចា(២) សម្ផប្បលាបី អភិជ្ឈាលូ ព្យាបន្នចិត្តា មិច្ឆាទិដ្ឋី តេ អបរេន សមយេន

១ ឱ. ម. ឯវំ មេ ។ ២ ឱ. ផរុសា គិរា ។





[១៤៧] ព្រះបាទបាយាសិរាជញ្ញក្រាបទូលថា ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះ គឺត្រូវក្ដីមែនហើយ ប៉ុន្តែ ខ្ញុំនៅតែមានសេចក្ដីយល់ឃើញក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកដទៃ មិនមាន ពួកសត្វជាឧបបាតិកៈ មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមានទេ ដោយហេតុនេះ ។ ថ្វាយព្រះពររាជញ្ញៈ ចុះបរិយាយដែលនាំឲ្យមហាបពិត្រមានសេចក្ដីយល់ឃើញយ៉ាងនេះថា លោកដទៃ មិនមាន ពួកសត្វជាឧបបាតិកៈ មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដូច្នេះតើមានឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយដែលនាំឲ្យខ្ញុំមានសេចក្ដីយល់ឃើញយ៉ាងនេះថា លោកដទៃ មិនមាន ពួកសត្វជាឧបបាតិកៈ មិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ មានដែរ ។ ថ្វាយព្រះពររាជញ្ញៈ បរិយាយនោះ តើដូចម្ដេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួកមិត្រអាមាត្យនិងញាតិសាលោហិតរបស់ខ្ញុំ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគំនុំ មានសេចក្ដីយល់ខុស ពួកមិត្រអាមាត្យជាដើមនោះ លុះសម័យតទៅក្រោយមក

អាពាធិកា ហោន្តិ ទុក្ខិតា ពាឡ្ហគិលានា យទាហំ ជានាមិ ន ទានិមេ ឥមម្ហា អាពាធា វុដ្ឋហិស្សន្តីតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សន្តិ ខោ ភោ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យេ តេ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចា ផរុសវាចា(១) សម្ផប្បលាបី អភិជ្ឈាលូ ព្យាបន្នចិត្តា មិច្ឆាទិដ្ឋី តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តីតិ តុម្ហេ ខោ បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចា ផរុស-វាចា(២) សម្ផប្បលាបី អភិជ្ឈាលូ ព្យាបន្នចិត្តា មិច្ឆាទិដ្ឋី សចេ តេសំ ភវតំ(៣) សមណព្រាហ្មណានំ សច្ចំ វចនំ ភវន្តោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជិស្សន្តិ

១-២ ម. ផរុសាវាចា ។ ៣ ម. ភវន្តានំ ។ ឧ. តេសំ ភវតំ ។



ជាបុគ្គលមានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ កាលដែលខ្ញុំដឹងថា ពួកមិត្រអាមាត្យទាំងនេះ មុខជានឹងមិនរស់ឡើយ ចាកអាពាធនេះ គង់កាលស្លាប់នេះ ខ្ញុំក៏បានចូលទៅរកពួកមិត្រអាមាត្យទាំងនោះ ហើយនិយាយយ៉ាងនេះថា នែអ្នកដ៏ចម្រើន មានសមណព្រាហ្មណ៍ ពួកមួយ និយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះ ថា ពួកជនណា ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគំនុំ មានសេចក្តីយល់ខុស ពួកជនទាំងនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងទៅកើត ក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ម្នាល អ្នកដ៏ចម្រើនទាំង-ឡាយ សុទ្ធតែជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម និយាយកុហក និយាយញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តគំនុំ មានសេចក្តីយល់ខុស ហើយ បើពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះជាពាក្យពិតមែន អ្នកដ៏ចម្រើនទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ មុខជានឹងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ពុំខាន

សចេ ភោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យាថ យេន មេ អាគន្ត្វា អារោចេយ្យាថ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ភវន្តោ ខោ បន មេ សទ្ធាយិកា បច្ចយិកា យំ ភវន្តេហិ[1] ទិដ្ឋំ យថា សាមំ ទិដ្ឋំ ឯវមេតំ ភវិស្សតីតិ តេ មេ សាធូតិ បដិស្សុត្វា នេវ អាគន្ត្វា អារោចេន្តិ ន បន ទូតំ បហិណន្តិ អយម្បិ[2] ខោ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

(១៤៦) តេនហិ រាជញ្ញ តញ្ញេវេត្ថ[3] បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ

១ ម. ភវន្តេហិ ។ ២ ម. អយម្បិ ។ ៣ ម. តំយេវេត្ថ ។



នែអ្នកដ៏ចម្រើនទាំងឡាយ បើអ្នកទាំងឡាយបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក មែន អ្នកទាំងឡាយត្រូវមកប្រាប់យើងផងថា លោកខាងមុខមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ព្រោះថា អ្នកទាំងឡាយដ៏ចម្រើន ជាបុគ្គលដែលខ្ញុំគួរជឿ ខ្ញុំគួរទុកចិត្តស្ដាប់ពាក្យបាន ហេតុណា ដែលអ្នកដ៏ចម្រើនទាំងឡាយបានឃើញហើយ ហេតុនុ៎ះ នឹងទុកដូចជាខ្ញុំបានឃើញចំពោះខ្លួនឯងដែរ ពួកមិត្រអាមាត្យទាំងនោះ ទទួលតបពាក្យរបស់ខ្ញុំថា ព្រះករុណាវិសេស ដូច្នេះហើយ (ស្លាប់ទៅ) តែមិនឃើញមកប្រាប់ ទាំងមិនបញ្ជូនបម្រើការឡើយ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយល់យ៉ាងនេះថា លោកខាងមុខមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ ។

(១៤៦) ម្នាលព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងត្រឡប់សួរមហាបពិត្រ ក្នុងបរិយាយនុ៎ះវិញ ប្រស្នានេះ គាប់ព្រះហឫទ័យមហាបពិត្រយ៉ាងណា សូមមហាបពិត្រ ព្យាករប្រស្នានោះយ៉ាងនោះចុះ

តំ កឹ មញ្ញសិ រាជញ្ញ ឥធ តេ បុរិសា ចោរំ អាគុចារឹ គហេត្វា ទស្សេយ្យុំ អយន្តេ ភន្តេ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ(១) តេ ត្វំ ឯវំ វទេយ្យាសិ តេនហិ ភោ ឥមំ បុរិសំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា(២) ខរស្សរេន បណវេន រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស អាឃាតនេ សីសំ ឆិន្ទថាតិ តេ តេ(៣) សាធូតិ បដិស្សុត្វា តំ បុរិសំ ទឡ្ហាយ រជ្ជុយា បច្ឆាពាហំ គាឡ្ហពន្ធនំ ពន្ធិត្វា ខុរមុណ្ឌំ ករិត្វា ខរស្សរេន បណវេន រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ បរិនេត្វា

១ ឱ. ម. បណេហីតិ ។ ២ ឱ. ករិត្វា ។ ៣ ឱ. ម. តេ ។



បពិត្ររាជញ្ញៈ មហាបពិត្រសម្គាល់នូវហេតុនោះដូចម្ដេច ពួកបុរសរបស់មហាបពិត្រក្នុងដែននេះ ចាប់បាននូវចោរដែលប្រព្រឹត្តអាក្រក់មកថ្វាយមហាបពិត្រ រួចក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព អ្នកនេះ ជាចោរប្រព្រឹត្តអាក្រក់នឹងព្រះអង្គ ទ្រង់សព្វព្រះហឫទ័យនឹង (ដាក់) អាជ្ញាណាដល់ចោរនេះ សូមទ្រង់ដាក់អាជ្ញានោះមក ទើបមហាបពិត្រមានបន្ទូលនឹងពួកបុរសទាំងនោះយ៉ាងនេះថា នែអ្នកដ៏ចម្រើនទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរនាំគ្នាចងបុរសនេះឲ្យមានដើមដៃទៅខាងក្រោយ (ចងស្លាបសេក) ឲ្យខ្ជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីងចេញ រួច (ក្រហូង) ស្គរដែលមានសំឡេងគ្រាំគ្រឹង នាំបណ្ដើរជុំវិញសព្វច្រកសព្វផ្លូវបែក រួចនាំចេញតាមទ្វារខាងត្បូង កាត់ក្បាលត្រង់កន្លែងសម្រាប់ពិឃាតជាខាងត្បូងនគរចុះ ពួកបុរសទាំងនោះ ទទួលព្រះឱង្ការរបស់មហាបពិត្រថា ព្រះករុណាវិសេស ហើយក៏នាំគ្នាចងបុរសនោះឲ្យមានដើមដៃទៅខាងក្រោយ ឲ្យខ្ជាប់ដោយខ្សែដ៏មាំ កោរក្បាលឲ្យរលីងចេញ (រួច) ស្គរដែលមានសំឡេងគ្រាំគ្រឹង នាំបណ្ដើរជុំវិញសព្វច្រកសព្វផ្លូវបែក

## បាយាសិរាជញ្ញសុត្តំ ចោរូបមាកថា

ទក្ខិណេន ទ្វារេន និក្ខាមេត្វា ទក្ខិណតោ នគរស្ស អាឃាតនេ និសីទាបេយ្យុំ លភេយ្យ នុ ខោ សោ ចោរោ ចោរឃាតេសុ អាគមេន្តុ តាវ ភវន្តោ ចោរឃាតកា អមុកស្មឹ គាមេ វា[១] និគមេ វា មិត្តាមច្ចា ញាតិសាលោហិតា យាវាហំ តេសុ ឧទ្ទិសិត្វា[២] អាគច្ឆាមីតិ ឧទាហុ វិប្បលបន្តស្សេវ ចោរឃាតកា សីសំ ឆិន្ទេយ្យុន្តិ ។ ន ហិ សោ ភោ កស្សប ចោរោ លភេយ្យ ចោរឃាតេសុ អាគមេន្តុ តាវ ភវន្តោ ចោរឃាតកា អមុកស្មឹ គាមេ វា និគមេ វា មិត្តាមច្ចា ញាតិសាលោហិតា យាវាហំ តេសុ ឧទ្ទិសិត្វា អាគច្ឆាមីតិ អថ ខោ នំ វិប្បលបន្តស្សេវ ចោរឃាតកា សីសំ ឆិន្ទេយ្យុន្តិ ។ សោ ហិ នាម រាជញ្ញ ចោរោ មនុស្សោ មនុស្សភូតេសុ ចោរឃាតេសុ ន លភិស្សតិ អាគមេន្តុ តាវ ភវន្តោ ចោរឃាតកា អមុកស្មឹ គាមេ វា និគមេ វា មិត្តាមច្ចា ញាតិសាលោហិតា យាវាហំ តេសុ ឧទ្ទិសិត្វា អាគច្ឆាមីតិ កឹ បន

១ ឱ. ម. អមុកស្មឹ មេ គាមេ វា ។ ២ ឱ. វចនីយំ ។



## បាយាសិរាជញ្ញសូត្រ ការឧបមាដោយចោរ

រួចនាំចេញទៅតាមទ្វារខាងទិសត្បូង ហើយឲ្យចោរនោះអង្គុយ ត្រង់កន្លែងសម្រាប់សំលាប់ជាខាងទិសត្បូងនៃនគរ ចុះចោរនោះ (នឹងអង្វរ) ពួកពេជ្ឈឃាតថា សូមពួកពេជ្ឈឃាតដ៏ចំរើនបង្អង់សិន (ព្រោះ) ពួកមិត្រអាមាត្យនិងញាតិសាលោហិត (របស់ខ្ញុំមាន) ក្នុងស្រុកឬនិគមឯណោះ ចាំខ្ញុំផ្ដែផ្ដាំដល់ពួកមិត្រអាមាត្យទាំងនោះ ហើយសឹមមកវិញ ដូច្នេះតើបានឬទេ ឬក៏ពួកនាយពេជ្ឈឃាត (ទាំងនោះ) នឹងនាំគ្នាកាត់ក្បាលចោរ ដែលកំពុងទួញយំ ដោយឥតយោគយល់ ។ បពិត្រព្រះកស្សបដ៏ចំរើន ចោរនោះ (មិនអង្វរ) ពួកពេជ្ឈឃាតថា សូមពួកពេជ្ឈឃាតដ៏ចំរើនបង្អង់ឲ្យសិន (ព្រោះ) ពួកមិត្រអាមាត្យនិងញាតិសាលោហិត (របស់ខ្ញុំមាន) ក្នុងស្រុកឬនិគមឯណោះ ចាំខ្ញុំផ្ដែផ្ដាំដល់ពួកមិត្រអាមាត្យនោះរួចសឹមមកវិញ ដូច្នេះ មិនបានឡើយ តាមដែលពិតនោះ ពួកពេជ្ឈឃាតនឹងចេះតែកាត់ក្បាលចោរ ដែលកំពុងទួញយំនោះឲ្យដាច់តែបាន ។ ម្នាលព្រះរាជញ្ញៈ ឥឡូវយ៉ាងនេះ ចោរនោះជាមនុស្សជាតិដូចគ្នាក្រឡាក៏ ម្ដេចក៏ (អង្វរ) ពួកពេជ្ឈឃាតជាមនុស្សជាតិដូចគ្នាថា សូមពួកនាយពេជ្ឈឃាតដ៏ចំរើន បង្អង់ឲ្យសិន (ព្រោះ) ពួកមិត្រអាមាត្យនិងញាតិសាលោហិត (របស់ខ្ញុំមាន) ក្នុងស្រុក ឬនិគមឯណោះ ចាំខ្ញុំទៅផ្ដែផ្ដាំដល់ពួកមិត្រអាមាត្យទាំងនោះសិន រួចសឹមមកវិញ ដូច្នេះមិនបានទៅហើយ ចំណង់បើ

តេ មិត្តាមច្ចា ញាតិសាលោហិតា បាណាតិបាតី អទិន្នាទាយី កាមេសុ មិច្ឆាចារី មុសាវាទី បិសុណាវាចា ផរុសវាចា សម្ផប្បលាបី អភិជ្ឈាលូ ព្យាបន្នចិត្តា មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា លភិស្សន្តិ និរយបាលេសុ អាគមេន្តុ តាវ ភវន្តោ និរយបាលា យាវ មយំ បាយាសិស្ស រាជញ្ញស្ស គន្ត្វា អារោចេម ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ(១) ឥមិនាបិ ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

(១៤៣) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ ឯវំមេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ

១ ម. ឧ. វិបាកោតិ ។



ពួកមិត្រអាមាត្យញាតិសាលោហិត របស់មហាបពិត្រ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ចង់បានទ្រព្យគេ មានចិត្តព្យាបាទ មានសេចក្តីយល់ខុស លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ដែលទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរកហើយ ធ្វើម្តេចឡើយ នឹងគប្បីពួកនាយនិរយបាលថា សូមពួកនាយនិរយបាលដ៏ចម្រើន បន្ធូរឲ្យសិន ចាំយើងទាំងឡាយទៅក្រាបទូលដល់ព្រះបាយាសិរាជញ្ញៈថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាក របស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មានពិតដោយហេតុនេះ ម្នាលរាជញ្ញៈ បើតាមបរិយាយនេះឯង សូមមហាបពិត្រ ចូរព្រះអង្គយល់យល់មកយ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ។

(១៤៣) ព្រះកស្សបដ៏ចម្រើនពោលយ៉ាងនេះ ក៏ពិតមែនហើយ ប៉ុន្តែ ខ្ញុំនៅតែមានសេចក្តីយល់ឃើញក្នុងហេតុនុះយ៉ាងនេះថា លោកដទៃមិនមាន

នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយាយោ យេន តេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ មេ ភោ កស្សប មិត្តាមច្ចា ញាតិសាលោហិតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុមិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា បិសុណាវាចា បដិវិរតា ផរុសវាចា បដិវិរតា សម្ផប្បលាបា បដិវិរតា អនភិជ្ឈាលូ អព្យាបន្នចិត្តា សម្មាទិដ្ឋី តេ អបរេន សមយេន អាពាធិកា ហោន្តិ ទុក្ខិតា ពាឡ្ហគិលានា យទាហំ ជានាមិ ន ទានិមេ ឥមម្ហា អាពាធា វុដ្ឋហិស្សន្តីតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ





ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់មិនមាន ដោយហេតុនេះ ៗ ម្នាលព្រះរាជញ្ញៈ ចុះបរិយាយដែលនាំឲ្យមហាបពិត្រមានសេចក្តីយល់ឃើញ យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាក របស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ ដូចម្តេចនៅមានឬទេ ៗ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយដែលនាំឲ្យខ្ញុំមានសេចក្តីយល់ឃើញយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ នៅមាន ៗ ម្នាលព្រះរាជញ្ញៈ បរិយាយនោះដូចម្តេច ៗ បពិត្រព្រះកស្សបដ៏ចម្រើន ពួកមិត្រអាមាត្យនិងញាតិសាលោហិតរបស់ខ្ញុំក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ គ្មានអភិជ្ឈា គ្មានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ លុះសម័យតទៅខាងក្រោយមក ពួកមិត្រអាមាត្យទាំងនោះ មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ជាទម្ងន់ កាលដែលខ្ញុំដឹងថា ពួកមិត្រអាមាត្យទាំងនេះ មុខជានឹងមិនស្បើយ ចាកអាពាធនេះទេ ខ្ញុំ

សន្តិ ខោ ភោ ឯកេ សមណព្រាហ្មណា ឯវំ-វាទិនោ ឯវំទិដ្ឋិនោ យេ តេ បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា បិសុណាវាចា បដិវិរតា ផរុសវាចា បដិវិរតា សម្ផប្បលាបា បដិវិរតា អនភិជ្ឈាលូ អព្យាបន្នចិត្តា សម្មាទិដ្ឋី តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តីតិ ភវន្តោ ខោ បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា បិសុណាវាចា បដិវិរតា ផរុសវាចា បដិវិរតា សម្ផប្បលាបា បដិវិរតា អនភិជ្ឈាលូ អព្យាបន្នចិត្តា សម្មាទិដ្ឋី សចេ តេសំ ភវតំ(១) សមណព្រាហ្មណានំ សច្ចំ វចនំ ភវន្តោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សន្តិ សចេ ភោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោ-កំ ឧបបជ្ជេយ្យាថ យេន មេ អាគន្ត្វា អាចិក្ខេយ្យាថ

១ ម. តេសន្តំ ។ ឧ. តេសំ ភវតំ ។



ចូលទៅគេហ៍អ្នកមិត្រអាមាត្យទាំងនោះ ហើយនិយាយយ៉ាងនេះថា នែអ្នកដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ និយាយយ៉ាងនេះ យល់យ៉ាងនេះថា ពួកជនណា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុស-វាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មា-ទិដ្ឋិ ពួកជននោះ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ តែងទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក (ឥឡូវនេះ) អ្នកដ៏ចម្រើនទាំងឡាយសុទ្ធតែជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេ-សុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិហើយ បើពាក្យសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះពិតមែន អ្នកដ៏ចម្រើនទាំងឡាយ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ មុខជានឹងទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ពុំខាន ម្នាលអ្នកដ៏ចម្រើនទាំងឡាយបើអ្នកទាំងឡាយ បែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ ទៅកើតក្នុងឋានសុគតិសួគ៌ទេវលោកមែន អ្នកទាំងឡាយគប្បីមកប្រាប់យើងផងថា

ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបា-
តិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ
វិបាកោតិ ករេយ្យាថ ខោ បន មេ សទ្ធាយិកា បច្ច-
យិកា យំ ករេយ្យាថ(១) ទិដ្ឋំ យថា សាមំ ទិដ្ឋំ
ឯវមេតំ ភវិស្សតីតិ តេ មេ សាធូតិ បដិស្សុត្វា នេវ
អាគន្ត្វា អារោចេន្តិ ន បន ទូតំ បហិណន្តិ អ-
យម្បិ ខោ ភោ កស្សប បរិយាយោ យេន មេ
បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ
នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ
កម្មានំ ផលំ វិបាកោតិ ។

[២៥៦] តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ
ឧបមាយបិធេកច្ចេ(២) វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ
អាជានន្តិ សេយ្យថាបិ រាជញ្ញ បុរិសោ គូថកូបេ
សសីសកោ(៣) និមុគ្គោ អស្ស អថ ត្វំ បុរិសេ
អាណាបេយ្យាសិ តេនហិ ភោ តំ បុរិសំ តម្ហា គូថ-
កូបា ឧទ្ធរថាតិ តេ តេ(៤) សាធូតិ បដិស្សុត្វា

១ ម. ឱ. ករេយ្យាថ ។ ២ ឱ. ឧបមាយបិ ធេកច្ចេ ។ ម. ឧបមាយមិធេកច្ចេ ។
៣ ម. សសីសកំ ។ ៤ ឱ. ម. តេ ។



លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាក របស់កម្មទាំង-
ឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ព្រោះថា អ្នក
ទាំងឡាយដ៏ចម្រើន ជាបុគ្គលគឺយើងគួរជឿ គួរទទួលស្តាប់ពាក្យបាន
ហេតុណា ដែលអ្នកដ៏ចម្រើនទាំងឡាយបានឃើញហើយ ហេតុនុ៎ះ នឹង
ទុកដូចជាយើងបានឃើញដោយខ្លួនឯងដែរ ពួកមិត្រអាមាត្យទាំងនោះ
ទទួលតបពាក្យខ្ញុំថា ករុណាវិសេស ហើយមិនឃើញត្រឡប់មកប្រាប់
ទាំងមិនបញ្ជូនបម្រើមកឡើយ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះ
ឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជា
ឧបបាតិកៈមិនមាន ផលវិបាក របស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើ
អាក្រក់មិនមាន ដោយហេតុនេះ ។

(២៥៦) ថ្វាយព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តី
ឧបមាថ្វាយមហាបពិត្រ (ដ្បិត) ពួកបុរសខ្លះជាអ្នកចេះដឹង ក្នុងលោក
នេះ គង់យល់សេចក្តីនៃភាសិត ដោយពាក្យឧបមាបាន បពិត្រព្រះរាជញ្ញៈ
ប្រៀបដូចបុរស លិចចុះព្រមទាំងក្បាលទៅក្នុងរណ្តៅលាមក គ្រានោះ
មហាបពិត្រ បានត្រាស់បង្គាប់ពួកបុរសទាំងឡាយថា ម្នាលអ្នកដ៏ចម្រើន
បើដូច្នោះ អ្នកទាំងឡាយ ចូរស្រង់បុរសនោះអំពីរណ្តៅលាមកនោះឡើង
ពួកបុរសទាំងនោះ ទទួលព្រះឧង្ការរបស់មហាបពិត្រថា ករុណាវិសេស

តំ បុរិសំ តម្ហា គូថកូបា ឧទ្ធរេយ្យុំ ។ តេ ត្វំ ឯវំ វទេយ្យាសិ តេនហិ ភោ តស្ស បុរិសស្ស កាយា វេឡុបេសិកាហិ គូថំ សុនិម្មជ្ជិតំ និម្មជ្ជថាតិ ។ តេ តេ[១] សាធូតិ បដិស្សុត្វា តស្ស បុរិសស្ស កាយា វេឡុបេសិកាហិ គូថំ សុនិម្មជ្ជិតំ និម្មជ្ជេយ្យុំ ។ តេ ត្វំ ឯវំ វទេយ្យាសិ តេនហិ ភោ តស្ស បុរិសស្ស កាយំ បណ្ឌុមត្តិកាយ តិក្ខត្តុំ ឧព្វដិតំ ឧព្វដេថាតិ[២] ។ តេ តេ សាធូតិ បដិស្សុត្វា តស្ស បុរិសស្ស[៣] កាយំ បណ្ឌុមត្តិកាយ តិក្ខត្តុំ ឧព្វដិតំ ឧព្វដេយ្យុំ ។ តេ ត្វំ ឯវំ វទេយ្យាសិ តេនហិ ភោ តំ បុរិសំ តេលេន អព្ភញ្ជិត្វា សុខុមេន ចុណ្ណេន តិក្ខត្តុំ សុប្បធោតំ ករោថាតិ ។ តេ តំ បុរិសំ តេលេន អព្ភញ្ជិត្វា សុខុមេន ចុណ្ណេន តិក្ខត្តុំ សុប្បធោតំ ករេយ្យុំ ។ តេ ត្វំ ឯវំ វទេយ្យាសិ

១ ម. ឱ. តេ ។ ២ ម. ម. សុព្វដ្ដិតំ ឧព្វដ្ដេថាតិ ។ ៣ ម. ម. តេ តស្ស បុរិសស្ស ។



ហើយពួកគេស្រង់បុរសនោះពីរណ្ដៅលាមកនោះមក ។ មហាបពិត្រគឺមានព្រះតម្រាស់នឹងពួកបុរសទាំងនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ យកចម្រៀកឫស្សី មកកោសកៀរលាមកអំពីកាយបុរសនោះឲ្យស្អាតចេញ ពួកបុរសទាំងនោះទទួលព្រះតម្រាស់នៃមហាបពិត្រថា ករុណាវិសេស ហើយក៏យកចម្រៀកឫស្សីមកកោសកៀរលាមកអំពីកាយបុរសនោះឲ្យស្អាត ទើបមហាបពិត្រមានព្រះបន្ទូល នឹងពួកបុរសទាំងនោះយ៉ាងនេះទៀតថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយយកដីស្អិតពណ៌លឿង មកដុះលាងកាយបុរសនោះអស់បីដង ពួកបុរសទាំងនោះទទួលព្រះតម្រាស់របស់មហាបពិត្រថា ករុណាវិសេស ហើយក៏យកដីស្អិតពណ៌លឿង មកដុះលាងកាយបុរសនោះ អស់បីដង មហាបពិត្រមានព្រះបន្ទូលនឹងពួកបុរសទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ អ្នកទាំងឡាយ ចូរយកប្រេងលាបបុរសនោះហើយយកគ្រឿងលម្អិតដ៏ម៉ដ្ឋទៅខាត់ឲ្យស្អាតល្អអស់បីដង ពួកបុរសទាំងនោះក៏បានយកប្រេងមកលាបបុរសនោះ ហើយយកគ្រឿងលម្អិតដ៏ម៉ដ្ឋទៅខាត់ឲ្យស្អាតល្អអស់បីដង មហាបពិត្រត្រាស់ទៅនឹងពួកបុរសទាំងនោះយ៉ាងនេះ

តេនហិ ភោ តស្ស បុរិសស្ស កេសមស្សុំ កប្បេថាតិ តេ តស្ស បុរិសស្ស កេសមស្សុំ កប្បេយ្យុំ ត្វំ(១) ឯវំ វទេយ្យាសិ តេនហិ(២) តស្ស បុរិសស្ស មហគ្ឃញ្ច មាលំ មហគ្ឃញ្ច វិលេបនំ មហគ្ឃានិ ច វត្ថានិ ឧបហរថាតិ តេ តស្ស បុរិសស្ស មហគ្ឃញ្ច មាលំ មហគ្ឃញ្ច វិលេបនំ មហគ្ឃានិ ច វត្ថានិ ឧបហរេយ្យុំ តេ ត្វំ ឯវំ វទេយ្យាសិ តេនហិ ភោ តំ បុរិសំ បាសាទំ អារោបេត្វា បញ្ច កាមគុណានិ ឧបដ្ឋាបេថាតិ តេ តំ បុរិសំ បាសាទំ អារោបេត្វា បញ្ច កាមគុណានិ ឧបដ្ឋាបេយ្យុំ តំ កឹ មញ្ញសិ រាជញ្ញ អបិ នុ តស្ស បុរិសស្ស សុន្ហាតស្ស(៣) សុវិលិត្តស្ស កប្បិតកេសមស្សុស្ស អាមុក្កមណិកុណ្ឌលស្ស(៤) ឱទាតវត្ថវសនស្ស ឧបរិបាសាទវរគតស្ស បញ្ចហិ កាមគុណេហិ សមប្បិតស្ស សមង្គីភូតស្ស បរិចារយមានស្ស បុនទេវ តស្មឹ គូថកូបេ និមុជ្ជិតុកាមតា

១ ម. ឆ. តេ ត្វំ ។ ២ ម. ឆ. តេនហិ ភោ ។ ៣ សុខនហាតស្សាតិបិ បាឋោ ។
៤ ម. ឆ. អាមុក្កមណិកុណ្ឌលស្ស ។



ថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ កាត់សក់និងពុកមាត់របស់បុរសនោះចេញ ពួកបុរសទាំងនោះ ក៏បានកាត់សក់និងពុកមាត់របស់បុរសនោះ មហាបពិត្រត្រាស់យ៉ាងនេះថា បើដូច្នោះ ចូរអ្នកទាំងឡាយ យកផ្កាកម្រងមានថ្លៃច្រើន គ្រឿងលាបមានថ្លៃច្រើន និងសំពត់ទាំងឡាយមានថ្លៃច្រើន ទៅប្រគល់ឲ្យបុរសនោះចុះ ពួកបុរសទាំងនោះ បាននាំយកផ្កាកម្រងមានថ្លៃច្រើន គ្រឿងលាបមានថ្លៃច្រើន និងសំពត់ទាំងឡាយមានថ្លៃច្រើន ទៅប្រគល់ឲ្យបុរសនោះ មហាបពិត្រត្រាស់ទៅនឹងពួកបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ឲ្យបុរសនោះឡើងទៅលើប្រាសាទ ហើយតាក់តែងនូវកាមគុណទាំង ៥ ចុះ ឯពួកបុរសទាំងនោះ ក៏ឲ្យបុរសនោះឡើងទៅលើប្រាសាទ ហើយតាក់តែងនូវកាមគុណទាំង ៥ បពិត្ររាជញ្ញៈ ចុះមហាបពិត្រ សម្គាល់ហេតុនោះដូចម្ដេច ការដែលបុរសនោះ បានងូតទឹកស្អាត ហើយលាបកាយស្រស់ល្អ កាត់សក់ កោរពុកមាត់ ស្រេចហើយ ពាក់គ្រឿងប្រដាប់កែវមណី ស្លៀកសំពត់ពណ៌ស ស្រេចហើយ ឡើងទៅលើប្រាសាទដ៏ប្រសើរ ឲ្យគេបម្រើឲ្យឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ ហើយ តើគេនៅតែមានសេចក្ដីប្រាថ្នានឹងមុជចុះទៅក្នុងរណ្ដៅ

អស្សាតិ ។ នោ ហិទំ ភោ កស្សប ។ តំ កិស្ស ហេតុ ។ អសុចិ ភោ កស្សប គូថកូបោ អសុចិ ចេវ អសុចិសង្ខាតោ ច ទុគ្គន្ធោ ច ទុគ្គន្ធសង្ខាតោ ច ជេគុច្ឆោ ច ជេគុច្ឆសង្ខាតោ ច បដិក្កូលោ ច បដិក្កូលសង្ខាតោ ចាតិ ។ ឯវមេវ ខោ រាជញ្ញ មនុស្សា ទេវានំ អសុចី ចេវ អសុចិសង្ខាតា ច ទុគ្គន្ធា ច ទុគ្គន្ធសង្ខាតា ច ជេគុច្ឆា ច ជេគុច្ឆសង្ខាតា ច បដិក្កូលា ច បដិក្កូលសង្ខាតា ច ។ យោជនសតំ ខោ រាជញ្ញ មនុស្សគន្ធោ ទេវេ ឧព្ពាហតិ ។ កឹ បន តេ មិត្តាមច្ចា ញាតិសាលោហិតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា បិសុណាវាចា បដិវិរតា ផរុសាវាចា បដិវិរតា សម្ផប្បលាបា បដិវិរតា អនភិជ្ឈាលូ អព្យាបន្នចិត្តា សម្មាទិដ្ឋី កាយស្ស ភេទា



លាមកនោះទៀតឬ ។ បពិត្រព្រះកស្សបដ៏ចម្រើន មិនត្រូវការប្រាថ្នាទៀតទេ ។ ចុះដំណើរនោះ តើព្រោះហេតុដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន (ព្រោះ) រណ្តៅលាមកមិនជាទីពេញចិត្ត ជារបស់មិនស្អាតផង ជាចំណែកនៃរបស់មិនស្អាតផង មានក្លិនស្អុយផង ជាចំណែកនៃរបស់មានក្លិនស្អុយផង ជារបស់គួរធុញទ្រាន់ផង ជាចំណែកនៃរបស់គួរធុញទ្រាន់ផង ជារបស់គួរខ្ពើមរអើមផង ជាចំណែកនៃរបស់គួរខ្ពើមរអើមផង ។ ម្នាលព្រះរាជញ្ញៈ មនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ គឺជាបុគ្គលមិនស្អាតផង ជាចំណែកនៃបុគ្គលមិនស្អាតផង មានក្លិនស្អុយផង ជាចំណែកនៃបុគ្គលមានក្លិនស្អុយផង គួរធុញទ្រាន់ផង ជាចំណែកនៃបុគ្គលគួរធុញទ្រាន់ផង គួរខ្ពើមរអើមផង ជាចំណែកនៃបុគ្គលគួរខ្ពើមរអើមផង នៃទេវតាទាំងឡាយ បពិត្ររាជញ្ញៈ ក្លិនមនុស្សតែងក្រក់ផ្សាយឡើងទៅកាន់ពួកទេវតា ចំនួន ១០០ យោជន៍ ពួកមិត្រអាមាត្យនិងញាតិសាលោហិត របស់មហាបពិត្រ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ មិនមានអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ លុះបែកធ្លាយរាងកាយ

បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា តេ អាគន្ត្វា អារោចេស្សន្តិ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ឥមិនាបិ ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

[១៦៥] កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ ឯវម្មេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយាយោ ។បេ។ អត្ថិ ភោ កស្សប បរិយាយោ ។បេ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ មេ ភោ កស្សប មិត្តាមច្ចា ញាតិសាលោហិតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា តេ អបរេន សមយេន អាពាធិកា ហោន្តិ





ខាងមុខអំពីសេចក្តីស្លាប់ បានទៅកើតឯឋានសុគតិសួគ៌ទេវលោកហើយ នឹងមកប្រាប់ថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាក របស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ដូចម្តេចបាន ។ រាជញ្ញៈ បើតាមបរិយាយនេះឯង សូមមហាបពិត្រ បែរព្រះរាជហឫទ័យយល់មកយ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាក របស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់មាន ដោយហេតុនេះ ។

[១៦៥] ព្រះកស្សបដ៏ចម្រើនពោលយ៉ាងនេះ ក៏គួរដែរហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ឃើញក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាក របស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ ។ ម្នាលព្រះរាជញ្ញៈ បរិយាយនៅមានទៀតឬ ។បេ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមានទៀត ។បេ។ ម្នាលព្រះរាជញ្ញៈ ចុះបរិយាយនោះ តើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួកមិត្រ អាមាត្យនិងញាតិសាលោហិតរបស់ខ្ញុំក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន លុះសម័យតទៅក្រោយមក ពួកមិត្រអាមាត្យជាដើមនោះ

ទុក្ខិតា ពាឡ្ហគិលានា យទាហំ ជានាមិ ន ទានិមេ ឥមម្ហា អាពាធា វុដ្ឋហិស្សន្តីតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សន្តិ ខោ ភោ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យេ តេ បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមា-ទដ្ឋានា បដិវិរតា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ទេវានំ តាវតឹសានំ សហព្យតន្តិ ភវន្តោ ខោ បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិ-វិរតា សចេ តេសំ ភវតំ សមណព្រាហ្មណានំ សច្ចំ វចនំ ភវន្តោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សន្តិ ទេវានំ តាវតឹសានំ សហព្យតំ សចេ ខោ ភោ(១) កាយស្ស ភេទា បរម្មរណា សុគតឹ

១ ម. ឆ. សចេ ភោ ។



មានអាពាធ ដល់នូវសេចក្ដីទុក្ខ ឈឺធ្ងន់ធ្ងរ កាលបើខ្ញុំ ដឹងថា ឥឡូវនេះ ពួកមិត្រអាមាត្យទាំងនេះ មុខជាមិនសះស្បើយ ចាកអាពាធនេះទេ ខ្ញុំក៏ចូលទៅរកពួកមិត្រអាមាត្យទាំងនោះ ហើយនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើនទាំងឡាយ មានសមណព្រាហ្មណ៍ ពួកមួយនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា ពួកជនណា ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន លុះពួកជនទាំងនោះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ តែងទៅកើតឯឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស (ឥឡូវនេះ) អ្នកដ៏ចំរើនទាំងឡាយសោត ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នា-ទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយ-មជ្ជប្បមាទដ្ឋានហើយ បើពាក្យរបស់សមណព្រាហ្មណ៍ទាំងនោះ ជាពាក្យពិតមែន អ្នកដ៏ចំរើនទាំងឡាយ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ គង់នឹងទៅកើតឯឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្សពុំខាន នែអ្នកដ៏ចំរើនទាំងឡាយ បើអ្នកទាំងឡាយបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្ដីស្លាប់ បានទៅកើតឯឋានសុគតិ

សគ្គំ លោកំ ឧបបជ្ជេយ្យាថ ទេវានំ តាវតិំសានំ សហព្យតំ យេន មេ អាគន្ត្វា អារោចេយ្យាថ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ភវន្តោ ខោ បន មេ សទ្ធាយិកា បច្ចយិកា យំ ភវន្តេហិ ទិដ្ឋំ យថា សាមំ ទិដ្ឋំ ឯវមេតំ ភវិស្សតីតិ តេ មេ សាធូតិ បដិស្សុត្វា នេវ អាគន្ត្វា អារោចេន្តិ ន បន ទូតំ បហិណន្តិ អយម្បិ ខោ ភោ[១] កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្ក-ដានំ កម្មានំ ផលំ វិបាកោតិ ។

[១៦២] តេនហិ រាជញ្ញ តញ្ញេវេត្ថ[២] បដិបុច្ឆិ-ស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេ-យ្យាសិ យំ ខោ បន រាជញ្ញ[៣] មនុស្សានំ វស្សសតំ ទេវានំ តាវតិំសានំ ឯសោ ឯកោ រត្តិន្ទិវោ

១ ម. អយម្បិ ខោ ។ ឧ. អយំបិ ខោ ភោ ។ ២ ម. តំយេវេត្ថ ។ ៣ ម. យំ ខោ រាជញ្ញ ។



សួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្សមែន អ្នកទាំងឡាយត្រូវមកប្រាប់យើងផងថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាក របស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់ មាន ដោយហេតុនេះ ព្រោះថា អ្នកទាំងឡាយជាទីជឿទុកចិត្ត ជាបុគ្គលដែលយើងគួរជឿ យើងគួរទទួលស្តាប់ពាក្យបាន ហេតុណា ដែលអ្នកជាទីជឿទុកចិត្តទាំងឡាយបានឃើញហើយ ហេតុនុ៎ះ នឹងដូចជាយើងបានឃើញដោយខ្លួនឯងដែរ ពួកមិត្រអាមាត្យទាំងនោះ ទទួលពាក្យរបស់ខ្ញុំថា ករុណាសេស ហើយមិនឃើញមកប្រាប់សោះ ទាំងមិនបញ្ជូនបម្រើមកឡើយ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាក របស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះ ។

(១៦២) ម្នាលព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាព នឹងត្រឡប់សួរមហាបពិត្រក្នុងបរិយាយនេះវិញ ប្រស្នានេះពេញព្រះហឫទ័យមហា-បពិត្រយ៉ាងណា សូមមហាបពិត្រព្យាករប្រស្នានោះយ៉ាងនោះចុះ បពិត្ររាជញ្ញៈ ១០០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស

តាយ រត្តិយា តឹស រត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វំ វស្សសហស្សំ ទេវានំ តាវតឹសានំ អាយុប្បមាណំ យេ តេ មិត្តាមច្ចា ញាតិសាលោហិតា បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមា-ទដ្ឋានា បដិវិរតា(១) កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នា ទេវានំ តាវតឹសានំ សហព្យតំ សចេ បន តេសំ ឯវំ ភវិស្សតិ យាវ មយំ ទ្វេ វា តីណិ វា រត្តិន្ទិវានិ ទិព្វេហិ បញ្ចហិ កាមគុណេហិ សមប្បិតា សមង្គីភូតា បរិចារេម អថ មយំ បាយាសិស្ស រាជញ្ញស្ស គន្ត្វា អារោចេយ្យាម ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ អបិ នុ តេ អាគន្ត្វា អារោចេយ្យុំ ឥតិបិ អត្ថិ

១ ឧ. ម. បដិវិរតា តេ ។



រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបានមួយពាន់ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវត្តឹង្ស ពួកមិត្រអាមាត្យញាតិសាលោហិតណា ជាអ្នកបានវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆា-ចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋានហើយ លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ បានទៅកើតឯឋានសុគតិសួគ៌ ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តឹង្ស លុះបើពួកមិត្រអាមាត្យទាំងនោះ មានគំនិតយ៉ាងនេះថា ចាំយើងទាំងឡាយឲ្យគេបម្រើឲ្យឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ ជាទិព្វ អស់យប់និងថ្ងៃពីរ ឬ បីសិន រួចសឹមយើងទៅប្រាប់ ដល់ព្រះបាយាសិរាជញ្ញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាក របស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ លុះពួកមិត្រអាមាត្យជាដើមនោះ គប្បីមក

បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ តេ ហនំ ភោ កស្សប អបិ ហំ មយំ ភោ កស្សប ចិរកាលកតាបិ(១) ភវេយ្យាម កោ បនេតំ ភោតោ កស្សបស្ស អារោចេតិ អត្ថិ ទេវា តាវត្តឹសាតិ វា ទីឃាយុកា ទេវា តាវត្តឹសាតិ វា ន មយំ ភោតោ កស្សបស្ស សទ្ទហាម អត្ថិ ទេវា តាវត្តឹសាតិ វា ទីឃាយុកា ទេវា តាវត្តឹសាតិ វា ។ សេយ្យថាបិ រាជញ្ញ ជច្ចន្ធោ បុរិសោ(២) ន បស្សេយ្យ កណ្ហសុក្កានិ រូបានិ ន បស្សេយ្យ នីលកានិ រូបានិ ន បស្សេយ្យ បីតកានិ រូបានិ ន បស្សេយ្យ លោហិតកានិ រូបានិ ន បស្សេយ្យ មញ្ជដ្ឋកានិ(៣) រូបានិ ន បស្សេយ្យ សមវិសមំ ន បស្សេយ្យ តារកានិ រូបានិ(៤) ន បស្សេយ្យ ចន្ទិមសុរិយេ សោ ឯវំ វទេយ្យ នត្ថិ កណ្ហសុក្កានិ

១ ឱ. ចិរត្តាលកតាបិ ។ ម. ចិរំ កាលំ កតាបិ ។ ២ ឱ. បុរិសោ យោ ។ ៣ ឱ. មញ្ជិដ្ឋិកានិ ។ ៤ ឱ. តារករូបានិ ។





ខ្លួនមហាបពិត្រថា លោកដទៃមាន ពួកសត្វដែលជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់មាន ដោយហេតុនេះ តើដូចម្ដេច ។ បពិត្រព្រះកស្សបដ៏ចម្រើន មកប្រាប់មិនទាន់ទេ បពិត្រព្រះកស្សបដ៏ចម្រើន បានជាមកប្រាប់មិនទាន់ ព្រោះថា ខ្ញុំមុខជានឹងស្លាប់ចាកទៅមុន យូរណាស់ហើយ ចុះអ្នកណាមកប្រាប់ដំណឹងនេះដល់ព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថាពួកទេវតាជាន់តាវត្តិង្ស មានអាយុវែង យ៉ាងនេះ យើងមិនទាន់ជឿព្រះកស្សបដ៏ចម្រើន ថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្ស មានអាយុវែង យ៉ាងនេះទេ ។ ម្នាលព្រះរាជញ្ញៈ ប្រៀបដូចជាបុរសខ្វាក់តាំងពីកំណើត មិនដែលឃើញរូបខ្មៅ ឬ ស មិនដែលឃើញរូបដែលមានសម្បុរខៀវ មិនដែលឃើញរូបមានសម្បុរលឿង មិនដែលឃើញរូបមានសម្បុរក្រហម មិនដែលឃើញរូបមានសម្បុរហង្សបាទ មិនដែលឃើញរបស់ស្មើនិងមិនស្មើ មិនដែលឃើញរូបផ្កាយទាំងឡាយ មិនដែលឃើញព្រះចន្ទ និងព្រះអាទិត្យទេ មនុស្សខ្វាក់នោះមុខជានឹងនិយាយយ៉ាងនេះថា រូបខ្មៅ ឬស គ្មានទេ បុគ្គល

រូបានិ នត្ថិ កណ្ហសុក្កានំ រូបានំ ទស្សាវី នត្ថិ នីលកា-
និ រូបានិ នត្ថិ នីលកានំ រូបានំ ទស្សាវី នត្ថិ បីតកានិ
រូបានិ នត្ថិ បីតកានំ រូបានំ ទស្សាវី នត្ថិ លោហិត-
កានិ រូបានិ នត្ថិ លោហិតកានំ រូបានំ ទស្សាវី នត្ថិ
មញ្ជេដ្ឋកានិ រូបានិ នត្ថិ មញ្ជេដ្ឋកានំ រូបានំ ទស្សាវី
នត្ថិ សមវិសមំ នត្ថិ សមវិសមស្ស ទស្សាវី នត្ថិ
តារកានិ រូបានិ នត្ថិ តារកានំ រូបានំ ទស្សាវី នត្ថិ
ចន្ទិមសុរិយា នត្ថិ ចន្ទិមសុរិយានំ ទស្សាវី អហមេតំ ន
ជានាមិ អហមេតំ ន បស្សាមិ តស្មា តំ នត្ថីតិ សម្មា
នុ ខោ សោ រាជញ្ញ វទមានោ វទេយ្យាតិ ។ នោ ហិទំ
ភោ កស្សប អត្ថិ កណ្ហសុក្កានិ រូបានិ អត្ថិ
កណ្ហសុក្កានំ រូបានំ ទស្សាវី អត្ថិ នីលកានិ រូបានិ
អត្ថិ នីលកានំ រូបានំ ទស្សាវី ។ បេ ។ អត្ថិ
សមវិសមំ អត្ថិ សមវិសមស្ស ទស្សាវី អត្ថិ
តារកានិ រូបានិ អត្ថិ តារកានំ រូបានំ ទស្សាវី
អត្ថិ ចន្ទិមសុរិយា អត្ថិ ចន្ទិមសុរិយានំ ទស្សាវី



អ្នកឃើញរូបខ្មៅ ឬ ស គ្មានទេ រូបខៀវគ្មានទេ បុគ្គលអ្នកឃើញរូប
មានសម្បុរខៀវគ្មានទេ រូបសម្បុរលឿងក៏គ្មានទេ បុគ្គលអ្នកឃើញរូប
សម្បុរលឿងក៏គ្មានទេ រូបសម្បុរក្រហមគ្មានទេ បុគ្គលអ្នកឃើញរូបសម្បុរ
ក្រហមគ្មានទេ រូបសម្បុរហង្សបាទគ្មានទេ បុគ្គលអ្នកឃើញរូបសម្បុរ
ហង្សបាទគ្មានទេ របស់ស្មើនិងមិនស្មើគ្មានទេ បុគ្គលអ្នកឃើញរបស់
ស្មើនិងមិនស្មើគ្មានទេ រូបផ្កាយគ្មានទេ បុគ្គលអ្នកឃើញរូបផ្កាយគ្មានទេ
ព្រះចន្ទនិងព្រះអាទិត្យគ្មានទេ បុគ្គលអ្នកឃើញនូវព្រះចន្ទ និងព្រះអា-
ទិត្យគ្មានទេ អាត្មាអញមិនស្គាល់របស់នុ៎ះ អាត្មាអញមិនឃើញរបស់នុ៎ះ
ហេតុដូច្នោះ របស់នោះគ្មានទេ បពិត្ររាជញ្ញៈដ៏ចំរើន កាលបើ
មនុស្សខ្វាក់អំពីកំណើតនិយាយ (យ៉ាងនេះ) ឈ្មោះថា និយាយត្រូវ
ឬទេ ។ បពិត្រព្រះកស្សបដ៏ចំរើន មិនត្រូវទេ (ព្រោះ) រូបខ្មៅ ឬ
ស មាន បុគ្គលអ្នកឃើញរូបខ្មៅ ឬ ស មាន រូបខៀវមាន បុគ្គលអ្នក
ឃើញរូបខៀវមាន ។ បេ ។ របស់ស្មើនិងមិនស្មើមាន បុគ្គលអ្នក
ឃើញរបស់ស្មើនិងមិនស្មើមាន រូបផ្កាយមាន បុគ្គលអ្នកឃើញរូបផ្កាយ
មាន ព្រះចន្ទព្រះអាទិត្យមាន បុគ្គលអ្នកឃើញព្រះចន្ទព្រះអាទិត្យមាន

អហមេតំ ន ជានាមិ អហមេតំ ន បស្សាមិ តស្មា តំ នត្ថីតិ ន ហិ សោ ភោ កស្សប សម្មា វទមានោ វទេយ្យាតិ ។ ឯវមេវ ខោ ត្វំ រាជញ្ញ ជច្ចន្ធូបមោ មញ្ញេ បដិភាសិ យមេតំ(១) ឯវំ វទេសិ កោ បនេតំ(២) ភោតោ កស្សបស្ស អារោចេតិ អត្ថិ ទេវា តាវតឹសាតិ វា ឯវំ ទីឃាយុកា ទេវា តាវតឹសាតិ វា ន មយំ ភោតោ កស្សបស្ស សទ្ទហាម អត្ថិ ទេវា តាវតឹសាតិ វា ឯវំ ទីឃាយុកា ទេវា តាវតឹសាតិ វា ន ខោ រាជញ្ញ ឯវំ បរោ លោកោ(៣) ទដ្ឋព្វោ យថា ត្វំ មញ្ញសិ ឥមិនា មំសចក្ខុនា ។ យេ ខោ តេ រាជញ្ញ សមណព្រាហ្មណា អរញ្ញវនបត្ថានិ(៤) បន្តានិ សេនាសនានិ បដិសេវន្តិ(៥) តេ តត្ថ អប្បមត្តា អាតាបិនោ បហិតត្តា វិហរន្តា ទិព្វចក្ខុំ វិសោធេន្តិ តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ឥមញ្ចេវ(៦) លោកំ បស្សន្តិ បរញ្ច(៧) សត្តេ ច ឱបបាតិកេ

---

១ ម. ឆ. យំ មំ ត្វំ ។ ២ ម. កោ បន តេ ។ ៣ ម. បរលោកោ ។ ៤ ម. អរញ្ញេ វនបត្ថានិ ។ ៥ ម. ឥតោ បរំ អប្បសទ្ទានិ អប្បនិគ្ឃោសានីតិ ទិស្សតិ ។ ៦ ម. ឥមញ្ច ។ ៧ ម. បរញ្ច ។





បពិត្រព្រះកស្សបដ៏ចម្រើន ការដែលបុរសខ្វាក់អំពីកំណើត និយាយថា អាត្មាអញ មិនស្គាល់របស់នុ៎ះ អាត្មាអញ មិនឃើញរបស់នុ៎ះ ព្រោះហេតុនោះ របស់នោះមិនមានទេ ដូច្នេះឈ្មោះថា និយាយមិនត្រូវសោះឡើយ ។ ម្នាលព្រះរាជញ្ញៈ ហើមហ៊ើងវៃមនោហើយ អន្លឹមហាបពិត្រដូចមនុស្សខ្វាក់អំពីកំណើតប្រាកដ (ចុះថា) មហាបពិត្រត្រាស់យ៉ាងនេះថា ចុះមានអ្នកណាមកប្រាប់ដំណឹងនេះ ដល់ព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្សមានអាយុវែង យ៉ាងនេះ យើងមិនជឿ (ពាក្យរបស់) ព្រះកស្សបដ៏ចម្រើនថា ពួកទេវតាជាន់តាវត្តិង្សមាន ឬថា ពួកទេវតាជាន់តាវត្តិង្សមានអាយុវែង យ៉ាងនេះទេ បពិត្ររាជញ្ញៈ ព្រះអង្គសម្គាល់បរលោកដោយមំសចក្ខុនេះ យ៉ាងណា ឯបរលោកដទៃ បុគ្គលមិនគប្បីឃើញបានយ៉ាងនោះឡើយ បពិត្ររាជញ្ញៈ ពួកសមណព្រាហ្មណ៍ណា អាស្រ័យសេពសេនាសនៈជាទីឆ្ងាយដ៏ស្ងាត់ ដែលជាទីនៅក្នុងព្រៃតូចនិងព្រៃធំ ពួកសមណព្រាហ្មណ៍ទាំងនោះ មិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន គប្បីជម្រះនូវទិព្វចក្ខុ នៅក្នុងព្រៃស្ងាត់នោះ ពួកសមណព្រាហ្មណ៍ទាំងនោះឯង ទើបឃើញលោកនេះផង លោកដទៃផង ពួកសត្វជាឱបបាតិកៈផង ដោយចក្ខុដ៏ជាទិព្វ ដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា

ឯវញ្ហិ ខោ(១) រាជញ្ញ បរោ លោកោ(២) ន ត្វេវ ទដ្ឋព្វោ យថា ត្វំ មញ្ញសិ ឥមិនា មំសចក្ខុនា ឥមិនាបិ ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

(១៤៧) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ ឯវម្មេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយាយោ ។ បេ ។ អត្ថិ ភោ កស្សប បរិយាយោ ។ បេ ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធាហំ ភោ កស្សប បស្សាមិ សមណព្រាហ្មណេ សីលវន្តេ កល្យាណធម្មេ ជីវិតុកាមេ អមរិតុកាមេ សុខកាមេ ទុក្ខប្បដិក្កូលេ តស្ស មយ្ហំ ភោ កស្សប ឯវំ ហោតិ សចេ ខោ

១ ម. ឯវំ ខោ ។ ២ ម. បរលោកោ ។



បពិត្រព្រះរាជញ្ញៈ ឯបុគ្គលគប្បីឃើញលោកខាងមុខ យ៉ាងនេះឯង មិនមែនដូចដែលមហាបពិត្រសំគាល់ដោយមំសចក្ខុនេះទេ ម្នាលរាជញ្ញៈ បើតាមបរិយាយនេះ សូមមហាបពិត្រទ្រង់ព្រះយោបល់ យ៉ាងនេះវិញថា លោកខាងមុខមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់មាន ដោយហេតុនេះ ។

(១៤៧) ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះក៏គួរមែនដែរ ហើយប៉ុន្តែខ្ញុំនៅតែមានសេចក្តីយល់ឃើញក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកខាងមុខមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អធ្វើអាក្រក់មិនមានដោយហេតុនេះ ។ ម្នាលព្រះរាជញ្ញៈ ចុះបរិយាយនៅមាន (ទៀត) ឬ ។ បេ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន ។ បេ ។ ម្នាលព្រះរាជញ្ញៈបរិយាយនោះតើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ក្នុងលោកនេះ ខ្ញុំឃើញពួកសមណព្រាហ្មណ៍មានសីលមានធម៌ល្អ ចង់តែរស់ មិនចង់ស្លាប់ ប្រាថ្នាតែសេចក្តីសុខ ស្អប់នូវទុក្ខ បពិត្រព្រះកស្សបដ៏ចម្រើន ខ្ញុំនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បើពួក

ឥមេ ភោន្តោ សមណព្រាហ្មណា សីលវន្តោ កល្យា-
ណធម្មា ឯវំ ជានេយ្យុំ ឥតោ នោ មតានំ សេយ្យោ
ភវិស្សតីតិ ឥធានិមេ ភោន្តោ សមណព្រាហ្មណា
សីលវន្តោ កល្យាណធម្មា វិសំ វា ខាទេយ្យុំ សត្ថំ វា
អាហរេយ្យុំ ឧព្ពន្ធិត្វា វា កាលំ ករេយ្យុំ បបាតេ វា
បបតេយ្យុំ យស្មា ច ខោ ឥមេ ភោន្តោ សមណ-
ព្រាហ្មណា សីលវន្តោ កល្យាណធម្មា ន ឯវំ ជានន្តិ
ឥតោ នោ មតានំ សេយ្យោ ភវិស្សតីតិ តស្មា ឥមេ
ភោន្តោ សមណព្រាហ្មណា សីលវន្តោ កល្យាណ-
ធម្មា ជីវិតុកាមា អមរិតុកាមា សុខកាមា ទុក្ខ-
បដិក្កូលា(១) អយម្បិ ខោ ភោ កស្សប បរិយាយោ
យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ
លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្ក-
ដានំ កម្មានំ ផលំ វិបាកោតិ ។

[១៦៨] តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ
ឧបមាយបីធេកច្ចេ(២) វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ

១ ឥតោ ចរ អត្ថានំ ឥ មាឡើកំ បាហោ ។ ២ ។ ឧបមាយបិ ឥធេកច្ចេ ។



សមណព្រាហ្មណ៍ដ៏ចំរើនទាំងនេះ មានសីល មានធម៌ល្អ គប្បីដឹង យ៉ាងនេះថា យើងទាំងឡាយ កាលបើស្លាប់ចាកលោកនេះទៅ មុខជានឹងបានសេចក្តីសុខប្រសើរ ឥឡូវនេះ ពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនេះ មានសីល មានធម៌ដ៏ល្អហើយ គួរតែស៊ីថ្នាំពិសក្តី យកកាំបិតមក (ចាក់ខ្លួន) ឯងក្តី ចងកសម្លាប់ក្តី លោតទំលាក់ខ្លួនចុះក្នុងជ្រោះក្តី តែពួកសមណ-ព្រាហ្មណ៍ដ៏ចំរើនទាំងនេះ មានសីល មានធម៌ល្អហើយ មិនដឹងយ៉ាងនេះថា យើងកាលបើស្លាប់ ចាកលោកនេះទៅ នឹងបានសេចក្តីសុខប្រសើរជាងនេះឡើយ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនេះ មានសីល មានធម៌ល្អហើយ នៅតែចង់រស់ មិនចង់ស្លាប់ ប្រាថ្នាតែសេចក្តីសុខ ស្អប់នូវទុក្ខ បពិត្រព្រះកស្សបដ៏ចំរើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានសេចក្តីយល់ចិត្ត យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

[១៦៨] ថ្វាយព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ ព្រោះពួកបុរសជាអ្នកចេះដឹងខ្លះ ក្នុងលោកនេះ

អាជានន្តិ ភូតបុព្វំ រាជញ្ញ អញ្ញតរស្ស ព្រាហ្មណស្ស ទ្វេ បជាបតិយោ អហេសុំ ឯកិស្សា បុត្តោ អហោសិ ទសវស្សុទ្ទេសិកោ វា ទ្វាទសវស្សុទ្ទេសិកោ វា ឯកា គព្ភិនី ឧបវិជញ្ញា អថខោ សោ ព្រាហ្មណោ កាលមកាសិ អថខោ សោ មាណវកោ មាតុសបត្តឹ(១) ឯតទវោច យម្បិទំ ភោតិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា សព្វន្តំ មយ្ហំ នត្ថិ តុយ្ហេត្ថ កិញ្ចិ បិតុ មេ សន្តកោ(២) ភោតិ ទាយជ្ជំ និយ្យាទេហីតិ ។ ឯវំ វុត្តេ សា ព្រាហ្មណី តំ មាណវកំ ឯតទវោច អាគមេហិ តាវ តាត យាវ វិជាយាមិ សចេ កុមារកោ ភវិស្សតិ តស្សបិ ឯកទេសោ ភវិស្សតិ សចេ កុមារិកា ភវិស្សតិ សាបិ តេ ឱបភោគ្គា(៣) ភវិស្សតីតិ ។ ទុតិយម្បិ ខោ សោ(៤) មាណវកោ មាតុសបត្តឹ ឯតទវោច យម្បិទំ ភោតិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា សព្វន្តំ

១ មាតុសបត្តិម្បិ ឈោ ។ ២ ម. សន្តកោតិ ន ទិស្សតិ ។ ៣ ម. ឱបភោគ្គា ។ ៤ ម. សោតិ ន ទិស្សតិ ។



នឹងយល់សេចក្តីនៃភាសិត ដោយការឧបមាបាន បពិត្រព្រះរាជញ្ញៈ កាលពីព្រេងនាយមក មានព្រាហ្មណ៍ម្នាក់ មានប្រពន្ធពីរនាក់ គឺ ប្រពន្ធម្នាក់ មានកូនប្រុស ១ មានអាយុ ១០ ឆ្នាំ ឬ ១២ ឆ្នាំ ប្រពន្ធម្នាក់ទៀត កំពុងតែមានគភ៌ ជិតនឹងសម្រាល គ្រានោះ ព្រាហ្មណ៍ ជា(ស្វាមី)នោះ ក៏ធ្វើមរណកាលទៅ លំដាប់នោះ មាណពជាកូននោះ បាននិយាយនឹងម្តាយចុង យ៉ាងនេះថា នែអ្នកម្តាយដ៏ចម្រើន របស់ណាគឺទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី របស់ទាំងអស់នោះ ជារបស់ខ្ញុំ ឯអ្នកមិនត្រូវបានចំណែកតិចតួច ក្នុងសម្បត្តិនេះទេ នែអ្នកម្តាយដ៏ចម្រើន សូមអ្នកម្តាយប្រគល់ទ្រព្យមត៌ក ជារបស់បិតាខ្ញុំមកខ្ញុំ ។ កាលមាណពនោះ និយាយយ៉ាងនេះ នាងព្រាហ្មណីនោះ បាននិយាយនឹងមាណពនោះយ៉ាងនេះថា នែកូន ចូរចាំបន្តិចសិន ទម្រាំអញសម្រាលកូនរួចសិន បើកូននោះ ជាកូនប្រុស កូនប្រុសនោះ នឹងត្រូវបានទ្រព្យបន្តិចបន្តួចដែរ បើកូននោះជាកូនស្រី កូនស្រីនោះ នឹងបានធ្វើជាភរិយារបស់អ្នក ។ មាណពនោះ និយាយនឹងម្តាយចុងជាគម្រប់ពីរដងយ៉ាងនេះថា នែអ្នកម្តាយ របស់ណា គឺទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី របស់ទាំងអស់នោះ

មយ្ហំ នត្ថិ តុយ្ហេត្ថ(១) កិញ្ចិ បិតុ មេ សន្តកោ ភោតិ ទាយជ្ជំ និយ្យាទេហីតិ ។ ទុតិយម្បិ ខោ សា ព្រាហ្មណី តំ មាណវកំ ឯតទវោច អាគមេហិ តាវ តាត យាវ វិជាយាមិ សចេ កុមារកោ ភវិស្សតិ តស្សបិ ឯកទេសោ ភវិស្សតិ សចេ កុមារិកា ភវិស្សតិ សាបិ តេ ឱបភោគ្គា ភវិស្សតីតិ ។ តតិយម្បិ ខោ សោ មាណវកោ មាតុសបត្តឹ ឯតទវោច យមិទំ ភោតិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា សព្វន្តំ មយ្ហំ នត្ថិ តុយ្ហេត្ថ កិញ្ចិ បិតុ មេ សន្តកោ ភោតិ ទាយជ្ជំ និយ្យាទេហីតិ ។ អថ ខោ សា ព្រាហ្មណី សត្ថំ គហេត្វា ឱវរកំ បវិសិត្វា ឧទរំ ឱប្បាទេសិ(២) យាវ វិជានាមិ(៣) យទិ វា កុមារកោ យទិ វា កុមារិកាតិ សា អត្តានញ្ចេវ ជីវិតញ្ច គព្ភញ្ច សាបតេយ្យញ្ច យថាតំ ពាលា អព្យត្តា អនយព្យសនំ អាបន្នា អយោនិសោ ទាយជ្ជំ គវេសន្តី ឯវមេវ ខោ ត្វំ រាជញ្ញ ពាលោ

១ ឱ. តុយ្ហំ ។ ២ ឱ. ម. ឱបាទេសិ ។ ៣ ឱ. វិជាយាមិ ។



ជារបស់ខ្ញុំ អ្នកមិនត្រូវបានចំណែកតិចតួចក្នុងសម្បត្តិនេះទេ ម្នាលអ្នកម្តាយដ៏ចម្រើន ចូរអ្នកប្រគល់ទ្រព្យមត៌កជារបស់បិតាឲ្យមកខ្ញុំ ។ នាងព្រាហ្មណីនោះនិយាយនឹងមាណពនោះ ជាគម្រប់ពីរដងទៀត យ៉ាងនេះថា នែបា ចូរអ្នកចាំទីសិន ទម្រាំអញសម្រាលកូនរួច បើកូននោះជាកូនប្រុស កូនប្រុសនោះនឹងត្រូវបានទ្រព្យមត៌កមួយចំណែកដែរ បើកូននោះជាកូនស្រី កូនស្រីនោះនឹងបានជាភរិយារបស់អ្នក ។ មាណពនោះ និយាយនឹងម្តាយចុង ជាគម្រប់បីដង យ៉ាងនេះថា នែអ្នកម្តាយដ៏ចម្រើន របស់ណា គឺទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី របស់ទាំងអស់នោះជារបស់ខ្ញុំ អ្នកមិនត្រូវបានចំណែកតិចតួចក្នុងសម្បត្តិនេះទេ នែអ្នកម្តាយ ចូរអ្នកប្រគល់ទ្រព្យមត៌កជារបស់បិតាឲ្យមកខ្ញុំ ។ លំដាប់នោះឯង នាងព្រាហ្មណីនោះ កាន់កាំបិតចូលទៅក្នុងបន្ទប់ ហើយវះពោះខ្លួនឯង ដោយគិតថា បើជាប្រុសឬស្រី គង់អញគង់ដឹងច្បាស់បាន នាងព្រាហ្មណីនោះ ហេតុតែល្ងង់មិនឈ្លាសវៃ ស្វែងរកទ្រព្យមត៌កដោយមិនត្រូវទំនង ក៏ធ្វើឲ្យសេចក្តីវិនាសដល់ខ្លួនផង ជីវិតផង កូនក្នុងគភ៌ផង សម្បត្តិផង ដោយពិត បពិត្ររាជញ្ញៈ ព្រះអង្គជាបុគ្គលល្ងង់

អព្យត្តោ អនយព្យសនំ អាបជ្ជិស្សសិ អយោនិសោ បរលោកំ គវេសន្តោ សេយ្យថា ព្រាហ្មណី(១) ពាលា អព្យត្តា អនយព្យសនំ អាបន្នា អយោនិសោ ទាយជ្ជំ គវេសន្តី ។ ន ខោ រាជញ្ញ សមណព្រាហ្មណា សីលវន្តោ កល្យាណធម្មា អបក្កំ បរិបាចេន្តិ អបិច បរិបាកំ អាគមេន្តិ បណ្ឌិតា(២) ។ អត្ថោ ហិ(៣) រាជញ្ញ សមណព្រាហ្មណានំ សីលវន្តានំ កល្យាណធម្មានំ ជីវិតេន យថា រាជញ្ញ សមណព្រាហ្មណា សីលវន្តោ កល្យាណធម្មា ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ តថា ពហុំ បុញ្ញំ បសវន្តិ ពហុជនហិតាយ ច បដិបជ្ជន្តិ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ ឥមិនាបិ ខោ(៤) រាជញ្ញ បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ ។ បេ ។ ដល់ វិបាកោតិ ។

---

១ ម. ឧ. សេយ្យថាបិ សា ព្រាហ្មណី ។ ២ ឧ. បណ្ឌិតានំ ។ ៣ ម. ឧ. អត្ថោ ហិ ។ ៤ ម. ឧ. ខោ តេ ។



មិនឈ្លាសវៃ ស្វែងរកបរលោកដោយខុសទំនង នឹងដល់នូវសេចក្តីវិនាស ដូចជាព្រាហ្មណី ដែលល្ងង់មិនឈ្លាសវៃ ស្វែងរកសម្បត្តិដោយមិនត្រូវទំនង ក៏បានដល់នូវសេចក្តីវិនាស ដូច្នោះមិនខាន ។ បពិត្ររាជញ្ញៈ សមណព្រាហ្មណ៍ទាំងឡាយមានសីល មានធម៌ល្អ រមែងមិនផ្តាច់បង់នូវអាយុ ដែលមិនទាន់ចាស់ទេ ម្យ៉ាងទៀត អ្នកប្រាជ្ញទាំងឡាយ តែងរង់ចាំកាលឲ្យអាយុដល់កំណត់ ។ បពិត្ររាជញ្ញៈ សមណព្រាហ្មណ៍ទាំងឡាយមានសីល មានធម៌ល្អ មានជីវិតរស់នៅជាផ្លែ ផលផ្កា បពិត្ររាជញ្ញៈ ពួកសមណព្រាហ្មណ៍ មានសីល មានធម៌ល្អ បើនៅរស់កាលយូរអង្វែង ដោយប្រការណា ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងបាននូវបុណ្យច្រើន និងប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការដូច្នោះឯង ។ រាជញ្ញៈ បើតាមបរិយាយនេះ សូមមហាបពិត្របែរព្រះហឫទ័យយល់មក យ៉ាងនេះវិញថា លោកដទៃមាន ។ បេ ។ ផលវិបាកមាន ដោយហេតុនេះ ។

[១៦៩] កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ ឯវំ មេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ ។ បេ ។ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយាយោ ។ បេ ។ អត្ថិ ភោ កស្សប បរិយាយោ ។ បេ ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ មេ ភោ កស្សប បុរិសា ចោរំ អាគុចារឹ គហេត្វា ទស្សេន្តិ អយន្តេ ភន្តេ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ[១] ត្យាហំ ឯវំ វទាមិ តេនហិ ភោ ឥមំ បុរិសំ ជីវន្តំយេវ កុម្ភិយា បក្ខិបិត្វា មុខំ បិទហិត្វា អល្លេន ចម្មេន ឱនន្ធិត្វា[២] អល្លាយ មត្តិកាយ ពហលាវលេបនំ[៣] ករិត្វា ឧទ្ធនំ អារោបេត្វា អគ្គឹ ទេថាតិ ។ តេ មេ សាធូតិ បដិស្សុត្វា[៤] តំ បុរិសំ ជីវន្តំយេវ កុម្ភិយា បក្ខិបិត្វា មុខំ បិទហិត្វា អល្លេន ចម្មេន ឱនន្ធិត្វា អល្លាយ មត្តិកាយ ពហលាវលេបនំ ករិត្វា ឧទ្ធនំ អារោបេត្វា អគ្គឹ ទេន្តិ ។

---

១ ម. ឱ. បណោហីតិ ។ ២ ម. ឱ. ឱនទ្ធិត្វា ។ ៣ ម. ពហលាវលេបនំ ។ ៤ បដិស្សុណិត្វាតិ កត្ថចិ បោត្ថកេ ទិស្សតិ ។





(១៦៩) ព្រះកស្សបដ៏ចំរើន និយាយយ៉ាងនេះក៏គួរហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្ដីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកដទៃមិនមាន ។ បេ ។ ផលវិបាកមិនមាន ដោយហេតុនេះ ។ ថ្វាយព្រះពររាជញ្ញៈ ចុះបរិយាយមានទៀតឬ ។ បេ ។ បពិត្រព្រះកស្សបដ៏ចំរើន បរិយាយនៅមាន ។ បេ ។ ថ្វាយព្រះពររាជញ្ញៈ ចុះបរិយាយនោះដូចម្ដេច ។ បពិត្រព្រះកស្សបដ៏ចំរើន ពួករាជបុរសក្នុងដែននេះ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ យកមកបង្ហាញខ្ញុំថា បពិត្រព្រះអង្គដ៏ចំរើន អ្នកនេះជាចោរប្រព្រឹត្តអាក្រក់នឹងព្រះអង្គ ព្រះអង្គសព្វព្រះហឫទ័យ ដាក់កម្មណាដល់ចោរនេះ សូមព្រះអង្គដាក់អាជ្ញានោះមក ខ្ញុំក៏និយាយទៅនឹងរាជបុរសទាំងនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន បើដូច្នោះ ចូរអ្នកទាំងឡាយ ចាប់បុរសនេះទាំងរស់ ហើយដាក់ក្នុងខ្ទះ ហើយគ្របមាត់ខ្ទះ យកស្បែកស្រស់ពាសពីលើ រួចយកដីស្អិតសើមមកបូកឲ្យក្រាស់ ហើយលើកដាក់លើចង្ក្រានរួចដុតភ្លើង ឯរាជបុរសទាំងនោះ ទទួលពាក្យរបស់ខ្ញុំថា ករុណាវិសេស ហើយក៏ចាប់បុរសនោះទាំងរស់ ហើយដាក់ក្នុងខ្ទះ គ្របមាត់ខ្ទះ យកស្បែកស្រស់មកពាសពីលើ រួចយកដីស្អិតសើមមកបូកឲ្យក្រាស់ រួចដាក់លើចង្ក្រាន ហើយដុតភ្លើង ។

យទា មយំ ជានាម កាលង្កតោ សោ បុរិសោតិ អថ តំ(១) កុម្ភឹ ឱរោបេត្វា ឧព្ភិន្ទិត្វា មុខំ វិវរិត្វា សណិកំ វិលោកេម(២) អប្បេវនាមស្ស ជីវំ និក្ខមន្តំ បស្សេយ្យាមាតិ នេវស្ស មយំ ជីវំ និក្ខមន្តំ បស្សាម ។ អយម្បិ ខោ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ តេនហិ រាជញ្ញ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ អភិជានាសិ នោ ត្វំ រាជញ្ញ ទិវាសេយ្យំ ឧបគតោ សុបិនកំ បស្សិតា អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណិរាមណេយ្យកន្តិ ។ អភិជានាមហំ ភោ កស្សប ទិវាសេយ្យំ ឧបគតោ សុបិនកំ បស្សិតា អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណិរាមណេយ្យកន្តិ ។

១ ម. ឆ. នំ ។ ២ ម. ឆ. និល្លោកេម ។



កាលដែលយើងដឹងថា បុរសនោះស្លាប់ហើយ ទើបឲ្យគេយកឆ្នាំងចុះ ដាក់ខួរនោះចុះមក គាស់ដីស្អិតបើកមាត់សន្សឹម ៗ ហើយពិនិត្យមើលដោយបំណងថា យើងនឹងចាំមើលជីវៈ (ព្រលឹង) របស់បុរសនោះដែលចេញទៅ តែយើងមិនឃើញជីវៈរបស់បុរសនោះចេញទៅសោះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិត យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ៗ ម្នាលព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងត្រឡប់សួរមហាបពិត្រ ក្នុងបរិយាយនេះវិញ ប្រស្នានេះ គាប់ព្រះហឫទ័យនៃមហាបពិត្រ យ៉ាងណា សូមមហាបពិត្រព្យាករប្រស្នានោះយ៉ាងនោះ ។ បពិត្រព្រះរាជញ្ញៈ ទ្រង់ធ្លាប់ចូលទៅកាន់ទីព្រះបន្ទំ ក្នុងវេលាថ្ងៃ បានទ្រង់ព្រះសុបិនឃើញសួនច្បារជាទីសប្បាយ ព្រៃជាទីសប្បាយ (ទេសភាព) ផែនដីជាទីសប្បាយ ស្រះឈូកជាទីសប្បាយ ដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន ខ្ញុំធ្លាប់ចូលទៅកាន់ដំណេក ក្នុងវេលាថ្ងៃ ធ្លាប់យល់សប្តិឃើញសួនច្បារជាទីសប្បាយ ព្រៃជាទីសប្បាយ ផែនដីជាទីសប្បាយ ស្រះឈូកជាទីសប្បាយដែរ ។

រក្ខន្តិ តំ តម្ហិ សមយេ ខុជ្ជាបិ វាមនកាបិ វេលាសិ-
កាបិ(១) កោមារិកាបីតិ ។ ឯវំ(២) ភោ កស្សប
រក្ខន្តិ មំ តម្ហិ សមយេ ខុជ្ជាបិ វាមនកាបិ វេលា-
សិកាបិ កោមារិកាបីតិ ។ អបិ នុ តា បស្សន្តិ ជីវំ
បវិសន្តំ វា និក្ខមន្តំ វាតិ ។ នោ ហិទំ ភោ
កស្សប ។ តា ហិ នាម រាជញ្ញ ជីវន្តស្ស
ជីវន្តិយោ ជីវំ ន បស្សិស្សន្តិ បវិសន្តំ វា និក្ខមន្តំ
វា កឹ បន ត្វំ កាលង្កតស្ស ជីវំ បស្សិស្សសិ
បវិសន្តំ វា និក្ខមន្តំ វា ។ ឥមិនាបិ ខោ តេ រាជញ្ញ
បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ
អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មា-
នំ ផលំ វិបាកោតិ ។

(១៩០) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថ-
ខោ ឯវំ មេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ
នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ
កម្មានំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិ-
យាយោ ។ បេ ។ អត្ថិ ភោ កស្សប បរិយាយោ

១ ម. វេលាមិកាបិ ។ ម. វេលាសិកាបិ ។ ២ ម. ឯវម្ភោ ។



ចុះក្នុងសម័យនោះ មានពួកស្រីគម្ពខ្លះ ស្រីកញ្ជិខ្លះ ក្មេងស្រីកំពុងពេញ
លេញខ្លះ ក្មេងស្រីតូច ៗ ខ្លះ ចាំរក្សាព្រះអង្គដែរឬទេ ។ បពិត្រព្រះកស្សប
ដ៏ចម្រើន ក្នុងសម័យនោះ មានពួកស្រីគម្ពខ្លះ ស្រីកញ្ជិខ្លះ ក្មេងស្រី
កំពុងពេញលេញខ្លះ ក្មេងស្រីតូច ៗ ខ្លះ ចាំរក្សាខ្ញុំដែរ ។ ចុះពួកស្រី
ទាំងនោះ ឃើញព្រលឹងរបស់មហាបពិត្រ កំពុងចូលមក ឬកំពុងចេញ
ទៅដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន មិនឃើញទេ ។ ម្នាលរាជញ្ញៈ
អម្បាលយ៉ាងពួកស្រីទាំងនោះនៅរស់ គង់មិនឃើញព្រលឹងរបស់មហា-
បពិត្រកំពុងរស់នៅ កាលចូលមកឬចេញទៅ ចំណង់បើមហាបពិត្រស្លាប់ទៅ
ហើយ មហាបពិត្រនឹងគប្បីឃើញព្រលឹង កាលចូលមក ឬចេញទៅដូច-
ម្តេចបាន ។ ម្នាលរាជញ្ញៈ បើតាមបរិយាយនេះផង សូមមហាបពិត្រយល់
យ៉ាងនេះវិញថា លោកខាងមុខមាន ពួកសត្វជាឱបបាតិកៈមាន ផលវិបាក
របស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ។

[១៩០] ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះ ក៏គួរដែរហើយ ប៉ុន្តែខ្ញុំ
នៅតែមានសេចក្តីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកខាងមុខមិនមាន ពួក
សត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ
ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ម្នាលរាជញ្ញៈ ចុះបរិយាយ
នៅមានទៀតដែរឬ ។ បេ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន

។ បេ ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ មេ ភោ កស្សប បុរិសា ចោរំ អាគុចារឹ គហេត្វា ទស្សេន្តិ អយន្តេ ភន្តេ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ ត្យាហំ ឯវំ វទាមិ តេនហិ ភោ ឥមំ បុរិសំ ជីវន្តំយេវ តុលាយ តុលេត្វា ជិយាយ អនស្សាសកំ មារេត្វា បុនទេវ តុលាយ តុលេថាតិ តេ មេ សាធូតិ បដិស្សុត្វា តំ(១) បុរិសំ ជីវន្តំយេវ តុលាយ តុលេត្វា ជិយាយ អនស្សាសកំ មារេត្វា បុនទេវ តុលាយ តុលេន្តិ ។ យទា សោ ជីវតិ តទា លហុតរោ ច ហោតិ មុទុតរោ ច កម្មញ្ញតរោ ច ។ យទា បន សោ កាលង្កតោ ហោតិ តទា គរុតរោ ច ហោតិ បត្ថិន្នតរោ ច(២) អកម្មញ្ញតរោ ច ។ អយម្បិ ខោ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកត-ទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

---

១ ម. តន្តិ បទំ នត្ថិ ។ ២ ម. បត្ថិន្នតរោ ច ។



។ បេ ។ ថ្វាយព្រះពររាជញ្ញៈ បរិយាយនោះ តើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួករាជបុរសក្នុងដែននេះ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ យកមកឲ្យខ្ញុំថា បពិត្រព្រះករុណាដ៏ចម្រើន អ្នកនេះ ជាចោរប្រព្រឹត្តអាក្រក់នឹងព្រះអង្គ ព្រះអង្គសព្វព្រះហឫទ័យ ដាក់ទោសដូចណា ដល់ចោរនេះ សូមដាក់ទោសដល់ចោរនុះ ខ្ញុំក៏និយាយនឹងរាជបុរសទាំងនោះ យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ យកជញ្ជីងថ្លឹងបុរសនេះទាំងរស់ ហើយយកខ្សែធ្នូរួតកឲ្យតឹង មិនឲ្យមានដង្ហើមចេញ រួចឲ្យស្លាប់ រួចយកជញ្ជីងមកថ្លឹងម្តងទៀត រាជបុរសទាំងនោះ ទទួលពាក្យរបស់ខ្ញុំថា ករុណាវិសេស ហើយក៏យកជញ្ជីងមកថ្លឹងបុរសនោះទាំងរស់ រួចយកខ្សែធ្នូរួតកឲ្យតឹង មិនឲ្យមានដង្ហើមចេញរួចឲ្យស្លាប់ ហើយយកជញ្ជីងមកថ្លឹងម្តងទៀត ។ កាលបុរសនោះនៅរស់ ជាបុគ្គលស្រាលជាងផង ទន់ជាងផង គួរដល់ការងារជាងផង លុះបុរសនោះស្លាប់ហើយ ក៏រឹតតែធ្ងន់ជាងវិញផង រឹងជាងវិញផង មិនគួរដល់ការងារទៀតផង ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំឲ្យខ្ញុំមានគំនិតយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

## បាយាសិរាជញ្ញសុត្តំ អយោគុឡូបមា

(១៩១) តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ សេយ្យថាបិ រាជញ្ញ បុរិសោ ទិវសសន្តត្តំ[១] អយោគុឡំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ តុលាយ តុលេយ្យ តមេនំ អបរេន សមយេន សីតំ និព្វុតំ តុលាយ តុលេយ្យ កតមោ នុ ខោ សោ អយោគុឡោ លហុតរោ វា ហោតិ មុទុតរោ វា កម្មញ្ញតរោ វា យទា វា អាទិត្តោ សម្បជ្ជលិតោ សជោតិភូតោ យទា វា សីតោ និព្វុតោតិ ។ យទា សោ ភោ កស្សប អយោគុឡោ តេជោសហគតោ ច ហោតិ វាយោសហគតោ ច[២] អាទិត្តោ សម្បជ្ជលិតោ សជោតិភូតោ តទា លហុតរោ ច ហោតិ មុទុតរោ ច កម្មញ្ញតរោ ច យទា បន សោ អយោគុឡោ នេវ តេជោសហគតោ ហោតិ ន វាយោសហគតោ សីតោ និព្វុតោ តទា គរុតរោ ច ហោតិ បត្ថិន្នតរោ ច អកម្មញ្ញតរោ ចាតិ ។

១ ម. ទិវសសន្តត្តំ ។ ឱ. ទិវសំ សន្តត្តំ ។ ២ ម. បាឋោ នត្ថិ ។



## បាយាសិរាជញ្ញសូត្រ សេចក្តីប្រៀបដោយដុំដែក

[១៩១] ម្នាលព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ បុរសអ្នកចេះដឹងពួកខ្លះ ក្នុងលោកនេះ តែងដឹងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្ររាជញ្ញៈ ដូចជាបុរសយកជញ្ជីងថ្លឹងដុំដែក ដែលភ្លើងឆេះឆួលច្រាលឆ្អៅ មានអណ្តាតសន្ធោសន្ធៅ ក្តៅអស់មួយថ្ងៃ លុះសម័យតទៅខាងក្រោយមក គេក៏បានយកជញ្ជីងមកថ្លឹងដុំដែក ដែលរលត់ភ្លើងត្រជាក់អស់ហើយនោះ (ម្តងទៀត) ចុះដុំដែកនោះ ដែលទៅជាស្រាលជាង ទន់ជាង គួរដល់ការងារជាង តើក្នុងកាលណា ក្នុងកាលដែលកំពុងឆេះឆួលច្រាលឆ្អៅ មានអណ្តាតសន្ធោសន្ធៅឬ ឬក្នុងកាលដែលរលត់ភ្លើងត្រជាក់អស់ហើយ ។ បពិត្រព្រះកស្សបដ៏ចម្រើន ក្នុងកាលណា ដែលដុំដែកនោះប្រកបដោយភ្លើង ទាំងប្រកបដោយខ្យល់ កំពុងឆេះឆួលច្រាលឆ្អៅ មានអណ្តាតសន្ធោសន្ធៅ ក្នុងកាលនោះឯង ដុំដែកនោះស្រាលជាងផង ទន់ជាងផង គួរដល់ការងារជាងផង លុះតែកាលណា ដុំដែកនោះ មិនប្រកបដោយភ្លើង មិនប្រកបដោយខ្យល់ រលត់ភ្លើងត្រជាក់អស់ហើយ ក្នុងកាលនោះ ដុំដែកនោះ ទៅជាធ្ងន់ជាងផង រឹងជាងផង មិនគួរដល់ការងារជាងផង ។

ឯវមេវ ខោ រាជញ្ញ យទា អយំ(១) កាយោ អាយុសហគតោ ច ហោតិ ឧស្មាសហគតោ ច វិញ្ញាណសហគតោ ច តទា លហុតរោ ច ហោតិ មុទុតរោ ច កម្មញ្ញតរោ ច យទា បនាយំ កាយោ នេវ អាយុសហគតោ ច(២) ហោតិ ន ឧស្មាសហគតោ ច(៣) ន វិញ្ញាណសហគតោ ច(៤) តទា គរុតរោ ច ហោតិ បត្ថិន្នតរោ ច អកម្មញ្ញតរោ ច ។ ឥមិនាបិ ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ(៥) ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

(២៩៦) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ ឯវម្មេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយាយោ ។ បេ ។ អត្ថិ ភោ កស្សប

១ ម. យទាយំ ។ ២-៣-៤- ម. ម. ចសទ្ទោ នត្ថិ ។ ៥. ម. ម. ហោតិ ។



ថ្វាយព្រះរាជញ្ញៈ កាយនេះឯងក៏យ៉ាងនោះដែរ កាលណាបើប្រកបដោយអាយុផង ប្រកបដោយភ្លើងធាតុផង ប្រកបដោយវិញ្ញាណផង ទើបកាយនេះ ទៅជាស្រាលជាងផង ទន់ជាងផង គួរដល់ការងារជាងផង តែបើកាលណា កាយនេះ មិនប្រកបដោយអាយុផង មិនប្រកបដោយភ្លើងធាតុផង មិនប្រកបដោយវិញ្ញាណផងទេ កាយនេះឯង ក៏ទៅជាធ្ងន់ជាងផង រឹងជាងផង មិនគួរដល់ការងារផង ។ រាជញ្ញៈ បើតាមបរិយាយនេះ សូមមហាបពិត្រ យល់យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលធ្វើល្អធ្វើអាក្រក់មាន ដោយហេតុនេះ ។

(២៩៦) ព្រះកស្សបដ៏ចំរើន ពោលយ៉ាងនេះ ក៏គួរដែរហើយ តែខ្ញុំនៅតែមានសេចក្តីយល់ក្នុងហេតុនុ៎ះ យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វ ជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ថ្វាយព្រះរាជញ្ញៈ ចុះបរិយាយនៅមានទៀតដែរឬ ។ បេ ។ បពិត្រព្រះកស្សបដ៏ចំរើន

បរិយាយោ ។ បេ ។ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ មេ ភោ កស្សប បុរិសា ចោរំ អាគុចារឹ គហេត្វា ទស្សេន្តិ អយន្តេ ភន្តេ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ ត្យាហំ ឯវំ វទាមិ តេនហិ ភោ ឥមំ បុរិសំ អនុបហច្ច ឆវិញ្ច ចម្មញ្ច មំសញ្ច ន្ហារុញ្ច អដ្ឋិញ្ច អដ្ឋិមិញ្ជញ្ច ជីវិតា វោរោបេថ អប្បេវនាមស្ស ជីវំ និក្ខមន្តំ បស្សេយ្យាមាតិ តេ មេ សាធូតិ បដិស្សុត្វា(១) តំ បុរិសំ អនុបហច្ច ឆវិញ្ច ចម្មញ្ច មំសញ្ច ន្ហារុញ្ច អដ្ឋិញ្ច អដ្ឋិមិញ្ជញ្ច ជីវិតា វោរោបេន្តិ ។ យទា សោ អទ្ធមតោ(២) ហោតិ ត្យាហំ ឯវំ វទាមិ តេនហិ ភោ ឥមំ បុរិសំ ឧត្តានំ និបាតេថ អប្បេវនាមស្ស ជីវំ និក្ខមន្តំ បស្សេយ្យាមាតិ តេ តំ បុរិសំ ឧត្តានំ និបាតេន្តិ ។ នេវស្ស មយំ ជីវំ និក្ខមន្តំ បស្សាម ត្យាហំ ឯវំ វទាមិ

១ ម. វោរោបេថាតិ ។ តេ មេ សាធូតិ បដិស្សុណិត្វាតិ បាឋោ ទិស្សតិ ។
២ ម. មតោ ។



បរិយាយនៅមាន ។ បេ ។ ដូចព្រះរាជញ្ញៈ ចុះបរិយាយនោះតើដូចម្ដេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួករាជបុរសក្នុងដែននេះ ចាប់បានចោរដែលប្រព្រឹត្តអាក្រក់មកឲ្យខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន បុរសនេះជាចោរប្រព្រឹត្តអាក្រក់នឹងព្រះអង្គ ព្រះអង្គសព្វព្រះហឫទ័យ នឹងដាក់អាជ្ញាណាដល់ចោរនេះ សូមព្រះអង្គដាក់អាជ្ញានោះចុះ ខ្ញុំក៏និយាយយ៉ាងនេះ នឹងរាជបុរសទាំងនោះថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរសម្លាប់បុរសនេះចុះ តែកុំឲ្យខូចស្បែកក្រៅ ស្បែកក្នុង សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ក្រែងយើងនឹងបានឃើញជីវៈ (ព្រលឹង) របស់បុរសនោះចេញមក រាជបុរសទាំងនោះទទួលពាក្យរបស់ខ្ញុំថា ករុណាពិសេស ហើយក៏សម្លាប់បុរសនោះ មិនឲ្យមានស្នាមដាំដាំ ត្រង់ស្បែកក្រៅ ស្បែកក្នុង សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹងឡើយ ។ ក្នុងកាលដែលគេកំពុងប្រែប្រៀបនឹងស្លាប់ហើយនោះ ខ្ញុំបាននិយាយនឹងរាជបុរសទាំងនោះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ឲ្យបុរសនេះដេកផ្ងារឡើង ក្រែងយើងនឹងបានឃើញជីវៈរបស់វាចេញមក រាជបុរសទាំងនោះ ក៏ឲ្យបុរសនោះដេកផ្ងារឡើង ។ យើងក៏មិនឃើញជីវៈរបស់ចោរនោះចេញមកសោះ ខ្ញុំនិយាយនឹងរាជបុរសទាំងនោះ យ៉ាងនេះទៀតថា

តេនហិ ភោ ឥមំ បុរិសំ អវកុជ្ជំ និបាតេថ បស្សេន និបាតេថ ទុតិយេន បស្សេន និបាតេថ ឧទ្ធំ ឋបេថ ឱមុទ្ធកំ ឋបេថ បាណិនា អាកោដេថ លេឌ្ឌុនា(១) អាកោដេថ ទណ្ឌេន អាកោដេថ សត្ថេន អាកោដេថ ឱធុនាថ សន្ធុនាថ និទ្ធុនាថ អប្បេវនាមស្ស ជីវំ និក្ខមន្តំ បស្សេយ្យាមាតិ ។ តេ តំ បុរិសំ ឱធុនន្តិ សន្ធុនន្តិ និទ្ធុនន្តិ ។ នេវស្ស មយំ ជីវំ និក្ខមន្តំ បស្សេយ្យាម ។ តស្ស តញ្ញេវ ចក្ខុំ ហោតិ តេ រូបា តញ្ចាយតនំ នប្បដិសំវេទេតិ ។ តញ្ញេវ សោតំ ហោតិ តេ សទ្ទា តញ្ចាយតនំ នប្បដិសំវេទេតិ ។ តញ្ញេវ ឃានំ ហោតិ តេ គន្ធា តញ្ចាយតនំ នប្បដិសំវេទេតិ ។ សាយេវ ជិវ្ហា ហោតិ តេ រសា តញ្ចាយតនំ នប្បដិសំវេទេតិ ។ ស្វេវ(២) កាយោ ហោតិ

---

១ ម. លេឌ្ឌុនាតិបិ បាឋោ ។ ២ ម. សោយេវ ។



ម្នាលអ្នកដ៏ចំរើន បើដូច្នោះ ចូរអ្នកទាំងឡាយ ឲ្យបុរសនេះដេកផ្កាប់ ដេកផ្អៀងទៅម្ខាងហើយ ឲ្យដេកផ្អៀងទៅម្ខាងទៀត ហើយលើកបញ្ឈរឡើង លើកសំយុងក្បាលចុះ យកដៃគោះមើល យកដុំដីគោះមើល យកដំបងគោះមើល យកគ្រឿងសាស្ត្រាគោះមើល ទាញមក ច្រានត្រឡប់ទៅវិញ ទាញប្រែត្រឡប់ទៅ ត្រឡប់មក ក្រែងយើងនឹងបានឃើញជីវៈរបស់បុរសនេះចេញទៅ ឯពួកបុរសទាំងនោះ ក៏ទាញបុរសនោះមក ច្រានត្រឡប់ទៅវិញ ទាញប្រែត្រឡប់ទៅត្រឡប់មក ។ យើងក៏មិនបានឃើញជីវៈរបស់បុរសនោះ ចេញមកសោះ ។ ភ្នែកនោះឯងរបស់បុរសនោះ ក៏នៅជាភ្នែកដដែល រូបទាំងឡាយនោះ ក៏នៅជារូបដដែល ប៉ុន្តែបុរសនោះឯង មើលមិនឃើញរូបរូបាយតនៈនោះ (ដោយភ្នែកនោះ) សោះ ។ ត្រចៀកនោះឯង ក៏នៅជាត្រចៀកដដែល សំឡេងទាំងឡាយនោះ ក៏នៅជាសំឡេងដដែល តែបុរសនោះស្តាប់សព្ទាយតនៈនោះមិនឮ (ដោយត្រចៀក) សោះ ។ ច្រមុះនោះឯង ក៏នៅជាច្រមុះដដែល ក្លិនទាំងឡាយនោះ ក៏នៅជាក្លិនដដែល តែបុរសនោះមិនធុំនូវគន្ធាយតនៈនោះ (ដោយច្រមុះនោះ) សោះ ។ អណ្តាតនោះឯង ក៏នៅជាអណ្តាតដដែល រសទាំងឡាយនោះក៏នៅជារសដដែល តែបុរសនោះមិនដឹងច្បាស់នូវរសាយតនៈនោះ (ដោយអណ្តាតនោះ) សោះ ។ កាយនោះឯង ក៏នៅជាកាយដដែល

តេ ផោដ្ឋព្វា កាយាយតនំ បដិសំវេទេតិ ។ អយម្បិ ខោ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

(២៤៣) តេនហិ រាជញ្ញ ឧបមំ តេ ករិស្សាមិ ឧបមាយមិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ ភូតបុព្វំ រាជញ្ញ អញ្ញតរោ សង្ខធមោ សង្ខំ អាទាយ បច្ចន្តិមំ ជនបទំ អគមាសិ ។ សោ យេន អញ្ញតរោ គាមោ តេនុបសង្កមិ ឧបសង្កមិត្វា មជ្ឈេ គាមស្ស ឋិតោ តិក្ខត្តុំ សង្ខំ ឧបល្លាសេត្វា សង្ខំ ភូមិយំ និក្ខិបិត្វា ឯកមន្តំ និសីទិ ។ អថ ខោ រាជញ្ញ តេសំ បច្ចន្តជនបទានំ មនុស្សានំ(១) ឯតទហោសិ អម្ភោ កស្ស(២) នុ ខោ ឯសោ សទ្ទោ ឯវំរជនិយោ(៣) ឯវំកមនិយោ ឯវំមទនិយោ ឯវំពន្ធនិយោ ឯវំមុច្ឆនិយោតិ ។ សន្និបតិត្វា តំ សង្ខធមំ ឯតទវោចុំ

១ ម. បច្ចន្តជានំ មនុស្សានំ ។ ឱ. បច្ចន្តជនបទមនុស្សានំ ។ ២ ម. ឯតទហោសិ កិស្ស ។ ៣ ម. ឱ. ឯវំរជនីយោ ... ឯវំមុច្ឆនីយោតិ ។





ដោយផោដ្ឋព្វៈទាំងឡាយនោះ ក៏មិនបានដឹងផោដ្ឋព្វៈបានដែល ចាស់តែបុរសនោះមិនដឹងច្បាស់នូវផោដ្ឋព្វាយតនៈនោះ (ដោយកាយនោះ) សោះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំខ្ញុំឲ្យមានសេចក្តីយល់ឃើញយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

(២៤៣) បពិត្ររាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ វិញ្ញូបុរសទាំងឡាយពួកខ្លះ ក្នុងលោកនេះ រមែងយល់សេចក្តីនៃការនិយាយដោយឧបមាបាន ។ បពិត្ររាជញ្ញៈ កាលពីព្រេងនាយមក មានបុរសផ្លុំស័ង្ខម្នាក់ កាន់ស័ង្ខដើរទៅកាន់ជនបទ ដែលនៅជាប់ដែន ។ បុរសនោះ ចូលទៅកាន់ស្រុកមួយ លុះចូលទៅដល់ហើយ ឈរកណ្តាលស្រុកផ្លុំស័ង្ខ ៣ ដង ហើយដាក់ស័ង្ខលើផែនដី រួចអង្គុយក្នុងទីដ៏សមគួរ ។ បពិត្ររាជញ្ញៈ លំដាប់នោះ ពួកមនុស្សនៅក្នុងបច្ចន្តជនបទនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នែអ្នកដ៏ចំរើន ចុះសម្លេងនោះ តើជាសម្លេងអ្វី ខានជាគួរឲ្យយើងត្រេកអរ អ្វីដល់ម្លេះ គួរឲ្យចង់ស្តាប់អ្វីម្លេះ គួរឲ្យភាន់ភាំងអ្វីម្លេះ គួរឲ្យជាប់ចិត្តអ្វីម្លេះ គួរឲ្យស្រលាញ់អ្វីម្លេះ ។ មនុស្សទាំងនោះប្រជុំគ្នា ហើយសួរទៅអ្នកផ្លុំស័ង្ខនោះយ៉ាងនេះថា

អម្ភោ កស្ស(១) នុ ខោ ឯសោ សទ្ទោ ឯវំរជនិយោ ឯវំកមនិយោ ឯវំមទនិយោ ឯវំពន្ធនិយោ ឯវំមុច្ឆនិយោតិ ។ ឯសោ ខោ ភោ សង្ខោ នាម យស្សេសោ(២) សទ្ទោ ឯវំរជនិយោ ឯវំកមនិយោ ឯវំមទនិយោ ឯវំពន្ធនិយោ ឯវំមុច្ឆនិយោតិ ។ តេ តំ សង្ខំ ឧត្តានំ និបាតេសុំ វទេហិ ភោ សង្ខ វទេហិ ភោ សង្ខាតិ ។ នេវ សោ សង្ខោ សទ្ទមកាសិ ។ តេ តំ សង្ខំ អវកុជ្ជំ និបាតេសុំ បស្សេន និបាតេសុំ ទុតិយេន បស្សេន និបាតេសុំ ឧទ្ធំ ឋបេសុំ អធោ ឋបេសុំ បាណិនា អាកោដេសុំ លេឌ្ឌុនា អាកោដេសុំ ទណ្ឌេន អាកោដេសុំ សត្ថេន អាកោដេសុំ ឱធុនឹសុ សន្ធុនឹសុ និទ្ធុនឹសុ វទេហិ ភោ សង្ខ វទេហិ ភោ សង្ខាតិ ។ នេវ សោ សង្ខោ សទ្ទមកាសិ ។ អថខោ រាជញ្ញ តស្ស សង្ខធមស្ស ឯតទហោសិ យាវ ចេ(៣) ពាលា ឥមេ បច្ចន្តជនបទា មនុស្សា(៤)

១ ម. កស្ស ។ ២ ម. យស្សេសោ ។ ៣ ម. ពាលា ឥមេ ។ ៤ ម. បច្ចន្តជា មនុស្សា ។ ម. បច្ចន្តជនបទមនុស្សា ។



នែអ្នកដ៏ចម្រើន ចុះសំឡេងនោះ ជាសំឡេងអ្វី បានជាគួរឲ្យយើងត្រេកអរដល់ម្ល៉េះ គួរឲ្យចង់ស្ដាប់ម្ល៉េះ គួរឲ្យភាន់ភាំងម្ល៉េះ គួរឲ្យជាប់ចិត្តម្ល៉េះ គួរឲ្យស្រាយទុក្ខម្ល៉េះ ។ បុរសអ្នកផ្លុំស័ង្ខ និយាយថា ម្នាលអ្នកដ៏ចម្រើន សំឡេងដែលគួរឲ្យអ្នកផង ត្រេកអរយ៉ាងនេះ គួរឲ្យចង់ស្ដាប់យ៉ាងនេះ គួរឲ្យភាន់ភាំងយ៉ាងនេះ គួរឲ្យជាប់ចិត្តយ៉ាងនេះ គួរឲ្យស្រាយទុក្ខយ៉ាងនេះ សំឡេងនោះ គឺជាសំឡេងស័ង្ខនេះឯង ។ មនុស្សទាំងនោះ ក៏ផ្ដួលស័ង្ខនោះ ឲ្យផ្ងារឡើង ហើយនិយាយថា នែស័ង្ខដ៏ចម្រើន ចូរឯងបន្លឺ (សំឡេង) ទៅមើល នែស័ង្ខដ៏ចម្រើន ចូរឯងបន្លឺ (សំឡេង) ទៅមើល ។ ស័ង្ខនោះ ក៏មិនបន្លឺ (សំឡេង) សោះ ។ មនុស្សទាំងនោះ ក៏ផ្កាប់ស័ង្ខនោះ ហើយផ្ដេកទៅម្ខាង ផ្ដេកទៅម្ខាងទៀត ហើយលើកបញ្ឈរឡើង សំយុងចុះ យកដៃគោះ យកដុំដីគោះ យកដំបងគោះ យកគ្រឿងសស្ត្រាគោះ ប្រវៀលមក ប្រវៀលទៅ ប្រវៀលចុះ ប្រវៀលឡើង ហើយនិយាយថា នែស័ង្ខដ៏ចម្រើន ចូរឯងបន្លឺ (សំឡេង) ទៅមើល នែស័ង្ខដ៏ចម្រើន ចូរឯងបន្លឺ (សំឡេង) ទៅមើល ។ ស័ង្ខនោះ ក៏នៅតែមិនបន្លឺ (សំឡេង) សោះ ។ បពិត្ររាជញ្ញ លំដាប់នោះ អ្នកផ្លុំស័ង្ខនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងបច្ចន្តជនបទ ទាំងអស់នេះ ហោចពេញជាមនុស្សល្ងង់

កថញ្ហិ(១) នាម អាហោកនិសោ សង្ខោ សទ្ទំ ករិស្សតីតិ ។ តេសំ បេក្ខមានានំ សង្ខំ គហេត្វា តិក្ខត្តុំ សង្ខំ ឧបឡាសេត្វា សង្ខំ អាទាយ បក្កាមិ ។ អថខោ រាជញ្ញ តេសំ បច្ចន្តជនបទានំ មនុស្សានំ ឯតទហោសិ យទា កិរ ភោ អយំ សង្ខោ នាម បុរិសសហគតោ ច ហោតិ វាយាមសហគតោ ច វាយុសហគតោ ច តទាយំ សង្ខោ សទ្ទំ ករោតិ យទា បនាយំ សង្ខោ នេវ បុរិសសហគតោ ហោតិ ន វាយាមសហគតោ ន វាយុសហគតោ នាយំ សង្ខោ សទ្ទំ ករោតីតិ ។ ឯវមេវ ខោ រាជញ្ញ យទាយំ កាយោ អាយុសហគតោ ច ហោតិ ឧស្មាសហគតោ ច វិញ្ញាណសហគតោ ច តទា អភិក្កមតិបិ បដិក្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យំបិ កប្បេតិ ចក្ខុនាបិ រូបំ បស្សតិ សោតេនបិ សទ្ទំ សុណាតិ ឃានេនបិ គន្ធំ ឃាយតិ ជិវ្ហាយបិ រសំ សាយតិ កាយេនបិ ផោដ្ឋព្វំ ផុសតិ មនសាបិ ធម្មំ វិជានាតិ

១ ម. កថំ ហិ ។





មិនសមបើនឹងនៅស្ងៀមឥតសម្លេងសោះ ដោយមនុស្សទាំងនោះ ៗ កាលពួកមនុស្សទាំងនោះ កំពុងមើល បុរសផ្លុំស័ង្ខនោះ ក៏ចាប់ស័ង្ខផ្លុំ ៣ ដង ហើយកាន់ស័ង្ខដើរចៀសចេញទៅ ។ បពិត្រព្រះរាជញ្ញៈ លំដាប់នោះ មនុស្សនៅក្នុងបច្ចន្តជនបទទាំងអស់នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា នៃគ្នាយើងអើយ ធម្មតាស័ង្ខនេះ លុះតែកាលណា ផ្សំនឹងបុរសផង ផ្សំនឹងសេចក្តីព្យាយាមផង ផ្សំនឹងខ្យល់ផង ទើបស័ង្ខនេះបន្លឺ(សម្លេង)ក្នុងកាលនោះបាន កាលណាបើស័ង្ខនេះ មិនបានផ្សំនឹងបុរស មិនបានផ្សំនឹងសេចក្តីព្យាយាម មិនបានផ្សំនឹងខ្យល់ទេ ស័ង្ខនេះ ក៏បន្លឺសម្លេងមិនបាន ។ បពិត្រព្រះរាជញ្ញៈ កាយនេះក៏ដូច្នោះដែរ កាលណាប្រកបដោយអាយុផង ប្រកបដោយកំដៅភ្លើងផង ប្រកបដោយវិញ្ញាណផង ក្នុងកាលនោះ ទើបកាយនោះ ឈានទៅក៏បាន ថយក្រោយក៏បាន ឈរក៏បាន អង្គុយក៏បាន សម្រេចការដេកក៏បាន ឃើញរូបដោយភ្នែកក៏បាន ស្តាប់សម្លេងដោយត្រចៀកក៏បាន ធុំក្លិនដោយច្រមុះក៏បាន លិទ្ធភ្លក្សរសដោយអណ្តាតក៏បាន ពាល់ត្រូវផោដ្ឋព្វៈដោយកាយក៏បាន ដឹងច្បាស់នូវធម្មារម្មណ៍ដោយ

យទា បនាយំ កាយោ ទេវ អាយុសហគតោ ច ហោតិ ច ឧស្មាសហគតោ ច ច វិញ្ញាណសហគតោ ច(១) តទា ទេវ អភិក្កមតិ ច បដិក្កមតិ ច តិដ្ឋតិ ច និសីទតិ ច សេយ្យំ កប្បេតិ ចក្ខុនាបិ រូបំ ច បស្សតិ សោតេនបិ សទ្ទំ ច សុណាតិ ឃានេនបិ គន្ធំ ច ឃាយតិ ជិវ្ហាយបិ រសំ ច សាយតិ កាយេនបិ ផោដ្ឋព្វំ ច ផុសតិ មនសាបិ ធម្មំ ច វិជានាតិ ។ ឥមិនាបិ ខោ តេ រាជញ្ញ បរិយាយេន ឯវំ ហោតុ ឥតិបិ អត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបាតិកា អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

បឋមភាណវារោ(២) ។

[១៥៤] កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថ-ខោ ឯវំមេ ឯត្ថ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មា-នំ ផលំ វិបាកោតិ ។ អត្ថិ បន រាជញ្ញ បរិយា-យោ ។ បេ ។ អត្ថិ ភោ កស្សប បរិយាយោ

១ ម. បលោតុ ឥតិ ។ ២ ម. ម. បឋមភាណវារំ និដ្ឋិតំ ។



ចិត្តក៏បាន តែកាលណាកាយនេះ មិនប្រកបដោយអាយុផង មិនប្រកបដោយកំដៅផង មិនប្រកបដោយវិញ្ញាណផងទេ ក្នុងកាលនោះ កាយនេះ ឈានទៅមុខក៏មិនបាន ថយក្រោយក៏មិនបាន ឈរក៏មិនបាន អង្គុយក៏មិនបាន សម្រេចឥរិយាបថ ដេកក៏មិនបាន ឃើញរូបដោយចក្ខុក៏មិនបាន ស្ដាប់សម្លេងដោយត្រចៀកក៏មិនបាន ធុំក្លិនដោយច្រមុះក៏មិនបាន លិទ្ធភ្លក្សរសដោយអណ្ដាតក៏មិនបាន ប៉ះពាល់ត្រូវផោដ្ឋព្វៈ ដោយកាយក៏មិនបាន ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តក៏មិនបាន ។ ឱរាជញ្ញៈ បើតាមបរិយាយនេះ សូមមហារាជត្រូវទ្រង់យល់មក យ៉ាងនេះវិញថា លោកដទៃមាន ពួកសត្វជាឧបបាតិកៈមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មាន ដោយហេតុនេះ ។

ចប់ បឋមភាណវារៈ ។

(១៥៤) ព្រះកស្សបដ៏ចម្រើន និយាយយ៉ាងនេះក៏គួរតែហើយ ប៉ុន្តែខ្ញុំនៅតែមានសេចក្ដីយល់ក្នុងរឿងនេះ យ៉ាងនេះទៀតថា លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាកនៃកម្មទាំងឡាយដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។ ម្នាលព្រះរាជញ្ញៈ ចុះបរិយាយនៅមានទៀតដែរឬ ។ បេ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនៅមាន

ៗ បេ ៗ យថាកថំ វិយ រាជញ្ញាតិ ។ ឥធ ភោ កស្សប បុរិសា ចោរំ អាគុចារឹ គហេត្វា ទស្សេន្តិ អយំ តេ ភន្តេ ចោរោ អាគុចារី ឥមស្ស យំ ឥច្ឆសិ តំ ទណ្ឌំ បណេហីតិ ត្យាហំ ឯវំ វទាមិ តេនហិ ភោ ឥមស្ស បុរិសស្ស ឆវឹ ឆិន្ទថ អប្បេវនាមស្ស ជីវំ បស្សេយ្យាមាតិ តេ តស្ស បុរិសស្ស ឆវឹ ឆិន្ទន្តិ ។ នេវស្ស មយំ ជីវំ បស្សាម ។ ត្យាហំ ឯវំ វទាមិ តេនហិ ភោ ឥមស្ស បុរិសស្ស ចម្មំ ឆិន្ទថ មំសំ ឆិន្ទថ ន្ហារុំ ឆិន្ទថ អដ្ឋឹ ឆិន្ទថ អដ្ឋិមិញ្ជំ ឆិន្ទថ អប្បេវនាមស្ស ជីវំ បស្សេយ្យាមាតិ តេ តស្ស បុរិសស្ស អដ្ឋិមិញ្ជំ ឆិន្ទន្តិ ។ នេវស្ស មយំ ជីវំ បស្សាម ។ អយម្បិ ខោ ភោ កស្សប បរិយាយោ យេន មេ បរិយាយេន ឯវំ ហោតិ ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។



ៗ បេ ៗ ថាយ៉ាងព្រះរាជញ្ញៈ បាយាសិនោះ តើដូចម្តេច ។ បពិត្រព្រះកស្សបដ៏ចម្រើន ពួកជនបុរសក្នុងផែនដីនេះ ចាប់ចោរដែលប្រព្រឹត្តអាក្រក់ បង្ហាញដល់ខ្ញុំថា បពិត្រព្រះអង្គដ៏ចម្រើន អ្នកនេះជាចោរប្រព្រឹត្តអាក្រក់ចំពោះព្រះអង្គ ព្រះអង្គសព្វព្រះហឫទ័យ នឹងដាក់ទោសយ៉ាងណាដល់ចោរនេះ សូមព្រះអង្គដាក់តាមប្រាថ្នាចុះ ខ្ញុំនិយាយនឹងពួកបុរសទាំងនោះ យ៉ាងនេះថា នែអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ចូរពន្លាត់ស្បែកក្រៅរបស់បុរសនេះមើល ក្រែងនឹងយើងឃើញជីវៈរបស់បុរសនេះ ពួកជនបុរសទាំងនោះ ក៏ពន្លាត់ស្បែកក្រៅរបស់បុរសនោះ ៗ យើងក៏មិនបានឃើញជីវៈរបស់បុរសនោះសោះ ។ ខ្ញុំនិយាយនឹងពួកបុរសទាំងនោះ យ៉ាងនេះទៀតថា ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ចូរអ្នកទាំងឡាយ ពន្លាត់ស្បែកក្នុង សាច់ សរសៃ កាត់ឆ្អឹង ខ្វៀលខួរក្នុងឆ្អឹងរបស់បុរសនេះមើល ក្រែងនឹងយើងបានឃើញជីវៈរបស់វា ពួកបុរសទាំងនោះ ក៏ខ្វៀលខួរក្នុងឆ្អឹង របស់បុរសនោះ ៗ យើងក៏នៅតែមិនឃើញជីវៈរបស់បុរសនោះសោះ ។ បពិត្រព្រះកស្សបដ៏ចម្រើន បរិយាយនេះឯង ដែលនាំខ្ញុំឲ្យមានគំនិតយ៉ាងនេះថា លោកខាងមុខមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

(១៥៩) តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ ឧបមាយបីធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ ភូតបុព្វំ រាជញ្ញ អញ្ញតរោ(១) អគ្គិកោ ជដិលោ អរញ្ញាយតនេ បណ្ណកុដិយា សម្មតិ(២) ។ អថខោ រាជញ្ញ អញ្ញតរោ ជនបទោ សត្ថវាសោ(៣) វុដ្ឋាសិ ។ អថខោ សោ សត្ថវាសោ(៤) តស្ស អគ្គិកស្ស ជដិលស្ស អស្សមស្ស សាមន្តា ឯករត្តឹ វសិត្វា បក្កាមិ ។ អថខោ រាជញ្ញ តស្ស អគ្គិកស្ស ជដិលស្ស ឯតទហោសិ យន្នូនាហំ(៥) យេន សោ សត្ថវាសោ តេនុបសង្កមេយ្យំ អប្បេវនាមេត្ថ កិញ្ចិ ឧបករណំ អធិគច្ឆេយ្យន្តិ ។ អថខោ សោ អគ្គិកោ ជដិលោ កាលស្សេវ វុដ្ឋាយ យេន សោ សត្ថវាសោ តេនុបសង្កមិ ឧបសង្កមិត្វា អទ្ទស តស្មឹ សត្ថវាសេ ទហរំ កុមារំ មន្ទំ(៦) ឧត្តានសេយ្យកំ ឆឌ្ឌិតំ ។ ទិស្វានស្ស ឯតទហោសិ ន ខោ មេតំ បតិរូបំ យំ មេ បេក្ខមានស្ស មនុស្សភូតោ កាលំ ករេយ្យ

១ ឱ. អញ្ញតរោតិ ន ទិស្សតិ ។ ២ ឱ. វសតិ ។ ៣ ឱ. ជនបទប្បទេសោ ។ ម. ជនបទេ សត្ថោ ។ ៤ ឱ. ម. សោ សត្ថោ ។ ៥ ម. យំនូនាហំ ។ ៦ ឱ. ទន្ធំ ។



(១៥៩) ម្នាលព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើឧបមា ថ្វាយមហាបពិត្រ វិញ្ញូបុរសពួកខ្លះ ក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតនេះ ដោយពាក្យឧបមាបាន ។ បពិត្រព្រះរាជញ្ញៈ កាលពីព្រេងនាយមក មានជដិលម្នាក់ ជាអ្នកបម្រើភ្លើងនៅក្នុងកុដិស្លឹក ក្នុងព្រៃស្ងាត់ ។ បពិត្រព្រះរាជញ្ញៈ ក្នុងកាលនោះ មានពួកឈ្មួញរទេះមួយពួកនៅក្នុងជនបទ បាននាំគ្នាចេញទៅអំពីជនបទនោះ ។ គ្រានោះ ពួកឈ្មួញរទេះនោះនៅ ឈប់សំចតជិតអាស្រមរបស់ជដិលអ្នកបម្រើភ្លើងនោះ អស់មួយយប់ ហើយនាំគ្នាចៀសចេញទៅ ។ បពិត្រព្រះរាជញ្ញៈ គ្រានោះឯង ជដិលអ្នកបម្រើភ្លើងនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា គួរតែអាត្មាអញចូលទៅក្រឡឹងកន្លែងជាទីសម្នាក់ របស់ពួកឈ្មួញរទេះនោះ ក្រែងដូចជាបានគ្រឿងឧបករណ៍អ្វីមួយក្នុងទីនុ៎ះ ។ ទើបជដិលអ្នកបម្រើភ្លើងនោះ ក្រោកឡើងពីព្រលឹម ចូលទៅក្រឡឹងកន្លែងជាទីសម្នាក់ របស់ពួកឈ្មួញរទេះនោះ លុះចូលទៅដល់ហើយ ក៏បានឃើញក្មេងតូច ល្ងង់ក្រអើល ដេកផ្ងារ ដែលគេបោះបង់ក្នុងទីសម្នាក់របស់ពួកឈ្មួញរទេះនោះ ។ ជដិលនោះ លុះឃើញហើយ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើអាត្មាអញមើលបំណាំ បណ្តោយឲ្យមនុស្សស្លាប់ ដោយហេតុណា ហេតុនុ៎ះ មិនសមគួរដល់

យន្នូនាហំ ឥមំ ទារកំ អស្សមំ នេត្វា អាបាទេយ្យំ បោសេយ្យំ វឌ្ឍេយ្យន្តិ ។ អថខោ សោ អគ្គិកោ ជដិលោ តំ ទារកំ អស្សមំ នេត្វា អាបាទេសិ បោសេសិ វឌ្ឍេសិ ។ យទា សោ ទារកោ ទសវស្សុទ្ទេសិកោ វា ហោតិ ទ្វាទសវស្សុទ្ទេសិកោ វា អថខោ តស្ស(១) អគ្គិកស្ស ជដិលស្ស ជនបទេ កិញ្ចិទេវ ករណីយំ ឧប្បជ្ជិ ។ អថខោ សោ អគ្គិកោ ជដិលោ តំ ទារកំ ឯតទវោច ឥច្ឆាមហំ តាត ជនបទំ គន្តុំ អគ្គឹ តាត(២) បរិចរេយ្យាសិ មា ច តេ អគ្គិ និព្វាយិ សចេ ច តេ អគ្គិ និព្វាយេយ្យ អយំ វាសី ឥមានិ កដ្ឋានិ ឥទំ អរណិសហិតំ អគ្គឹ និព្វត្តេត្វា អគ្គឹ បរិចរេយ្យាសីតិ ។ អថខោ សោ អគ្គិកោ ជដិលោ តំ ទារកំ ឯវំ អនុសាសិត្វា(៣) ជនបទំ អគមាសិ ។ តស្ស ខិឌ្ឌាបសុតស្ស អគ្គិ និព្វាយិ ។ អថខោ តស្ស ទារកស្ស ឯតទហោសិ បិតា ខោ មំ ឯវំ អវច

១ ម. អថស្ស ។ ២ ម. តាតាតិ ន ទិស្សតិ ។ ៣ ម. ឯវមនុសាសិត្វា ។





អាត្មាអញឡើយ បើដូច្នោះ គួរតែអាត្មាអញយកទារកនេះទៅឯអាស្រម ថែទាំ ចិញ្ចឹមឲ្យចម្រើនឡើង ។ ទើបជដិលអ្នកបម្រើភ្លើងនោះ នាំយកទារកនោះ ទៅអាស្រម ថែទាំ ចិញ្ចឹមឲ្យចម្រើនឡើង ។ ក្នុងកាលដែលទារកនោះ មានអាយុ ១០ ឆ្នាំ ឬ ១២ ឆ្នាំ ទើបជដិលអ្នកបម្រើភ្លើងនោះ មានករណីយកិច្ចមួយកើតឡើង ក្នុងជនបទ ។ ទើបជដិលអ្នកបម្រើភ្លើងនោះ បានពោលនឹងទារកនោះ យ៉ាងនេះថា នែបា អញ ប្រាថ្នានឹងទៅកាន់ជនបទ នែបា ចូរឯងបម្រើភ្លើង ប្រុងកុំឲ្យភ្លើងរបស់ឯងរលត់ឡើយ បើដូចជាភ្លើងរបស់ឯងរលត់ កាំបិតនេះ ឧសនេះ ឈើគោះភ្លើងនេះ មាន ចូរឯងយកទៅបង្កាត់ភ្លើង ហើយបម្រើភ្លើង (កុំខាន) ។ លំដាប់នោះ ជដិលអ្នកបម្រើភ្លើងនោះ ផ្តាំទារកយ៉ាងនេះហើយ ក៏ទៅកាន់ជនបទ ។ ទារកនោះ កំពុងតែខ្វល់ខ្វាយដោយល្បែង ភ្លើងក៏រលត់អស់ ។ ទើបទារកនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា បិតាបានផ្តាំអាត្មាអញ យ៉ាងនេះថា

អគ្គឹ តាត បរិចរេយ្យាសិ មា ច តេ អគ្គិ និព្វាយិ សចេ ច តេ អគ្គិ និព្វាយេយ្យ អយំ វាសី ឥមានិ កដ្ឋានិ ឥទំ អរណីសហិតំ អគ្គឹ និព្វត្តេត្វា អគ្គឹ បរិចរេយ្យាសីតិ យន្នូនាហំ អគ្គឹ និព្វត្តេត្វា អគ្គឹ បរិចរេយ្យន្តិ ។ អថ ខោ សោ ទារកោ អរណីសហិតំ វាសិយា តច្ឆិ អប្បេវនាម អគ្គឹ អធិគច្ឆេយ្យន្តិ ។ នេវ សោ អគ្គឹ អធិគច្ឆិ អរណីសហិតំ ទ្វិធា ផាលេសិ តិធា ផាលេសិ ចតុធា ផាលេសិ បញ្ចធា ផាលេសិ ទសធា ផាលេសិ វីសតិធា(១) ផាលេសិ សកលិកំ សកលិកំ អកាសិ សកលិកំ សកលិកំ ករិត្វា ឧទុក្ខលេ កោដ្ដេសិ ឧទុក្ខលេ កោដ្ដេត្វា មហាវាតេ ឱបុនិ(២) អប្បេវនាម អគ្គឹ អធិគច្ឆេយ្យន្តិ ។ នេវ សោ អគ្គឹ អធិគច្ឆិ ។ អថ ខោ សោ អគ្គិកោ ជដិលោ ជនបទេ តំ ករណីយំ តីរេត្វា យេន សកោ អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា តំ ទារកំ ឯតទវោច កច្ចិ តេ តាត អគ្គិ និព្វុតោតិ ។

១ ម. ឱ. សតធា ។ ២ ឱ. ឱបុនិ ។



នែបា ឯងចូរបម្រើភ្លើង កុំឲ្យភ្លើងរបស់ឯងរលត់ឡើយ បើដូចជាភ្លើងរបស់ឯងរលត់ហើយ កាំបិតនេះ ឧសនេះ ឈើគោលភ្លើងនេះ មាន ត្រូវឯងយកទៅបង្កាត់ភ្លើង ហើយបម្រើភ្លើង (កុំខាន) បើដូច្នោះ គួរតែ អាត្មាអញ បង្កាត់ភ្លើង ហើយបម្រើភ្លើងចុះ ។ កាលនោះ ទារកនោះ យកកាំបិត ចាំងឈើគោលមើល ដោយគិតថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើងនេះ ។ ទារកនោះ ក៏មិនបានភ្លើងសោះ ហើយក៏ពុះឈើគោលជាពីរចំណែក បីចំណែក បួនចំណែក ប្រាំចំណែក ដប់ចំណែក ម្ភៃចំណែក ធ្វើឲ្យជាចម្រៀកតូចៗ លុះធ្វើឲ្យជាចម្រៀកល្អិតៗ ហើយ ក៏យកទៅបុកក្នុងត្បាល់ លុះបុកក្នុងត្បាល់រួចហើយ រោយទៅតាមខ្យល់ខ្លាំង ដោយសំគាល់ថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើងនេះ ។ ទារកនោះ ក៏នៅតែមិនបានភ្លើងសោះ ។ លំដាប់នោះ ជដិលអ្នកបម្រើភ្លើងនោះ សម្រេចកិច្ចដែលត្រូវធ្វើ ក្នុងជនបទនោះហើយ បានចូលទៅកាន់អាស្រមរបស់ខ្លួន លុះចូលទៅដល់ហើយ បាននិយាយនឹងទារកនោះ យ៉ាងនេះថា នែបា ហេតុដូចម្តេច ក៏ឯងឲ្យភ្លើងរលត់ ។

ឥធ មេ តាត ខិឌ្ឌាបសុតស្ស អគ្គិ និព្វាយិ តស្ស មេ ឯតទហោសិ បិតា ខោ មំ ឯវំ អវច អគ្គិ តាត បរិចរេយ្យាសិ មា ច តេ តាត អគ្គិ និព្វាយិ សចេ ច តេ អគ្គិ និព្វាយេយ្យ អយំ វាសី ឥមានិ កដ្ឋានិ ឥទំ អរណីសហិតំ អគ្គិំ និព្វត្តេត្វា អគ្គិំ បរិចរេយ្យាសីតិ យន្នូនាហំ អគ្គិំ និព្វត្តេត្វា អគ្គិំ បរិចរេយ្យន្តិ អថខោហំ(១) តាត អរណីសហិតំ វាសិយា តច្ឆិំ អប្បេវនាម អគ្គិំ អធិគច្ឆេយ្យន្តិ ។ នេវាហំ អគ្គិំ អធិគច្ឆិំ អរណីសហិតំ ទ្វិធា ផាលេសិំ តិធា ផាលេសិំ ចតុធា ផាលេសិំ បញ្ចធា ផាលេសិំ ទសធា ផាលេសិំ វីសតិធា(២) ផាលេសិំ សកលិកំ អកាសិំ សកលិកំ សកលិកំ ករិត្វា ឧទុក្ខលេ កោដ្ដេសិំ ឧទុក្ខលេ កោដ្ដេត្វា មហាវាតេ ឱបុនិំ អប្បេវនាម អគ្គិំ អធិគច្ឆេយ្យន្តិ នេវាហំ អគ្គិំ អធិគច្ឆិន្តិ ។ អថខោ តស្ស អគ្គិកស្ស ជដិលស្ស ឯតទហោសិ យាវ ពាលោ អយំ ទារកោ អព្យត្តោ កថញ្ហិ នាម អយោនិសោ អគ្គិំ គវេសិស្សតីតិ ។

១ ឱ. អថខោ អហំ ។ ម. អថខ្វាហំ ។ ២ ឱ. ម. សតធា ។





ទារកនោះនិយាយថា បពិត្រឪពុក ខ្ញុំកំពុងតែខ្វល់ខ្វាយដោយការលេងក្នុងទីនេះ ភ្លើងក៏រលត់ ខ្ញុំមានសេចក្តីត្រិះរិះ យ៉ាងនេះថា ឪពុកបានផ្តាំអាត្មាអញ យ៉ាងនេះថា នែបា ឯងត្រូវបម្រើភ្លើង នែបា ឯងកុំឲ្យភ្លើងរលត់ឡើយ បើដូចជាភ្លើងរបស់ឯងរលត់ កាំបិតនេះ ឧសនេះ ឈើគល់គូតភ្លើងនេះ ឯងត្រូវយកទៅបង្កាត់ភ្លើង ហើយបម្រើភ្លើង (កុំខាន) បើដូច្នោះ អាត្មាអញគួរតែបង្កាត់ភ្លើង ហើយបម្រើភ្លើងចុះ បពិត្រឪពុក លំដាប់នោះឯង ខ្ញុំក៏យកកាំបិតឈូសឈើគល់គូត ដោយគំនិតថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើងនេះ ។ ខ្ញុំក៏មិនបានភ្លើងសោះឡើយ ខ្ញុំក៏ពុះឈើគល់គូតភ្លើង ជាពីរចំណែក បីចំណែក បួនចំណែក ប្រាំចំណែក ដប់ចំណែក ម្ភៃចំណែក ធ្វើឲ្យជាបន្ទៀកតូច ៗ លុះធ្វើឲ្យជាបន្ទៀកតូច ៗ រួចហើយ ក៏យកទៅបុកក្នុងត្បាល់ លុះបុកក្នុងត្បាល់ហើយ ក៏រោយតាមខ្យល់ខ្លាំង ដោយគំនិតថា ធ្វើម្តេចហ្ន៎ អាត្មាអញនឹងបានភ្លើង ខ្ញុំក៏មិនបានភ្លើងសោះ ។ គ្រានោះឯង ជដិលជាអ្នកបម្រើភ្លើងនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ទារកនេះ ល្ងង់ពេញជាមនុស្សខ្លៅ មិនឆ្លាតវៃមែន មិនសមបើនឹងស្វែងរកភ្លើង ដោយខុសទំនងសោះ ។

តស្ស បេក្ខមានស្ស អរណិសហិតំ គហេត្វា អគ្គឹ និព្វត្តេត្វា តំ ទារកំ ឯតទវោច ឯវំ ខោ តាត អគ្គិ និព្វត្តេតព្វោ ន ត្វេវ យថា ត្វំ ពាលោ អព្យត្តោ អយោនិសោ អគ្គឹ គវេសិស្សសីតិ ។ ឯវមេវ ខោ ត្វំ រាជញ្ញ ពាលោ អព្យត្តោ អយោនិសោ បរលោកំ គវេសិស្សសិ (១) បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

(១៥៦) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ នេវាហំ សក្កោមិ (២) ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិតុំ រាជាបិ មំ បសេនទិ កោសលោ ជានាតិ តិរោរាជានោបិ បាយាសិ រាជញ្ញោ ឯវំវាទី ឯវំទិដ្ឋី ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ ។

១ ម. គវេសសិ ។ ២ ម. សក្កុណោមិ ។



កាលដែលទារកនោះកំពុងសម្លឹងមើល ជដិលនោះ ក៏ចាប់យកឈើពិគួតភ្លើង ហើយឲ្យកើតភ្លើង រួចនិយាយនឹងទារកនោះ យ៉ាងនេះថា នែកូន ភ្លើងគេត្រូវរកឲ្យដូច្នេះ យ៉ាងនេះ មិនមែនដូចជាកូនឯង ជាមនុស្សល្ងង់ មិនឈ្លាសវៃ ស្វែងរកភ្លើង ដោយមិនសមគួរនោះទេ ។ បពិត្ររាជញ្ញៈ ឯងមហាបពិត្រក៏យ៉ាងនោះដែរ គឺជាមនុស្សល្ងង់ មិនឈ្លាសវៃ ស្វែងរកបរលោកដោយមិនសមគួរ បពិត្ររាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នោះចេញ បពិត្ររាជញ្ញៈ សូមមហាបពិត្រ លះបង់ទិដ្ឋិអាក្រក់នុះចេញ ទិដ្ឋិដ៏អាក្រក់ (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលយូរ កុំបីមាន ដល់មហាបពិត្រឡើយ ។

(១៥៦) ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះ ក៏សមមែនដែរហើយ ក៏ប៉ុន្តែ ខ្ញុំមិនអាចនឹងលះបង់នូវទិដ្ឋិអាក្រក់នេះចេញបានទេ ព្រោះថា ព្រះបាទបសេនទិកោសលក្ដី ពួកព្រះរាជាឯទៀតក្ដី ដឹងច្បាស់នូវខ្ញុំ ថា ព្រះបាទបាយាសិរាជញ្ញៈ ធ្លាប់មានវាទៈ យ៉ាងនេះ មានទិដ្ឋិ យ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ ។

សចាហំ ភោ កស្សប ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិស្សាមិ ភវិស្សន្តិ មេ វត្តារោ យាវ ពាលោ បាយាសិ រាជញ្ញោ អព្យត្តោ ទុគ្គហិតគាហីតិ កោបេនបិ នំ ហរិស្សាមិ មក្ខេនបិ នំ ហរិស្សាមិ បឡាសេនបិ នំ ហរិស្សាមីតិ ។

(៤៨៧) តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ ឧបមាយបិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ ភូតបុព្វំ រាជញ្ញ មហាសកដសត្ថោ សកដសហស្សំ បុរត្ថិមា ជនបទា បច្ឆិមំ ជនបទំ អគមាសិ ។ សោ យេន យេន គច្ឆតិ ខិប្បំយេវ បរិយាទិយតិ តិណកដ្ឋោទកំ ហរិតកបណ្ណំ(១) ។ តស្មិំ ខោ បន សត្ថេ ទ្វេ សត្ថវាហា អហេសុំ ឯកោ បញ្ចន្នំ សកដសតានំ ឯកោ បញ្ចន្នំ សកដសតានំ ។ អថខោ តេសំ សត្ថវាហានំ ឯតទហោសិ អយំ ខោ(២) មហាសកដសត្ថោ

១ ឱ. តិណកដ្ឋោទកំ ហរិតកវណ្ណំ ។ ២ ឱ. ភោ បន ។



បពិត្រព្រះកស្សបដ៏ចម្រើន បើខ្ញុំនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញហើយ មុខជាអ្នកផងនឹងនិយាយខ្ញុំថា ព្រះបាទបាយាសិរាជញ្ញៈ ពេញជាមនុស្សល្ងង់ មិនឆ្លាត ប្រកាន់តែសេចក្ដីខុស ដូច្នេះ ខ្ញុំមុខជានឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្ដីក្រោធខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការលុបគុណខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រឡូកសន្ធានខ្លះ ។

(៤៨៧) ថ្វាយព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះ ក្នុងលោកនេះ រមែងយល់សេចក្ដីនៃភាសិត ដោយពាក្យឧបមាបាន ។ បពិត្ររាជញ្ញៈ កាលពីព្រេងនាយមក មានឈ្មួញរទេះច្រើន នាំរទេះប្រមាណ ១ ពាន់ ចេញពីជនបទខាងកើត ទៅកាន់ជនបទខាងលិច ។ ពួកឈ្មួញរទេះនោះ ទៅក្នុងទីណាៗ ស្មៅ ឧស ទឹក និងស្លឹកឈើខៀវខ្ចី ក្នុងទីនោះៗ ក៏បាត់អស់ទៅ ។ ក្នុងពួកឈ្មួញរទេះនោះឯង មាននាយឈ្មួញរទេះពីរនាក់ ម្នាក់មានរទេះ ៥០០ ម្នាក់ទៀតមានរទេះ ៥០០ ។ លំដាប់នោះឯង នាយឈ្មួញរទេះទាំងនោះ មានសេចក្ដីត្រិះរិះ ដូច្នេះថា ពួកឈ្មួញរទេះនេះឯង

សកដសហស្សំ តេ មយំ យេន យេន គច្ឆាម ខិប្បមេវ បរិយាទិយតិ តិណំ កដ្ឋោទកំ ហរិតកបណ្ណំ យន្នូន មយំ ឥមំ សត្ថំ ទ្វិធា វិភជេយ្យាម ឯកតោ បញ្ច សកដសតានិ ឯកតោ បញ្ច សកដសតានីតិ ។ តេ តំ សត្ថំ ទ្វិធា វិភជឹសុ(១) ឯកតោ បញ្ច សកដសតានិ ឯកតោ បញ្ច សកដសតានិ ។ ឯកោ តាវ សត្ថវាហោ ពហុំ តិណញ្ច កដ្ឋញ្ច ឧទកញ្ច អារោបេត្វា សត្ថំ បយាបេសិ(២) ។ ទ្វីហតីហបយាតោ(៣) ខោ បន សោ សត្ថោ អទ្ទស បុរិសំ កាឡំ លោហិតក្ខឹ អាសន្នទ្ធកលាបំ(៤) កុមុទមាលឹ អល្លវត្ថំ អល្លកេសំ កទ្ទមមក្ខិតេហិ ចក្កេហិ ភទ្រេន រថេន(៥) បដិបថំ អាគច្ឆន្តំ ទិស្វា ឯតទវោច កុតោ ភោ អាគច្ឆសីតិ ។ អមុកម្ហា ជនបទាតិ ។ កុហឹ គមិស្សសីតិ ។

១ ម. វិភជឹសុ ។ ២ ម. បាយាបេសិ ។ ៣ ទ្វិហំ តិហំ បយាតោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៤ ម. អបនទ្ធកលាបំ កុមុទមាលឹ ។ ម. អសន្នទ្ធកលាបំ កុមុទមាលឹ ។ ៥ ម. ភទ្ររថេន ។



មានរទេះ ១ ពាន់ យើងទាំងឡាយទៅនៅក្នុងទីណា ៗ ស្មៅ ឧស ទឹក និងស្លឹកឈើខៀវខ្ចី ក្នុងទីនោះ ៗ ក៏ឆាប់អស់ទៅណាស់ បើដូច្នោះ មានតែយើងបែកគ្នា ចែកក្បួនឈ្មួញរទេះនេះ ជាពីរចំណែក គឺ ១ ចំណែក ៥០០ រទេះ ១ ចំណែកទៀត ៥០០ រទេះ ។ នាយឈ្មួញទាំងនោះ ក៏បានចែកឈ្មួញរទេះនោះជាពីរចំណែក គឺ ១ ចំណែក ៥០០ រទេះ ១ ចំណែកទៀត ៥០០ រទេះ ។ នាយឈ្មួញរទេះម្នាក់ បានផ្ទុកឧសស្មៅ ឧស ទឹកជាច្រើន ហើយនាំក្បួនរទេះទៅ ។ កាលដែលពួកឈ្មួញរទេះនោះ បរចេញទៅ អស់ពីរបីថ្ងៃ ក៏បានឃើញបុរសមានសម្បុរខ្មៅ មានភ្នែកក្រហម ចងព្រួញនិងសរ ប្រដាប់ដោយផ្កាកុមុទ មានសំពត់ទទឹក មានសក់ទទឹក បររថដ៏ល្អ មានកង់ប្រឡាក់ដោយភក់ មកដួបគ្នាទៅតាមកណ្តាលផ្លូវ លុះឃើញហើយក៏សួរ ដូច្នេះថា នែអ្នកដ៏ចម្រើន អ្នកមកពីទីណា ។ បុរសសម្បុរខ្មៅនោះ ឆ្លើយថា ខ្ញុំមកពីជនបទឯណោះ ។ ពួកឈ្មួញរទេះក៏សួរទៀតថា អ្នកនឹងទៅក្នុងទីណា ។

អម្ហាកំ នាម ជនបទន្តិ ។ កច្ចិ ភោ បុរតោ កន្តារេ មហាមេឃោ អភិប្បវុដ្ឋោតិ(១) ។ ឯវំ ភោ(២) បុរតោ កន្តារេ មហាមេឃោ អភិប្បវុដ្ឋោ អាសិត្តោទកានិ វដុមានិ ពហុំ តិណញ្ច កដ្ឋញ្ច ឧទកញ្ច ឆឌ្ឌេថ ភោ បុរាណានិ តិណានិ កដ្ឋានិ ឧទកានិ លហុភារេហិ សកដេហិ សីឃំ សីឃំ គច្ឆថ មា យោគ្គានិ កិលមេត្ថាតិ(៣) ។ អថខោ សោ សត្ថវាហោ សត្ថិកេ អាមន្តេសិ អយំ ភោ បុរិសោ ឯវមាហ បុរតោ កន្តារេ មហាមេឃោ អភិប្បវុដ្ឋោ អាសិត្តោទកានិ វដុមានិ ពហុំ តិណញ្ច កដ្ឋញ្ច ឧទកញ្ច ឆឌ្ឌេថ ភោ បុរាណានិ... តិណានិ កដ្ឋានិ ឧទកានិ លហុភារេហិ សកដេហិ សីឃំ សីឃំ គច្ឆថ មា យោគ្គានិ កិលមេត្ថាតិ ឆឌ្ឌេថ ភោ បុរាណានិ តិណានិ កដ្ឋានិ ឧទកានិ លហុភារេហិ សកដេហិ សត្ថំ បយាបេថាតិ ។ ឯវំ ភោតិ ខោ តេ សត្ថិកា

១ ម. អភិប្បវុដ្ឋោតិ ។ ២ ម. ឯវំ ភោ ភោ ។ ៣ ម. កិលមេថាតិ ។



បុរសនោះប្រាប់ថា ខ្ញុំគឺនៅជនបទឯណោះ ។ ពួកឈ្មួញរទេះសួរថា នែអ្នកដ៏ចម្រើន ផ្លូវលំបាកខាងមុខ ៗ មានមហាមេឃបង្អុរភ្លៀងដ៏ជោគជាំខ្លះដែរឬ ។ បុរសនោះ ឆ្លើយប្រាប់ថា អើអ្នកដ៏ចម្រើន ផ្លូវលំបាកខាងមុខៗ មានមហាមេឃ បង្អុរភ្លៀងដ៏ជោគជាំ ផ្លូវទាំងឡាយ មានទឹកពេញពាស មានតាំងស្មៅ ឧស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយ ចោលស្មៅ ឧស ទឹកចាស់ទាំងឡាយចេញទៅ ចូររទេះទាំងឡាយ ដែលមានបន្ទុកស្រាល ៗ ទៅឆាប់ ៗ ចុះ កុំឲ្យពួកគោលំបាកឡើយ ។ លំដាប់នោះឯង នាយឈ្មួញរទេះនោះ ប្រាប់ពួកឈ្មួញរទេះថា នែអ្នកដ៏ចម្រើន បុរសនេះ បាននិយាយ យ៉ាងនេះថា ផ្លូវលំបាកខាងមុខ ៗ មានមហាមេឃបង្អុរភ្លៀងដ៏ជោគជាំ ផ្លូវទាំងឡាយ មានទឹកពេញពាស មានតាំងស្មៅ ឧស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយចោលស្មៅ ឧស ទឹកចាស់ចេញទៅ ចូររទេះទាំងឡាយ មានបន្ទុកស្រាល ៗ ទៅឆាប់ ៗ ចុះ កុំឲ្យពួកគោលំបាកឡើយ នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយ ចោលស្មៅ ឧស ទឹកចាស់ទាំងឡាយចេញទៅ ចូរនាំគ្នាបររទេះទាំងឡាយ មានបន្ទុកស្រាល ៗ ទៅចុះ ។ ពួកឈ្មួញរទេះ

តស្ស សត្ថកភាវស្ស បដិសង្ខា ឆន្ទេត្វា មុកណាតិ តិណានិ គច្ឆានិ ខុទ្ទកានិ លតាការេហិ សកាដេហិ សត្ថំ ឧបយាចេសុំ ។ តេ បឋមេបិ សត្តាហេ ន អន្ត-សិំសុ តិណំ វា គច្ឆំ វា ខុទ្ទកំ វា ទុតិយេបិ សត្ត-ហេ ។ តតិយេបិ សត្តាហេ ។ ចតុត្ថេបិ សត្តាហេ ។ បញ្ចមេបិ សត្តាហេ ។ ឆដ្ឋេបិ សត្តាហេ ។ សត្ត-មេបិ សត្តាហេ ន អន្តសិំសុ តិណំ វា គច្ឆំ វា ខុទ្ទកំ វា សព្វេ អនយព្យសនំ អាបជ្ជិសុ ។ យេ ។ តស្មិំ សត្ត អាហេសុំ មនុស្សា វា បសូ វា ។ សព្វេ តេ យក្ខា អមនុស្សា ភក្ខេសុំ ។ អដ្ឋិកាវសេសា-វ(១) ។ យទា អញ្ញាសិ ទុតិយោ សត្តាហោ ពហុ-ទិក្ខត្តេ(២) ទេវតានិ សោ សត្តាហំ ពហុំ តិណញ្ច គច្ឆញ្ច ខុទ្ទកញ្ច អាកាបេត្វា សត្ថំ ឧបយាចេសុំ ។ ទ្វិហតីហាទយោ តោ ទេ ឯវ សោ(៣) សរត្ថា អត្ត-ស បុរិសំ កាឡំ លោហិតក្ខំ អាសន្នក្កលាបំ

១ ឱ. សោសេសិ ។ ២ ឱ. ទ. ពហុទិក្ខត្តេ ។ ៣ ឱ. បរេសោ ។



កាំបិតនោះ ខ្លួនពាក្យគាយឈ្លោះគ្នានោះថា កើតកាំបិតច្រើន ហើយក៏ចាប់ស្មៅ ដូច ទឹកបាស់ចេញ ហើយតាំងគ្នាបាបគ្នា ដែលមានបន្តុកស្រាយ ១ ទៅ ។ ពួកឈ្លោះគ្នាទាំងនោះ ក៏មិនបានឃើញស្មៅ ដូច ប្តីកន្លងណាក់ពួកឈ្លោះគ្នាទាំងពីរថ្ងៃ ក្នុងពេលណាក់ពួកឈ្លោះគ្នាថាស្រួលប៉ុន្មានថ្ងៃ ។ ក្នុងពេលណាក់ពួកឈ្លោះគ្នាទី ៣ ថ្ងៃ ។ ក្នុងពេល-ណាក់ពួកឈ្លោះគ្នាទី ៤ ថ្ងៃ ។ ក្នុងពេលណាក់ពួកឈ្លោះគ្នាទី ៥ ថ្ងៃ ។ ក្នុងពេលណាក់ពួកឈ្លោះគ្នាទី ៦ ថ្ងៃ ។ មិនបានឃើញស្មៅ ដូច ប្តីក ក្នុងពេលណាក់ពួកឈ្លោះគ្នាទី ៧ ថ្ងៃ ហើយក៏ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ។ ពួកមនុស្ស ឬពួកសត្វចិញ្ចឹម ក៏មានច្រើនក្នុងឈ្លោះគ្នានោះ ។ ព្រោះមានសេចក្តីច្រើនទាំងនោះ គឺជាយក្ស ជាអមនុស្ស(១) ក៏ស៊ីពួកមនុស្សនឹងសត្វចិញ្ចឹមទាំងអស់នោះ ។ នៅសល់តែធ្នឹមទេ ប៉ុណ្ណោះឯង ។ កាលណា ឆាយឈ្លោះគ្នាទី ២ បានដឹងថា សង្គ្រាម ពួកឈ្លោះគ្នានោះ ចេញទៅយូរថ្ងៃហើយ ក៏ផុតស្មៅ ដូច ទឹកជាច្រើន ហើយនាំគ្នាបោះចោលទៅទៀត ។ លុះពួកឈ្លោះគ្នានោះ យកទៅអស់ពីរបីថ្ងៃ ក៏បានឃើញបុរសមានសម្បុរខ្មៅ មានស្នាក្រហម ចរិយាប់ទួងសេរ

១ អមនុស្ស ប្រែថា សត្វមានខ្លួនមិនដូចជាមនុស្ស ឬថា មិនមែនមនុស្ស ។

កុមុទមាលី អល្លវត្ថោ អល្លកេសោ កទ្ទមមក្ខិតេហិ ចក្កេហិ ភទ្រេន រថេន បដិបថំ អាគច្ឆន្តំ ទិស្វា ឯតទវោច កុតោ ភោ អាគច្ឆសីតិ ។ អមុកម្ហា(១) ជនបទាតិ ។ កុហឹ គមិស្សសីតិ ។ អមុកំ នាម ជនបទន្តិ ។ កច្ចិ ភោ បុរតោ កន្តារេ មហាមេឃោ អភិប្បវុដ្ឋោតិ ។ ឯវំ ភោ បុរតោ កន្តារេ មហាមេឃោ អភិប្បវុដ្ឋោ អាសិត្តោទកានិ វដុមានិ ពហុំ តិណញ្ច កដ្ឋញ្ច ឧទកញ្ច ឆឌ្ឌេថ ភោ បុរាណានិ តិណានិ កដ្ឋានិ ឧទកានិ លហុភារេហិ សកដេហិ សីឃំ សីឃំ គច្ឆថ មា យោគ្គានិ កិលមេថាតិ ។ អថខោ សោ សត្ថវាហោ សត្ថិកេ អាមន្តេសិ អយំ ភោ បុរិសោ ឯវមាហ បុរតោ កន្តារេ មហាមេឃោ អភិប្បវុដ្ឋោ អាសិត្តោទកានិ វដុមានិ ពហុំ តិណញ្ច កដ្ឋញ្ច ឧទកញ្ច ឆឌ្ឌេថ ភោ បុរាណានិ តិណានិ កដ្ឋានិ ឧទកានិ លហុភារេហិ សកដេហិ សីឃំ

១ អសុកម្ហាតិ ពហូសុ បោត្ថកេសុ ទិស្សតិ ។





ប្រដាប់ដោយផ្កាកុមុទ មានសំពត់ទទឹក មានសក់ទទឹក កំពុងជិះរទេះដ៏ល្អ មានកង់ប្រឡាក់ដោយភក់ មកផ្ទុយគ្នានៅពាក់កណ្ដាលផ្លូវ លុះឃើញហើយក៏សួរ យ៉ាងនេះថា នែអ្នកដ៏ចម្រើន អ្នកមកពីទីណា ។ បុរសសម្បុរខ្មៅនោះ ឆ្លើយថា ខ្ញុំមកពីជនបទឯណោះ ។ ពួកឈ្មួញរទេះសួរថា អ្នកនឹងទៅកាន់ទីណា ។ បុរសនោះប្រាប់ថា ខ្ញុំនឹងទៅជនបទឯណោះ ។ ពួកឈ្មួញរទេះសួរថា នែអ្នកដ៏ចម្រើន ផ្លូវលំបាកខាងមុខ ។ មានមហាមេឃ បង្អុរភ្លៀងដោតជាំទេឬ ។ បុរសនោះឆ្លើយប្រាប់ថា អើអ្នកដ៏ចម្រើន ក្នុងផ្លូវលំបាកខាងមុខ ។ មានមហាមេឃ បង្អុរភ្លៀងដោតជាំ ផ្លូវទាំងឡាយ មានទឹកពេញពាស មានទាំងស្មៅ ឧស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយ ចោលស្មៅ ឧស ទឹកចាស់ចេញទៅ ចូរបររទេះទាំងឡាយ ដែលមានបន្ទុកស្រាល ។ ទៅឆាប់ ៗ កុំឲ្យគោរទេះលំបាកឡើយ ។ លំដាប់នោះឯង នាយឈ្មួញរទេះនោះ ក៏បានប្រាប់ពួកឈ្មួញថា នែអ្នកដ៏ចម្រើន បុរសនេះបាននិយាយ យ៉ាងនេះថា ក្នុងផ្លូវលំបាកខាងមុខ ។ មានមហាមេឃ បង្អុរភ្លៀងដោតជាំ ផ្លូវទាំងឡាយ មានទឹកពេញពាស មានទាំងស្មៅ ឧស ទឹកជាច្រើន នែអ្នកដ៏ចម្រើន ចូរអ្នកទាំងឡាយ ចោលស្មៅ ឧស ទឹកចាស់ចេញទៅ ចូរបររទេះទាំងឡាយ មានបន្ទុកស្រាល ។ ទៅឲ្យឆាប់ ៗ កុំ

សយំ គច្ឆថ មា យោគ្គានិ កិលមិត្ថាតិ អយំ ភោ បុរិសោ នោ អម្ហាកំ មិត្តោ ន(១) ញាតិសាលោហិ-តោ កថំ មយំ ឥមស្ស សទ្ធាយ គមិស្សាម ច កេ(២) ឆឌ្ឌេត្វានិ បុរាណានិ តិណានិ កដ្ឋានិ ឧទកានិ ។ យថាភតេន(៣) ភណ្ឌេន សត្ថំ បយា-បេថ ច ទោ(៤) បុរាណំ ឆឌ្ឌេស្សាមាតិ ។ ឯវំ ភោតិ ខោ តេ សត្ថិកា តស្ស សត្ថវាហស្ស បដិស្សុត្វា យថាភតេន ភណ្ឌេន សត្ថំ បយាបេសុំ ។ តេ បឋមេបិ សត្ថកាសេ ន អទ្ទសំសុ តិណំ វា កដ្ឋំ វា ឧទកំ វា ទុតិយេបិ សត្ថកាសេ ។ តតិយេបិ សត្ថកាសេ ។ ចតុត្ថេបិ សត្ថកាសេ ។ បញ្ចមេបិ សត្ថកាសេ ។ ឆដ្ឋេបិ សត្ថកាសេ ។ សត្តមេបិ សត្ថកាសេ ន អទ្ទសំសុ តិណំ វា កដ្ឋំ វា ឧទកំ វា តញ្ច សត្ថំ អទ្ទសំសុ

១ ម. នបិ ។ ២ ម. ភោ ។ យ. ភេ ។ ៣ ម. យថាភតេន ។ ឱ-យថាភតេន ។ ៤ ម. ហោ ។



កុំឲ្យពួកគោលំបាកឡើយ ម្នាលអ្នកដ៏ចំរើន បុរសនេះ មិនមែនជាមិត្ត មិនមែនជាញាតិសាលោហិតរបស់យើងទេ យើងនឹងទៅដោយជឿពាក្យបុរសនេះ ដូចម្ដេចបាន អ្នកទាំងឡាយ មិនត្រូវចោលស្មៅ ឧស ទឹកចាស់ឡើយ ។ ចូរអ្នកទាំងឡាយ នាំគ្នាបររទេះទៅ យកទំនិញរបស់ដែលបានផ្ទុកមកហើយ យើងកុំចោលរបស់ចាស់យើងឡើយ ។ ពួកឈ្មួញរទេះទាំងនោះ ទទួលពាក្យនាយឈ្មួញរទេះនោះថា អើអ្នកដ៏ចំរើន ហើយក៏នាំគ្នាបររទេះទៅ យកទំនិញរបស់ដែលបានផ្ទុកមកហើយនោះ ។ ពួកឈ្មួញរទេះទាំងនោះ ក៏មិនបានឃើញស្មៅ ឧស ទឹកក្នុងដំណាក់ពួកឈ្មួញរទេះ ជាដំបូងដង ។ ក្នុងដំណាក់ពួកឈ្មួញរទេះ ទី ២ ដង ។ ក្នុងដំណាក់ពួកឈ្មួញរទេះ ទី ៣ ដង ។ ក្នុងដំណាក់ពួកឈ្មួញរទេះ ទី ៤ ដង ។ ក្នុងដំណាក់ពួកឈ្មួញរទេះ ទី ៥ ដង ។ ក្នុងដំណាក់ពួកឈ្មួញរទេះ ទី ៦ ដង ។ មិនបានឃើញស្មៅ ឧស ឬទឹកក្នុងដំណាក់ពួកឈ្មួញរទេះ ទី ៧ ដង បានឃើញតែពួកឈ្មួញរទេះនោះ ដែលសល់តែឆ្អឹង

អនយព្យសនំ អាបន្នាយេ ។ តស្មិំ សត្ថេ អហេសុំ មនុស្សា វា បសូ វា ។ តេសញ្ច អដ្ឋិកានេវ អវសិសុ ។ តេន យក្ខេន អមនុស្សេន ភក្ខិតា(១) ។ អថខោ សោ សត្ថវាហោ សត្ថិកេ អាមន្តេសិ អយំ ខោ ភោ សោ សត្ថោ អនយព្យសនំ អាបន្នោ យថា តំ តេន ពាលេន សត្ថវាហេន បរិណាយកេន ។ តេនហិ ភោ យានិ អម្ហាកំ សត្ថេ អប្បសារានិ បណិ-យានិ តានិ ឆឌ្ឌេត្វា យានិ ឥមស្មិំ សត្ថេ មហា-សារានិ បណិយានិ តានិ អាទិយថាតិ ។ ឯវំ ភោតិ ខោ តេ សត្ថិកា តស្ស សត្ថវាហស្ស បដិស្សុត្វា យានិ សកស្មិំ សត្ថេ អប្បសារានិ បណិយានិ តានិ ឆឌ្ឌេត្វា យានិ តស្មិំ សត្ថេ មហា-សារានិ បណិយានិ តានិ អាទិយិត្វា សោត្ថិនា តំ កន្តារំ និត្ថរិំសុ យថា តំ បណ្ឌិតេន សត្ថ-វាហេន បរិណាយកេន ។ ឯវមេវ ខោ ត្វំ រាជញ្ញ

១ ម. ភក្ខិតានិ ។



វិនាសប៉ុណ្ណោះ ។ ពួកមនុស្ស ឬសត្វចិញ្ចឹម គឺមានច្រើន ក្នុងពួកឈ្មួញរទេះនោះ ។ ពួកឈ្មួញរទេះទាំងនោះ បានឃើញតែឆ្អឹងមនុស្ស និងសត្វចិញ្ចឹមទាំងនេះ ។ ឯបុរសមានសម្បុរខ្មៅនោះ គឺជាយក្សជាអមនុស្ស បានស៊ីមនុស្សនិងសត្វចិញ្ចឹមនោះ (អស់ទៅ) ។ លំដាប់នោះ ឯនាយឈ្មួញរទេះនោះ បានប្រាប់ពួកឈ្មួញរទេះថា នែអ្នកដ៏ចម្រើន ពួកឈ្មួញរទេះនោះឯង ដែលដល់នូវសេចក្ដីវិនាស ព្រោះតែនាយឈ្មួញរទេះជាបរិនាយក ជាមនុស្សល្ងង់នោះ ។ ម្នាលអ្នកដ៏ចម្រើន បើដូច្នោះ ទ្រព្យរបស់ទាំងឡាយណា ក្នុងពួករទេះរបស់យើង ជារបស់មានថ្លៃតិច ចូរអ្នកទាំងឡាយ ចោលទ្រព្យរបស់ទាំងនោះចេញ ហើយយកតែរបស់ទាំងឡាយ ដែលមានថ្លៃច្រើន ក្នុងពួករទេះនេះចុះ ។ ពួកឈ្មួញរទេះទាំងនោះ ទទួលពាក្យរបស់នាយឈ្មួញរទេះថា អើអ្នកដ៏ចម្រើន ហើយក៏ចោលទ្រព្យរបស់ទាំងឡាយ ដែលមានថ្លៃតិច ក្នុងពួករទេះខ្លួន ហើយយកតែទ្រព្យរបស់ ដែលមានថ្លៃច្រើន ក្នុងពួករទេះនោះ រួចឆ្លងផុតអំពីផ្លូវលំបាកនោះ បានដោយសួស្ដី ព្រោះតែនាយឈ្មួញរទេះ ជាបរិនាយកនោះឯង ជាបណ្ឌិតឈ្លាសវៃ ។ បពិត្ររាជញ្ញៈ

ពាលោ អព្យត្តោ អនយព្យសនំ អាបជ្ជិស្សសិ អយោនិសោ បរលោកំ គវេសន្តោ សេយ្យថាបិ សោ បុរិមោ(១) សត្ថវាហោ យេបិ តវ(២) សោតព្វំ សទ្ធាតព្វំ(៣) មញ្ញិស្សន្តិ តេបិ អនយព្យសនំ អាបជ្ជិស្សន្តិ សេយ្យថាបិ តេ សត្ថិកា បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

(៤៩៨) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថខោ នេវាហំ សក្កោមិ(៤) ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិតុំ រាជាបិ មំ បសេនទិ កោសលោ ជានាតិ(៥) តិរោរាជានោបិ បាយាសិ រាជញ្ញោ ឯវំវាទី ឯវំទិដ្ឋី ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ សចាហំ ភោ កស្សប ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិស្សាមិ ភវិស្សន្តិ មេ វត្តារោ

១ ម. បុរិសោ ។ ២ ម. តេ ។ ៣ ឱ. ម. សទ្ទហាតព្វំ ។ ៤ ឱ. សក្ខិមិ ។ ៥ ឱ. ជានាតីតិ ។



មហាបពិត្រក៏យ៉ាងនោះដែរ ជាបុគ្គលខ្លៅ មិនឆ្លាត ស្វែងរកបរលោក ដោយខុសទំនង នឹងដល់នូវសេចក្តីវិនាស ដូចបុរស ជាមេឈ្មួញមុខនោះ មួយទៀត ពួកជនណា សំគាល់នូវពាក្យរបស់មហាបពិត្រ ថា ជាពាក្យគួរស្តាប់ គួរជឿ ជនទាំងនោះ មុខជានឹងដល់នូវសេចក្តីវិនាស ដូចពួកឈ្មួញរទេះនោះ បពិត្ររាជញ្ញ សូមមហាបពិត្រលះបង់នូវទិដ្ឋិអាក្រក់នុ៎ះចេញ បពិត្ររាជញ្ញ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ទិដ្ឋិអាក្រក់ (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង កុំបីមានដល់មហាបពិត្រឡើយ ។

(៤៩៨) ព្រះកស្សបដ៏ចម្រើន ពោលយ៉ាងនេះក៏សមមែនហើយ ប៉ុន្តែ ខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញបានទេ ព្រោះថា ស្តេចបសេនទិកោសលក្តី ពួកស្តេចខាងក្រៅក្តី នឹងដឹងស្គាល់នូវខ្ញុំថា ព្រះបាយាសិរាជញ្ញ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ បពិត្រព្រះកស្សបដ៏ចម្រើន បើខ្ញុំនឹងលះបង់នូវទិដ្ឋិអាក្រក់នេះចេញ មុខជានឹងមានអ្នកដទៃ ស្តីឱ្យខ្ញុំថា

យាវ ពាលោ បាយាសិ រាជញ្ញោ អព្យត្តោ ទុគ្គហិតគ្គាហីតិ ។ កោបេនបិ នំ ហរិស្សាមិ មក្ខេនបិ នំ ហរិស្សាមិ បឡាសេនបិ នំ ហរិស្សាមីតិ ។

(១៥៩) តេនហិ រាជញ្ញ ឧបមំ តេ ករិស្សាមិ ឧបមាយបីធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ ភូតបុព្វំ រាជញ្ញ អញ្ញតរោ សូករបោសកោ បុរិសោ សកម្ហា គាមា អញ្ញំ គាមំ អគមាសិ តត្ថ អទ្ទស បហូតំ សុក្ខំ គូថំ ឆឌ្ឌិតំ ។ ទិស្វានស្ស ឯតទហោសិ អយំ ខោ បហុតោ(១) សុក្ខគូថោ ឆឌ្ឌិតោ មម សូករានំ ភត្តោ(២) យន្នូនាហំ ឥតោ សុក្ខគូថំ ហារេយ្យន្តិ ។ សោ ឧត្តរាសង្គំ បត្ថរិត្វា បហូតំ សុក្ខគូថំ អាកិរិត្វា(៣) ភណ្ឌិកំ ពន្ធិត្វា សីសេ ឧព្ពាហេត្វា អគមាសិ ។ តស្ស អន្តរាមគ្គេ មហាអកាលមេឃោ បាវស្សិ ។ សោ

១ ឱ. អយំ មេ ពហុកោ ។ ម. អយំ ខោ ពហុកោ ។ ២ ឱ. មមញ្ច សូករភត្តំ ។ ម. មម ច សូករភត្តំ ។ ៣ ឱ. អាហរិត្វា ។



ព្រះបាទបាយាសិរាជញ្ញៈ ទៅពេញជាមនុស្សល្ងង់ មិនឈ្លាស ប្រកាន់តែសេចក្តីខុស ដូច្នេះ ខ្ញុំមុខជានឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការលុបគុណខ្លះ ខ្ញុំនឹងត្រឡប់ប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រឡងនឹងសមណខ្លះ ។

[ ១៥៩ ] ថ្វាយព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះ ក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្ររាជញ្ញៈ កាលពីព្រេងនាយមក មានបុរសម្នាក់ ជាអ្នកចិញ្ចឹមជ្រូក បានចេញពីស្រុករបស់ខ្លួន ទៅកាន់ស្រុកដទៃ ក៏បានឃើញលាមកក្រៀមច្រើន ដែលគេចោលក្នុងទីនោះ ។ លុះបុរសនោះ ឃើញហើយ មានសេចក្តីត្រិះរិះដូច្នេះថា គេចោលលាមកក្រៀមនេះច្រើនណាស់ លាមកក្រៀមនេះ គួរជាចំណីជ្រូកចំណ-ង្វាយរបស់អាត្មាអញ គួរតែអាត្មាអញយកលាមកក្រៀមពីទីនេះទៅ ។ បុរសនោះក៏លាសំពត់ចងក ហើយគរលាមកក្រៀមជាច្រើនលើ ចងជាបង្វិច លើកទូលលើក្បាលហើយដើរទៅ ។ កាលបុរសនោះដើរទៅដល់ពាក់កណ្តាលផ្លូវ មហាមេឃក៏បង្អុរភ្លៀងខុសកាល ។ បុរសនោះប្រឡាក់

ឧគ្ឃរន្តំ បគ្ឃរន្តំ យាវ អគ្គនខា គូថេន មក្ខិតោ គូថភារំ អាទាយ អគមាសិ ។ តមេនំ មនុស្សា ទិស្វា ឯវមាហំសុ កច្ចិ នោ ត្វំ ភណេ ឧម្មត្តោ កច្ចិ នុ វិចេតោ(១) កថញ្ហិ នាម ឧគ្ឃរន្តំ បគ្ឃរន្តំ យាវ អគ្គនខា គូថេន មក្ខិតោ គូថភារំ ហរិស្សសីតិ(២) ។ តុម្ហេ ខ្វេត្ថ(៣) ភណេ ឧម្មត្តា តុម្ហេ វិចេតា(៤) តថា ហិ បន មេ សូករភត្តន្តិ ។ ឯវមេវ ខោ ត្វំ រាជញ្ញ គូថហារិកូបមោ(៥) មញ្ញេ បដិភាសិ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

---

១ ឱ. កច្ចិ វេចេតោ ។ ម. កច្ចិ វិចេតោ ។ ២ ហរិស្សសីតិ បាឋេន ភវិតព្វំ ។ ៣ ឱ. ខ្វេត្ថ ។ ៤ ឱ. វេចេតា ។ ៥ ឱ. គូថហារិកូបមោ ។



លាមក ជាប់ប្រលាក់ចុងក្រចក គាំនៅតែទូលទ្រទូលលាមកដែលកំពុងហូរហៀរធ្លាក់សស្រាក់ដើរទៅ ។ មនុស្សទាំងឡាយ ឃើញបុរសនោះហើយ បាននិយាយយ៉ាងនេះថា នែ៎អ្នក ឯងជាមនុស្សឆ្កួតទេឬអ្វី ឯងជាមនុស្សលេលាឬអ្វី មិនសមបើឯងប្រឡាក់ ដោយលាមកដល់ចុងក្រចក ហើយនៅតែទូលទ្រទូលលាមក ដែលកំពុងហូរហៀរធ្លាក់សស្រាក់ដូច្នេះឡើយ ។ បុរសនោះឆ្លើយថា នែ៎អ្នក ពួកឯងទាំងឡាយនុ៎ះ អ្នកឯងទេតើ ជាមនុស្សឆ្កួត អ្នកឯងទេតើ ជាមនុស្សលេលា បានជាអញហាបដូច្នោះ ព្រោះថា លាមកនេះ ជាចំណីជ្រូករបស់អញ ។ បពិត្រព្រះរាជញ្ញៈ មហាបពិត្រ ទុកដូចជាបុរសអ្នកទូលទ្រទូលលាមកយ៉ាងនោះដែរ បពិត្រព្រះរាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ បពិត្រព្រះរាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុ៎ះចេញ ទិដ្ឋិដ៏លាមក (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ អស់កាលជាយូរអង្វែង កុំបីមានដល់មហាបពិត្រឡើយ ។

[១៦០] កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថ ខោ នេវាហំ សក្កោមិ(១) ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិតុំ រាជាបិ មំ បសេនទិ កោសលោ ជានាតិ(២) តិរោរាជានោបិ បាយាសិ រាជញ្ញោ ឯវំវាទី ឯវំទិដ្ឋី ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ សចាហំ ភោ កស្សប ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិស្សាមិ ភវិស្សន្តិ មេ វត្តារោ យាវ ពាលោ បាយាសិ រាជញ្ញោ អព្យត្តោ ទុគ្គហិតគាហីតិ កោបេនបិ នំ ហរិស្សាមិ មក្ខេនបិ នំ ហរិស្សាមិ បឡាសេនបិ នំ ហរិស្សាមីតិ ។

[១៦១] តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ ឧបមាយបីធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ ភូតបុព្វំ រាជញ្ញ ទ្វេ អក្ខធុត្តា អក្ខេហិ ទិព្វិំសុ ។ ឯកោ អក្ខធុត្តោ អាគតាគតំ កលឹ គិលតិ ។ អទ្ទសា(៣) ខោ ទុតិយោ អក្ខធុត្តោ តំ អក្ខធុត្តំ

១ ម. សណ្ឋាតុំ ។ ២ ម. ជានាតីតិ ។ ៣ ម. អទ្ទស ។





[១៦០] ព្រះកស្សបដ៏ចំរើន ពោលយ៉ាងនេះក៏សមមែនហើយ ប៉ុន្តែ ខ្ញុំនៅតែមិនអាចលះបង់ទិដ្ឋិអាក្រក់នេះចេញបានទេ (ព្រោះ) ស្តេចបសេនទិកោសលក្តី ពួកស្តេចខាងក្រៅក្តី តែងជ្រាបច្បាស់ខ្ញុំថា ស្តេចបាយាសិរាជញ្ញៈ ប្រកាន់វាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មិនមាន ដោយហេតុនេះ បពិត្រព្រះកស្សបដ៏ចំរើន បើខ្ញុំនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញ មុខជានឹងមានអ្នកផង ស្តីឲ្យខ្ញុំថា ស្តេចបាយាសិរាជញ្ញៈនេះ ល្ងង់ពេញជាមនុស្សខ្លៅ មិនឆ្លៀវឆ្លាត ប្រកាន់តែសេចក្តីខុស ដូច្នេះ ខ្ញុំមុខជាត្រូវតែប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំនឹងត្រូវតែប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីលុបគុណខ្លះ ខ្ញុំនឹងត្រូវតែប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រឡូកសកាខ្លះ ។

[១៦១] ថ្វាយព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាពនឹងធ្វើសេចក្តីឧបមាថ្វាយមហាបពិត្រ ព្រោះវិញ្ញូបុរសខ្លះក្នុងលោកនេះ រមែងយល់សេចក្តីនៃភាសិត ដោយឧបមាបាន ។ បពិត្ររាជញ្ញៈ កាលពីព្រេងនាយមក មានអ្នកលេងបាសក ពីរនាក់ បានលេងល្បែងបាសក ។ អ្នកលេងបាសកម្នាក់ តែងលេបកូនបាសកាដែលចាញ់ ដែលបានមកដល់ខ្លួន ៗ ។ អ្នកលេងបាសក ជាគម្រប់ពីរ បានឃើញ នូវអ្នកលេងបាសកនោះ

អាគតាគតំ កលឹ គិលន្តំ ទិស្វា តំ អក្ខធុត្តំ ឯតទវោច ត្វំ ខោ សម្ម ឯកន្តិកេន ជិនាសិ ទេហិ មេ សម្ម អក្ខេ បជោហិស្សាមីតិ(១) ។ ឯវំ សម្មាតិ ខោ សោ អក្ខធុត្តោ តស្ស អក្ខធុត្តស្ស អក្ខេ បាទាសិ ។ អថខោ សោ អក្ខធុត្តោ អក្ខេ វិសេន បរិភាវេត្វា តំ អក្ខធុត្តំ ឯតទវោច ឯហិ ខោ សម្ម អក្ខេហិ ទិព្វិស្សាមាតិ ។ ឯវំ សម្មាតិ ខោ សោ អក្ខធុត្តោ តស្ស អក្ខធុត្តស្ស បច្ចស្សោសិ ។ ទុតិយម្បិ(២) ខោ តេ អក្ខធុត្តា អក្ខេហិ ទិព្វិំសុ ។ ទុតិយម្បិ ខោ សោ អក្ខធុត្តោ អាគតាគតំ កលឹ គិលតិ ។ អទ្ទសា ខោ ទុតិយោ អក្ខធុត្តោ តំ អក្ខធុត្តំ ទុតិយម្បិ អាគតាគតំ កលឹ គិលន្តំ ទិស្វា តំ អក្ខធុត្តំ ឯតទវោច

១ ម. ឯវំ ។ បជោហិស្សាមីតិ ឥតិ បន បាឋេន ភវិតព្វំ ។ ២ ម. យ. ទុតិយំបិ ។



កំពុងលេបកូនបាសកាដែលចាញ់ ដែលបានមកដល់ខ្លួនៗ លុះឃើញហើយក៏និយាយនឹងអ្នកលេងបាសកានោះ យ៉ាងនេះថា នែសំឡាញ់ អ្នកឯងចេះតែឈ្នះយើងជាដរាប នែសំឡាញ់ ចូរអ្នកឯងឲ្យបាសកាមកយើងចុះ យើងនឹងធ្វើការបូជាសែន ។ អ្នកលេងបាសកានោះ និយាយថា អើសំឡាញ់ ហើយក៏បានប្រគល់បាសកាទាំងឡាយ ដល់អ្នកលេងបាសកា (ដែលសុំ) នោះ ។ គ្រានោះ អ្នកលេងបាសកា (ដែលចាញ់) នោះ យកថ្នាំពិស ប្រឡាក់កូនបាសកាទាំងឡាយ ហើយនិយាយនឹងអ្នកលេងបាសកា (វៀច) នោះ យ៉ាងនេះថា នែសំឡាញ់ អ្នកចូរមក យើងនឹងលេងបាសកា (ទៀត) ។ អ្នកលេងបាសកា (វៀច) នោះ ទទួលពាក្យអ្នកលេងបាសកានោះថា អើសំឡាញ់ ។ អ្នកលេងបាសកាទាំងនោះ បានលេងបាសកាលើកទីពីរទៀត ។ អ្នកលេងបាសកា (វៀច) នោះ នៅតែលេបកូនបាសកាដែលចាញ់ ដែលបានមកដល់ខ្លួនៗ ក្នុងលើកទីពីរទៀត ។ អ្នកលេងបាសកាជាគំរប់ពីរ បានឃើញអ្នកលេងបាសកា (វៀច) នោះ កំពុងលេបកូនបាសកាដែលចាញ់ ដែលបានមកដល់ខ្លួនៗ ក្នុងលើកទីពីរទៀត លុះឃើញហើយ ក៏និយាយនឹងអ្នកលេងបាសកានោះ យ៉ាងនេះថា

(១៦២) លិត្តំ បរមេន តេជសា
គិលមក្ខំ បុរិសោ ន ពុជ្ឈតិ
គិលរេ(១) បាបធុត្ត កាបណា(២)
តេ កដុកំ ភវិស្សតីតិ ។

(១៦៣) ឯវមេវ ខោ ត្វំ រាជញ្ញ អក្ខធុត្តកូបមោ មញ្ញេ បដិភាសិ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

(១៦៤) កិញ្ចាបិ ភវំ កស្សបោ ឯវមាហ អថ ខោ នេវាហំ សក្កោមិ(៣) ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិតុំ រាជាបិ មំ បសេនទិ កោសលោ ជានាតិ តិរោរដ្ឋាបិ បាយាសិ រាជញ្ញោ ឯវំវាទី ឯវំទិដ្ឋី ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ សចាហំ ភោ កស្សប ឥទំ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជិស្សាមិ ភវិស្សន្តិ មេ វត្តារោ យាវ

១ ឧ. គិលរេ ។ ២ ឧ. គិលបាបធុត្តក បា ។ ម. បាបធុត្តក បា ។ ៣ ឧ. សក្កោមិ ។





(១៦២) បុរសអ្នកលេបនូវគ្រាប់បាសកា ដែលគេលាបដោយថ្នាំពិស ដ៏ក្លៀវក្លាបំផុត គឺនៅតែមិនដឹងខ្លួន ម្នាលអ្នកលេងបៀរអាក្រក់ ជាអ្នកកម្សត់ ចូរលេប (គ្រាប់បាសកា) សេចក្តីក្តៅក្រហាយ នឹងមានដល់អ្នកឯង ។

(១៦៣) ម្នាលព្រះរាជញ្ញៈ មហាបពិត្រ ទ្រង់ដូចជាអ្នកលេងបាសកា យ៉ាងនោះឯង បពិត្ររាជញ្ញៈ សូមមហាបពិត្រលះបង់ទិដ្ឋិអាក្រក់នុះចេញ បពិត្ររាជញ្ញៈ សូមមហាបពិត្រ លះបង់ទិដ្ឋិអាក្រក់នុះចេញ ទិដ្ឋិអាក្រក់ (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង កុំបីមាន ដល់មហាបពិត្រឡើយ ។

(១៦៤) ព្រះកស្សបដ៏ចំរើន និយាយយ៉ាងនេះក៏សមដែរហើយ តែខ្ញុំមិនអាចនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញទេ (ព្រោះ) ស្តេចបសេនទិកោសលក្តី ពួកស្តេចខាងក្រៅក្តី សឹងតែជ្រាបនូវខ្ញុំថា ស្តេចបាយាសិរាជញ្ញៈ ប្រាប់មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា លោកខាងមុខមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន ដោយហេតុនេះ បពិត្រព្រះកស្សបដ៏ចំរើន បើខ្ញុំនឹងលះបង់ទិដ្ឋិអាក្រក់នេះចេញ មុខជានឹងមានអ្នកផង ស្តីឱ្យខ្ញុំថា ស្តេច

ពាលោ ចាយាសិ រាជញ្ញោ អព្យត្តោ ទុគ្គហិតគាហីតិ កោបេនបិ នំ ហរិស្សាមិ មក្ខេនបិ នំ ហរិស្សាមិ បឡាសេនបិ នំ ហរិស្សាមីតិ ។

[២៦៨] តេនហិ រាជញ្ញ ឧបមន្តេ ករិស្សាមិ ឧបមាយមិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ ។ ភូតបុព្វំ រាជញ្ញ អញ្ញតរោ ជនបទោ(១) វុដ្ឋាសិ ។ អថខោ សហាយកោ សហាយកំ អាមន្តេសិ អាយាម សម្ម យេន សោ ជនបទោ តេនុបសង្កមិស្សាម អប្បេវនាមេត្ថ កិញ្ចិ ធនំ អធិគច្ឆេយ្យាមាតិ ។ ឯវំ សម្មាតិ ខោ សហាយកោ សហាយកស្ស បច្ចស្សោសិ ។ តេ យេន សោ ជនបទោ យេន អញ្ញតរំ គាមបទំ(២) តេនុបសង្កមឹសុ តត្ថ អទ្ទសំសុ បហូតំ សាណំ ឆឌ្ឌិតំ ។ ទិស្វា សហាយកោ សហាយកំ អាមន្តេសិ ឥទំ ខោ សម្ម បហូតំ សាណំ ឆឌ្ឌិតំ តេនហិ សម្ម ត្វញ្ច សាណភារំ ពន្ធ អហញ្ច សាណភារំ ពន្ធិស្សាមិ ឧភោ

១ ម. ឆ. ពិលបកោ ។ ២. គាមបទ្ទំ ។ ម. គាមបទំ ។



បាយាសិរាជញ្ញៈ ហៅពេញជាមនុស្សល្ងង់ មិនឆ្លាតវៃ ប្រកាន់តែសេចក្តីខុស ដូច្នេះ ខ្ញុំនឹងគ្រប់គ្រងប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីក្រោធខ្លះ ខ្ញុំនឹងគ្រប់គ្រងប្រកាន់ទិដ្ឋិនោះវិញ ដោយសេចក្តីលុបគុណខ្លះ ខ្ញុំនឹងគ្រប់គ្រងប្រកាន់ទិដ្ឋិនោះវិញ ដោយការប្រទូស្តនឹងគេខ្លះ ។

[២៦៨] បពិត្រព្រះរាជញ្ញៈ បើដូច្នោះ អាត្មាភាព នឹងធ្វើសេចក្តីឧបមា ថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសខ្លះ ក្នុងលោកនេះ តែងយល់សេចក្តីនៃភាសិតដោយឧបមាបាន ។ បពិត្រព្រះរាជញ្ញៈ កាលពីព្រេងនាយមក មានបុរសមួយនាក់ទៅក្នុងជនបទ ។ គ្រានោះឯង បុរសជាសំឡាញ់ បានហៅបុរសជាសំឡាញ់ថា នែសំឡាញ់ មក យើងនឹងទៅកាន់ជនបទនោះ ក្រែងនឹងជួបជាយើងបានទ្រព្យបន្តិចបន្តួច ក្នុងជនបទនោះ ។ បុរសជាសំឡាញ់ បានទទួលពាក្យបុរសជាសំឡាញ់ថា អើសំឡាញ់ ។ បុរសទាំងពីរនាក់នោះ បានចូលទៅកាន់ស្រុកមួយ ដែលគេបោះបង់ចោល ទៅក្នុងជនបទនោះ ក៏បានឃើញសម្បកធ្មៃជាច្រើន ដែលគេបោះបង់ក្នុងទីនោះ ។ លុះបុរសជាសំឡាញ់ឃើញ ហើយក៏ប្រាប់បុរសជាសំឡាញ់ថា នែសំឡាញ់ សម្បកធ្មៃជាច្រើននេះ គេបោះបង់ហើយ នែសំឡាញ់ បើដូច្នោះ ចូរឯងចងសម្បកធ្មៃមួយបាច់ ឯអញក៏ចងសម្បកធ្មៃមួយបាច់ដែរ យើងទាំងពីរនាក់នឹងនាំយក

### បាយាសិរាជញ្ញសុត្តំ សាណភារិកូបមា

សាណភារំ អាទាយ គមិស្សាមាតិ ។ ឯវំ សម្មាតិ ខោ សហាយកោ សហាយកស្ស បដិស្សុត្វា សាណភារំ ពន្ធិ(១) ។ តេ ឧភោ សាណភារំ អាទាយ យេន អញ្ញតរំ គាមបដ្តំ(២) តេនុបសង្កមិំសុ តត្ថ អទ្ទសំសុ បហូតំ សាណសុត្តំ ឆឌ្ឌិតំ ។ ទិស្វា សហាយកោ សហាយកំ អាមន្តេសិ យស្ស ខោ សម្ម អត្ថាយ ឥច្ឆេយ្យាម សាណំ ឥទំ បហូតំ សាណសុត្តំ ឆឌ្ឌិតំ តេនហិ សម្ម ត្វញ្ច សាណភារំ ឆឌ្ឌេហិ អហញ្ច សាណភារំ ឆឌ្ឌេស្សាមិ ឧភោ សាណសុត្តភារំ អាទាយ គមិស្សាមាតិ ។ អយំ ខោ មេ សម្ម សាណភារោ ទូរាភតោ ច(៣) សុសន្នទ្ធោ ច អលំ មេ ត្វំ បជានាហីតិ ។ អថ ខោ សោ សហាយកោ សាណភារំ ឆឌ្ឌេត្វា

១ ម. ពន្ធិត្វា ។ ២ ឱ. គាមបដ្ដំ ។ ៣ ឱ. ម. ទូរាហតោ ប ។



### បាយាសិរាជញ្ញសូត្រ សេចក្តីប្រៀបដោយបុរសអ្នកនាំយកបាច់សំបកធ្មៃ

បាច់សំបកធ្មៃទៅ ។ បុរសជាសម្លាញ់ ទទួលពាក្យបុរសជាសម្លាញ់ថា អើ សម្លាញ់ ហើយក៏ចងសំបកធ្មៃជាបាច់ ។ បុរសទាំងពីរនាក់នោះបាននាំយកបាច់សំបកធ្មៃ ដើរចូលទៅកាន់ស្រុកមួយ ដែលគេចេញចោល ក៏បានឃើញសរសៃធ្មៃជាច្រើន ដែលគេចោល ក្នុងទីនោះ ។ បុរសជាសម្លាញ់លុះឃើញហើយ ក៏ប្រាប់បុរសជាសម្លាញ់ថា នែសម្លាញ់ យើងត្រូវការសំបកធ្មៃ ដើម្បីប្រយោជន៍ដល់សរសៃធ្មៃណា ឥឡូវនេះ សរសៃធ្មៃនេះ គេចោលគរគោកស្រាប់ហើយ នែសម្លាញ់ បើដូច្នោះ អ្នកឯង ចូរចោលបាច់សំបកធ្មៃទៅ ឯខ្ញុំ ក៏នឹងចោលបាច់សំបកធ្មៃដែរ យើងទាំងពីរនាក់ នឹងនាំយកបាច់សរសៃធ្មៃនេះទៅវិញ ។ សម្លាញ់ម្នាក់ និយាយថា នែសម្លាញ់ បាច់សំបកធ្មៃនេះឯង ខ្ញុំបាននាំយកមកពីចម្ងាយផង បានជាចងត្រឹមត្រូវផង របស់នោះ ល្មមដល់ខ្ញុំហើយ អ្នកចូរដឹងចុះ ។ លំដាប់នោះ បុរសជាសម្លាញ់នោះ ចោលបាច់សំបកធ្មៃ

សាណសុត្តភារំ អាទិយិ ។ តេ យេន អញ្ញតរំ គាមបដ្ដំ តេនុបសង្កមឹសុ តត្ថ អទ្ទសំសុ បហូតា សាណិយោ ឆឌ្ឌិតា ។ ទិស្វា សហាយកោ សហាយកំ អាមន្តេសិ យស្ស ខោ សម្ម អត្ថាយ ឥច្ឆេយ្យាម សាណំ វា សាណសុត្តំ វា ឥមា បហូតា សាណិយោ ឆឌ្ឌិតា តេនហិ សម្ម ត្វញ្ច សាណសុត្តភារំ ឆឌ្ឌេហិ អហញ្ច សាណសុត្តភារំ ឆឌ្ឌេស្សាមិ ឧភោ សាណិភារំ អាទាយ គមិស្សាមាតិ ។ អយំ ខោ មេ សម្ម សាណភារោ ទូរាភតោ ច សុសន្នទ្ធោ ច អលំ មេ ត្វំ បជានាហីតិ ។ អថខោ សោ សហាយកោ សាណសុត្តភារំ ឆឌ្ឌេត្វា សាណិភារំ អាទិយិ ។ តេ យេន អញ្ញតរំ គាមបដ្ដំ តេនុបសង្កមឹសុ តត្ថ អទ្ទសំសុ បហូតំ ខោមំ ឆឌ្ឌិតំ ។ ទិស្វា បហូតំ ខោមសុត្តំ ឆឌ្ឌិតំ ។ ទិស្វា បហូតំ ខោមទុស្សំ ឆឌ្ឌិតំ ។ ទិស្វា បហូតំ កប្បាសំ ឆឌ្ឌិតំ ។



ហើយកាន់យកបាច់សរសៃធ្មៃវិញ ។ សម្លាញ់ទាំងពីរនាក់នោះ បានចូលទៅដល់ស្រុកមួយ ដែលគេចេញចោល ក៏បានឃើញសំពត់ដែលគេត្បាញពីសរសៃធ្មៃជាច្រើន ដែលគេចោល ក្នុងទីនោះ ។ បុរសជាសម្លាញ់ លុះឃើញហើយ ក៏ប្រាប់បុរសជាសម្លាញ់ថា នែសម្លាញ់ យើងត្រូវការ នូវសំបកធ្មៃ សរសៃធ្មៃ ដើម្បីប្រយោជន៍ដល់សំពត់ធ្មៃណា (សំឡូរនេះ) សំពត់ដែលគេត្បាញដោយសរសៃធ្មៃទាំងនេះ គេចោលគរគោកស្រាប់ហើយ នែសម្លាញ់ បើដូច្នោះ អ្នកចូរចោលបាច់សំបកធ្មៃទៅ ខ្ញុំ ក៏នឹងចោលបាច់សរសៃធ្មៃដែរ យើងទាំងពីរនាក់ នឹងនាំយកបាច់សំពត់ធ្មៃនេះទៅវិញ ។ សម្លាញ់ម្នាក់និយាយថា នែសម្លាញ់ បាច់សំបកធ្មៃនេះឯង ខ្ញុំបាននាំមកពីឆ្ងាយផង បានចំណងចងត្រឹមត្រូវផង របស់នោះ ល្មមដល់ខ្ញុំហើយ អ្នកចូរដឹងចុះ ។ ឯបុរសជាសម្លាញ់នោះ ក៏ចោលបាច់សរសៃធ្មៃចេញ ហើយប្រមូលយកបាច់សំពត់ដែលគេត្បាញពីសរសៃធ្មៃវិញ ។ អ្នកទាំងពីរនោះ បានចូលទៅដល់ស្រុកមួយទៀត ដែលគេចេញចោល ហើយបានឃើញសំបកឈើជាច្រើន ដែលគេចោលហើយក្នុងទីនោះ ។ ឃើញសរសៃសំបកឈើជាច្រើនដែលគេចោលហើយ ។ ឃើញសំពត់សំបកឈើជាច្រើន ដែលគេចោលហើយ ។ ឃើញកប្បាសជាច្រើន ដែលគេចោលហើយ ។

ទិស្វា ពហុំ កប្បាសិកសុត្តំ ឆឌ្ឌិតំ ។ ទិស្វា ពហុំ កប្បាសិកទុស្សំ ឆឌ្ឌិតំ ។ ទិស្វា ពហុំ អយសំ(១) ឆឌ្ឌិតំ ។ ទិស្វា ពហុំ លោហំ ឆឌ្ឌិតំ ។ ទិស្វា ពហុំ តិបុំ ឆឌ្ឌិតំ ។ ទិស្វា ពហុំ សីសំ(២) ឆឌ្ឌិតំ ។ ទិស្វា ពហុំ សជ្ឈុំ ឆឌ្ឌិតំ ។ ទិស្វា ពហុំ សុវណ្ណំ ឆឌ្ឌិតំ ។ ទិស្វា សហាយកោ សហាយកំ អាមន្តេសិ យស្ស ខោ សម្ម អត្ថាយ ឥច្ឆេយ្យាម សាណំ វា សាណសុត្តំ វា សាណទុស្សំ វា ខោមំ វា ខោមសុត្តំ វា ខោមទុស្សំ វា កប្បាសំ វា កប្បាសិកសុត្តំ វា កប្បាសិកទុស្សំ វា អយសំ វា លោហំ វា តិបុំ វា សីសំ វា សជ្ឈុំ វា ឥទំ ពហុំ សុវណ្ណំ ឆឌ្ឌិតំ តេនហិ សម្ម ត្វញ្ច សាណភារំ ឆឌ្ឌេហិ អហញ្ច សជ្ឈុភារំ ឆឌ្ឌេស្សាមិ ឧភោ សុវណ្ណភារំ អាទាយ គមិស្សាមាតិ អយំ ខោ មេ សម្ម សាណភារោ ទូរាភតោ ច

១ ម. យ. អយំ ។ ២ ម. យ. សីសំ ។





ឃើញសរសៃកប្បាសជាច្រើន ដែលគេចោលហើយ ។ ឃើញសំពត់ធ្វើដោយកប្បាសជាច្រើន ដែលគេចោលហើយ ។ ឃើញដែកជាច្រើន ដែលគេចោលហើយ ។ ឃើញទង់ដែងជាច្រើន ដែលគេចោលហើយ ។ ឃើញសំណប៉ាហាំងជាច្រើន ដែលគេចោលហើយ ។ ឃើញសំណពក់ជាច្រើន ដែលគេចោលហើយ ។ ឃើញប្រាក់ជាច្រើន ដែលគេចោលហើយ ។ ឃើញមាសជាច្រើន ដែលគេចោលហើយ ។ បុរសជាសម្លាញ់ម្នាក់លុះឃើញហើយ ក៏ហៅបុរសជាសម្លាញ់ថា នែសម្លាញ់ យើងត្រូវការសំបកធ្មៃ សរសៃធ្មៃ សំពត់ដែលគេត្បាញដោយសរសៃធ្មៃ សំបកឈើក្តី សរសៃសំបកឈើក្តី សំពត់សំបកឈើក្តី កប្បាសក្តី សរសៃកប្បាសក្តី សំពត់ដែលគេធ្វើដោយសរសៃកប្បាសក្តី ដែកក្តី ទង់-ដែងក្តី សំណប៉ាហាំងក្តី សំណពក់ក្តី ប្រាក់ក្តី ដើម្បីប្រយោជន៍ដល់មាសណា (វត្ថុ) មាសនេះ គេចោលគរគោកស្រាប់ហើយ នែសម្លាញ់ បើដូច្នោះ អ្នកចូរចោលបាច់សំបកធ្មៃទៅ ឯខ្ញុំនឹងចោលបង្វិចប្រាក់ដែរ យើងទាំងពីរនាក់ នឹងយកបង្វិចមាសទៅវិញ ។ សម្លាញ់ម្នាក់និយាយថា នែសម្លាញ់ បាច់សំបកធ្មៃនេះឯង ខ្ញុំបាននាំយកមកពីឆ្ងាយផង

សុសន្នទ្ធោ ច អលំ មេ តំ បជានាហីតិ ។ អថខោ សោ(១) សហាយកោ សាណភារំ ឆឌ្ឌេត្វា សុវណ្ណភារំ អគ្គហេសិ ។ តេ យេន សកោ គាមោ តេនុបសង្កមឹសុ ។ តត្ថ យោ សោ សហាយកោ សាណភារំ អាគមាសិ តស្ស នេវ មាតាបិតរោ អភិនន្ទឹសុ ន បុត្តទារា អភិនន្ទឹសុ ន មិត្តាមច្ចា អភិនន្ទឹសុ ន ច តតោនិទានំ សុខំ សោមនស្សំ អធិគច្ឆិ ។ យោ បន សោ សហាយកោ សុវណ្ណភារំ អាគមាសិ តស្ស មាតាបិតរោ(២) អភិនន្ទឹសុ បុត្តទារាបិ អភិនន្ទឹសុ មិត្តាមច្ចាបិ អភិនន្ទឹសុ តតោនិទានញ្ច សុខំ សោមនស្សំ អធិគច្ឆិ ។ ឯវមេវ ខោ រាជញ្ញ សាណភារិកូបមោ មញ្ញេ បដិភាសិ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ បដិនិស្សជ្ជេតំ រាជញ្ញ បាបកំ ទិដ្ឋិគតំ មា តេ អហោសិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។

១ ម. អយំ បាឋោ ន ទិស្សតិ ។ ២ ម. មាតាបិតរោបិ ។



បានចងនិងចងត្រឹមត្រូវផង របស់នេះល្មមដល់ខ្ញុំហើយ អ្នកដឹងចុះ ។ លំដាប់នោះ បុរសជាសម្លាញ់នោះ ចោលបាច់ធ្មៃចេញ ហើយយកបាច់មាសទៅ ។ បុរសទាំងពីរនាក់នោះ បានវិលចូលទៅដល់ស្រុករបស់ខ្លួនវិញ ។ បណ្តាបុរសទាំងពីរនាក់នោះ បុរសជាសម្លាញ់ ណាដែលនាំយកបាច់សំបកធ្មៃទៅ មាតាបិតារបស់បុរសជាសម្លាញ់នោះ មិនត្រេកអរសោះ ទាំងបុត្រភរិយាក៏មិនត្រេកអរ ទាំងពួកមិត្រអាមាត្យក៏មិនត្រេកអរ បុរសនោះ ក្រឡប់ជាមិនបានសេចក្តីសុខ សោមនស្ស ព្រោះតែសំបកធ្មៃនោះជាហេតុ ។ ចំណែកឯបុរសជាសម្លាញ់ណា បាននាំយកបាច់មាសទៅ មាតាបិតារបស់បុរសជាសម្លាញ់នោះ ក៏ត្រេកអរ ទាំងបុត្រភរិយាក៏ត្រេកអរ ទាំងពួកមិត្រអាមាត្យក៏ត្រេកអរ បុរសនោះ ក៏បានសេចក្តីសុខ សោមនស្ស ព្រោះមាសនោះជាហេតុ ។ បពិត្ររាជញ្ញៈ មហាបពិត្រ ក៏ប្រៀបដូចជា បុរសអ្នកស្ពាយសំបកធ្មៃ យ៉ាងនោះឯង បពិត្ររាជញ្ញៈ សូមមហាបពិត្រ លះបង់ទិដ្ឋិលាមកនុ៎ះចេញ បពិត្ររាជញ្ញៈ សូមមហាបពិត្រ លះបង់ទិដ្ឋិលាមកនុ៎ះចេញ ទិដ្ឋិដ៏លាមក (ប្រព្រឹត្តទៅ) ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាយូរអង្វែង កុំបីមាន ដល់ព្រះអង្គឡើយ ។

បាយាសិរាជញ្ញសុត្តំ បាយាសិរាជញ្ញស្ស ឧបាសកត្តបវេទនា

(១៦៦) បុរិមេនេវាហំ(១) ឱបម្មេន ភោតោ កស្សបស្ស អត្តមនោ អភិរទ្ធោ អបិចាហំ ឥមានិ វិចិត្រានិ បញ្ហបដិភានានិ(២) សោតុកាមោ ឯវាហំ ភវន្តំ កស្សបំ បច្ចនិកំ កាតព្វំ អមញ្ញិស្សំ(៣) អភិក្កន្តំ ភោ កស្សប អភិក្កន្តំ ភោ កស្សប សេយ្យថាបិ ភោ កស្សប និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា កស្សបេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភោ កស្សប(៤) តំ ភគវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ(៥) ភវំ កស្សបោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ឥច្ឆាមិ ចាហំ ភោ កស្សប មហាយញ្ញំ យជិតុំ

១ ម. បុរិមេនេវាហំ ។ ឱ. បុរិមេនេវ អហំ ។ ២ ម. បញ្ហប្បដិភានានិ ។ ៣ ម. បច្ចនីកាតព្វំ អមញ្ញិស្សំ ។ ឱ. បច្ចនីកំ កាតព្វំ អមញ្ញិស្សំ ។ ៤ ម. ឱ. កស្សប តំ ។ ៥ ម. ឧបាសកន្តំ ។



បាយាសិរាជញ្ញសូត្រ ការសម្តែងនូវខ្លួនជាឧបាសករបស់ព្រះបាទបាយាសិរាជញ្ញៈ

(១៦៦) ព្រះបាទបាយាសិរាជញ្ញៈ មានបន្ទូលថា ខ្ញុំមានចិត្តត្រេកអរជ្រះថ្លាហើយ ដោយសារសេចក្តីឧបមារបស់ព្រះកស្សបដ៏ចម្រើន តាំងពីដំបូងមកម្ល៉េះ ប៉ុន្តែ ខ្ញុំចង់ស្តាប់បញ្ហាបដិភាណដ៏វិចិត្រទាំងនេះទៀត ទើបបានជាខ្ញុំធ្វើជាប្រកាន់ធ្វេស ឲ្យទាស់ទុំបច្ចានឹងព្រះកស្សបដ៏ចម្រើនយ៉ាងនេះ បពិត្រព្រះកស្សបដ៏ចម្រើន ការសំដែងរបស់លោកម្ចាស់ពីរោះណាស់ បពិត្រព្រះកស្សបដ៏ចម្រើន ការសំដែងរបស់លោកម្ចាស់ពីរោះណាស់ បពិត្រព្រះកស្សបដ៏ចម្រើន ធម៌ដែលព្រះកស្សប បានសម្តែងដោយអនេកបរិយាយ យ៉ាងនេះ (ភ្លឺច្បាស់ណាស់) ធៀបដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចជាគេបើកបង្ហាញរបស់ដែលកំបាំង ឬក៏ ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា ពួកមនុស្សមានចក្ខុនឹងមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះកស្សបដ៏ចម្រើន ខ្ញុំនេះសូមដល់នូវព្រះគោតមមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក តាំងពីថ្ងៃនេះទៅ សូមព្រះកស្សបដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះករុណា ថាជាឧបាសក ដល់នូវសរណៈ ស្មើដោយជីវិត បពិត្រព្រះកស្សបដ៏ចម្រើន មិនតែប៉ុណ្ណោះទេ ខ្ញុំត្រូវការនឹងបូជាមហាយញ្ញ

អនុសាសតុ មំ ភវំ កស្សបោ យំ មម អស្ស(១) ទីឃរត្តំ ហិតាយ សុខាយាតិ ។ យថារូបេ ខោ រាជញ្ញ យញ្ញេ គាវោ ច ហញ្ញន្តិ អជេឡកា ច ហញ្ញន្តិ កុក្កុដសូករា ច ហញ្ញន្តិ វិវិធា ច បាណា សង្ឃាតំ អាបជ្ជន្តិ បដិគ្គាហកា ច ហោន្តិ មិច្ឆាទិដ្ឋី មិច្ឆាសង្កប្បា មិច្ឆាវាចា មិច្ឆា-កម្មន្តា មិច្ឆាអាជីវា មិច្ឆាវាយាមា មិច្ឆាសតី មិច្ឆា-សមាធី ។ ឯវរូបោ ខោ រាជញ្ញ យញ្ញោ(២) ន មហប្ផលោ ហោតិ ន មហានិសំសោ ន មហា-ជុតិកោ ន មហាវិប្ផារោ ។ សេយ្យថាបិ រាជញ្ញ កស្សកោ ពីជនង្គលំ អាទាយ វនំ បវិសេយ្យ សោ តត្ថ ទុក្ខេត្តេ ទុព្ភូមេ(៣) អវិហតខាណុកណ្ដកេ(៤) ពីជានិ បតិដ្ឋាបេយ្យ ខណ្ឌានិ បូតីនិ វាតា-តបហតានិ អសារទានិ អសុខសយិតានិ ទេវោ ច ន កាលេន កាលំ សម្មាធារំ អនុប្បវេច្ឆេយ្យ(៥)

---

១ ម. មមស្ស ។ ឱ. មមស្ស ។ ២ ម. យញ្ញោ នាម ។ ៣ ទុព្ភូមេតិ ក បាឋោ ។ ៤ ម. អវិហតខាណុកេ ។ ឱ. អវិហតខាណុកណ្ដកេ ។ ៥ ឱ. អនុប្បវេច្ឆេយ្យ ។



សូមព្រះកស្សបដ៏ចំរើន ប្រៀនប្រដៅខ្ញុំផង ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាយូរអង្វែងដល់ខ្ញុំ ។ ម្នាលព្រះរាជញ្ញៈ ពួកមនុស្សសម្លាប់គោក្នុងយញ្ញ សម្លាប់ពពែនិងចៀមក្នុងយញ្ញ សម្លាប់មាន់និងជ្រូកក្នុងយញ្ញ ពួកសត្វមានជីវិតផ្សេងៗ ដល់នូវសេចក្តីវិនាសក្តី ទាំងបដិគ្គាហកៈ (អ្នកទទួល) ក៏ជាអ្នកយល់ឃើញខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានសេចក្តីព្យាយាមខុស មានសតិខុស មានសមាធិខុស ក្នុងយញ្ញដ៏ មានសភាពយ៉ាងណា ។ បពិត្រព្រះរាជញ្ញៈ យញ្ញដ៏ មានសភាពយ៉ាងនោះឯង មិនមានផលច្រើនទេ មិនមានអានិសង្សច្រើនទេ មិនមានសេចក្តីរុងរឿងធំទេ មិនមានគុណផ្សាយទៅច្រើនទេ ។ បពិត្រព្រះរាជញ្ញៈ ប្រៀបដូចកសិករ កាន់យកពូជនិងចង្កូលចូលទៅព្រៃ អ្នកនោះយកពូជទាំងឡាយ ដែលបែកធ្លាយ ស្អុយ ត្រូវខ្យល់និងកម្ដៅថ្ងៃបៀតបៀន ជាពូជមិនបានដាក់ត្រាំ មិនបានហាលឲ្យស្ងួត ទៅព្រោះក្នុងស្រែមិនល្អនោះ ដែលមានទីមិនស្មើ មិនទាន់បានគាស់រំលើងនូវដង្កត់និងបន្លាចេញ ទាំងភ្លៀងសោតក៏មិនបង្អុរ នូវធារទឹកដោយល្អ តាមកាលដ៏គួរ ចុះពូជទាំងឡាយ

អបិ នុ តានិ ពីជានិ វុឌ្ឍឹ វិរុឡ្ហឹ(១) វេបុល្លំ អាបជ្ជេយ្យុំ កស្សកោ ច វិបុលំ ផលំ(២) អធិគច្ឆេយ្យាតិ ។ ន ហិទំ(៣) ភោ កស្សប ។ ឯវមេវ ខោ រាជញ្ញ ឯវរូបេ យញ្ញេ គាវោ វា ហញ្ញន្តិ អជេឡកា វា ហញ្ញន្តិ កុក្កុដសូករា វា ហញ្ញន្តិ វិវិធា វា បាណា សង្ឃាតំ អាបជ្ជន្តិ បដិគ្គាហកា ច ហោន្តិ មិច្ឆាទិដ្ឋី មិច្ឆាសង្កប្បា មិច្ឆាវាចា មិច្ឆាកម្មន្តា មិច្ឆាអាជីវា មិច្ឆាវាយាមា មិច្ឆាសតី មិច្ឆាសមាធី ។ ឯវរូបោ ខោ រាជញ្ញ យញ្ញោ ន មហប្ផលោ ហោតិ ន មហានិសំសោ ន មហាជុតិកោ ន មហាវិប្ផារោ ។ ឯវរូបេ ច ខោ រាជញ្ញ យញ្ញេ នេវ គាវោ ហញ្ញន្តិ ន អជេឡកា ហញ្ញន្តិ ន កុក្កុដសូករា ហញ្ញន្តិ ន វិវិធា បាណា សង្ឃាតំ អាបជ្ជន្តិ បដិគ្គាហកា ច ហោន្តិ សម្មាទិដ្ឋី សម្មាសង្កប្បា សម្មាវាចា សម្មាកម្មន្តា

១ ម. ម. វិរូឡ្ហឹ ។ ២ ម. វិបុលភាវំ ។ ៣ ម. នោ ហិទំ ។





នោះ នឹងដល់នូវសេចក្តីចម្រើន លូតលាស់ ដុះដាលល្អឡើងបានដែរ ឬទេ អ្នកភ្ជួរនោះ គួរបានផលដ៏ធំទូលាយដែរឬទេ ។ បពិត្រព្រះកស្សប មិនច្រើន ការនេះ នឹងប្រព្រឹត្តទៅយ៉ាងនោះ មិនបានទេ ។ ម្នាលរាជញ្ញៈ ពួកមនុស្សសម្លាប់គោទាំងឡាយក្តី សម្លាប់ពពែនិងចៀមក្តី សម្លាប់មាន់និងជ្រូកក្តី ពួកសត្វមានជីវិតផ្សេងៗ ដល់នូវសេចក្តីវិនាសក្តី ទាំងបដិគ្គាហកៈ ក៏សុទ្ធតែជាអ្នកយល់ខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានសេចក្តីព្យាយាមខុស មានសតិខុស មានសមាធិខុស ក្នុងយញ្ញដ៏ មានសភាពយ៉ាងណា ។ បពិត្ររាជញ្ញៈ យញ្ញដ៏ មានសភាពយ៉ាងនោះឯង មិនមានផលច្រើនទេ មិនមានអានិសង្សច្រើនទេ មិនមានសេចក្តីរុងរឿងធំទេ ជាយញ្ញដែលមិនមានគុណផ្សាយទៅច្រើនទេ ។ បពិត្ររាជញ្ញៈ (ប្រសិនបើ) ពួកជន មិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែនិងចៀមទាំងឡាយ មិនសម្លាប់មាន់និងជ្រូកទាំងឡាយ ពួកសត្វមានជីវិតផ្សេងៗ មិនដល់នូវសេចក្តីវិនាស ទាំងពួកបដិគ្គាហកៈសោត ក៏មានសេចក្តីយល់ត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ

សម្មាអាជីវា សម្មាវាយាមា សម្មាសតី សម្មាសមា-
ធិ ។ ឯវរូបោ ខោ រាជញ្ញ យញ្ញោ មហប្ផលោ
ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផា-
រោ ។ សេយ្យថាបិ រាជញ្ញ កស្សកោ ពីជនង្គ-
លំ អាទាយ វនំ បវិសេយ្យ សោ តត្ថ សុខេត្តេ
សុកេទ្ទេ សុវិហតខាណុកណ្ដកេ(១) ពីជានិ បតិដ្ឋា-
បេយ្យ អខណ្ឌានិ អបូតីនិ អវាតាតបហតានិ សារ-
ទានិ សុខសយិតានិ ទេវោ ច កាលេន កាលំ
សម្មាធារំ អនុប្បវេច្ឆេយ្យ អបិ នុ តានិ ពីជានិ
វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជេយ្យុំ កស្សកោ វា វិបុលំ
ផលំ អធិគច្ឆេយ្យាតិ ។ ឯវំ ភោ កស្សប ។ ឯវមេវ
ខោ រាជញ្ញ យថារូបេ យញ្ញេ នេវ គាវោ ហញ្ញន្តិ ន
អជេឡកា ហញ្ញន្តិ ន កុក្កុដសូករា ហញ្ញន្តិ ន វិវិធា
បាណា សង្ឃាតំ អាបជ្ជន្តិ បដិគ្គាហកា ច ហោន្តិ
សម្មាទិដ្ឋី សម្មាសង្កប្បា សម្មាវាចា សម្មាកម្មន្តា

---

១ ឱ. សុខេត្តេ សុក្ខេមេ សុវិហតខាណុកេ ។ ម.... សុវិហតខាណុកណ្ដកេ ។



មានការចិញ្ចឹមជីវិតត្រូវ មានសេចក្ដីព្យាយាមត្រូវ មានសតិត្រូវ មាន
សមាធិត្រូវ ក្នុងយញ្ញាដ៏ មានសភាពយ៉ាងណា ។ បពិត្ររាជញ្ញៈ យញ្ញ-
ដ៏ មានសភាពយ៉ាងនោះឯង រមែងមានផលច្រើន មានអានិសង្សច្រើន
មានសេចក្ដីរុងរឿងធំផង ជាយញ្ញដ៏មានគុណផ្សាយទៅច្រើន ។ បពិត្រ
រាជញ្ញៈ ប្រៀបដូចជាកសិករ នាំយកពូជនិងនង្គ័លចូលទៅព្រៃ អ្នកនោះ
យកពូជទាំងឡាយ ដែលមិនបែកធ្លាយ មិនស្អុយ មិនត្រូវខ្យល់និងកម្ដៅ
ថ្ងៃបៀតបៀន ជាពូជដាក់ត្រាច់ គេហាលស្ងួត ទៅព្រោះក្នុងស្រែដីល្អ
នោះ ដែលមានទឹកបស្មើ គេបានកាប់គាស់យក គល់ដង្គត់និងបន្លាចេញ
ដោយល្អ ទាំងភ្លៀងក៏បង្អុរនូវធារទឹកដោយល្អតាមកាលគួរ ពូជទាំង
នោះ នឹងដល់នូវសេចក្ដីចម្រើន លូតលាស់ ដុះដាលបានឬទេ ទាំងអ្នក
កសិករ ត្រូវបានផលបរិបូណ៌ដែរឬទេ ។ បពិត្រព្រះកស្សបដ៏ចម្រើន
ការនេះ ប្រព្រឹត្តទៅយ៉ាងនោះបាន ។ ម្នាលរាជញ្ញៈ សេចក្ដីនេះ
មានឧបមេយ្យដូចពួកជន មិនសម្លាប់គោទាំងឡាយ មិនសម្លាប់ពពែនិង
ចៀមទាំងឡាយ មិនសម្លាប់មាន់និងជ្រូកទាំងឡាយ ពួកសត្វមានជីវិត
ផ្សេងៗ មិនដល់នូវសេចក្ដីវិនាស ទាំងពួកបដិគ្គាហកៈ ក៏មានសេចក្ដី
យល់ឃើញត្រូវ មានសេចក្ដីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ

សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ ឯវរូបេ ខោ រាជញ្ញ យញ្ញេ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោតិ ។

[១៦៧] អថខោ ពាយាសិ រាជញ្ញោ ទានំ បដ្ឋបេសិ សមណព្រាហ្មណកបណទ្ធិកវណិព្វកយាចកានំ ។ តស្មិំ ខោ បន ទានេ ឯវរូបំ ភោជនំ ទីយតិ កណាជកំ(១) ពិលង្គទុតិយំ ធោរកានិ(២) ច វត្ថានិ គុឡវាលកានិ ។ តស្មិំ ខោ បន ទានេ ឧត្តរោ នាម មាណវោ វាវដោ(៣) អហោសិ ។ សោ ទានំ ទត្វា ឯវំ អនុទ្ទិសតិ ឥមិនា(៤) ទានេន ពាយាសិ រាជញ្ញមេវ(៥) ឥមស្មិំ លោកេ សមាគច្ឆិ(៦) មា បរស្មិន្តិ ។ អស្សោសិ ខោ ពាយាសិ រាជញ្ញោ ឧត្តរោ កិរ មាណវោ ទានំ ទត្វា ឯវំ អនុទ្ទិសតិ ឥមិនា ទានេន ពាយាសិ រាជញ្ញមេវ ឥមស្មិំ លោកេ សមាគច្ឆិ មា បរស្មិន្តិ ។ អថខោ ពាយាសិ រាជញ្ញោ ឧត្តរំ មាណវំ អាមន្តាបេត្វា

១ កណាជកន្តិ ក៏ បាឋោ ។ ២ ឱ. ថោរកានិ ។ ម. ធោរកានិ ។ ៣ ឱ. វ្យាវដោ ។ ៤ ម. ឥមិនាហំ ។ ៥ ឱ. ពាយាសិរាជញ្ញមេវ ។ ៦ ឱ. សមាគច្ឆំ ។



មានការចិញ្ចឹមជីវិតត្រូវ មានសេចក្ដីព្យាយាមត្រូវ មានសតិត្រូវ មានសមាធិត្រូវ ក្នុងយញ្ញណា មានសភាពយ៉ាងណា ។ ម្នាលព្រះរាជញ្ញៈ យញ្ញវិធី មានសភាពយ៉ាងនេះឯង ទើបមានផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងធំធំ ជាយញ្ញវិធីមានគុណផ្សាយទៅច្រើន ។

[១៦៧] គ្រានោះឯង ស្ដេចបាយាសិរាជញ្ញៈ បានផ្ដើមតម្កល់ទាន ចំពោះសមណព្រាហ្មណ៍ មនុស្សកម្សត់ អ្នកដើរផ្លូវ អ្នកពណ៌នាគុណនិងយាចកទាំងឡាយ ។ ក្នុងទាននោះឯង ស្ដេចបាយាសិរាជញ្ញៈ តែងឲ្យភោជនមានសភាពយ៉ាងនេះ គឺបាយចុងអង្ករមានជ្រក់ជាគម្រប់ពីរ និងសំពត់សាច់គគ្រាត មានជាយពីរក្រាស់ ។ ក្នុងការឲ្យទាននោះ មានមាណពម្នាក់ឈ្មោះឧត្តរៈ ជាអ្នកចាត់ចែងទាន ឧត្តរមាណពនោះ ឲ្យទានហើយឧទ្ទិសយ៉ាងនេះថា ដោយការឲ្យទាននេះ សូមឲ្យខ្ញុំបានជួបនឹងស្ដេចបាយាសិរាជញ្ញៈតែក្នុងលោកនេះចុះ សូមកុំឲ្យជួប នៅក្នុងលោកខាងមុខទៀតឡើយ ។ ស្ដេចបាយាសិរាជញ្ញៈបានឮដំណឹងថា ឧត្តរមាណពឲ្យទានហើយ ក៏ឧទ្ទិសយ៉ាងនេះថា ដោយការឲ្យទាននេះ សូមឲ្យខ្ញុំបានជួបនឹងស្ដេចបាយាសិរាជញ្ញៈតែក្នុងលោកនេះ សូមកុំឲ្យជួបក្នុងលោកខាងមុខឡើយ ។ ទើបព្រះបាទបាយាសិរាជញ្ញៈ ត្រាស់ឲ្យហៅឧត្តរមាណពមក

ឯតទវោច សច្ចំ កិរ ត្វំ តាត ឧត្តរ ទានំ ទត្វា ឯវំ-មុទ្ទិសសិ ឥមិនា ទានេន បាយាសិំ រាជញ្ញមេវ ឥ-មស្មិំ លោកេ សមាគច្ឆំ មា បរស្មិន្តិ ។ ឯវំ ភោ(១) ។ កស្មា(២) បន ត្វំ តាត ឧត្តរ ទានំ ទត្វា ឯវមុទ្ទិសសិ ឥមិនា ទានេន ។បេ។ មា បរស្មិន្តិ ននុ មយំ តាត ឧត្តរ បុញ្ញត្ថិកា ទានស្សេវ ផលំ បាដិកង្ខិនោតិ ។ ភោតោ ខោ(៣) ទានេ ឯវរូបំ ភោជនំ ទីយតិ កណា-ជកំ ពិលង្គទុតិយំ ភវំ បាទាបិ ន ឥច្ឆេយ្យ សម្ផុសិតុំ(៤) កុតោ ភុញ្ជិតុំ ឱរកានិ ច វត្ថានិ ថុល្លក-លកានិ(៥) ភវំ បាទាបិ ន ឥច្ឆេយ្យ សម្ផុសិតុំ កុតោ បរិទហិតុំ ភវំ ខោ បនម្ហាកំ(៦) បិយោ មនាបោ

១ ឱ. ឯវំ ភោ ។ ២ ឱ. កិស្ស ។ ៣ ឱ. ភោ បន ។ ៤ ឱ. ឆុបិតុំ ។ ម. សំផុសិតុំ ។ ៥ ឱ. ថូល្លកលកានិ យានិ ។ ម. ថុល្លកាលកានិ យានិ ។ ៦ ឱ. បនម្ហាកំ ។



ហើយមានព្រះឱង្ការ យ៉ាងនេះថា នែបាឧត្តរៈ ឮថា អ្នកឯងឲ្យទានទាំង-ពួងហើយ តែងឧទ្ទិស យ៉ាងនេះថា ដោយការឲ្យទាននេះ សូមឲ្យខ្ញុំបានជួបនឹងស្តេចបាយាសិរាជញ្ញៈតែក្នុងលោកនេះ សូមកុំឲ្យជួបក្នុងលោកខាងមុខឡើយ ពិតមែនឬ ។ ឧត្តរមាណពក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះករុណាវិសេស ។ ព្រះបាទបាយាសិរាជញ្ញៈ មានព្រះឱង្ការសួរថា នែបាឧត្តរៈ ហេតុអ្វី ក៏អ្នកឲ្យទានហើយ ឧទ្ទិស យ៉ាងនេះថា ដោយការឲ្យទាននេះ ។បេ។ សូមកុំឲ្យជួបនៅក្នុងលោកខាងមុខឡើយ ដូច្នេះ នែបា ឧត្តរៈ យើងមានសេចក្តីត្រូវការដោយបុណ្យ មានសេចក្តីសង្ឃឹមយកផល របស់ទានប៉ុណ្ណោះ ដោយពិត ។ ឧត្តរមាណព ក្រាបទូលថា ខ្ញុំព្រះអង្គតែងឲ្យភោជនមានសភាពយ៉ាងនេះ ក្នុងទានរបស់ព្រះអង្គនោះឯង គឺ បាយចុងអង្ករមានជ្រក់ជាគម្រប់ពីរ សូម្បីតែព្រះអង្គ ក៏មិនសព្វព្រះទ័យប៉ះពាល់ដោយព្រះបាទផង តើនឹងសោយ ដូចម្តេចកើត មួយទៀត សំពត់មានសាច់គគ្រាត មានជាយចីក្រាស់ សូម្បីតែព្រះអង្គ ក៏មិនសព្វព្រះទ័យប៉ះពាល់ដោយព្រះបាទផង តើនឹងទ្រង់ ដូចម្តេចកើត ចំណែកខាងព្រះអង្គ ទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្ត របស់ខ្ញុំព្រះអង្គ

បាយាសិរាជញ្ញសុត្តំ បាយាសិរាជញ្ញទានកថា

កថំ មយំ បិយំ មនាបំ អមនាបេន សំយោជេមាតិ ។ តេនហិ ត្វំ តាត ឧត្តរ យាទិសាហំ ភោជនំ ភុញ្ជាមិ តាទិសំ ភោជនំ បដ្ឋបេហិ យាទិសានិ ចាហំ វត្ថានិ បរិទហាមិ តាទិសានិ ច វត្ថានិ បដ្ឋបេហីតិ ។ ឯវំ ភោតិ ខោ ឧត្តរោ មាណវោ បាយាសិរាជញ្ញស្ស(១) បដិស្សុត្វា យាទិសំ ភោជនំ បាយាសិ រាជញ្ញោ ភុញ្ជតិ តាទិសំ ភោជនំ បដ្ឋបេសិ យាទិសានិ ច វត្ថានិ បាយាសិ រាជញ្ញោ បរិទហតិ តាទិសានិ ច វត្ថានិ បដ្ឋបេសិ ។ អថខោ បាយាសិ រាជញ្ញោ អសក្កច្ចំ ទានំ ទត្វា អសហត្ថា ទានំ ទត្វា អចិត្តិកតំ ទានំ ទត្វា អបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជិ សុញ្ញំ សេរីសកំ វិមានំ(២) ។ យោ បន តស្ស(៣) ទានេ វាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ សក្កច្ចំ ទានំ ទត្វា សហត្ថា ទានំ ទត្វា ចិត្តិកតំ ទានំ ទត្វា

១ បាយាសិស្ស រាជញ្ញស្សាតិ បាឋេន ភវិតព្វំ ។ ២ ឱ. សេរីសកំ វិមានំ ។ ៣ ឱ. ម. យោ បន តស្ស ។



បាយាសិរាជញ្ញសូត្រ ការឲ្យទានរបស់ព្រះបាទបាយាសិរាជញ្ញៈ

នៃខ្ញុំព្រះអង្គនឹងយករបស់ជាទីស្រឡាញ់ ជាទីពេញចិត្ត ទៅលាយចម្រុះដោយវត្ថុមិនជាទីគាប់ចិត្ត ដូចម្តេចបាន ។ ព្រះបាទបាយាសិរាជញ្ញៈ មានព្រះឱង្ការថា ម្នាលបាឧត្តរៈ បើដូច្នោះ យើងបរិភោគភោជនយ៉ាងណា ចូរអ្នកឯងតាក់តែងភោជនយ៉ាងនោះចុះ មួយទៀត យើងស្លៀកដណ្តប់សំពត់យ៉ាងណា ចូរអ្នកឯងតាក់តែងសំពត់យ៉ាងនោះចុះ ។ ឧត្តរមាណព ទទួលព្រះឱង្ការនៃព្រះបាទបាយាសិរាជញ្ញៈថា ព្រះករុណាវិសេស ហើយក៏តាក់តែងភោជនដូចជាភោជនដែលស្តេចបាយាសិរាជញ្ញៈតែងសោយ មួយទៀត តាក់តែងសំពត់ ដូចជាព្រះពស្ត្រដែលស្តេចបាយាសិរាជញ្ញៈតែងទ្រង់ ។ គ្រានោះឯង ព្រះបាទបាយាសិរាជញ្ញៈ ឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយព្រះហស្តព្រះអង្គឯង ឲ្យទានដោយមិនផ្ចិតផ្ចង់ ឲ្យទានដោយការបោះឲ្យ លុះបែកធ្លាយរាងកាយបន្ទាប់អំពីមរណកាល ក៏ចូលទៅកើតជាបួយមិត្តនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈ ក្នុងសេរីសកវិមាន(១) ជាវិមានស្ងាត់ស្ងៀមតែឯង ។ ចំណែកខាងឧត្តរមាណព ជាអ្នកចាត់ចែង ក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈនុះ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់

១ អដ្ឋកថាថា វិមាននោះ ជាវិមានប្រហោង មានដើមស្រីសធំ ដុះនៅត្រង់ទ្វារវិមាននោះ ព្រោះហេតុនោះ ទើបលោកហៅថា សេរីសកវិមាន ។

ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ អបិចាហំ អយ្យេន កុមារកស្សបេន ឯតស្មា បាបកា ទិដ្ឋិគតា វិវេចិតោតិ ។ យោ បន តេ អាវុសោ ទានេ ព្យាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ កុហឹ ឧបបន្នោតិ ។ យោ មេ ភន្តេ ទានេ ព្យាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ សក្កច្ចំ ទានំ ទត្វា សហត្ថា ទានំ ទត្វា ចិត្តីកតំ ទានំ ទត្វា អនបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នោ ទេវានំ តាវតិំសានំ សហព្យតំ អហំ បន ភន្តេ អសក្កច្ចំ ទានំ ទត្វា អសហត្ថា ទានំ ទត្វា អចិត្តីកតំ ទានំ ទត្វា អបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបន្នោ សុញ្ញំ សេរីសកវិមានំ តេនហិ ភន្តេ គវម្បតិ



លោកដទៃមិនមាន ពួកសត្វជាឧបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះពិតមែន តែខ្ញុំនេះត្រូវ បានលោកម្ចាស់ព្រះនាមកុមារកស្សប បានដោះខ្ញុំឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះហើយ ។ នែអ្នកមានអាយុ ចុះចំណែកឧត្តរមាណព ជាអ្នកតាក់តែងក្នុងទានរបស់អ្នកនោះ តើទៅកើតក្នុងទីណា ។ បពិត្រលោកដ៏ចំរើន ឧត្តរមាណព ដែលជាអ្នកខ្វល់ខ្វាយក្នុងទានរបស់ខ្ញុំ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់ ឲ្យទានដោយមិនបានបោះចោល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណកាលទៅ ក៏បានទៅកើតក្នុងឋានសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស បពិត្រលោកដ៏ចំរើន ចំណែកខាងខ្ញុំឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទានដោយមិនផ្ចិតផ្ចង់ ឲ្យទានដោយបោះចោល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណកាលមក ក៏បានមកកើតក្នុងសេរីសកវិមាន ជាវិមានស្ងាត់ ជាមួយនឹងពួកទេវតាក្នុងជាន់ចាតុម្មហារាជិកៈ បពិត្រព្រះគវម្បតិដ៏ចំរើន បើដូច្នោះ (សូម)

ឥតិបិ នត្ថិ បរោ លោកោ នត្ថិ សត្តា ឱបបាតិកា នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោតិ អបិចាហំ អយ្យេន កុមារកស្សបេន ឯតស្មា បាបកា ទិដ្ឋិគតា វិវេចិតោតិ ។ យោ បន តេ អាវុសោ ទានេ ព្យាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ កុហឹ ឧបបន្នោតិ ។ យោ មេ ភន្តេ ទានេ ព្យាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ សក្កច្ចំ ទានំ ទត្វា សហត្ថា ទានំ ទត្វា ចិត្តីកតំ ទានំ ទត្វា អនបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នោ ទេវានំ តាវតឹសានំ សហព្យតំ អហំ បន ភន្តេ អសក្កច្ចំ ទានំ ទត្វា អសហត្ថា ទានំ ទត្វា អចិត្តីកតំ ទានំ ទត្វា អបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបន្នោ សុញ្ញំ សេរីសកំ វិមានំ តេនហិ ភន្តេ គវម្បតិ



លោកដទៃមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អធ្វើអាក្រក់ មិនមាន ដោយហេតុនេះពិតមែន តែខ្ញុំនេះ បានលោកម្ចាស់ព្រះនាមកុមារកស្សប បានដោះខ្ញុំឲ្យរួចចាកទិដ្ឋិអាក្រក់នុ៎ះហើយ ។ នែអ្នកមានអាយុ ចុះចំណែកឧត្តរមាណព ជាអ្នកចាត់ចែងក្នុងទានរបស់អ្នកនោះ តើទៅកើតក្នុងទីណា ។ បពិត្រលោកដ៏ចម្រើន ឧត្តរមាណព ដែលជាអ្នកខ្វល់ខ្វាយក្នុងទានរបស់ខ្ញុំ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់ ឲ្យទានដោយមិនបានបោះចោល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណកាលទៅ ក៏បានទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស បពិត្រលោកដ៏ចម្រើន ចំណែកខាងខ្ញុំឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទានដោយមិនផ្ចិតផ្ចង់ ឲ្យទានដោយបោះចោល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណកាលមក ក៏បានមកកើតក្នុងសេរីសកវិមាន ជាវិមានស្ងាត់ ជាមួយនឹងពួកទេវតាក្នុងជាន់ចាតុម្មហារាជិកៈ បពិត្រព្រះគវម្បតិដ៏ចម្រើន បើដូច្នោះ (សូម

មនុស្សលោកំ គន្ត្វា ឯវមារោចេហិ សក្កច្ចំ ទានំ ទេថ សហត្ថា ទានំ ទេថ ចិត្តីកតំ ទានំ ទេថ អនបវិទ្ធំ ទានំ ទេថ បាយាសិ រាជញ្ញោ អសក្កច្ចំ ទានំ ទត្វា អសហត្ថា ទានំ ទត្វា អចិត្តីកតំ ទានំ ទត្វា អបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបន្នោ សុញ្ញំ សេរីសកំ វិមានំ យោ បន តស្ស ទានេ ព្យាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ សក្កច្ចំ ទានំ ទត្វា សហត្ថា ទានំ ទត្វា ចិត្តីកតំ ទានំ ទត្វា អនបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នោ ទេវានំ តាវតិំសានំ សហព្យតន្តិ ។ អថខោ អាយស្មា គវម្បតិ មនុស្សលោកំ អាគន្ត្វា ឯវមារោចេសិ សក្កច្ចំ ទានំ ទេថ សហត្ថា ទានំ ទេថ ចិត្តីកតំ ទានំ ទេថ អនបវិទ្ធំ ទានំ ទេថ បាយាសិ រាជញ្ញោ អសក្កច្ចំ ទានំ ទត្វា អសហត្ថា ទានំ ទត្វា អចិត្តីកតំ ទានំ ទត្វា អបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា



លោកម្ចាស់ និមន្តទៅឯមនុស្សលោកវិញ សូមប្រាប់អស់ពពួកមនុស្ស យ៉ាងនេះថា អ្នកទាំងឡាយ ចូរឲ្យទានដោយគោរព ចូរឲ្យទានដោយដៃខ្លួនឯង ចូរឲ្យទានដោយផ្ចិតផ្ចង់ ចូរឲ្យទានដោយមិនបោះឲ្យ (ចោល) ស្តេចបាយាសិរាជញ្ញៈ ឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទានដោយមិនផ្ចិតផ្ចង់ ឲ្យទានដោយបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណភាពទៅ ក៏ទៅកើតក្នុងសេរីសកវិមានស្ងាត់ ជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈហើយ ចំណែកឧត្តរមាណព ជាអ្នកជាប់ចិត្ត ក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈនោះ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់ ឲ្យទានដោយមិនបានបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណភាពទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្សហើយ ។ គ្រានោះឯង ព្រះគវម្បតិមានអាយុ ត្រឡប់មកមនុស្សលោកវិញ ហើយបានប្រាប់ (អស់ពពួកមនុស្ស) យ៉ាងនេះថា អ្នកទាំងឡាយ ចូរឲ្យទានដោយគោរព ចូរឲ្យទានដោយដៃខ្លួនឯង ចូរឲ្យទានដោយផ្ចិតផ្ចង់ ចូរឲ្យទានដោយមិនបោះឲ្យ (ចោល) ស្តេចបាយាសិរាជញ្ញៈ បានឲ្យទានដោយមិនគោរព ឲ្យទានមិនបានឲ្យដោយដៃខ្លួនឯង ឲ្យទានដោយមិនផ្ចិតផ្ចង់ ឲ្យដោយបោះឲ្យ លុះបែក

បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបន្នោ សុញ្ញំ សេរីសកំ វិមានំ យោ បន តស្ស ទានេ វាវដោ អហោសិ ឧត្តរោ នាម មាណវោ សោ សក្កច្ចំ ទានំ ទត្វា សហត្ថា ទានំ ទត្វា ចិត្តីកតំ ទានំ ទត្វា អនបវិទ្ធំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នោ ទេវានំ តាវតឹសានំ សហព្យតន្តិ ។

បាយាសិរាជញ្ញសុត្តំ ទសមំ និដ្ឋិតំ (១) ។

តស្សុទ្ទានំ (២)

មហាបទានំ និទានញ្ច (៣)
និព្វានញ្ច សុទស្សនំ
ជនវសភគោវិន្ទំ
សមយំ សក្កបញ្ហកំ (៤)
សតិបដ្ឋានបាយាសិ
មហាវគ្គោតិ វុច្ចតីតិ (៥) ។

១ ឱ. បាយាសិសុត្តន្តំ និដ្ឋិតំ ។ មហាវគ្គោ ។ ឧ. បាយាសិសុត្តន្តំ ទសមំ ។ ២ ឱ. ម. តស្សុទ្ទានន្តិ ន ទិស្សតិ ។ ៣ ម. មហាបទាននិទានំ ។ ៤ ឱ. សក្កបញ្ហោ ។ ៥ ឱ. សតិបដ្ឋានបាយាសិ មហាវគ្គស្ស សង្គហោ ។ ម. មហាសតិបដ្ឋានញ្ច បាយាសិ ទសមំ កតំ ។



ធ្លាយកាយ បន្ទាប់អំពីមរណកាលទៅ ក៏ទៅកើតក្នុងសេរីសកវិមាន ស្ងាត់ ជាមួយនឹងពួកទេវតា ជាន់ចាតុម្មហារាជិកៈទៅហើយ ចំណែកខាងឧត្តរមាណព ជាអ្នកខ្វល់ខ្វាយ ក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈ នោះ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់ ឲ្យទានដោយមិនបោះចោល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណកាលទៅ ក៏ទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្សទៅហើយ ។

ចប់ បាយាសិរាជញ្ញសូត្រ ទី ១០ ។

ឧទ្ទាននៃមហាវគ្គនោះ គឺ

មហាបទានសូត្រ ១ មហានិទានសូត្រ ១ មហាបរិនិព្វានសូត្រ ១ មហាសុទស្សនសូត្រ ១ ជនវសភសូត្រ ១ មហាគោវិន្ទសូត្រ ១ មហាសមយសូត្រ ១ សក្កបញ្ហសូត្រ ១ មហាសតិប្បដ្ឋានសូត្រ ១ បាយាសិរាជញ្ញសូត្រ ១ (ចំនួន ១០ សូត្រនេះ) លោកឲ្យឈ្មោះថា មហាវគ្គ ។